# ទម្រង់លិខិតគំរូ
# ដែលប្រើប្រាស់ក្នុងរឿងក្ដីរដ្ឋប្បវេណី




**ក្រសួងយុត្តិធម៌**

**និង**

**ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA)**

**ដកស្រង់ចេញពីគេហទំព័រផ្លូវការក្រសួងយុត្តិធម៌**

http://www.moj.gov.kh/kh/sample-civil-documents

ដកស្រង់ដោយលោក **ឡោ ក្រឹម**

**ឆ្នាំ២០២៣**

| រឿងក្តី | ឈ្មោះឯកសារ |
|---|---|
| ១. | **រឿងក្តីទាមទារឲ្យសងប្រាក់កម្ចី** |
| | ក-សេចក្តីពន្យល់ទូទៅអំពី ពាក្យបណ្តឹង ឯកសារចម្លើយ ឯកសារត្រៀម និងលិខិតសាលក្រម |
| | ខ-ការអះអាងនីមួយៗរបស់ដើមចោទ និងចុងចម្លើយ |
| | គ-តារាងពេលវេលា |
| | ឃ-ដ្យាក្រាមនៃរឿងក្តីទាមទារឲ្យសងប្រាក់កម្ចី |
| | ង-ពាក្យបណ្តឹង |
| | ច-ឯកសារចម្លើយ |
| | ឆ-ឯកសារត្រៀមលើកទី១របស់ដើមចោទ |
| | ជ-លិខិតសាលក្រម |
| | ឈ-ការពន្យល់អំពីភស្តុតាង |
| ២ | **រឿងក្តីទាមទារឲ្យធ្វើនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិដោយផ្អែកលើកិច្ចសន្យាលក់ទិញ** |
| | ក-អំពីនីតិវិធីចុះបញ្ជីអចលនវត្ថុ |
| | ខ-គោលការណ៍នៃការដាក់ (បង្កើតនិងដាក់) ពាក្យសុំរួមគ្នា |
| | គ.ការអះអាងនីមួយៗរបស់ដើមចោទ និងចុងចម្លើយ |
| | ឃ-តារាងពេលវេលា |
| | ង-ដ្យាក្រាមនៃរឿងក្តីទាមទារឲ្យចុះបញ្ជីផ្ទេរកម្មសិទ្ធិទាំងមូលដោយផ្អែកលើកិច្ចសន្យាលក់ទិញ |
| | ច-ពាក្យបណ្តឹង |
| | ឆ-ឯកសារចម្លើយ |
| | ជ-ឯកសារត្រៀមលើកទី១របស់ដើមចោទ |
| | ឈ-លិខិតសាលក្រម |

| | |
|---|---|
| ៣ | **រឿងក្តីទាមទារឲ្យធ្វើនីតិវិធីចុះបញ្ជីអំពីការលុបការចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិដោយផ្អែកលើការរំលាយកិច្ចសន្យា** |
| | ក-អំពីការសន្យាលក់ទិញជាមុន |
| | ខ-អំពីសាលក្រមដែលបង្គាប់ឲ្យផ្តល់តាវកាលិកតប |
| | គ-គោលការណ៍នៃការដាក់ (បង្កើតនិងដាក់) ពាក្យសុំរួមគ្នា |
| | ឃ-ការអះអាងនីមួយៗរបស់ដើមចោទ និងចុងចម្លើយ |
| | ង-តារាងពេលវេលា |
| | ច-ដ្យាក្រាមនៃរឿងក្តីទាមទារឲ្យធ្វើនីតិចុះបញ្ជីអំពីការលុបការចុះបញ្ជីការផ្ទេរកម្មសិទ្ធិដោយផ្អែកលើការរំលាយកិច្ចសន្យា |
| | ឆ-ពាក្យបណ្តឹង |
| | ជ-ឯកសារចម្លើយ |
| | ឈ-ឯកសារត្រៀមលើកទី១របស់ដើមចោទ |
| | ញ-លិខិតសាលក្រម |
| ៤ | **ការទាមទារលែងលះ និងបែងចែកទ្រព្យសម្បត្តិ** |
| | ក.តារាលំហូរនៃនីតិវិធី |
| | ខ.កំណត់ត្រារឿងក្តីលែងលះ |
| | គ.ទ្រព្យសម្បត្តិរួម និងទ្រព្យសម្បត្តិដោយឡែក |
| | ឃ.ករណីសិក្សានិងឧបសម្ព័ន្ធ |
| | ង.ពាក្យបណ្តឹង |
| | ច.លិខិតពាក្យសុំកែតម្រូវពាក្យបណ្តឹង |
| | ឆ.ឯកសារចម្លើយ |
| | ជ.កំណត់ត្រានៃដំណើរការនីតិវិធី |
| | ឈ.លិខិតសាលក្រម |
| | ញ.ការបែងចែកទ្រព្យសម្បត្តិ |
| | ដ.វិធីពិនិត្យពាក្យបណ្តឹង |

| | |
|---|---|
| **៥** | **រឿងក្តីបើបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ និងរឿងក្តីអនុវត្តចំពោះអចលនវត្ថុ** |
| | ក-ករណីសិក្សា Case.5 |
| | ខ.តារាងពេលវេលា Case.5 |
| | គ.លិខិតពាក្យសុំ-ការបើបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ |
| | ឃ.លិខិតដីកាសម្រេច-ការបើបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ |
| | ង.លិខិតពាក្យសុំឱ្យអនុវត្ត-ការបើបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ |
| | ច-សេចក្តីពន្យល់អំពីនីតិវិធី-ការបើបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ |
| | ឆ-សេចក្តីពន្យល់អំពីឯកសារទម្រង់គំរូ-ការបើបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ |
| | ជ-លិខិតពាក្យសុំ |
| | ឈ-សេចក្តីពន្យល់អំពីឯកសារទម្រង់គំរូ-ការអនុវត្តចំពោះអចលនវត្ថុ |
| | ញ-លំហាត់អនុវត្ត |
| **៦** | **រឿងក្តីចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ** |
| | ក-ករណីសិក្សា Case.6 |
| | ខ.លិខិតពាក្យសុំ-ការចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ |
| | គ.លិខិតដីកាសម្រេច-ការចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ |
| | ឃ.សេចក្តីពន្យល់អំពីនីតិវិធី-ការចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ |
| | ង.លំហាត់អនុវត្ត |

# រឿងក្តីទាមទារឲ្យសងប្រាក់កម្ចី

Yoshie SASAKI / JICA Expert

# សេចក្តីពន្យល់ទូទៅអំពី ពាក្យបណ្តឹង ឯកសារចម្លើយ ឯកសារត្រៀម និង លិខិតសាលក្រម

★ **ការដាក់ពាក្យបណ្តឹង (មាត្រា ៧៥ កថា.ទី១)**

១. ពាក្យបណ្តឹង (មាត្រា ៧៥)

□ តើមានសរសេរអំពីចំណុចចាំបាច់ដែលត្រូវសរសេរ(មាត្រា ៧៥ កថា.ទី២)ដែរទេ?

○ ឈ្មោះ ឬ នាមករណ៍ និង អាសយដ្ឋានរបស់ភាគី ឈ្មោះ និង អាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់ (ចំណុច ក.)

○ ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ (ចំណុច ខ.)

តើមានបញ្ជាក់ច្បាស់អំពីចំនួនទឹកប្រាក់ដែរឬទេ?

បើសរសេរថា "ចំនួនទឹកប្រាក់ដែលតុលាការទទួលស្គាល់ថា សមរម្យ" គឺ មិនទាន់គ្រប់គ្រាន់ទេ។

○ អង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ (ចំណុច ខ.)

តើទាមទារប្រាក់ចំនួន ១០.០០០ ដុល្លារអាមេរិកដោយផ្អែកលើអ្វី ?

វាគឺជាប្រាក់កម្ចី ចំនួន ១០.០០០ដុល្លារអាមេរិក ? ឬ ជាប្រាក់ថ្លៃលក់ទិញចំនួន ១០.០០០ដុល្លារអាមេរិក ឬ ជាប្រាក់ដែលគេមិនទាន់បើកឲ្យចំនួន ១០.០០០ដុល្លារអាមេរិក ?

ឧបមាថា ជាប្រាក់កម្ចី តើខ្ចី ១លើក ឬ ខ្ចីច្រើនលើក?

← ចាំបាច់ត្រូវតែសរសេរនៅក្នុងពាក្យបណ្តឹង។

※ ក្នុងករណីដែលមិនមានការសរសេរអំពីចំណុចចាំបាច់ដែលត្រូវសរសេរនៅក្នុងពាក្យបណ្តឹង តុលាការនឹងបង្គាប់ឲ្យដើមចោទកែតម្រូវ ហើយក្នុងករណីដែលមិនមានការកែតម្រូវ តុលាការនឹងលើកពាក្យបណ្តឹងចោលដោយដីកាសម្រេច (មាត្រា ៧៨)។

ដីកាសម្រេច គឺជា ការសម្រេចសេចក្តីដែលតុលាការ ឬ ចៅក្រមអាចធ្វើដោយមិនឆ្លងកាត់តាមការទាញហេតុផលដោយផ្ទាល់មាត់បាន ហើយមិនមែនជាសាលក្រម(មាត្រា ១៧៩ កថា.ទី២)។

□ តើមានសរសេរអំពីអង្គហេតុដែលជាមូលហេតុនៃការទាមទារ និង ភស្តុតាងជាដើម (មាត្រា ៧៥ កថា. ទី៣) ដែរឬទេ?

○ តើមានសរសេរអំពីអង្គហេតុដែលជាមូលហេតុនៃការទាមទារ (អង្គហេតុចម្បង)ដែរទេ?

ផ្អែកតាមរយៈចំណុចដែលចាំបាច់ត្រូវសរសេរនៅក្នុងពាក្យបណ្ដឹង ត្រូវធ្វើការស្វែងយល់ថា បណ្ដឹងនេះ គឺជាបណ្ដឹងដែលទាមទារឲ្យសងប្រាក់កម្ចីចំនួន ១០.០០០ ដុល្លារអាមេរិក ផ្អែកតាមកិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី ១ ខែ វិច្ឆិកា ឆ្នាំ២០០៧ ដូច្នេះហើយ តើមានសរសេរអំពីអង្គហេតុចម្បងដើម្បីឲ្យកើតឡើងនូវសិទ្ធិទាមទារ (ការព្រមព្រៀងអំពីការខ្ចីប្រាក់ ការប្រគល់ប្រាក់ចំនួន ១០.០០០ ដុល្លារអាមេរិកដោយផ្អែកតាមការព្រមព្រៀង ការមកដល់នៃពេលកំណត់សង)ដែរទេ?

※ ក្នុងករណីដែលមិនមានការសរសេរអំពីចំណុចទាំងនេះនៅក្នុងពាក្យបណ្ដឹង តុលាការនឹងប្រើប្រាស់សិទ្ធិឲ្យស្រាយបំភ្លឺ ហើយជំរុញឲ្យដើមចោទអះអាង និង បញ្ជាក់ភស្តុតាង (មាត្រា ៩០ កថា.ទី១)។

□ ការបង្កើតផ្នែកដែលនិយាយអំពី Kg នៅក្នុងដ្យាក្រាម

□ ការបញ្ជូនទៅចុងចម្លើយ (មាត្រា ៧៩ កថា.ទី១)

□ កំណត់អំឡុងពេលដែលត្រូវដាក់ឯកសារត្រៀម (មាត្រា ១០២)

ការឲ្យចុងចម្លើយដែលដាក់ឯកសារចម្លើយឲ្យបានត្រឹមមុនពេលចាប់ផ្ដើមនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល នឹងអាចធ្វើការជំនុំជម្រះដោយមានភាពពេញលេញ។

ឧទាហរណ៍ ៖ កំណត់អំពីអំឡុងពេលដែលត្រូវដាក់ឯកសារត្រៀមថា "ឲ្យបាន១សប្ដាហ៍មុនកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល"។

□ ការកំណត់អំពីកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល (ជាគោលការណ៍ ក្នុងអំឡុងពេល ៣០ ថ្ងៃ) (មាត្រា ៨០)

២. ឯកសារចម្លើយ (មាត្រា ១០១ កថា.ទី៣)

□ ការឆ្លើយតបចំពោះខ្លឹមសារនៃសាលក្រមដែលដើមចោទបានសរសេរទាមទារនៅក្នុងពាក្យបណ្ដឹង

□ ការទទួលស្គាល់ ឬ មិនទទួលស្គាល់ចំពោះអង្គហេតុដែលមានសរសេរនៅក្នុងពាក្យបណ្ដឹង

○ ក្នុងករណីដែលនៅក្នុងពាក្យបណ្ដឹងមិនមានការសរសេរឲ្យអំពី "អង្គហេតុដែលជាមូលហេតុនៃការទាមទារ" (មាត្រា ៧៥ កថា.ទី៣) (អង្គហេតុចម្បង) ឲ្យបានគ្រប់គ្រាន់ទេ តុលាការ

ចាំបាច់ត្រូវជំរុញឲ្យដើមចោទអះអាង ហើយឲ្យចុងចម្លើយធ្វើការទទួលស្គាល់ ឬ មិនទទួលស្គាល់សាជាថ្មីទៅលើអង្គហេតុនោះ។

□ អង្គហេតុតវ៉ា

○ តើមានសរសេរអំពីអង្គហេតុចម្បងទាំងអស់ដែលនាំឲ្យកើតសិទ្ធិតវ៉ា ហើយឬនៅ? (ឧទាហរណ៍ ៖ ប្រសិនបើជាការតវ៉ាអំពីការទូទាត់ ត្រូវលើកឡើងដូចជា អត្ថិភាពនៃសិទ្ធិលើបំណុលដែលផ្ដើមការ
ទូទាត់ ការបង្ហាញអំពីឆន្ទៈទូទាត់ មិនមានភ្ជាប់នូវសិទ្ធិតវ៉ារបស់ភាគីម្ខាងទៀតចំពោះសិទ្ធិលើបំណុលដែលផ្ដើមការទូទាត់)

※ ក្នុងករណីដែលមិនមានសរសេរអំពីចំណុចទាំងអស់នេះទេ តុលាការនឹងប្រើប្រាស់សិទ្ធិស្រាយបំភ្លឺ ហើយជំរុញឲ្យចុងចម្លើយអះអាង និង បញ្ជាក់ភស្តុតាង (មាត្រា ៩០ កថា.ទី១)។

□ ការទទួលស្គាល់ ឬ មិនទទួលស្គាល់អំពី Kg ដែលសរសេរនៅក្នុងដ្យាក្រាម ហើយបង្កើតនូវផ្នែកស្ដីពីកាតវ៉ា

※ ប្រសិនបើមានការដាក់ឯកសារចម្លើយតាមដំណាក់កាល នឹងអាចធ្វើឲ្យតុលាការអាចរៀបចំនូវចំណុចវិវាទចំពោះមូលហេតុនៃការទាមទារ។

ពោល គឺដោយសារតែ តុលាការពុំចាំបាច់ទទួលស្គាល់ទៅលើ "អង្គហេតុដែលភាគីបានសារភាព" និង " អង្គហេតុដែលតុលាការយល់ឃើញថា មានភាពជាក់ស្ដែង" ទេ ដូច្នេះ នៅក្នុងចំណោមអង្គហេតុដែលជាមូលហេតុនៃការទាមទារ តុលាការមិនចាំបាច់ធ្វើការពិនិត្យភស្តុតាងចំពោះអង្គហេតុដែលចុងចម្លើយបានទទួលស្គាល់នៅក្នុងឯកសារចម្លើយ។

ចំពោះអង្គហេតុដែលចុងចម្លើយមិនបានទទួលស្គាល់នៅក្នុងឯកសារចម្លើយ តុលាការចាំបាច់ត្រូវពិនិត្យភស្តុតាងនៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់នៅពេលបន្ទាប់ (មាត្រា ១២៣ កថា.ទី ១ និង មាត្រា ១២៧ កថា.ទី១) ។ តើដើមចោទដាក់ភស្តុតាងហើយឬទេ? ប្រសិនបើមិនទាន់បានដាក់ទេ តុលាការនឹងជំរុញឲ្យដាក់ភស្តុតាង (មាត្រា ៩០ កថា.ទី១)

→ នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការត្រូវរៀបចំនូវសេចក្ដីអះអាងរបស់ភាគី បំភ្លឺនូវចំណុចវិវាទនៃរឿងក្ដី និង រៀបចំភស្តុតាងភស្តុតាងដែលទាក់ទងទៅនឹងចំណុចវិវាទនៃរឿងក្ដី ដើម្បី

អាចធ្វើការវិនិច្ឆ័យរឿងក្តីនៅក្នុងនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ឲ្យបានល្អិតល្អន់ (មាត្រា ១០៣)។

★ <u>កាលបរិច្ឆេទលើកទី ១ នៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល</u>

□ បើដើមចោទមិនបានបង្ហាញខ្លួននៅកាលបរិច្ឆេទលើកទី ១ នៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលទេ តុលាការត្រូវច្រាន់ចោលការទាមទាររបស់ដើមចោទនោះ ដោយសាលក្រមកំបាំងមុខ (មាត្រា ២០០ កថា.ទី១)។

□ បើចុងចម្លើយមិនបានបង្ហាញខ្លួននៅកាលបរិច្ឆេទលើកទី ១ នៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលទេ តុលាការត្រូវបញ្ឈប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលភ្លាមៗ ហើយកំណត់នូវកាលបរិច្ឆេទលើកទី ១ នៃការទាញហេតុផលដោយផ្ទាល់មាត់ (មាត្រា ២០១ កថា.ទី១)។

៣. ឯកសារត្រៀម (មាត្រា ១០១ កថា.ទី២)

□ នៅពេលធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហាតុផល និង ការទាញហេតុផលដោយផ្ទាល់មាត់ តុលាការអាចបង្គាប់ឲ្យភាគីដាក់ឯកសារត្រៀមបាន។(មាត្រា ១០១ កថា.ទី១)

តើនៅក្នុងករណីបែបណាដែលចំបាច់ឲ្យភាគី (ដើមចោទ ឬ ចុងចម្លើយ) ដាក់ឯកសារត្រៀម?
← គឺនៅក្នុងករណីដើម្បីរៀបចំនូវសេចក្តីអះអាងរបស់ភាគី បំភ្លឺចំណុចវិវាទនៃរឿងក្តី ឬ រៀបចំភស្តុតាងដែលទាក់ទងនឹងចំណុចវិវាទនៃរឿងក្តី (មាត្រា ១០៣)។

ចំពោះឯកសារត្រៀម គឺ មិនកំណត់ថាមានតែ ១ច្បាប់ទេ។ នៅក្នុងរឿងក្តីដែលមានលក្ខណៈស្មុគស្មាញ ក៏មានការដាក់ឯកសារត្រៀមច្រើនដងផងដែរ (ឯកសារត្រៀមលើកទី១ របស់ដើមចោទ ឯកសារត្រៀមលើកទី១ របស់ចុងចម្លើយ ឯកសារត្រៀមលើកទី២ របស់ដើមចោទ ឯកសារត្រៀមលើកទី២ របស់ចុងចម្លើយ...)។

□ ករណីដែលតម្រូវឲ្យដើមចោទដាក់ឯកសារត្រៀម

- ○ ការទទួលស្គាល់ ឬ មិនទទួលស្គាល់ចំពោះអង្គហេតុតវ៉ា (ករណីដែលចុងចម្លើយបានអះអាងអំពីអង្គហេតុតវ៉ា)
- ○ ករណីដែលមានការតវ៉ាតបចំពោះការតវ៉ា
- ○ ការអះអាងអំពីអង្គហេតុប្រយោល (ករណីដែលមិនមានភស្តុតាងផ្ទាល់ដើម្បីបញ្ជាក់អំពី

អង្គហេតុដែលចុងចម្លើយមិនបានទទួលស្គាល់ នៅក្នុងចំណោមអង្គហេតុដែលដើមចោទមានបន្ទុកត្រូវបញ្ជាក់ភស្តុតាង (អង្គហេតុដែលជាមូលហេតុនៃការទាមទារ ឬ អង្គហេតុតវ៉ាតបជាដើម))

○ ការទទួលស្គាល់ ឬ មិនទទួលស្គាល់ចំពោះអង្គហេតុប្រយោល (ករណីដែលចុងចម្លើយបានអះអាងអំពីអង្គហេតុប្រយោល) ជាអាទិ៍

□ ករណីដែលតម្រូវឲ្យចុងចម្លើយដាក់ឯកសារត្រៀម

○ ការទទួលស្គាល់ ឬ មិនទទួលស្គាល់អំពីអង្គហេតុតវ៉ាតប (ករណីដែលដើមចោទបានអះអាងអំពីអង្គហេតុតវ៉ាតប)

○ ករណីដែលមានអង្គហេតុតវ៉ាតបម្តងទៀត

○ ការអះអាងអំពីអង្គហេតុប្រយោល (ករណីដែលមិនមានភស្តុតាងផ្ទាល់ដើម្បីបញ្ជាក់អំពីអង្គហេតុដែលដើមចោទមិនបានទទួលស្គាល់ នៅក្នុងចំណោមអង្គហេតុដែលចុងចម្លើយមានបន្ទុកត្រូវបញ្ជាក់ភស្តុតាង (អង្គហេតុតវ៉ា ឬ អង្គហេតុតវ៉ាតបម្តងទៀតជាដើម))

○ ការទទួលស្គាល់ ឬ មិនទទួលស្គាល់ចំពោះអង្គហេតុប្រយោល (ករណីដែលដើមបានអះអាងអំពីអង្គហេតុប្រយោល) ជាអាទិ៍

★ **<u>កាលបរិច្ឆេទដើម្បីបន្តនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល</u>**

□ បើដើមចោទមិនបានបង្ហាញខ្លួននៅកាលបរិច្ឆេទដើម្បីបន្តនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលទេ តុលាការអាចបញ្ឈប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដោយភ្លាមៗ ហើយកំណត់នូវកាល់បរិច្ឆេទលើកទី ១ នៃការទាញហេតុផលដោយផ្ទាល់មាត់បាន (មាត្រា ២០០ កឋ.ទី២)។

★ **<u>ការបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល</u>**

□ បញ្ចប់នូវការធ្វើដ្យាក្រាម

ប្រសិនបើមិនអាចបញ្ចប់នូវការធ្វើដ្យាក្រាមបានទេ នឹងមានន័យថា ការរៀបចំនូវសេចក្តីអះអាងរបស់ភាគី គឺមិនទាន់គ្រប់ជ្រុងជ្រោយនៅឡើយទេ។ ចំពោះផ្នែកដែលមិនបានបញ្ចប់ពេញលេញ នឹងត្រូវឲ្យភាគី (ដើមចោទ ឬ ចុងចម្លើយ) ដាក់ឯកសារត្រៀម ហើយរៀបចំនូវសេចក្តីអះអាងសាជាថ្មី។ (មាត្រា១០៣)

□ ការបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

ផ្អែកតាមមាត្រា ១០៧ ចែងថា " នៅពេលបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដោយបានបញ្ចប់ការរៀបចំចំណុចវិវាទនៃរឿងក្ដី និង ភស្តុតាងហើយ នោះតុលាការត្រូវធ្វើការ បញ្ជាក់ជាមួយភាគីនូវអង្គហេតុដែលនឹងត្រូវបំភ្លឺនៅពេលពិនិត្យភស្តុតាងនៅពេលក្រោយ" ។

□ ការកំណត់អំពីការបរិច្ឆេទដើម្បីធ្វើការទាញហេតុផលដោយផ្ទាល់មាត់ និង ការកោះហៅគូភាគី (មាត្រា ១១៣)

★ <u>កាលបរិច្ឆេទនៃការទាញហេតុដោយផ្ទាល់មាត់</u>

□ បើដើមចោទមិនបានបង្ហាញខ្លួន នៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ទេ តុលាការត្រូវច្រានចោលការទាមទាររបស់ដើមចោទនោះ ដោយសាលក្រមកំបាំងមុខ (មាត្រា ២០០ កថា.ទី៣)។

□ សេចក្ដីថ្លែងការណ៍អំពីលទ្ធផលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល (ធ្វើឡើងនៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់) (មាត្រា ១១៦ កថា.ទី១ និង ទី២)

ចាំបាច់ត្រូវបង្ហាញឲ្យបានច្បាស់លាស់នូវអង្គហេតុដែលនឹងត្រូវបញ្ជាក់ដោយការពិនិត្យភស្តុតាង (អង្គហេតុដែលមានវិវាទ = ចំណុចវិវាទ)។

□ ការពិនិត្យភស្តុតាង (មាត្រា ១២៣ ដល់ មាត្រា ១៧២)

□ ការបើកនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលជាថ្មីម្ដងទៀត (អាស្រ័យតាមភាពចាំបាច់) (មាត្រា ១១៦ កថា.ទី៤)

ចំពោះតែករណីពិសេសតែប៉ុណ្ណោះ (ក្រោយលទ្ធផលនៃការពិនិត្យភស្តុតាង លេចចេញនូវចំណុចវិវាទថ្មីតុលាការមិនអាចព្យាករណ៍បាននៅក្នុងនីតិវិធីនៃការត្រៀមសម្រាប់ការទាញហេតុផលលើកដំបូង ហើយមានភាពចាំបាច់នៅក្នុងការរៀបចំសេចក្ដីអះអាងរបស់ភាគីអំពីចំណុចនោះ)។

ដើម្បីកុំឲ្យភាពចាំបាច់នៅក្នុងការបើកនីតិវិធីត្រៀមសម្រាម់ការទាញហេតុផលសាជាថ្មីកើតមានឡើង គប្បីរៀបចំនូវសេចក្ដីអះអាងរបស់ភាគីឲ្យបានច្បាស់លាស់តាំងពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកដំបូងទើបប្រសើរ។

□ ការទាញហេតុផលចុងក្រោយដោយភាគី (មាត្រា ១១៦ កឋ.ទី៥)

★ <u>ការបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់</u>

□ ការបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ (មាត្រា ១៨០ កឋ.ទី១)

□ ការបើកការទាញហេតុផលដោយផ្ទាល់មាត់សាជាថ្មី (អាស្រ័យតាមភាពចាំបាច់) (មាត្រា ១៨០ កឋ.ទី៣)

ចំពោះតែករណីពិសេសតែប៉ុណ្ណោះ (ករណីដែលមានការសងនៅក្រោយពេលដែលបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ ហើយគួរតែយកខ្លឹមសារនោះឆ្លុះបញ្ចាំងដាក់នៅក្នុងសាលក្រមចុងក្រោយជាដើម (ក្នុងករណីដែលមានការសង ហើយតុលាការបានចេញសាលក្រមចុងក្រោយដោយមិនបានបង្ហាញឲ្យឃើញអំពីការសងនោះ នាំឲ្យគេអាចព្យាករណ៍ទុកបានថា នឹងអាចមានបណ្ដឹងឧទ្ធរណ៍ដែលជាការធ្វើឧបាស្រ័យទៅលើកសាលក្រមចុងក្រោយនោះ ពីខាងភាគីដែលបានសង))។

៤. លិខិតសាលក្រម

□ ការកំណត់អំពីកាលបរិច្ឆេទប្រកាសសាលក្រម (មាត្រា ១៨៨ កឋ.ទី១)

※ ជាគោលការណ៍ គឺនៅក្នុងអំឡុងពេល ១ខែគិតចាប់ពីថ្ងៃដែលបានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ (មាត្រា ១៨៧)

□ តើមានសរសេរចំណុចដែលចាំបាច់ត្រូវតែសរសេរ (មាត្រា ១៨៩ កឋ.ទី១)ឬទេ?

○ តុលាការ (ចំណុច ក.)

○ ថ្ងៃដែលបានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ (ចំណុច. ខ)

← សាលក្រម គឺការកំណត់ជាស្ថាពរនូវទំនាក់ទំនងសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត នាពេលបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ (មាត្រា ១៩៤ កឋ.ទី២) ដូច្នេះហើយចាំបាច់ត្រូវតែបញ្ជាក់ឲ្យបានច្បាស់លាស់ថា តើពេលណាបានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់?

ពោលគឺ មានន័យថា បើមានការរលត់សិទ្ធិដោយសារការសងនៅចន្លោះថ្ងៃបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ រហូតដល់ថ្ងៃប្រកាសសាលក្រមក៏ដោយ ក៏អង្គហេតុនៃការសងនោះ តុលាការមិនបានយកមកពិចារណានៅក្នុងលិខិតសាលក្រមឡើយ។

○ ឈ្មោះ ឬ នាមករណ៍ និង អាសយដ្ឋានរបស់ភាគី ហើយនិង ឈ្មោះ និង អាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់ (ចំណុច គ.)

○ អង្គហេតុ និង ចំណុចវិវាទ (ចំណុច ឃ.)

ចាំបាច់ត្រូវតែរៀបចំឲ្យបានរួចជាស្រេចត្រឹមពេលដែលបញ្ចប់នូវនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល។

ត្រូវយកអង្គហេតុដែលតុលាការមិនចាំបាច់ទទួលស្គាល់ដោយផ្អែកលើភស្តុតាង ("អង្គហេតុដែលភាគីបានសារភាព" និង "អង្គហេតុដែលតុលាការយល់ឃើញថា មានភាពជាក់ស្តែង" (មាត្រា ១២៣ កថា.ទី២) ) មកសរសេរនៅក្នុងចំណុចដែលមានចំណងជើងថា "អង្គហេតុ"។ ហើយ ត្រូវយកអង្គហេតុដែលតុលាការចាំបាច់ត្រូវទទួលស្គាល់ដោយផ្អែកលើភស្តុតាង មកសរសេរនៅត្រង់ចំណុចដែលមានចំណងជើងថា "ចំណុចវិវាទ" (មាត្រា ១២៣ កថា.ទី១)។

○ សំអាងហេតុ (ចំណុច ង)

ក្នុងការចេញសាលក្រម តុលាការត្រូវវិនិច្ឆ័យទទួលស្គាល់ ឬ មិនទទួលស្គាល់ថា ការអះអាងអំពីអង្គហេតុ មាន ឬ គ្មានភាពពិត ដោយគិតពិចារណាយ៉ាងហ្មត់ចត់នូវលទ្ធផលនៃការពិនិត្យភស្តុតាង និង ដំណើរការ និងខ្លឹមសារនៃការទាញហេតុផលដោយផ្ទាល់មាត់តាមជំនឿទុកចិត្តដោយសេរីរបស់ខ្លួន (មាត្រា ១៨៤)។

ចំពោះចំណុចដែលមានចំណងជើងថា " សំអាងហេតុ" ត្រូវភាពពិត និង មូលហេតុនៃការទទួលស្គាល់ ឬ ភាពពិត និង មូលហេតុនៃការមិនទទួលស្គាល់មកសរសេរចូល។

○ សេចក្តីសម្រេចបញ្ចប់ (ចំណុច ច.)

សរសេរអំពីសេចក្តីសន្និដ្ឋាន។

- មានការវិនិច្ឆ័យចំពោះការទាមទារទាំងអស់ដែលភាគីបានសុំ (មាត្រា ១៨២ កថា.ទី១)
- មិនមានការវិនិច្ឆ័យចំពោះចំណុចដែលភាគីមិនបានសុំ (មាត្រា ១៨២ កថា.ទី២)
- ការសម្រេចសេចក្តីអំពីករណីកិច្ចទទួលបន្ទុកលើប្រាក់ប្រដាប់ក្តី (មាត្រា ១៨២ កថា.ទី៣ និង មាត្រា ៦៤)
- ការប្រកាសឲ្យអនុវត្តជាបណ្តោះអាសន្ន (មាត្រា ១៩៦)
  ធ្វើការប្រកាសផ្អែកតាមពាក្យសុំ ឬ ដោយឆន្ទានុសិទ្ធិ

□ ការបញ្ចប់នូវការធ្វើច្បាប់ដើមនៃមូលសាលក្រម (មាត្រា ១៨៨ កថា.ទី១)

★ <u>**កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់លើកទី....(កាលបរិច្ឆេទនៃការប្រកាសសាលក្រម)**</u>

□ ការប្រកាស (មាត្រា ១៨៦)

សាលក្រមនឹងមានអានុភាពដោយការប្រកាស។

□ ការបញ្ជូនអនុសារសាលក្រម (ក្នុងអំឡុងពេល ២ សប្តាហ៍ គិតចាប់ពីថ្ងៃដែលបានប្រកាសសាលក្រម) (មាត្រា ១៩០)

# រឿងក្ដីទាមទារឲ្យសងប្រាក់កម្ចី

○ ការអះអាងរបស់ X

ខ្ញុំជាអ្នកទិញនំធ្វើពីផ្លែឈើត្រូពិកពីគេ មកលក់បន្ត។

Y គឺជាអ្នកបោះដុំឱ្យខ្ញុំម្នាក់។ នៅថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ២០០៧ Y បានស្នើមកខ្ញុំថា ″Yត្រូវបង់ថ្លៃទិញផ្លែឈើត្រូពិកទៅឱ្យ Z ដូច្នេះ សុំខ្ចីប្រាក់ចំនួន ១០.០០០ (មួយម៉ឺន) ដុល្លារអាមេរិកផង ហើយនឹងសងវិញនៅថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០០៨″ ។ នៅថ្ងៃដដែលនោះ ខ្ញុំក៏បានប្រគល់ប្រាក់ចំនួន ១០.០០០ (មួយម៉ឺន) ដុល្លារអាមេរិកដោយបានបង្កើតកិច្ចសន្យាដែលមានហត្ថលេខារបស់ Y ហើយនៅថ្ងៃនោះ ក៏បានប្រគល់ប្រាក់ ១០.០០០ (មួយម៉ឺន) ដុល្លារអាមេរិកជូន Y ភ្លាមទៅ។ លើសពីនេះ ខ្ញុំ និង Y បានព្រមព្រៀងស្តីពីការប្រាក់ដែរ គឺ ៥ % ក្នុងមួយឆ្នាំ ហើយប្រាក់សំណងនៃការខូចខាតដោយសារការយឺតយ៉ាវ គឺ ១០% ក្នុងមួយឆ្នាំ ហើយបានចុះក្នុងកិច្ចសន្យាខាងលើនេះដែរ។

តាំងពីនោះមក Y បានសងខ្ញុំតែ ១.០០០ (មួយពាន់) ដុល្លារអាមេរិក នៅថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១២ ប៉ុណ្ណោះ។ ពេលនោះខ្ញុំបានចុះហត្ថលេខានៅលើលិខិតទទួលប្រាក់ដោយបានបញ្ជាក់យ៉ាងច្បាស់ថាបានទទួលប្រាក់ដែលជាការសងមួយផ្នែកនៃប្រាក់កម្ចីខាងលើ។

ក្រៅពីនេះ Y មិនបានសងទាល់តែសោះ ហើយណាមួយពេលនោះ ខ្ញុំមិនទាន់ទ័ល ហើយក៏មិនទាន់ត្រូវការប្រាក់នោះ ម្ល៉ោះហើយ ខ្ញុំមិនបានដាស់តឿនឱ្យ Y សងនៅឡើយទេ។

តាំងពីដើមរហូតមកដល់ពេលប្តឹង Y នេះ ខ្ញុំនិង Y បានធ្វើជំនួញជាមួយគ្នាជាអាទិ៍ ហើយមានទំនាក់ទំនងជិតស្និទ្ធនឹងគ្នាខ្លាំងណាស់។ ជាការពិតណាស់ នៅថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០១២ ខ្ញុំបានទិញនំធ្វើពីផ្លែឈើត្រូពិកចំនួន ១០.០០០ កញ្ចប់ ក្នុងតម្លៃសរុប ១០.០០០ (មួយម៉ឺន) ដុល្លារអាមេរិកពី Y នៅក្នុងនោះ ក៏មាននំជាង ៥០០ កញ្ចប់ ដែលមានរូបរាងខុសប្លែកពីរាល់ដងផងដែរ។ ប៉ុន្តែ វាមិនដល់ថ្នាក់ថាមិនអាចយកមកលក់បាននោះទេ ហើយជាក់ស្តែង ដោយសារតែនំទាំងនោះបានលក់ដាច់ទាំងអស់ ដូច្នេះហើយ ខ្ញុំមិនបានទាមទារឲ្យ Y សងនោះទេ ហើយគ្រាន់តែឲ្យប្រុងប្រយ័ត្នថា កុំឲ្យមានបញ្ហាបែបនេះកើតឡើងទៀតនៅពេលក្រោយ។ ហេតុនេះហើយ ខ្ញុំមិនធ្លាប់បានទទួលសំណងចំពោះនំទាំងនោះពី Y ទេ។ នៅថ្ងៃទី ៣១ ខែ

តុលា ឆ្នាំ ២០១៣ ខ្ញុំបានទិញរថយន្តពី Y ដែលគាត់កំពុងប្រើក្នុងតម្លៃ ៧.០០០ (ប្រាំពីរពាន់) ដុល្លារអាមេរិក ហើយ ជាក់ស្តែងខ្ញុំក៏បានទទួលការប្រគល់រថយន្តនៅថ្ងៃនោះដែរ។ តាមដែលខ្ញុំចងចាំអំឡុងខែ ធ្នូ ឆ្នាំ ២០១៣ ខ្ញុំបានបង់ប្រាក់ចំនួន ៧.០០០ (ប្រាំពីរពាន់) ដុល្លារអាមេរិក ។

ពេលដែលខ្ញុំបើកហាងថ្មី ខ្ញុំត្រូវការដើមទុន ហើយក៏បានទាមទារ Y ឱ្យគាត់សងបំណុលវិញ ដោយកាត់ប្រាក់ ១.០០០ (មួយពាន់) ដុល្លារអាមេរិកដែលបានសងហើយ និង ប្រាក់ដែលនៅសល់។ តែ Y មិនព្រមសងទាល់តែសោះ ហេតុនេះហើយ នៅថ្ងៃទី ៣ ខែ វិច្ឆិកា ឆ្នាំ ២០១៤ ខ្ញុំបានដាក់ពាក្យបណ្តឹងនេះចំពោះ Y ទៅតុលាការ។

○ ការអះអាងរបស់ Y

មុខរបរខ្ញុំគឺ ទិញផ្លែឈើត្រូពិកពីអ្នកចំការ ហើយកែច្នៃជានំ ទៅលក់ឱ្យម៉ូយខ្ញុំ។ X គឺជាម៉ូយខ្ញុំម្នាក់សំខាន់ដែរ គឺគាត់ទិញនំធ្វើពីផ្លែឈើត្រូពិក ពីខ្ញុំតាំងពីមុនមក។

នៅថ្ងៃទី ១ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ខ្ញុំត្រូវបង់ផ្លែឈើដែលបានទិញនោះ ទៅឱ្យអ្នកចំការ ម្ល៉ោះហើយខ្ញុំក៏បានស្នើទៅ X ថា "សុំខ្ចីប្រាក់ ១០.០០០ (មួយម៉ឺន) ដុល្លារអាមេរិក ហើយនឹងសងនៅថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០០៨ " ហើយនៅថ្ងៃដដែលនោះ ក៏បានបង្កើតកិច្ចសន្យាជាលាយលក្ខណ៍អក្សរ ដើម្បីខ្ចីប្រាក់ ១០.០០០ (មួយម៉ឺន) ដុល្លារអាមេរិកពិតមែន។យ៉ាងណាមិញ នៅពេលនោះមានការព្រមព្រៀងអំពីការប្រាក់ ៥% ក្នុង ១ឆ្នាំ និង ការប្រាក់យឺតយ៉ាវចំនួន ១០% ក្នុង ១ឆ្នាំ ពិតមែន។

នៅថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១២ ខ្ញុំបានប្រគល់ប្រាក់ ១.០០០ (មួយពាន់) ដុល្លារអាមេរិកទៅឱ្យ X ពិតមែន។

ក៏ប៉ុន្តែ ប្រាក់ ១.០០០ (មួយពាន់) ដុល្លារអាមេរិកនេះ គឺខ្ញុំបានបង់ឱ្យទៅ X ដើម្បីសងនូវទំនិញមួយភាគដែលខ្វះគុណភាពក្នុងចំណោមទំនិញដែលខ្ញុំបានលក់ឱ្យគាត់។ ពោលគឺ នៅថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០១២ ខ្ញុំបានលក់នំធ្វើពីផ្លែឈើត្រូពិកចំនួន ១០.០០០ កញ្ចប់ក្នុងតម្លៃសរុប ១០.០០០ (មួយម៉ឺន) ដុល្លារអាមេរិកឲ្យទៅ X ។ ប៉ុន្តែ ដោយសារតែ X បាននិយាយថា នៅក្នុងចំណោមនំទាំងនោះ មាននំចំនួន ៥០០ កញ្ចប់ ដែលខូចទ្រង់ទ្រាយ ហើយមិនអាចលក់បានទេ ដូច្នេះហើយទើបនៅថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១២ ខ្ញុំបានបង់ប្រាក់ឲ្យ X ចំនួន ១.០០០ (មួយពាន់) ដុល្លារអាមេរិក

ជាសំណងចំពោះផ្ទែកនំទាំងនោះ។ ដូច្នេះ មិនមែនមានន័យថា ខ្ញុំបានសងមួយភាគនៃប្រាក់កម្ចីចំនួន ១០.០០០ (មួយម៉ឺន) ដុល្លារអាមេរិកនោះទេ។

ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៣ ខ្ញុំបានលក់រថយន្តដែលខ្ញុំកំពុងជិះទៅឱ្យ X ក្នុងតម្លៃ ៧.០០០ (ប្រាំពីរពាន់) ដុល្លារអាមេរិក។ ពាក់ព័ន្ធនឹងការលក់រថយន្តនេះ ខ្ញុំបានប្រគល់រថយន្តទៅឱ្យ X នៅថ្ងៃនោះហើយ ប៉ុន្តែ ចំពោះប្រាក់ថ្លៃលក់ ៧.០០០ (ប្រាំពីរពាន់) ដុល្លារអាមេរិកនោះ ទោះបីជាខ្ញុំបានដាស់តឿន ឬ ទាមទារប៉ុន្មានដងក៏ដោយ ក៏គាត់មិនទាន់បានបង់ឱ្យខ្ញុំទេ។

រឿងពិត គឺដូចដែលខ្ញុំបានរៀបរាប់ខាងលើនេះ។

ចំពោះ ប្រាក់ដែលខ្ញុំបានខ្ចីពី X គឺអំឡុងពេលនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលបានកន្លងផុតហើយ ហេតុនេះ ខ្ញុំនឹងលើកឡើងអំពី អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល នៅក្នុងនីតិវិធីនៃបណ្ដឹង ។

ម៉្យាងទៀត ទោះបីជាមិនមានការទទួលស្គាល់នូវអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលក៏ដោយ ក៏ខ្ញុំនឹងអះអាងនូវការទូទាត់នឹងសិទ្ធិលើបំណុលនៃប្រាក់ថ្លៃទិញលក់រថយន្ត ៧.០០០ (ប្រាំពីរពាន់) ដុល្លារអាមេរិកដែរ។

**1.11.2007**

X・Y ចុះកិច្ចសន្យាខ្ចីប្រាក់
- ចំនួនទឹកប្រាក់ 10.000$
- កាលបរិច្ឆេទសង ត្រឹម 31.10.2008

X→Y ប្រគល់ប្រាក់ 10.000$ ផ្អែកតាមកិច្ចសន្យាខ្ចីប្រាក់ខាងលើ

X・Y ផ្អែកតាមកិច្ចសន្យាខ្ចីបរិភោគខាងលើ មានចុះការព្រមព្រៀងបង្កើតនូវសិទ្ធិលើបំណុលដែលជាការប្រាក់ 5 % ក្នុង 1 ឆ្នាំ + ការព្រមព្រៀងនេះត្រូវបានធ្វើឡើងតាមលិខិតជាលាយល័ក្ខណ៍អក្សរ ដោយមានចុះហត្ថលេខារបស់ Y (កថា.ទី 3 មាត្រា 583 នៃក្រមរដ្ឋប្បវេណី)

អាចសរសេររួមគ្នាតែនៅក្នុងលិខិតតែមួយក៏បាន

X・Y ផ្អែកតាមកិច្ចសន្យាខ្ចីបរិភោគខាងលើ មានចុះការព្រមព្រៀងអំពីការបង់ប្រាក់សំណងការខូចខាតចំពោះការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ច 10% ក្នុង1 ឆ្នាំ + ការព្រមព្រៀងនេះត្រូវបានធ្វើឡើងតាមលិខិតជាលាយល័ក្ខណ៍អក្សរ ដោយមានចុះហត្ថលេខារបស់ Y (ការអនុវត្តស្រដៀងគ្នានឹង កថា.ទី 3 មាត្រា 584 នៃក្រមរដ្ឋប្បវេណី)

**31.10.2008** ការកន្លងផុតនូវកាលបរិច្ឆេទសង

ការកំណត់ជាមុននូវចំនួននៃសំណង (កថា.ទី 1 មាត្រា 403 នៃក្រមរដ្ឋប្បវេណី)

អំឡុងពេលនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល 5 ឆ្នាំ (មាត្រា 482 នៃក្រមរដ្ឋប្បវេណី)

**31.10.2012**

Y→X បង់ប្រាក់ 1.000$

តើមានហេតុនៃការផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល (ចំណុច គ. មាត្រា 489 នៃក្រមរដ្ឋប្បវេណី) ដែរទេ ?

**31.10.2013**

Y・X ចុះកិច្ចសន្យាលក់ទិញ (រថយន្ត ថ្លៃលក់ទិញ 7.000$)

Y→X ប្រគល់រថយន្តផ្អែកតាមកិច្ចសន្យាលក់ទិញ

**12.12.2014**

Y→X បង្ហាញឆន្ទៈអំពីការលើកឡើងនូវអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល (កថា.ទី 1 មាត្រា 486 នៃក្រមរដ្ឋប្បវេណី) បង្ហាញឆន្ទៈអំពីការទូទាត់នូវសិទ្ធិលើបំណុលដែលជាថ្លៃលក់ទិញ និង សិទ្ធិលើបំណុលដែលជាប្រាក់កម្ចី (កថា.ទី 1 មាត្រា 465 នៃក្រមរដ្ឋប្បវេណី)

# ដ្យាក្រាមនៃរឿងក្តីទាមទារឲ្យសងប្រាក់កម្ចី

Kg ប្រាក់ដើមនៃប្រាក់កម្ចី

| | | |
|---|---|---|
| a | 1.11.2007 X និងY<br>ចុះកិច្ចសន្យាខ្ចីបរិភោគដូចតទៅ៖<br>ចំនួនទឹកប្រាក់ 10.000$<br>ពេលកំណត់សង 31.10.2008 | ○ |
| b | 1.11.2007 X→Y ប្រគល់ប្រាក់ចំនួន<br>10.000$ ដោយផ្អែកតាមកិច្ចសន្យានៃចំណុច a | ○ |
| c | 31.10. 2008 បានមកដល់ | Ob |

ការប្រាក់

| | | |
|---|---|---|
| d | X・Y បានព្រមព្រៀងថាបង់ការប្រាក់ 5% ក្នុងមួយឆ្នាំនៅក្នុង<br>កិច្ចសន្យាចំណុច ក. | ○ |
| e | 1.11.2007 X→Y ប្រគល់ប្រាក់ចំនួន<br>10.000$ ដោយផ្អែកតាមកិច្ចសន្យានៃចំណុច a | ○ |
| f | កិច្ចសន្យានៃចំណុច d ត្រូវបានធ្វើឡើងដោយលិខិតលាយលក្ខណ៍<br>អក្សរដោយមានហត្ថលេខារបស់ Y (អ្នកខ្ចី) | ○ |
| g | 31.10.2008 បានមកដល់ | Ob |

Kg ប្រាក់សំណងការខូចខាតចំពោះ
ការយឺតយ៉ាវក្នុងការអនុវត្ត
"ពាក្យនៅក្នុងកថា.ទី6 នៃមាត្រា 17 នៃច្បាប់ស្តីពី
ការអនុវត្តក្រមរដ្ឋប្បវេណី "

| | | |
|---|---|---|
| h | X・Y បានព្រមព្រៀងថា បង់ប្រាក់សំណងការខូចខាតចំពោះ<br>ការយឺតយ៉ាវក្នុងការអនុវត្ត "ពាក្យនៅក្នុងកថា.ទី6 នៃមាត្រា 17 នៃ<br>ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី " ចំនួន 10 % ក្នុង 1ឆ្នាំ នៅក្នុង<br>កិច្ចសន្យាចំណុច a | ○ |
| i | 1.11.2007 X→Y ប្រគល់ប្រាក់ចំនួន<br>10.000$ ដោយផ្អែកតាមកិច្ចសន្យានៃចំណុច a | ○ |
| j | កិច្ចសន្យានៃចំណុច h ត្រូវបានធ្វើឡើងដោយលិខិតលាយលក្ខណ៍<br>អក្សរដោយមានហត្ថលេខារបស់ Y (អ្នកខ្ចី) | ○ |
| k | 31.10. 2008 បានកន្លងផុត | Ob |

E1 អាជ្ញាយុកាលនៃការរលត់សិទ្ធិលើបំណុល

| | | |
|---|---|---|
| l | 31.10.2013 បានកន្លងផុត | Ob |
| m | Y→X ការបង្ហាញឆន្ទៈអំពីការលើកឡើងនូវអាជ្ញាយុកាលនៅក្នុង<br>ឯកសារចម្លើយបានទៅដល់ដើមចោទនៅ 12.12.2014 | Ob |

E2 ការទូទាត់

| | | |
|---|---|---|
| n | Y→X 31.10.2013<br>បានលក់រថយន្តក្នុងតម្លៃ 7.000$ | ○ |
| o | Y→X 31.10.2013 បានប្រគល់រថយន្តតាមកិច្ចសន្យា ចំណុច n | ○ |
| p | Y→X ការបង្ហាញឆន្ទៈទូទាត់ប្រាក់ថ្លៃលក់ទិញនៃចំណុច n ក្នុងចំនួនប្រាក់ស្មើគ្នា<br>ជាមួយនឹងកាតព្វកិច្ចប្រាក់កម្ចីនៃចំណុច a នៅក្នុង<br>ឯកសារចម្លើយបានទៅដល់ដើមចោទនៅ 12.12.2014 | Ob |

R1 ការផ្អាកអាជ្ញាយុកាល (មាត្រា 489 ចំណុច គ. នៃក្រមរដ្ឋប្បវេណី)

| | | |
|---|---|---|
| q | Y→X 31.10.2012 ការសងប្រាក់ចំនួន 1.000$ ចំពោះកាតព្វកិច្ចនៃ<br>ចំណុច a | × |

R2 ការសង

| | | |
|---|---|---|
| r | X→Y 12.2013<br>ការសងប្រាក់ចំនួន 7.000$ ផ្អែកតាមកាតព្វកិច្ចនៃចំណុច n | × |

និមិត្តសញ្ញា ៖

Kg : អង្គហេតុដែលជាមូលហេតុនៃការទាមទារ
E : ការតវ៉ា
R : ការតវ៉ាតប
D : ការតវ៉ាចំពោះការតវ៉ាតប
O : ការទទួលស្គាល់
X : ការមិនទទួលស្គាល់
△ : មិនដឹង
Ob : អង្គហេតុជាក់ស្តែង

# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

## ពាក្យបណ្ដឹង

### ដើមចោទ

ឈ្មោះ ៖ X

អាសយដ្ឋាន ៖ ផ្ទះលេខ 00 ផ្លូវលេខ 00 សង្កាត់ទំនប់ទឹក ខណ្ឌចំការមន រាជធានីភ្នំពេញ[1]។

### អ្នកតំណាងដោយអាណត្តិ

លោក/លោកស្រី ៖ P

អាសយដ្ឋានការិយាល័យមេធាវី / ក្រុមមេធាវី / ក្រុមហ៊ុនមេធាវី ៖ ...................

ការិយាល័យមេធាវី / ក្រុមមេធាវី / ក្រុមហ៊ុនមេធាវី ៖ ...............................................

លេខទូរស័ព្ទ ៖ ......................................................................................

**ទីកន្លែងបញ្ជូន** ៖ ការិយាល័យមេធាវី/ ក្រុមមេធាវី/ ក្រុមហ៊ុនមេធាវី.................[2]

### ចុងចម្លើយ

ឈ្មោះ ៖ Y

អាសយដ្ឋាន ៖ ផ្ទះលេខ 00 ផ្លូវលេខ 00 សង្កាត់មនោរម្យ ខណ្ឌ ៧មករា រាជធានីភ្នំពេញ។

[1] ឈ្មោះ និងអាសយដ្ឋាន មានបញ្ញត្តិនៅក្នុងមាត្រា ៧៥ កថាខណ្ឌទី ២ ចំណុច ក នៃក្រមនីតិវិធីរដ្ឋប្បវេណី ប៉ុន្តែ ចំពោះចំណុចផ្សេងទៀត ដូចជា ខែឆ្នាំកំណើតជាអាទិ៍ ជាចំណុចដែលពុំមានបញ្ញត្តិក្នុងច្បាប់ទេ។ ប៉ុន្តែ ក៏មានករណីដែលពុំអាចកំណត់អំពី ភាគី តាមរយៈឈ្មោះ និង អាសយដ្ឋានផងដែរ ដូច្នេះហើយ ត្រូវសរសេរចំណុចទាំងនោះក្នុងកម្រិតមួយដែលចាំបាច់ដើម្បីអាចកំណត់អំពីភាគី ។

[2] មាត្រា ២៤៩ និងមាត្រា ២៥០ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ ការដាក់ពីទីកន្លែងដែលត្រូវបញ្ជូន មិនមែនជាកាតព្វកិច្ចនោះទេ។ ប្រសិនបើពុំមានការសរសេរអំពីទីកន្លែងដែលត្រូវបញ្ជូនទេ ការបញ្ជូននឹងត្រូវបានធ្វើទៅកាន់អាសយដ្ឋានរបស់ដើមចោទជាអាទិ៍។ ហេតុនេះ ក្នុងករណីដែលអ្នកតំណាងដោយអាណត្តិរបស់ដើមចោទមានបំណងធ្វើការបញ្ជូនទៅកាន់ទីកន្លែងណាផ្សេងក្រៅពីអាសយដ្ឋានរបស់ដើមចោទជាអាទិ៍ គឺមានភាពចាំបាច់ក្នុងការសរសេរអំពីទីកន្លែងដែលត្រូវបញ្ជូននៅក្នុងលិខិតពាក្យបណ្ដឹងជាអាទិ៍។

**សូមគោរពជូន**

**លោកប្រធានសាលាដំបូងរាជធានីភ្នំពេញ**[3]

**ក. ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ**[4] ៖

(១) បង្គាប់ឲ្យចុងចម្លើយបង់ប្រាក់ចំនួន ១៣.៥០០ (មួយម៉ឺនបីពាន់ប្រាំរយ) ដុល្លារអាមេរិក និង ប្រាក់ ១០% (ដប់ភាគរយ) នៃប្រាក់ចំនួន ១០.០០០ (មួយម៉ឺន) ដុល្លារអាមេរិកក្នុងទឹកប្រាក់ ១៣.៥០០ (មួយម៉ឺនបីពាន់ប្រាំរយ) ដុល្លារអាមេរិក គិតចាប់ពីថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០១២ រហូតដល់ពេលសងរួចទៅដើមចោទ។

(២) ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ចុងចម្លើយ។[5]

(៣) សាលក្រមនេះអាចអនុវត្តជាបណ្ដោះអាសន្នបាន។[6]

**ខ. អង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ និង អង្គហេតុដែលជាមូលហេតុនៃការទាមទារ**[7]

**ខ.១. ការទាមទារប្រាក់ដើម និង ប្រាក់សំណងការខូចខាតចំពោះការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ច[8]គិតចាប់ពីថ្ងៃទី ១ ខែ វិច្ឆិកា ឆ្នាំ ២០០៨ រហូតដល់ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១២**[9]

**ខ.១.១.** ថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ចុងចម្លើយបានព្រមព្រៀងលើកិច្ចសន្យាកម្ចីបរិភោគជាមួយដើមចោទក្នុងទឹកប្រាក់ចំនួន ១០.០០០

---

[3] ពាក្យបណ្ដឹងត្រូវតែដាក់ផ្ញើទៅតុលាការដែលមានសមត្ថកិច្ច (សមត្ថកិច្ចសាលាជម្រះក្ដី) ( មាត្រា ៨ មាត្រា ៩ ជាអាទិ៍នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ អាសយដ្ឋានរបស់ចុងចម្លើយក្នុងរឿងក្ដីនេះ គឺស្ថិតនៅរាជធានីភ្នំពេញ ដូច្នេះតុលាការដែលមានសមត្ថកិច្ច គឺសាលាដំបូងរាជធានីភ្នំពេញ ( ក្រមនីតិវិធិរដ្ឋប្បវេណីមាត្រា ៨ ចំណុច ក)។

[4] ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារ គឺមានភាពចាំបាច់ដែលត្រូវសរសេរក្នុងពាក្យបណ្ដឹង (មាត្រា ៧៥ កថាខណ្ឌទី ២ ចំណុច ខ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

[5] តុលាការត្រូវសម្រេចអំពីប្រាក់ប្រដាប់ក្ដី (មាត្រា ១៨២ កថាខណ្ឌទី ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ) ហើយប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់អ្នកចាញ់ក្ដី (មាត្រា ៦៤ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

[6] មាត្រា ១៩៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

[7] មាត្រា ៧៥ កថាខណ្ឌទី ២ ចំណុច ខ និង កថាខណ្ឌទី ៣ នៃក្រមនិតិវិធីរដ្ឋប្បវេណី។

[8] ប្រើប្រាស់ពាក្យដែលចែងនៅក្នុងកថាខណ្ឌទី ៦ មាត្រា ១៧ នៃច្បាប់ស្ដីពីការអនុវត្តក្រមរដ្ឋប្បវេណី។

[9] ចាប់ពីមាត្រា ៥៧៨ ដល់ មាត្រា ៥៩៥ ព្រមទាំង មាត្រា ៣៩៨ មាត្រា ៣៩៩ និង មាត្រា ៤០៣ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី។

(មួយម៉ឺន) ដុល្លារអាមេរិក [10] ។ កិច្ចសន្យានេះបានកំណត់កាលបរិច្ឆេទសងនៅថ្ងៃ ទី៣១ ខែ តុលា ឆ្នាំ ២០០៨។ ដើមចោទ និង ចុងចម្លើយបានព្រមព្រៀងជាលិខិតលាយលក្ខណ៍អក្សរដោយមានហត្ថលេខារបស់ចុងចម្លើយ អំពីការបង់ការប្រាក់ចំនួន ៥ % ក្នុង ១ ឆ្នាំ (ប្រាំភាគរយក្នុងមួយឆ្នាំ) និង ប្រាក់សំណងការខូចខាតចំពោះការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ច ចំនួន ១០% ក្នុង ១ ឆ្នាំ (ដប់ភាគរយក្នុងមួយឆ្នាំ) នៃប្រាក់កម្ចីចំនួន ១០.០០០ (មួយម៉ឺន) ដុល្លារអាមេរិកខាងលើ[11] [12]។ **(ភស្តុតាង $X_1$)**

នៅថ្ងៃទី ១ ខែវិច្ឆិកា ឆ្នាំ ២០០៧ ដើមចោទបានប្រគល់សាច់ប្រាក់ចំនួន ១០.០០០ (មួយម៉ឺន) ដុល្លារអាមេរិកទៅចុងចម្លើយដោយផ្អែកតាមកិច្ចសន្យាខាងលើ។ **(ភស្តុតាង $X_2$)**

---

[10] អង្គហេតុចម្បងដើម្បីទាមទារប្រាក់ដើម ៖ មាត្រា ៥៧៨ មាត្រា ៥៧៩ មាត្រា ៥៩១ និង មាត្រា ៥៩៤ នៃក្រមរដ្ឋប្បវេណី ។ ①ការឲ្យខ្ចីប្រាក់ និង ការព្រមព្រៀងសង ②ការប្រគល់ប្រាក់ដោយផ្អែកលើចំណុចទាំងនេះ ③ ការព្រមព្រៀងអំពីពេលកំណត់ដែលត្រូវសង ④ការមកដល់នៃពេលកំណត់ដែលត្រូវសង។

[11] អង្គហេតុចម្បងដើម្បីទាមទារការប្រាក់ ៖ មាត្រា ៥៨៣ និង មាត្រា ៥៨៤ នៃក្រមរដ្ឋប្បវេណី។ ① ការព្រមព្រៀងអំពីការបង់ការប្រាក់ ② ការប្រគល់ប្រាក់ដើម ③ ការព្រមព្រៀងនៃចំណុច ① ត្រូវបានធ្វើឡើងជាលាយលក្ខណ៍អក្សរដោយមានចុះហត្ថលេខារបស់អ្នកខ្ចី ④ ការកន្លងផុតនៃអំឡុងពេលជាក់លាក់ (ចាប់ពីថ្ងៃឲ្យខ្ចីរហូតដល់ការកន្លងផុតនៃពេលកំណត់ដែលត្រូវសង) ហើយក្នុងករណីដែលមានការព្រមព្រៀងអំពីការបង់ការប្រាក់ដែលមានអត្រាខ្ពស់ជាងអត្រាការប្រាក់ដែលច្បាប់បានកំណត់ ត្រូវបន្ថែមនូវ ⑤ ការព្រមព្រៀងអំពីអត្រាការប្រាក់ ⑥ ការព្រមព្រៀងនៃចំណុច ⑤ ត្រូវបានធ្វើឡើងជាលាយលក្ខណ៍អក្សរដោយមានចុះហត្ថលេខារបស់អ្នកខ្ចី។ ម្យ៉ាងទៀតត្រូវប្រុងប្រយ័ត្នចំពោះការកម្រិតការប្រាក់ (មាត្រា ៥៨៥ នៃក្រមរដ្ឋប្បវេណី)។

[12] អង្គហេតុចម្បងដើម្បីទាមទារប្រាក់សំណងការខូចខាតចំពោះការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ច ៖ មាត្រា ៣៩៨ កថាខណ្ឌទី ១ មាត្រា ៣៩៩ កថាខណ្ឌទី ១ មាត្រា ៤០៣ កថាខណ្ឌទី១ មាត្រា ៥៨៤ កថាខណ្ឌទី ៣ និង មាត្រា ៥៨៣ កថាខណ្ឌទី ៣ នៃក្រមរដ្ឋប្បវេណី។ ក្នុងករណីដែលធ្វើការទាមទារនូវប្រាក់សំណងការខូចខាតចំពោះការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ច ដោយផ្អែកតាមអត្រាការប្រាក់ដែលច្បាប់បានកំណត់ ( ៥ % ក្នុង ១ឆ្នាំ មាត្រា ៣១៨ នៃក្រមរដ្ឋប្បវេណី) ត្រូវមាន ① ការប្រគល់ប្រាក់ដើម ②ការកន្លងផុតនៃអំឡុងពេលជាក់លាក់ (ការកន្លងផុតនៃពេលកំណត់ដែលត្រូវសង រហូតដល់ ការកន្លងផុតនៃអំឡុងពេលជាក់លាក់) គឺជាការគ្រប់គ្រាន់។ ក្នុងករណីដែលអត្រាការប្រាក់ក្នុងកិច្ចសន្យា ខ្ពស់ជាងអត្រាការប្រាក់ដែលច្បាប់បានកំណត់ ហើយធ្វើការទាមទារប្រាក់សំណងការខូចខាតចំពោះការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ច ដោយផ្អែកតាមអត្រាការប្រាក់ក្នុងកិច្ចសន្យា ត្រូវបន្ថែមនូវ ③ ការព្រមព្រៀងអំពីអត្រាការប្រាក់ ④ ការព្រមព្រៀងនៃចំណុច ③ ត្រូវបានធ្វើឡើងជាលាយលក្ខណ៍អក្សរដោយមានចុះហត្ថលេខារបស់អ្នកខ្ចី។ យ៉ាងណាមិញ ចំពោះ ចំណុច ③ គឺជាចំណុចដែលកើតមានឡើងតាមគោលគំនិតនៃកថាខណ្ឌទី ៣ មាត្រា ៥៨៤ នៃក្រមរដ្ឋប្បវេណី។

ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០០៨ ដែលជាថ្ងៃកំណត់សងបានកន្លងផុត[13]។

**ខ.១.២.** ទឹកប្រាក់ដែលទាមទារចំនួន ១៣.៥០០ (មួយម៉ឺនបីពាន់ប្រាំរយ) ដុល្លារអាមេរិកនេះបានមកពីៈ

ប្រាក់ដើម ៖ ១០.០០០ (មួយម៉ឺន) ដុល្លារអាមេរិក

ការប្រាក់ ៖ ៥០០ (ប្រាំរយ) ដុល្លារអាមេរិក (អត្រាការប្រាក់ ៥ % ក្នុង១ឆ្នាំ គិតចាប់ពីថ្ងៃទី ១ ខែ វិច្ឆិកា ឆ្នាំ ២០០៧ រហូតដល់ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០០៨)

ប្រាក់សំណងការខូចខាតចំពោះការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ច ៖ ៤.០០០ (បួនពាន់) ដុល្លារអាមេរិក (ប្រាក់សំណងការខូចខាតចំពោះការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ច១០% ក្នុង១ឆ្នាំ គិតចាប់ពីថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ដល់ថ្ងៃទី ៣១ ខែតុលា ឆ្នាំ ២០១២)

ប្រាក់សងមួយភាគ ៖ ចំពោះប្រាក់ចំនួន ១.០០០ (មួយពាន់) ដុល្លារអាមេរិកដែលបានទទួលនៅថ្ងៃទី ៣១ ខែតុលា ឆ្នាំ ២០១២ (**ភស្តុតាង**$X_3$) ជាដំបូងត្រូវយកមកកាត់នឹងការប្រាក់ចំនួន ៥០០ (ប្រាំរយ) ដុល្លារអាមេរិក ហើយទឹកប្រាក់ដែលនៅសល់ត្រូវយកមកកាត់នឹងប្រាក់សំណងការខូចខាតចំពោះការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ចចំនួន ៤.០០០ (បួនពាន់) ដុល្លារអាមេរិកដែលបានកើត

[13] ចំពោះការទាមទារប្រាក់ដើម និង ការប្រាក់ បើថ្ងៃទី៣១ ខែតុលា ឆ្នាំ ២០០៨ ដែលជាពេលកំណត់ដែលត្រូវសងបានមកដល់គឺអាចទាមទារបាន ប៉ុន្តែ ដោយសារតែនៅក្នុងរឿងក្តីនេះ មានការទាមទាររួមបញ្ចូលទាំងប្រាក់សំណងការខូចខាតចំពោះការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ច ផងដែរ ដូច្នេះ ចាំបាច់ត្រូវអះអាងអំពី ការកន្លងផុតនៃថ្ងៃទី ៣១ ខែតុលា ឆ្នាំ ២០០៨។ ម្យ៉ាងវិញទៀត ពាក្យថា "មកដល់" គឺសំដៅទៅលើពេលវេលាដែលហួសពីម៉ោង 0 ពេលព្រឹកនៃថ្ងៃកំណត់នោះ ប៉ុន្តែ ពាក្យថា "កន្លងផុត" គឺសំដៅទៅលើ ការបញ្ចប់នៃថ្ងៃដែលបានកំណត់នោះដូច្នេះហើយ គឺខុសគ្នាប្រហែលជា ១ថ្ងៃ ( តាមន័យចង្អៀត គឺ សំដៅទៅលើ ២៣ ម៉ោង ៥៩នាទី និង ៥៩ វិនាទី....)។

ឡើងនៅពេលនោះ។[14] [15]

នាំឲ្យចំនួនទឹកប្រាក់នៃការទាមទារមានដូចខាងក្រោមនេះ ៖

**៥០០ + ៤.០០០ - ១.០០០ = ៣.៥០០ (ចំនួនទឹកប្រាក់ដែលនៅសល់នៃប្រាក់សំណងការខូចខាតចំពោះការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ច ក្រោយពីការកាត់បំណុលផ្អែកតាមការសងមួយភាគ)**

**១០.០០០ (ប្រាក់ដើម) + ៣.៥០០ = ១៣.៥០០**

## ខ.២. ការទាមទារនូវប្រាក់សំណងការខូចខាតចំពោះការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ច គិតចាប់ពីថ្ងៃទី០១ ខែ វិច្ឆិកា ឆ្នាំ ២០១២ រហូតថ្ងៃសងគ្រប់

ចុងចម្លើយមានកាតព្វកិច្ចត្រូវបង់ប្រាក់សំណងការខូចខាតចំពោះការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ចឲ្យទៅដើមចោទចំនួន ១០% ក្នុង១ឆ្នាំ ចំពោះប្រាក់កម្ចីចំនួន ១០.០០០ (មួយម៉ឺន) ដុល្លារអាមេរិកខាងលើនេះ គិតចាប់ពីថ្ងៃទី ១ ខែវិច្ឆិកា ឆ្នាំ ២០១២ រហូតដល់ថ្ងៃសងរួច។

**ហេតុនេះ ដើមចោទទាមទារឲ្យចុងចម្លើយបង់ ① ប្រាក់ដើមចំនួន ១០.០០០ (មួយម៉ឺន) ដុល្លារអាមេរិក និង ②ចំនួនទឹកប្រាក់ដែលនៅសល់នៃប្រាក់សំណងការខូចខាតចំពោះការ**

---

[14] លំដាប់នៃការកាត់បំណុល (មាត្រា ៤៥១ នៃក្រមរដ្ឋប្បវេណី) កំណត់ឲ្យកាត់នឹង សោហ៊ុយ ការប្រាក់ (ការប្រាក់ និង ប្រាក់សំណងការខូចខាតចំពោះការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ច) និងប្រាក់ដើម ហេតុនេះ ចំពោះប្រាក់ចំនួន ១.០០០ (មួយពាន់) ដុល្លារអាមេរិក ជាដំបូង គឺត្រូវយកមកកាត់ជាមួយនឹងការប្រាក់ (៥០០ដុល្លារអាមេរិក) ហើយប្រាក់ដែលនៅសល់នឹងត្រូវបានយកមកកាត់ជាមួយនឹងប្រាក់សំណងការខូចខាតចំពោះការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ចមួយផ្នែកនៃចំនួន ៤.០០០ដុល្លារអាមេរិកដែលបានកើតឡើងនៅពេលសង។

[15] នៅក្នុងរឿងក្តីនេះ គឺបានអនុវត្តលំដាប់នៃការកាត់បំណុតតាមច្បាប់កំណត់ផ្អែកតាមមាត្រា ៤៥១ នៃក្រមរដ្ឋប្បវេណី ប៉ុន្តែ នៅពេលដែលម្ចាស់បំណុលគណនាចំនួនទឹកប្រាក់នៃការទាមទារ គឺពុំមានភាពចាំបាច់ត្រូវធ្វើការកាត់បំណុលតាមច្បាប់កំណត់ជាដាច់ខាតនោះឡើយ។ ផ្អែកតាមមាត្រា ៤៤៩ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណីក៏អាចធ្វើការកាត់បំណុលដោយការជ្រើសរើសបានដែរ។ ក្នុងករណីដែលការសងមួយផ្នែកត្រូវបានធ្វើឡើងច្រើនលើក ហើយពេលវេលានោះក៏មានផ្សេងៗគ្នាទៀត នឹងធ្វើឲ្យការគណនាប្រាក់សំណងការខូចខាតចំពោះការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ចជាអាទិ៍ដែលបានកើតឡើងកន្លងមកមានភាពស្មុគស្មាញ ដូច្នេះហើយ ក៏អាចយកចំនួនទឹកប្រាក់នៃការសងមួយផ្នែកមកកាត់នឹងប្រាក់ដើមទាំងអស់ក៏បានដែរ។ ចំពោះកូនបំណុលវិញការកាត់ជាមួយនឹងប្រាក់ដើមជាមុននឹងធ្វើឲ្យការប្រាក់ និង ប្រាក់សំណងការខូចខាតចំពោះការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ចដែលកើតឡើងនឹងមានភាពថយចុះ ហើយក៏ជាប្រយោជន៍ផងដែរ ដូច្នេះ ពុំមានបញ្ហាទេ។

**យឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ចចំនួន ៣.៥០០ (បីពាន់ប្រាំរយ) ដុល្លារអាមេរិក គិតត្រឹមថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១២ និង ព្រមទាំងប្រាក់សំណងការខូចខាតចំពោះការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ចចំនួន ១០ % ក្នុង ១ ឆ្នាំ លើប្រាក់ដើមចំនួន ១០.០០០ (មួយម៉ឺន) ដុល្លារអាមេរិកគិតចាប់ពីថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ២០១២ រហូតដល់ថ្ងៃដែលសងរួចដោយផ្អែកតាមកិច្ចសន្យានេះ។**[16]

## គ. ប្រាក់ប្រដាប់ក្តី

ប្រាក់ប្រដាប់ក្តីនៃរឿងក្តីនេះគប្បីជាបន្ទុករបស់ចុងចម្លើយ (កថាខណ្ឌទី ១ មាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

## ឃ. ការប្រកាសឲ្យអនុវត្តជាបណ្តោះអាសន្ន

រឿងក្តីនេះគឺជារឿងក្តីដែលទាមទារឲ្យសងប្រាក់កម្ចី ហើយមានភស្តុតាងគ្រប់គ្រាន់ក្នុងការទទួលស្គាល់នូវការអះអាងរបស់ដើមចោទ។ ដើមចោទស្នើសុំនូវការប្រកាសឲ្យអនុវត្តជាបណ្តោះអាសន្ន (មាត្រា ១៩៦ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

## ង. ភស្តុតាង

**១.** លិខិតកិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០០៧ **(ភស្តុតាង$X_1$)**

**២.** លិខិតប្រគល់ទទួលប្រាក់ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ២០០៧ **(ភស្តុតាង$X_2$)**

**៣.** លិខិតទទួលប្រាក់សងមួយផ្នែកចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ ២០១២ **(ភស្តុតាង$X_3$)**

[16] ត្រូវបញ្ជាក់ឲ្យបានច្បាស់នូវលក្ខណៈគតិយុត្តនៃប្រាក់ដែលទាមទារ (កម្មវត្ថុនៃបណ្តឹង)។

សេចក្តីដូចមានកំណត់ សូម **លោកប្រធាន** សម្រេចតាមការស្នើសុំដោយក្តីអនុគ្រោះ។ សូម **លោកប្រធាន** ទទួលនូវសេចក្តីគោរពដ៏ជ្រាលជ្រៅអំពីខ្ញុំ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០១៤

**អ្នកតំណាងដោយអាណត្តិ**

P

<u>ឯកសារភ្ជាប់</u>

១-លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ "ច្បាប់ដើម"
២-ច្បាប់ថតចម្លងនៃភស្តុតាងនីមួយៗខាងលើ "ចំនួន ០២ ច្បាប់"

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# ឯកសារចម្លើយ[1]

## ដើមចោទ

ឈ្មោះ ៖ X

អាសយដ្ឋាន៖ ផ្ទះលេខ 00 ផ្លូវលេខ 00 សង្កាត់ទំនប់ទឹក ខណ្ឌចំការមន រាជធានីភ្នំពេញ។

## ចុងចម្លើយ

ឈ្មោះ ៖ Y

អាសយដ្ឋាន ៖ ផ្ទះលេខ 00 ផ្លូវលេខ 00 សង្កាត់មនោរម្យ ខណ្ឌ៧មករា រាជធានីភ្នំពេញ។

## អ្នកតំណាងដោយអាណត្តិ

លោក/ លោកស្រី ៖ B

អាសយដ្ឋានការិយាល័យមេធាវី / ក្រុមមេធាវី / ក្រុមហ៊ុនមេធាវី ៖..............................

ការិយាល័យមេធាវី / ក្រុមមេធាវី / ក្រុមហ៊ុនមេធាវី ៖..............................................

លេខទូរស័ព្ទ ៖....................................................

**ទីកន្លែងបញ្ជូន** ៖ ការិយាល័យមេធាវី/ ក្រុមមេធាវី/ ក្រុមហ៊ុនមេធាវី.................[2]

---

[1] ឯកសារត្រៀមដែលចុងចម្លើយដាក់ទៅតុលាការជាលើកដំបូង ហៅថា "ឯកសារចម្លើយ"។ នៅក្នុងឯកសារនេះនឹងត្រូវសរសេរអំពី ① ការឆ្លើយតបចំពោះខ្លឹមសារនៃសាលក្រមដែលដើមចោទបានសរសេរនៅក្នុងពាក្យបណ្តឹង ② ការទទួលស្គាល់ ឬ មិនទទួលស្គាល់នូវអង្គហេតុដែលមានសរសេរនៅក្នុងពាក្យបណ្តឹង និង ③ អង្គហេតុដើម្បីតវ៉ាចំពោះអង្គហេតុដែលមានសរសេរនៅក្នុងពាក្យបណ្តឹង (កថាខណ្ឌទី៣ មាត្រា ១០១នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

[2] មាត្រា ២៤៩ និង មាត្រា ២៥០ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ ការសរសេរអំពីកន្លែងបញ្ជូន មិនមែនជាកាតព្វកិច្ចទេ។ ប្រសិនបើមិនបានសរសេរអំពីទីកន្លែងបញ្ជូន ការបញ្ជូននឹងត្រូវធ្វើឡើងនៅលំនៅដ្ឋានរបស់ចុងចម្លើយជាអាទិ៍។ ដូច្នេះ ក្នុងករណីដែលអ្នកតំណាងដោយអាណត្តិរបស់ចុងចម្លើយចង់ធ្វើការបញ្ជូនទៅទីកន្លែងណាផ្សេងក្រៅពីលំនៅដ្ឋានរបស់ចុងចម្លើយជាអាទិ៍ ចាំបាច់ត្រូវសរសេរអំពីកន្លែងបញ្ជូនចូលទៅក្នុងលិខិតលាយលក្ខណ៍អក្សរ ដូចជា ឯកសារចម្លើយជាអាទិ៍។

**សូមគោរពជូន**

**លោក ឬ ចៅក្រមនៃសាលាដំបូងរាជធានីភ្នំពេញ**

**<u>កម្មវត្ថុ</u>៖** សុំដាក់**ឯកសារចម្លើយដើម្បីឆ្លើយតប**នឹងពាក្យបណ្តឹងចុះថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០១៤ របស់ឈ្មោះ X

**<u>យោង</u>៖**-មាត្រា **១០១ កថាខណ្ឌទី ៣** នៃក្រមនីតិវិធីរដ្ឋប្បវេណី

-សំណុំរឿងរដ្ឋប្បវេណីលេខ........ ចុះថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០១៤

## ក. ការឆ្លើយតបចំពោះខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារ

(១) ច្រានចោលការទាមទារទាំងអស់របស់ដើមចោទ។

(២) ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ។

## ខ. ការទទួលស្គាល់ ឬ មិនទទួលស្គាល់អង្គហេតុដែលមានសរសេរនៅក្នុងពាក្យបណ្តឹង

**ខ.១.** ស្តីពីអង្គហេតុ "**ខ.១.១**" ដែលត្រូវបានសរសេរនៅក្នុងពាក្យបណ្តឹង ៖ ចុងចម្លើយទទួលស្គាល់ទាំងស្រុង ។

**ខ.២.** ស្តីពីអង្គហេតុសងប្រាក់មួយភាគ "**ខ.១.២**" ដែលត្រូវបានសរសេរនៅក្នុងពាក្យបណ្តឹង៖ ចុងចម្លើយទទួលស្គាល់នូវការប្រគល់ប្រាក់ឲ្យទៅដើមចោទចំនួន ១.០០០ (មួយពាន់) ដុល្លារមេរិកនៅថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១២ ចំពោះអង្គហេតុក្រៅពីនេះ ចុងចម្លើយមិនទទួលស្គាល់ទេ។

នៅថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១២ ចុងចម្លើយបានប្រគល់ប្រាក់ចំនួន ១.០០០ (មួយពាន់) ដុល្លារអាមេរិកឲ្យទៅដើមចោទ ប៉ុន្តែ ប្រាក់នេះ គឺជាការសងបំណុលផ្សេង ហើយមិនមែនជាការសងទៅលើសិទ្ធិលើបំណុលជាប្រាក់ដែលដើមចោទកំពុងទាមទារនៅក្នុងរឿងក្តីនេះទេ។ ពោលគឺ នៅថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០១២ ចុងចម្លើយបានលក់នំធ្វើពីផ្លែឈើចំនួន ១០.០០០ កញ្ចប់ដែលសរុបទឹកប្រាក់ចំនួន ១០.០០០ (មួយម៉ឺន) ដុល្លារអាមេរិកឲ្យទៅដើមចោទ ហើយដោយសារតែដើមចោទបាននិយាយថា នៅក្នុងចំណោមនំ

ទាំងនោះ មាននំចំនួន ៥០០កញ្ចប់ដែលខូច ហើយមិនអាចយកមកលក់បានទេ ហេតុដូច្នេះហើយ នៅថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១២ ចុងចម្លើយបានបង់ប្រាក់ ១.០០០ (មួយពាន់) ដុល្លារអាមេរិកឲ្យទៅដើមចោទជាថ្លៃសងការខូចខាតចំពោះទំនិញទាំងនោះ។[3]

**ខ.៣.** ស្តីពីអង្គហេតុ "**ខ.២**" ដែលសរសេរនៅក្នុងពាក្យបណ្តឹង ៖ ចុងចម្លើយមានវិវាទ។

ដូចដែលបានលើកឡើងនៅខាងលើ នៅក្នុងរឿងក្តីនេះ ដោយសារតែអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលបានសម្រេចឡើង ដូច្នេះ ចុងចម្លើយមិនមានករណីយកិច្ចបង់ប្រាក់សំណងការខូចខាតចំពោះការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ចទេ ។

## គ. អង្គហេតុតវ៉ា

### គ.១. អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល

ចុងចម្លើយបានលើកឡើងអំពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល[4]។

ពោលគឺ បើគិតចាប់ពីថ្ងៃទី ៣១ ខែ តុលា ឆ្នាំ២០០៨ ដែលជាពេលកំណត់ត្រូវសងនៃប្រាក់កម្ចីក្នុងរឿងក្តីនេះមក នាំឲ្យថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៣ ដែលជាអំឡុងពេលនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលបានកន្លងផុត។ ចុងចម្លើយលើកឡើងអំពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលខាងលើតាមរយៈឯកសារចម្លើយ។

---

[3] ដូចដើមចោទបានអះអាងនៅក្នុងពាក្យបណ្តឹង ប្រសិនបើចុងចម្លើយទទួលស្គាល់ថា ដើមចោទបានទទួលការសងមួយផ្នែកនៃប្រាក់កម្ចីពីចុងចម្លើយ អង្គហេតុនោះ នឹងត្រូវក្លាយជាមូលហេតុនៃការផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល (ក្រមរដ្ឋប្បវេណី មាត្រា ៤៨៩ កថាខណ្ឌទី ៣) ។ ហេតុនេះ ដើម្បីឲ្យគេទទួលស្គាល់នូវការតវ៉ាអំពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល ក្នុងនាមជាចុងចម្លើយ ចាំបាច់ត្រូវតែពន្យល់ឲ្យបានលម្អិតថា ប្រាក់ដែលសង គឺមិនមែនជាការសងមួយផ្នែកនៃប្រាក់កម្ចីទេ។

[4] អង្គហេតុចម្បងស្តីអំពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលមាន ① ពេលដែលអាចអនុវត្តសិទ្ធិលើបំណុលបាន (ក្រមរដ្ឋប្បវេណី មាត្រា ៤៨១) ② អំឡុងពេលនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលគិតចាប់ពីពេលនោះបានកន្លងផុត (ក្រមរដ្ឋប្បវេណី មាត្រា ៤៨២) និង ③ ការលើកឡើងនូវអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល (ក្រមរដ្ឋប្បវេណី មាត្រា ៤៨៦ កថាខណ្ឌទី១)។ នៅក្នុងរឿងក្តីនេះ ចំពោះចំណុច ① គូភាគីមិនមានវិវាទទេ ហើយដោយសារតែចំណុច ② និង ③ គឺជាអង្គហេតុដែលមានលក្ខណៈជាក់ស្តែងចំពោះតុលាការ (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ១២៣ កថាខណ្ឌទី២) ហេតុនេះ ចុងចម្លើយមិនចាំបាច់បញ្ជាក់ភស្តុតាងស្តីពី អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលទេ។

**គ.២. ការទូទាត់**[5] [6]

នៅថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៣ ចុងចម្លើយបានលក់រថយន្តក្នុងតម្លៃ ៧.០០០ (ប្រាំពីរពាន់) ដុល្លារអាមេរិក **(ភស្តុតាង $Y_1$)** និង បានប្រគល់រថយន្ត **(ភស្តុតាង $Y_2$)** ទៅឱ្យដើមចោទចំពោះថ្លៃលក់រថយន្តចំនួន ៧.០០០ (ប្រាំពីរពាន់) ដុល្លារអាមេរិកនោះ ចុងចម្លើយបានដាស់តឿនឲ្យបង់ជាច្រើនលើកច្រើនសារ ប៉ុន្តែ ដើមចោទមិនបានបង់ទេ។

ក្នុងករណីតុលាការមិនទទួលស្គាល់អំពីការតវ៉ាស្តីពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលទេ ចុងចម្លើយបង្ហាញឆន្ទៈទូទាត់នូវទឹកប្រាក់ចំនួន ៧.០០០ (ប្រាំពីរពាន់) ដុល្លារអាមេរិកនៃសិទ្ធិលើបំណុលនៃប្រាក់ថ្លៃលក់ទិញខាងលើនេះជាមួយនឹងកាតព្វកិច្ចប្រាក់កម្ចីក្នុងចំនួនសមស្រប។

**ដូច្នេះ ចុងចម្លើយមិនមានករណីកិច្ចបង់ប្រាក់ដើម និង ប្រាក់សំណងការខូចខាតចំពោះការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ចដោយផ្អែកលើកិច្ចសន្យានៃរឿងក្តីនេះឲ្យដើមចោទទេ។**

---

[5] ការអះអាងនូវការតវ៉ាអំពីការទូទាត់ ចាំបាច់ត្រូវតែធ្វើការប្រុងប្រយ័ត្ន ដោយសារតែ គេព្រួយបារម្ភថា ការអះអាងនូវការតវ៉ា អំពីការទូទាត់នឹងនាំឲ្យមានការទទួលស្គាល់ អំពីការផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល (ក្រមរដ្ឋប្បវេណី មាត្រា ៤៨៩ កថាខណ្ឌទី ៣) ទៅជាមួយគ្នា។ ប៉ុន្តែ ការតវ៉ាអំពីការទូទាត់នឹងនាំឲ្យកើតមានអានុភាពនៃអាជ្ញាអស់ជំនុំលើការវិនិច្ឆ័យនោះ (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ១៩៤ កថាខណ្ឌទី ៤) ព្រមទាំងធ្វើឲ្យចុងចម្លើយខាតបង់ប្រយោជន៍ ជាងនៅពេលដែលតុលាការទទួលស្គាល់អំពីការតវ៉ាផ្សេងទៀត ដូច្នេះ ជាគោលការណ៍តុលាការគប្បីសម្រេចនូវការតវ៉ាអំពីការទូទាត់នៅក្រោយពេលមិនទទួលស្គាល់ទៅលើការតវ៉ាទាំងអស់ផ្សេងទៀត។ ដូច្នេះហើយ ទោះបីជាធ្វើការអះអាងអំពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល និង អះអាងនូវការតវ៉ាអំពីការទូទាត់ក្នុងពេលជាមួយគ្នាក៏ដោយ ក៏គ្មានបញ្ហាដែរ។ ជាក់ស្តែង នៅក្នុងរឿងក្តីនេះ ក្នុងករណីដែលការតវ៉ាអំពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល ត្រូវតុលាការមិនទទួលស្គាល់ នាំឲ្យតុលាការនឹងត្រូវវិនិច្ឆ័យអំពីការតវ៉ា អំពីការទូទាត់។

[6] អង្គហេតុចម្បងនៃការទូទាត់ គឺ ① អត្ថិភាពនៃសិទ្ធិលើបំណុលដែលផ្តើមការទូទាត់ (ក្រមរដ្ឋប្បវេណី មាត្រា ៤៦៤ កថាខណ្ឌទី ១ ) ② ការបង្ហាញឆន្ទៈអំពីការទូទាត់ (ក្រមរដ្ឋប្បវេណី មាត្រា ៤៦៥ កថាខណ្ឌទី ១) ③ សិទ្ធិតវ៉ារបស់ភាគីម្ខាងទៀតទៅលើសិទ្ធិលើបំណុលដែលផ្តើមការទូទាត់ មិនទាន់បានភ្ជាប់ (ក្រមរដ្ឋប្បវេណី មាត្រា ៤៦៨ កថាខណ្ឌ ទី១) ។ អង្គហេតុចម្បងនៃកិច្ចសន្យាលក់ទិញ ខណៈពេលដែលមានការអះអាងអំពីសិទ្ធិលើបំណុលនៃប្រាក់ថ្លៃលក់ទិញធ្វើជាសិទ្ធិលើបំណុលដែលផ្តើមការទូទាត់នៅក្នុងរឿងក្តីនេះ គឺ ការព្រមព្រៀងអំពីកម្មវត្ថុ និង ប្រាក់ថ្លៃលក់ទិញ (ក្រមរដ្ឋប្បវេណី មាត្រា ៥១៥ និង មាត្រា ៥១៦) ។ ម្យ៉ាងវិញទៀត ដោយសារតែមានការភ្ជាប់នូវសិទ្ធិតវ៉ាឲ្យអនុវត្តព្រមគ្នារបស់អ្នកទិញ (មាត្រា ៥៥៨ កថាខណ្ឌទី ១) ចំពោះសិទ្ធិលើបំណុលនៃប្រាក់ថ្លៃលក់ទិញ ខណៈពេលដែលចុងចម្លើយជាអ្នកលក់បានលើកឡើងអំពីការតវ៉ា ហេតុនេះ តាមភាពជាក់ស្តែង គឺមានភាពចាំបាច់ក្នុងការអះអាងអំពី ការបានប្រគល់រថយន្ត ។

**ឃ. ភស្តុតាង**

**១.**លិខិតកិច្ចសន្យាទិញលក់រថយន្ត ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៣ **(ភស្តុតាង$Y_1$)**

**២.**លិខិតប្រគល់ទទួលរថយន្ត ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៣ **(ភស្តុតាង$Y_2$)**

សូម **លោកចៅក្រម** សម្រេចតាមការអះអាងខាងលើ ដោយក្តីអនុគ្រោះ។

រាជធានីភ្នំពេញ, ថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០១៤

**អ្នកតំណាងដោយអាណត្តិ**

B

ឯកសារភ្ជាប់

១-លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ "ច្បាប់ដើម"

២-ច្បាប់ថតចម្លងនៃភស្តុតាងនីមួយៗខាងលើ "ចំនួន ០២ ច្បាប់"

៣-ឯកសារចម្លងនៃឯកសារចម្លើយ "ចំនួន ០២ ច្បាប់"

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# ឯកសារត្រៀមលើកទី១របស់ដើមចោទ

## ដើមចោទ

ឈ្មោះ ៖ X

អាសយដ្ឋាន ៖ ផ្ទះលេខ 00 ផ្លូវលេខ 00 សង្កាត់ទំនប់ទឹក ខណ្ឌចំការមន រាជធានីភ្នំពេញ។

## អ្នកតំណាងដោយអាណត្តិ

លោក/លោកស្រី ៖ P

អាសយដ្ឋានការិយាល័យមេធាវី / ក្រុមមេធាវី / ក្រុមហ៊ុនមេធាវី ៖ ...................

ការិយាល័យមេធាវី / ក្រុមមេធាវី / ក្រុមហ៊ុនមេធាវី ៖ ................................................

លេខទូរស័ព្ទ ៖ ...........................................................................................

**ទីកន្លែងបញ្ជូន** ៖ ការិយាល័យមេធាវី/ ក្រុមមេធាវី/ ក្រុមហ៊ុនមេធាវី.................

## ចុងចម្លើយ

ឈ្មោះ ៖ Y

អាសយដ្ឋាន ៖ ផ្ទះលេខ 00 ផ្លូវលេខ 00 សង្កាត់មនោរម្យ ខណ្ឌ ៧មករា រាជធានីភ្នំពេញ។

**សូមគោរពជូន**
**លោក J ចៅក្រមនៃសាលាដំបូងរាជធានីភ្នំពេញ**

**<u>កម្មវត្ថុ</u> ៖** សំណើសុំដាក់ **ឯកសារត្រៀមលើកទី១ របស់ដើមចោទ**ដើម្បីឆ្លើយតប ចំពោះឯកសារចម្លើយរបស់ឈ្មោះ Y ចុះថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០១៤ ។

**<u>យោង</u> ៖** -មាត្រា **១០១ កថាខណ្ឌទី ២**នៃក្រមនីតិវិធីរដ្ឋប្បវេណី

-សំណុំរឿងរដ្ឋប្បវេណីលេខ........ ចុះថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០១៤

## ក. ការទទួលស្គាល់ ឬ មិនទទួលស្គាល់ចំពោះអង្គហេតុដែលមានសរសេរនៅក្នុងឯកសារចម្លើយ[1]

**ក.១.** អង្គហេតុដែលមានសរសេរនៅក្នុងចំណុច "**ខ.២.**" នៃឯកសារចម្លើយ ៖ ដើមចោទទទួលស្គាល់ថា បានទិញនំផ្លែឈើ ចំនួន ១០.០០០ កញ្ចប់ ក្នុងតម្លៃ ១០.០០០ (មួយម៉ឺន) ដុល្លារអាមេរិកពីចុងចម្លើយនៅថ្ងៃទី ៣០ ខែកញ្ញា ឆ្នាំ ២០១២ ហើយនៅក្នុងចំណោមនំចំនួន ១០.០០០ កញ្ចប់នោះមាន ៥០០ កញ្ចប់ដែលខូច ហើយដើមចោទមិនទទួលស្គាល់ចំពោះអង្គហេតុក្រៅពីនេះ។

ចំពោះនំ ៥០០កញ្ចប់ដែលលើកឡើងខាងលើនេះ មិនមែនថា មិនអាចលក់ចេញបាននោះទេ ហើយតាមការពិតដើមចោទបានលក់អស់ហើយ ហេតុនេះ ដើមចោទគ្រាន់តែព្រមានមិនឲ្យដាក់របស់បែបនេះទៀតពេលក្រោយ ហើយមិនបានទាមទារសំណងពីចុងចម្លើយទេ។ ដើមចោទមិនបានទទួលការសងប្រាក់ទាក់ទងនឹងរឿងនំផ្លែឈើនេះពីចុងចម្លើយនោះទេ។

**ក.២.** ការអះអាងអំពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលដែលមានសរសេរនៅក្នុងចំណុច "**គ.១**" នៃឯកសារចម្លើយ ៖ ដើមចោទមានវិវាទ [2]។

**ក.៣.** ការអះអាងអំពីការទូទាត់ដែលមានសរសេរនៅក្នុងចំណុច "**គ.២**" នៃ ឯកសារចម្លើយ ៖ ដើមចោទទទួលស្គាល់ថា ចុងចម្លើយបានលក់រថយន្តក្នុងតម្លៃ ៧.០០០ (ប្រាំពីរពាន់) ដុល្លារអាមេរិក មកឲ្យដើមចោទនៅថ្ងៃទី ៣១ ខែ

[1] ចំណុចដែលត្រូវសរសេរនៅក្នុងឯកសារត្រៀម៖ ① មធ្យោបាយតទល់ ឬ ការពារខ្លួន និង ② សេចក្តីថ្លែងការណ៍ចំពោះមធ្យោបាយតទល់ ឬ ការពារខ្លួនរបស់ភាគីម្ខាងទៀត (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ១០១ កថាខណ្ឌទី ២)។

[2] អង្គហេតុចម្បងស្តីអំពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលគឺ ① ពេលដែលសិទ្ធិលើបំណុលអាចអនុវត្តបាន (ក្រមរដ្ឋប្បវេណី មាត្រា ៤៨១) ② អំឡុងពេលនៃអាជ្ញាយុកាលបានកន្លងផុតគិតចាប់ពីពេលនោះ (ក្រមរដ្ឋប្បវេណី មាត្រា៤៨២) ③ ការលើកឡើងនូវអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល (ក្រមរដ្ឋប្បវេណី មាត្រា ៤៨៦ កថាខណ្ឌទី ១) ។ នៅក្នុងរឿងក្តីនេះ ចំពោះចំណុចទាំងនេះ ចំណុចទី ① គូភាគីពុំមានវិវាទទេ រីឯចំណុចទី ② និងចំណុចទី ③ គឺជាអង្គហេតុដែលមានភាពជាក់ស្តែងចំពោះតុលាការ (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ១២៣ កថាខណ្ឌទី ២ ) ដូច្នេះហើយ ចុងចម្លើយមិនចាំបាច់បញ្ជាក់ភស្តុតាងទៅលើ អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលទេ។ ហេតុនេះ ដើមចោទ ក៏មិនចាំបាច់ទទួលស្គាល់ ឬ មិនទទួលស្គាល់ដែរ ប៉ុន្តែ ដើមចោទបានគិតថាចង់បដិសេធនូវ ការសម្រេចបាននូវអាជ្ញាយុកាលដែលជា អានុភាពគតិយុត្ត។ ក្នុងករណីបែបនេះ គួរតែសរសេរថា "មានវិវាទ" ទើបប្រសើរ។

តុលា ឆ្នាំ ២០១៣ ហើយចុងចម្លើយបានប្រគល់រថយន្តនោះមកឲ្យដើមចោទនៅថ្ងៃដដែល ហើយដើមចោទមិនទទួលស្គាល់អង្គហេតុផ្សេងក្រៅពីនេះ ។

ដើមចោទបានបង់ប្រាក់ថ្លៃទិញរថយន្តឲ្យទៅចុងចម្លើយដូចក្នុងចំណុច "ខ.២." នៃដែលបានសរសេរខាងក្រោម ។

## ខ. អង្គហេតុស្ដីពីការតវ៉ាតប

### ខ.១. ការផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល [3] (ចំពោះការតវ៉ាអំពីការផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល [4])

នៅថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០១២ ដើមចោទបានទទួលប្រាក់ចំនួន ១.០០០ (មួយពាន់) ដុល្លារអាមេរិកដែលជាការសងប្រាក់កម្ចីក្នុងរឿងក្ដីនេះពីចុងចម្លើយ។ នៅក្នុងលិខិតប្រគល់ ទទួលប្រាក់ដែលដើមចោទបានសរសេរ និងចេញឲ្យចុងចម្លើយ បានសរសេរអំពីខ្លឹមសារថា បានទទួលប្រាក់ចំនួន ១.០០០ (មួយពាន់) ដុល្លារអាមេរិក ជាការសងប្រាក់កម្ចីនៃរឿងក្ដីនេះ **(ភស្តុតាង $X_3$)**។

ដោយសារតែចុងចម្លើយបានសងប្រាក់មួយផ្នែកនៃប្រាក់កម្ចីក្នុងរឿងក្ដីនេះ ដូច្នេះ នាំឲ្យអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលបានផ្អាក។

### ខ.២. ការសង [5] (ចំពោះការតវ៉ាអំពីការទូទាត់)

ដើមចោទបានបង់ប្រាក់ចំនួន ចំនួន ៧.០០០ (ប្រាំពីរពាន់) ដុល្លារអាមេរិកជាថ្លៃលក់ទិញរថយន្តឲ្យទៅចុងចម្លើយនៅអំឡុងខែធ្នូ ឆ្នាំ២០១៣។

---

[3] ដើមចោទអាចអះអាងអំពីការសងមួយផ្នែក ធ្វើជាមូលហេតុនៃការផ្អាកអាជ្ញាយុកាលតាមផ្លូវច្បាប់បាន (ក្រមរដ្ឋប្បវេណី មាត្រា ៤៨៩ កថាខណ្ឌទី ៣)។

[4] នៅពេលអះអាងអំពីការតវ៉ាតប យើងត្រូវបង្ហាញឲ្យច្បាស់ថាជាការតវ៉ាតបចំពោះការតវ៉ាមួយណា។

[5] អង្គហេតុចម្បងនៃការសងមាន ① មានការផ្ដល់តាវកាលិកផ្អែកតាមខ្លឹមសារនៃកាតព្វកិច្ចពីកូនបំណុលទៅម្ចាស់បំណុល (សូមយោងមាត្រា៤៩០ នៃក្រមរដ្ឋប្បវេណី) និង ② ទំនាក់ទំនងនៃតាវកាលិកជាមួយសិទ្ធិលើបំណុល។ ជាក់ស្ដែងត្រូវបង្ហាញថា ៖ ① គឺ "បានប្រគល់ប្រាក់ចំនួន ៧.០០០ (ប្រាំពីរពាន់) ដុល្លារអាមេរិក និង ② តើប្រាក់ចំនួន ៧.០០០ (ប្រាំពីរពាន់) ដុល្លារអាមេរិកនេះ ត្រូវបានប្រគល់ដើម្បីអ្វី? គឺចាំបាច់ត្រូវសរសេរថា "ជាថ្លៃលក់ទិញរថយន្ត" ។

សូម **លោកចៅក្រម** សម្រេចតាមការអះអាងខាងលើ ដោយក្តីអនុគ្រោះ។

រាជធានីភ្នំពេញ, ថ្ងៃទី ២ ខែ មករា ឆ្នាំ ២០១៥

**អ្នកតំណាងដោយអាណត្តិ**

P

"**ចំណុចដែលត្រូវប្រុងប្រយ័ត្ន**"

នៅក្នុងឯកសារត្រៀមលើកទី១ របស់ដើមចោទ ដើមចោទបានអះអាងនូវការតវ៉ាតបចំពោះការតវ៉ាដែលចុងចម្លើយបានអះអាងនៅក្នុងឯកសារចម្លើយ។ ហេតុនេះ ច្បាស់ជាត្រូវដាក់ឯកសារត្រៀមដើម្បីឲ្យចុងចម្លើយធ្វើការទទួលស្គាល់ ឬ មិនទទួលស្គាល់ ឬ ការធ្វើការតវ៉ា (ឯកសារត្រៀមលើកទី ១ របស់ចុងម្លើយ) ជាក់ជាមិនខាន (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ១០១ កថាខណ្ឌទី ២) ។ ប៉ុន្តែ តាមរយៈឯកសារចម្លើយនៅក្នុងរឿងក្តីនេះ ចុងចម្លើយបានអះអាងរួចហើយថា ការសង ១.០០០ ដុល្លារមេរិក គឺជាការសងចំពោះកាតព្វកិច្ចផ្សេង ហើយមិនមានការសងចំពោះប្រាក់ថ្លៃលក់ទិញទេ ហេតុនេះ គឺបង្ហាញឲ្យឃើញច្បាស់ថា ចុងចម្លើយមានវិវាទទៅលើគ្រប់ចំណុចដែលដើមចោទអះអាងនៅក្នុងការតវ៉ាតប។ ដូច្នេះទោះបីជាចុងចម្លើយមិនដាក់ឯកសារត្រៀមលើកទី ១ ក៏ដោយ ក៏តុលាការអាចធ្វើការសម្រេចបានថា ចុងចម្លើយមានវិវាទចំពោះការតវ៉ាតបរបស់ដើមចោទ ហេតុនេះ គឺមិនមានការសារភាពទេ (យោងក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ៩៦ កថាខណ្ឌទី ១)។

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងរាជធានីភ្នំពេញ

**តុលាការរដ្ឋប្បវេណី**
សំណុំរឿងលេខ........
ចុះថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០១៤
សាលក្រមលេខ ........
ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ២០១៥

# សាលក្រម[1]
# ក្នុងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងរាជធានីភ្នំពេញ[2]

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៅ
ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១៥[3] [4]

## ចៅក្រមជំនុំជម្រះ

លោក J ជាចៅក្រមនៃសាលាដំបូងរាជធានីភ្នំពេញ

## ក្រឡាបញ្ជី

លោកស្រី C ជាក្រឡាបញ្ជីនៃសាលាដំបូងរាជធានីភ្នំពេញ

---

[1] ការសម្រេចសេចក្តី គឺចែកចេញជា សាលក្រម និង ដីកាសម្រេច (មាត្រា ១៧៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ដូច្នេះ មានភាពចាំបាច់នៅក្នុងការបញ្ជាក់ឲ្យបានច្បាស់លាស់ថា អំពីប្រភេទនៃការសម្រេចសេចក្តីដាក់នៅត្រង់ចំណុចចាប់ផ្តើម។ ដោយសារតែ សាលក្រម និង ដីកាសម្រេចមានភាពខុសគ្នាចំពោះវិធីក្នុងការធ្វើឧបាស្រ័យជាអាទិ៍ ។ ជាគោលការណ៍បណ្តឹងឧបាស្រ័យចំពោះសាលក្រម គឺ បណ្តឹងឧទ្ធរណ៍ ហើយ បណ្តឹងឧបាស្រ័យចំពោះដីកាសម្រេច គឺ បណ្តឹងជំទាស់ (កថាខណ្ឌទី ១ មាត្រា ២៥៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

[2] សាលក្រមរដ្ឋប្បវេណីត្រូវតែសរសេរអំពីចំណុចដែលចែងនៅក្នុងមាត្រា ១៨៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

[3] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ១៨៩ កថាខណ្ឌទី ១ ចំណុច ខ ។ សាលក្រមនឹងត្រូវកំណត់ជាស្ថាពរនូវទំនាក់ទំនងសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តិនាពេលបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ១៩៤ កថាខណ្ឌទី ២) ហេតុនេះ ចាំបាច់ត្រូវសរសេរឲ្យបានច្បាស់លាស់អំពី ពេលដែលបានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់។ ពោលគឺ សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលតុលាការបានទទួលស្គាល់ដោយសាលក្រម គឺមានន័យថា តុលាការបានសម្រេចជាមុនទៅលើអង្គហេតុដែលមានគិតមកដល់ត្រឹមការបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នោះ ហេតុនេះ ឧទាហរណ៍ថា នៅចន្លោះថ្ងៃដែលបានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ រហូតដល់ថ្ងៃប្រកាសសាលក្រម មានការសងដែលនាំឲ្យសិទ្ធិលើបំណុលរលត់ក៏ដោយ ក៏តុលាការមិនលើកយកអង្គហេតុនៃការសងមកដាក់នៅក្នុងលិខិតសាលក្រមដែរ។

[4] ការប្រកាសសាលក្រមត្រូវធ្វើឡើងក្នុងអំឡុងពេល ១ (មួយ) ខែ គិតចាប់ពីថ្ងៃដែលបានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ (មាត្រា ១៨៧ នៃក្រមរដ្ឋប្បវេណី)។ ហើយការប្រកាសសាលក្រមចាំបាច់ត្រូវធ្វើឡើងដោយផ្អែកលើច្បាប់ដើមនៃមូលសាលក្រម (កថាខណ្ឌទី ១ មាត្រា ១៨៨ នៃក្រមរដ្ឋប្បវេណី) ដូច្នេះហើយ ចាំបាច់ត្រូវតែបញ្ចប់នូវការតាក់តែងច្បាប់ដើមនៃមូលសាលក្រមឲ្យបាន គិតត្រឹមពេលប្រកាសសាលក្រម។

## ដើមចោទ

ឈ្មោះ ៖ X

អាសយដ្ឋាន ៖ ផ្ទះលេខ 00 ផ្លូវលេខ 00 សង្កាត់ទំនប់ទឹក ខណ្ឌចំការមន រាជធានីភ្នំពេញ[5]។

## អ្នកតំណាងដោយអាណត្តិ

លោក/លោកស្រី ៖ P

អាសយដ្ឋានការិយាល័យមេធាវី / ក្រុមមេធាវី / ក្រុមហ៊ុនមេធាវី ៖ ....................

ការិយាល័យមេធាវី / ក្រុមមេធាវី / ក្រុមហ៊ុនមេធាវី ៖ ...............................................

លេខទូរស័ព្ទ ៖ ..........................................................................................

## ចុងចម្លើយ

ឈ្មោះ ៖ Y

អាសយដ្ឋាន ៖ ផ្ទះលេខ 00 ផ្លូវលេខ 00 សង្កាត់មនោរម្យ ខណ្ឌ៧មករា រាជធានីភ្នំពេញ។

## អ្នកតំណាងដោយអាណត្តិ

លោក លោកស្រីមេធាវី ៖ B

អាសយដ្ឋានការិយាល័យមេធាវី / ក្រុមមេធាវី / ក្រុមហ៊ុនមេធាវី ៖..............................

ការិយាល័យមេធាវី / ក្រុមមេធាវី / ក្រុមហ៊ុនមេធាវី ៖.................................................

លេខទូរស័ព្ទ ៖...................................................

## អង្គហេតុ និងចំណុចវិវាទ

## ក. ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ

(១) បង្គាប់ឲ្យចុងចម្លើយបង់ប្រាក់ចំនួន ១៣.៥០០ (មួយម៉ឺនបីពាន់ប្រាំរយ) ដុល្លារអាមេរិក និង ប្រាក់ ១០% (ដប់ភាគរយ) នៃប្រាក់ចំនួន ១០.០០០

[5] ឈ្មោះ និងអាសយដ្ឋាន មានបញ្ញត្តិនៅក្នុងមាត្រា ៧៥ កថាខណ្ឌទី ២ ចំណុច ក នៃក្រមនីតិវិធីរដ្ឋប្បវេណី ប៉ុន្តែចំពោះចំណុចផ្សេងទៀត ដូចជា ឆ្នាំកំណើត ជាចំណុចដែលពុំមានបញ្ញត្តិក្នុងច្បាប់ទេ។ ប៉ុន្តែ ក៏មានករណីដែលពុំអាចកំណត់អំពី ភាគី តាមរយៈឈ្មោះ និង អាសយដ្ឋានផងដែរ ដូច្នេះហើយ អាចសរសេរចំណុចទាំងនោះក្នុងកម្រិតមួយដែលចាំបាច់ដើម្បីអាចកំណត់អំពីភាគី ។

(មួយម៉ឺន) ដុល្លារអាមេរិកនៅក្នុងទឹកប្រាក់ ១៣.៥០០ (មួយម៉ឺនបីពាន់ប្រាំរយ) ដុល្លារអាមេរិកគិតចាប់ពីថ្ងៃទី ១ ខែវិច្ឆិកា ឆ្នាំ២០១២ រហូតដល់ពេលសងរួចទៅដើមចោទ។

**(២)** ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ចុងចម្លើយ។

**(៣)** សាលក្រមនេះអាចអនុវត្តជាបណ្ដោះអាសន្នបាន។

## ខ. ដំណើររឿងក្ដី និង ចំណុចវិវាទ

### ខ.១. ការសង្ខេបអំពីរឿងក្ដី[6]

នៅក្នុងរឿងក្ដីនេះ ដើមចោទបានទាមទារឲ្យចុងចម្លើយបង់ប្រាក់ដើមចំនួន ១០.០០០ (មួយម៉ឺន) ដុល្លារអាមេរិក ដោយផ្អែកតាមកិច្ចសន្យាខ្ចីប្រាក់ចុះនៅថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ២០០៧ រវាងដើមចោទ និង ចុងចម្លើយ ហើយទាមទារឲ្យបង់ប្រាក់សំណងការខូចខាតចំពោះការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ច ចំនួន ៣.៥០០ (បីពាន់ប្រាំរយ) ដុល្លារអាមេរិក (ចំនួនទឹកប្រាក់ដែលនៅសល់នៃប្រាក់សំណងការខូចខាតចំពោះការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ចចំនួន ៤.០០០ (បួនពាន់) ដុល្លារអាមេរិកដែលគិតចាប់ពីថ្ងៃទី ១ ខែ វិច្ឆិកា ឆ្នាំ ២០០៨ រហូតដល់ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១២) និង ប្រាក់សំណងការខូចខាតចំពោះការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ចចំនួន ១០% ក្នុង ១ ឆ្នាំ (ដប់ភាគរយក្នុងមួយឆ្នាំ) នៃប្រាក់ចំនួន ១០.០០០ (មួយម៉ឺន) ដុល្លារអាមេរិកខាងលើ គិតចាប់ពីថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០១២ រហូតដល់ថ្ងៃសងរួចផ្អែកលើការមិនអនុវត្តកាតព្វកិច្ច។

### ខ.២. អង្គហេតុដែលគ្មានវិវាទ[7]

**ខ.២.១.** ថ្ងៃទី០១ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ដើមចោទ និង ចុងចម្លើយបានចុះកិច្ចសន្យាខ្ចីប្រាក់ចំនួន ១០.០០០ (មួយម៉ឺន) ដុល្លារអាមេរិកដោយកំណត់យក ថ្ងៃទី៣១ ខែតុលា ឆ្នាំ ២០០៨ ជាកាលបរិច្ឆេទសង ហើយដើមចោទបាន

---

[6] នៅត្រង់ចំណុចនេះ ជាចំណុចដែលមើលពីតុលាការថាតើដើមចោទកំពុងទាមទារអ្វីខ្លះ? ពោលគឺត្រូវសរសេរឲ្យបានច្បាស់លាស់អំពីកម្មវត្ថុនៃបណ្ដឹង ហើយត្រូវបង្ហាញឲ្យឃើញអំពីកម្មវត្ថុនៃការសម្រេចសេចក្ដី។

[7] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ១២៣ កថាខណ្ឌទី ២។ ត្រូវសរសេរអំពី អង្គហេតុដែលភាគីបានសារភាពនៅចំពោះមុខតុលាការ និង អង្គហេតុដែលតុលាការយល់ឃើញថា មានភាពជាក់ស្ដែង។

ប្រគល់ចំនួន ១០.០០០ (មួយម៉ឺន) ដុល្លារអាមេរិកឲ្យទៅចុងចម្លើយផ្អែកតាមកិច្ចសន្យានេះ។ នៅក្នុងកិច្ចសន្យានេះ ដើមចោទ និង ចុងចម្លើយបានព្រមព្រៀង អំពីការបង់នូវការប្រាក់ចំនួន ៥% ក្នុង ១ ឆ្នាំ (ប្រាំភាគរយក្នុងមួយឆ្នាំ) និង ប្រាក់សំណងការខូចខាតចំពោះការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ច ចំនួន ១០% ក្នុង ១ ឆ្នាំ (ដប់ភាគរយក្នុងមួយឆ្នាំ) នៃប្រាក់កម្ចីចំនួន ១០.០០០ (មួយម៉ឺន) ដុល្លារអាមេរិក ហើយការព្រមព្រៀងនេះបានធ្វើឡើងជាលាយលក្ខណ៍អក្សរដោយមានហត្ថលេខារបស់ចុងចម្លើយ។ តទៅកិច្ចសន្យានេះនឹងហៅថា "កិច្ចសន្យាខ្ចីប្រាក់នៃរឿងក្តីនេះ" ហើយរឿងក្តីនេះនឹងហៅថា "រឿងក្តីស្តីពីការទាមទារឲ្យសងប្រាក់កម្ចីនៃរឿងក្តីនេះ" ។

**ខ.២.២.** នៅថ្ងៃទី ៣១ ខែតុលា ឆ្នាំ ២០១២ ដើមចោទបានទទួលប្រាក់ ១.០០០ (មួយពាន់) ដុល្លារអាមេរិកពីចុងចម្លើយ។

**ខ.២.៣.** នៅថ្ងៃទី ៣១ ខែតុលា ឆ្នាំ២០១៣ ដើមចោទបានទិញរថយន្តពីចុងចម្លើយក្នុងតម្លៃ ៧.០០០ (ប្រាំពីរពាន់) ដុល្លារអាមេរិក ហើយបានទទួលនូវការប្រគល់រថយន្តនោះ។

**ខ.២.៤.** ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៣ បានកន្លងផុត។

**ខ.២.៥.** នៅក្នុងឯកសារចម្លើយដែលបានទៅដល់ដើមចោទនៅថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១៤ ចុងចម្លើយបានបង្ហាញឆន្ទៈអំពីការលើកឡើងនូវការរលត់អាជ្ញាយុកាលលើកាតព្វកិច្ចសងប្រាក់កម្ចីផ្អែកតាម "កិច្ចសន្យាខ្ចីប្រាក់នៃរឿងក្តីនេះ" ។ ម្យ៉ាងវិញទៀត នៅក្នុងឯកសារចម្លើយដដែលនេះ ចុងចម្លើយបានអះអាងត្រៀមថា នឹងបង្ហាញឆន្ទៈទូទាត់នូវចំនួនប្រាក់ស្មើគ្នានៃសិទ្ធិលើបំណុលនៃប្រាក់ថ្លៃលក់ទិញរថយន្តដែលបានសរសេរនៅក្នុងចំណុច ខ.២.៣ ខាងលើជាមួយនិង សិទ្ធិលើបំណុលផ្អែក "កិច្ចសន្យាខ្ចីប្រាក់នៃរឿងក្តីនេះ" ។

## ខ.៣. ចំណុចវិវាទ

**ខ.៣.១.** ការតវ៉ាតបចំពោះការតវ៉ាអំពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល (ការផ្អាកអាជ្ញាយុកាល)

តើប្រាក់ចំនួន ១.០០០ (មួយពាន់) ដុល្លារអាមេរិក ដែលដើមចោទទទួលពីចុងចម្លើយគឺ ការសងមួយផ្នែកចំពោះកាតព្វកិច្ចផ្អែកតាម "កិច្ចសន្យាខ្ចីប្រាក់នៃរឿងក្តីនេះ" ឬ ទេ?

**ខ.៣.២.** ការតវ៉ាតបចំពោះការតវ៉ាអំពីការទូទាត់ (ការរលត់នៃសិទ្ធិលើបំណុលដែលផ្តើមការទូទាត់តាមរយៈការតវ៉ា)

តើដើមចោទបានបង់ថ្លៃរថយន្តចំនួន ៧.០០០ (ប្រាំពីរពាន់) ដុល្លារអាមេរិកឲ្យចុងចម្លើយ ឬ ទេ?

## ខ.៤. ការអះអាងរបស់ភាគីស្តីពីចំណុចវិវាទ [8]

**ខ.៤.១.** ស្តីពីចំណុចវិវាទទី១ (តើប្រាក់ចំនួន ១.០០០ (មួយពាន់) ដុល្លារអាមេរិក ដែលដើមចោទទទួលពីចុងចម្លើយ គឺ ការសងមួយផ្នែកចំពោះកាតព្វកិច្ចផ្អែកតាម "កិច្ចសន្យាខ្ចីប្រាក់នៃរឿងក្តីនេះ" ឬ ទេ?)

**ខ.៤.១.១.** ការអះអាងរបស់ដើមចោទ

នៅថ្ងៃទី ៣១ ខែ តុលា ឆ្នាំ២០១២ ដើមចោទបានទទួលប្រាក់ចំនួន ១.០០០ (មួយពាន់) ដុល្លារអាមេរិកពីចុងចម្លើយដែលជាការសងកាតព្វកិច្ចផ្អែកតាម "កិច្ចសន្យាខ្ចីប្រាក់នៃរឿងក្តីនេះ" ។ នៅពេលនោះ ដើមចោទបានធ្វើលិខិតទទួលប្រាក់ ដែលបានសរសេរថា បានទទួលប្រាក់ចំនួន ១.០០០ (មួយពាន់) ដុល្លារអាមេរិក ជាការសងកាតព្វកិច្ចផ្អែកតាម "កិច្ចសន្យាខ្ចីប្រាក់នៃរឿងក្តីនេះ" ហើយបានប្រគល់លិខិតនេះឲ្យទៅចុងចម្លើយ **(ភស្តុតាង $X_3$)**។

---

[8] បញ្ចូលនូវអង្គហេតុដែលគ្មានវិវាទ និង ការអះអាងរបស់ភាគីស្តីអំពីចំណុចវិវាទចូលជាមួយគ្នា ហើយចាំបាច់ត្រូវធ្វើយ៉ាងណាកុំឲ្យមានការខ្វះចន្លោះចំពោះការអះអាងរបស់ភាគី ជាពិសេសគឺការអះអាងដែលទាក់ទងទៅនឹងអង្គហេតុចម្បង។ មូលហេតុដែលត្រូវធ្វើបែបនេះ គឺដោយសារតែតុលាការមិនអាចយកអង្គហេតុណាដែលភាគីណាមួយមិនបានអះអាងមកធ្វើជាមូលដ្ឋាននៃសាលក្រមបានឡើយ (មាត្រា ៩៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

**ខ.៤.១.២.** ការអះអាងរបស់ចុងចម្លើយ

ចុងចម្លើយមិនទទួលស្គាល់។

ចំពោះប្រាក់ចំនួន ១.០០០ (មួយពាន់) ដុល្លារអាមេរិកដែលចុងចម្លើយបានប្រគល់ទៅដើមចោទគឺជាការសងកាតព្វកិច្ចផ្សេង ហើយមិនមែនជាការសងចំពោះកាតព្វកិច្ចដោយផ្អែកតាម "កិច្ចសន្យាខ្ចីប្រាក់នៃរឿងក្ដីនេះ" ទេ។

**ខ.៤.២.** ស្ដីពីចំណុចវិវាទទី២ (តើដើមចោទបានបង់ថ្លៃរថយន្តចំនួន ៧.០០០ (ប្រាំពីរពាន់) ដុល្លារអាមេរិកឲ្យចុងចម្លើយ ឬ ទេ?)

**ខ.៤.២.១.** ការអះអាងរបស់ដើមចោទ

នៅអំឡុងខែធ្នូ ឆ្នាំ២០១៣ ដើមចោទបានបង់ប្រាក់ថ្លៃរថយន្តចំនួន ៧.០០០ (ប្រាំពីរពាន់) ដុល្លារអាមេរិកដែលមានក្នុងចំណុច "**ខ.២.៣.**" ខាងលើឲ្យទៅចុងចម្លើយ។

**ខ.៤.២.២.** ការអះអាងរបស់ចុងចម្លើយ

ចុងចម្លើយមិនទទួលស្គាល់។

ចុងចម្លើយបានដាស់តឿនទៅដើមចោទឲ្យបង់ប្រាក់ជាច្រើនលើកច្រើនសារ ប៉ុន្តែ ដើមចោទមិនបានបង់ប្រាក់ទេ។

## សំអាងហេតុ

## ក. ស្ដីពីចំណុចវិវាទទី១

ផ្អែកតាម **ភស្តុតាង** $X_3$ តុលាការទទួលស្គាល់នូវអង្គហេតុដែលដើមចោទបានទទួលប្រាក់ចំនួន ១.០០០ (មួយពាន់) ដុល្លារអាមេរិក ជាការសងកាតព្វកិច្ចផ្អែកតាម "កិច្ចសន្យាខ្ចីប្រាក់នៃរឿងក្ដីនេះ" ពីចុងចម្លើយនៅថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១២ ។

ដូច្នេះ អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល ចំពោះសិទ្ធិលើបំណុលជាប្រាក់កម្ចីរបស់ដើមចោទបានផ្អាក។

## ខ. ស្ដីពីចំណុចវិវាទទី២

ដើមចោទបានអះអាងអំពីអង្គហេតុថា ដើមចោទបានបង់ប្រាក់ចំនួន ៧.០០០ (ប្រាំពីរពាន់) ដុល្លារអាមេរិកនៃថ្លៃលក់ទិញរថយន្តទៅឲ្យចុងចម្លើយ ប៉ុន្តែ ពុំមានភស្តុតាងដើម្បីឲ្យតុលាការអាចទទួលស្គាល់នូវការអះអាងនោះបានទេ។

ហេតុនេះ តុលាការមិនទទួលស្គាល់អំពីការតវ៉ាតបរបស់ដើមចោទទេ។

## គ. ការវិនិច្ឆ័យអំពីចំនួនទឹកប្រាក់ដែលបានទទួលស្គាល់

ផ្អែកតាម "កិច្ចសន្យាខ្ចីប្រាក់នៃរឿងក្ដីនេះ" បើគិតត្រឹមថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១២ ដើមចោទមានសិទ្ធិលើបំណុលចំពោះចុងចម្លើយដូចតទៅ។ ទី១ នៅថ្ងៃដដែលមុនពេលនៃការសងមួយផ្នែក ដើមចោទមានសិទ្ធិលើបំណុលចំពោះចុងម្លើយជាប្រាក់ដើមចំនួន ១០.០០០ (មួយម៉ឺន) ដុល្លារអាមេរិក ការប្រាក់ចំនួន ៥០០ (ប្រាំរយ) ដុល្លារអាមេរិក និង ប្រាក់សំណងការខូចខាតចំពោះការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ចចំនួន ៥.០០០ (បួនពាន់) ដុល្លារអាមេរិក។ ហើយនៅថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១២ ចុងចម្លើយបានសងប្រាក់ចំនួន ១.០០០ (មួយពាន់) ដុល្លារអាមេរិកឲ្យទៅដើមចោទ ហើយចំពោះប្រាក់ចំនួន ១.០០០ (មួយពាន់) ដុល្លារអាមេរិកនោះ ជាដំបូងនឹងយកមកកាត់ជាមួយនិងការប្រាក់ចំនួន ៥០០ (ប្រាំរយ) ដុល្លារអាមេរិក រីឯប្រាក់ចំនួន ៥០០ (ប្រាំរយ) ដុល្លារអាមេរិកដែលនៅសល់នឹងយកមកកាត់ជាមួយនិងប្រាក់សំណងការខូចខាតចំពោះការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ច (ក្រមរដ្ឋប្បវេណី មាត្រា ៥៥១) ។ ដូច្នេះ គិតត្រឹមថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១២ ចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលនៅសល់ដែលដើមចោទមានចំពោះចុងម្លើយគឺ ប្រាក់ដើមចំនួន ១០.០០០ (មួយម៉ឺន) ដុល្លារអាមេរិក និង ប្រាក់សំណងការខូចខាតចំពោះការយឺតយ៉ាវក្នុងការអនុវត្ត ចំនួន ៣.៥០០ (បីពាន់ប្រាំរយ) ដុល្លារអាមេរិក ។

ម្យ៉ាងវិញទៀត មូលហេតុដែលមានស្ថានភាពសមស្របទៅនឹងការទូទាត់នូវប្រាក់ចំនួន ៧.០០០ (ប្រាំពីរពាន់) ដុល្លារអាមេរិកដែលជាសិទ្ធិលើបំណុលនៃប្រាក់ថ្លៃលក់ទិញរថយន្តរបស់ចុងចម្លើយមានចំពោះដើមចោទនៅថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៣។ ដោយសារតែថ្ងៃនោះ គឺជាថ្ងៃកិច្ចសន្យាលក់ទិញលក់ទិញរថយន្តបានបង្កើតឡើង

ហើយចុងម្លើយបានប្រគល់រថយន្តទៅឲ្យដើមចោទ។[9] ដោយសារតែគិតមកដល់ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៣ ចំនួននៃសិទ្ធិលើបំណុលរបស់ដើមចោទមានចំពោះចុងចម្លើយមានដូចជា ប្រាក់ដើមចំនួន ១០.០០០ (មួយម៉ឺន) ដុល្លារអាមេរិក និង ប្រាក់សំណងការខូចខាតចំពោះការយឺតយ៉ាវក្នុងការអនុវត្តចំនួន ៤.៥០០ (បួនពាន់ប្រាំរយ) ដុល្លារអាមេរិក ហេតុនេះ ជាលទ្ធផលក្រោយពីការកាត់បំណុលដោយការទូទាត់ (ក្រមរដ្ឋប្បវេណី មាត្រា ៤៧២ និង មាត្រា ៤៥១) ចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលរបស់ដើមចោទមានចំពោះចុងចម្លើយក្រោយពេលទូទាត់គឺ មានតែប្រាក់ដើមចំនួន ៧.៥០០ (ប្រាំពីរពាន់ប្រាំរយ) ដុល្លារអាមេរិកតែប៉ុណ្ណោះ។[10]

ដូច្នេះ ដើមចោទអាចទាមទាមឲ្យចុងចម្លើយបង់ប្រាក់ដើមចំនួន ៧.៥០០ (ប្រាំពីរពាន់ប្រាំរយ) ដុល្លារអាមេរិក និង ប្រាក់សំណងការខូចខាតចំពោះការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ចក្នុងអត្រាចំនួន ១០% ក្នុង ១ឆ្នាំនៃប្រាក់ដើមនេះ គិតចាប់ពីថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០១៣ រហូតដល់ថ្ងៃសងរួចតែប៉ុណ្ណោះ ដោយផ្អែកតាម "កិច្ចសន្យាខ្ចីប្រាក់នៃរឿងក្តីនេះ" ។

## ឃ. ស្តីពីបន្ទុកនៃប្រាក់ប្រដាប់ក្តី

នៅក្នុង "រឿងក្តីស្តីពីការទាមទារឲ្យសងប្រាក់កម្ចីនៃរឿងក្តីនេះ" ដើមចោទបានចាញ់ក្តីមួយផ្នែក ហេតុនេះ ចំពោះបន្ទុកប្រាក់ប្រដាប់ក្តីឲ្យដើមចោទ និង ចុងម្លើយទទួលបន្ទុក ម្នាក់ ១ ភាគ (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ៦៤ កថាខណ្ឌទី ១) ។ ការទាមទារចម្បងរបស់ដើមចោទ គឺ ការបង់ប្រាក់ដើមចំនួន ១០.០០០ (មួយម៉ឺន) ដុល្លារអាមេរិក ប៉ុន្តែ ដោយសារតែតុលាការទទួលស្គាល់ការទាមទារនោះតែចំនួន ៧.៥០០ (ប្រាំពីរពាន់ប្រាំរយ) ដុល្លារអាមេរិកប៉ុណ្ណោះ ហេតុនេះ ចំពោះប្រាក់ប្រដាប់ក្តីគឺឲ្យ

[9] អានុភាពនៃការរលត់កាតព្វកិច្ចតាមរយៈការទូទាត់ នឹងកើតមានឡើងដោយប្រតិសកម្មទៅនឹងពេលស្ថានភាពសមស្របទៅនឹងការទូទាត់ (ក្រមរដ្ឋប្បវេណី មាត្រា ៤៦៦)។

[10] លំដាប់នៃការកាត់បំណុល (មាត្រា ៤៧២ មាត្រា ៤៥១ នៃក្រមរដ្ឋប្បវេណី) គឺសោហ៊ុយការប្រាក់ (ការប្រាក់ និងប្រាក់សំណងការខូចខាតចំពោះការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ច) និង ប្រាក់ដើម ដូច្នេះហើយ ចំពោះប្រាក់ចំនួន ៧.០០០ (ប្រាំពីរពាន់) ដុល្លារអាមេរិក ដំបូងនឹងយកមកកាត់ជាមួយនឹង ប្រាក់សំណងការខូចខាតចំពោះការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ចចំនួន ៤.៥០០ (បួនពាន់ប្រាំរយ) ដុល្លារអាមេរិក ហើយប្រាក់ដែលនៅសល់ចំនួន ២.៥០០ (ពីរពាន់ប្រាំរយ) ដុល្លារអាមេរិកនឹងត្រូវយកមកកាត់ជាមួយនឹងប្រាក់ដើមមួយផ្នែកចំនួន។

ចុងចម្លើយទទួលបន្ទុក ចំនួន ៧៥% (ចិតសិបប្រាំភាគរយ) រីឯដើមចោទទទួលបន្ទុក ចំនួន ២៥% (ម្ភៃប្រាំភាគរយ)។

## ខ. ស្តីពីការប្រកាសឲ្យអនុវត្តជាបណ្តោះអាសន្ន

ការទាមទាររបស់ដើមចោទ គឺជាការទាមទារជាប្រាក់ ហើយតុលាការទទួលស្គាល់ថា មានភាពចាំបាច់ ដូច្នេះ ប្រកាសឲ្យអនុវត្តជាបណ្តោះអាសន្នចំពោះសេចក្តីសម្រេចបញ្ចប់ខាងក្រោមចាប់ពីចំណុចទី ១ ដល់ ទី ៣។

## សេចក្តីសម្រេចបញ្ចប់

**១.** បង្គាប់ឲ្យចុងចម្លើយបង់ប្រាក់ចំនួន ៧.៥០០ (ប្រាំពីរពាន់ប្រាំរយ) ដុល្លារអាមេរិក និង ប្រាក់ក្នុងអត្រាចំនួន ១0% ក្នុង ១ ឆ្នាំនៃប្រាក់នេះ គិតចាប់ពីថ្ងៃទី 0១ ខែវិច្ឆិកា ឆ្នាំ ២0១៣ រហូតដល់ថ្ងៃសងរួចទៅដើមចោទ។

**២.** ក្រៅពីចំណុចទី ១ ច្រានចោលនូវការទាមទាររបស់ដើមចោទលើសពីនេះ ។

**៣.** ប្រាក់ប្រដាប់ក្តី ៧៥ % (ចិតសិបប្រាំភាគរយ) គឺជាបន្ទុករបស់ចុងចម្លើយ ហើយ ២៥% (ម្ភៃប្រាំភាគរយ) គឺជាបន្ទុករបស់ដើមចោទ ។

**៤.** ចំណុចទី ១ និង ចំណុចទី ៣ នៃសេចក្តីសម្រេចបញ្ចប់នៃសាលក្រមនេះ អាចអនុវត្តជាបណ្តោះអាសន្នបានចំពោះ ។

សាលក្រមនេះត្រូវបានប្រកាសនៅសវនការជាសាធារណៈនៅថ្ងៃទី ២0 ខែ កុម្ភៈ ឆ្នាំ ២0១៥។ ក្នុងករណីដែលប្តឹងឧទ្ធរណ៍ ត្រូវតែធ្វើឡើងនៅក្នុងរយៈពេល 0១ (មួយ) ខែ គិតចាប់ពីថ្ងៃដែលបានទទួលការបញ្ជូនលិខិតសាលក្រមនេះ។

ថ្ងៃសុក្រ ១៣ កើត ខែផល្គុន ឆ្នាំមមី ឆស័កព.ស.២៥៥៨

រាជធានីភ្នំពេញ, ថ្ងៃទី ២0 ខែ កុម្ភៈ ឆ្នាំ ២0១៥

**ចៅក្រម**


ប្រធានបទដែលត្រូវបញ្ជាក់ =
(ការដែលត្រូវបញ្ជាក់ដោយភស្តុតាង)
ទឹកប្រាក់ចំនួន ១.០០០ដុល្លារអាមេរិកដែលXបានទទួល ពី Yគឺជាប្រាក់សម្រាប់ករណីយកិច្ចសងប្រាក់កម្ចី។
X មានបន្ទុកបញ្ជាក់ភស្តុតាង !!
Y គ្រាន់តែតទល់អំពីចំណុចនេះ នឹងឈ្នះ
មិនចាំបាច់តទល់
(ភស្តុតាង X3)
(ភស្តុតាង ∞)
បើសិនមិនអាចបដិសេធភស្តុតាង X3 បានទេ Y មិនឈ្នះទេ។
X បានទទួលប្រាក់ពី Y ចំនួន ១.០០០ដុល្លារអាមេរិកជាការសងនៃប្រាក់កម្ចី
ថ្ងៃទី ៣១ ខែតុលា ឆ្នាំ ២០១២
X បានទទួលប្រាក់ពី Y ចំនួន ១.០០០ដុល្លារអាមេរិក
ថ្ងៃទី ៣១ ខែតុលា ឆ្នាំ ២០១២
មិនចាំបាច់តទល់

# រឿងក្តីទាមទារឲ្យធ្វើនីតិវិធីចុះបញ្ជី
# ផ្ទេរកម្មសិទ្ធិដោយផ្អែកលើ
# កិច្ចសន្យាលក់ទិញ

Yoshie SASAKI / JICA Expert

# អំពីនីតិវិធីចុះបញ្ជីអចលនវត្ថុ

## ១. ច្បាប់ដែលទាក់ទងនឹងនីតិវិធីចុះបញ្ជីអចលនវត្ថុ

(១) លំដាប់ដែលត្រូវបានយកមកអនុវត្ត

ក. "ប្រកាសអន្តរក្រសួងស្តីពី ការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី" (ចុះថ្ងៃទី ៣ ខែ ឧសភា ឆ្នាំ ២០១១ អនុវត្តនៅថ្ងៃទី ៣ ខែ វិច្ឆិកា ឆ្នាំ ២០១១ (ប្រកាស ៤៣))

ខ. "ប្រកាសអន្តរក្រសួងស្តីពី នីតិវិធីនៃការចុះបញ្ជីអំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី" (ចុះថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០១៣ អនុវត្តនៅថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៣ (មានករណីលើកលែងមួយផ្នែក ។ ប្រកាស ១៤១))

គ. "ប្រកាសអន្តរក្រសួងស្តីពី នីតិវិធីនៃការចុះបញ្ជីទាក់ទងនឹងការចាត់ចែងរក្សាការពារ និង ការរឹបអូសចំពោះអចលនវត្ថុដែលមិនទាន់បានចុះបញ្ជី" (ចុះថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១៤ អនុវត្តនៅថ្ងៃដដែល (ប្រកាស ១៣))

នៅក្នុងសេចក្តីសម្រេចដែលខ្លួនទទួលបន្ទុក ក្នុងករណីដែលមានការពាក់ព័ន្ធនឹងការចុះបញ្ជីអចលនវត្ថុ ចាំបាច់ត្រូវតែយោងលើប្រកាសអន្តរក្រសួងទាំងនេះឲ្យបានជាដាច់ខាត ។

ជាពិសេសចំពោះនីតិវិធីនៃការចុះបញ្ជីអលនវត្ថុ មិនត្រឹមតែមានទំនាក់ទំនងនឹងតុលាការប៉ុណ្ណោះទេ ថែមទាំងមានទំនាក់ទំនងនឹងរដ្ឋបាលសុរិយោដី ហើយនិងក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ផងដែរ។ ដើម្បីធ្វើឲ្យការចុះបញ្ជីនៅរដ្ឋបាលសុរិយោដីដែលផ្អែកតាមសាលក្រម / សាលដីកាដែលបានចេញដោយតុលាការ មានភាពត្រឹមត្រូវ ជាដំបូងបង្អស់ តុលាការដែលចេញសាលក្រម / សាលដីកា ចាំបាច់ត្រូវចេញជាសាលក្រម / សាលដីកាឲ្យមានភាពត្រឹមត្រូវដែលបានផ្អែកតាមច្បាប់ទាំងនេះ។

ចំណុចដែលគួរធ្វើការចាប់អារម្មណ៍គឺ គេបានយល់ថា ពុំមានបញ្ហាអ្វីឡើយ បើទោះបីជាសាលក្រម / សាលដីកាមានភាពខ្វះចន្លោះ ក៏មន្រ្តីចុះបញ្ជីនៅតែធ្វើការចុះបញ្ជីឲ្យដែរ ប៉ុន្តែលទ្ធផលចុងក្រោយ វានឹងធ្វើឲ្យអំណាចនៃសាលក្រម / សាលដីកាដែលយើងចេញនឹងធ្លាក់ចុះ (អនុញ្ញាតឲ្យមានសិទ្ធិសម្រេចពីមន្រ្តីចុះបញ្ជី) ។

(២) "ប្រកាសអន្តរក្រសួងស្តីពី នីតិវិធីនៃការចុះបញ្ជីអំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី"

នៅក្នុងប្រកាសអន្តរក្រសួងនេះ ចែងអំពី ១. នីតិវិធីនៃការដាក់ពាក្យសុំចុះបញ្ជីដោយយោងតាមក្រមរដ្ឋប្បវេណី និង ២. នីតិវិធីនៃការចុះបញ្ជីអំពីសិទ្ធិប្រត្យក្សលើអចលនវត្ថុដោយយោងតាមក្រមរដ្ឋប្បវេណី (ប្រការ ២)។

ដូច្នេះហើយ ចំពោះនីតិវិធីនៃការចុះបញ្ជីអំពីសិទ្ធិប្រត្យក្សលើអចលនវត្ថុ ជាគោលការណ៍នឹងត្រូវចាប់ផ្ដើមចេញពីការប្រើប្រាស់ប្រកាសអន្តរក្រសួងទាំង ៣ ខាងលើនៃចំណុច (១)។

ចំពោះនីតិវិធីចុះបញ្ជីផ្អែកតាមសាលក្រម / សាលដីកា មានចែងនៅក្នុង "ប្រកាសអន្តរក្រសួងស្ដីពី ការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី" (កថាខណ្ឌទី ២ ប្រការ ២ ប្រការ ៤ និង ប្រការ ៥០)។ ប្រសិនបើផ្អែកតាមបទប្បញ្ញត្តិទាំងនេះ ចំពោះការចុះបញ្ជីដោយផ្អែកតាមសាលក្រម / សាលដីកា គឺត្រូវតែដាក់ពាក្យសុំចុះបញ្ជី។ ចំពោះនីតិវិធីនៃការចុះបញ្ជីនោះលម្អិត គឺមានចែងនៅក្នុង "ប្រកាសអន្តរក្រសួងស្ដីពី នីតិវិធីនៃការចុះបញ្ជីអំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី" ដែលជាបទប្បញ្ញត្តិទូទៅ។

ដូច្នេះហើយ ចំពោះការចុះបញ្ជីដោយផ្អែកតាមសាលក្រម / សាលដីកា ចាំបាច់ត្រូវតែយោង "ប្រកាសអន្តរក្រសួងស្ដីពី នីតិវិធីនៃការចុះបញ្ជីអំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី" ជាដាច់ខាត។

## ២. ប្រធាននៃការចុះបញ្ជី

※ ប្រការដែលបានដកស្រង់នៅខាងក្រោមនេះ គឺជាប្រការដែលចែងនៅក្នុង "ប្រកាសអន្តរក្រសួងស្ដីពី នីតិវិធីនៃការចុះបញ្ជីអំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី" លើកលែងតែមានការចែងផ្សេងពីនេះ។

(១) ការតម្រៀបប្រការដែលពាក់ព័ន្ធ

"បុគ្គលដែលដាក់ពាក្យសុំចុះបញ្ជី អំពីសិទ្ធិប្រត្យក្សលើអចលនវត្ថុ"

"កថាខណ្ឌទី ១ ប្រការ ១០"

ពាក្យសុំចុះបញ្ជី អំពីសិទ្ធិប្រត្យក្សលើអចលនវត្ថុ ត្រូវធ្វើឡើងរួមគ្នាដោយបុគ្គលមានសិទ្ធិចុះបញ្ជី និង បុគ្គលមានកាតព្វកិច្ចចុះបញ្ជី។

"កថាខណ្ឌទី ១ ប្រការ ៦"

ពាក្យសុំចុះបញ្ជី អំពីសិទ្ធិប្រត្យក្សលើអចលនវត្ថុ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ។

(※ចំពោះទម្រង់នៃពាក្យសុំ និង ឯកសារភ្ជាប់មានចែងចាប់ពីប្រការ ២៦ រហូតដល់ប្រការ ៧៨។ )

→ **ពាក្យសុំចុះបញ្ជី** អំពីសិទ្ធិប្រត្យក្សលើអចលនវត្ថុ ត្រូវធ្វើនិងដាក់រួមគ្នាដោយបុគ្គលមានសិទ្ធិចុះបញ្ជី និង បុគ្គលមានកាតព្វកិច្ចចុះបញ្ជី ហើយត្រូវធ្វើជាលាយលក្ខណ៍អក្សរ។

"កថាខណ្ឌទី ២ ប្រការ ៦"

រដ្ឋបាលសុរិយោដីរាជធានី ខេត្ត ដែលមានសមត្ថកិច្ចចុះបញ្ជី ត្រូវចុះបញ្ជីទៅតាមចំណុចដែលមាននៅក្នុងពាក្យសុំរបស់អ្នកដាក់ពាក្យសុំ ឬ លិខិតផ្ទុកផ្តាក់។

(※ចំពោះវិធីនៃការចុះបញ្ជីមានចែងចាប់ពីប្រការ ៨៩ រហូតដល់ប្រការ ១៣៧។ )

→ **រដ្ឋបាលសុរិយោដី** ត្រូវចុះបញ្ជីទៅតាមចំណុចដែលមាននៅក្នុងលិខិតពាក្យសុំ។ ការចុះបញ្ជីនេះគឺជាកាតព្វកិច្ច។

ច្បាប់អនុញ្ញាតឲ្យរដ្ឋបាលសុរិយោដីមិនចុះបញ្ជីទៅតាមចំណុចដែលមាននៅក្នុងលិខិតពាក្យសុំតែនៅក្នុងករណីដែលបានលើកចោលពាក្យសុំប៉ុណ្ណោះ (ប្រការ ៩) ។

(២) សរុបជារួម

កិច្ចការដែលភាគីត្រូវធ្វើគឺ ការធ្វើនិងដាក់ពាក្យសុំចុះបញ្ជី ហើយជាក់ស្តែងអ្នកដែលត្រូវចុះបញ្ជីគឺរដ្ឋបាលសុរិយោដី។ រដ្ឋបាលសុរិយោដីមានករណីយកិច្ចធ្វើការចុះបញ្ជីទៅតាមចំណុចដែលមាននៅក្នុងលិខិតពាក្យសុំ លើកលែងតែករណីដែលបានលើកចោលពាក្យសុំ។

ផ្ទុយមកវិញ រដ្ឋបាលសុរិយោដី ពុំមានករណីយកិច្ចចុះបញ្ជីទេ បើគ្មានការធ្វើនិងដាក់ពាក្យសុំចុះបញ្ជីដែលត្រឹមត្រូវតាមច្បាប់។

## ៣. គោលការណ៍នៃពាក្យសុំដែលបានធ្វើនិងដាក់រួមគ្នា

(១) អត្ថន័យនៃអត្ថិភាពនៃការចុះបញ្ជី

សៀវភៅចុះបញ្ជី គឺជាសៀវភៅដែលប្រជាពលរដ្ឋជឿជាក់ថា គ្រាន់តែមើលសៀវភៅនោះនឹងដឹងច្បាស់អំពីអ្នកមានសិទ្ធិពិតប្រាកដ ហើយកំណត់ទុកជាមុនក្នុងការយកមកយោងនៅមុនពេលធ្វើប្រតិបត្តិការជំនួញ។ ដូច្នេះហើយ ការចុះបញ្ជីនឹងមិនមានអត្ថន័យឡើយ ប្រសិនបើទំនាក់ទំនងនៃ

សិទ្ធិពិតប្រាកដមិនបានឆ្លុះបញ្ចាំងដោយមានភាពត្រឹមត្រូវ។

អានុភាពក្នុងការសន្មត់នៃការចុះបញ្ជីមានការទទួលស្គាល់ (មាត្រា ១៣៧ ក្រមរដ្ឋប្បវេណី) គឺដោយសារតែមានការកំណត់ទុកជាមុនថា ការចុះបញ្ជីគឺឆ្លុះបញ្ចាំងអំពីទំនាក់ទំនងសិទ្ធិពិតប្រាកដ។

ដូច្នេះហើយ រក្សាអត្ថន័យនៃអត្ថិភាពនៃការចុះបញ្ជី ចាំបាច់ត្រូវជៀសវាងនូវការចុះបញ្ជីមិនពិតដែលត្រូវបានធ្វើឡើងដោយមិនបានឆ្លុះបញ្ចាំងអំពីទំនាក់ទំនងសិទ្ធិពិតប្រាកដ។

ម្យ៉ាងទៀត យុទ្ធសាស្ត្រមួយដើម្បីជៀសវាងពីការចុះបញ្ជីដែលមិនពិត គឺ ការធ្វើនិងដាក់ពាក្យសុំរួមគ្នា។

(២) គោលការណ៍នៃពាក្យសុំដែលបានធ្វើនិងដាក់រួមគ្នា

ប្រសិនបើអនុញ្ញាតឲ្យអ្នកដែលអះអាងអំពីសិទ្ធិអាចធ្វើនិងដាក់ពាក្យសុំចុះបញ្ជីតែម្នាក់ឯងបាន វានឹងធ្វើឲ្យមានការផ្ទេរតែទៅលើការចុះបញ្ជីតាមតែអំពើចិត្ត បើទោះបីជាមិនទាន់មានការផ្ទេរសិទ្ធិពិតប្រាកដក៏ដោយ។ បើធ្វើដូច្នេះ វានឹងធ្វើឲ្យការចុះបញ្ជីមិនឆ្លុះបញ្ចាំងអំពីទំនាក់ទំនងសិទ្ធិពិតប្រាកដដោយមានភាពត្រឹមត្រូវទេ។ ហេតុនេះ វានឹងធ្វើឲ្យបាត់បង់អត្ថន័យនៃអត្ថិភាពនៃការចុះបញ្ជី។

ដូច្នេះហើយ ប្រកាសអន្តរក្រសួងបានឲ្យអ្នកដែលបាត់បង់សិទ្ធិ និង អ្នកដែលអះអាងអំពីសិទ្ធិធ្វើនិងដាក់ពាក្យសុំរួមគ្នា ដើម្បីធ្វើការការពារកុំឲ្យមានការចុះបញ្ជីមិនពិតដែលមិនមានការឆ្លុះបញ្ចាំងអំពីទំនាក់ទំនងសិទ្ធិពិតប្រាកដ។

ពោល ប្រកាសអន្តរក្រសួងមិនត្រឹមតែបានទាមទារ (កថាខណ្ឌទី ១ ប្រការ ១០) ឲ្យបុគ្គលមានសិទ្ធិចុះបញ្ជី (កថាខណ្ឌទី ៣ ប្រការ ៤) ដែលទទួលសិទ្ធិដោយផ្ទាល់តាមរយៈការចុះបញ្ជីបង្ហាញឆន្ទៈទៅកាន់បុគ្គលមានកាតព្វកិច្ចចុះបញ្ជីអំពីការធ្វើនិងដាក់ពាក្យសុំចុះបញ្ជីតែប៉ុណ្ណោះទេ ថែមទាំងបានទាមទារឲ្យបុគ្គលមានកាតព្វកិច្ចចុះបញ្ជី (កថាខណ្ឌទី ៤ ប្រការ ៤) ដែលទទួលរងការខាតបង់ផលប្រយោជន៍ដោយផ្ទាល់តាមរយៈការចុះបញ្ជីបង្ហាញឆន្ទៈទៅកាន់បុគ្គលមានសិទ្ធិចុះបញ្ជីអំពីការធ្វើ និង ដាក់ពាក្យសុំដែលមានខ្លឹមសារដូចគ្នាផងដែរ។

ប្រសិនបើការបង្ហាញឆន្ទៈរបស់បុគ្គលមានសិទ្ធិចុះបញ្ជី និង បុគ្គលមានកាតព្វកិច្ចចុះបញ្ជីត្រូវគ្នានាំឲ្យការធ្វើនិងដាក់ពាក្យសុំចុះបញ្ជីនោះបានឆ្លុះបញ្ចាំងអំពីទំនាក់ទំនងសិទ្ធិពិតប្រាកដប្រកបដោយលទ្ធភាពខ្ពស់ ដោយសារតែបុគ្គលដែលទទួលរងការខាតបង់ផលប្រយោជន៍ដោយផ្ទាល់តាមរយៈការចុះបញ្ជី (បុគ្គលមានកាតព្វកិច្ចចុះបញ្ជី) បានផ្តល់ការយល់ព្រមទៅលើការធ្វើ និង ដាក់ពាក្យសុំ

ចុះបញ្ជីនោះ។ ប្រសិនបើធ្វើដូច្នេះ ទោះបីជារដ្ឋបាលសុរិយោដីចុះបញ្ជីតាមចំណុចដែលត្រូវចុះបញ្ជី ដែលបានសរសេរនៅក្នុងលិខិតពាក្យសុំនោះក៏ដោយ (កឋាខណ្ឌទី ២ ប្រការ ៦) ក៏លទ្ធភាពដែលនាំឲ្យការចុះបញ្ជីនោះមិនពិតប្រាកដ ក៏មានទាបដែរ។

## ៤. ពាក្យសុំដែលបានដាក់តែម្នាក់ឯងដោយផ្អែកតាមសាលក្រម សាលដីកា

(១) ភាពចាំបាច់នៃពាក្យសុំដែលបានធ្វើនិងដាក់តែម្នាក់ឯង

យ៉ាងណាមិញ នៅក្នុងករណីដែលមិនអាចធ្វើនិងដាក់ពាក្យសុំរួមគ្នាបានដោយសារតែគ្មានការសហការពីបុគ្គលមានកាតព្វកិច្ចចុះបញ្ជីចំពោះការធ្វើនិងដាក់ពាក្យសុំចុះបញ្ជី តើគួរតែធ្វើដូចម្ដេចទៅ? ចំពោះករណីនេះ ប្រសិនបើមើលតាមគោលការណ៍នៃពាក្យសុំដែលបានធ្វើនិងដាក់រួមគ្នាវិញ នឹងក្លាយទៅជាករណីដែលមិនអាចធ្វើការចុះបញ្ជីជារៀងរហូតបាត់ទៅហើយ។

ប៉ុន្តែ បើការធ្វើបែបនេះ វានឹងធ្វើឲ្យបាត់បង់នូវអត្ថន័យនៃអត្ថិភាពនៃការចុះបញ្ជី (បើសិនជាទំនាក់ទំនងសិទ្ធិពិតប្រាកដត្រូវបានឆ្លុះបញ្ចាំង នាំឲ្យមានការចូលរួមចំណែកដល់សុវត្ថិភាពនៃប្រតិបត្តិការជំនួញ)។ ត្រូវតែមានការជៀសវាងនូវការទុកចោលការចុះបញ្ជី ដែលមិនមានការឆ្លុះបញ្ចាំងអំពីទំនាក់ទំនងសិទ្ធិពិតប្រាកដ ដោយមូលហេតុថា ភាគីម្ខាងទៀតមិនសហការចំពោះការធ្វើ និង ដាក់ពាក្យសុំចុះបញ្ជី។

ហេតុនេះ ក្នុងករណីដូចខាងលើទើបនាំឲ្យកើតឡើងនូវភាពចាំបាច់ដែលអាចធ្វើនិងដាក់ពាក្យសុំចុះបញ្ជីដែលអាចធ្វើតែម្នាក់ឯងបាន។

ចុះលក្ខខណ្ឌបែបណាខ្លះទើបអាចធ្វើការទទួលស្គាល់នូវការធ្វើនិងដាក់ពាក្យសុំចុះបញ្ជីតែម្នាក់ឯងបាន?

(២) លក្ខខណ្ឌនៃពាក្យសុំដែលបានធ្វើនិងដាក់តែម្នាក់ឯង

ដើម្បីជៀសវាងការចុះបញ្ជីមិនពិត ចាំបាច់ត្រូវមានការបង្ហាញឆន្ទៈជំនួសឲ្យការបង្ហាញឆន្ទៈអំពីការធ្វើពាក្យសុំចុះបញ្ជីរបស់បុគ្គលមានកាតព្វកិច្ចចុះបញ្ជីទៅបុគ្គលមានសិទ្ធិចុះបញ្ជី ។

ការបង្ហាញឆន្ទៈនោះគឺជា "សាលក្រម សាលដីកា ឬ ដីកាសម្រេច ដែលបានចូលជាស្ថាពរ ឬ លិខិតអនុវត្តដោយផ្អែកលើការផ្សះផ្សា ឬ ការទទួលស្គាល់នូវការទាមទារ ដែលលិខិតអនុវត្តទាំង

អស់នោះ បង្គាប់ឲ្យមាននីតិវិធីចុះបញ្ជី" (កថាខណ្ឌទី ២ ប្រការ ១០)។[1]

(៣) ខ្លឹមសារដែលត្រូវសរសេរនៅក្នុងសេចក្តីសម្រេចបញ្ចប់នៃសាលក្រម សាលដីកា

ដូច្នេះ តើចាំបាច់ត្រូវតែសរសេរអ្វីខ្លះនៅក្នុង "សាលក្រម សាលដីកាដែលបានចូលជាស្ថាពរ" "ដែលជាលិខិតអនុវត្ត" "បង្គាប់ឲ្យមាននីតិវិធីចុះបញ្ជី"។

សាលក្រម សាលដីកាដែលបានចូលជាស្ថាពរ គឺជាការជំនួសនូវការបង្ហាញឆន្ទៈអំពីការធ្វើពាក្យសុំចុះបញ្ជីរបស់បុគ្គលមានកាតព្វកិច្ចចុះបញ្ជី ដូច្នេះហើយ នៅក្នុងសាលក្រម សាលដីកានោះចាំបាច់ត្រូវតែសរសេរទាំងអស់អំពីចំណុចដែលត្រូវសរសេរនៅក្នុងលិខិតពាក្យសុំចុះបញ្ជី។

ម្យ៉ាងវិញទៀត ដោយសារតែអានុភាពនៃអាជ្ញាអស់ជំនុំនៃសាលក្រមមានចំពោះតែខ្លឹមសារដែលបានវិនិច្ឆ័យនៅក្នុងសេចក្តីសម្រេចបញ្ចប់តែប៉ុណ្ណោះ ហើយមិនមានចំពោះសេចក្តីវិនិច្ឆ័យនៅក្នុងសំអាងហេតុនៃសាលក្រមទេ (កថាខណ្ឌទី ៣ មាត្រា ១៩៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ដូច្នេះហើយ ត្រូវតែបង្ហាញឲ្យបានច្បាស់លាស់ទាំងអស់អំពីចំណុចដែលត្រូវសរសេរនៅក្នុងលិខិតពាក្យសុំចុះបញ្ជីដាក់នៅក្នុងសេចក្តីសម្រេចបញ្ចប់នៃសាលក្រម សាលដីកា។

នៅក្នុងមាត្រា ២៦ មានចែងអំពីបទប្បញ្ញត្តិទូទៅ អំពីចំណុចដែលត្រូវសរសេរនៅក្នុងលិខិតពាក្យសុំចុះបញ្ជី ហើយចាប់ពីមាត្រា ២៨ តទៅ គឺចែងអំពីបទប្បញ្ញត្តិនីមួយៗអំពីប្រភេទនៃពាក្យសុំចុះបញ្ជី។ ខ្លឹមសារដែលមានចែងនៅក្នុងបទប្បញ្ញត្តិទាំងនេះ នឹងក្លាយទៅជាខ្លឹមសារដែលត្រូវយកមកសរសេរនៅក្នុងខ្លឹមសារនៃសេចក្តីសម្រេចបញ្ចប់នៃសាលក្រម សាលកដីកា (យោង "ពាក្យសុំចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិ")។

សាលក្រម សាលដីកាដែលមានការសរសេរអំពីចំណុចដូចគ្នាទៅនឹងចំណុចដែលត្រូវសរសេរនៅក្នុងលិខិតពាក្យសុំចុះបញ្ជីខាងលើនេះ នឹងជំនួសឲ្យការបង្ហាញឆន្ទៈអំពីការធ្វើពាក្យសុំចុះបញ្ជីរបស់

---

[1] អាចធ្វើការដាក់ពាក្យសុំតែម្នាក់ឯង (※អត្ថន័យនៃពាក្យថា " ការដាក់ពាក្យសុំ") បាន លុះត្រាតែ នៅក្នុងសាលក្រម ឬ សាលដីកា "**បង្គាប់ឲ្យមាននីតិវិធីចុះបញ្ជី**" ដែរ។ "បង្គាប់ឲ្យមាននីតិវិធីចុះបញ្ជី" គឺមានន័យថា " បង្គាប់អំពីការបង្ហាញឆន្ទៈរបស់ចុងចម្លើយ (បុគ្គលមានកាតព្វកិច្ចចុះបញ្ជី) ទៅដើមចោទ (បុគ្គលមានសិទ្ធិចុះបញ្ជី) អំពីការធ្វើពាក្យសុំចុះបញ្ជី"។

ចំពោះសាលក្រម សាលដីកាដែលសរសេរថា "បង្គាប់ឲ្យចុងចម្លើយប្រគល់ដីទៅដើមចោទ" ឬ "បង្គាប់ឲ្យចុងចម្លើយប្រគល់វិញ្ញាបនបត្រសំគាល់ម្ចាស់អចលនវត្ថុទៅដើមចោទ" ឬ "បញ្ជាក់ថាដើមចោទមានកម្មសិទ្ធិលើដី" គឺមិនអាចធ្វើការដាក់ពាក្យសុំចុះបញ្ជីតែម្នាក់ឯង (※អត្ថន័យនៃពាក្យថា " ការដាក់ពាក្យសុំ") បានទេ។

បុគ្គលមានកាតព្វកិច្ចចុះបញ្ជីទៅបុគ្គលមានសិទ្ធិចុះបញ្ជី។

(៤) បញ្ហានៅក្នុងការអនុវត្តជាក់ស្តែង

សេចក្តីសម្រេចបញ្ចប់ដែលសរសេរថា "បង្គាប់ឲ្យមន្ត្រីចុះបញ្ជីចុះចុះបញ្ជីទៅឲ្យដើមចោទ" គឺជាការយល់ច្រឡំ។[2]

រដ្ឋបាលសុរិយោដីមានករណីយកិច្ចចុះបញ្ជី ក្នុងករណីដែលមានពាក្យសុំដែលបានធ្វើនិងដាក់រួមគ្នាដែលមានភាពត្រឹមត្រូវតាមច្បាប់ (ពាក្យសុំដែលបានធ្វើនិងដាក់រួមគ្នាដោយបុគ្គលមានសិទ្ធិ និង បុគ្គលមានកាតព្វកិច្ច) ។ បើនិយាយផ្ទុយមកវិញ គឺមានន័យថា រដ្ឋបាលសុរិយោដីពុំមានករណីយកិច្ចចុះបញ្ជីទេ បើពុំមានពាក្យសុំដែលបានធ្វើនិងដាក់រួមគ្នាដោយភាពត្រឹមត្រូវតាមច្បាប់ (យោងតាម ចំណុច ២ ខាងលើ)។

រឿងក្តីភាគច្រើន ដោយសារតែចុងចម្លើយ (បុគ្គលមានកាតព្វកិច្ចចុះបញ្ជី) មិនចូលរួមសហការក្នុងការធ្វើ និង ដាក់ពាក្យសុំចុះបញ្ជី ដូច្នេះហើយទើបកើតមានជាបណ្តឹង ហើយពុំមានពាក្យសុំចុះបញ្ជីដែលបានធ្វើនិងដាក់រួមគ្នាដោយបុគ្គលមានសិទ្ធិ និង បុគ្គលមានកាតព្វកិច្ចតាំងពីដំបូង។ ដូច្នេះហើយ រដ្ឋបាលសុរិយោដីពុំមានករណីយកិច្ចចុះបញ្ជីទេ។ ដរាបណាគ្មានការធ្វើនិងដាក់ពាក្យសុំដែលមានភាពត្រឹមត្រូវតាមច្បាប់ទេ គឺមិនគួរឲ្យកើតមានករណីដែលតុលាការបង្គាប់ឲ្យរដ្ឋបាលសុរិយោដីមានករណីយកិច្ចចុះបញ្ជីឡើយ។

---

[2] គេបានដឹងថា នៅរដ្ឋបាលសុរិយោដីមួយចំនួន កំពុងតែធ្វើការអនុវត្តដោយមិនទទួលយកនូវការដាក់ពាក្យសុំចុះបញ្ជីដែលផ្អែកតាមសាលក្រម សាលដីកាទេ ប្រសិនបើនៅក្នុងសេចក្តីសម្រេចបញ្ចប់មិនបានសរសេរថា " បង្គាប់ឲ្យមន្ត្រីចុះបញ្ជីចុះបញ្ជីឲ្យទៅដើមចោទ"។ ប៉ុន្តែ ការអនុវត្តបែបនេះ គឺផ្ទុយទៅនឹងប្រកាសអន្តរក្រសួងដែលបានបញ្ជាក់ច្បាស់ដូចសរសេរនៅក្នុងខ្លឹមសារនៃតួសេចក្តីខាងលើ។

ឧទាហរណ៍ថា បើសិនជាចៅក្រមបានយល់ថា "ដើម្បីឲ្យគេចុះបញ្ជីឲ្យបាន មានតែត្រូវចេញសេចក្តីសម្រេចបញ្ចប់ដែលផ្ទុយនឹងប្រកាសអន្តរក្រសួង ព្រោះបើចេញសេចក្តីសម្រេចបញ្ចប់ផ្អែកតាមប្រកាសអន្តរក្រសួង គេនឹងមិនព្រមចុះបញ្ជីឲ្យទេ" ការយល់បែបនោះ គឺមានន័យថា ជាការមើលរំលងនូវអត្ថិភាពនៃប្រកាសអន្តរក្រសួង ហេតុនេះក្នុងនាមចៅក្រមដែលសម្រេចសេចក្តីដោយការគោរពច្បាប់ មិនគួរឲ្យមានករណីបែបនេះទេ។ សូមធ្វើការកែតម្រូវចំណុចនេះឲ្យបានឆាប់រហ័ស។

គេយល់ថា ចំពោះការអនុវត្តជាក់ស្តែងដែលរដ្ឋបាលសុរិយោដីមានការយល់ច្រឡំ នឹងចង់មានការរៀបចំកែលម្អតាមរយៈក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់នៅពេលក្រោយ។ នៅពេលក្រោយនឹងមានការស្នើសុំការកែលម្អពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ប៉ុន្តែ ជាដំបូងសូមឲ្យចៅក្រមដែលចេញសាលក្រម សាលដីកា អនុវត្តឲ្យមានភាពត្រឹមត្រូវតាមច្បាប់ជាមុនសិន។

ម្យ៉ាងទៀត គេគិតថា មន្ត្រីចុះបញ្ជីមិនមែនជាចុងចម្លើយនៅក្នុងនីតិវិធីបណ្តឹងតាំងពីដើម ប៉ុន្តែ បែរជាតុលាការបង្គាប់នូវករណីយកិច្ចទៅកាន់បុគ្គលនោះដែលមិនមែនជាចុងចម្លើយទៅវិញ ដែលជាការផ្ទុយទៅនឹងគោលការណ៍ធំ (សិទ្ធិទាមទារឲ្យសាកសួរ គោលការណ៍ចំពោះមុខ) (មាត្រា ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី) នៅក្នុងនីតិវិធីរដ្ឋប្បវេណី ដែលមិនត្រូវបានគេអនុញ្ញាតឲ្យកើតមានឡើយ។ នៅក្នុងនីតិវិធីបណ្តឹងដែលមន្ត្រីចុះបញ្ជីមិនមែនជាចុងចម្លើយ អានុភាពនៃសាលក្រមដែលបានចូលជាស្ថាពរនោះ ក៏មិនកើតមានចំពោះមន្ត្រីចុះបញ្ជីដែរ (យោង មាត្រា ១៩៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

យ៉ាងណាមិញ អ្នកដែលមានករណីយកិច្ចចុះបញ្ជីមិនមែនជាមន្ត្រីសុរិយោដីទេ ដែលចំណុចនេះគឺជាការយល់ច្រឡំផងដែរ ព្រោះរដ្ឋបាលសុរិយោដីទើបជាអ្នកមានករណីយកិច្ចចុះបញ្ជី ។

## ៥. វិធីធ្វើនិងដាក់ពាក្យសុំចុះបញ្ជីដែលផ្អែកតាមលិខិតសាលក្រម សាលដីកា

(១) ការសន្មតជាមុន

"កថាខណ្ឌទី ២ ប្រការ ៦"

រដ្ឋបាលសុរិយោដីរាជធានី ខេត្ត ដែលមានសមត្ថកិច្ចចុះបញ្ជី ត្រូវចុះបញ្ជីទៅតាមចំណុចដែលមាននៅក្នុងពាក្យសុំរបស់អ្នកដាក់ពាក្យសុំ ឬ លិខិតផ្ទុកផ្តាក់។

→ ដើម្បីធ្វើការចុះបញ្ជីបាន ចាំបាច់ត្រូវមានពាក្យសុំ ឬ លិខិតផ្ទុកផ្តាក់។

ដូច្នេះ តើការចុះបញ្ជីដោយផ្អែកតាមសាលក្រម សាលដីកា ធ្វើឡើងតាមរយៈពាក្យសុំ ឬ លិខិតផ្ទុកផ្តាក់?

"ប្រការ ៤០ នៃប្រកាសអន្តរក្រសួងស្តីពី ការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី"

ចំពោះការចុះបញ្ជីអំពីការបង្កើត ការកែប្រែ និង ការលុបនូវសិទ្ធិតាមសាលក្រម សាលដីកា ដីកាសម្រេច ឬ លិខិតអនុវត្តដោយផ្អែកលើការផ្សះផ្សា ឬ ការទទួលស្គាល់នូវការទាមទារ ភាគីឈ្នះក្តី ឬ ភាគីដែលមានកំណត់ហេតុសះជា ឬ កំណត់ហេតុទទួលស្គាល់នូវការទាមទារ ត្រូវដាក់ពាក្យសុំទៅស្ថាប័នមានសមត្ថកិច្ច ដោយភ្ជាប់ជាមួយនូវអនុសារសាលក្រម សាលដីកា ដីកាសម្រេច ឬ លិខិតអនុវត្តដោយផ្អែកលើការផ្សះផ្សា ឬ ការទទួលស្គាល់នូវការទាមទារ ព្រមទាំងឯកសារដែលចាំបាច់ផ្សេងទៀត។

→ ចំពោះការចុះបញ្ជីដែលធ្វើឡើងដោយផ្អែកតាមសាលក្រម សាលដីកា ភាគីចាំបាច់ត្រូវតែធ្វើ និងដាក់ពាក្យសុំ។

តុលាការមិនចាំបាច់ធ្វើការផ្ទុកផ្ដាក់ ឬ ធ្វើការអនុវត្តដោយបង្ខំនូវសាលក្រមដែលបង្គាប់ឲ្យមាននីតិវិធីចុះបញ្ជីជាដើមទេ។

(២) វិធីធ្វើនិងដាក់ពាក្យសុំ

បុគ្គលមានសិទ្ធិចុះបញ្ជីត្រូវធ្វើពាក្យសុំចុះបញ្ជី (កថាខណ្ឌទី ១ ប្រការ ៦) តែម្នាក់ឯងម្ដងទៀត (ពុំមានហត្ថលេខា ឬ ស្នាមម្រាមដៃរបស់បុគ្គលមានកាតព្វកិច្ចចុះបញ្ជី) ហើយភ្ជាប់សាលក្រម សាលដីកាដែលបានចូលជាស្ថាពរដែលមានខ្លឹមសារដូចគ្នានឹងពាក្យសុំនោះ (ប្រការ ២៧) ហើយត្រូវដាក់ពាក្យចុះបញ្ជីតែម្នាក់ឯង (កថាខណ្ឌទី ២ ប្រការ ១០)។

ហេតុអ្វីបានជាចាំបាច់ត្រូវមានឯកសារលោយលក្ខណ៍អក្សរដែលមានខ្លឹមសារដូចគ្នា (លិខិតពាក្យសុំចុះបញ្ជី និង សាលក្រមដែលបានចូលជាស្ថាពរ)? មូលហេតុ គឺដោយសារតែអាចមានការយល់ឃើញថា " ពាក្យសុំចុះបញ្ជី គឺជាការបង្ហាញឆន្ទៈអំពីការធ្វើពាក្យសុំចុះបញ្ជីរបស់បុគ្គលមានសិទ្ធិចុះបញ្ជី" ហើយគេបានសន្មតថា "សាលក្រម សាលដីកាដែលបានចូលជាស្ថាពរ គឺជាការបង្ហាញឆន្ទៈអំពីការធ្វើពាក្យសុំចុះបញ្ជីរបស់បុគ្គលមានកាតព្វកិច្ចចុះបញ្ជី" (កថាខណ្ឌទី ១ មាត្រា ៥២៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ដូច្នេះហើយផ្អែកតាមលិខិតលាយលក្ខណ៍អក្សរដែលមានខ្លឹមសារដូចគ្នា ចំនួន ២ នាំឲ្យគេអាចយល់បានថា ឆន្ទៈរបស់បុគ្គលមានសិទ្ធិចុះបញ្ជី និង បុគ្គលមានកាតព្វកិច្ចចុះបញ្ជីចាប់ផ្ដើមមានភាពត្រូវគ្នាទៅលើការធ្វើពាក្យសុំចុះបញ្ជី។ ដូច្នេះហើយ បើសិនជាផ្អែកទៅលើលិខិតដែលខ្លឹមសារដូចគ្នាវិញ ក៏គេមិនអនុញ្ញាតឲ្យមានការសង្ខេបនូវខ្លឹមសារមួយផ្នែកណាឡើយ។

## ៦. សេចក្ដីបញ្ចប់

គេបានឮថានៅក្នុងបណ្ដឹងដែលពាក់ព័ន្ធអចលនវត្ថុភាគច្រើន គឺមានវិវាទដែលពាក់ព័ន្ធនឹងវិញ្ញាបនបត្រសំគាល់ម្ចាស់អលនវត្ថុ (បណ្ដឹងទាមទារឲ្យបញ្ជាក់អំពីមោឃភាពនៃវិញ្ញាបនបត្រសំគាល់ម្ចាស់អចលនវត្ថុជាដើម) ដែលឃ្លាតចេញឆ្ងាយពីប្រធានបទអំពីនីតិវិធីនៃការចុះបញ្ជីអចលនវត្ថុ។

តើបណ្ដឹងទាមទារឲ្យបញ្ជាក់អំពីមោឃភាពនៃវិញ្ញាបនបត្រសំគាល់ម្ចាស់អចលនវត្ថុ មានភាពត្រឹមត្រូវផ្អែកតាមនីតិវិធីបណ្ដឹងរដ្ឋប្បវេណីដែរទេ?

ដើមឡើយ តើវិញ្ញាបនបត្រសំគាល់ម្ចាស់អលនវត្ថុគឺជាអ្វី?

សូមឲ្យសិក្ខាកាមទាំងអស់ពិចារណាឲ្យបានល្អិតល្អន់ទៅលើសំណួរទាំង ២នេះ។

វិញ្ញាបនបត្រសំគាល់ម្ចាស់អលចនវត្ថុ គឺជាលិខិតបញ្ជាក់ដែលកំណត់អំពីកម្មសិទ្ធិករនៃអចលនវត្ថុ (មាត្រា ២៤១ និង មាត្រា ២៤២ នៃច្បាប់ភូមិបាល)។ ពោលគឺមានន័យថា វាគឺជាលិខិតដែលបញ្ជាក់ថា តើកម្មសិទ្ធិនៃអចលនវត្ថុជារបស់អ្នកណា?

តើយើងអាចនិយាយបានថា បណ្តឹងទាមទារឲ្យបញ្ជាក់អំពីមោឃភាពនៃ "លិខិត" គឺជា "វិវាទតាមផ្លូវច្បាប់" (មាត្រា ៧៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី)ដែរទេ? បើគិតអំពី "វិវាទតាមផ្លូវច្បាប់" គួរតែជាបណ្តឹងដែលទាមទារឲ្យបញ្ជាក់អំពីកម្មសិទ្ធិដែលបានបង្ហាញដោយលិខិតនោះទៅវិញទេ ទើបជាការត្រឹមត្រូវ។ ហើយ "ទំនាក់ទំនងសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តនាពេលបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់" ដែលសាលក្រម ឬ សាលដីកាត្រូវកំណត់ជាស្ថាពរ ក៏ប្រាកដជា កម្មសិទ្ធិ ដែរ។ ដូច្នេះ គេមិនអាចនិយាយបានថា "លិខិតត្រូវមោឃៈ" គឺជាទំនាក់ទំនងគតិយុត្តឡើយ។

ដោយសារតែបញ្ហាខាងលើនេះគឺឃ្លាតឆ្ងាយពីប្រធានបទនៃសិក្ខាសាលាលើកនេះ ហេតុនេះហើយ វាគ្មិនគ្រាន់តែចង់ចូលរួមចែករំលែកគំនិតយោបល់ខាងលើនេះដល់សិក្ខាកាមតែប៉ុណ្ណោះ។ ប្រសិនបើសិក្ខាកាមទាំងអស់គ្នាយល់ឃើញថា វិវាទដែលពាក់ព័ន្ធនឹងប័ណ្ណកម្មសិទ្ធិ គឺជាវិវាទដែលផ្អែកតាមក្រមនីតិវិធីរដ្ឋប្បវេណី ហើយមានភាពត្រឹមត្រូវតាមច្បាប់ ដូច្នេះ សូមសាកល្បងពិចារណាទៅលើទល្វីករណ៍នៃចំណុចទាំងនោះ។

សូមអរគុណ

# គោលការណ៍នៃការដាក់ (បង្កើតនិងដាក់) ពាក្យសុំរួមគ្នា

មាត្រា ៥៥៤ ក្រម/រដ្ឋ

**បុគ្គលមានសិទ្ធិចុះបញ្ជី** ---- X

ប្រការ ៤-៣ ប្រ.អន្ត.ចុះ.ក្រម/រដ្ឋ

អ្នកទិញ

Y ---- **បុគ្គលមានកាតព្វកិច្ចចុះបញ្ជី**

មាត្រា ៥៣០ ក្រម/រដ្ឋ

ប្រការ ៤-៤ ប្រ.អន្ត.ចុះ.ក្រម/រដ្ឋ

អ្នកលក់



ដី L



ការចុះបញ្ជី

"ការបង្ហាញឆន្ទៈ"

តោះដាក់ពាក្យសុំចុះបញ្ជីផ្ទេរកម្មសិទ្ធិ !!

ប្រការ ៦-១ និង ប្រការ ១០-១ ប្រ.អន្ត.ចុះ.ក្រម/រដ្ឋ

"ការបង្ហាញឆន្ទៈ"

តោះដាក់ពាក្យសុំចុះបញ្ជីផ្ទេរកម្មសិទ្ធិ !!

ពាក្យសុំចុះបញ្ជីផ្ទេរកម្មសិទ្ធិ

X និង Y

(ប្រការ ២៨ ប្រ.អន្ត.ចុះ.ក្រម/រដ្ឋ)

ឯកសារភ្ជាប់ (ប្រការ ២៧ ប្រ.អន្ត.ចុះ.ក្រម/រដ្ឋ)



X និង Y រួមគ្នាទៅដាក់នៅរដ្ឋបាលសុរិយោដី

ប្រការ ៥-១ និង ប្រការ ១០-១ ប្រ.អន្ត.ចុះ.ក្រម/រដ្ឋ

ផ្អែកតាមច្បាប់ នឹងកើតមានកាតព្វកិច្ចចុះបញ្ជីចំពោះរដ្ឋបាលសុរិយោដី

ប្រការ ៦-២ ប្រ.អន្ត.ចុះ.ក្រម/រដ្ឋ

# ការដាក់ពាក្យសុំ(ដាក់)តែម្នាក់ឯងដោយផ្អែកតាមសាលក្រម សាលដីកា (ករណីលើកលែង)

មាត្រា ៥៥៤ ក្រម/រដ្ឋ $$$

មាត្រា ៥៣០ ក្រម/រដ្ឋ

បុគ្គលមានសិទ្ធិចុះបញ្ជី

ប្រការ ៤-៣ ប្រ.អន្ត.ចុះ.ក្រម/រដ្ឋ

X

អ្នកទិញ

Y

អ្នកលក់

បុគ្គលមានកាតព្វកិច្ចចុះបញ្ជី

ប្រការ ៤-៤ ប្រ.អន្ត.ចុះ.ក្រម/រដ្ឋ



ដី L

ប្រការ ៦-១ ប្រ.អន្ត.ចុះ.ក្រម/រដ្ឋ

មាត្រា ៥២៩ ក្រមនីតិ/រដ្ឋ



ការចុះបញ្ជី

"ការបង្ហាញឆន្ទៈ"

តោះដាក់ពាក្យសុំចុះបញ្ជីផ្ទេរកម្មសិទ្ធិ !!

"ការបង្ហាញឆន្ទៈ"

តោះដាក់ពាក្យសុំចុះបញ្ជីផ្ទេរកម្មសិទ្ធិ !!

សាលក្រម សាលដីកា

មាត្រា ៥២៩ ក្រមនីតិ/រដ្ឋ

ពាក្យសុំចុះបញ្ជីផ្ទេរក

X និង

(ប្រការ ២៨ ប្រ.អន្ត.ចុះ.ក្រម/រដ្ឋ)

ឯកសារភ្ជាប់ (ប្រការ ២៧ ប្រ.អន្ត.ចុះ.ក្រម/រដ្ឋ)

X ទៅតែម្នាក់ឯងដាក់នៅរដ្ឋបាលសុរិយោដី

ប្រការ ៥-១ និង ប្រការ ១០-២ ប្រ.អន្ត.ចុះ.ក្រម/រដ្ឋ



ផ្អែកតាមច្បាប់ នឹងកើតមានកាតព្វកិច្ចចុះបញ្ជីចំពោះរដ្ឋបាលសុរិយោដី

ប្រការ ៦-២ ប្រ.អន្ត.ចុះ.ក្រម/រដ្ឋ

# រឿងក្ដីទាមទារ[1]ឲ្យធ្វើនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិ ដោយផ្អែកលើកិច្ចសន្យាលក់ទិញ

[1] ការទាមទាររបស់ X គឺជាការទាមទារនូវការធ្វើនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិ ហើយអ្នកដែលអនុវត្តនូវការចុះបញ្ជី គឺជារដ្ឋបាលសុរិយោដី (ប្រការ ៩០ នៃប្រកាសអន្តរក្រសួងស្ដីពីការចុះបញ្ជីអំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី) មិនមែនជា Yទេ។ Y មានករណីយកិច្ចធ្វើនីតិវិធីដាក់ពាក្យសុំចុះបញ្ជី (កថាខណ្ឌទី ១ ប្រការ ១០ នៃប្រកាសដដែល) ពោល គឺ Y ពុំមានករណីយកិច្ចលើសពីការបង្ហាញឆន្ទៈអំពីការដាក់ពាក្យសុំចុះបញ្ជីទេ ដូច្នេះហើយ ការទាមទារពី X ទៅ Y មិនមែនជាការទាមទារអំពី "ការចុះបញ្ជី" ទេ ប៉ុន្តែ គឺជាការទាមទារអំពី "នីតិវិធី" នៃការចុះបញ្ជីនោះ។

○ ការអះអាងរបស់ X

នៅថ្ងៃទី ១ ខែ សីហា ឆ្នាំ ២០១៨ ខ្ញុំបានទិញដី (ដីលំនៅដ្ឋាន ទំហំ ១២០ $m^2$ ក្បាលដីលេខ ១៣០៦ ដែលមានទីតាំងស្ថិតនៅផ្លូវលេខ ១០២ ភូមិ ៣ សង្កាត់ ជ្រោយចង្វារ ខណ្ឌ ជ្រោយចង្វារ រាជធានីភ្នំពេញ) (តទៅនេះហៅថា " ដី L ") ដែលជាកម្មសិទ្ធិរបស់ Y នៅក្នុងតម្លៃ ២០០.០០០ (ពីរសែន) ដុល្លារអាមេរិក ពី Y (តទៅហៅថា "កិច្ចសន្យាលក់ទិញនៃរឿងក្តីនេះ") ហើយបានធ្វើលិខិតយថាភូតនៅថ្ងៃនោះផងដែរ។ នៅពេលនោះ ខ្ញុំ និង Y បានព្រមព្រៀងគ្នាអំពីការបង់ប្រាក់កក់ចំនួន ២០.០០០ (ពីរម៉ឺន) ដុល្លារអាមេរិក ហើយខ្ញុំបានប្រគល់ឲ្យ Y ចំនួន ២០.០០០ (ពីរម៉ឺន) ដុល្លារអាមេរិក។ នៅក្នុងកិច្ចសន្យានៃរឿងក្តីនេះ បានកំណត់ថា រយៈពេល១ខែក្រោយដែលត្រូវនឹងថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ២០១៨ Y ត្រូវប្រគល់ និង ធ្វើនីតិវិធីចុះបញ្ជីនៃដី L ដែលជាថ្នូរនឹងការបង់ប្រាក់ថ្លៃលក់ចំនួន ២០០.០០០ (ពីរសែន) ដុល្លារអាមេរិករបស់ខ្ញុំ ហើយចំពោះប្រាក់ចំនួន ២០.០០០ (ពីរម៉ឺន) ដុល្លារអាមេរិកជាប្រាក់កក់ដែលខ្ញុំបានប្រគល់ឲ្យមុននោះនឹងត្រូវយកមកគណនាធ្វើជាថ្លៃលក់ទិញមួយភាគ។

រយៈពេល ៣ សប្តាហ៍ក្រោយពីបានចុះកិច្ចសន្យានៃរឿងក្តីនេះដែលត្រូវនឹងថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១៨ Y ស្រាប់តែយកប្រាក់ចំនួន ៤០.០០០ ( បួនម៉ឺន) ដុល្លារអាមេរិកមកដល់ផ្ទះរបស់ខ្ញុំ ហើយបានអះអាងតែម្នាក់ឯងថា "ខ្ញុំនឹងរំលាយកិច្ចសន្យានៃរឿងក្តីនេះដោយសារតែខ្ញុំរកបានអ្នកដែលទិញដី L ក្នុងតម្លៃខ្ពស់ជាងនេះ" ។ ខ្ញុំបានភ្ញាក់ផ្អើលនឹងរឿងនោះភ្លាមៗ ហើយដោយសារតែខ្ញុំមិនអាចទទួលយកនូវការអះអាងរបស់ Y បែបនោះទេ ទើបខ្ញុំមិនបានទទួលប្រាក់ចំនួន ៤០.០០០ (បួនម៉ឺន) ដុល្លារអាមេរិកដែល Y បានយកមក។

Y មិនព្រមប្រគល់ និង ធ្វើនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិទាំងមូលលើដី L ទេ ទោះបីជាថ្ងៃទី ១ ខែកញ្ញា ឆ្នាំ ២០១៨ ដែលបានកំណត់នៅក្នុងកិច្ចសន្យានៃរឿងក្តីនេះបានកន្លងផុតក៏ដោយ។

ហេតុនេះហើយ ខ្ញុំទាមទារឲ្យ Y ប្រគល់ដី L និង ធ្វើនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិទាំងមូលដោយមូលហេតុនៃកិច្ចសន្យាលក់ទិញនៃរឿងក្តីនេះ។

- ការអះអាងរបស់ Y

ខ្ញុំទទួលស្គាល់ថា បានចុះកិច្ចសន្យានៃរឿងក្តីនេះជាមួយ X ហើយបានធ្វើលិខិតយថាភូត។

ប៉ុន្តែ រយៈពេល ២ សប្តាហ៍ក្រោយពីបានចុះកិច្ចសន្យានៃរឿងក្តីនេះ ដែលត្រូវនឹងថ្ងៃទី១៥ ខែ សីហា ឆ្នាំ ២០១៨ មានក្រុមហ៊ុនអចលនវត្ថុ Z ថា ចង់ទិញដី L ក្នុងតម្លៃ ៣០០.០០០ (បីសែន) ដុល្លារអាមេរិក ហេតុនេះ ខ្ញុំបានសម្រេចចិត្តថា លក់ដី L ឲ្យទៅ Z ដោយធ្វើការរំលាយកិច្ចសន្យាលក់ទិញនៃរឿងក្តីនេះជាមួយ X ។ ដូច្នេះហើយ នៅថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១៨ ខ្ញុំបានទៅផ្ទះរបស់ X ហើយបានផ្តល់ប្រាក់ចំនួន ៤០.០០០ (បួនម៉ឺន) ដុល្លារអាមេរិកដែលជាចំនួនទឹកប្រាក់ ២ ដងនៃប្រាក់ ២០.០០០ (ពីរម៉ឺន) ដុល្លារអាមេរិកជាប្រាក់កក់ដែលខ្ញុំបានទទួលរួចរាល់ ព្រមទាំងបានបង្ហាញឆន្ទៈថា រំលាយកិច្ចសន្យានៃរឿងក្តីនេះ។ ខ្ញុំមានអារម្មណ៍ថា សោកស្តាយចំពោះ X ប៉ុន្តែ កិច្ចសន្យានៃរឿងក្តីនេះ ត្រូវបានរំលាយប្រកបដោយសុពលភាព។

អាស្រ័យហេតុនេះ ខ្ញុំមិនអាចយល់ព្រមចំពោះការទាមទាររបស់ X ទេ។

1. 8. 2018 ការចុះកិច្ចសន្យាលក់ទិញនៃរឿងក្តីនេះ
- កម្មសិទ្ធិលើដី L
- ប្រាក់ថ្លៃលក់ 200.000 $
- 1. 9. 2018 ការបង់ប្រាក់ ⇔ ការប្រគល់ដីL និង ធ្វើនីតិវិធីចុះបញ្ជី

ការបង្កើតលិខិតយថាភូត

ការចុះកិច្ចសន្យាប្រាក់កក់ និង ការប្រគល់ ( X→Y 20.000$ )

15. 8. 2018 Z បង្ហាញខ្លួន

22. 8. 2018 Y→X ការផ្តល់ប្រាក់ 40.000$
ការបង្ហាញឆន្ទៈថា នឹងរំលាយកិច្ចសន្យានៃរឿងក្តីនេះ នៅផ្ទះរបស់ X

1. 9. 2018

បច្ចុប្បន្ន

# ដ្យាក្រាមនៃរឿងក្តីទាមទារឲ្យចុះបញ្ជីផ្ទេរកម្មសិទ្ធិទាំងមូលដោយផ្អែកលើកិច្ចសន្យាលក់ទិញ

## មូលហេតុនៃការទាមទារ

Kg　កិច្ចសន្យាលក់ទិញ

| | | |
|---|---|---|
| a | X・Y　1.8.2018 កិច្ចសន្យាលក់ទិញ<br>ដី L<br>តម្លៃ 200.000$ | ○ |
| b | កិច្ចសន្យានៃចំណុច a ត្រូវបានធ្វើឡើងជាលិខិតយថាភូត | ○ |

## ការតវ៉ា

E　ការរំលាយកិច្ចសន្យាដោយការសងប្រាក់កក់

| | | |
|---|---|---|
| c | X・Y　1.8.2018 ព្រមព្រៀងអំពីការប្រគល់ប្រាក់ 20.000$ ជាប្រាក់កក់ | ○ |
| d | X→Y　1.8.2018 ប្រគល់ប្រាក់ 20.000$ | ○ |
| e | Y→X　22.8.2018 ផ្តល់ប្រាក់ជាក់ស្តែង 40.000$ | ○ |
| f | Y→X　22.8.2018 បង្ហាញឆន្ទៈថា រំលាយកិច្ចសន្យានៃចំណុច a | ○ |

# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

## ពាក្យបណ្តឹង

### ដើមចោទ

ឈ្មោះ ៖ X

អាសយដ្ឋាន ៖ ផ្ទះលេខ 00 ផ្លូវលេខ 00 សង្កាត់ទំនប់ទឹក ខណ្ឌចំការមន រាជធានីភ្នំពេញ[1]។

### អ្នកតំណាងដោយអាណត្តិ

លោក/លោកស្រី ៖ P

អាសយដ្ឋានការិយាល័យមេធាវី/ ក្រុមមេធាវី/ ក្រុមហ៊ុនមេធាវី ៖ ...............................

ការិយាល័យមេធាវី/ ក្រុមមេធាវី/ ក្រុមហ៊ុនមេធាវី ៖ .................................................

លេខទូរស័ព្ទ៖ ..........................................................................................................

**ទីកន្លែងបញ្ជូន** ៖ ការិយាល័យមេធាវី/ ក្រុមមេធាវី/ ក្រុមហ៊ុនមេធាវី.................[2]

### ចុងចម្លើយ

ឈ្មោះ ៖ Y

អាសយដ្ឋាន ៖ ផ្ទះលេខ 00 ផ្លូវលេខ 00 សង្កាត់មនោរម្យ ខណ្ឌ៧មករា រាជធានីភ្នំពេញ។

---

[1] ឈ្មោះ និងអាសយដ្ឋាន មានបញ្ញត្តិនៅក្នុងមាត្រា ៧៥ កថាខណ្ឌទី ២ ចំណុច ក នៃក្រមនីតិវិធីរដ្ឋប្បវេណី ប៉ុន្តែ ចំពោះចំណុចផ្សេងទៀត ដូចជា ថ្ងៃខែឆ្នាំកំណើតជាអាទិ៍ ជាចំណុចដែលពុំមានបញ្ញត្តិក្នុងច្បាប់ទេ។ ប៉ុន្តែ ក៏មានករណីដែលពុំអាចកំណត់អំពីភាគី តាមរយៈឈ្មោះ និង អាសយដ្ឋានបានផងដែរ ដូច្នេះ ត្រូវសរសេរចំណុចទាំងនោះក្នុងកម្រិតមួយដែលចាំបាច់ ដើម្បីអាចកំណត់អំពីភាគី។

[2] មាត្រា ២៤៩ និងមាត្រា ២៥០ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ ការដាក់ពីទីកន្លែងដែលត្រូវបញ្ជូន មិនមែនជាកាតព្វកិច្ចនោះទេ។ ប្រសិនបើពុំមានការសរសេរអំពីទីកន្លែងដែលត្រូវបញ្ជូនទេ ការបញ្ជូននឹងត្រូវធ្វើឡើងនៅលំនៅឋានរបស់ដើមចោទជាអាទិ៍។ ហេតុនេះ ក្នុងករណីដែលអ្នកតំណាងដោយអាណត្តិរបស់ដើមចោទមានបំណងធ្វើការបញ្ជូនទៅកាន់ទីកន្លែងណាផ្សេងក្រៅពីលំនៅដ្ឋានរបស់ដើមចោទជាអាទិ៍ គឺមានភាពចំបាច់ក្នុងការសរសេរអំពីទីកន្លែងដែលត្រូវបញ្ជូននៅក្នុងលិខិតពាក្យបណ្តឹងជាអាទិ៍។

**សូមគោរពជូន**

**លោកប្រធានសាលាដំបូងរាជធានីភ្នំពេញ**[3]

**ក. ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ**[4] **៖**

**(១)** បង្គាប់ឲ្យចុងចម្លើយប្រគល់អចលនវត្ថុដែលបានកត់ត្រាក្នុងបញ្ជីឧបសម្ព័ន្ធ [5] ឲ្យទៅដើមចោទ។

**(២)** បង្គាប់ឲ្យចុងចម្លើយធ្វើនីតិវិធីចុះបញ្ជីអចលនវត្ថុដែលបានកត់ត្រាក្នុងបញ្ជីឧបសម្ព័ន្ធឲ្យទៅដើមចោទ។ [6]

**(៣)** ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ចុងចម្លើយ។[7]

---

[3] ការដាក់ពាក្យបណ្ដឹងត្រូវធ្វើទៅតុលាការដែលមានសមត្ថកិច្ច (សមត្ថកិច្ចសាលាជម្រះក្ដី) (មាត្រា ៨ មាត្រា ៩ ជាអាទិ៍នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ ដោយសារតែលំនៅឋានរបស់ចុងចម្លើយ និង កន្លែងដែលអចលនវត្ថុស្ថិតនៅ គឺនៅរាជធានីភ្នំពេញទាំងពីរ ដូច្នេះ តុលាការដែលមានសមត្ថកិច្ច គឺសាលាដំបូងរាជធានីភ្នំពេញ ( ក្រមនីតិវិធិរដ្ឋប្បវេណីមាត្រា ៨ ចំណុច ក និង មាត្រា ៩ ចំណុច ឆ)។

[4] ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារ គឺជាចំណុចដែលចាំបាច់ត្រូវសរសេរនៅក្នុងពាក្យបណ្ដឹង (មាត្រា ៧៥ កថាខណ្ឌទី ២ ចំណុច ខ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

[5] ឧបសម្ព័ន្ធ ជាឯកសារមួយដែលបានបង្កើតដើម្បីដាក់បញ្ចូលព័ត៌មាននោះ ហើយជាផ្នែកតែមួយនៃឯកសារដើម។ ឧបសម្ព័ន្ធ គឺគ្រាន់តែជាការសរសេរដើម្បីធ្វើការសរុបនូវខ្លឹមសារមួយផ្នែកដាក់នៅក្នុងទំព័រចុងក្រោយ ដោយផ្អែកលើការពិចារណាអំពីភាពងាយស្រួលនៃការអានខ្លឹមសារទាំងស្រុងនៃឯកសារដើម។ ដូច្នេះហើយ ប្រសិនបើ "ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ" ត្រូវបានដកស្រង់ខ្លឹមសារទៅដាក់នៅក្នុងឧបសម្ព័ន្ធ នោះមានន័យថា គេគ្រាន់តែបានយកខ្លឹមសារមួយផ្នែកដែលមានភាពចាំបាច់ត្រូវសរសេរនៅក្នុង "ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ" មកសរសេរសរុបដាក់នៅក្នុងទំព័រចុងក្រោយតែប៉ុណ្ណោះ ហើយ "ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ" ក៏រួមបញ្ចូលទាំងឧបសម្ព័ន្ធ ផងដែរ។

 រីឯឯកសារភ្ជាប់ ជាឯកសារដែលគេបានយកមកភ្ជាប់ជាមួយឯកសារដើម ហើយឯកសារភ្ជាប់នេះមិនមែនជាផ្នែកមួយនៃឯកសារដើមឡើយ។

[6] អ្នកចុះបញ្ជី គឺជាមន្ត្រីសុរិយោដី ( ប្រកាសអន្តរក្រសួងស្តីពីការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមរដ្ឋប្បវេណី (តទៅនៅពេលដែលហៅដោយសង្ខេបថា "ប្រកាសអន្តរក្រសួង" ដែលសំដៅទៅលើប្រកាសអន្តរក្រសួងនេះ ) មាត្រា ៩០) មិនមែនជាចុងចម្លើយទេ។ ចុងចម្លើយមានកាតព្វកិច្ចធ្វើនីតិវិធីដាក់ពាក្យសុំចុះបញ្ជី (មាត្រា ១០ កថាខណ្ឌទី ១ នៃប្រកាសអន្តរក្រសួង) ពោលគឺ ចុងចម្លើយមានកាតព្វកិច្ចមិនលើសពីការបង្ហាញឆន្ទៈក្នុងការដាក់ពាក្យសុំចុះបញ្ជីឡើយ។ នៅពេលដែលសាលក្រមបង្គាប់ទៅចុងចម្លើយអំពីការត្រូវធ្វើការបង្ហាញឆន្ទៈក្នុងការដាក់ពាក្យសុំចុះបញ្ជី (ធ្វើនីតិវិធីដាក់ពាក្យសុំចុះបញ្ជី) បាន ចូលជាស្ថាពរ នឹងត្រូវបានចាត់ទុកថា ចុងចម្លើយបានធ្វើការបង្ហាញឆន្ទៈនៅពេលចូលជាស្ថាពរនោះ (មាត្រា ៥២៩ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ ជាងនេះទៅទៀត ដើមចោទដែលជាអ្នកមានសិទ្ធិចុះបញ្ជី នៅពេលដែលទទួលបានសាលក្រមស្ថាពរដែលបង្គាប់អំពីនីតិវិធីចុះបញ្ជីមកធ្វើជាលិខិតអនុវត្ត គឺអាចដាក់ពាក្យសុំចុះបញ្ជីតែម្នាក់ឯងបាន (មាត្រា ១០ កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ មន្ត្រីសុរិយោដីនឹងមានកាតព្វកិច្ចចុះបញ្ជីនៅពេលដែលចាប់ផ្តើមមានពាក្យសុំ (ប្រកាសដដែល មាត្រា ៦ កថាខណ្ឌទី ២)។ វានឹងមិនអាចទៅរួចឡើយដែលមន្ត្រីសុរិយោដីមានកាតព្វកិច្ចចុះបញ្ជី ទាំងពុំមានពាក្យសុំពីភាគី។

[7] តុលាការត្រូវសម្រេចអំពីករណីយកិច្ចទទួលបន្ទុកប្រាក់ប្រដាប់ក្ដី (មាត្រា ១៨២ កថាខណ្ឌទី ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ហើយ ប្រាក់ប្រដាប់ក្ដីគឺជាបន្ទុករបស់ភាគីចាញ់ក្ដី (មាត្រា ៦៤ កថាខណ្ឌទី ១)។

## ខ. អង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ និង អង្គហេតុដែលជាមូលហេតុនៃការទាមទារ

**ស្តីអំពីការបង្កើតកិច្ចសន្យាលក់ទិញ** [8]

**ខ.១.** នៅថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១៨ ដើមចោទបានទិញអចលនវត្ថុដែលបានកត់ត្រាក្នុងបញ្ជីឧបសម្ព័ន្ធ (តទៅហៅថា "ដី L") ក្នុងតម្លៃ ២០០.០០០ (ពីរសែន) ដុល្លារអាមេរិកពីចុងចម្លើយ(តទៅនេះហៅថា "កិច្ចសន្យាលក់ទិញនៃរឿងក្តីនេះ) ។ **( ភស្តុតាង $X_1$)**

**ខ.២.** "កិច្ចសន្យាលក់ទិញនៃរឿងក្តីនេះ" ត្រូវបានធ្វើឡើងជាលិខិតយថាភូត។ **( ភស្តុតាង $X_1$)**

**ដូច្នេះ ដើមចោទទាមទារឲ្យចុងចម្លើយ ប្រគល់ដី L និង ធ្វើនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិទាំងមូលដោយផ្អែកលើ " កិច្ចសន្យាលក់ទិញនៃរឿងក្តីនេះ " ។** [9]

## គ.អង្គហេតុពាក់ព័ន្ធ

**គ.១.** នៅក្នុង "កិច្ចសន្យានៃរឿងក្តីនេះ" បានកំណត់ថា នៅថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៨ ចុងចម្លើយត្រូវប្រគល់ដី L និង ធ្វើនីតិវិធីចុះបញ្ជី ជាថ្នូរនឹងដើមចោទបង់ប្រាក់ ២០០.០០០ (ពីរសែន) ដុល្លារអាមេរិក។

**គ.២.** យ៉ាងណាមិញ នៅថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១៨ ចុងចម្លើយបានយកប្រាក់ចំនួន ៤០.០០០ (បួនម៉ឺន) ដុល្លារអាមេរិកមកផ្ទះរបស់ដើមចោទ

---

[8] អង្គហេតុចម្បងនៃ ① ការទាមទារឲ្យប្រគល់វត្ថុនៃការលក់ទិញ និង ② សិទ្ធិទាមទារឲ្យធ្វើនិតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិទាំង មូលដោយផ្អែកលើកិច្ចសន្យាលក់ទិញរួមមាន ៖ មាត្រា ៥១៥ មាត្រា ៥១៦ មាត្រា ៥៣០ និង កថាខណ្ឌទី ១ មាត្រា ៥៣១នៃក្រមរដ្ឋប្បវេណី។ តាមរយៈការបង្កើតកិច្ចសន្យាលក់ទិញ នឹងនាំឲ្យកើតមាននូវសិទ្ធិទាមទារ ① និង ② ដូច្នេះហើយជាដំបូងចាំបាច់ត្រូវធ្វើការអះអាងអំពីការចុះកិច្ចសន្យា។

ម្យ៉ាងវិញទៀត ចំពោះកិច្ចសន្យា ① ខាងលើនេះ ក្នុងករណីដែល "ភាគីម្ខាងធ្វើអនុប្បទាននូវកម្មសិទ្ធិលើអចលនវត្ថុ ឬករណីយកិច្ចធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើអចលនវត្ថុ" ប្រសិនបើមិនធ្វើជាលិខិតយថាភូតទេ កិច្ចសន្យានេះនឹងមិនមានអានុភាពទេ (មាត្រា ៣៣៦ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណី)។ លើសពីនេះទៀតចំពោះ "លិខិតយថាភូត" នៃកថាខណ្ឌទី២ មាត្រា ៣៣៦ នៃក្រមរដ្ឋប្បវេណី មានចែងនៅក្នុងច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី មាត្រា ៩ កថាខណ្ឌទី ១។

[9] បញ្ជាក់ឲ្យបានច្បាស់អំពីមូលដ្ឋានគតិយុត្ត។

ហើយបានអះអាងតែម្នាក់ឯងថា "នឹងរំលាយ "កិច្ចសន្យាលក់ទិញនៃរឿងក្ដីនេះ" ដោយសារតែរកបានអ្នកទិញដី L ក្នុងតម្លៃខ្ពស់ជាងនេះ" ជាអាទិ៍ រួចហើយទើបត្រឡប់ទៅផ្ទះវិញ។

## ឃ. ប្រាក់ប្រដាប់ក្ដី

ប្រាក់ប្រដាប់ក្ដីនៃរឿងក្ដីនេះ គប្បីជាបន្ទុករបស់ចុងចម្លើយ។ (មាត្រា ៦៤ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

## ង. ភស្តុតាង

**១.**លិខិតយថាភូតស្ដីពីការលក់ទិញ ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១៨ (**ភស្តុតាង**$X_1$)

សេចក្ដីដូចមានកំណត់ សូម **លោកប្រធាន** សម្រេចតាមការស្នើសុំ ដោយក្ដីអនុគ្រោះ។ សូម **លោកប្រធាន** ទទួលនូវសេចក្ដីគោរពដ៏ជ្រាលជ្រៅអំពីខ្ញុំ។

រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០១៩

**អ្នកតំណាងដោយអាណត្តិ**

P

<u>ឯកសារភ្ជាប់</u>

១-លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ "ច្បាប់ដើម"

២-ច្បាប់ថតចម្លងនៃភស្តុតាងនីមួយៗខាងលើ "ចំនួន ០២ ច្បាប់"

**ឧបសម្ព័ន្ធ**

## បញ្ជី[10]

| | |
|---|---|
| "គោលបំណងនៃពាក្យសុំចុះបញ្ជី" | ផ្ទេរកម្មសិទ្ធិទាំងមូល |
| "មូលហេតុនៃពាក្យសុំចុះបញ្ជី និង កាលបរិច្ឆេទ" | ការលក់ទិញចុះថ្ងៃទី ១ ខែ សីហា ឆ្នាំ ២០១៨ |
| "បុគ្គលមានសិទ្ធិចុះបញ្ជី" | ដើមចោទ ( X )<br>ថ្ងៃខែឆ្នាំកំណើត ៖ ថ្ងៃ......ខែ..........ឆ្នាំ.........<br>ទីកន្លែងកំណើត ៖ ......................................<br>ឈ្មោះរបស់ឪពុកម្តាយ៖ ...................(ឪពុក)<br>.....................(ម្តាយ) |
| "បុគ្គលមានកាតព្វកិច្ចចុះបញ្ជី" | ចុងចម្លើយ ( Y )<br>ថ្ងៃខែឆ្នាំកំណើត ៖ ថ្ងៃ......ខែ..........ឆ្នាំ.........<br>ទីកន្លែងកំណើត ៖ ......................................<br>ឈ្មោះរបស់ឪពុកម្តាយ៖ ...................(ឪពុក)<br>.....................(ម្តាយ) |
| "អត្តសញ្ញាណនៃអចលនវត្ថុ" | ទីតាំងដី ៖ ផ្លូវលេខ ១០២ ភូមិ ៣ សង្កាត់ជ្រោយចង្វារ ខណ្ឌ ជ្រោយចង្វារ រាជធានីភ្នំពេញ<br>លេខក្បាលដី ៖ ១៣០៦ |

[10] ដើម្បីទាមទារនូវនីតិវិធីចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិ មានភាពចាំបាច់ត្រូវសរសេរអំពីចំណុចដែលត្រូវបានកំណត់នៅក្នុងប្រការ ២៦ និង ២៨ នៃប្រកាសអន្តរក្រសួងស្តីពីនីតិវិធីនៃការចុះបញ្ជីអំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី។

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

## ឯកសារចម្លើយ[1]

### ដើមចោទ

ឈ្មោះ ៖ X

អាសយដ្ឋាន ៖ ផ្ទះលេខ 00 ផ្លូវលេខ 00 សង្កាត់ទំនប់ទឹក ខណ្ឌចំការមន រាជធានីភ្នំពេញ។

### ចុងចម្លើយ

ឈ្មោះ ៖ Y

អាសយដ្ឋាន ៖ ផ្ទះលេខ 00 ផ្លូវលេខ 00 សង្កាត់មនោរម្យ ខណ្ឌ៧មករា រាជធានីភ្នំពេញ។

### អ្នកតំណាងដោយអាណត្តិ

លោក/លោកស្រីមេធាវី ៖ B

អាសយដ្ឋានការិយាល័យមេធាវី / ក្រុមមេធាវី / ក្រុមហ៊ុនមេធាវី ៖...............................

ការិយាល័យមេធាវី / ក្រុមមេធាវី / ក្រុមហ៊ុនមេធាវី ៖.................................................

លេខទូរស័ព្ទ៖.....................................................................

**ទីកន្លែងបញ្ជូន** ៖ ការិយាល័យមេធាវី/ ក្រុមមេធាវី/ ក្រុមហ៊ុនមេធាវី..................[2]

---

[1] ឯកសារត្រៀមដែលចុងចម្លើយដាក់ទៅតុលាការជាលើកដំបូង ហៅថា "ឯកសារចម្លើយ"។ នៅក្នុងឯកសារនេះនឹងត្រូវសរសេរអំពី ① ការឆ្លើយតបចំពោះខ្លឹមសារនៃសាលក្រមដែលដើមចោទបានសរសេរនៅក្នុងពាក្យបណ្តឹង ② ការទទួលស្គាល់ ឬ មិនទទួលស្គាល់នូវអង្គហេតុដែលមានសរសេរនៅក្នុងពាក្យបណ្តឹង និង ③ អង្គហេតុដើម្បីតវ៉ាចំពោះអង្គហេតុដែលមានសរសេរនៅក្នុងពាក្យបណ្តឹង (កថាខណ្ឌទី៣ មាត្រា ១០១នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

[2] មាត្រា ២៤៩ និង មាត្រា ២៥០ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ ការសរសេរអំពីកន្លែងបញ្ជូន មិនមែនជាកាតព្វកិច្ចទេ។ ប្រសិនបើមិនបានសរសេរអំពីទីកន្លែងបញ្ជូន ការបញ្ជូននឹងត្រូវធ្វើឡើងនៅលំនៅដ្ឋានរបស់ចុងចម្លើយជាអាទិ៍។ ដូច្នេះ ក្នុងករណីដែលអ្នកតំណាងដោយអាណត្តិរបស់ចុងចម្លើយចង់ធ្វើការបញ្ជូនទៅទីកន្លែងណាផ្សេងក្រៅពីលំនៅដ្ឋានរបស់ចុងចម្លើយជាអាទិ៍ ចាំបាច់ត្រូវសរសេរអំពីកន្លែងបញ្ជូនចូលទៅក្នុងលិខិតលាយលក្ខណ៍អក្សរ ដូចជា ឯកសារចម្លើយជាអាទិ៍។

**សូមគោរពជូន**

**លោក  ចៅក្រមនៃសាលាដំបូងរាជធានីភ្នំពេញ**

**<u>កម្មវត្ថុ</u>** ៖ សុំដាក់**ឯកសារចម្លើយដើម្បីឆ្លើយតប**នឹងពាក្យបណ្ដឹងចុះថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០១៩ របស់ឈ្មោះ X

**<u>យោង</u>**៖-មាត្រា **១០១ កថាខណ្ឌទី ៣** នៃក្រមនីតិវិធីរដ្ឋប្បវេណី

-សំណុំរឿងរដ្ឋប្បវេណីលេខ ....... ចុះថ្ងៃទី០១ ខែ កុម្ភៈ ឆ្នាំ ២០១៩

## ក. ការឆ្លើយតបចំពោះខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារ

(១) ច្រានចោលការទាមទារ[3]ទាំងអស់របស់ដើមចោទ។

(២) ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ដើមចោទ។

## ខ. ការទទួលស្គាល់ ឬ មិនទទួលស្គាល់អង្គហេតុដែលមានសរសេរនៅក្នុងពាក្យបណ្ដឹង

### ខ.១. ការទទួលស្គាល់ ឬ មិនទទួលស្គាល់អំពីការបង្កើតកិច្ចសន្យាលក់ទិញនៅក្នុងពាក្យបណ្ដឹង

**ខ.១.១.** អង្គហេតុដែលត្រូវបានសរសេរនៅក្នុងចំណុច "**ខ.១.**" នៃពាក្យបណ្ដឹង៖ ចុងចម្លើយទទួលស្គាល់ ។

**ខ.១.២.** អង្គហេតុដែលត្រូវបានសរសេរនៅក្នុងចំណុច "**ខ.២.**" នៃពាក្យបណ្ដឹង ៖ ចុងចម្លើយទទួលស្គាល់ ។

### ខ.២. ការទទួលស្គាល់ ឬ មិនទទួលស្គាល់អំពីអង្គហេតុពាក់ព័ន្ធនៃចំណុច "គ" នៅក្នុងពាក្យបណ្ដឹង

**ខ.២.១.** អង្គហេតុដែលត្រូវបានសរសេរនៅក្នុងចំណុច "**គ.១.**" នៃពាក្យបណ្ដឹង ៖ ចុងចម្លើយទទួលស្គាល់ ។

---

[3] សិទ្ធិដែលដើមចោទកំពុងតែទាមទារមាន ២ ( ១. សិទ្ធិទាមទារឲ្យប្រគល់វត្ថុនៃការលក់ទិញដោយផ្អែកតាមកិច្ចសន្យាលក់ទិញ និង ២. សិទ្ធិទាមទារឲ្យធ្វើនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិទាំងមូលដោយផ្អែកតាមកិច្ចសន្យាលក់ទិញ) ដូច្នេះហើយនៅពេលដែលទាមទារឲ្យច្រានចោលនូវចំណុចទាំងអស់នោះ ត្រូវសរសេរពាក្យថា "ទាំងអស់" ។

ខ.២.២. អង្គហេតុដែលត្រូវបានសរសេរនៅក្នុងចំណុច "**គ.២.**" នៃពាក្យបណ្តឹង ៖ ចុងចម្លើយទទួលស្គាល់ ។

## គ. អង្គហេតុតទល់

### គ.១. ការរំលាយកិច្ចសន្យាដោយសងប្រាក់កក់ [4]

**គ.១.១.** នៅថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១៨ នៅពេលដែលចុះ "កិច្ចសន្យាលក់ទិញនៃរឿងក្តីនេះ" ជាមួយចុងចម្លើយ ដើមចោទបានព្រមព្រៀងបង់ប្រាក់កក់ចំនួន ២០.០០០ (ពីរម៉ឺន) ដុល្លារអាមេរិក ហើយបានប្រគល់ប្រាក់នោះឲ្យទៅចុងចម្លើយ។

[4] អង្គហេតុចម្បងនៃការរំលាយកិច្ចសន្យាដោយសងប្រាក់កក់ ៖ មាត្រា ៥១៨ មាត្រា ៤១៤ មាត្រា ៤០៩ កថាខណ្ឌទី ១ ។ ដោយសារតែភាពចាំបាច់ដំបូងគឺ " អ្នកទិញបានបង់ប្រាក់កក់ទៅឲ្យអ្នកលក់" (មាត្រា ៥១៨) ដូច្នេះហើយ ចាំបាច់ត្រូវធ្វើការអះអាងថា ៖ ① អ្នកទិញបានព្រមព្រៀងជាមួយអ្នកលក់អំពីការប្រគល់ប្រាក់កក់នៃកិច្ចសន្យាលក់ទិញ ② អ្នកទិញបានប្រគល់ប្រាក់កក់ដោយផ្អែកលើកចំណុច ① ឲ្យទៅអ្នកលក់។ បន្ទាប់មកទៀត ភាពចាំបាច់គឺ "ការសងប្រាក់ស្មើនឹងពីរដងនៃប្រាក់កក់" (មាត្រា ៥១៨) ហេតុនេះ ចាំបាច់ត្រូវធ្វើការអះអាងថា ៖ ③ អ្នកទិញបានធ្វើសំណើផ្តល់ប្រាក់កក់ជាក់ស្តែងចំនួន ២ដង នៃប្រាក់កក់ឲ្យទៅអ្នកទិញ (យោងតាម Footnote 5 ដែលសរសេរខាងក្រោមផងដែរ)។ ហើយ ដោយសារតែភាពចាំបាច់នៅពេលដែលធ្វើការរំលាយកិច្ចសន្យា គឺ " ការបង្ហាញឆន្ទៈអំពីការរំលាយកិច្ចសន្យាទៅភាគីម្ខាងទៀត" (មាត្រា ៤១៤ កថាខណ្ឌទី ១ មាត្រា ៤០៩ កថាខណ្ឌទី ១) ហេតុនេះ ចាំបាច់ត្រូវធ្វើការអះអាងថា ៖ ④អ្នកលក់បានបង្ហាញឆន្ទៈអំពីការរំលាយកិច្ចសន្យាទៅអ្នកទិញ។ យ៉ាងណាមិញ ដោយសារតែ ការបង្ហាញឆន្ទៈនឹងកើតមានអានុភាពនៅពេលដែលបានទៅដល់ភាគីម្ខាងទៀត (មាត្រា ៣១០ កថាខណ្ឌទី ២) ដូច្នេះហើយ នៅក្នុងរឿងក្តីនេះ ត្រូវធ្វើការអះអាងអំពី ការបានបង្ហាញឆន្ទៈដែលបានធ្វើឡើងនៅចំពោះមុខដើមចោទដែលជាភាគីម្ខាងទៀត។

**គ.១.២.** នៅថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១៨ចុងចម្លើយបានធ្វើសំណើផ្តល់[5] ប្រាក់ជាក់ស្តែងចំនួន ៤០.០០០ (បួនម៉ឺន) ដុល្លារអាមេរិកនៅផ្ទះរបស់ដើមចោទ (ផ្ទះលេខ 00 ផ្លូវលេខ 00 សង្កាត់ទំនប់ទឹក ខណ្ឌចំការមន រាជធានីភ្នំពេញ) ហើយបានបង្ហាញឆន្ទៈអំពីការរំលាយ "កិច្ចសន្យាលក់ទិញនៃរឿងក្តីនេះ" ទៅកាន់ដើមចោទ។

**ដូច្នេះហើយ ដោយសារតែចុងចម្លើយបាន "រំលាយកិច្ចសន្យាលក់ទិញនៃរឿងក្តីនេះ" ដោយផ្អែកតាមមាត្រា ៥១៨ នៃក្រមរដ្ឋប្បវេណី ហេតុនេះ ចុងចម្លើយពុំមានទំនួលខុសត្រូវក្នុងការអនុវត្ត "កិច្ចសន្យាលក់ទិញនៃរឿងក្តីនេះ" ទេ ។**

## ឃ. ភស្តុតាង

១. លិខិតទទួលប្រាក់ចំនួន ២០.០០០ (ពីរម៉ឺន) ដុល្លារអាមេរិកចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១៨ **(ភស្តុតាង$Y_1$)**

---

[5] ដោយសារតែអ្នកលក់អាចរំលាយកិច្ចសន្យាលក់ទិញដោយ "**សងប្រាក់**ស្មើនឹងពីរដងនៃប្រាក់កក់" (មាត្រា ៥១៨ នៃក្រមរដ្ឋប្បវេណី) ដូច្នេះ បើសិនជាអ្នកលក់គ្រាន់តែជូនដំណឹងអំពីការបញ្ចប់នូវការរៀបចំសង និង ដាស់តឿនទៅអ្នកទិញឲ្យទទួលការសងនូវទឹកប្រាក់ ២ដង នៃចំនួនប្រាក់កក់ តែប៉ុណ្ណឹង គឺមិនទាន់មានភាពគ្រប់គ្រាន់ទេ (មិនអាចរំលាយកិច្ចសន្យាលក់ទិញបានទេ) ។

តាមមាត្រា ៥១៨ នៃក្រមរដ្ឋប្បវេណី ចែងថា "អ្នកលក់សងប្រាក់ស្មើនឹងពីរដងនៃប្រាក់កក់" គឺជាការចែងអំពីសកម្មភាពរបស់អ្នកលក់តែប៉ុណ្ណោះ ដូច្នេះហើយ ចំពោះឥរិយាបថរបស់អ្នកទិញដែលឆ្លើយតបទៅកាន់សកម្មភាពរបស់អ្នកលក់វិញ (ទទួលយក ឬ យ៉ាងណា? ) គឺពុំមានបញ្ហាអ្វីឡើយ។ ដូច្នេះហើយ ចំពោះអ្នកលក់ គឺគ្រាន់តែអះអាងអំពី "ការធ្វើសំណើផ្តល់ប្រាក់ជាក់ស្តែង" ចំនួន ២ដង នៃប្រាក់កក់ គឺគ្រប់គ្រាន់។

នៅក្នុងរឿងក្តីនេះ ដើមចោទដែលជាអ្នកទិញមិនទាន់បានទទួលប្រាក់ចំនួន ៤០.០០០ (បួនម៉ឺន) ដុល្លារអាមេរិកទេ ប៉ុន្តែ ចុងចម្លើយដែលជាអ្នកលក់បានធ្វើសំណើផ្តល់ ប្រាក់ជាក់ស្តែងចំនួន ៤០.០០០ (បួនម៉ឺន) ដុល្លារអាមេរិកនៅផ្ទះរបស់ដើមចោទ ដូច្នេះហើយ គឺអាចធ្វើការរំលាយ "កិច្ចសន្យាលក់ទិញនៃរឿងក្តីនេះ" ផ្អែកតាមមាត្រា ៥១៨ នៃក្រមរដ្ឋប្បវេណី។

យ៉ាងណាមិញ បើទោះបីជា "កិច្ចសន្យាលក់ទិញនៃរឿងក្តីនេះ" ត្រូវបានរំលាយផ្អែកតាមមាត្រា ៥១៨ នៃក្រមរដ្ឋប្បវេណីក៏ដោយ ក៏សិទ្ធិទាមទារឲ្យបង់ប្រាក់ចំនួន ៤០.០០០ (បួនម៉ឺន) ដុល្លារអាមេរិកដែលដើមចោទមានចំពោះចុងចម្លើយ មិនរលត់ឡើយ ( នៅក្នុងមូលហេតុនៃការរលត់កាតព្វកិច្ចនៃមាត្រា ៤៣៣ នៃក្រមរដ្ឋប្បវេណី មិនមានបញ្ចូលនូវ "សំណើផ្តល់ការសង" ទេ។ ដរាបណា ចុងចម្លើយមិនសង ឬ មិនតម្កល់ (មាត្រា ៤៥៧ នៃក្រមរដ្ឋប្បវេណី) ទេ កាតព្វកិច្ចរបស់ចុងម្លើយមិនរលត់ឡើយ ) ដូច្នេះ ហើយដើមចោទអាចទាមទារម្តងទៀតឲ្យចុងចម្លើយបង់ប្រាក់ចំនួន ៤០.០០០ (បួនម៉ឺន) ដុល្លារអាមេរិក។

សូម **លោកចៅក្រម** សម្រេចតាមការស្នើសុំ ដោយក្ដីអនុគ្រោះ។

រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១៩

**អ្នកតំណាងដោយអាណត្តិ**

B

<u>ឯកសារភ្ជាប់</u>

១-លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ "ច្បាប់ដើម"

២-ច្បាប់ថតចម្លងនៃភស្តុតាងនីមួយៗខាងលើ "ចំនួន ០២ ច្បាប់"

៣-ឯកសារចម្លងនៃឯកសារចម្លើយ "ចំនួន ០២ ច្បាប់"

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# ឯកសារត្រៀមលើកទី១របស់ដើមចោទ

## ដើមចោទ

ឈ្មោះ ៖ X

អាសយដ្ឋាន ៖ ផ្ទះលេខ 00 ផ្លូវលេខ 00 សង្កាត់ទំនប់ទឹក ខណ្ឌចំការមន រាជធានីភ្នំពេញ។

## អ្នកតំណាងដោយអាណត្តិ

លោក/លោកស្រី ៖ P

អាសយដ្ឋានការិយាល័យមេធាវី/ ក្រុមមេធាវី/ ក្រុមហ៊ុនមេធាវី ៖................................

ការិយាល័យមេធាវី/ ក្រុមមេធាវី/ ក្រុមហ៊ុនមេធាវី ៖ ..................................................

លេខទូរស័ព្ទ៖.........................................................

**ទីកន្លែងបញ្ជូន** ៖ ការិយាល័យមេធាវី/ ក្រុមមេធាវី/ ក្រុមហ៊ុនមេធាវី.............................

## ចុងចម្លើយ

ឈ្មោះ ៖ Y

អាសយដ្ឋាន ៖ ផ្ទះលេខ 00 ផ្លូវលេខ 00 សង្កាត់មនោរម្យ ខណ្ឌ៧មករា រាជធានីភ្នំពេញ។

**សូមគោរពជូន**

**លោក J ចៅក្រមនៃសាលាដំបូងរាជធានីភ្នំពេញ**

**<u>កម្មវត្ថុ</u> ៖** សំណើសុំដាក់**ឯកសារត្រៀមលើកទី១របស់ដើមចោទ**ដើម្បីឆ្លើយតបចំពោះ
ឯកសារចម្លើយរបស់ឈ្មោះ Y ចុះថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១៩

**<u>យោង</u> ៖** -មាត្រា **១០១ កថាខណ្ឌទី ២** នៃក្រមនីតិវិធីរដ្ឋប្បវេណី

-សំណុំរឿងរដ្ឋប្បវេណីលេខ ........ ចុះថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០១៩

**ក. ការទទួលស្គាល់ ឬ មិនទទួលស្គាល់ចំពោះអង្គហេតុដែលមានសរសេរនៅក្នុងឯកសារចម្លើយ**

**ក.១.** អង្គហេតុដែលត្រូវបានសរសេរនៅក្នុងចំណុច "**គ.១.១.**" នៃឯកសារចម្លើយ ៖ ដើមចោទទទួលស្គាល់។

**ក.២.** អង្គហេតុដែលត្រូវបានសរសេរនៅក្នុងចំណុច "**គ.១.២.**" នៃឯកសារចម្លើយ ៖ ដើមចោទទទួលស្គាល់។

សូម **លោកចៅក្រម**សម្រេចតាមការស្នើសុំ ដោយក្តីអនុគ្រោះ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១៩

**អ្នកតំណាងដោយអាណត្តិ**

P

សាលាដំបូងរាជធានីភ្នំពេញ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**តុលាការរដ្ឋប្បវេណី**
សំណុំរឿងលេខ ........
ចុះថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០១៩
សាលក្រមលេខ ........
ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ២០១៩

## សាលក្រម[1]
## ក្នុងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងរាជធានីភ្នំពេញ [2]

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៅ
ថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៩ [3] [4]

**ចៅក្រមជំនុំជម្រះ**

លោក J ជាចៅក្រមនៃសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជី**

លោកស្រី C ជាក្រឡាបញ្ជីនៃសាលាដំបូងរាជធានីភ្នំពេញ

---

[1] ការសម្រេចសេចក្ដី គឺចែកចេញជា សាលក្រម និង ដីកាសម្រេច (មាត្រា ១៧៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ដូច្នេះ មានភាពចាំបាច់នៅក្នុងការបញ្ជាក់ឲ្យបានច្បាស់លាស់ថា អំពីប្រភេទនៃការសម្រេចសេចក្ដីដាក់នៅត្រង់ចំណុចចាប់ផ្ដើម។ ដោយសារតែ សាលក្រម និង ដីកាសម្រេចមានភាពខុសគ្នាចំពោះវិធីក្នុងការធ្វើឧបាស្រ័យជាអាទិ៍ ។ ជាគោលការណ៍បណ្ដឹងឧបាស្រ័យចំពោះសាលក្រម គឺ បណ្ដឹងឧទ្ធរណ៍ ហើយ បណ្ដឹងឧបាស្រ័យចំពោះដីកាសម្រេច គឺ បណ្ដឹងជំទាស់ (កថាខណ្ឌទី ១ មាត្រា ២៥៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

[2] សាលក្រមរដ្ឋប្បវេណីត្រូវតែសរសេរអំពីចំណុចដែលចែងនៅក្នុងមាត្រា ១៨៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

[3] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ១៨៩ កថាខណ្ឌទី ១ ចំណុច ខ ។ សាលក្រមនឹងត្រូវកំណត់ជាស្ថាពរនូវទំនាក់ទំនងសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តិនាពេលបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ១៩៥ កថាខណ្ឌទី ២) ហេតុនេះ ចាំបាច់ត្រូវសរសេរឲ្យបានច្បាស់លាស់អំពី ពេលដែលបានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់។ សាលក្រមគឺជាការសម្រេចសេចក្ដីរបស់តុលាការដែលត្រូវបានធ្វើឡើងដោយកំណត់ជាមុននូវទំនាក់ទំនងអង្គហេតុគិតមកដល់ត្រឹមថ្ងៃបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់។

[4] ការប្រកាសសាលក្រមត្រូវធ្វើឡើងក្នុងអំឡុងពេល ១ (មួយ) ខែ គិតចាប់ពីថ្ងៃដែលបានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ (មាត្រា ១៨៧ នៃក្រមរដ្ឋប្បវេណី)។ ហើយការប្រកាសសាលក្រមចាំបាច់ត្រូវធ្វើឡើងដោយផ្អែកលើច្បាប់ដើមនៃមូលសាលក្រម (កថាខណ្ឌទី ១ មាត្រា ១៨៨ នៃក្រមរដ្ឋប្បវេណី) ដូច្នេះហើយ ចាំបាច់ត្រូវតែបញ្ចប់នូវការតាក់តែងច្បាប់ដើមនៃមូលសាលក្រមឲ្យបាន គិតត្រឹមពេលប្រកាសសាលក្រម។

**ដើមចោទ**

ឈ្មោះ ៖ X

អាសយដ្ឋាន ៖ ផ្ទះលេខ 00 ផ្លូវលេខ 00 សង្កាត់ទំនប់ទឹក ខណ្ឌចំការមន រាជធានីភ្នំពេញ។

**អ្នកតំណាងដោយអាណត្តិ**

លោក/លោកស្រី ៖ P

អាសយដ្ឋានការិយាល័យមេធាវី / ក្រុមមេធាវី / ក្រុមហ៊ុនមេធាវី ៖ ..............................

ការិយាល័យមេធាវី / ក្រុមមេធាវី / ក្រុមហ៊ុនមេធាវី ៖ ...............................................

លេខទូរស័ព្ទ ៖ .....................................................................................

**ចុងចម្លើយ**

ឈ្មោះ ៖ Y

អាសយដ្ឋាន ៖ ផ្ទះលេខ 00 ផ្លូវលេខ 00 សង្កាត់មនោរម្យ ខណ្ឌ៧មករា រាជធានីភ្នំពេញ។

**អ្នកតំណាងដោយអាណត្តិ**

លោក/លោកស្រី ៖ B

អាសយដ្ឋានការិយាល័យមេធាវី / ក្រុមមេធាវី / ក្រុមហ៊ុនមេធាវី ៖ .....................

ការិយាល័យមេធាវី / ក្រុមមេធាវី / ក្រុមហ៊ុនមេធាវី ៖ .......................................

លេខទូរស័ព្ទ ៖ .....................................................................................

## អង្គហេតុ និងចំណុចវិវាទ

**ក. ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ**

(១) បង្គាប់ឲ្យចុងចម្លើយប្រគល់អចលនវត្ថុដែលបានកត់ត្រាក្នុងបញ្ជីឧបសម្ព័ន្ធ[5]ឲ្យទៅដើមចោទ។

(២) បង្គាប់ឲ្យចុងចម្លើយធ្វើនីតិវិធីចុះបញ្ជីអចលវត្ថុដែលបានកត់ត្រាក្នុងបញ្ជីឧបសម្ព័ន្ធឲ្យទៅដើមចោទ។

(៣) ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ចុងចម្លើយ។

## ខ. ដំណើររឿងក្ដី និង ចំណុចវិវាទ

### ខ.១. ការសង្ខេបអំពីរឿងក្ដី

នៅក្នុងរឿងក្ដីនេះ ដើមចោទបានទាមទារនូវការប្រគល់អចលនវត្ថុដែលបានកត់ត្រាក្នុងបញ្ជីឧបសម្ព័ន្ធ (តទៅហៅថា "ដី L" ) និង ការធ្វើនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិទាំងមូលលើអចលនវត្ថុដដែលដោយផ្អែកលើកិច្ចសន្យាលក់ទិញចុះថ្ងៃទី ១ ខែ សីហា ឆ្នាំ ២០១៨ ពីចុងចម្លើយ។

### ខ.២. អង្គហេតុដែលគ្មានវិវាទ[6]

ខ.២.១. នៅថ្ងៃទី ១ ខែ សីហា ឆ្នាំ ២០១៨ ដើមចោទបានទិញ "ដី L" ក្នុងតម្លៃ ២០០.០០០ (ពីរសែន) ដុល្លារអាមេរិកពីចុងចម្លើយ (តទៅហៅថា "កិច្ចសន្យាលក់ទិញនៃរឿងក្ដីនេះ" )។

---

[5] ឧបសម្ព័ន្ធ ជាឯកសារមួយដែលបានបង្កើតដើម្បីដាក់បញ្ចូលព័ត៌មាននោះ ហើយជាផ្នែកតែមួយនៃឯកសារដើម។ ដូច្នេះហើយចំពោះអនុសារនៃសាលក្រម (កថាខណ្ឌទី ២ មាត្រា ១៩០ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ក៏ ប្រាកដជាត្រូវតែ**ធ្វើឡើងដោយរួមបញ្ចូលទាំងឧបសម្ព័ន្ធ**ផងដែរ។ ឧបសម្ព័ន្ធ គឺជាគ្រាន់តែសរសេរដើម្បីធ្វើការសរុបនូវខ្លឹមសារមួយផ្នែកដាក់នៅក្នុងទំព័រចុងក្រោយតែប៉ុណ្ណោះ ដោយផ្អែកធ្វើការពិចារណាអំពីភាពងាយស្រួលនៃការអានខ្លឹមសារទាំងស្រុងនៃអត្ថបទ។ ប្រសិនបើនៅក្នុង លិខិតសាលក្រម មានការដកស្រង់ខ្លឹមសារទៅដាក់នៅក្នុងឧបសម្ព័ន្ធនោះមានន័យថា គេគ្រាន់តែបានយកខ្លឹមសារមួយផ្នែកដែលមានភាពចាំបាច់ត្រូវសរសេរនៅក្នុងលិខិតសាលក្រមមកសរសេរសរុបដាក់នៅក្នុងទំព័រចុងក្រោយតែប៉ុណ្ណោះ ហើយ**ខ្លឹមសារនៃលិខិតសាលក្រមក៏រួមបញ្ចូលទាំងឧបសម្ព័ន្ធ**ផងដែរ។

រីឯ ឯកសារភ្ជាប់ ជាឯកសារដែលគេបានយកមកភ្ជាប់ជាមួយឯកសារដើម ហើយឯកសារភ្ជាប់នេះមិនមែនជាផ្នែកមួយនៃឯកសារដើមឡើយ។

[6] មាត្រា ១២៣ កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ ចំណុចនេះនឹងត្រូវសរសេរអំពីអង្គហេតុដែលភាគីបានសារភាពនៅចំពោះមុខតុលាការ និង អង្គហេតុដែលតុលាការយល់ឃើញថា អត្ថិភាពនៃអង្គហេតុនោះមានភាពជាក់ស្ដែង។

**ខ.២.២.** "កិច្ចសន្យាលក់ទិញនៃរឿងក្តីនេះ" ត្រូវបានធ្វើឡើងជាលិខិតយថាភូត[7]។

**ខ.២.៣.** ដើមចោទបានព្រមព្រៀងបង់ប្រាក់កក់ចំនួន ២០.០០០ (ពីរម៉ឺន) ដុល្លារអាមេរិកចំពោះការចុះ "កិច្ចសន្យានៃរឿងក្តីនេះ" ជាមួយចុងចម្លើយ ហើយបានប្រគល់ប្រាក់នេះឲ្យទៅចុងចម្លើយ។

**ខ.២.៤.** នៅថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១៨ ចុងចម្លើយបានធ្វើសំណើផ្តល់ [8]ប្រាក់ជាក់ស្តែងចំនួន ៤០.០០០ (បួនម៉ឺន) ដុល្លារអាមេរិកនៅផ្ទះរបស់ដើមចោទ (ផ្ទះលេខ ០០ ផ្លូវលេខ ០០ សង្កាត់ទំនប់ទឹក ខណ្ឌចំការមនរាជធានីភ្នំពេញ) ហើយបានបង្ហាញឆន្ទៈថា នឹងរំលាយ "កិច្ចសន្យានៃរឿងក្តីនេះ" [9]។

## សំអាងហេតុ

### ក. ការវិនិច្ឆ័យអំពីការទាមទារ

ផ្អែកតាមអង្គហេតុដែលគូភាគីគ្មានវិវាទ តុលាការទទួលស្គាល់ថា "កិច្ចសន្យាលក់ទិញនៃរឿងក្តីនេះ" ត្រូវបានចុះរវាងដើមចោទ និង ចុងចម្លើយមានសុពលភាព ប៉ុន្តែចុងចម្លើយដែលជាភាគីអ្នកលក់បានរំលាយ "កិច្ចសន្យាលក់ទិញនៃរឿងក្តីនេះ" ដោយធ្វើសំណើផ្តល់ប្រាក់ជាក់ស្តែងចំនួន ៤០.០០០ (បួនម៉ឺន) ដុល្លារអាមេរិកដែលជាចំនួនទឹកប្រាក់ពីរដងនៃចំនួនប្រាក់កក់ដែលត្រូវបានប្រគល់នៅពេលចុះ "កិច្ចសន្យាលក់ទិញនៃរឿងក្តីនេះ" (យោងមាត្រា ៥១៨ នៃក្រមរដ្ឋប្បវេណី)។

ដូច្នេះហើយ ការទាមទាររបស់ដើមចោទដែលទាមទារនូវការប្រគល់ "ដី L" និងការធ្វើនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិទាំងមូល ដោយផ្អែកតាម "កិច្ចសន្យាលក់ទិញនៃរឿងក្តីនេះ" គឺពុំមានមូលហេតុទេ (កថាខណ្ឌទី ១ មាត្រា ៤១៤ និង កថាខណ្ឌទី ១ មាត្រា ៤១១ នៃក្រមរដ្ឋប្បវេណី )។

---

[7] ក្រមរដ្ឋប្បវេណី មាត្រា ៣៣៦ កថាខណ្ឌទី ២។ អង្គហេតុដែលមានភាពចាំបាច់ដើម្បីបញ្ជាក់ឲ្យបានច្បាស់លាស់នូវ "កិច្ចសន្យានៃរឿងក្តីនេះ" ដែលបានបង្កើតឡើងដោយមានសុពលភាព។ (ការពន្យល់លម្អិត សូមយោងតាម Footnote នៃពាក្យបណ្តឹង។)

[8] ការពន្យល់លម្អិតអំពីពាក្យថា "ការធ្វើសំណើផ្តល់ជាក់ស្តែង" សូមយោងតាម Footnote នៃឯកសារចម្លើយ។

[9] មាត្រា ៥១៨ មាត្រា ៤១៤ កថាខណ្ឌទី ១ មាត្រា ៤០៩ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី ។ (ការពន្យល់លម្អិត សូមយោងតាម Footnote នៃឯកសារចម្លើយ។)

**ខ. ស្តីពីបន្ទុកនៃប្រាក់ប្រដាប់ក្តី**

ដោយសារតែការទាមទារទាំងអស់របស់ដើមចោទពុំមានមូលហេតុ ដូច្នេះ ប្រាក់ប្រដាប់ក្តី គឺជាបន្ទុករបស់ដើមចោទ (មាត្រា ៦៤ កថាខណ្ឌទី ១ វាក្យខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

## សេចក្តីសម្រេចបញ្ចប់

១. ច្រានចោលការទាមទារទាំងអស់របស់ដើមចោទ។

២. ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ ។

សាលក្រមនេះត្រូវបានប្រកាសនៅសវនការជាសាធារណៈនៅថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១៩ ។ ក្នុងករណីដែលប្តឹងឧទ្ធរណ៍ ត្រូវតែធ្វើឡើងនៅក្នុងរយៈពេល ០១ (មួយ) ខែ គិតចាប់ពីថ្ងៃបានទទួលការបញ្ជូនលិខិតសាលក្រមនេះ។

ថ្ងៃអង្គារ ១១ រោច ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ, ថ្ងៃ ទី៣០ ខែ មេសា ឆ្នាំ២០១៩

**ចៅក្រម**

**ឧបសម្ព័ន្ធ**

## បញ្ជី[10]

| | |
|---|---|
| "គោលបំណងនៃពាក្យសុំចុះបញ្ជី" | ផ្ទេរកម្មសិទ្ធិទាំងមូល |
| "មូលហេតុនៃពាក្យសុំចុះបញ្ជី និង កាលបរិច្ឆេទ" | ការលក់ទិញចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១៨ |
| "បុគ្គលមានសិទ្ធិចុះបញ្ជី" | ដើមចោទ ( X )<br>ថ្ងៃខែឆ្នាំកំណើត ៖ ថ្ងៃ......ខែ..........ឆ្នាំ.........<br>ទីកន្លែងកំណើត ៖ ......................................<br>ឈ្មោះរបស់ឪពុកម្តាយ៖ ..................(ឪពុក)<br>.....................(ម្តាយ) |
| "បុគ្គលមានកាតព្វកិច្ចចុះបញ្ជី" | ចុងចម្លើយ ( Y )<br>ថ្ងៃខែឆ្នាំកំណើត ៖ ថ្ងៃ......ខែ..........ឆ្នាំ.........<br>ទីកន្លែងកំណើត ៖ ......................................<br>ឈ្មោះរបស់ឪពុកម្តាយ៖ ..................(ឪពុក)<br>.....................(ម្តាយ) |
| "អត្តសញ្ញាណនៃអចលនវត្ថុ" | ទីតាំងដី ៖ ផ្លូវលេខ ១០២ ភូមិ ៣ សង្កាត់ ជ្រោយចង្វារ ខណ្ឌ ជ្រោយចង្វារ រាជធានីភ្នំពេញ<br>លេខក្បាលដី៖ ១៣០៦ |

[10] នៅក្នុងសាលក្រម សាលដីកាដែលជំនួសឲ្យការបង្ហាញឆន្ទៈរបស់បុគ្គលមានកាតព្វកិច្ចចុះបញ្ជី ចាំបាច់ត្រូវតែមានការសរសេរទាំងអស់នូវចំណុចដែលចាំបាច់នៅពេលធ្វើពាក្យសុំចុះបញ្ជី (ឧទាហរណ៍ ៖ ចំពោះពាក្យសុំចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិ គឺត្រូវសរសេរអំពីចំណុចដែលបានកំណត់នៅក្នុងប្រការ ២៦ និង ប្រការ ២៨ នៃប្រកាសអន្តរក្រសួងស្តីពីនីតិវិធីនៃការចុះបញ្ជីអំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី)។ ហើយត្រូវធ្វើការបញ្ជាក់ថា គ្មានភាពខ្វះចន្លោះឡើយ។

# រឿងក្តីទាមទារឲ្យធ្វើនីតិវិធីចុះបញ្ជីអំពី
# ការលុបការចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិ
# ដោយផ្អែកលើការរំលាយកិច្ចសន្យា

Yoshie SASAKI / JICA Expert

# អំពីការសន្យាលក់ទិញជាមុន

## ១. បញ្ញត្តិដែលមាននៅក្នុងច្បាប់ទាក់ទងនឹងការបង្កើតកិច្ចសន្យា

(១) មាត្រា ៣៣៦ នៃក្រមរដ្ឋប្បវេណី

ក. "គោលការណ៍"

កថាខណ្ឌទី ១

"កិច្ចសន្យាមានអានុភាពដោយសារសំណើ និង ស្ទីការត្រូវគ្នា។"

→ កិច្ចសន្យាបង្កើតឡើងតាមការព្រមព្រៀងរបស់គូភាគីតែប៉ុណ្ណោះ។

ដើម្បីបង្កើតកិច្ចសន្យា មិនចាំបាច់ត្រូវការអ្វីផ្សេងក្រៅពីការព្រមព្រៀងឡើយ (គោលការណ៍)។

ខ. "ករណីលើកលែង"

កថាខណ្ឌទី ២

"ទោះបីជាមានបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះក៏ដោយ ក៏កិច្ចសន្យាដែលភាគីម្ខាងទទួលករណីកិច្ចធ្វើអនុប្បទាននូវកម្មសិទ្ធិលើអចលនវត្ថុ ឬ ករណីកិច្ចធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើអចលនវត្ថុ នឹងមានអានុភាព លុះត្រាតែបានធ្វើលិខិតយថាភូត។"

→ ចំពោះកិច្ចសន្យាដែលបង្កើតឲ្យមាន "អនុប្បទាននូវកម្មសិទ្ធិលើអចលនវត្ថុ ឬ ករណីយកិច្ចធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើអលចនវត្ថុ" ចាំបាច់ត្រូវមានលិខិតយថាភូត (ករណីលើកលែង)។

ហេតុអ្វីបានជាចាំបាច់ត្រូវធ្វើលិខិតយថាភូត?

① ការពារអនុប្បទាយី

② ការពារអនុប្បទានិក

③ ជៀសវាងវិវាទ

※ សម្រាប់ការពន្យល់ក្បោះក្បាយ សូមយោងតាមសេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី!

(២) មាត្រា ៩ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី

"លិខិតយថាភូត" ដែលកំណត់ក្នុងក្រមរដ្ឋប្បវេណី សំដៅទៅលើលិខិតដូចខាងក្រោម៖

ក- លិខិតយថាភូតដែលកំណត់ក្នុងមាត្រា ៣៣៦ (ការបង្កើតកិច្ចសន្យាដោយសំណើ និង

ស្ទីការ) មាត្រា ៥១៦ (ការបង្កើតកិច្ចសន្យាលក់ទិញ) និង មាត្រា ៨៦២ (អានុភាពនៃការចាត់ចែងហ៊ីប៉ូតែក) នៃក្រមរដ្ឋប្បវេណី សំដៅទៅលើ ① លិខិតដែលត្រូវធ្វើឡើងដោយសារការី ឬ ② លិខិតឯកជនដែលសារការីចុះនិទ្ទេសថា លិខិតនោះមានភាពត្រឹមត្រូវតាមច្បាប់ និង ចុះកាលបរិច្ឆេទ និង ហត្ថលេខាក្រោយពេលខ្លួនបញ្ជាក់ថា លិខិតនោះមានភាពត្រឹមត្រូវតាមច្បាប់។ ប៉ុន្តែ ចំពោះលិខិតយថាភូតដែលកំណត់នៅក្នុងមាត្រា ៣៣៦ (ការបង្កើតកិច្ចសន្យាដោយសំណើ និង ស្ទីការ) និងមាត្រា ៨៦២ (អានុភាពនៃការចាត់ចែងហ៊ីប៉ូតែក)នៃក្រមរដ្ឋប្បវេណី ③ លិខិតដែលមន្ត្រីមានសមត្ថកិច្ចធ្វើឡើងដើម្បីធ្វើនីតិវិធីនៃការចុះបញ្ជីក៏ជាលិខិតយថាភូតដែរ។

→ ③ លិខិតដែលមន្ត្រីមានសមត្ថកិច្ចធ្វើឡើងដើម្បីធ្វើនីតិវិធីនៃការចុះបញ្ជី គឺជាអ្វី?

ឯកសារដែលមានសរសេរឈ្មោះ អត្តសញ្ញាណដីដែលជាកម្មវត្ថុនៃការចុះបញ្ជី និង ចំណុចផ្សេងទៀតដែលត្រូវសរសេរចូលទៅក្នុងទម្រង់ជាក់លាក់មួយ ហើយអនុប្បទាយី អនុប្បទានិក សាក្សី ២រូប ផ្តិតស្នាមមេដៃ និង មេឃុំ ចៅសង្កាត់ ឬ ចៅហ្វាយស្រុក-ខណ្ឌ ចុះហត្ថលេខា និង ប្រថាប់ត្រាផ្លូវការផងដែរ ចំពោះមុខការិយាល័យចុះបញ្ជី។ នៅក្នុងការអនុវត្តជាក់ស្តែង គេឃើញថាជា "លិខិតលក់ផ្តាច់"។

※ សម្រាប់ការពន្យល់ក្បោះក្បាយ សូមយោងតាមសេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី!

## ២. ការអនុវត្តជាក់ស្តែងនៅប្រទេសកម្ពុជាអំពី អចលនវត្ថុ

គិតចាប់ពីក្រោយពេលដែលភាគី (អនុប្បទានយីនៃកម្មសិទ្ធិលើអចលនវត្ថុ និង អនុប្បទានិក) បានព្រមព្រៀងគ្នាចំពោះការលក់ទិញរហូតដល់ពេលដែលលិខិតយថាភូត (រួមទាំងលិខិតលក់ផ្តាច់) ត្រូវបានបង្កើតឡើង គឺមានគម្លាតពេលវេលាពីគ្នា។ នៅក្នុងអំឡុងពេលនោះ ក៏មានការបង់ប្រាក់ផងដែរ។

នៅមុនពេលដែលកិច្ចសន្យាបង្កើតឡើង តើអាចមានការបកស្រាយតាមផ្លូវច្បាប់ដោយបែបណាដែរ អំពីការព្រមព្រៀងដែលបានធ្វើឡើងនៅមុនពេលដែលបង្កើតលិខិតយថាភូត (រួមទាំងលិខិតលក់ផ្តាច់)?




## ៣. ការសន្យាលក់ទិញជាមុនដោយឯកតោភាគី

(១) <u>មាត្រា ៥១៧ នៃក្រមរដ្ឋប្បវេណី</u>

ក. <u>កថាខណ្ឌទី ១</u>

ក្នុងករណីដែលភាគីម្ខាងសន្យាជាមុនក្នុងការលក់ ឬ ទិញ ការលក់ទិញនេះនឹងមានអានុភាពចាប់តាំងពីពេលដែល ភាគីម្ខាងទៀតបង្ហាញឆន្ទៈបំពេញការទិញ ឬ លក់ចំពោះអ្នកសន្យានោះ។

ខ. <u>កថាខណ្ឌទី ២</u>

ប្រសិនបើអំឡុងពេលសម្រាប់ការបង្ហាញឆន្ទៈដែលបានចែងក្នុងកថាខណ្ឌទី ១ នេះមិនត្រូវបានកំណត់ទេ អ្នកសន្យាជាមុនអាចកំណត់នូវអំឡុងពេលសមរម្យមួយ ហើយអាចដាស់តឿនឲ្យភាគីម្ខាងទៀតបង្ហាញឆន្ទៈថា ព្រម ឬ មិនព្រមបំពេញការទិញ ឬ លក់នៅក្នុងអំឡុងពេលនោះ។ ក្នុងករណីដែលភាគីម្ខាងទៀតមិនបានបង្ហាញឆន្ទៈនៅក្នុងអំឡុងពេលកំណត់ទេ ការសន្យាជាមុននោះ ត្រូវបាត់បង់អានុភាព។




(២) <u>ភាពខុសគ្នាជាមួយនឹងការលក់ទិញដែលមានភ្ជាប់អំឡុងពេល</u>

ឧទាហរណ៍ថា គូភាគីបានព្រមព្រៀងគ្នាថា ៣ឆ្នាំក្រោយនឹងបង់ថ្លៃលក់ទិញ ហើយក្នុងពេលជាមួយគ្នានោះ ក៏ធ្វើការប្រគល់យន្តហោះដែរ តើករណីនេះនឹងទៅជាយ៉ាងណាវិញ?

ក្នុងករណីបែបនេះគឺមានន័យថា កិច្ចសន្យាលក់ទិញដែលមានភ្ជាប់អំឡុងពេលបានបង្កើតឡើងរួចរាល់ហើយ។ ចំពោះអំឡុងពេលអនុវត្តកិច្ចសន្យានោះ គឺមិនត្រូវឲ្យលើសពី ៣ឆ្នាំក្រោយឡើយ។ ករណីនេះមិនមែនជាការសន្យាជាមុនទេ។

ផ្ទុយមកវិញ បើគិតអំពីការសន្យាលក់ទិញជាមុនដោយឯកតោភាគីវិញ មានន័យថា កិច្ចសន្យាលក់ទិញដែលជាគោលនោះនៅមិនទាន់បានបង្កើតឡើងនៅឡើយទេ។ ម្យ៉ាងទៀត ជាគោលការណ៍ ដើម្បីបង្កើតកិច្ចសន្យាលក់ទិញនោះបាន គឺចាំបាច់ត្រូវតែមានឆន្ទៈរបស់គូភាគីដែលត្រូវគ្នា ប៉ុន្តែ ចំពោះករណីនៃការសន្យាលក់ទិញជាមុនដោយឯកតោភាគីវិញ ដោយសារតែគូភាគីបានព្រមព្រៀងគ្នាទុកជាមុនអំពីការសន្យាជាមុនរួចហើយ ដូច្នេះហើយ ចំពោះកិច្ចសន្យាលក់ទិញ នឹងអាចធ្វើការបង្កើតឡើងបានតាមរយៈការបង្ហាញឆន្ទៈជាឯកតោភាគីរបស់ភាគីម្ខាងទៀត។ ពោលគឺមានន័យថា ការសន្យាលក់ទិញជាមុនដោយឯកតោភាគីបានផ្តល់សិទ្ធិទៅភាគីម្ខាងទៀតនៃកិច្ចសន្យាក្នុងការសម្រេចថា ទិញ ឬ មិនទិញ ឬក៏ លក់ ឬ មិនលក់។

(៣) <u>អត្ថប្រយោជន៍នៃការសន្យាជាមុន</u>

ខ្លឹមសារខាងក្រោមនេះនឹងបកស្រាយដោយលើកឧទាហរណ៍នៃការសន្យាជាមុនអំពីការលក់។

※ សម្រាប់ការពន្យល់ក្បោះក្បាយ សូមយោងតាមសេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី!

ក. អត្ថប្រយោជន៍សម្រាប់ភាគីម្ខាងទៀត

គូភាគីបានឈានផុតដំណាក់កាលនៃការព្រមព្រៀងអំពីលក្ខខណ្ឌនៃកិច្ចសន្យា (ចំនួនទឹកប្រាក់នៃថ្លៃលក់ទិញ ឬ វិធីបង់ប្រាក់ជាដើម) រួចហើយ ប៉ុន្តែ ភាគីម្ខាងទៀតមិនទាន់ចង់ធ្វើការសម្រេចចិត្តអំពីការបង្កើតកិច្ចសន្យាភ្លាមៗឡើយទេ ដោយចង់ធ្វើការសម្រេចចិត្តថា ទិញ ឬ មិនទិញ ក្រោយពេលដែលបានមើលទៅលើស្ថានភាពនាពេលខាងមុខសិន (ការវិវត្តនៃចំនួនអ្នកប្រើប្រាស់យន្តហោះជាដើម)។ ប៉ុន្តែ បើសិនជាភាគីម្ខាងទៀតសម្រេចចិត្តថា ទិញ គេប្រាកដជាចង់បានលក្ខខណ្ឌដែលបានព្រមព្រៀងគ្នារួចរាល់ដោយភាពជាក់លាក់ (ចំនួនទឹកប្រាក់នៃថ្លៃលក់ទិញ និង វិធីបង់ប្រាក់ជាដើម) នោះមកប្រើ។ ដូច្នេះហើយ លក្ខខណ្ឌទាំងអស់នេះ ភាគីម្ខាងទៀតអាចយកមកការសន្យាទុកជាមុន (ជាប្រភេទមួយនៃកិច្ចសន្យា) ជាមួយនិងអ្នកសន្យាបានផងដែរ។

ខ. អត្ថប្រយោជន៍សម្រាប់អ្នកសន្យា

ប្រសិនបើភាគីម្ខាងទៀតបានសម្រេចចិត្តថា ទិញ នាំឲ្យកិច្ចសន្យាលក់ទិញនឹងត្រូវបង្កើតឡើងស្របតាមលក្ខខណ្ឌនៃកិច្ចសន្យាដែលធ្លាប់បានព្រមព្រៀងគ្នារួចមកហើយ (ចំនួនទឹកប្រាក់ និង វិធីបង់ប្រាក់ជាដើម)។ ហេតុនេះ អ្នកសន្យាមិនចាំបាច់ចរចារគ្នាសាជាថ្មីម្តងទៀតឡើយ។

ម្យ៉ាងវិញទៀត ប្រាក់ដែលភាគីម្ខាងទៀតបានបង់មកឲ្យអ្នកសន្យានៅពេលដែលធ្វើការសន្យាជាមុន គឺជាតម្លៃតបដើម្បីធ្វើលទ្ធកម្មនូវសិទ្ធិដែលភាគីម្ខាងទៀតនោះអាចបង្កើតកិច្ចសន្យាលក់ទិញបាន ដោយធ្វើឡើងតាមរយៈការបង្ហាញឆន្ទៈជាឯកតោភាគី ។ តម្លៃតបនេះ នៅក្នុងការអនុវត្តជាក់ស្តែង គេហៅថា "ប្រាក់កក់"។ បើនិយាយចំពោះអ្នកសន្យាវិញ ប្រាក់នេះ គឺជាប្រាក់ដែលភាគីម្ខាងទៀតបានបង់មកឲ្យ ក្នុងខណៈពេលដែល ភាគីម្ខាងទៀតមិនទាន់កំណត់ច្បាស់ អំពីការបង្កើតកិច្ចសន្យា ឬ ក៏យ៉ាងណានៅឡើយទេ ដោយមានការកំណត់អំឡុងពេលជាក់លាក់ណាមួយផងដែរ ហើយបើទោះបីជាចុងបញ្ចប់ កិច្ចសន្យាមិនបានបង្កើតឡើងក៏ដោយ ក៏អ្នកសន្យាអាចយកប្រាក់នេះមកបំពេញផ្នែកសេដ្ឋកិច្ចបានដោយការធ្វើលទ្ធកម្ម (យ៉ាងណាមិញ ភាគច្រើន មានការព្រមព្រៀងគ្នាថា បើចុងបញ្ចប់កិច្ចសន្យាលក់ទិញបានបង្កើតឡើង តម្លៃតបនេះ (ប្រាក់កក់) នឹងយកមកកាត់ជាមួយនឹងថ្លៃលក់ទិញ )។

## ៤. ការពិចារណាអំពីការអនុវត្តជាក់ស្តែងនៃអចលនវត្ថុនៅប្រទេសកម្ពុជា

(១) ការសន្មតជាមុន

ក. ប្រសិនបើមានការសន្យាលក់ទិញជាមុនជាឯកតោភាគីគឺមានន័យថា នៅពេលនោះគូភាគីទាំង

ពីរបានព្រមព្រៀងគ្នាអំពីលក្ខខណ្ឌនៃកិច្ចសន្យា (ចំនួនទឹកប្រាក់ និង វិធីបង់ប្រាក់ជាដើម ) ពោលគឺ ពេលវេលាដែលគូភាគីបានធ្វើការសន្យាជាមុន នឹងមានគម្លាតពីគ្នារវាងពេលវេលាដែលគូភាគីបង្កើតកិច្ចសន្យាលក់ទិញពិតប្រាកដ (ពេលវេលាដែលភាគីម្ខាងទៀតបានបង្ហាញឆន្ទៈអំពីការបំពេញការទិញ ឬ លក់ទៅអ្នកសន្យា)។

ខ. ចំពោះការលក់ទិញនូវកម្មសិទ្ធិលើអចលនវត្ថុនៅក្នុងប្រទេសកម្ពុជា គឺមានគម្លាតពីគ្នារវាងពេលវេលាដែលគូភាគីទាំងពីរបានព្រមព្រៀងគ្នាទៅលើលក្ខខណ្ឌនៃកិច្ចសន្យា (ចំនួនទឹកប្រាក់ និង វិធីនៃការបង់ប្រាក់ជាដើម) និង ពេលវេលាដែលគូភាគីបង្កើតកិច្ចសន្យាលក់ទិញ (ពេលវេលាដែលលិខិតយថាភូត (រួមទាំងលិខិតលក់ផ្ដាច់)ត្រូវបានបង្កើតឡើង)។

(២) ដូច្នេះ នៅប្រទេសកម្ពុជា បើសិនជាធ្វើការបកស្រាយដោយផ្អែកតាមក្រមរដ្ឋប្បវេណីទៅលើដំណាក់កាលមុនពេលដែលបង្កើតកិច្ចសន្យាលក់ទិញអចលនវត្ថុ ពោលគឺ ការព្រមព្រៀងដែលបានធ្វើឡើងនៅមុនពេលដែលបង្កើតលិខិតយថាភូត (រួមទាំងលិខិតលក់ផ្ដាច់) គឺអាចបកស្រាយប្រហាក់ប្រហែលគ្នាទៅនឹងការសន្យាជាមុនដែរ។




(៣) បញ្ហាដែលនៅសេសសល់

ក. <u>ទំនាក់ទំនងគតិយុត្តក្នុងករណីដែលភាគីម្ខាងទៀតបង្ហាញឆន្ទៈមិនបំពេញការលក់ ឬ ទិញ</u>

→ កិច្ចសន្យាលក់ទិញ នឹងមិនបង្កើតឡើង។

ដើមឡើយ ដោយសារតែភាគីម្ខាងទៀតមានសិទ្ធិសម្រេចថា បំពេញការលក់ ឬ ការទិញ ឬ មិនបំពេញការលក់ ឬ ការទិញ ដូច្នេះហើយ ភាគីម្ខាងទៀត មិនអាចអនុវត្តឲ្យលើសពីសិទ្ធិនេះបានទេ។

ក្នុងករណីដែលភាគីម្ខាងទៀតបានបង់តម្លៃថ្នូរនៃលទ្ធកម្មសិទ្ធិបញ្ចប់ការសន្យាជាមុន និង សម្រេចបង្កើតកិច្ចសន្យាលក់ទិញ គឺយើងច្បាស់ជាអាចគិតថា ដោយសារតែភាគីម្ខាងទៀតបានអនុវត្តនូវសិទ្ធិបញ្ចប់ការសន្យាជាមុន និង សម្រេចបង្កើតកិច្ចសន្យា (លទ្ធផលនៃការអនុវត្តសិទ្ធិបញ្ចប់ការសន្យាជាមុន និង សម្រេចបង្កើតកិច្ចសន្យា គឺ បានបង្ហាញឆន្ទៈមិនបំពេញការលក់ ឬ ទិញ) ទើបអ្នកសន្យាធ្វើលទ្ធកម្មនូវតម្លៃថ្នូរនោះ (មិនចាំបាច់សងទៅឲ្យភាគីម្ខាងទៀតវិញទេ)។ ការយល់ឃើញនេះ មិនមែនយកមាត្រា ៥១៨ នៃក្រមរដ្ឋប្បវេណីយកមកអនុវត្តទេ (ការសន្យាលក់ទិញជាមុន គឺជាការពិភាក្សាគ្នាមុនពេលបង្កើតកិច្ចសន្យាលក់ទិញ ។) ប៉ុន្តែ ការយល់ឃើញនេះ គឺស្រដៀងគ្នាទៅនឹងក្នុងករណីដែលអ្នកទិញបានបង់ប្រាក់កក់ឲ្យទៅអ្នកលក់នៅក្នុងកិច្ចសន្យាលក់ទិញដែលកំពុងកើតមានរៀងរាល់ថ្ងៃនេះ ដោយអ្នកទិញអាចរំលាយកិច្ចសន្យាលក់ទិញបានដោយការបោះបង់ចោលនូវប្រាក់កក់នោះ ។

ខ. <u>ទំនាក់ទំនងគតិយុត្តក្នុងករណីដែលភាគីម្ខាងទៀតបានបង្ហាញឆន្ទៈបំពេញការលក់ ឬ ទិញ</u>

→ ទោះបីជាមានបញ្ញត្តិនៃកថាខណ្ឌទី ១ មាត្រា ៥១៧ នៃក្រមរដ្ឋប្បវេណីក៏ដោយ ក៏កិច្ចសន្យាលក់ទិញនឹងមិនបង្កើតឡើងភ្លាមៗដែរ ដោយសារតែមានកថាខណ្ឌទី ២ មាត្រា ៣៣៦ នៃក្រមរដ្ឋប្បវេណី។

ចាំបាច់ត្រូវវែកញែកករណីបែបនេះ ហើយពិចារណាបន្ថែមទៀត។

i <u>ករណីដែលគូភាគីទាំងពីរបានធ្វើលិខិតយថាភូត (រួមទាំងលិខិតលក់ផ្តាច់)</u>

→ កិច្ចសន្យានឹងកើតមានឡើង (កថាខណ្ឌទី ២ មាត្រា ៣៣៦ នៃក្រមរដ្ឋប្បវេណី)។ គូភាគីទាំងពីរ មានបន្ទុកលើករណីយកិច្ចផ្អែកតាមកិច្ចសន្យាលក់ទិញ។

ii <u>ករណីដែលអ្នកសន្យាមិនសហការក្នុងការបង្កើតលិខិតយថាភូត (រួមទាំងលិខិតលក់ផ្តាច់)</u>

→ កិច្ចសន្យានឹងមិនកើតមានឡើងទេ (កថាខណ្ឌទី ២ មាត្រា ៣៣៦ នៃក្រមរដ្ឋប្បវេណី)។

ប៉ុន្តែ អ្នកសន្យាមានករណីយកិច្ចក្នុងការបំពេញកិច្ចសន្យាលក់ទិញ ផ្អែកតាមការសន្យា

ជាមុន (ជាប្រភេទមួយនៃកិច្ចសន្យា)។ មូលហេតុនេះគឺ ផ្អែកតាមការសន្យាជាមុន គូភាគីទាំងពីរបានព្រមព្រៀងគ្នាអំពីការអនុញ្ញាតឲ្យភាគីម្ខាងទៀតអាចបង្កើតកិច្ចសន្យាលក់ទិញតាមរយៈការបង្ហាញឆន្ទៈជាឯកតោភាគី។ ពោល ក្នុងករណីដែលភាគីម្ខាងទៀតបានបង្ហាញឆន្ទៈអំពីការបំពេញការលក់ ឬ ទិញ អ្នកសន្យាត្រូវមានករណីយកិច្ចតបទៅនឹងការបង្ហាញឆន្ទៈនោះ ជាក់ស្តែងគឺ មានករណីយកិច្ចក្នុងការបំពេញកិច្ចសន្យាលក់ទិញ។

ដូច្នេះហើយ ភាគីម្ខាងទៀត ច្បាស់ជាអាចទាមទារ (មាត្រា ៣៩៦ នៃក្រមរដ្ឋប្បវេណី) ឲ្យអ្នកសន្យាអនុវត្តករណីកិច្ចក្នុងការបំពេញការលក់ ឬ ទិញដោយផ្អែកតាមការសន្យាជាមុន (ជាប្រភេទមួយនៃកិច្ចសន្យា)បាន។ ចំពោះខ្លឹមសារលម្អិតនៃការបកស្រាយបែបនេះ មានទស្សនៈដែលបានយល់ឃើញដូចខាងក្រោម។ ប៉ុន្តែ បើទោះបីជាយកតាមទស្សនៈណាមួយក៏ដោយ ក៏ទស្សនៈនីមួយៗសុទ្ធសឹងតែមានបញ្ហាផ្អែកតាមការពិភាក្សានីមួយៗនោះផងដែរ ហេតុនេះហើយ ចំណុចទាំងនេះ សូមឲ្យអ្នកច្បាប់នៅក្នុងប្រទេសកម្ពុជាពិចារណានៅពេលក្រោយ។

① ការចេញសាលក្រម ( សាលក្រមនៃបណ្តឹងទាមទារឲ្យបង្កើត ប្តូរ ឬ រំលត់ទំនាក់ទំនងគតិយុត្ត) ដែលទទួលស្គាល់អំពីការបង្កើតកិច្ចសន្យា។ តាមរយៈសាលក្រមនេះនឹងជំនួសឲ្យលិខិតយថាភូត (រួមទាំងលិខិតលក់ផ្តាច់)។

② ការចេញសាលក្រមដែលបង្គាប់នូវករណីយកិច្ចទៅកាន់អ្នកសន្យាឲ្យធ្វើលិខិតយថាភូតដែលស្របតាមលក្ខខណ្ឌនៃកិច្ចសន្យា (ចំនួនទឹកប្រាក់ និង វិធីបង់ប្រាក់ជាដើម) ដូចមានចែងនៅក្នុងការសន្យា ។

វិធីបែបនេះ គឺជាវិធីមួយដែលនឹងធ្វើការជំនួសនូវការបង្ហាញឆន្ទៈរបស់ភាគីម្ខាងតាមរយៈសាលក្រម ក្នុងករណីដែលភាគីម្ខាងទៀតនោះមិនឆ្លើយតបចំពោះការបង្កើតលិខិតយថាភូត។ វិធីនេះគឺដូចគ្នាទៅនឹងករណីដែលចេញសាលក្រមទៅកាន់ភាគីដែលមិនសហការក្នុងការដាក់ពាក្យសុំចុះបញ្ជី ដែលជំនួសឲ្យការបង្ហាញឆន្ទៈអំពីការដាក់ពាក្យសុំចុះបញ្ជីដូច្នេះដែរ។

③ ការចេញសាលក្រមដែលបង្គាប់ទៅអ្នកសន្យាអំពីករណីយកិច្ចធ្វើនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិដោយផ្ទាល់តែម្តង។

នៅក្នុងវិធីទី ① និង ទី ② ភាគីម្ខាងទៀតនឹងដាក់ពាក្យសុំចុះបញ្ជីផ្ទេរកម្មសិទ្ធិដោយផ្អែកលើ កិច្ចសន្យាលក់ទិញដែលបានបង្កើតឡើងតាមវិធីទី ① និង ទី ②

ដូច្នេះហើយ មិនចាំបាច់ត្រូវការនូវសាលក្រមដែលបង្គាប់អំពីនីតិវិធីនៃការចុះបញ្ជីទៅកាន់អ្នកសន្យាសាជាថ្មីម្ដងទៀតទេ ។ មូលហេតុនេះ ដោយសារតែកម្រមានករណីណាមួយដែលអ្នកសន្យាដែលមិនបានសហការក្នុងការធ្វើលិខិតយថាភូត នឹងមកចូលរួមសហការក្នុងការធ្វើពាក្យសុំចុះបញ្ជីនៅពេលក្រោយនោះវិញឡើយ ហើយករណីដែលភាគីម្ខាងទៀតត្រូវតែដាក់ពាក្យសុំចុះបញ្ជីតែម្នាក់ឯងវិញនឹងអាចកើតមានច្រើនជាងទៅវិញ។ ដូច្នេះហើយ វិធីទី ៣ គឺជាវិធីដែលបានទទួលស្គាល់នូវវិធីសាស្ត្រដែលមានលក្ខខណៈដោយផ្ទាល់ ជាជាងការបន្ថែមនូវការប្រើវិធីទី ① និង ទី ②។

យ៉ាងណាមិញ ទោះបីជាភាគីម្ខាងទៀតបានទាមទារទៅកាន់តុលាការឲ្យអ្នកសន្យាអនុវត្តនូវការបំពេញការលក់ ឬ ទិញ នៅពេលដែលអ្នកសន្យាបានធ្វើអនុប្បទាននូវកម្មសិទ្ធិលើអចលនវត្ថុឲ្យទៅតតិយជនចប់សព្វគ្រប់ ហើយការចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិបានដាក់ទៅជារបស់តតិយជននោះ ភាគីម្ខាងទៀតនឹងមិនអាចធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើអចលនវត្ថុបានទេ (យោង មាត្រា ១៣៥ នៃក្រមរដ្ឋប្បវេណី)។

អាស្រ័យហេតុនេះ នៅក្នុងករណីបែបនោះ ភាគីម្ខាងទៀតនឹងអាចទាមទារទៅកាន់អ្នកសន្យាអំពីសំណងការខូចខាតដោយផ្អែកលើការមិនអនុវត្តកាតព្វកិច្ចរបស់អ្នកសន្យាក្នុងការបំពេញនូវការលក់ ឬ ទិញ (មាត្រា ៣៩៧ នៃក្រមរដ្ឋប្បវេណី)។ ចំនួនទឹកប្រាក់នៃសំណងការខូចខាតក្នុងករណីនេះ អាចនឹងមានទស្សនៈដូចខាងក្រោម៖

① ក្នុងករណីដែលមានការព្រមព្រៀងជាមុនអំពីចំនួនទឹកប្រាក់នៃសំណងការខូចខាត
→ នឹងត្រូវយកតាមចំនួនទឹកប្រាក់ដែលបានកំណត់តាមការព្រមព្រៀង (មាត្រា ៤០៣ )។

② ក្នុងករណីដែលមិនមានការព្រមព្រៀងជាមុនអំពីចំនួនទឹកប្រាក់នៃសំណងការខូចខាត
→ អាចនឹងមានទស្សនៈថា នឹងត្រូវគិតតាមចំនួនទឹកប្រាក់ដែលស្មើនឹងតម្លៃនៃអចលនវត្ថុនាពេលនោះ

មូលហេតុដែលមានទស្សនៈបែបនេះដោយសារតែ ជាគោលការណ៍ ភាគីម្ខាងទៀតអាចបង្កើតកិច្ចសន្យាលក់ទិញដោយគ្រាន់តែបង្ហាញឆន្ទៈជាឯកតោភាគីរបស់ភាគីនោះ គឺច្បាស់ជាអាចធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើអចលនវត្ថុជាក់ជាមិនខាន។ ហើយមូលហេតុដែលនាំឲ្យភាគីម្ខាងទៀតមិនអាចធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើអលចនវត្ថុបាន

គឺគ្មានអ្វីក្រៅពីការមិនបានសហការចំពោះការធ្វើលិខិតយថាភូតដោយអ្នកសន្យានោះទេ។ ដូច្នេះហើយ ភាគីម្ខាងទៀត អាចទាមទារសំណងការខូចខាត (កថាខណ្ឌទី ១ មាត្រា ៤០០ នៃក្រមរដ្ឋប្បវេណី) នូវចំនួនទឹកប្រាក់ដែលស្មើនឹងតម្លៃនៃអចលនវត្ថុនោះមកធ្វើជាសំណងនៃផលប្រយោជន៍ដែលនឹងត្រូវកើតមានឡើងប្រសិនបើការសន្យា ជាមុន (ជាប្រភេទមួយនៃកិច្ចសន្យា) ត្រូវបានអនុវត្ត ពោលគឺ ចំនួនទឹកប្រាក់ដែលស្មើនឹងតម្លៃនៃអចលនវត្ថុនាពេលនោះ ។

ចំណុចបន្ទាប់សូមលើកឧទាហរណ៍ទាក់ទងនឹងករណីដែលតម្លៃនៃអចលនវត្ថុនាពេលនោះ មានការកើនឡើងខ្លាំងជាងពេលដែលបានធ្វើការសន្យា។ ឧទាហរណ៍ ៖ នៅពេលដែលធ្វើការសន្យាលក់ទិញជាមុនជាឯកតោភាគីមានការលើកឡើងថា "នឹងធ្វើការលក់ទិញអចលនវត្ថុក្នុងតម្លៃ ១០០.០០០ (មួយសែន) ដុល្លារអាមេរិក" ប៉ុន្តែក្រោយមក អចលនវត្ថុនោះបានកើនតម្លៃឡើងដល់ ១.០០០.០០០ (មួយលាន) ដុល្លារអាមេរិក ។ ក្នុងករណីបែបនេះ បើសិនជាភាគីម្ខាងទៀត គ្រាន់តែធ្វើការបង្ហាញឆន្ទៈអំពីការបំពេញការលក់ ឬ ទិញនោះ ច្បាស់ជាអាចទិញបាននូវអចលនវត្ថុដែលមានតម្លៃ ១.០០០.០០០ (មួយលាន) ដុល្លារអាមេរិកជាក់ជាមិនខាន។ ប៉ុន្តែដោយសារតែអ្នកសន្យាខកខានក្នុងការអនុវត្តកាតព្វកិច្ចក្នុងការបំពេញការលក់ ឬ ទិញ ទើបបានជាភាគីម្ខាងទៀតមិនអាចទិញអចលនវត្ថុ (មានតម្លៃ ១.០០០.០០០ (មួយលាន) ដុល្លារអាមេរិក) នោះបាន។ ដូច្នេះ ភាគីម្ខាងទៀត អាចទាមទារទៅអ្នកសន្យានូវចំនួនទឹកប្រាក់ដែលស្មើនឹងតម្លៃនៃអចលនវត្ថុនោះមកធ្វើជាផលប្រយោជន៍ដែលនឹងត្រូវកើតមានឡើងនៅពេលដែលការសន្យា ជាមុន (ជាប្រភេទមួយនៃកិច្ចសន្យា) ត្រូវបានអនុវត្ត ពោល គឺទាមទារនូវការបង់ប្រាក់ចំនួន ១.០០០.០០០ (មួយលាន) ដុល្លារអាមេរិក (យ៉ាងណាមិញ ក្នុងករណីដែលមិនទាន់មានការបង់ប្រាក់នៃថ្លៃលក់ទិញចំនួន ១០០.០០០ (មួយសែន) ដុល្លារអាមេរិកទេ នាំឲ្យចំនួនទឹកប្រាក់នៃសំណងនាពេលជាក់ស្តែងស្មើនឹង ៩០០.០០០ (ប្រាំបួនសែន) ដុល្លារអាមេរិក។) ។

ចំពោះទស្សនៈបែបនេះ ក្នុងករណីដែលអចលនវត្ថុដែលមានការបង្កើតនូវការសន្យាជាមុនវិញ ហើយក្រោយមក តម្លៃនោះមានការកើនឡើង ហើយអ្នកសន្យា (អនុប្បទាយី) បានលក់អចលនវត្ថុដែលមានការបង្កើតនូវការសន្យាជាមុននេះឲ្យទៅតតិយជនដោយចិត្តឯងក៏ដោយ ក៏ទស្សនៈនេះអាចធ្វើការការពារជាមុននូវរឿងរ៉ាវដែលកើតមានជាក់ស្តែងអំពី ការលក់បន្តបែបនេះបានផងដែរ ដោយឲ្យអ្នកសន្យាធ្វើការសងសំណងនូវចំនួនទឹកប្រាក់ដែលស្មើនឹងតម្លៃនៃចលនវត្ថុដែលបានកើនឡើងនៅពេលក្រោយនោះ

ឲ្យទៅភាគីម្ខាងទៀត (ទោះបីជាអ្នកសន្យាបានលក់បន្តឲ្យទៅតតិយជនក៏ដោយ ក៏អ្នកសន្យានឹងត្រូវសងសំណងជាផលប្រយោជន៍ដែលខ្លួនទទួលបានពីការលក់បន្តនោះឲ្យទៅភាគីម្ខាងទៀតដែរ ដូច្នេះហើយ បើនិយាយចំពោះអ្នកសន្យាវិញ គឺគ្មានអត្ថប្រយោជន៍ជាលក្ខណៈសេដ្ឋកិច្ចចំពោះការលក់បន្តនេះឡើយ)។ ចំណុចនេះគឺជាការផ្សាភ្ជាប់ទៅនឹងការការពារដល់ភាគីម្ខាងទៀត (អនុប្បទានិក) ដែលមានសិទ្ធិបញ្ចប់ការសន្យាជាមុន និង សម្រេចបង្កើតកិច្ចសន្យាលក់ទិញផងដែរ។

សូមអរគុណ

Yoshie SASAKI / JICA Expert

# អំពីសាលក្រមដែលបង្គាប់ឲ្យផ្តល់តាវកាលិកតប

※មាត្រាដែលបានដកស្រង់ដាក់នៅក្នុងឯកសារនេះ គឺជាមាត្រាដែលចែងនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី លុះត្រាតែមានការចែងផ្សេងពីនេះ។

## ១. តើសាលក្រមដែលបង្គាប់ឲ្យផ្តល់តាវកាលិកតបគឺជាអ្វី?

(១) មាត្រាដែលពាក់ព័ន្ធ

ក. កថាខណ្ឌទី ៣ មាត្រា ៣៦១

ក្នុងករណីតាវកាលិករបស់កូនបំណុលនៃការអនុវត្ត ត្រូវផ្តល់ដោយប្តូរនឹងតាវកាលិកតប ស្ថាប័នអនុវត្តអាចចាប់ផ្តើមអនុវត្តដោយបង្ខំបាន លុះត្រាតែម្ចាស់បំណុលនៃការអនុវត្តបញ្ជាក់ថា ខ្លួនបានផ្តល់តាវកាលិកតបនោះ ឬ បានស្នើផ្តល់តាវកាលិកតបនោះ។

ខ. មាត្រា ៥២៩

i កថាខណ្ឌទី ១

(....)បើការបង្ហាញឆន្ទៈរបស់កូនបំណុលនៃការអនុវត្ត ត្រូវធ្វើដោយប្តូរជាមួយនឹងតាវកាលិកតប ត្រូវចាត់ទុកថាកូនបំណុលនោះបានបង្ហាញឆន្ទៈ នៅពេលដែលរូបមន្តអនុវត្តត្រូវបានផ្តល់ តាមបញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រានេះ។

ii កថាខណ្ឌទី ២

ក្នុងករណីដែលការបង្ហាញឆន្ទៈរបស់កូនបំណុលនៃការអនុវត្ត ត្រូវធ្វើដោយប្តូរជាមួយនឹងតាវកាលិកតបរបស់ម្ចាស់បំណុលនៃការអនុវត្ត រូបមន្តអនុវត្តអាចផ្តល់បានលុះត្រាតែម្ចាស់បំណុលនៃការអនុវត្តបានដាក់លិខិតបញ្ជាក់ថា ខ្លួនបានផ្តល់ ឬ បានស្នើផ្តល់តាវកាលិកតបនោះហើយ។

(២) តើករណីបែបណាដែលជា "ករណីដែលតាវកាលិក (ឬ ការបង្ហាញឆន្ទៈ) របស់កូនបំណុលនៃការអនុវត្តត្រូវធ្វើដោយប្តូរជាមួយនឹងតាវកាលិកតបរបស់ម្ចាស់បំណុលនៃការអនុវត្ត"?

→នៅពេលដែលនីតិវិធីនៃបណ្តឹង ចុងចម្លើយបានអះអាងនូវការតវ៉ាអំពីការអនុវត្តព្រមគ្នា ឬ

ការតវ៉ាអំពីសិទ្ធិឃាត់ទុក ហើយតុលាការទទួលស្គាល់ចំពោះការតវ៉ានេះ

ក តើការតវ៉ាអំពីការអនុវត្តព្រមគ្នាគឺជាអ្វី?

មាត្រា ៣៨៦ នៃក្រមរដ្ឋប្បវេណី ជាដើម[1]

ភាគីនីមួយៗ នៃកិច្ចសន្យាអញ្ញមញ្ញអាចប្រកែកមិនព្រមអនុវត្តកាតព្វកិច្ចរបស់ខ្លួនរហូតដល់ពេលដែលភាគីម្ខាងទៀតផ្ដល់នូវការអនុវត្តកាតព្វកិច្ច។

ខ តើសិទ្ធិឃាត់ទុកគឺជាអ្វី?

កថាខណ្ឌទី ១ មាត្រា ៧៧៤

ប្រសិនបើអ្នកកាន់កាប់វត្ថុរបស់អ្នកដទៃ មានសិទ្ធិលើបំណុលដែលបានកើតឡើង ដោយទាក់ទងនឹងវត្ថុនោះ អ្នកនោះអាចឃាត់ទុកនូវវត្ថុនោះបាន រហូតដល់ពេលដែលខ្លួនទទួលការសងចំពោះសិទ្ធិលើបំណុលនោះ។

នៅក្នុងនីតិវិធីនៃបណ្ដឹង ប្រសិនបើដើមចោទទាមទារនូវសាលក្រមដែលបង្គាប់ឲ្យផ្ដល់តាវកាលិកធម្មតា (សាលក្រមដែលបង្គាប់ឲ្យផ្ដល់តាវកាលិកដោយពុំមានលក្ខខណ្ឌ) ហើយចុងចម្លើយបានអះអាងនូវការតវ៉ាអំពីការអនុវត្តព្រមគ្នា ឬ ការតវ៉ាអំពីសិទ្ធិឃាត់ទុក ហើយតុលាការទទួលស្គាល់ចំពោះការតវ៉ានេះ តុលាការនឹងត្រូវចេញសាលក្រមដែលបង្គាប់ឲ្យផ្ដល់តាវកាលិកតប ដោយពុំធ្វើការច្រានចោលនូវការទាមទារទាំងអស់របស់ដើមចោទ (សាលក្រមដែលច្រានចោលការទាមទារទាំងអស់)ឡើយ ។

មូលហេតុដែលតុលាការត្រូវចេញសាលក្រមបង្គាប់ឲ្យផ្ដល់តាវកាលិកតប ព្រោះការទាមទាររបស់ដើមចោទ (សាលក្រមដែលបង្គាប់ឲ្យផ្ដល់តាវកាលិកដោយគ្មានលក្ខខណ្ឌ) មិនមែនគ្មានមូលហេតុចំពោះការទាមទារនោះទាំងស្រុងឡើយ គឺគ្រាន់តែគ្មានមូលហេតុចំពោះផ្នែកដែល "គ្មានលក្ខខណ្ឌ" តែប៉ុណ្ណោះ ដូច្នេះហើយ ប្រសិនបើ តុលាការច្រានចោលការទាមទាររបស់ដើមចោទទាំងអស់ នឹងមិនមានភាពសមហេតុផលទេ។ ពោល គឺ បើសិនជាការទាមទាររបស់ដើមចោទ មានការប្ដូរជាមួយនឹងការផ្ដល់នូវការ អនុវត្តកាតព្វកិច្ចដោយដើមចោទផ្ទាល់ នឹងធ្វើឲ្យការទាមទារនោះមានមូលហេតុ មានន័យថា បើសិនជាភ្ជាប់ជាមួយលក្ខខណ្ឌបែបណា

[1] ក្រៅពីមាត្រា ៣៨៦ នៃក្រមរដ្ឋប្បវេណី ក៏នៅមានមាត្រាផ្សេងទៀតដូចជា កថាខណ្ឌទី ២ នៃមាត្រា ៤១១ កថាខណ្ឌទី ១ នៃមាត្រា ៥៥១ កថាខណ្ឌទី ១ នៃមាត្រា ៥៥៨ ជាដើម។

មួយជាមួយនឹងការទាមទារនោះ ដូច្នេះហើយ តុលាការចាំបាច់ត្រូវតែទទួលត្រឹមកម្រិតដែលភ្ជាប់លក្ខខណ្ឌនោះ។

ឧទាហរណ៍៖ នៅក្នុងពាក្យបណ្តឹង ត្រង់ "ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ" ដើមចោទបានសរសេរថា " បង្គាប់ឲ្យចុងចម្លើយធ្វើនីតិវិធីចុះបញ្ជីអចលនវត្ថុដែលបានកត់ត្រាក្នុងបញ្ជីឧបសម្ព័ន្ធឲ្យទៅដើមចោទ" ។ ការសរសេរបែបនេះ គឺមិនបានភ្ជាប់ជាមួយលក្ខខណ្ឌនៅពេលដែលចុងចម្លើយអនុវត្តកាតព្វកិច្ចនោះទេ ដូច្នេះហើយ វានឹងក្លាយទៅជាការទាមទារដែលដើមចោទទាមទារទៅចុងចម្លើយឲ្យអនុវត្តកាតព្វកិច្ចធ្វើនីតិវិធីចុះបញ្ជីដោយគ្មានលក្ខខណ្ឌ។ ទាក់ទងចំណុចនេះ បើសិនជាចុងចម្លើយអះអាងអំពី ការបដិសេធមិនអនុវត្តកាតព្វកិច្ចធ្វើនីតិវិធីចុះបញ្ជីទេ លុះត្រាតែដើមចោទផ្តល់នូវការអនុវត្តកាតព្វកិច្ចរបស់ដើមចោទ (ឧទាហរណ៍ ៖ សងប្រាក់ដែលចុងចម្លើយបានបង់ឲ្យទៅដើមចោទ) ហើយតុលាការបានទទួលស្គាល់ទៅលើការអះអាងរបស់ចុងចម្លើយបែបនេះ នាំឲ្យមានអត្ថិភាពនៃកាតព្វកិច្ច ដែលចុងចម្លើយធ្វើនីតិវិធីចុះបញ្ជីឲ្យទៅដើមចោទពិតមែន ប៉ុន្តែ ចំពោះការអនុវត្តកាតព្វកិច្ចនោះ នឹងត្រូវភ្ជាប់ជាមួយលក្ខខណ្ឌដែលត្រូវអនុវត្តព្រមគ្នា ដោយទទួលបាននូវការផ្តល់ការអនុវត្តកាតព្វកិច្ចពីដើមចោទ (ការសងប្រាក់)មកវិញ ទើបជាការប្រសើរ។ ដូច្នេះហើយ តុលាការមិនមែនច្រានចោលនូវការទាមទារទាំងអស់របស់ដើមចោទទេ គឺចាំបាច់ត្រូវទទួលស្គាល់(ទទួលស្គាល់មួយផ្នែក ច្រានចោលមួយផ្នែក) នូវការទាមទារដោយភ្ជាប់នូវលក្ខខណ្ឌបែបនោះ ។

(៣) រៀបសរសេរសេចក្តីសម្រេចបញ្ចប់

ឧទាហរណ៍៖ នៅក្នុងរឿងក្តីដែលដើមចោទទាមទារទៅចុងចម្លើយឲ្យធ្វើនីតិវិធីចុះបញ្ជីអចលនវត្ថុ ចុងចម្លើយបានអះអាងនូវការតវ៉ាអំពីការអនុវត្តព្រមគ្នា ហើយក្នុងករណីដែលតុលាការបានទទួលស្គាល់នូវការតវ៉ានោះ រួចចេញសាលក្រមដែលបង្គាប់ឲ្យផ្តល់តាវកាលិកតប សេចក្តីសម្រេចបញ្ចប់នឹងសរសេរដូចខាងក្រោម៖

" ១. <u>បង្គាប់ឲ្យចុងចម្លើយធ្វើនីតិវិធីចុះបញ្ជីអលចនវត្ថុដែលបានកត់ត្រានៅក្នុងបញ្ជីឧបសម្ព័ន្ធឲ្យទៅដើមចោទជាថ្នូរនឹងការទទួលនូវការបង់ប្រាក់ចំនួន................ ដុល្លារអាមេរិកពីដើមចោទ។</u>

២. <u>ច្រានចោលការទាមទារផ្សេងពីនោះរបស់ដើមចោទ។</u>

៣. ប្រាក់ប្រដាប់ក្តីចែកជា......ចំណែក ដោយ..........ចំណែកនោះជាបន្ទុករបស់ ដើមចោទ

ក្រៅពីនោះជាបន្ទុករបស់ចុងចម្លើយ។”

ដោយសារតែតុលាការមិនបានទទួលស្គាល់នូវការទាមទារដែលដើមចោទបានទាមទារនូវតាវកាលិកធម្មតា (តាវកាលិកដែលគ្មានលក្ខខណ្ឌ) តែម្តងនោះទេ ដូច្នេះហើយចាំបាច់ត្រូវមានចំណុច ២.។

## ២. តើសាលក្រមដែលបង្គាប់អំពីតាវកាលិកតប ផ្ទុយនឹងកថាខណ្ឌទី ២ នៃមាត្រា ១៨២ ឬទេ?

(១) កថាខណ្ឌទី ២ នៃមាត្រា ១៨២

តុលាការមិនអាចចេញសាលក្រមចំពោះចំណុចណាដែលភាគីមិនបានសុំឡើយ។

(២) <u>សាលក្រមដែលបង្គាប់អំពីតាវកាលិកតប មិនផ្ទុយនឹងកថាខណ្ឌទី ២ នៃមាត្រា ១៨២ ទេ!</u>

នៅក្នុងសាលក្រមដែលបង្គាប់អំពីតាវកាលិកតប តុលាការនឹងសរសេរសេចក្តីសម្រេចបញ្ចប់អំពី ការបង្គាប់នូវការផ្តល់តាវកាលិក (ផ្នែកដែលសរសេរថា "បង្គាប់ឲ្យចុងចម្លើយធ្វើនីតិវិធីចុះបញ្ជីអលចលនវត្ថុដែលបានកត់ត្រានៅក្នុងបញ្ជីឧបសម្ព័ន្ធឲ្យទៅដើមចោទ”) ជាមួយគ្នានឹងការសរសេរអំពីការផ្តល់តាវកាលិកតប (ផ្នែកដែលសរសេរថា "ជាថ្នូរនឹងការទទួលនូវការបង់ប្រាក់ចំនួន ............ដុល្លារអាមេរិកពីដើមចោទ។”)។ ប៉ុន្តែ ផ្នែកដែលបានសរសេរអំពីតាវកាលិកតបនេះ គឺគ្រាន់តែជាការសរសេរដើម្បីសម្គាល់ឲ្យឃើញអំពី ① លក្ខខណ្ឌនៃការចាប់ផ្តើមអនុវត្តដោយបង្ខំ (កថាខណ្ឌទី ៣ មាត្រា ៣៦១) ឬ ② លក្ខខណ្ឌនៃការផ្តល់ រូបមន្តអនុវត្តដែលមានភាពចាំបាច់ដើម្បីអាចចាត់ទុកថាមានការបង្ហាញឆន្ទៈ (មាត្រា ៥២៩) ប៉ុណ្ណោះ ហើយការសរសេរនេះមិនមែនជាការបង្កើតនូវកម្មវត្ថុនៃបណ្តឹងទេ (ការទាមទាររបស់ដើមចោទ)។

ពោល សាលក្រមដែលបង្គាប់អំពីតាវកាលិកតបចំពោះចំណុចដែលដើមចោទបានទាមទារអំពីការអនុវត្តករណីយកិច្ចធ្វើនីតិវិធីចុះបញ្ជីដោយគ្មានលក្ខខណ្ឌពីចុងចម្លើយមកដើមចោទ គឺជាសាលក្រមដែលបង្គាប់អំពីការអនុវត្តករណីយកិច្ចធ្វើនីតិវិធីចុះបញ្ជីដោយភ្ជាប់លក្ខខណ្ឌថា "ជាថ្នូរនឹងការទទួលនូវការបង់ប្រាក់ចំនួន.........ដុល្លារអាមេរិកពីដើមចោទ” ។ ដូច្នេះហើយ សាលក្រមដែលបង្គាប់អំពីតាវកាលិកតប គឺជាសាលក្រមដែលទទួលស្គាល់នូវការទាមទារមួយផ្នែក ហេតុនេះមិនមែនមានន័យថា ជាសាលក្រមដែលបានវិនិច្ឆ័យអំពីចំណុចដែលដើមចោទមិនបានទាមទារនោះទេ ។ ហេតុនេះ សាលក្រមដែលបង្គាប់អំពីតាវកាលិកតប គឺមិនផ្ទុយនឹងកថា

ខណ្ឌទី ២ មាត្រា ១៨២ ទេ។

ដើម្បី ① ចាប់ផ្តើមអនុវត្តដោយបង្ខំ ឬ ② ទទួលបាននូវការផ្តល់រូបមន្តអនុវត្តដែលមានភាពចាំបាច់ដើម្បីអាចចាត់ទុកថាមានការបង្ហាញឆន្ទៈ ដើមចោទចាំបាច់ត្រូវបញ្ជាក់ភស្តុតាងថាបានផ្តល់តាវកាលិកតប ឬ បានស្នើផ្តល់តាវកាលិកតបនោះ។ ពោល នៅក្នុងសាលក្រមដែលបង្គាប់អំពីការផ្តល់តាវកាលិកតប ត្រង់ផ្នែកដែលបានសរសេរអំពីការផ្តល់តាវកាលិកតប (ផ្នែកដែលសរសេរថា "ដាថ្នូរនឹងការទទួលនូវការបង់ប្រាក់ចំនួន.........ដុល្លារអាមេរិកពីដើមចោទ") បើទោះបីជាសាលក្រមបានចូលជាស្ថាពរក៏ដោយក៏មិនមែនមានន័យថា ម្ចាស់បំណុលនៃការអនុវត្តអាចធ្វើការទាមទារឲ្យចាប់ផ្តើមធ្វើការអនុវត្តដោយបង្ខំបានដោយគ្មានលក្ខខណ្ឌទេ (ឬត្រូវបានចាត់ទុកថាជាផ្នែកដែលមានការបង្ហាញឆន្ទៈរបស់កូនបំណុលនៃការអនុវត្ត) ពោលគឺមានន័យថា គឺជាការសរសេរដែលធ្វើឡើងដើម្បីសម្គាល់ឲ្យឃើញថា ក្រៅពី សាលក្រមបានចូលជាស្ថាពររួចហើយ ចាំបាច់ត្រូវមានការបញ្ជាក់ភស្តុតាងថា ដើមចោទ (ម្ចាស់បំណុលនៃការអនុវត្ត) បានផ្តល់នូវតាវកាលិកតប ឬ បានស្នើផ្តល់តាវកាលិកតបនោះរួចហើយ។

ផ្ទុយមកវិញ ចំពោះចុងចម្លើយ មិនអាចនិយាយថា ខ្លួនមិនអាចទទួលបាននូវ "ការសងប្រាក់ចំនួន........ដុល្លារអាមេរិក" រួចហើយដាក់ពាក្យសុំអនុវត្តដោយបង្ខំទៅដើមចោទដោយផ្អែកទៅលើសាលក្រមដែលបង្គាប់ឲ្យផ្តល់តាវកាលិកតបនេះបានទេ។ មូលហេតុ គឺដោយសារតែសាលក្រមដែលបង្គាប់ឲ្យផ្តល់តាវកាលិកតបជាសាលក្រមដែលតុលាការគ្រាន់តែបានទទួលស្គាល់នូវការទាមទាររបស់ដើមចោទមួយភាគប៉ុណ្ណោះ ហើយមិនមែនជាសាលក្រមដែលសម្រេចចំពោះចុងចម្លើយទេ។ នៅក្នុងសាលក្រមដែលបង្គាប់ឲ្យផ្តល់តាវកាលិកតប ត្រង់ផ្នែកដែលសរសេរអំពីការផ្តល់តាវកាលិកតប ("ដាថ្នូរនឹងការទទួលនូវការបង់ប្រាក់ចំនួន...........ដុល្លារអាមេរិកពីដើមចោទ") គឺគ្រាន់តែជាការសរសេរកំណត់សម្គាល់ថា ទាល់តែដើមចោទបានអនុវត្តនូវការកត់ត្រាដែលមាននៅក្នុងសាលក្រម តែប៉ុណ្ណោះ។

(៣) ចុះតើធ្វើគួរធ្វើបែបណាទើបចុងចម្លើយក៏អាចដាក់ពាក្យសុំអនុវត្តដោយបង្ខំអំពីការផ្តល់តាវកាលិកតបរបស់ដើមចោទបានដែរ?

→ <u>នៅក្នុងនីតិវិធីនៃបណ្តឹងចាំបាច់ត្រូវមានការដាក់ពាក្យបណ្តឹងតប (មាត្រា ៨៦) ចំពោះតាវកាលិករបស់ដើមចោទ</u> ដោយមិនមែនគ្រាន់តែធ្វើការអះអាងនូវការតវ៉ាអំពីការអនុវត្តព្រម

គ្នា ឬ ការតវ៉ាអំពីសិទ្ធិឃាត់ទុកតែប៉ុណ្ណោះទេ។

នៅក្នុងផ្នែកទី 1 ត្រង់ចំណុចលេខ (3) ដែលស្ដីអំពីឧទាហរណ៍អំពីសេចក្ដីសម្រេចបញ្ចប់នៃករណីសិក្សាខាងលើ ប្រសិនបើ ចុងចម្លើយបានដាក់ពាក្យបណ្ដឹងតបទៅដើមចោទវិញថា "បង្គាប់ឲ្យចុងចម្លើយនៃបណ្ដឹងតប (ដើមចោទនៃបណ្ដឹងអង្គសេចក្ដី) បង់ប្រាក់ចំនួន...... ដុល្លារអាមេរិកឲ្យទៅដើមចោទនៃបណ្ដឹងអង្គសេចក្ដី (ចុងម្លើយនៃបណ្ដឹងអង្គសេចក្ដី)" ហើយចុងចម្លើយនៃបណ្ដឹងតប (ដើមចោទនៃបណ្ដឹងអង្គសេចក្ដី) បានអះអាងនូវការតវ៉ាអំពីការអនុវត្តព្រមគ្នាដូចគ្នានឹងការអះអាងរបស់ចុងចម្លើយនៃបណ្ដឹងអង្គសេចក្ដី (ដើមចោទនៃបណ្ដឹងតប) ដែរ ហើយប្រសិនបើតុលាការទទួលស្គាល់នូវការតវ៉ានោះ សេចក្ដីសម្រេចបញ្ចប់នឹងសរសេរដូចខាងក្រោម៖

"១. បង្គាប់ឲ្យចុងចម្លើយនៃបណ្ដឹងអង្គសេចក្ដី (ដើមចោទនៃបណ្ដឹងតប) ធ្វើនីតិវិធីចុះបញ្ជីអចលនវត្ថុដែលបានកត់ត្រាក្នុងបញ្ជីឧបសម្ព័ន្ធឲ្យទៅដើមចោទនៃបណ្ដឹងអង្គសេចក្ដី (ចុងចម្លើយនៃបណ្ដឹងតប) ជាថ្នូរនៃការបង់ប្រាក់នៃចំណុច ២. ពីដើមចោទនៃបណ្ដឹងអង្គសេចក្ដី (ចុងចម្លើយនៃបណ្ដឹងតប)។

២. បង្គាប់ឲ្យដើមចោទនៃបណ្ដឹងអង្គសេចក្ដី (ចុងចម្លើយនៃបណ្ដឹងតប) បង់ប្រាក់ចំនួន............ដុល្លារអាមេរិកឲ្យទៅចុងចម្លើយនៃបណ្ដឹងអង្គសេចក្ដី (ដើមចោទនៃបណ្ដឹងតប) ជាថ្នូរនៃការធ្វើនីតិវិធីចុះបញ្ជីអចលនវត្ថុនៃចំណុច ១.។[2]

៣. ច្រានចោលគ្រប់ការទាមទារផ្សេងពីនោះនៃបណ្ដឹងអង្គសេចក្ដីរបស់ដើមចោទនៃបណ្ដឹងអង្គសេចក្ដី (ចុងចម្លើយនៃបណ្ដឹងតប) និងការទាមទារផ្សេងពីនោះនៃបណ្ដឹងតប

[2] ចំណុចនេះទាល់តែដើមចោទនៃបណ្ដឹងអង្គសេចក្ដី (ចុងចម្លើយនៃបណ្ដឹងតប) បានអះអាងនូវការតវ៉ាអំពីការអនុវត្តព្រមគ្នាផងដែរ ហើយតុលាការក៏បានទទួលស្គាល់នូវការអះអាងនោះផងដែរ ទើបសេចក្ដីសម្រេចបញ្ចប់សរសេរបែបនេះ។

ឧបមាថា ដើមចោទនៃបណ្ដឹងអង្គសេចក្ដី (ចុងចម្លើយនៃបណ្ដឹងតប) មិនបានអះអាងនូវការតវ៉ាអំពីការអនុវត្តព្រមគ្នា នៅក្នុងនីតិវិធីនៃបណ្ដឹងទេនោះ បើទោះបីជាតុលាការបានពិចារណាថា ការទាមទារនៃបណ្ដឹងតប និង ការទាមទារនៃបណ្ដឹងអង្គសេចក្ដីមានទំនាក់ទំនងគ្នាអំពីការអនុវត្តព្រមគ្នាក៏ដោយ ក៏មិនអាចចេញសាលក្រមបង្គាប់ឲ្យផ្ដល់តាវកាលិកតបដូចនៅក្នុងចំណុចទី ២ បានឡើយ។ ក្នុងករណីនេះ តុលាការនឹងត្រូវទទួលស្គាល់ទាំងអស់ចំពោះការទាមទារនៃបណ្ដឹងតប ហើយខ្លឹមសារនៃចំណុច ២. នឹងត្រូវសរសេរថា "បង្គាប់ឲ្យដើមចោទនៃបណ្ដឹងអង្គសេចក្ដី (ចុងចម្លើយនៃបណ្ដឹងតប) បង់ប្រាក់ចំនួន.............. ដុល្លារអាមេរិកឲ្យទៅចុងចម្លើយនៃបណ្ដឹងអង្គសេចក្ដី (ដើមចោទនៃបណ្ដឹងតប)" ។ ហើយចំពោះខ្លឹមសារនៃចំណុចទី ៣ ក៏មិនចាំបាច់សរសេរផ្នែកដែលច្រានចោលនូវការទាមទារផ្សេងពីនោះនៃបណ្ដឹងតបឡើយ។

យ៉ាងណាមិញ បើសិនជាតុលាការចេញសាលក្រមបង្គាប់ឲ្យផ្ដល់តាវកាលិកតបចំពោះចំណុចទី ២ ទាំងពុំមានការអះអាងនូវការតវ៉ាអំពីការអនុវត្តព្រមគ្នាពីដើមចោទនៃបណ្ដឹងអង្គសេចក្ដី (ចុងចម្លើយនៃបណ្ដឹងតប)ទេ សាលក្រមនោះនឹងក្លាយទៅជាសាលក្រមខុសច្បាប់ដែលផ្ទុយនឹងមាត្រា ៩៥ ដូច្នេះហើយ សូមប្រុងប្រយ័ត្ន។

របស់ចុងចម្លើយនៃបណ្តឹងអង្គសេចក្តី (ដើមចោទនៃបណ្តឹងតប)។

៤. បន្ទុកនៃប្រាក់ប្រដាប់ក្តីតាមរយៈបណ្តឹងអង្គសេចក្តីនិងបណ្តឹងតបចែកជា......ចំណែក ដោយ........ ចំណែកនោះ គឺជាបន្ទុករបស់ដើមចោទនៃបណ្តឹងអង្គសេចក្តី (ចុងចម្លើយនៃបណ្តឹងតប) ក្រៅពីនោះគឺជាបន្ទុករបស់ចុងម្លើយនៃបណ្តឹងអង្គសេចក្តី (ដើមចោទនៃបណ្តឹងតប)។"

(៤) ឧទាហរណ៍នៃសេចក្តីសម្រេចបញ្ចប់ដែលត្រូវបានមើលឃើញថា នៅក្នុងការអនុវត្តជាក់ស្តែងមានការភាន់ច្រឡំ

ឧទាហរណ៍ នៅក្នុងរឿងក្តីដែលដើមចោទទាមទារឲ្យចុងចម្លើយធ្វើនីតិវិធីចុះបញ្ជីអចលនវត្ថុ ចុងចម្លើយបានអះអាងនូវការតវ៉ាអំពីការអនុវត្តព្រមគ្នា ហើយក្នុងករណីដែលតុលាការទទួលស្គាល់ចំពោះការតវ៉ានោះ ការសរសេរនូវសេចក្តីសម្រេចបញ្ចប់មានការភាន់ច្រឡំដូចខាងក្រោម៖

"១. បង្គាប់ឲ្យចុងចម្លើយធ្វើនីតិវិធីចុះបញ្ជីអចលនវត្ថុដែលបានកត់ត្រានៅក្នុងបញ្ជីឧបសម្ព័ន្ធឲ្យទៅដើមចោទ។

២. បង្គាប់ឲ្យដើមចោទបង់ប្រាក់ចំនួន........ដុល្លារអាមេរិកឲ្យទៅចុងចម្លើយ។

៣. ប្រាក់ប្រដាប់ក្តីចែកជា......ចំណែក ដោយ..........ចំណែកនោះជាបន្ទុករបស់ដើមចោទ ក្រៅពីនោះជាបន្ទុករបស់ចុងចម្លើយ។"

ជាដំបូង ចំពោះចំណុចទី ១ ក្នុងឧទាហរណ៍នៃសេចក្តីសម្រេចបញ្ចប់ខាងលើនេះ នឹងក្លាយទៅជាការបង្គាប់ទៅចុងចម្លើយអំពីករណីយកិច្ចធ្វើនីតិវិធីចុះបញ្ជីដោយគ្មានលក្ខខណ្ឌ ប៉ុន្តែ បើនៅក្នុងខ្លឹមសារនៃសំអាងហេតុ តុលាការបានទទួលស្គាល់ចំពោះការអះអាងនូវការតវ៉ាឲ្យអនុវត្តព្រមគ្នារបស់ចុងចម្លើយ ហើយបែរជាសរសេរនូវខ្លឹមសារនៃសេចក្តីសម្រេចបញ្ចប់បែបនេះវិញ គឺធ្វើឲ្យមិនមានភាពស៊ីសង្វាក់គ្នាទៅនឹងសំអាងហេតុឡើយ។ ពោល សាលក្រមបែបនេះ គឺជាសាលក្រមខុសច្បាប់ ដែលមានមូលហេតុដាច់ខាតនៃបណ្តឹងសាទុក្ខ (ចំណុច ច. នៃកថាខណ្ឌទី ១ មាត្រា ២៨៥)។

ម្យ៉ាងទៀត ចំពោះចំណុចទី ២ ក្នុងឧទាហរណ៍នៃសេចក្តីសម្រេចបញ្ចប់ខាងលើនេះ គឺបានបង្គាប់ទៅដើមចោទអំពីករណីយកិច្ចបង់ប្រាក់ ប៉ុន្តែ ចុងចម្លើយមិនបានដាក់បណ្តឹងតបទេ ដូច្នេះ ការបង្គាប់អំពីករណីយកិច្ចបែបនេះ គឺជាការបង្គាប់ខុសច្បាប់ ដែលផ្ទុយនឹងកថាខណ្ឌទី ២

នៃមាត្រា ១៨២ ។ ដើមចោទបានទាមទារនូវការអនុវត្តករណីយកិច្ចចុះបញ្ជីរបស់ចុងចម្លើយតែប៉ុណ្ណោះ ហើយមិនបានទាមទារនូវសាលក្រមដែលបង្គាប់នូវការអនុវត្តករណីយកិច្ចមកដើមចោទខ្លួនឯងវិញឡើយ។

## ៣. ភាពខុសគ្នារវាង កថាខណ្ឌទី ៣ នៃមាត្រា ៣៦១ និង មាត្រា ៥២៩

(១) ភាពខុសគ្នារវាងលក្ខខណ្ឌនៃការផ្តល់រូបមន្តអនុវត្ត និង លក្ខខណ្ឌនៃការចាប់ផ្តើមអនុវត្ត

ក. ជាគោលការណ៍ ការអនុវត្តដោយបង្ខំត្រូវធ្វើឡើង ដោយផ្អែកលើឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលភ្ជាប់ជាមួយនឹងរូបមន្តអនុវត្ត (កថាខណ្ឌទី ១ នៃមាត្រា ៣៥៤)។

ជាគោលការណ៍ រូបមន្តអនុវត្តត្រូវផ្តល់ដោយក្រឡាបញ្ជីនៃតុលាការដែលមានសំណុំរឿងនោះតាមពាក្យសុំ (កថាខណ្ឌទី ២ នៃមាត្រា ៣៥៤)។

ស្ថាប័នដែលចេញរូបមន្តអនុវត្ត (ក្រឡាបញ្ជី ឬ សារការី) ចាំបាច់ត្រូវស្រាវជ្រាវ ថា តើអាចចេញរូបមន្តអនុវត្តបាន ឬ យ៉ាងណា (លក្ខខណ្ឌនៃការចេញរូបមន្តអនុវត្ត) (មាត្រា ៣៥៦) ។

ខ. យ៉ាងណាក៏ដោយ ចំពោះករណីដែលតាវកាលិករបស់កូនបំណុលនៃការអនុវត្ត ត្រូវធ្វើឡើងដោយប្តូរជាមួយនឹងតាវកាលិកតបរបស់ម្ចាស់បំណុលនៃការអនុវត្ត "ម្ចាស់បំណុលនៃការអនុវត្តបានផ្តល់តាវកាលិកតប ឬ បានស្នើផ្តល់តាវកាលិកតបនោះ (កថាខណ្ឌទី ៣ នៃមាត្រា ៣៦១) " គឺលក្ខខណ្ឌនៃការផ្តល់រូបមន្តអនុវត្តមិនត្រូវបានទាមទារឡើយ (យោងមាត្រា ៣៥៦)។

ដូច្នេះហើយ ស្ថាប័នដែលផ្តល់រូបមន្តអនុវត្ត នឹងត្រូវផ្តល់រូបមន្តអនុវត្តដោយពុំធ្វើការស្រាវជ្រាវអំពីលក្ខខណ្ឌនោះទេ។

បន្ទាប់ពីរូបមន្តអនុវត្តចំពោះលិខិតអនុវត្តត្រូវបានផ្តល់ឲ្យ នឹងមានការស្រាវជ្រាវទៅលើ "ម្ចាស់បំណុលនៃការអនុវត្តបានផ្តល់តាវកាលិកតប ឬ បានស្នើផ្តល់តាវកាលិកតបនោះ" ដែលជាលក្ខខណ្ឌក្នុងការចាប់ផ្តើមអនុវត្ត (កថាខណ្ឌទី ៣ នៃមាត្រា ៣៦១)។

គ. ហេតុអ្វីបានជា "ម្ចាស់បំណុលនៃការអនុវត្តបានផ្តល់តាវកាលិកតប ឬ បានស្នើផ្តល់តាវកាលិកតបនោះ" មិនមែនជាលក្ខខណ្ឌនៃការផ្តល់រូបមន្តអនុវត្ត ហើយបែរជាក្លាយទៅជាលក្ខខណ្ឌនៃការចាប់ផ្តើមអនុវត្តទៅវិញ ?

ប្រសិនបើ "ម្ចាស់បំណុលនៃការអនុវត្តបានផ្តល់តាវកាលិកតប ឬ បានស្នើផ្តល់តាវកាលិកតបនោះ" គឺជាលក្ខខណ្ឌនៃការផ្តល់រូបមន្តអនុវត្តនោះ ម្ចាស់បំណុលនៃការអនុវត្តនឹងត្រូវតែផ្តល់តាវកាលិកតប ឬ ស្នើផ្តល់តាវកាលិកនោះ នៅក្នុងដំណាក់កាលនៃការដាក់ពាក្យសុំផ្តល់រូបមន្ត

អនុវត្តដែលបានធ្វើឡើងមុនពេលដាក់ពាក្យសុំអនុវត្តដោយបង្ខំ។ ដូច្នេះហើយ ចំពោះការផ្តល់តាវកាលិកតប ឬ ការស្នើផ្តល់តាវកាលិកនោះ បើផ្អែកតាមច្បាប់សារជាតុវិញ (ក្រមរដ្ឋប្បវេណី) ទោះបីជាមានទំនាក់ទំនងរវាងកាតព្វកិច្ចរបស់កូនបំណុលនៃការអនុវត្ត និង ការទាមទារឲ្យអនុវត្តព្រមគ្នាក៏ដោយ ក៏ផ្អែកតាមភាពជាក់ស្តែងម្ចាស់បំណុលនៃការអនុវត្តមិនអាចជៀសវាងផុតពីការផ្តល់តាវកាលិកតប ឬ ស្នើផ្តល់តាវកាលិកនោះជាមុនសិនដើម្បីទទួលបាននូវការផ្តល់រូបមន្តអនុវត្តឡើយ។ ប្រសិនបើធ្វើបែបនេះ វានឹងក្លាយទៅជាការមើលរំលងច្បាប់សារជាតុ (ក្រមរដ្ឋប្បវេណី)។

ហេតុនេះហើយ ដើម្បីថែរក្សានូវទំនាក់ទំនងនៃការអនុវត្តព្រមគ្នាឲ្យបានអស់លទ្ធភាពទាំងនៅក្នុងករណីនៃការអនុវត្តដោយបង្ខំផងដែរនោះ ទើបគេមិនបានយក "ម្ចាស់បំណុលនៃការអនុវត្តបានផ្តល់តាវកាលិកតប ឬ បានស្នើផ្តល់តាវកាលិកតបនោះ" មកធ្វើជាលក្ខខណ្ឌនៃការផ្តល់រូបមន្តអនុវត្តទេ ហើយបានយកទៅធ្វើជាលក្ខខណ្ឌនៃការចាប់ផ្តើមអនុវត្តវិញ។

<u>※ ការពន្យល់លម្អិត សូមយោងតាមសេចក្តីកំណត់ចំពោះមាត្រា ៣៦១ និង សៀវភៅសេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគ ២ ៖ ការអនុវត្តដោយបង្ខំ និង ការចាត់ចែងរក្សាការពារ (ទំព័រ ៦៧ )!!</u>

(២) ភាពខុសគ្នារវាងកថាខណ្ឌទី ៣ នៃមាត្រា ៣៦១ និងមាត្រា ៥២៩

ក. បើការបង្ហាញឆន្ទៈរបស់កូនបំណុលនៃការអនុវត្ត ត្រូវធ្វើដោយប្តូរជាមួយនឹងតាវលិកតប ត្រូវចាត់ទុកថា កូនបំណុលនៃការអនុវត្តនោះបានបង្ហាញឆន្ទៈ នៅពេលដែលរូបមន្តអនុវត្តត្រូវបានផ្តល់ (កថាខណ្ឌទី ១ មាត្រា ៥២៩ )។

ហើយ រូបមន្តអនុវត្តនេះនឹងអាចផ្តល់បានលុះត្រាតែម្ចាស់បំណុលនៃការអនុវត្តបានដាក់លិខិតបញ្ជាក់ថា ខ្លួនបានផ្តល់ ឬ បានស្នើផ្តល់តាវកាលិកតបនោះហើយ (កថាខណ្ឌទី ២ នៃមាត្រា ៥២៩)។

ខ. បើការបង្ហាញឆន្ទៈរបស់កូនបំណុលនៃការអនុវត្ត ត្រូវធ្វើដោយប្តូរជាមួយនឹងតាវកាលិកតបរបស់ម្ចាស់បំណុល ហេតុអ្វីបានជា "ម្ចាស់បំណុលនៃការអនុវត្តបានផ្តល់តាវកាលិកតបនោះ ឬ បានស្នើផ្តល់តាវកាលិកតបនោះ" ត្រូវបានគេយកមកធ្វើជាលក្ខខណ្ឌនៃការផ្តល់រូបមន្តអនុវត្ត?

មូលហេតុនេះ គឺដោយសារតែលិខិតអនុវត្តដែលបង្គាប់អំពីការបង្ហាញឆន្ទៈ គឺមិនត្រូវបានគេព្យាករនូវការធ្វើសកម្មភាពនៃការអនុវត្តជាក់ស្តែងឡើយ ហើយប្រសិនបើអានុភាពដែលបានចាត់ទុកថាជាការបង្ហាញឆន្ទៈរបស់កូនបំណុលនៃការអនុវត្តបានបង្កើតមានឡើង ដូច្នេះ ម្ចាស់បំណុល

នឹងអាចវាស់ស្ទង់នូវផលប្រយោជន៍តាមភាពជាក់ស្តែងបាន ដោយផ្អែកទៅលើការបង្ហាញឆន្ទៈបានគ្រប់ពេល ហើយអាចដាក់ពាក្យសុំចុះបញ្ជីតែម្នាក់ឯងបានជាដើម ។ បើផ្អែកតាមច្បាប់សារជាតុ (ក្រមរដ្ឋប្បវេណី) ការបង្ហាញឆន្ទៈរបស់កូនបំណុលនៃការអនុវត្ត បើទោះបីជាត្រូវធ្វើឡើងដោយប្តូរនឹងការផ្តល់តាវកាលិកតបពីម្ចាស់បំណុលនៃការអនុវត្តក៏ដោយ ប្រសិនបើពុំមានការផ្តល់តាវកាលិកតបពីម្ចាស់បំណុលនៃការអនុវត្ត ឬ មានការស្នើផ្តល់តាវកាលិកតបនោះទេ ហើយត្រូវចាត់ទុកថាមានការបង្ហាញឆន្ទៈរបស់កូនបំណុលនៃការអនុវត្ត នឹងក្លាយទៅជាការមើលរំលងនូវសិទ្ធិតវ៉ាអំពីការអនុវត្តព្រមគ្នាដែលចែងនៅក្នុងច្បាប់សារជាតុ (ក្រមរដ្ឋប្បវេណី)។

ហេតុដូច្នេះហើយ ទើប "ម្ចាស់បំណុលនៃការអនុវត្តបានផ្តល់តាវកាលិកតបនោះ ឬ បានស្នើផ្តល់តាវកាលិកតបនោះ" ត្រូវបានគេយកមកធ្វើជាលក្ខខណ្ឌនៃការផ្តល់រូបមន្តអនុវត្ត ហើយឲ្យស្ថាប័នអនុវត្តដែលផ្តល់រូបមន្តអនុវត្តធ្វើការស្រាវជ្រាវ ប្រសិនបើមានការបញ្ជាក់ច្បាស់លាស់ថា "ម្ចាស់បំណុលនៃការអនុវត្តបានផ្តល់តាវកាលិកតបនោះ ឬ បានស្នើផ្តល់តាវកាលិកតបនោះ" នឹងត្រូវផ្តល់រូបមន្តអនុវត្ត ហើយអានុភាពនៃការចាត់ទុកថាបានបង្ហាញឆន្ទៈ នឹងកើតមានឡើងនៅពេលដែលរូបមន្តត្រូវបានផ្តល់ឲ្យ (កថាខណ្ឌទី ១ និង កថាខណ្ឌទី ២ នៃមាត្រា ៥២៩)។

<u>※ ការពន្យល់លម្អិត សូមយោងតាមសេចក្តីកំណត់ចំពោះមាត្រា ៥២៩ និង សៀវភៅសេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគ ២ ៖ ការអនុវត្តដោយបង្ខំ និង ការចាត់ចែងរក្សាការពារ (ទំព័រ ១៨៨-១៩០ )!!</u>

សូមអរគុណ

# គោលការណ៍នៃការដាក់ (បង្កើតនិងដាក់) ពាក្យសុំរួមគ្នា



# ការដាក់ពាក្យសុំ(ដាក់)តែម្នាក់ឯងដោយផ្អែកតាមសាលក្រម សាលដីកា (ករណីលើកលែង)

មាត្រា ៥៥៤ ក្រម/រដ្ឋ



បុគ្គលមានសិទ្ធិចុះបញ្ជី ---- X

ប្រការ ៤-៣ ប្រ.អនុ.ចុះ.ក្រម/រដ្ឋ

អ្នកទិញ

Y ---- បុគ្គលមានកាតព្វកិច្ចចុះបញ្ជី

ប្រការ ៤-៤ ប្រ.អនុ.ចុះ.ក្រម/រដ្ឋ

មាត្រា ៥៣០ ក្រម/រដ្ឋ

អ្នកលក់



ដី L

ប្រការ ៦-១ ប្រ.អនុ.ចុះ.ក្រម/រដ្ឋ

មាត្រា ៥២៩ ក្រមនីតិ/រដ្ឋ



ការចុះបញ្ជី

"ការបង្ហាញឆន្ទៈ"

តោះដាក់ពាក្យសុំចុះបញ្ជី

ផ្ទេរកម្មសិទ្ធិ !!

"ការបង្ហាញឆន្ទៈ"

តោះដាក់ពាក្យសុំចុះបញ្ជី

ផ្ទេរកម្មសិទ្ធិ !!

សាលក្រម សាលដីកា

មាត្រា ៥២៩ ក្រមនីតិ/រដ្ឋ

ពាក្យសុំចុះបញ្ជីផ្ទេរក

X និង

(ប្រការ ២៨ ប្រ.អនុ.ចុះ.ក្រម/រដ្ឋ)

ឯកសារភ្ជាប់ (ប្រការ ២៧ ប្រ.អនុ.ចុះ.ក្រម/រដ្ឋ)

X ទៅតែម្នាក់ឯងដាក់នៅរដ្ឋបាលសុរិយោដី

ប្រការ ៥-១ និង ប្រការ ១០-២ ប្រ.អនុ.ចុះ.ក្រម/រដ្ឋ



ផ្អែកតាមច្បាប់ នឹងកើតមានកាតព្វកិច្ចចុះបញ្ជីចំពោះរដ្ឋបាលសុរិយោដី

ប្រការ ៦-២ ប្រ.អនុ.ចុះ.ក្រម/រដ្ឋ

# គោលការណ៍នៃការដាក់ (បង្កើតនិងដាក់) ពាក្យសុំរួមគ្នា



# ការដាក់ពាក្យសុំ(ដាក់)តែម្នាក់ឯងដោយផ្អែកតាមសាលក្រម សាលដីកា (ករណីលើកលែង)



# រឿងក្តីទាមទារឲ្យធ្វើនីតិវិធីចុះបញ្ជីអំពីការលុបការចុះបញ្ជី
# អំពីការផ្ទេរកម្មសិទ្ធិដោយផ្អែកលើការរំលាយកិច្ចសន្យា

- ការអះអាងរបស់ X

នៅថ្ងៃទី ១ ខែ តុលា ឆ្នាំ ២០១៨ ខ្ញុំបានធ្វើការសន្យាជាមុនជាមួយ Y អំពីការលក់ដីដែលជាកម្មសិទ្ធិរបស់ខ្ញុំ (ទីតាំង ៖ ផ្លូវលេខ....... ភូមិ............ ឃុំ............. ស្រុក.......... ខេត្ត រតនគិរី លេខក្បាលដី ៖................) (តទៅហៅថា "ដី L") ស្របតាមលក្ខខណ្ឌដូចខាងក្រោម ដោយកំណត់អំពីអំឡុងពេលនៃការអនុវត្តសិទ្ធិសម្រេចបង្កើតកិច្ចសន្យាលក់ទិញចំនួន ៣ខែ ហើយ Y បានបង់ប្រាក់ចំនួន ១០.០០០ (មួយម៉ឺន) ដុល្លារអាមេរិកជាតម្លៃថ្នូរនៃលទ្ធកម្មសិទ្ធិសម្រេចបង្កើតកិច្ចសន្យាលក់ទិញមកឲ្យខ្ញុំ។

"លក្ខខណ្ឌនៃការលក់"

កម្មវត្ថុ ៖ កម្មសិទ្ធិលើដី L

ថ្លៃលក់ទិញ ៖ ១០០.០០០ (មួយសែន) ដុល្លារអាមេរិក (ប្រាក់ដែល Y បានបង់ចំនួន ១០.០០០ (មួយម៉ឺន) ដុល្លារអាមេរិកដែលជាតម្លៃថ្នូរនៃលទ្ធកម្មសិទ្ធិសម្រេចបង្កើតកិច្ចសន្យាលក់ទិញ នឹងត្រូវកាត់ជាមួយថ្លៃលក់ទិញនៅពេលដែលបានបង្កើតកិច្ចសន្យាលក់ទិញ។)

អំឡុងពេលនៃការអនុវត្ត ៖ នៅក្នុងអំឡុងពេល ២សប្តាហ៍ គិតចាប់ពីថ្ងៃដែល Y បានបង្ហាញឆន្ទៈអំពីការបំពេញការទិញទៅកាន់ X X និង Y ត្រូវធ្វើលិខិតយថាភូតនៃកិច្ចសន្យាលក់ទិញ (លិខិតដែលមន្ត្រីមានសមត្ថកិច្ចធ្វើឡើង) ជាមួយគ្នានេះ Y ត្រូវបង់ប្រាក់ថ្លៃលក់ទិញចំនួន ៥០.០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិក (ចំពោះប្រាក់ចំនួន ១០.០០០ (មួយម៉ឺន) ដុល្លារអាមេរិកក្នុងចំនួនទឹកប្រាក់ ៥០.០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិកនេះ ត្រូវកាត់ជាមួយទឹកប្រាក់ចំនួន ១០.០០០ (មួយម៉ឺន) ដុល្លារអាមេរិកដែលត្រូវបានបង់ជាតម្លៃថ្នូរនៃលទ្ធកម្មសិទ្ធិសម្រេចបង្កើតកិច្ចសន្យាលក់ទិញ។ ដូច្នេះហើយ ចំនួនទឹកប្រាក់ដែលY ត្រូវបង់ទៅឲ្យ X ជាក់ស្តែង គឺចំនួន ៤០.០០០ (បួនម៉ឺន) ដុល្លារអាមេរិក) ឲ្យទៅ X បន្ទាប់មក X និង Y ត្រូវរួមគ្នាធ្វើ និង ដាក់ពាក្យសុំអំពីការចុះបញ្ជីផ្ទេរកម្មសិទ្ធិទាំងមូលទៅរដ្ឋបាលសុរិយោដីខេត្តរតនគិរី។

X ត្រូវប្រគល់ដី L ឲ្យទៅ Y ហើយ Y ត្រូវបង់ប្រាក់ថ្លៃលក់ទិញចំនួន ៥០.០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិកដែលនៅខ្វះឲ្យទៅ X ។

នៅថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨ Y បានបង្ហាញឆន្ទៈថាព្រមបំពេញការទិញដែលលើកឡើងខាងលើនេះ មកកាន់ខ្ញុំ។

នៅថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១៨ ខ្ញុំ និង Y បានធ្វើលិខិតយថាភូតនៃកិច្ចសន្យាលក់ទិញខាងលើ (លិខិតដែលមន្ត្រីមានសមត្ថកិច្ចធ្វើឡើង) ជាមួយគ្នានេះ បន្ទាប់ពី Y បានបង់ប្រាក់មកឲ្យខ្ញុំចំនួន ៥០.០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិក (ចំពោះប្រាក់ចំនួន ១០.០០០ (មួយម៉ឺន) ដុល្លារអាមេរិកក្នុងចំនួនទឹកប្រាក់ ៥០.០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិកនេះ ត្រូវកាត់ជាមួយទឹកប្រាក់ចំនួន ១០.០០០ (មួយម៉ឺន) ដុល្លារអាមេរិកដែលត្រូវបានបង់ជាតម្លៃថ្នូរនៃលទ្ធកម្មសិទ្ធិសម្រេចបង្កើតកិច្ចសន្យាលក់ទិញ ដូច្នេះហើយ ចំនួនទឹកប្រាក់ដែលY ត្រូវបង់ទៅឲ្យ X ជាក់ស្តែង គឺចំនួន ៤០.០០០ (បួនម៉ឺន) ដុល្លារអាមេរិក) ដែលជាប្រាក់មួយផ្នែកនៃថ្លៃលក់ទិញ ពួកយើងបានទៅរដ្ឋបាលសុរិយោដីខេត្តរតនគិរីជាមួយគ្នា និងបានដាក់លិខិតពាក្យសុំចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិទាំងមូលលើដី L ។

នៅថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១៨ រដ្ឋបាលសុរិយោដីខេត្តរតនគិរីបានចុះបញ្ជីអំពីចំណុចដែលត្រូវបានសរសេរនៅក្នុងលិខិតពាក្យសុំចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិទាំងមូលដូចបានលើកឡើងខាងលើ ដាក់នៅក្នុងសៀវភៅគោលបញ្ជីដីធ្លី។

បន្ទាប់ពីខ្ញុំបានសម្អាតសំរាមដែលមាននៅលើដី L និង បានប្រែក្លាយសភាពដី L ទុកសម្រាប់ការប្រគល់រួចរាល់ហើយ នៅថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៨ ដែលត្រូវនឹងរយៈពេល ១ខែ គិតចាប់ពីថ្ងៃដែលបានដាក់លិខិតពាក្យសុំចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិទាំងមូល ខ្ញុំបានជូនដំណឹងអំពី ការបានប្រែក្លាយសភាពដី L ទុកសម្រាប់ការប្រគល់ និង បានដាស់តឿនឲ្យ Y មកទទួល ស្របជាមួយគ្នានេះដែរ ខ្ញុំក៏បានសួរថា តើការបង់ប្រាក់ថ្លៃលក់ទិញដែលនៅខ្វះយ៉ាងណាដែរហើយ? តាមរយៈ Telegram។

Y បានឆ្លើយមកខ្ញុំវិញតាម Telegram ថា "គាត់មិនអាចរៀបចំប្រាក់ចំនួន ៥០.០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិកឲ្យបានភ្លាមៗទេ ដោយសារតែ គាត់ត្រូវបានមនុស្សអាក្រក់បោកយកលុយបាត់ទៅហើយ។ គាត់នឹងរកមធ្យោបាយណាមួយ ហើយចង់ឲ្យខ្ញុំរង់ចាំគាត់រយៈពេល ៣ ខែបន្តទៀត។" ជាដើម។ ប៉ុន្តែ ខ្ញុំមិនយល់ស្របតាមការទាមទាររបស់ Y ទេ ដោយសារតែ គេបានព្យាករថា តម្លៃដី L នឹងនៅតែបន្តឡើងថ្លៃ ហើយក៏អាចរកអ្នកទិញបានភ្លាមៗដែរ។

ឆ្នាំថ្មីត្រូវនឹងថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១៩ ខ្ញុំបានដាស់តឿនទៅ Y តាម Telegram

ឲ្យបង់ប្រាក់ថ្លៃលក់ទិញចំនួន ៥០.០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិកដែលនៅខ្វះ ឲ្យបាននៅក្នុងអំឡុងពេល ២សប្តាហ៍ ជាមួយគ្នានេះខ្ញុំក៏បានបង្ហាញឆន្ទៈថា នឹងរំលាយកិច្ចសន្យាលក់ទិញ នៅពេលដែលគាត់មិនបង់ប្រាក់នៅក្នុងអំឡុងពេលនោះ។ នៅថ្ងៃនោះដែរ Y ក៏បានឆ្លើយតបមកខ្ញុំវិញតាម Telegram ថា "គាត់យល់ហើយ"។ ចុងក្រោយ Y មិនបានបង់ប្រាក់ថ្លៃលក់ទិញចំនួន ៥០.០០០ ដុល្លារអាមេរិកដែលនៅខ្វះឲ្យបានត្រឹមថ្ងៃទី ២៥ ខែមករា ឆ្នាំ ២០១៩ ទេ។

ដូច្នេះហើយ ខ្ញុំទាមទារទៅ Y អំពីការធ្វើនីតិវិធីចុះបញ្ជីអំពីការលុបការចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិលើដី L ដោយមូលហេតុការរំលាយកិច្ចសន្យាលក់ទិញចុះថ្ងៃទី ២៥ ខែមករា ឆ្នាំ ២០១៩។

○ ការអះអាងរបស់ Y

ទំនាក់ទំនងនៃអង្គហេតុដែលគិតចាប់ពីថ្ងៃ ១ ខែ តុលា ឆ្នាំ ២០១៨ រហូតដល់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៨ ដែលខ្ញុំបានឆ្លើយតបទៅ X គឺ ខ្ញុំទទួលស្គាល់ទាំងអស់។

នៅថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៨ បន្ទាប់ពីខ្ញុំបានឆ្លើយតបតាម Telegram ទៅ X ថា " ខ្ញុំចង់ឲ្យរង់ចាំរយៈពេល ៣ ខែបន្តទៀត" X បានទូរស័ព្ទមកខ្ញុំភ្លាមៗ ហើយគាត់បានបញ្ជាក់យ៉ាងលម្អិតអំពីការរងគ្រោះពីការឆបោកដែលខ្ញុំបានជួបប្រទះ ហើយគាត់បានសម្តែងក្តីអាណិតអាសូរមកលើរូបខ្ញុំ ព្រមទាំងបានលើកទឹកចិត្តខ្ញុំដោយនិយាយថា " គាត់យល់ហើយ។ គាត់សង្ឃឹមថា ឆ្នាំក្រោយនឹងមានភាពប្រសើរឡើងវិញ" ។

ប៉ុន្តែបែរជានៅថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១៩ X បានផ្ញើសារមកខ្ញុំតាម Telegram ដែលមានខ្លឹមសារដូច X បានអះអាងទៅវិញ។ ដោយសារតែ ខ្ញុំបានគិតថា X បានពន្យារពេលឲ្យខ្ញុំរយៈពេល ៣ ខែ ក្នុងការបង់ប្រាក់ថ្លៃលក់ទិញចំនួន ៥០.០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិកដែលនៅខ្វះ ហើយខ្ញុំក៏មានបំណងថានឹងបង់ឲ្យខានតែបានត្រឹមខែមីនា ឆ្នាំ ២០១៩ ដូច្នេះហើយ ខ្ញុំបានទៅរកមិត្តភក្តិ និង ធនាគារជាដើម ដើម្បីពិភាក្សាសុំខ្ចីប្រាក់ចំនួន ៥០.០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិក បន្ទាប់មកក៏ឆ្លើយតបទៅវិញយ៉ាងខ្លីថា "ខ្ញុំយល់ហើយ" ។ ចុងក្រោយគិតមកដល់ត្រឹមថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៩ ខ្ញុំពុំអាចរកមិត្តភក្តិ ឬក៏ធនាគារដែលអាចឲ្យខ្ញុំខ្ចីប្រាក់ចំនួន ៥០.០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិកបានទេ ដូច្នេះទើប ខ្ញុំមិនអាចបង់ប្រាក់ថ្លៃលក់ទិញចំនួន ៥០.០០០

(ប្រាំម៉ឺន) ដុល្លារអាមេរិកដែលនៅខ្វះឲ្យទៅ X ឲ្យបានត្រឹមថ្ងៃនោះឡើយ។

ដរាបណា X បានព្រមព្រៀងទៅលើការផ្លាស់ប្តូរនូវកាលបរិច្ឆេទបង់ប្រាក់ថ្លៃលក់ទិញចំនួន ៥០.០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិកដែលនៅខ្វះ មកត្រឹមថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៩ នោះ ការរំលាយកិច្ចសន្យាដោយយកមូលហេតុនៃការមិនបានបង់ប្រាក់គិតត្រឹមថ្ងៃទី ២៥ ខែមករា ឆ្នាំ ២០១៩នោះ គឺពុំអាចធ្វើឡើងបានទេ ។ ខ្ញុំមិនអាចយល់ព្រមចំពោះការទាមទាររបស់ X ទេ។

ម្យ៉ាងទៀត ឧបមាថា បើទោះបីជាការព្រមព្រៀងខាងលើនេះពុំត្រូវបានទទួលស្គាល់ក៏ដោយ ក៏ខ្ញុំនឹងនៅតែធ្វើការបដិសេធអំពីការធ្វើនីតិវិធីចុះបញ្ជីអំពីការលុបការចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិលើដីL ដែរ រហូតទាល់តែ X សងប្រាក់ ៥០.០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិកដែលបានទទួលរួចរាល់ ដែលជាមួយផ្នែកនៃថ្លៃលក់ទិញ ដោយភ្ជាប់ជាមួយនឹងការប្រាក់ដែលគិតចាប់ពីថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១៨ ដែលជាថ្ងៃទទួលប្រាក់សិន។


· កម្មសិទ្ធិលើដី L
· 100.000$
· ① ការបង្កើតលិខិតលក់ផ្តាច់ + ការបង់ថ្លៃលក់ទិញ 50.000$ + ដាក់ពាក្យសុំចុះបញ្ជីផ្ទេរកម្មសិទ្ធិ
→ក្នុងអំឡុងពេល ២សប្តាហ៍ គិតចាប់ពីថ្ងៃដែល Y បង្ហាញឆន្ទៈបំពេញការទិញទៅកាន់ X
② ការប្រគល់ដី L + ការបង់ថ្លៃលក់ទិញ 50.000$
→ អំឡុងពេល 1 ខែ គិតចាប់ពីថ្ងៃដែលបានដាក់ពាក្យសុំចុះបញ្ជីផ្ទេរកម្មសិទ្ធិ
1.10.2018 X · Y ការសន្យាលក់ទិញជាមុន
នៅក្នុងអំឡុងពេល 3 ខែ
Y→X ការបង់ប្រាក់ចំនួន 10.000$ ( តម្លៃថ្នូរនៃលទ្ធកម្មសិទ្ធិបញ្ចប់ការសន្យាជាមុន និង សម្រេចបង្កើតកិច្ចសន្យាលក់ទិញ )
※ ប៉ុន្តែ ប្រាក់ 10.000$ នេះ នឹងត្រូវយកមកកាត់ជាមួយថ្លៃលក់ទិញនៅពេលដែលកិច្ចសន្យាបានបង្កើតឡើង។
16.11.2018 Y→X ការបង្ហាញឆន្ទៈបំពេញការទិញ
នៅក្នុងអំឡុងពេល 2 សប្តាហ៍
30.11.2018 X · Y ការបង្កើតលិខិតលក់ផ្តាច់ + ការបង់ប្រាក់ 50.000$ + ការដាក់ពាក្យសុំចុះបញ្ជីផ្ទេរកម្មសិទ្ធិ
ការបង្កើតកិច្ចសន្យាលក់ទិញ
នៅក្នុងអំឡុងពេល 1 ខែ
31.12.2018 X→Y ការស្នើផ្តល់នូវការប្រគល់ដី L
11. 1.2019 X→Y ការដាស់តឿនឲ្យបង់ប្រាក់ 50.000$ (នៅក្នុងអំឡុងពេល 2 សប្តាហ៍) + ការបង្ហាញឆន្ទៈអំពីការរំលាយកិច្ចសន្យាដោយដាក់លក្ខខណ្ឌបង្អង់
25.1.2019

## ដ្យាក្រាមនៃរឿងក្ដីទាមទារឲ្យធ្វើនីតិវិធីចុះបញ្ជីអំពីការលុបការចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិដោយផ្អែកលើការរំលាយកិច្ចសន្យា

### មូលហេតុនៃការទាមទារ

Kg ការរំលាយកិច្ចសន្យាលក់ទិញដោយមូលហេតុការមិនអនុវត្តកាតព្វកិច្ច

| | | |
|---|---|---|
| a | X・Y 30.11.2018 កិច្ចសន្យាលក់ទិញ<br>ដី L<br>ថ្លៃលក់ 100.000$ | ◯ |
| b | កិច្ចសន្យានៃចំណុច a ត្រូវបានធ្វើឡើងជាលិខិតយថាភូត | ◯ |
| c | X・Y បានព្រមព្រៀងអំពីកាលបរិច្ឆេទបង់ប្រាក់នៅក្នុងកិច្ចសន្យានៃចំណុច a ដូចខាងក្រោម ៖<br>① ចំពោះប្រាក់ចំនួន 50.000$ នៃថ្លៃលក់ ត្រូវបង់នៅពេលដែលបានដាក់ពាក្យសុំចុះបញ្ជីផ្ទេរកម្មសិទ្ធិទាំងមូល<br>② ចំពោះប្រាក់ចំនួន 50.000$ ដែលខ្វះ ត្រូវបង់នៅក្នុងអំឡុងពេល 1 ខែគិតចាប់ពីថ្ងៃដែលបានដាក់ពាក្យសុំចុះបញ្ជីផ្ទេរកម្មសិទ្ធិទាំងមូល | ◯ |
| d | X・Y 30.11.2018 បានដាក់ពាក្យសុំចុះបញ្ជីផ្ទេរកម្មសិទ្ធិទាំងមូលដោយផ្អែកលើកិច្ចសន្យានៃចំណុច a | ◯ |
| e | 2018.12.31 បានកន្លងផុត | Ob |
| f | X→Y 11.1.2019 ការដាស់តឿនឲ្យបង់ប្រាក់ថ្លៃលក់ចំនួន 50.000$ ដែលខ្វះនៅក្នុងអំឡុងពេល 2 សប្ដាហ៍ | ◯ |
| g | X→Y នៅពេលដែលដាស់តឿនតាមចំណុច f បានធ្វើការបង្ហាញឆន្ទៈអំពីការរំលាយកិច្ចសន្យានៃចំណុច a ប្រសិនបើមិនបង់ប្រាក់ថ្លៃលក់ចំនួន 50.000$ នៅក្នុងអំឡុងពេល 2 សប្ដាហ៍ | ◯ |
| h | Y គិតត្រឹម 25.1.2019 មិនបានបង់ថ្លៃលក់ទិញចំនួន 50.000$ ដែលខ្វះទេ | ◯ |
| i | X→Y 31.12.2018 បានធ្វើសំណើផ្ដល់ការប្រគល់ដី L ផ្អែកតាមកិច្ចសន្យានៃចំណុច a | ◯ |

### ការតវ៉ា

E1 ការព្រមព្រៀងអំពីការផ្លាស់ប្ដូរកាលបរិច្ឆេទអនុវត្ត

| | | |
|---|---|---|
| j | X・Y 31.12.2018 បានព្រមព្រៀងអំពីការផ្លាស់ប្ដូរ ចំពោះការព្រមព្រៀងនៃចំនុច c ដូចខាងក្រោម ៖<br>② ចំពោះប្រាក់ 50.000$ ដែលខ្វះនឹងត្រូវបង់ត្រឹម 31.3.2019 | × |

(j → a)

E2 ការអនុវត្តព្រមគ្នា

| | | |
|---|---|---|
| k | Y→X 30.11.2018 បានបង់ប្រាក់ 50.000$ នៃថ្លៃលក់ ផ្អែកតាមកិច្ចសន្យាចំណុច a | ◯ |
| l | Y បដិសេធនូវការធ្វើនីតិវិធីចុះបញ្ជីអំពីការលុបការចុះបញ្ជីផ្ទេរកម្មសិទ្ធិ ដរាបណា X សងប្រាក់ 50.000$ និងការប្រាក់ចំនួន 5 ភាគរយក្នុងមួយឆ្នាំទៅលើប្រាក់នេះ គិតចាប់ពី30.11.2018 រហូតដល់ថ្ងៃសងរួច។ | |

(k → a)

## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

# ពាក្យបណ្ដឹង

## ដើមចោទ

ឈ្មោះ ៖ X

អាសយដ្ឋាន ៖ ផ្ទះលេខ ០០ ផ្លូវលេខ ០០ ភូមិ...... ឃុំ.......ស្រុក......... ខេត្តរតនគិរី[1]។

## អ្នកតំណាងដោយអាណត្តិ

លោក/លោកស្រី ៖ P

អាសយដ្ឋានការិយាល័យមេធាវី/ ក្រុមមេធាវី/ ក្រុមហ៊ុនមេធាវី ៖ ..................................

ការិយាល័យមេធាវី/ ក្រុមមេធាវី/ ក្រុមហ៊ុនមេធាវី ៖ ..................................................

លេខទូរស័ព្ទ ៖ ..................................................

**ទីកន្លែងបញ្ជូន** ៖ ការិយាល័យមេធាវី/ ក្រុមមេធាវី/ ក្រុមហ៊ុនមេធាវី.................. [2]

## ចុងចម្លើយ

ឈ្មោះ ៖ Y

អាសយដ្ឋាន ៖ ផ្ទះលេខ ០០ ផ្លូវលេខ ០០ សង្កាត់មនោរម្យ ខណ្ឌ ៧មករា រាជធានីភ្នំពេញ។

---

[1] ឈ្មោះ និងអាសយដ្ឋាន មានបញ្ញត្តិនៅក្នុងមាត្រា ៧៥ កថាខណ្ឌទី ២ ចំណុច ក នៃក្រមនីតិវិធីរដ្ឋប្បវេណី ប៉ុន្តែចំពោះចំណុចផ្សេងទៀត ដូចជា ថ្ងៃខែឆ្នាំកំណើតជាអាទិ៍ ជាចំណុចដែលពុំមានបញ្ញត្តិក្នុងច្បាប់ទេ។ ប៉ុន្តែ ក៏មានករណីដែលពុំអាចកំណត់អំពីភាគី តាមរយៈឈ្មោះ និង អាសយដ្ឋានបានផងដែរ ដូច្នេះ ត្រូវសរសេរចំណុចទាំងនោះក្នុងកម្រិតមួយដែលចាំបាច់ ដើម្បីអាចកំណត់អំពីភាគី។

[2] មាត្រា ២៤៩ និងមាត្រា ២៥០ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ ការដាក់ពីទីកន្លែងដែលត្រូវបញ្ជូន មិនមែនជាកាតព្វកិច្ចនោះទេ។ ប្រសិនបើពុំមានការសរសេរអំពីទីកន្លែងដែលត្រូវបញ្ជូនទេ ការបញ្ជូននឹងត្រូវធ្វើឡើងនៅលំនៅឋានរបស់ដើមចោទ ជាអាទិ៍។ ហេតុនេះ ក្នុងករណីដែលអ្នកតំណាងដោយអាណត្តិរបស់ដើមចោទមានបំណងធ្វើការបញ្ជូនទៅកាន់ទីកន្លែងណាផ្សេងក្រៅពីលំនៅដ្ឋានរបស់ដើមចោទជាអាទិ៍ គឺមានភាពចំបាច់ក្នុងការសរសេរអំពីទីកន្លែងដែលត្រូវបញ្ជូននៅក្នុងលិខិតពាក្យបណ្ដឹងជាអាទិ៍។

## សូមគោរពជូន

## លោកប្រធានសាលាដំបូងខេត្តរតនគិរី[3]

### ក. ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ[4] ៖

(១) បង្គាប់ឲ្យចុងចម្លើយធ្វើនីតិវិធីចុះបញ្ជីអចលនវត្ថុដែលបានកត់ត្រាក្នុងបញ្ជីឧបសម្ព័ន្ធឲ្យទៅដើមចោទ។[5]

(២) ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ចុងចម្លើយ។[6]

---

[3] ដើមចោទត្រូវតែដាក់ពាក្យបណ្ដឹងទៅតុលាការដែលមានសមត្ថកិច្ច (មាត្រា ៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ សមត្ថកិច្ចសាលាជម្រះក្ដីត្រូវកំណត់តាមពេលដាក់ពាក្យបណ្ដឹង (មាត្រា ១៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

នៅក្នុងរឿងក្ដីនេះ លំនៅឋានរបស់ចុងចម្លើយ នៅរាជធានីភ្នំពេញ ដូច្នេះ សាលាដំបូងរាជធានីភ្នំពេញមានសមត្ថកិច្ចជម្រះក្ដី (ចំណុច ក មាត្រា ៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

ម្យ៉ាងវិញទៀត ដោយសារតែរឿងក្ដីនេះ គឺជារឿងក្ដីដែលទាមទារឲ្យធ្វើនីតិវិធីចុះបញ្ជីអំពីការលុបការចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិ (បណ្ដឹងទាក់ទងនឹងការចុះបញ្ជី) ដូច្នេះ តុលាការដែលមានសមត្ថកិច្ចទៅលើ "ទីកន្លែងដែលត្រូវចុះបញ្ជី" មានសមត្ថកិច្ចជម្រះក្ដី (ចំណុច ជ មាត្រា ៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ "ទីកន្លែងដែលត្រូវចុះបញ្ជី" គឺជា "រដ្ឋបាលសុរិយោដី រាជធានី ខេត្តដែលអចលនវត្ថុស្ថិតនៅ (ប្រកាសអន្តរក្រសួងស្ដីពីការចុះបញ្ជីអំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី)។ នៅក្នុងរឿងក្ដីនេះ ដោយសារតែអចលនវត្ថុស្ថិតនៅខេត្តរតនគិរី ដូច្នេះហើយ រដ្ឋបាលសុរិយោដីខេត្តរតនគិរី គឺជា "ទីកន្លែងដែលត្រូវចុះបញ្ជី" ហើយសាលាដំបូងខេត្តរតនគិរីដែលមានសមត្ថកិច្ចនៅទីនោះ ក៏មានសមត្ថកិច្ចជម្រះក្ដីដែរ។

ដើមចោទ អាចដាក់ពាក្យបណ្ដឹងទៅតុលាការណាមួយក៏បានដូចជាសាលាដំបូងរាជធានីភ្នំពេញ ឬ សាលាដំបូងខេត្តរតនគិរី ប៉ុន្តែ នៅក្នុងរឿងក្ដីនេះ ដោយសារតែដើមចោទកំពុងរស់នៅខេត្តរតនគិរី ហេតុនេះក៏បានដាក់ពាក្យបណ្ដឹងទៅសាលាដំបូងខេត្តរតនគិរី។

[4] ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារ គឺជាចំណុចដែលចាំបាច់ត្រូវសរសេរនៅក្នុងពាក្យបណ្ដឹង (មាត្រា ៧៥ កថាខណ្ឌទី ២ ចំណុច ខ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

[5] អ្នកចុះបញ្ជី គឺជាមន្ត្រីសុរិយោដី (ប្រកាសអន្តរក្រសួងស្ដីពីការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមរដ្ឋប្បវេណី (តទៅនៅពេលដែលហៅដោយសង្ខេបថា "ប្រកាសអន្តរក្រសួង" ដែលសំដៅទៅលើប្រកាសអន្តរក្រសួងនេះ ) មាត្រា ៩០) មិនមែនជាចុងចម្លើយទេ។ ចុងចម្លើយមានកាតព្វកិច្ចធ្វើនីតិវិធីដាក់ពាក្យសុំចុះបញ្ជី (មាត្រា ១០ កថាខណ្ឌទី ១ នៃប្រកាសអន្តរក្រសួង) ពោលគឺ ចុងចម្លើយមានកាតព្វកិច្ចមិនលើសពីការបង្ហាញឆន្ទៈក្នុងការដាក់ពាក្យសុំចុះបញ្ជីឡើយ។ នៅពេលដែលសាលក្រមបង្គាប់ទៅចុងចម្លើយអំពីការត្រូវធ្វើការបង្ហាញឆន្ទៈក្នុងការដាក់ពាក្យសុំចុះបញ្ជី (ធ្វើនីតិវិធីដាក់ពាក្យសុំចុះបញ្ជី) បាន ចូលជាស្ថាពរ នឹងត្រូវបានចាត់ទុកថា ចុងចម្លើយបានធ្វើការបង្ហាញឆន្ទៈនៅពេលចូលជាស្ថាពរនោះ (មាត្រា ៥២៩ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ ជាងនេះទៅទៀត ដើមចោទដែលជាអ្នកមានសិទ្ធិចុះបញ្ជីនៅពេលដែលទទួលបានសាលក្រមស្ថាពរដែលបង្គាប់អំពីនីតិវិធីចុះបញ្ជីមកធ្វើជាលិខិតអនុវត្ត គឺអាចដាក់ពាក្យសុំចុះបញ្ជីតែម្នាក់ឯងបាន (មាត្រា ១០ កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ មន្ត្រីសុរិយោដីនឹងមានកាតព្វកិច្ចចុះបញ្ជីនៅពេលដែលចាប់ផ្ដើមមានពាក្យសុំ (ប្រកាសដដែល មាត្រា ៦ កថាខណ្ឌទី ២)។ វានឹងមិនអាចទៅរួចឡើយដែលមន្ត្រីសុរិយោដីមានកាតព្វកិច្ចចុះបញ្ជី ទាំងពុំមានពាក្យសុំពីភាគី។

[6] តុលាការត្រូវសម្រេចសេចក្ដីអំពីករណីយកិច្ចទទួលបន្ទុកប្រាក់ប្រដាប់ក្ដី ទោះបីជាគ្មានពាក្យសុំរបស់ភាគីក៏ដោយ (កថាខណ្ឌទី ៣ មាត្រា ១៨២ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ ហើយ ប្រាក់ប្រដាប់ក្ដី គឺជាបន្ទុករបស់ភាគីចាញ់ក្ដី (មាត្រា ៦៤ កថាខណ្ឌទី ១)។

## ខ. អង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ និង អង្គហេតុដែលជាមូលហេតុនៃការទាមទារ [7]

### ខ.១. ការបង្កើតកិច្ចសន្យាលក់ទិញ [8]

**ខ.១.១.** នៅថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ២០១៨ ដើមចោទបានលក់អចលនវត្ថុដែលបានកត់ត្រាក្នុងបញ្ជីឧបសម្ព័ន្ធ (តទៅហៅថា "ដី L") ក្នុងតម្លៃ ១០០.០០០ (មួយសែន) ដុល្លារអាមេរិកទៅឲ្យចុងចម្លើយ (តទៅហៅថា "កិច្ចសន្យាលក់ទិញនៃរឿងក្ដីនេះ")។ **(ភស្តុតាង $X_1$)**

**ខ.១.២.** ដើមចោទ និង ចុងចម្លើយបានធ្វើលិខិតយថាភូត (លិខិតលក់ផ្ដាច់) ចំពោះ "កិច្ចសន្យាលក់ទិញនៃរឿងក្ដីនេះ" ។ **( ភស្តុតាង $X_1$)**

**ខ.១.៣.** ចំពោះ "កិច្ចសន្យាលក់ទិញនៃរឿងក្ដីនេះ" ដើមចោទ និង ចុងចម្លើយបានព្រមព្រៀងគ្នាដូចខាងក្រោមអំពីកាលបរិច្ឆេទបង់ប្រាក់ថ្លៃលក់៖

- **ក.** ចំពោះប្រាក់ចំនួន ៥០.០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិកនៃថ្លៃលក់ នឹងបង់នៅពេលដែលបានដាក់ពាក្យសុំចុះបញ្ជីផ្ទេរកម្មសិទ្ធិទាំងមូល។
- **ខ.** ចំពោះប្រាក់ចំនួន ៥០.០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិកដែលខ្វះ នឹងត្រូវបង់នៅក្នុងអំឡុងពេល ១ខែ គិតចាប់ពីពេលដែលបានដាក់ពាក្យសុំចុះបញ្ជីផ្ទេរកម្មសិទ្ធិទាំងមូល។

---

[7] អង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ គឺជាចំណុចដែលចាំបាច់ត្រូវសរសេរនៅក្នុងពាក្យបណ្ដឹង (ចំណុច ខ កថាខណ្ឌទី ២ មាត្រា ៧៥ នៃក្រមរដ្ឋប្បវេណី)។

ម្យ៉ាងទៀត នៅក្នុងពាក្យបណ្ដឹង ត្រូវសរសេរបញ្ជាក់ឲ្យបានច្បាស់លាស់នូវអង្គហេតុដែលជាមូលហេតុនៃការទាមទារ និង តាមចំណុចដែលត្រូវការបញ្ជាក់ភស្តុតាង គប្បីសរសេរបញ្ជាក់នូវអង្គហេតុសំខាន់ៗ ក្នុងចំណោមអង្គហេតុទាំងមូលដែលទាក់ទងនឹងអង្គហេតុដែលជាមូលហេតុនៃការទាមទារ និង ភស្តុតាង (កថាខណ្ឌទី ៣ មាត្រា ៧៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

[8] កិច្ចសន្យាលក់ទិញ អាចត្រូវបានបង្កើតឡើងដោយមានការព្រមព្រៀងគ្នារវាងភាគីទាំងសងខាងតែប៉ុណ្ណោះ លើកលែងតែក្នុងករណីដែលមានបញ្ញត្តិពិសេសក្នុងច្បាប់ (មាត្រា ៥១៦ នៃក្រមរដ្ឋប្បវេណី)។ ចំពោះ "បញ្ញត្តិពិសេសក្នុងច្បាប់" មានដូចជា កថាខណ្ឌទី ២ មាត្រា ៣៣៦ នៃក្រមរដ្ឋប្បវេណី។ ពោលគឺ ក្នុងករណីកិច្ចសន្យាលក់ទិញ គឺជាកិច្ចសន្យាដែល "ភាគីម្ខាងមានករណីយកិច្ចធ្វើអនុប្បទាននូវកម្មសិទ្ធិលើអចលនវត្ថុ ឬ ករណីយកិច្ចធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើអចលនវត្ថុ" កិច្ចសន្យានេះ នឹងមានអានុភាពលុះត្រាតែបានធ្វើលិខិតយថាភូត (កថាខណ្ឌទី ២ មាត្រា ៣៣៦ នៃក្រមរដ្ឋប្បវេណី)។ ចំពោះអត្ថន័យនៃ "លិខិតយថាភូត" ក្នុងកថាខណ្ឌទី ២ មាត្រា ៣៣៦ នៃក្រមរដ្ឋប្បវេណី ត្រូវបានកំណត់នៅក្នុងកថាខណ្ឌទី ១ មាត្រា ៩ នៃច្បាប់ស្ដីពីការអនុវត្តក្រមរដ្ឋប្បវេណី។

## ខ.២. ការរំលាយកិច្ចសន្យាលក់ទិញដោយមូលហេតុចុងចម្លើយមិនអនុវត្តកាតព្វកិច្ច[9]

**ខ.២.១.** នៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ២០១៨ ដើមចោទ និង ចុងម្លើយបានដាក់ពាក្យសុំចុះបញ្ជីផ្ទេរកម្មសិទ្ធិទាំងមូលទៅរដ្ឋបាលសុរិយោដីខេត្តរតនគិរីដោយផ្អែកតាម "កិច្ចសន្យាលក់ទិញនៃរឿងក្តីនេះ"។ **(ភស្តុតាង $X_2$)**

**ខ.២.២.** ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០១៨ បានកន្លងផុត។

**ខ.២.៣.** នៅថ្ងៃទី១១ ខែមករា ឆ្នាំ២០១៩ ដើមចោទបានដាស់តឿន[10]ទៅចុងចម្លើយឲ្យបង់ប្រាក់ថ្លៃលក់ចំនួន ៥០.០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិកដែលខ្វះ

---

[9] ភាគីម្ខាងនៃកិច្ចន្យាអញ្ញមញ្ញអាចរំលាយកិច្ចសន្យាបានភ្លាមៗ ក្នុងករណីដែលភាគីម្ខាងទៀត "បំពានកិច្ចសន្យាធ្ងន់ធ្ងរ" (មាត្រា ៤០៧ នៃក្រមរដ្ឋប្បវេណី)។

ជាដំបូង កិច្ចសន្យាលក់ទិញ គឺជាកិច្ចសន្យាដែលភាគីម្ខាងហៅថា អ្នកលក់មានករណីកិច្ចត្រូវផ្ទេរកម្មសិទ្ធិ ឬ សិទ្ធិផ្សេងទៀតលើទ្រព្យសម្បត្តិឲ្យទៅភាគីម្ខាងទៀតហៅថា អ្នកទិញ ហើយអ្នកទិញមានករណីយកិច្ចត្រូវចេញថ្លៃជាប្រាក់ឲ្យអ្នកលក់ (មាត្រា ៥១៥ នៃក្រមរដ្ឋប្បវេណី) ដូច្នេះហើយ កិច្ចសន្យានេះ គឺជាកិច្ចសន្យាអញ្ញមញ្ញ។

បន្ទាប់មកទៀត ចំពោះខ្លឹមសារនៃ "ការបំពានកិច្ចសន្យាធ្ងន់ធ្ងរ" គឺត្រូវបានកំណត់នៅក្នុងកថាខណ្ឌទី ១ មាត្រា ៤០៨ នៃក្រមរដ្ឋប្បវេណី។ ភាគីម្ខាងនៃកិច្ចសន្យាដែលចង់រំលាយកិច្ចសន្យាអញ្ញមញ្ញ ចាំបាច់ត្រូវអះអាងអំពីមូលហេតុដែលត្រូវបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រាដដែលនេះ។

ហើយ ភាគីម្ខាងនៃកិច្ចសន្យាដែលមានសិទ្ធិរំលាយកិច្ចសន្យា អាចរំលាយកិច្ចសន្យាដោយការបង្ហាញឆន្ទៈអំពីការរំលាយទៅភាគីម្ខាងទៀតបាន។ **<u>ការបង្ហាញឆន្ទៈរំលាយកិច្ចសន្យាអាចធ្វើឡើងនៅក្រៅតុលាការបាន (កថាខណ្ឌទី ១ មាត្រា ៤០៩ នៃក្រមរដ្ឋប្បវេណី) ដើម្បីអះអាងអំពីការរំលាយកិច្ចសន្យា ពុំចាំបាច់ធ្វើការដាក់ពាក្យបណ្តឹងទេ។</u>**

<u>ការរំលាយកិច្ចសន្យានាំឲ្យគូភាគីរួចផុតពីករណីយកិច្ចក្នុងកិច្ចសន្យា លើកលែងតែករណីយកិច្ចសងការខូចខាត (កថាខណ្ឌទី ១ មាត្រា ៤១១ នៃក្រមរដ្ឋប្បវេណី)។ ម្យ៉ាងវិញទៀត ភាគីដែលបានទទួលតាវកាលិកនៃកិច្ចសន្យាតែមួយភាគ ឬ ទាំងអស់ ត្រូវមានករណីកិច្ចសងតាវកាលិកនោះទៅភាគីម្ខាងទៀត ដើម្បីឲ្យភាគីនោះទទួលបដិទានឡើងវិញ ដោយសារការរំលាយ (កថាខណ្ឌទី ២ មាត្រា ៤១១នៃក្រមរដ្ឋប្បវេណី)។ ក្នុងករណីដែលដើមចោទពុំមានតាវកាលិកដែលចង់ទាមទារឲ្យចុងចម្លើយដែលជាភាគីម្ខាងទៀតសងមកវិញទេនោះ គ្រាន់តែបង្ហាញឆន្ទៈអំពីការរំលាយកិច្ចសន្យាទៅកាន់ចុងចម្លើយនៅក្រៅតុលាការ គឺជាការគ្រាប់គ្រាន់ ហើយពុំចាំបាច់ដាក់ពាក្យបណ្តឹងមកកាន់តុលាការទេ។</u>

[10] នៅក្នុងរឿងក្តីនេះ ដោយហេតុថា ដើមចោទកំពុងតែអះអាងអំពី "ការបំពានកិច្ចសន្យាធ្ងន់ធ្ងរ" ផ្អែកតាមចំណុច ក កថាខណ្ឌទី ១ មាត្រា ៤០៨ នៃក្រមរដ្ឋប្បវេណី ដូច្នេះហើយ ចាំបាច់ត្រូវតែអះអាងអំពី ① កាលបរិច្ឆេទបង់ប្រាក់ថ្លៃលក់ (ថ្ងៃទី ៣១ ខែ វិច្ឆិកា ឆ្នាំ ២០១៨) បានកន្លងផុត ("ខ.២.១." និង "ខ.២.២.") និង ② ការបានដាស់តឿនដោយកំណត់អំឡុងពេលសមរម្យ ("ខ.២.៣.")។

នៅក្នុងអំឡុងពេល២សប្តាហ៍ ជាមួយគ្នានេះ ក៏បានធ្វើការបង្ហាញឆន្ទៈ[11] អំពីការរំលាយ "កិច្ចសន្យានៃរឿងក្តីនេះ" នៅពេលដែលមិនបានបង់ប្រាក់ថ្លៃលក់នៅក្នុងអំឡុងពេល ២សប្តាហ៍។ **(ភស្តុតាង $X_3$)**

**ខ.២.៤.** ចុងចម្លើយមិនបានបង់ប្រាក់ថ្លៃលក់ចំនួន ៥០.០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិកដែលខ្វះទេ គិតមកដល់ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៩ ។[12]

**ខ.២.៥.** នៅថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០១៨ បានផ្តល់នូវការប្រគល់ "ដីL" ទៅចុងចម្លើយ ផ្អែកតាម "កិច្ចសន្យានៃរឿងក្តីនេះ" ។[13] **(ភស្តុតាង $X_4$)**

**ដូច្នេះ ដើមចោទទាមទារឲ្យចុងចម្លើយធ្វើនីតិវិធីចុះបញ្ជីអំពីការលុបការចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិលើ "ដី L" ដោយផ្អែកលើកការរំលាយ "កិច្ចសន្យាលក់ទិញនៃរឿងក្តីនេះ"។**[14]

## គ. ប្រាក់ប្រដាប់ក្តី

ប្រាក់ប្រដាប់ក្តីនៃរឿងក្តីនេះ គប្បីជាបន្ទុករបស់ចុងចម្លើយ (កថាខណ្ឌទី ១ មាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

[11] ការបង្ហាញឆន្ទៈអំពីការរំលាយកិច្ចសន្យា អាចដាក់លក្ខខណ្ឌបង្អង់បាន (កថាខណ្ឌទី ៣ មាត្រា ៤០៩ និង វាក្យខណ្ឌទី ២ កថាខណ្ឌទី ១ មាត្រា ៣២៥ នៃក្រមរដ្ឋប្បវេណី)។ នៅក្នុងរឿងក្តីនេះ នៅពេលដែលបង្ហាញឆន្ទៈរំលាយ "កិច្ចសន្យាលក់ទិញនៃរឿងក្តីនេះ" ដើមចោទបានដាក់លក្ខខណ្ឌបង្អង់ថា "បើមិនបង់ប្រាក់នៅក្នុងអំឡុងពេលដាស់តឿន (អំឡុងពេល ២សប្តាហ៍) ។

[12] ដើមចោទអះអាងអំពីលក្ខខណ្ឌបង្អង់ ( លក្ខខណ្ឌដែលលើកឡើងថា "មិនបង់ប្រាក់នៅក្នុងអំឡុងពេលដាស់តឿន") ដែលបានដាក់នៅពេលបង្ហាញឆន្ទៈអំពីការរំលាយកិច្ចសន្យា គឺត្រូវបានបំពេញ (កថាខណ្ឌទី ៣ មាត្រា ៣២៥ នៃក្រមរដ្ឋប្បវេណី)។

[13] អ្នកទិញអាចមិនព្រមបង់ប្រាក់ថ្លៃទិញបាន រហូតដល់ពេលដែលអ្នកលក់បានផ្តល់នូវការសងចំពោះកាតព្វកិច្ចរបស់ខ្លួន (កថាខណ្ឌទី ១ មាត្រា ៥៥៨ នៃក្រមរដ្ឋប្បវេណី)។ ដូច្នេះហើយ ទោះបីជាអ្នកទិញមិនបានអនុវត្តកាតព្វកិច្ចបង់ថ្លៃទិញក៏ដោយ ដរាបណានៅក្នុងអំឡុងពេលដែលត្រូវទទួលនូវការផ្តល់ការសងកាតព្វកិច្ចរបស់អ្នកលក់ គឺមិនអាចនិយាយថា " បំពានកិច្ចសន្យាធ្ងន់ធ្ងរ"បានទេ។

នៅក្នុងរឿងក្តីនេះ ដើមចោទដែលជាអ្នកលក់ ក្រៅពីមានករណីយកិច្ចធ្វើការចុះបញ្ជីផ្ទេរកម្មសិទ្ធិ នៅមានករណីយកិច្ចប្រគល់ដី L (មាត្រា ៥៣០ នៃក្រមរដ្ឋប្បវេណី) ដូច្នេះ បើសិនជាមិនអះអាងអំពីការបានធ្វើនីតិវិធីផ្ទេរកម្មសិទ្ធិ ("ខ.២.១.") ហើយបន្ថែមនូវការអះអាងអំពីការបានផ្តល់នូវការប្រគល់ដី L ("ខ.២.៥.") ទេនោះ មិនអាចនិយាយបានថា ការមិនអនុវត្តករណីយកិច្ចបង់ថ្លៃទិញរបស់ចុងចម្លើយ គឺជា "ការបំពានកិច្ចសន្យាធ្ងន់ធ្ងរ" បានទេ។

[14] បញ្ជាក់ឲ្យបានច្បាស់អំពីសារធាតុគតិយុត្តនៃសិទ្ធិទាមទារ។

## ខ. ភស្តុតាង

១. លិខិតលក់ផ្តាច់ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១៨ (**ភស្តុតាង** $X_1$)

២. ច្បាប់ចម្លងនៃពាក្យសុំចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិ (**ភស្តុតាង** $X_2$)

៣. រូបថត (សារនៅក្នុងTelegram ដែលត្រូវបានផ្ញើទៅមករវាងដើមចោទ និងចុងចម្លើយនៅថ្ងៃទី១១ ខែមករា ឆ្នាំ២០១៩) (**ភស្តុតាង** $X_3$)

៤. រូបថត (សារនៅក្នុងTelegram ដែលត្រូវបានផ្ញើទៅមករវាងដើមចោទ និងចុងចម្លើយនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨) (**ភស្តុតាង** $X_4$)

សេចក្តីដូចមានកំណត់ សូម **លោកប្រធាន** សម្រេចតាមការស្នើសុំ ដោយក្តីអនុគ្រោះ។ សូម **លោកប្រធាន** ទទួលនូវសេចក្តីគោរពដ៏ជ្រាលជ្រៅអំពីខ្ញុំ។

ខេត្តរតនគិរី, ថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១៩

**អ្នកតំណាងដោយអាណត្តិ**

P

<u>ឯកសារភ្ជាប់</u>

១-លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ "ច្បាប់ដើម"

២-ច្បាប់ថតចម្លងនៃភស្តុតាងនីមួយៗខាងលើ "ចំនួន ០២ ច្បាប់"

**ឧបសម្ព័ន្ធ**

**បញ្ជី**[15]

| | |
|---|---|
| "គោលបំណងនៃពាក្យសុំចុះបញ្ជី" | ការលុបការចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិ |
| "មូលហេតុនៃពាក្យសុំចុះបញ្ជី និង កាលបរិច្ឆេទ" | ការរំលាយកិច្ចសន្យាចុះថ្ងៃទី ២៥ ខែមករា ឆ្នាំ ២០១៩ |
| "បុគ្គលមានសិទ្ធិចុះបញ្ជី" | ដើមចោទ ( X )<br>ថ្ងៃខែឆ្នាំកំណើត ៖ ថ្ងៃ......ខែ..........ឆ្នាំ.........<br>ទីកន្លែងកំណើត ៖ ......................................<br>ឈ្មោះរបស់ឪពុកម្តាយ៖ ...................(ឪពុក)<br>.....................(ម្តាយ) |
| "បុគ្គលមានកាតព្វកិច្ចចុះបញ្ជី" | ចុងចម្លើយ ( Y )<br>ថ្ងៃខែឆ្នាំកំណើត ៖ ថ្ងៃ......ខែ..........ឆ្នាំ.........<br>ទីកន្លែងកំណើត ៖ ......................................<br>ឈ្មោះរបស់ឪពុកម្តាយ៖ ...................(ឪពុក)<br>.....................(ម្តាយ) |
| "អត្តសញ្ញាណនៃអចលនវត្ថុ" | ទីតាំងដី ៖ ផ្លូវលេខ....... ភូមិ....... ឃុំ........ ស្រុក....... ខេត្ត រតនគិរី<br>លេខក្បាលដី ៖ ......... |

[15] ដើម្បីទាមទារនូវនីតិវិធីចុះបញ្ជីអំពីការលុបការចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិ មានភាពចាំបាច់ត្រូវសរសេរអំពីចំណុចដែលត្រូវបានកំណត់នៅក្នុងប្រការ ២៦ និង ប្រការ ៣១ នៃប្រកាសអន្តរក្រសួងស្តីពីនីតិវិធីនៃការចុះបញ្ជីអំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី។

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# ឯកសារចម្លើយ[1]

## ដើមចោទ

ឈ្មោះ ៖ X

អាសយដ្ឋាន ៖ ផ្ទះលេខ 00 ផ្លូវលេខ 00 ភូមិ...... ឃុំ.......ស្រុក......... ខេត្តរតនគិរី។

## ចុងចម្លើយ

ឈ្មោះ ៖ Y

អាសយដ្ឋាន ៖ ផ្ទះលេខ 00 ផ្លូវលេខ 00 សង្កាត់មនោរម្យ ខណ្ឌ៧មករា រាជធានីភ្នំពេញ។

## អ្នកតំណាងដោយអាណត្តិ

លោក/លោកស្រីមេធាវី ៖ B

អាសយដ្ឋានការិយាល័យមេធាវី / ក្រុមមេធាវី / ក្រុមហ៊ុនមេធាវី ៖............................

ការិយាល័យមេធាវី / ក្រុមមេធាវី / ក្រុមហ៊ុនមេធាវី ៖...............................................

លេខទូរស័ព្ទ ៖...................................................

**ទីកន្លែងបញ្ជូន** ៖ ការិយាល័យមេធាវី/ ក្រុមមេធាវី/ ក្រុមហ៊ុនមេធាវី.................[2]

---

[1] ឯកសារត្រៀមដែលចុងចម្លើយដាក់ទៅតុលាការជាលើកដំបូង ហៅថា "ឯកសារចម្លើយ"។ នៅក្នុងឯកសារនេះនឹងត្រូវសរសេរអំពី ① ការឆ្លើយតបចំពោះខ្លឹមសារនៃសាលក្រមដែលដើមចោទបានសរសេរនៅក្នុងពាក្យបណ្ដឹង ② ការទទួលស្គាល់ ឬ មិនទទួលស្គាល់នូវអង្គហេតុដែលមានសរសេរនៅក្នុងពាក្យបណ្ដឹង និង ③ អង្គហេតុដើម្បីតវ៉ាចំពោះអង្គហេតុដែលមានសរសេរនៅក្នុងពាក្យបណ្ដឹង (កថាខណ្ឌទី៣ មាត្រា ១០១នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

[2] មាត្រា ២៤៩ និង មាត្រា ២៥០ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ ការសរសេរអំពីកន្លែងបញ្ជូន មិនមែនជាកាតព្វកិច្ចទេ។ ប្រសិនបើមិនបានសរសេរអំពីទីកន្លែងបញ្ជូន ការបញ្ជូននឹងត្រូវធ្វើឡើងនៅលំនៅដ្ឋានរបស់ចុងចម្លើយជាអាទិ៍។ ដូច្នេះ ក្នុងករណីដែលអ្នកតំណាងដោយអាណត្តិរបស់ចុងចម្លើយចង់ធ្វើការបញ្ជូនទៅទីកន្លែងណាផ្សេងក្រៅពីលំនៅដ្ឋានរបស់ចុងចម្លើយជាអាទិ៍ ចាំបាច់ត្រូវសរសេរអំពីកន្លែងបញ្ជូនចូលទៅក្នុងលិខិតលាយលក្ខណ៍អក្សរ ដូចជា ឯកសារចម្លើយជាអាទិ៍។

**សូមគោរពជូន**

**លោក ┘ ចៅក្រមនៃសាលាដំបូងខេត្តរតនគិរី**

**<u>កម្មវត្ថុ</u>** ៖ សុំដាក់**ឯកសារចម្លើយដើម្បីឆ្លើយតប**នឹងពាក្យបណ្ដឹងចុះថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១៩ របស់ឈ្មោះ X

**<u>យោង</u>**៖-មាត្រា **១០១ កថាខណ្ឌទី ៣** នៃក្រមនីតិវិធីរដ្ឋប្បវេណី

-សំណុំរឿងរដ្ឋប្បវេណីលេខ .........ចុះថ្ងៃទី០១ ខែ មីនា ឆ្នាំ ២០១៩

## ក. ការឆ្លើយតបចំពោះខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារ

(១) ច្រានចោលការទាមទាររបស់ដើមចោទ។

(២) ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ដើមចោទ។

## ខ. ការទទួលស្គាល់ ឬ មិនទទួលស្គាល់នូវអង្គហេតុដែលមានសរសេរនៅក្នុងពាក្យបណ្ដឹង

### ខ.១. ការទទួលស្គាល់ ឬ មិនទទួលស្គាល់អំពី "ការបង្កើតកិច្ចសន្យាលក់ទិញនៃចំណុច ខ.១." នៅក្នុងពាក្យបណ្ដឹង

**ខ.១.១.** អង្គហេតុដែលត្រូវបានសរសេរនៅក្នុងចំណុច **"ខ.១.១."** នៃពាក្យបណ្ដឹង ៖ ចុងចម្លើយទទួលស្គាល់ ។

**ខ.១.២.** អង្គហេតុដែលត្រូវបានសរសេរនៅក្នុងចំណុច **"ខ.១.២."** នៃពាក្យបណ្ដឹង ៖ ចុងចម្លើយទទួលស្គាល់ ។

**ខ.១.៣.** អង្គហេតុដែលត្រូវបានសរសេរនៅក្នុងចំណុច **"ខ.១.៣."** នៃពាក្យបណ្ដឹង ៖ ចុងចម្លើយទទួលស្គាល់ ។

### ខ.២. ការទទួលស្គាល់ ឬ មិនទទួលស្គាល់អំពី "ការរំលាយកិច្ចសន្យាលក់ទិញដោយមូលហេតុចុងចម្លើយមិនអនុវត្តកាតព្វកិច្ចនៃចំណុច "ខ.២." នៅក្នុងពាក្យបណ្ដឹង[3]

---

[3] អង្គហេតុដែលត្រូវបានសរសេរនៅក្នុងចំណុច "ខ.២.២." នៃពាក្យបណ្ដឹង (ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៨ បានកន្លងផុត) គឺជា "អង្គហេតុដែលអត្ថិភាពនៃអង្គហេតុនោះមានភាពជាក់ស្ដែងចំពោះតុលាការ" (កថាខណ្ឌទី ២ មាត្រា ១២៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ដូច្នេះ តុលាការពុំចាំបាច់ទទួលស្គាល់ដោយផ្អែកលើភស្តុតាងទេ។ ហេតុនេះ ភាគីក៏ពុំចាំបាច់ធ្វើការទទួលស្គាល់ ឬ មិនទទួលស្គាល់ដែរ។

ខ.២.១. អង្គហេតុដែលត្រូវបានសរសេរនៅក្នុងចំណុច **"ខ.២.១."** នៃពាក្យបណ្តឹង ៖ ចុងចម្លើយទទួលស្គាល់ ។

ខ.២.២. អង្គហេតុដែលត្រូវបានសរសេរនៅក្នុងចំណុច **"ខ.២.៣."** នៃពាក្យបណ្តឹង ៖ ចុងចម្លើយទទួលស្គាល់ ។

ខ.២.៣. អង្គហេតុដែលត្រូវបានសរសេរនៅក្នុងចំណុច **"ខ.២.៤."** នៃពាក្យបណ្តឹង ៖ ចុងចម្លើយទទួលស្គាល់ ។

ខ.២.៤. អង្គហេតុដែលត្រូវបានសរសេរនៅក្នុងចំណុច **"ខ.២.៥."** នៃពាក្យបណ្តឹង ៖ ចុងចម្លើយទទួលស្គាល់ ។

## គ. អង្គហេតុតវ៉ា

### គ.១. ការព្រមព្រៀងអំពីការផ្លាស់ប្តូរកាលបរិច្ឆេទអនុវត្ត[4]

គ.១.១. នៅថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៨ ដើមចោទ និង ចុងចម្លើយបានព្រមព្រៀងអំពីការផ្លាស់ប្តូរកាលបរិច្ឆេទបង់ប្រាក់ចំនួន ៥០.០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិកដែលមិនទាន់បានបង់នៃប្រាក់ថ្លៃលក់ទិញក្នុង "កិច្ចសន្យាលក់ទិញនៃរឿងក្តីនេះ" ពីថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០១៨ ទៅជាថ្ងៃទី ៣១ ខែមីនា ឆ្នាំ ២០១៩។[5]

---

[4] លក្ខខណ្ឌមួយនៃ "ការបំពានកិច្ចសន្យាធ្ងន់ធ្ងរ" ដែលមាននៅក្នុងចំណុច ក កថាខណ្ឌទី ១ មាត្រា ៤០៨ នៃក្រមរដ្ឋប្បវេណី គឺ "ភាគីម្ខាង "មិនបានអនុវត្តកាតព្វកិច្ចតាមពេលកំណត់" ។ ប្រសិនបើ "ពេលកំណត់" នេះត្រូវបានផ្លាស់ប្តូរ ហើយភាគីម្ខាងបានអនុវត្តសិទ្ធិរំលាយនៅពេលដែលអំឡុងពេលអនុវត្តកាតព្វកិច្ចមិនទាន់បានមកដល់ គឺមានន័យថាមិនទាន់បានបំពេញលក្ខខណ្ឌដែលលើកឡើងថា "មិនបានអនុវត្តតាមពេលកំណត់" នៅឡើយទេ ហេតុនេះ ភាគីម្ខាងមិនអាចរំលាយកិច្ចសន្យាបានទេ។ ដូច្នេះ កាលបរិច្ឆេទអនុវត្តដែលត្រូវបានផ្លាស់ប្តូរ នឹងមានតួនាទីសម្រាប់ធ្វើជាការតវ៉ាអំពី ការរំលាយកិច្ចសន្យាដោយមូលហេតុការមិនអនុវត្តកាតព្វកិច្ច។

[5] អង្គហេតុដែលសរសេរនៅក្នុងចំណុច "គ.១.១." ពុំមានឯកសារបញ្ជាក់ដោយផ្ទាល់ទៅលើចំណុចនេះទេ (ឧទាហរណ៍៖ សារដែលដើមចោទបានយល់ព្រមទៅលើចំណុចនោះ)។

ប៉ុន្តែ ដើមចោទកំពុងតែអះអាងអំពីការកន្លងផុតនៃថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៨ ដែលជាកាលបរិច្ឆេទអនុវត្តកាតព្វកិច្ចនៅពេលដំបូងដោយគិតជាមុនថាកាលបរិច្ឆេទអនុវត្តកាតព្វកិច្ចមិនត្រូវបានផ្លាស់ប្តូរទេ ដូច្នេះហើយ តុលាការព្យាករថា ការព្រមព្រៀងអំពីការផ្លាស់ប្តូរកាលបរិច្ឆេទអនុវត្ត ប្រាកដជាមានវិវាទ។

ដូច្នេះហើយ ក្នុងនាមជាចុងចម្លើយ គប្បីអះអាងទុកជាមុនអំពី អង្គហេតុសំខាន់ (គ.១.២.) ដែលជាអង្គហេតុដែលពាក់ព័ន្ធនឹងការព្រមព្រៀងអំពីការផ្លាស់ប្តូរកាលបរិច្ឆេទ ទើបជាការប្រសើរ។ ចំណុចនេះគឺមានគោលបំណងដូចគ្នាទៅនឹងការកំណត់ដែលលើកឡើងថា "នៅក្នុងពាក្យបណ្តឹង តាមចំណុចដែលត្រូវបញ្ជាក់ភស្តុតាង គប្បីសរសេរបញ្ជាក់ឲ្យបានច្បាស់លាស់នូវអង្គហេតុសំខាន់ៗ ក្នុងចំណោមអង្គហេតុទាំងមូលដែលទាក់ទងនឹងអង្គហេតុដែលជាមូលហេតុនៃការទាមទារ និង ភស្តុតាង (កថាខណ្ឌទី ៣ មាត្រា ៧៥ នៃក្រមរដ្ឋប្បវេណី)។

**គ.១.២.** ការព្រមព្រៀងនៅក្នុងចំណុច **"គ.១.១."** ខាងលើ ដោយចុងចម្លើយធ្វើសំណើអំពីការផ្លាស់ប្តូរទៅកាន់ដើមចោទ ហើយដើមចោទបានធ្វើស្វីការយល់ព្រមលើសំណើនោះ។ នៅខណៈពេលដែលចុងចម្លើយកំពុងរៀបចំរើចាកចេញពីភ្នំពេញទៅខេត្តរតនគិរី ត្រូវបានគេបបួលពិភាក្សារឿងដែលធ្វើឲ្យចំណេញលុយ ដោយសារតែចិត្តនឹកឃើញចង់បាន ក៏ចូលរួមនិយាយរឿងនោះ ដូច្នេះហើយក៏ត្រូវបានគេបោកយកលុយបានសម្រេច។ ហើយចំពោះប្រាក់ចំនួន ៥០.០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិកដែលចុងចម្លើយមានគម្រោងបង់ទៅឲ្យដើមចោទឲ្យបានត្រឹមថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០១៨ ដែលជាគម្រោងកាលពីដើមនោះក៏ពិបាកនឹងបង់បានដែរ។ ដូច្នេះហើយ នៅពេលដែលបានទទួលការទាក់ទងពីដើមចោទអំពីការប្រគល់ "ដី L" ចុងចម្លើយក៏បានផ្ញើសារទៅវិញថា "សូមឲ្យរង់ចាំ ៣ ខែតទៀត" ។ បន្ទាប់មក ដើមចោទក៏បានទូរស័ព្ទមកចុងចម្លើយភ្លាមៗ និងក្រោយពីបានស្តាប់អំពីខ្លឹមសារដែលចុងចម្លើយត្រូវបានគេបោក ដើមចោទក៏បាននិយាយមកកាន់ចុងចម្លើយថា "ខ្ញុំដឹងហើយ។ ឆ្នាំក្រោយនឹងមានភាពប្រសើរឡើងវិញហើយ"។ **(ភស្តុតាង $Y_1$ និង $Y_2$)**

**គ.១.៣.** យោងតាមការព្រមព្រៀងចំណុច **"គ.១.១."** ខាងលើនេះ ប្រាក់ចំនួន ៥០.០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិកនៃ "កិច្ចសន្យាលក់ទិញនៃរឿងក្តីនេះ" ដែលខ្វះត្រូវបានផ្លាស់ប្តូរកាលបរិច្ឆេទអនុវត្តបង់ប្រាក់នោះមកនៅត្រឹមថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៩ វិញ។

**ដូច្នេះហើយ គិតត្រឹមថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១៩ ដែលដើមចោទបានបង្ហាញឆន្ទៈអំពីការរំលាយកិច្ចសន្យាគឺ ចុងចម្លើយមិនទាន់បានបំពានកិច្ចសន្យធ្ងន់ធ្ងរនៅឡើយទេ (កថាខណ្ឌទី ១ មាត្រា ៤០៨ នៃក្រមរដ្ឋប្បវេណី) ដូច្នេះ ការរំលាយ "កិច្ចសន្យាលក់ទិញនៃរឿងក្តីនេះ" ដែលធ្វើឡើងដោយដើមចោទគឺ ត្រូវមោឃៈ។ ចុងចម្លើយមិនមានករណីយកិច្ចធ្វើនីតិវិធីចុះបញ្ជីអំពីការលុបការចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិលើ "ដី L" ទេ។**

**បើទោះបីជាការរំលាយ "កិច្ចសន្យាលក់ទិញនៃរឿងក្ដីនេះ" ដែលធ្វើឡើងដោយដើមចោទ មានសុពលភាពក៏ដោយ ក៏ចុងចម្លើយនឹងអះអាងអំពីការតវ៉ាដូចមានខាងក្រោម ៖[6]**

**គ.២. ការអនុវត្តព្រមគ្នា**

**គ.២.១.** នៅថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ២០១៨ ចុងចម្លើយបានបង់ប្រាក់ចំនួន ៥០.០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិកដែលជាមួយភាគនៃថ្លៃលក់ទិញដោយផ្អែកលើ "កិច្ចសន្យាលក់ទិញនៃរឿងក្ដីនេះ" ឲ្យទៅដើមចោទ។[7] **(ភស្តុតាង$Y_3$)**

**គ.២.២.** ចុងចម្លើយបដិសេធអំពីការធ្វើនីតិវិធីចុះបញ្ជីអំពីការលុបការចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិលើ "ដី L" ដែរ រហូតទាល់តែដើមចោទសងប្រាក់ ៥០.០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិក ដោយភ្ជាប់ជាមួយនឹងការប្រាក់ ៥ % ក្នុងមួយឆ្នាំ ដែលគិតចាប់ពីថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១៨ រហូតដល់ថ្ងៃសងរួច (កថាខណ្ឌទី ២ និង ទី ៣ មាត្រា ៥១១) ។[8]

---

[6] ភាគីដែលបានទទួលតាវកាលិកនៃកិច្ចសន្យាតែមួយភាគ ឬ ទាំងអស់ត្រូវមានករណីយកិច្ចសងតាវកាលិកនោះទៅភាគីម្ខាងទៀត ដើម្បីឲ្យភាគីនោះទទួលបដិទានឡើងវិញ ដោយសារការរំលាយ។ ក្នុងករណីដែលភាគីទាំងសងខាង មានករណីយកិច្ចធ្វើបដិទានទៅវិញទៅមក ករណីកិច្ចទាំងនោះត្រូវអនុវត្តនៅពេលជាមួយគ្នា។ (កថាខណ្ឌទី ២ មាត្រា ៥១១ នៃក្រមរដ្ឋប្បវេណី)

បើទោះបីជាការរំលាយ "កិច្ចសន្យាលក់ទិញនៃរឿងក្ដីនេះ" ដែលធ្វើឡើងដោយដើមចោទមានសុពលភាពក៏ដោយ ក៏ចុងចម្លើយអះអាងថា ការទាមទាររបស់ដើមចោទ (ការធ្វើនីតិវិធីចុះបញ្ជីអំពីការលុបការចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិលើ "ដី L" ) និង ការអនុវត្តនូវករណីយកិច្ចធ្វើបដិទានស្ថានភាពដើមដែលដើមចោទមានចំពោះចុងចម្លើយត្រូវធ្វើឡើងនៅក្នុងពេលតែមួយ ដូច្នេះហើយ ចុងចម្លើយអាចរារាំងតុលាការពីការទទួលស្គាល់ទាំងមូលទៅលើការទាមទាររបស់ដើមចោទបាន។ ក្នុងករណីដែលតុលាការបានទទួលស្គាល់នូវការតវ៉ានេះ នាំឲ្យតុលាការត្រូវទទួលស្គាល់នូវការទាមទារដែលដើមចោទបានទាមទារនូវតាវកាលិកធម្មតាដោយកម្រិតនូវការផ្ដល់តាវកាលិកតបវិញ (ទទួលស្គាល់មួយផ្នែក ហើយច្រានចោលមួយផ្នែក)។

ហើយ ខ្លឹមសារនៃករណីយកិច្ចធ្វើបដិទានស្ថានភាពដើមដែលដើមចោទមានចំពោះចុងចម្លើយ គឺជាការសងប្រាក់ចំនួន ៥០.០០០ (ប្រាំម៉ឺន)ដុល្លារអាមេរិក និង ការប្រាក់ ៥% ក្នុងមួយឆ្នាំនៃប្រាក់នេះ ដោយគិតចាប់ពីថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១៨ រហូតដល់ថ្ងៃសងរួច (កថាខណ្ឌទី ៣ មាត្រា ៥១១នៃក្រមរដ្ឋប្បវេណី)។

[7] ដើម្បីអះអាងអំពីការតវ៉ាឲ្យអនុវត្តព្រមគ្នា ក៏ចាំបាច់ត្រូវអះអាងអំពីភាគីម្ខាងដែល " កំពុងទទួលតាវកាលិកនៃកិច្ចសន្យាមួយភាគ ឬ ទាំងអស់" ផងដែរ (កថាខណ្ឌទី ២ មាត្រា ៥១១ នៃក្រមរដ្ឋប្បវេណី)។ នៅក្នុងរឿងក្ដីនេះ ចុងចម្លើយចាំបាច់ត្រូវអះអាងថា បានបង់ថ្លៃលក់ទិញមួយភាគឲ្យទៅដើមចោទផ្អែកតាម "កិច្ចសន្យាលក់ទិញនៃរឿងក្ដីនេះ"។

[8] ការប្រើនូវការតវ៉ាឲ្យអនុវត្តព្រមគ្នា ឬ យ៉ាងណានោះ គឺអាស្រ័យទៅលើឆន្ទៈរបស់ម្ចាស់សិទ្ធិដែលមានសិទ្ធិតវ៉ាឲ្យអនុវត្តព្រមគ្នា។ បើទោះបីជានៅពេលដែលមានសិទ្ធិតវ៉ាឲ្យអនុវត្តព្រមគ្នាក៏ដោយ ហើយមិនបានអះអាងអំពីសិទ្ធិតវ៉ានោះ ហើយអនុវត្តកាតព្វកិច្ចរបស់ខ្លួនវិញ ក៏ពុំមានបញ្ហាណាមួយតាមផ្លូវច្បាប់ដែរ។ ដូច្នេះហើយ ក្នុងករណីដែលម្ចាស់សិទ្ធិប្រើសិទ្ធិតវ៉ាឲ្យអនុវត្តព្រមគ្នា ចាំបាច់ត្រូវអះអាងអំពីឆន្ទៈថានឹងប្រើសិទ្ធិនោះ។

ដូច្នេះហើយ បើទោះបីជា ការរំលាយ "កិច្ចសន្យាលក់ទិញនៃរឿងក្តីនេះ" ដែលធ្វើឡើងដោយដើមចោទ មានសុពលភាពក៏ដោយ ក៏ចុងចម្លើយបដិសេធអំពីការធ្វើនីតិវិធីចុះបញ្ជីអំពីការលុបការចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិលើ "ដី ៤" ដែរ រហូតទាល់តែដើមចោទសងប្រាក់ ៥០.០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិក ដោយភ្ជាប់ជាមួយនឹងការប្រាក់ ៥ ភាគរយក្នុងមួយឆ្នាំ ដែលគិតចាប់ពីថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១៨ រហូតដល់ថ្ងៃសងរួច។

**ឃ. ភស្តុតាង**

១. រូបថត (សារនៅក្នុង Telegram ដែលត្រូវបានផ្ញើទៅមករវាងដើមចោទ និងចុងចម្លើយនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨) **(ភស្តុតាង$Y_1$)**

២. កំណត់ត្រាដែលចុងចម្លើយបានសរសេរអំពីខ្លឹមសារដែលបាននិយាយគ្នាតាមទូរស័ព្ទជាមួយដើមចោទ នៅថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០១៨ **(ភស្តុតាង$Y_2$)**

៣. លិខិតទទួលប្រាក់ **(ភស្តុតាង$Y_3$)**

៤. ការសាកសួរសាមីចុងចម្លើយ

សូម **លោកចៅក្រម** សម្រេចតាមការស្នើសុំ ដោយក្តីអនុគ្រោះ។

រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែមេសា ឆ្នាំ ២០១៩

**អ្នកតំណាងដោយអាណត្តិ**

B

<u>ឯកសារភ្ជាប់</u>

១-លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ "ច្បាប់ដើម"

២-ច្បាប់ថតចម្លងនៃភស្តុតាងនីមួយៗខាងលើ "ចំនួន ០២ ច្បាប់"

៣-ឯកសារចម្លងនៃឯកសារចម្លើយ "ចំនួន ០២ ច្បាប់"

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# ឯកសារត្រៀមលើកទី១របស់ដើមចោទ

## ដើមចោទ

ឈ្មោះ ៖ X

អាសយដ្ឋាន ៖ ផ្ទះលេខ ០០ ផ្លូវលេខ ០០ ភូមិ...... ឃុំ.......ស្រុក......... ខេត្តរតនគិរី។

## អ្នកតំណាងដោយអាណត្តិ

លោក/លោកស្រី ៖ P

អាសយដ្ឋានការិយាល័យមេធាវី/ ក្រុមមេធាវី/ ក្រុមហ៊ុនមេធាវី ៖ ................................

ការិយាល័យមេធាវី/ ក្រុមមេធាវី/ ក្រុមហ៊ុនមេធាវី ៖ .................................................

លេខទូរស័ព្ទ ៖ .................................................

**ទីកន្លែងបញ្ជូន** ៖ ការិយាល័យមេធាវី/ ក្រុមមេធាវី/ ក្រុមហ៊ុនមេធាវី.................

## ចុងចម្លើយ

ឈ្មោះ ៖ Y

អាសយដ្ឋាន ៖ ផ្ទះលេខ ០០ ផ្លូវលេខ ០០ សង្កាត់មនោរម្យ ខណ្ឌ៧មករា រាជធានីភ្នំពេញ។

**សូមគោរពជូន**
**លោក J ចៅក្រមនៃសាលាដំបូងខេត្តរតនគិរី**

**<u>កម្មវត្ថុ</u> ៖** សំណើសុំដាក់**ឯកសារត្រៀមលើកទី១របស់ដើមចោទ**ដើម្បីឆ្លើយតបចំពោះ
ឯកសារចម្លើយរបស់ឈ្មោះ Y ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៩

**<u>យោង</u> ៖** -មាត្រា **១០១ កថាខណ្ឌទី ២** នៃក្រមនីតិវិធីរដ្ឋប្បវេណី
-សំណុំរឿងរដ្ឋប្បវេណីលេខ **........**ចុះថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១៩

## គ. ការទទួលស្គាល់ ឬ មិនទទួលស្គាល់ចំពោះអង្គហេតុដែលមានសរសេរនៅក្នុងឯកសារចម្លើយ

**គ.១.** អង្គហេតុដែលត្រូវបានសរសេរនៅក្នុងចំណុច "**គ.១.១.**" នៃឯកសារចម្លើយ ៖ ដើមចោទមិនទទួលស្គាល់។

នៅថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៨ ដើមចោទបានទទួលឆ្លើយតបសារពីចុងចម្លើយថា "សូមឲ្យរង់ចាំ ៣ ខែតទៀត"។ ដើមចោទបានទូរស័ព្ទទៅចុងចម្លើយដើម្បីសួរឲ្យបានលម្អិតអំពីមូលហេតុដែលចុងចម្លើយមិនអាចបង់ប្រាក់បានទាន់តាមកាលបរិច្ឆេទ។ ចុងចម្លើយបានពន្យល់ថា គាត់ត្រូវបានមនុស្សអាក្រក់បោកយកលុយជាដើម។ ដើមចោទមានអារម្មណ៍ទៅលើការគិតថា តើចុងចម្លើយពិតជាអាចបង់ប្រាក់ដែលនៅខ្វះចំនួន ៥0.000 (ប្រាំម៉ឺន) ដុល្លារអាមេរិកបានដែរ ឬ យ៉ាងណា? ច្រើនជាងការគិតថា តើសម្ដីរបស់ចុងចម្លើយនិយាយនោះពិតដែរ ឬយ៉ាងណា? ពីព្រោះ គេបានព្យាករថា តម្លៃរបស់ "ដី៤" នឹងនៅតែបន្តកើនឡើង ហើយក៏អាចរកអ្នកទិញបានភ្លាមៗដែរ ដូច្នេះហើយ បើសិនជាចុងចម្លើយមិនអាចរកលុយដែលនៅខ្វះមកបង់ឲ្យបានពិតប្រាកដទេ ដើមចោទនឹង "រំលាយកិច្ចសន្យាលក់ទិញនៃរឿងក្ដីនេះ" ហើយចង់លក់ទៅឲ្យអ្នកផ្សេង។ ម្យ៉ាងទៀត តាមរយៈការឆ្លើយឆ្លងនៅក្នុងទូរស័ព្ទជាមួយចុងចម្លើយ ដើមចោទមិនបានទទួលស្គាល់ថា មានស្ថានភាពដែលចុងម្លើយពិតជាអាចរៀបចំប្រាក់ចំនួន ៥0.000 (ប្រាំម៉ឺន) ដុល្លារអាមេរិកបានទេ ហេតុនេះហើយ ដើមចោទមិនបានតបតចំពោះការទាមទាររបស់ចុងចម្លើយទេហើយបានដាក់ទូរស័ព្ទចុះ (**ភស្តុតាង**$X_5$)។

ដូច្នេះហើយ ការព្រមព្រៀងផ្លាស់ប្ដូរកាលបរិច្ឆេទទៅជាថ្ងៃទី ៣១ ខែមីនា ឆ្នាំ ២០១៩ គឺពុំបានបង្កើតឡើងទេ។

**គ.២.** នៅក្នុងចំណោមអង្គហេតុដែលត្រូវបានសរសេរនៅក្នុងចំណុច "**គ.១.២.**" នៃឯកសារចម្លើយ ៖ ដើមចោទទទួលស្គាល់ទៅលើអង្គហេតុដែលលើកឡើងថា នៅពេលដែលដើមចោទបានទំនាក់ទំនងអំពីការប្រគល់ "ដី ៤" ចុងចម្លើយបានផ្ញើសារមកថា "សូមឲ្យរង់ចាំ ៣ ខែ តទៀត។" និង អង្គហេតុដែលលើកឡើងថា ក្រោយមក ដើមចោទបានទូរស័ព្ទទៅចុងចម្លើយភ្លាមៗ ។

អង្គហេតុដែលចុងចម្លើយត្រូវបានគេបោកយកលុយ ៖ ដើមចោទមិនដឹង។

អង្គហេតុលើកឡើងថា ដើមចោទបានធ្វើស្ទីការចំពោះសំណើរបស់ចុងចម្លើយអំពីការផ្លាស់ប្តូរកាលបរិច្ឆេទអនុវត្តកិច្ចសន្យា និង អង្គហេតុដែលលើកឡើងថា ដើមចោទបាននិយាយទៅកាន់ចុងចម្លើយថា "ខ្ញុំដឹងហើយ" ៖ ដើមចោទមិនទទួលស្គាល់។

ដូចដែលបានលើកឡើងនៅក្នុងចំណុច "**ក.១.**" ដើមចោទមិនអាចគិតថាចុងចម្លើយអាចបង់ប្រាក់ដែលនៅខ្វះឲ្យបានពិតប្រាកដទេ ដូច្នេះហើយ ទើបមិនបានឆ្លើយតបទៅនឹងសំណើអំពីការផ្លាស់ប្តូរកាលបរិច្ឆេទអនុវត្តកិច្ចសន្យាទេ។ បើទោះបីជា ដើមចោទ បាននិយាយទៅចុងចម្លើយថា "ឆ្នាំក្រោយនឹងមានភាពប្រសើរឡើងវិញហើយ" ក៏ដោយ ក៏ការនិយាយនោះមិនលើសពីគោលបំណងក្នុងការលើកទឹកចិត្តចុងចម្លើយឡើយ ដោយសារតែ ខ្ញុំមានអារម្មណ៍សោកស្តាយចំពោះចុងម្លើយនិយាយពិតប៉ុន្តែត្រូវបានគេឆបោកហើយស្របពេលនោះ ក៏ដល់ពេលចុងឆ្នាំល្មម ដូច្នេះ ការនិយាយបែបនោះមិនមែនជាការឆ្លើយតបចំពោះការផ្លាស់ប្តូរកាលបរិច្ឆេទអនុវត្តកិច្ចសន្យាទេ។

**ក.៣.** អង្គហេតុដែលត្រូវបានសរសេរនៅក្នុងចំណុច "**គ.១.៣.**" នៃឯកសារចម្លើយ ៖ ដើមចោទមិនទទួលស្គាល់។

**ក.៤.** អង្គហេតុដែលត្រូវបានសរសេរនៅក្នុងចំណុច "**គ.២.១.**" នៃឯកសារចម្លើយ ៖ ដើមចោទ ទទួលស្គាល់។[1]

## ខ. ភស្តុតាង

១. កំណត់ត្រាដែលដើមចោទបានសរសេរអំពីខ្លឹមសារដែលបាននិយាយគ្នាតាមទូរស័ព្ទជាមួយចុងចម្លើយ នៅថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០១៨ (**ភស្តុតាង$X_5$**)

២. ការសាកសួរសាមីដើមចោទ

[1] ចំណុច "គ.២.២." នៃឯកសារចម្លើយ មិនលើសពីការអះអាងអំពីសិទ្ធិរបស់ចុងចម្លើយ (ការអះអាងអំពីការអនុវត្តនូវសិទ្ធិតវ៉ាឲ្យអនុវត្តព្រមគ្នា) ឡើយ ហើយមិនមែនជាការសរសេរនូវអង្គហេតុទេ។ ដូច្នេះហើយ មិនចាំបាច់ធ្វើការទទួលស្គាល់ ឬ មិនទទួលស្គាល់ទៅលើចំណុច "គ.២.២." នៃឯកសារចម្លើយទេ។

សូម **លោកចៅក្រម**សម្រេចតាមការស្នើសុំ ដោយក្ដីអនុគ្រោះ។

ខេត្តរតនគិរី, ថ្ងៃទី ១ ខែ ឧសភា ឆ្នាំ ២០១៩

**អ្នកតំណាងដោយអាណត្តិ**

P

<u>ឯកសារភ្ជាប់</u>

២-ច្បាប់ថតចម្លងនៃភស្តុតាងនីមួយៗខាងលើ "ចំនួន ០២ ច្បាប់"

**សាលាដំបូងខេត្តរតនគិរី**

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**តុលាការរដ្ឋប្បវេណី**

សំណុំរឿងលេខ .......

ចុះថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១៩

សាលក្រមលេខ .........

ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ២០១៩

## សាលក្រម[1]

## ក្នុងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្តរតនគិរី [2]

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៅ

ថ្ងៃទី ៣១ ខែឧសភា ឆ្នាំ២០១៩ [3] [4]

**ចៅក្រមជំនុំជម្រះ**

លោក J ជាចៅក្រមនៃសាលាដំបូងខេត្តរតនគិរី

**ក្រឡាបញ្ជី**

លោកស្រី C ជាក្រឡាបញ្ជីនៃសាលាខេត្តរតនគិរី

---

[1] ការសម្រេចសេចក្តី គឺចែកចេញជា សាលក្រម និង ដីកាសម្រេច (មាត្រា ១៧៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ដូច្នេះ មានភាពចាំបាច់នៅក្នុងការបញ្ជាក់ឲ្យបានច្បាស់លាស់ថា អំពីប្រភេទនៃការសម្រេចសេចក្តីដាក់នៅត្រង់ចំណុចចាប់ផ្តើម។ ដោយសារតែ សាលក្រម និង ដីកាសម្រេចមានភាពខុសគ្នាចំពោះវិធីក្នុងការធ្វើឧបាស្រ័យជាអាទិ៍ ។ ជាគោលការណ៍បណ្តឹងឧបាស្រ័យចំពោះសាលក្រម គឺ បណ្តឹងឧទ្ធរណ៍ ហើយ បណ្តឹងឧបាស្រ័យចំពោះដីកាសម្រេច គឺ បណ្តឹងជំទាស់ (កថាខណ្ឌទី ១ មាត្រា ២៥៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

[2] សាលក្រមរដ្ឋប្បវេណីត្រូវតែសរសេរអំពីចំណុចដែលចែងនៅក្នុងមាត្រា ១៨៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

[3] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ១៨៩ កថាខណ្ឌទី ១ ចំណុច ខ ។ សាលក្រមនឹងត្រូវកំណត់ជាស្ថាពរនូវទំនាក់ទំនងសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តិនាពេលបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ១៩៤ កថាខណ្ឌទី ២) ហេតុនេះ ចាំបាច់ត្រូវសរសេរឲ្យបានច្បាស់លាស់អំពី ពេលដែលបានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់។ សាលក្រមគឺជាការសម្រេចសេចក្តីរបស់តុលាការដែលត្រូវបានធ្វើឡើងដោយកំណត់ជាមុននូវទំនាក់ទំនងអង្គហេតុគិតមកដល់ត្រឹមថ្ងៃបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់។

[4] ការប្រកាសសាលក្រមត្រូវធ្វើឡើងក្នុងអំឡុងពេល ១ (មួយ) ខែ គិតចាប់ពីថ្ងៃដែលបានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ (មាត្រា ១៨៧ នៃក្រមរដ្ឋប្បវេណី)។ ហើយការប្រកាសសាលក្រមចាំបាច់ត្រូវធ្វើឡើងដោយផ្អែកលើច្បាប់ដើមនៃមូលសាលក្រម (កថាខណ្ឌទី ១ មាត្រា ១៨៨ នៃក្រមរដ្ឋប្បវេណី) ដូច្នេះហើយ ចាំបាច់ត្រូវតែបញ្ចប់នូវការតាក់តែងច្បាប់ដើមនៃមូលសាលក្រមឲ្យបាន គិតត្រឹមពេលប្រកាសសាលក្រម។

**ដើមចោទ**

ឈ្មោះ ៖ X

អាសយដ្ឋាន ៖ ផ្ទះលេខ ០០ ផ្លូវលេខ ០០ ភូមិ...... ឃុំ.......ស្រុក......... ខេត្តរតនគិរី។

**អ្នកតំណាងដោយអាណត្តិ**

លោក/លោកស្រី ៖ P

អាសយដ្ឋានការិយាល័យមេធាវី/ ក្រុមមេធាវី/ ក្រុមហ៊ុនមេធាវី ៖ ................................

ការិយាល័យមេធាវី/ ក្រុមមេធាវី/ ក្រុមហ៊ុនមេធាវី ៖ ................................................

លេខទូរស័ព្ទ ៖ ..................................................

**ចុងចម្លើយ**

ឈ្មោះ ៖ Y

អាសយដ្ឋាន ៖ ផ្ទះលេខ ០០ ផ្លូវលេខ ០០ សង្កាត់មនោរម្យ ខណ្ឌ៧មករា រាជធានីភ្នំពេញ។

**អ្នកតំណាងដោយអាណត្តិ**

លោក/លោកស្រី ៖ B

អាសយដ្ឋានការិយាល័យមេធាវី/ ក្រុមមេធាវី/ ក្រុមហ៊ុនមេធាវី ៖ ................................

ការិយាល័យមេធាវី/ ក្រុមមេធាវី/ ក្រុមហ៊ុនមេធាវី ៖ ................................................

លេខទូរស័ព្ទ ៖ ..................................................

**អង្គហេតុ និង ចំណុចវិវាទ**

**ក. ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ**

(១) បង្គាប់ឲ្យចុងចម្លើយធ្វើនីតិវិធីចុះបញ្ជីអចលនវត្ថុដែលបានកត់ត្រាក្នុងបញ្ជីឧបសម្ព័ន្ធឲ្យទៅដើមចោទ។

(២) ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ចុងចម្លើយ។

## ខ. ដំណើររឿងក្ដី និង ចំណុចវិវាទ

### ខ.១. ការសង្ខេបអំពីរឿងក្ដី

នៅក្នុងរឿងក្ដីនេះ ចំពោះអចលនវត្ថុដែលបានកត់ត្រានៅក្នុងបញ្ជីឧបសម្ព័ន្ធ (តទៅហៅថា "ដីL" ) ដើមចោទបានទាមទារនូវការធ្វើនីតិវិធីចុះបញ្ជីអំពីការលុបការចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិលើអចលនវត្ថុដដែល ដោយផ្អែកលើការរំលាយកិច្ចសន្យាលក់ទិញចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៩ ។

### ខ.២. អង្គហេតុដែលគ្មានវិវាទ[5]

**ខ.២.១.** នៅថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១៨ ដើមចោទបានទិញ "ដី L" ក្នុងតម្លៃ ១០០.០០០ (មួយសែន) ដុល្លារអាមេរិកពីចុងចម្លើយ (តទៅហៅថា "កិច្ចសន្យាលក់ទិញនៃរឿងក្ដីនេះ" )។

**ខ.២.២.** ដើមចោទ និង ចុងចម្លើយបាន "កិច្ចសន្យាលក់ទិញនៃរឿងក្ដីនេះ" ជាលិខិតយថាភូត (លិខិតលក់ផ្ដាច់)។[6]

**ខ.២.៣.** ចំពោះ "កិច្ចសន្យាលក់ទិញនៃរឿងក្ដីនេះ" ដើមចោទ និង ចុងចម្លើយបានព្រមព្រៀងគ្នាដូចខាងក្រោមអំពីកាលបរិច្ឆេទបង់ប្រាក់ថ្លៃលក់៖

**ក.** ចំពោះប្រាក់ចំនួន ៥០.០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិកនៃថ្លៃលក់ នឹងបង់នៅពេលដែលបានដាក់ពាក្យសុំចុះបញ្ជីផ្ទេរកម្មសិទ្ធិទាំងមូល។

**ខ.** ចំពោះប្រាក់ចំនួន ៥០.០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិកដែលខ្វះ នឹងត្រូវបង់នៅក្នុងអំឡុងពេល ១ខែ គិតចាប់ពីពេលដែលបានដាក់ពាក្យសុំចុះបញ្ជីផ្ទេរកម្មសិទ្ធិទាំងមូល។

**ខ.២.៤.** ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១៨ ចុងចម្លើយបានបង់ប្រាក់[7]ថ្លៃលក់ទិញចំនួន ៥០.០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិកនៃ "កិច្ចសន្យាលក់ទិញនៃ

[5] មាត្រា ១២៣ កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ ចំណុចនេះនឹងត្រូវសរសេរអំពីអង្គហេតុដែលភាគីបានសារភាពនៅចំពោះមុខតុលាការ និង អង្គហេតុដែលតុលាការយល់ឃើញថា អត្ថិភាពនៃអង្គហេតុនោះមានភាពជាក់ស្ដែង។

[6] ក្រមរដ្ឋប្បវេណី មាត្រា ៣៣៦ កថាខណ្ឌទី ២។ អង្គហេតុដែលមានភាពចាំបាច់ដើម្បីបញ្ជាក់ឲ្យបានច្បាស់លាស់នូវ "កិច្ចសន្យានៃរឿងក្ដីនេះ" ដែលបានបង្កើតឡើងដោយមានសុពលភាព។ (ការពន្យល់លម្អិត សូមយោងតាម Footnote នៃពាក្យបណ្ដឹង។)

[7] ចំណុចនេះគឺជាអង្គហេតុដែលមានភាពចាំបាច់ដើម្បីធ្វើជាមូលហេតុ អំពីការតវ៉ាឲ្យអនុវត្តព្រមគ្នាដែលចុងចម្លើយអះអាង។(ការពន្យល់លម្អិត សូមយោងតាម Footnote នៃឯកសារចម្លើយ។)

រឿងក្តីនេះឲ្យទៅដើមចោទ ហើយ ដើមចោទ និង ចុងចម្លើយបានដាក់ពាក្យសុំចុះបញ្ជីផ្ទេរកម្មសិទ្ធិទាំងមូលដោយផ្អែកលើ "កិច្ចសន្យាលក់ទិញនៃរឿងក្តីនេះ" ។

**ខ.២.៥.** នៅថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៨ បានកន្លងផុត។

**ខ.២.៦.** នៅថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១៩ ដើមចោទបានដាស់តឿនឲ្យចុងចម្លើយបង់ប្រាក់ថ្លៃលក់ទិញចំនួន ៥០.០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិកដែលនៅខ្វះឲ្យបានក្នុងអំឡុងពេល ២ សប្តាហ៍ ហើយព្រមគ្នានោះ ក៏បានធ្វើការបង្ហាញឆន្ទៈ[8] អំពីការរំលាយ "កិច្ចសន្យានៃរឿងក្តីនេះ" នៅពេលដែលមិនមានការបង់ប្រាក់ថ្លៃលក់ទិញនៅក្នុងអំឡុងពេល ២សប្តាហ៍។

**ខ.២.៧.** ចុងចម្លើយមិនបង់ប្រាក់ថ្លៃលក់ទិញដែលនៅខ្វះចំនួន ៥០.០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិកឲ្យបានត្រឹមថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៩ ទេ។[9]

**ខ.២.៨.** នៅថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៨ ដើមចោទបានផ្តល់នូវការប្រគល់ដី L ទៅឲ្យចុងចម្លើយ ដោយផ្អែកតាម "កិច្ចសន្យាលក់ទិញនៃរឿងក្តីនេះ" ។[10]

**ខ.២.៩.** នៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនៃរឿងក្តីនេះនាថ្ងៃទី ៥ ខែ មេសា ឆ្នាំ ២០១៩ ចុងចម្លើយបានប្រើសិទ្ធិតវ៉ាឲ្យអនុវត្តព្រមគ្នា ក្នុងករណីដែលតុលាការវិនិច្ឆ័យថា "ការរំលាយកិច្ចសន្យាលក់ទិញនៃរឿងក្តីនេះ" មានសុពលភាព ចុងចម្លើយនឹងបដិសេធនូវការធ្វើនីតិវិធីចុះបញ្ជីអំពីការលុបការចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិលើ "ដី L" លុះត្រាតែបានទទួលនូវការសងប្រាក់ចំនួន ៥០.០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិក និងការប្រាក់ចំនួន ៥ % ក្នុង ១ឆ្នាំនៃប្រាក់នេះ គិតចាប់ពីថ្ងៃទី ៣០ ខែ វិច្ឆិកា

---

[8] ការបង្ហាញឆន្ទៈអំពីការរំលាយកិច្ចសន្យាដោយដាក់ល័ក្ខខ័ណ្ឌបង្អង់ (កថាខណ្ឌទី៣ មាត្រា ៤០៩ និង កថាខណ្ឌទី ១ វាក្យខណ្ឌទី ២ មាត្រា ៣២៥ នៃក្រមរដ្ឋប្បវេណី) ។ (ការពន្យល់លម្អិត សូមយោងតាម Footnote នៃពាក្យបណ្តឹង។)

[9] ចំណុចនេះគឺជាអង្គហេតុដែលចាំបាច់ដើម្បីបង្ហាញថា លក្ខខណ្ឌបង្អង់ត្រូវបានបំពេញ។ (ការពន្យល់លម្អិត សូមយោងតាម Footnote នៃពាក្យបណ្តឹង។)

[10] ចំណុចនេះគឺជាអង្គហេតុដែលចាំបាច់ដើម្បីធ្វើជាមូលហេតុអំពី "ការបំពានកិច្ចសន្យា" របស់ចុងចម្លើយ (មាត្រា ៤០៧ នៃក្រមរដ្ឋប្បវេណី)។ (ការពន្យល់លម្អិត សូមយោងតាម Footnote នៃពាក្យបណ្តឹង។)

ឆ្នាំ២០១៨ រហូតដល់ថ្ងៃសងរួច ។[11]

## ខ.៣. ចំណុចវិវាទ

**នៅថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៨ តើដើមចោទ និង ចុងចម្លើយបានធ្វើការព្រមព្រៀងអំពីការផ្លាស់ប្តូរកាលបរិច្ឆេទបង់ប្រាក់ថ្លៃលក់ទិញចំនួន ៥០.០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិកដែលនៅខ្វះមកជាថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៩វិញដែរ ឬ ទេ? (តទៅ ការព្រមព្រៀងនេះ ហៅថា "ការព្រមព្រៀងអំពីការផ្លាស់ប្តូរនៃរឿងក្តីនេះ")។**

## ខ.៤. ការអះអាងរបស់ភាគីចំពោះចំណុចវិវាទ

### ខ.៤.១. ការអះអាងរបស់ចុងចម្លើយ

នៅថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៨ ដើមចោទបានបង្កើត "ការព្រមព្រៀងអំពីការផ្លាស់ប្តូរនៃរឿងក្តីនេះ" ជាមួយចុងចម្លើយ។

ពោល នៅថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៨ នៅពេលដែលមានការទាក់ទងពីដើមចោទ អំពីការប្រគល់ "ដីL" ចុងម្លើយបានផ្ញើសារថា "សុំឲ្យរង់ចាំ ៣ខែតទៀត" ចំពោះការបង់ប្រាក់ថ្លៃលក់ទិញដែលនៅខ្វះ។ ចំពោះសារនេះ ដើមចោទបានទូរស័ព្ទទៅចុងចម្លើយ ភ្លាមៗ ដោយបានបញ្ជាក់អំពីមូលហេតុនោះ ហើយបានឆ្លើយតបថា " ខ្ញុំយល់ហើយ។ ឆ្នាំក្រោយនឹងមានភាពប្រសើរឡើងវិញ" ។ តាមរយៈការឆ្លើយតបនេះ នាំឲ្យ "ការព្រមព្រៀងអំពីការផ្លាស់ប្តូរនៃរឿងក្តីនេះ" បានបង្កើតឡើង។

### ខ.៤.២. ការអះអាងរបស់ដើមចោទ

"ការព្រមព្រៀងអំពីការផ្លាស់ប្តូរនៃរឿងក្តីនេះ" ពុំបានបង្កើតឡើងទេ។

---

[11] ចំពោះការប្រើសិទ្ធិតវ៉ាឲ្យអនុវត្តព្រមគ្នា ឬ យ៉ាងណានោះ គឺអាស្រ័យទៅលើឆន្ទៈរបស់ម្ចាស់សិទ្ធិដែលមានសិទ្ធិតវ៉ាឲ្យអនុវត្តព្រមគ្នា (មាត្រា ៩០៧ នៃក្រមរដ្ឋប្បវេណី) ។ (ការពន្យល់លម្អិត សូមយោងតាម Footnote នៃឯកសារចម្លើយ។)

ចុងចម្លើយបង្ហាញឆន្ទៈយ៉ាងច្បាស់អំពីការអនុវត្តសិទ្ធិតវ៉ាឲ្យអនុវត្តព្រមគ្នានៅក្នុងឯកសារចម្លើយចុះថ្ងៃទី ១ ខែមេសា ឆ្នាំ ២០១៩ (ចំណុច "គ.២.២." នៃឯកសារចម្លើយ) ប៉ុន្តែការបង្ហាញឆន្ទៈរបស់ចុងចម្លើយនេះមានភាពច្បាស់លាស់ចំពោះតុលាការ គឺនៅពេលដែលខ្លឹមសារដែលបានសរសេរនៅក្នុងឯកសារចម្លើយនេះត្រូវបានអះអាងនៅក្នុងកាលវិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់។ ដូច្នេះហើយ ចាំបាច់ត្រូវតែសរសេរអំពីពេលវេលាឲ្យច្បាស់លាស់ចំពោះតុលាការអំពី ការបង្ហាញឆន្ទៈរបស់ចុងចម្លើយក្នុងការប្រើសិទ្ធិតវ៉ាឲ្យអនុវត្តព្រមគ្នា (នៅក្នុងរឿងក្តីនេះ កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលត្រូវបានធ្វើឡើងនៅថ្ងៃទី ៥ ខែមេសា ឆ្នាំ ២០១៩) ។

ដើមចោទបានទូរស័ព្ទទៅចុងចម្លើយវិញភ្លាមៗ ក្រោយពីបានទទួលសារពីចុងចម្លើយថា "សូមឲ្យរង់ចាំ ៣ ខែតទៀត" ចំពោះការបង់ប្រាក់ថ្លៃលក់ទិញដែលនៅខ្វះ ប៉ុន្តែ ការទូរស័ព្ទនោះ គឺគ្រាន់តែបញ្ជាក់ពីមូលហេតុដែលចុងចម្លើយមិនអាចបង់ប្រាក់ថ្លៃលក់ទិញឲ្យបានត្រឹមកាលបរិច្ឆេទតែប៉ុណ្ណោះ។ ដើមចោទមិនទាន់បានធ្វើស្ទីការទទួលសំណើពីចុងម្លើយទេ។

## សំអាងហេតុ

### ក. ការវិនិច្ឆ័យចំពោះចំណុចវិវាទ

#### ក.១. ការទទួលស្គាល់អង្គហេតុ

អង្គហេតុដែលគូភាគីគ្មានវិវាទ និង អង្គហេតុដែលត្រូវបានទទួលស្គាល់តាមរយៈភស្តុតាងដែលបានកត់ត្រានៅតាមចំណុចចុងក្រោយនីមួយៗ មានដូចខាងក្រោម៖

**ក.១.១.** នៅថ្ងទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៨ ដើមចោទបានជូនដំណឹងអំពីការបានប្រែក្លាយសភាព "ដី L" សម្រាប់ធ្វើការប្រគល់ និងដាស់តឿនអំពីការទទួលយកការប្រគល់នោះ ជាមួយគ្នានេះ ក៏បានផ្ញើសារបញ្ជាក់អំពីការបង់ប្រាក់ថ្លៃលក់ទិញដែលនៅខ្វះនៃ "កិច្ចសន្យាលក់ទិញនៃរឿងក្តីនេះ" ទៅចុងចម្លើយ ។ (**ភស្តុតាង$X_4$ និង $Y_1$**)

**ក.១.២.** នៅថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៨ ចំពោះសារដែលបានសរសេរនៅក្នុងចំណុច "**ក.១.១.**" ខាងលើនេះ ចុងម្លើយបានផ្ញើសារថា " សុំឲ្យរង់ចាំ ៣ ខែតទៀត" ទៅកាន់ដើមចោទ ។ (**គ្មានវិវាទ**)

**ក.១.៣.** ដើមចោទបានទូរស័ព្ទទៅចុងចម្លើយវិញភ្លាម នៅក្រោយពេលដែលទទួលបានសារដូចបានសរសេរនៅក្នុងចំណុច "**ក.១.២.**" ។ នៅក្នុងការសន្ទនាតាមទូរស័ព្ទនោះ ចុងចម្លើយបានពន្យល់ទៅដើមចោទថា ចុងម្លើយត្រូវបានគេបោកយកប្រាក់ ហើយមិនអាចបង់ប្រាក់ថ្លៃលក់ទិញចំនួន ៥០.០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិកដែលនៅខ្វះឲ្យបានភ្លាមៗទេ ។ (**គ្មានវិវាទ**)

**ក.១.៤.** ក្រោយពីការទូរស័ព្ទនៅក្នុងចំណុចដែលសរសេរនៅ "**ក.១.៣.**" រហូតដល់ថ្ងៃទី១១ ខែមករា ឆ្នាំ ២០១៩ ដែលដើមចោទធ្វើការបង្ហាញឆន្ទៈទៅចុងចម្លើយ ដូចនៅក្នុងចំណុចស្តីពី "អង្គហេតុនិង ចំណុចវិវាទ" ដែលបានសរសេរខាងលើ ត្រង់ចំណុច "**ខ.២.៦.**" ដើមចោទ និង ចុងចម្លើយពុំបានទាក់ទងគ្នាទេ ។ **(ភស្តុតាង $X_3$ ភស្តុតាង $X_4$ លទ្ធផលនៃការសាកសួរសាមីដើមចោទ និង ចុងចម្លើយនីមួយៗ ទំនាក់ទំនង និង ខ្លឹមសារនៃការទាញហេតុផលដោយផ្ទាល់មាត់[12])**

## ក.២. សេចក្តីសន្និដ្ឋានចំពោះចំណុចវិវាទ

ប្រសិនបើប្រៀបផ្ទឹមអង្គហេតុដែលបានទទួលស្គាល់នៅក្នុងចំណុច "**ក.១.**" ខាងលើ និង "អង្គហេតុដែលគ្មានវិវាទ ចំណុច **ខ.២.**" នៃចំណុចស្តីពី "អង្គហេតុ និង ចំណុចវិវាទ" ខាងលើ តុលាការទទួលស្គាល់ថា អង្គហេតុដែលដើមចោទបានទូរស័ព្ទទៅចុងចម្លើយ និង បានសន្ទនាគ្នាជាមួយចុងចម្លើយ នៅក្រោយពេលដែលបានទទួលសំណើពីចុងចម្លើយអំពី "ការព្រមព្រៀងផ្លាស់ប្តូរនៃរឿងក្តីនេះ" ភ្លាមៗ។

ប៉ុន្តែ នៅក្នុងការសន្ទនាគ្នាខាងលើនេះ ពុំមានភស្តុតាងដែលជាក់លាក់គ្រប់គ្រាន់ដើម្បីទទួលស្គាល់ថា ដើមចោទបានធ្វើស្វីការទៅចុងចម្លើយចំពោះសំណើអំពី "ការព្រមព្រៀងផ្លាស់ប្តូរនៃរឿងក្តីនេះ" ទេ ។ ពោលគឺ ចុងចម្លើយអះអាងថា ដើមចោទបានឆ្លើយតបនៅក្នុងការសន្ទនាគ្នាខាងលើនេះថា " ខ្ញុំយល់ហើយ។ ឆ្នាំក្រោយនឹងមានភាពប្រសើរឡើង" ហើយបានថ្លែងការដូចគ្នាទៅបែបនេះដែរ[13] ប៉ុន្តែ បើទោះបីជា ដើមចោទបាននិយាយបែបនោះក៏ដោយ ក៏ឃ្លាភ្ជាប់ដែលនៅខាងមុខការនិយាយបែបនោះ មិនមានភាពច្បាស់លាស់ឡើយ ក្រៅពីនេះទៀត ដោយសារ

---

[12] មាត្រា ១៨៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ ក្នុងការចេញសាលក្រម តុលាការត្រូវវិនិច្ឆ័យទទួលស្គាល់ដោយគិតពិចារណាអំពី "ដំណើរការ និង ខ្លឹមសារនៃការទាញហេតុផលដោយផ្ទាល់មាត់" ផងដែរ មិនមែនពិចារណាតែទៅលើលទ្ធផលនៃការស្រាវជ្រាវភស្តុតាងនោះទេ។

[13] "ការអះអាង" និង "ការថ្លែងការ" ផ្អែកតាមន័យច្បាប់ គឺមានភាពខុសគ្នា។ "ការអះអាង" គឺជាពាក្យដែលត្រូវបានបញ្ញត្តនៅក្នុងមាត្រា ៩៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី រីឯ "ការថ្លែងការ" គឺជាលទ្ធផលនៃការសាកសួរសាមីភាគី ហើយគឺជាវិធីមួយនៃការបញ្ជាក់ ។ យ៉ាងណាមិញ នៅពេលដែលជាសាក្សី ហើយមិនមែនភាគី គេហៅថា "កស្សិណសាក្សី"។

ភាគីចាំបាច់ត្រូវ "អះអាង" អំពីអង្គហេតុណាមួយ ហើយ "បញ្ជាក់" អង្គហេតុនោះ។ ហេតុនេះហើយ នៅក្នុងរឿងក្តីនេះ បានសរសេរថា ចុងចម្លើយបាន "អះអាង" ហើយ បាន "ថ្លែងការ" ដែលជាវិធីមួយនៃការបញ្ជាក់។

តែពុំមានភស្តុតាងគ្រប់គ្រាន់ដើម្បីទទួលស្គាល់ថា ការនិយាយរបស់ដើមចោទនេះគឺជាស្ទីការចំពោះសំណើនៃ "ការព្រមព្រៀងអំពីការផ្លាស់ប្តូរនៃរឿងក្តីនេះ" ឡើយ។

ហេតុនេះ ដោយសារតែ អង្គហេតុដែលលើកឡើងថាដើមចោទបានធ្វើស្ទីការចំពោះសំណើនៃ "ការព្រមព្រៀងអំពីការផ្លាស់ប្តូរនៃរឿងក្តីនេះ" មិនត្រូវបានទទួលស្គាល់ទេ ដូច្នេះ តុលាការមិនអាចទទួលស្គាល់ថា "ការព្រមព្រៀងអំពីការផ្លាស់ប្តូរនៃរឿងក្តីនេះ" បានបង្កើតឡើងទេ។

## ខ. ការវិនិច្ឆ័យចំពោះការទាមទារ

### ខ.១. ស្តីអំពី ការរំលាយ "កិច្ចសន្យាលក់ទិញនៃរឿងក្តីនេះ" ដោយផ្អែកលើមូលហេតុនៃការមិនអនុវត្តកាតព្វកិច្ចរបស់ចុងចម្លើយ (ការមិនបង់ថ្លៃលក់ទិញ)

ផ្អែកតាមការលើកឡើងខាងលើ ដោយសារតែតុលាការទទួលស្គាល់ថា ចុងចម្លើយមិនបានបង់ប្រាក់ថ្លៃលក់ទិញឲ្យបានត្រឹមថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៨ ដែលជាកាលបរិច្ឆេទបង់ប្រាក់ថ្លៃលក់ទិញចំនួន ៥០.០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិកដែលនៅខ្វះនៃ "កិច្ចសន្យាលក់ទិញនៃរឿងក្តីនេះ" ទេ ហើយទោះបីជាដើមចោទបានដាស់តឿនឲ្យអនុវត្តកាតព្វកិច្ចនោះដោយបានកំណត់អំឡុងពេល ២ សប្តាហ៍គិតចាប់ថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១៩ រហូតដល់ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៩ ក៏ដោយ ក៏ចុងចម្លើយមិនបានអនុវត្តកាតព្វកិច្ចដែរ ដូច្នេះ តុលាការទទួលស្គាល់ថា ចុងចម្លើយបានបំពានកិច្ចសន្យាធ្ងន់ធ្ងរ (ចំណុច ក. កថាខណ្ឌទី ១ មាត្រា ៤០៨ នៃក្រមរដ្ឋប្បវេណី)។

ហើយ នៅថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១៩ ដើមចោទបានបង្ហាញឆន្ទៈ ទៅចុងចម្លើយ ដោយបានដាក់លក្ខខណ្ឌបង្អង់ថា "បើមិនបង់ប្រាក់ថ្លៃលក់ទិញដែលនៅខ្វះឲ្យបានក្នុងអំឡុងពេល ២សប្តាហ៍" នឹងរំលាយ "កិច្ចសន្យាលក់ទិញនៃរឿងក្តីនេះ" ហើយដោយសារតែ ចុងម្លើយមិនបានបង់ប្រាក់ថ្លៃលក់ទិញដែលនៅខ្វះឲ្យបានត្រឹមថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៩ទេ ដូច្នេះហើយតុលាការទទួលស្គាល់ថា ការបង្ហាញឆន្ទៈអំពីការរំលាយកិច្ចសន្យាមានអានុភាព ( កថាខណ្ឌទី ១ និង កថាខណ្ឌទី ៣ មាត្រា ៤០៩ និង កថាខណ្ឌទី ៣ មាត្រា ៣២៥ )

ហេតុដូច្នេះហើយ "កិច្ចសន្យាលក់ទិញនៃរឿងក្តីនេះ" ត្រូវបានរំលាយ។

## ខ.២. ស្តីអំពី ការតវ៉ាឲ្យអនុវត្តព្រមគ្នា

ផ្អែកតាមការរំលាយ "កិច្ចសន្យាលក់ទិញនៃរឿងក្តីនេះ" ចុងចម្លើយមានករណីយកិច្ចធ្វើនីតិវិធីចុះបញ្ជីអំពីការលុបការចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិលើ "ដីL" ឲ្យទៅដើមចោទ (កថាខណ្ឌទី ២ មាត្រា ៤១១ នៃក្រមរដ្ឋប្បវេណី)។

ប៉ុន្តែ ផ្អែកតាមការរំលាយ "កិច្ចសន្យាលក់ទិញនៃរឿងក្តីនេះ" ដើមចោទក៏មានករណីយកិច្ចសងប្រាក់ចំនួន ៥០.០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិកជាថ្លៃលក់ទិញមួយភាគនៃ "កិច្ចសន្យាលក់ទិញនៃរឿងក្តីនេះ" ដែលបានទទួលរួចរាល់ និង ការប្រាក់ចំនួន ៥ % ក្នុង ១ឆ្នាំ នៃប្រាក់នេះ ដោយគិតចាប់ពីថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១៨ (កថាខណ្ឌទី ២ និង កថាខណ្ឌទី ៣ មាត្រា ៤១១ និង មាត្រា ៣១៨ នៃក្រមរដ្ឋប្បវេណី)។

ម្យ៉ាងវិញទៀត តុលាការទទួលស្គាល់ថា ចុងចម្លើយបានអនុវត្តសិទ្ធិតវ៉ាឲ្យអនុវត្តព្រមគ្នា (កថាខណ្ឌទី ២ មាត្រា ៤១១ នៃក្រមរដ្ឋប្បវេណី) នៅក្នុងនីតិវិធីនៃបណ្តឹងនេះ។

ហេតុនេះ ការទាមទាររបស់ដើមចោទទៅចុងចម្លើយ មានមូលហេតុដែលត្រូវកម្រិតឲ្យផ្តល់តាវកាលិកតប។

## គ. ស្តីពីបន្ទុកនៃប្រាក់ប្រដាប់ក្តី

ដោយសារតែការទាមទារនូវតាវកាលិកធម្មតារបស់ដើមចោទមានមូលហាតុដែលត្រូវកម្រិតឲ្យផ្តល់តាវកាលិកតប ដូច្នេះ ដើមចោទក៏សក្តិសមចំពោះការទទួលបន្ទុកលើប្រាក់ប្រដាប់ក្តីផងដែរ។ ហើយដើមចោទដាក់ពាក្យបណ្តឹងនៃរឿងក្តីនេះ ក៏ដោយសារតែចុងចម្លើយមិនបានអនុវត្តកាតព្វកិច្ច ប៉ុន្តែ ប្រសិនបើពិចារណាអំពីតាវកាលិកតបរបស់ដើមចោទវិញ គឺលើសពី ១ ភាគ ២ នៃចំនួនទឹកប្រាក់ថ្លៃលក់ទិញ ដូច្នេះ គប្បីឲ្យដើមចោទទទួលបន្ទុក ១ ភាគ ៣ ហើយចុងចម្លើយទទួលបន្ទុក ២ ភាគ ៣ ចំពោះភាគលើបន្ទុកនៃប្រាក់ប្រដាប់ក្តី ។ (កថាខណ្ឌទី ១ នៃមាត្រា ៦៤ ក្រមនីតិវិធីរដ្ឋប្បវេណី)។

## សេចក្តីសម្រេចបញ្ចប់

១. បង្គាប់ឲ្យចុងចម្លើយធ្វើនីតិវិធីចុះបញ្ជីអចលនវត្ថុដែលបានកត់ត្រាក្នុងបញ្ជីឧបសម្ព័ន្ធឲ្យទៅដើមចោទ ជាថ្នូរនឹងការទទួលនូវការបង់ប្រាក់ពីដើមចោទចំនួន ៥០.០០០

(ប្រាំម៉ឺន) ដុល្លារអាមេរិក និង ប្រាក់ចំនួន ៥ % ក្នុង ១ឆ្នាំនៃទឹកប្រាក់នេះ ដោយគិតចាប់ពីថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១៨ រហូតដល់ថ្ងៃសងរួច។

២. ច្រានចោលការទាមទារផ្សេងពីនោះរបស់ដើមចោទ។[14]

៣. ប្រាក់ប្រដាប់ក្តីចែកជា ៣ភាគ ដោយ ១ភាគ គឺជាបន្ទុករបស់ដើមចោទ ក្រៅពីនេះជាបន្ទុករបស់ចុងចម្លើយ។

សាលក្រមនេះ ត្រូវបានប្រកាសនៅសវនការជាសាធារណៈ នៅថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៩ ។ ក្នុងករណីដែលប្តឹងឧទ្ធរណ៍ ត្រូវតែធ្វើឡើងនៅក្នុងរយៈពេល ០១ (មួយ) ខែ គិតចាប់ពីថ្ងៃបានទទួលការបញ្ជូនលិខិតសាលក្រមនេះ។

ថ្ងៃសុក្រ ទី១១ រោច ខែជេស្ឋ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ខេត្តរតនគិរី, ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ២០១៩

**ចៅក្រម**

[14] តុលាការមិនមែនទទួលស្គាល់នូវការទាមទារដែលដើមចោទបានទាមទារនូវតារាកាលិកធម្មតាទាំងបែបនោះតែម្តងទេ ដូច្នេះ ត្រូវតែបញ្ជាក់អំពីចំណុចការទទួលស្គាល់នោះឲ្យបានច្បាស់លាស់។ (ខ្លឹមសារលំអិត សូមយោងតាម Footnoteនៃឯកសារចម្លើយ)

**ឧបសម្ព័ន្ធ**

**បញ្ជី**[15]

| | |
|---|---|
| "គោលបំណងនៃពាក្យសុំចុះបញ្ជី" | ការលុបការចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិ |
| "មូលហេតុនៃពាក្យសុំចុះបញ្ជី និង កាលបរិច្ឆេទ" | ការរំលាយកិច្ចសន្យាចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៩ |
| "បុគ្គលមានសិទ្ធិចុះបញ្ជី" | ដើមចោទ ( X )<br>ថ្ងៃខែឆ្នាំកំណើត ៖ ថ្ងៃ......ខែ..........ឆ្នាំ.........<br>ទីកន្លែងកំណើត ៖ .....................................<br>ឈ្មោះរបស់ឪពុកម្តាយ៖ ...................(ឪពុក)<br>.....................(ម្តាយ) |
| "បុគ្គលមានកាតព្វកិច្ចចុះបញ្ជី" | ចុងចម្លើយ ( Y )<br>ថ្ងៃខែឆ្នាំកំណើត ៖ ថ្ងៃ......ខែ..........ឆ្នាំ.........<br>ទីកន្លែងកំណើត ៖ .....................................<br>ឈ្មោះរបស់ឪពុកម្តាយ៖ ...................(ឪពុក)<br>.....................(ម្តាយ) |
| "អត្តសញ្ញាណនៃអចលនវត្ថុ" | ទីតាំងដី ៖ ផ្លូវលេខ....... ភូមិ....... ឃុំ........ ស្រុក ....... ខេត្ត រតនគិរី<br>លេខក្បាលដី ៖ ........ |

[15] នៅក្នុងសាលក្រម សាលដីកាដែលជំនួសឲ្យការបង្ហាញឆន្ទៈរបស់បុគ្គលមានកាតព្វកិច្ចចុះបញ្ជី ចាំបាច់ត្រូវតែមានការសរសេរទាំងអស់នូវចំណុចដែលចាំបាច់នៅពេលធ្វើពាក្យសុំចុះបញ្ជី (ឧទាហរណ៍ ៖ ចំពោះពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិ គឺត្រូវសរសេរអំពីចំណុចដែលបានកំណត់នៅក្នុងប្រការ ២៦ និង ប្រការ ៣១ នៃប្រកាសអន្តរក្រសួងស្តីពីនីតិវិធីនៃការចុះបញ្ជីអំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី)។ ហើយត្រូវធ្វើការបញ្ជាក់ថា គ្មានភាពខ្វះចន្លោះឡើយ។

# ការទាមទារលែងលះ

# និងបែងចែកទ្រព្យសម្បត្តិ

# តារាងលំហូរនៃនីតិវិធីលែងលះ

បានចុះបញ្ជីអាពាហ៍ពិពាហ៍ → YES → ភាគីទាំងពីរបានព្រមព្រៀងលែងលះគ្នា → YES → មានកូនដែលជាអនីតិជន → YES → បានកំណត់អំពីអ្នកមានអំណាចមេបា → YES

"ការលែងលះគ្នា និង ការកំណត់អ្នកមានអំណាចមេបា (ដីកាសម្រេច)"

ពាក្យសុំលែងលះដោយការព្រមព្រៀងផ្អែកតាមបញ្ញត្តិនៃមាត្រា ៩៧៩ នៃក្រមរ/ដ (មាត្រា ៣ និង ចំណុច ៥ ផ្នែក ៤ ក្នុងតារាងឧបសម្ព័ន្ធនៃ**ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង**)

NO

"ការលែងលះគ្នា និង ការកំណត់អ្នកមានអំណាចមេបា (សាលក្រម)"

បណ្តឹងទាមទារលែងលះគ្នា តាមបញ្ញត្តិនៃចំណុច ង កថា/ទី ១ មាត្រា ៩៧៨ នៃក្រមរ/ដ (ចំណុច គ មាត្រា ៣ និង កថា/ទី ១ មាត្រា ២២ នៃ**ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល** )

NO

"បើមានតែការលែងលះគ្នា (ដីកាសម្រេច)"

ពាក្យសុំលែងលះដោយការព្រមព្រៀងផ្អែកតាមបញ្ញត្តិនៃមាត្រា ៩៧៩ នៃក្រមរ/ដ ( មាត្រា ៣ និង ចំណុច ៥ ផ្នែក ៤ ក្នុងតារាងឧបសម្ព័ន្ធ នៃ**ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង**)

NO

"ការលែងលះគ្នា និង ការកំណត់អ្នកមានអំណាចមេបា (ករណីដែលមានកូនជាអនីតិជន) (សាលក្រម)"

បណ្តឹងទាមទារលែងលះគ្នា តាមបញ្ញត្តិនៃចំណុចនីមួយៗ កថា/ទី ១ មាត្រា ៩៧៨ នៃក្រមរ/ដ (ចំណុច គ មាត្រា ៣ និង កថា/ទី ១ មាត្រា ២២ នៃ**ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល** )

NO

"មិនចាំបាច់ត្រូវធ្វើនីតិវិធីលែងលះគ្នាទេ! !"

ការលែងលះ គឺជានីតិវិធីរំលាយទំនាក់ទំនងអាពាហ៍ពិពាហ៍ (យោងវាក្យខណ្ឌទី ២ មាត្រា ៩៧៩ នៃក្រមរ/ដ)។
អាពាហ៍ពិពាហ៍ នឹងមានអានុភាព ដោយការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ការជូនដំណឹងជាសាធារណៈ ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ និង ការចុះបញ្ជីនៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន (មាត្រា ៩៥៥ នៃក្រមរ/ដ)។ ពោលគឺ ប្រសិនបើមិនបានបញ្ចប់ឲ្យសព្វគ្រប់នូវការចុះបញ្ជីអាពាហ៍ពិពាហ៍ទេ អានុភាពនៃអាពាហ៍ពិពាហ៍នឹងមិនកើតមានឡើងទេ។
ក្នុងករណីដែលមិនបានចុះបញ្ជីអាពាហ៍ពិពាហ៍ទេ គឺពុំចាំបាច់ត្រូវធ្វើនីតិវិធីលែងលះគ្នាទេ!
ប៉ុន្តែ បុគ្គលដែលបានបដិសេធចោលដោយមិនត្រឹមត្រូវនូវ "ទំនាក់ទំនងអនីតិសង្វាស" ត្រូវទទួលខុសត្រូវសងសំណងខូចខាតដោយមូលហេតុនៃអំពើអនីត្យានុកូល ចំពោះភាគីម្ខាងទៀត។ ថាតើជា "ទំនាក់ទំនងអនីតិសង្វាស" ឬយ៉ាងណានោះ ត្រូវវិនិច្ឆ័យទៅលើ ទាំងឆន្ទៈរបស់គូភាគី និង ទៅលើស្ថានភាពជីវភាពជាក់ស្តែង។

# តារាងលំហូរនៃនីតិវិធីលែងលះ

បានចុះបញ្ជីអាពាហ៍ពិពាហ៍

ករណីដែលមានកូនជាអនីតិជន

**ជាគោលការណ៍៖ ម្តាយ គឺជាអ្នកមានអំណាចមេបា (កថាខណ្ឌទី ១ មាត្រា ១០៣៨ នៃក្រមរ/ដ)**

ករណីលើកលែង៖ ករណីដែលឪពុកទទួលស្គាល់កូននោះ (※) និង ការពិភាក្សារបស់ឪពុកម្តាយបានកំណត់យកឪពុកជាអ្នកមានអំណាចមេបា នោះឪពុកជាអ្នកមានអំណាចមេបា (កថាខណ្ឌទី ២ មាត្រា ១០៣៨ នៃក្រមរ/ដ)។

※ការទទួលស្គាល់ នឹងត្រូវធ្វើឡើងដោយការជូនដំណឹងទៅមន្ត្រីអត្រានុកូលដ្ឋាន (មាត្រា ៩៩៧ នៃក្រមរ/ដ)។ ព្រមទាំងករណីដែលបានចុះហត្ថលេខា ឬ ផ្តិតមេដៃនៅក្នុងសៀវភៅកំណើតថាឈ្មោះខ្លួនជាឪពុក ត្រូវចាត់ទុកថាបានទទួលស្គាល់ (មាត្រា ៩៩៨ នៃក្រមរ/ដ)។

**អ្នកមានអំណាចមេបា កំណត់ដោយយកនរណាម្នាក់រវាងម្តាយឬឪពុកតាំងពីដើម។ នៅពេលពីរនាក់បែកគ្នា ពុំចាំបាច់កំណត់អ្នកមានអំណាចមេបាជាថ្មីម្តងទៀតទេ។**

ករណីដែលចង់ផ្លាស់ប្តូរអ្នកមានអំណាចមេបា ត្រូវដាក់ពាក្យសុំនីតិវិធីដើម្បីផ្លាស់ប្តូរអ្នកដែលមានអំណាចមេបា (មាត្រា ១០៣៩ នៃក្រមរ/ដ, មាត្រា ៣ និង ចំណុច ១២ ផ្នែក ៤ ក្នុងតារាងឧបសម្ព័ន្ធ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង)។

NO

"មិនចាំបាច់ត្រូវធ្វើនីតិវិធីលែងលះគ្នាទេ！！"

ការលែងលះ គឺជានីតិវិធីរំលាយទំនាក់ទំនងអាពាហ៍ពិពាហ៍ (យោងវាក្យខណ្ឌទី ២ មាត្រា ៩៧៩ នៃក្រមរ/ដ)។
អាពាហ៍ពិពាហ៍ នឹងមានអានុភាព ដោយការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ការជូនដំណឹងជាសាធារណៈ ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ និង ការចុះបញ្ជីនៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន (មាត្រា ៩៥៥ នៃក្រមរ/ដ)។ ពោលគឺ ប្រសិនបើមិនបានបញ្ចប់ឲ្យសព្វគ្រប់នូវការចុះបញ្ជីអាពាហ៍ពិពាហ៍ទេ អានុភាពនៃអាពាហ៍ពិពាហ៍នឹងមិនកើតមានឡើងទេ។
ក្នុងករណីដែលមិនបានចុះបញ្ជីអាពាហ៍ពិពាហ៍ទេ គឺពុំចាំបាច់ត្រូវធ្វើនីតិវិធីលែងលះគ្នាទេ!
ប៉ុន្តែ បុគ្គលដែលបានបដិសេធចោលដោយមិនត្រឹមត្រូវនូវ "ទំនាក់ទំនងអនីតិសង្វាស" ត្រូវទទួលខុសត្រូវសងសំណងខូចខាតដោយមូលហេតុនៃអំពើអនីត្យានុកូលចំពោះភាគីម្ខាងទៀត។ ថាតើជា "ទំនាក់ទំនងអនីតិសង្វាស" ឬយ៉ាងណានោះ ត្រូវវិនិច្ឆ័យទៅលើ ទាំងឆន្ទៈរបស់គូភាគី និង ទៅលើស្ថានភាពជីវភាពជាក់ស្តែង។

# ករណីមានវិវាទលើទ្រព្យសម្បត្តិ




ដាក់ពាក្យសុំលែងលះដោយការព្រមព្រៀង។ ព្រមទាំងដាក់ពាក្យសុំបែងចែកទ្រព្យសម្បត្តិ ផ្អែកតាមមាត្រា ៣ និង ចំណុច ៦ ផ្នែក ៤ ក្នុងតារាងឧបសម្ព័ន្ធ នៃ**ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង។**

ដាក់បណ្តឹងទាមទារលែងលះគ្នា។ ព្រមទាំងដាក់ពាក្យសុំចាត់ចែងទាក់ទងនឹងការបែងចែកទ្រព្យសម្បត្តិ ផ្អែកតាមកថា/ទី ១ មាត្រា ២២ នៃ**ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល។**

ដោយសារតែមិនបានចុះបញ្ជីអាពាហ៍ពិពាហ៍ ហេតុនេះនាំឲ្យមិនមានទ្រព្យសម្បត្តិរួមដែលកំណត់នៅក្នុងមាត្រា ៩៧៣ នៃក្រមរ/ដទេ។ ទ្រព្យសម្បត្តិដែលមានកម្មសិទ្ធិតែម្ខាង គឺជាទ្រព្យសម្បត្តិដែលបុគ្គលនោះមានកម្មសិទ្ធិ។ ពុំចាំបាច់បែងចែកទ្រព្យសម្បត្តិទេ។
បន្ទាប់ពីបានកំណត់ទ្រព្យសម្បត្តិដែលមានវិវាទ សូមពិចារណាលើការដាក់បណ្តឹងរដ្ឋប្បវេណី ដើម្បីដោះស្រាយវិវាទនោះ។

Yoshie SASAKI / JICA Expert

# ស្តីអំពី របៀបចាត់ចែងរឿងក្តីលែងលះ

## 1. តារាងលំហូរនៃនីតិវិធីលែងលះ




## 2. វិធីចាត់ចែងក្នុងករណីដែលភាគីមិនបានជ្រើសរើសនីតិវិធីបានត្រឹមត្រូវ

（1） ករណីដែលគូភាគីទាំងសងខាងបានព្រមព្រៀងអំពីការលែងលះគ្នា (និង ករណីដែលមានកូនជាអនីតិជនបានកំណត់អ្នកមានអំណាចមេបា) តែមិនបានដាក់ពាក្យសុំលែងលះដោយផ្អែកតាមច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងទេ បែរជាបានដាក់ពាក្យបណ្តឹងទាមទារលែងលះ (យោងតារាងលំហូរ ① )

→ មាន ២ វិធី។ ដំបូង ធ្វើតាមវិធីនៃចំណុច ក ហើយបើសិនជាភាគីមិនយល់ព្រម នឹងធ្វើតាមវិធីនៃចំណុច ខ។

ក. ធ្វើការពន្យល់ថា ក្នុងករណីនេះអាចដាក់ពាក្យសុំលែងលះដោយផ្អែកតាមច្បាប់ស្តីពីនីតិវិធីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ហើយឲ្យភាគីដកពាក្យបណ្តឹងទាមទារលែងលះរួចជំរុញឲ្យដាក់ពាក្យសុំលែងលះគ្នា។

"មូលហេតុ"

- ចំណាយប្រាក់តិចលើពន្ធដាក់ពាក្យសុំ

  ពន្ធដាក់ពាក្យសុំនៃបណ្ដឹងទាមទារលែងលះមានចំនួន ៥៥០០០ (ប្រាំម៉ឺនប្រាំពាន់) រៀល (កថាខណ្ឌទី ៣ មាត្រា ៦០ និង កថាខណ្ឌទី ១ មាត្រា ៦១ នៃក្រមនីតិវិធីរដ្ឋប្បវេណី)[1] រីឯពន្ធដាក់ពាក្យសុំនៃពាក្យសុំលែងលះមានចំនួន ៥.០០០ (ប្រាំពាន់) រៀល (កថាខណ្ឌទី ១ មាត្រា ២២ នៃច្បាប់ស្ដីពីនីតិវិធីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង)។

- ពាក្យសុំគឺអាចធ្វើឡើងដោយផ្ទាល់មាត់បាន

  ពាក្យបណ្ដឹងទាមទារលែងលះ ភាគីត្រូវតែដាក់ពាក្យបណ្ដឹងជាលាយលក្ខណ៍អក្សរទៅតុលាការ (កថាខណ្ឌទី ១ មាត្រា ៧៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី) រីឯពាក្យសុំលែងលះអាចធ្វើឡើងដោយផ្ទាល់មាត់បាន (កថាខណ្ឌទី ១ មាត្រា ២៦ នៃក្រមនីតិវិធីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង)។

- ការសម្រេចសេចក្ដីចេញបានឆាប់រហ័ស

  ដើម្បីចេញសាលក្រម ឬ សាលដីកាទៅលើបណ្ដឹងទាមទារលែងលះ តុលាការត្រូវតែឆ្លងកាត់នូវការទាញហេតុផលដោយផ្ទាល់មាត់ (កថាខណ្ឌទី ១ មាត្រា ១១៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ ប៉ុន្តែ មិនត្រូវបានធ្វើឡើងជាសាធារណៈទេ (កថាខណ្ឌទី ១ មាត្រា ១៦ នៃច្បាប់ស្ដីពីនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល)) ចំណែកឯ ករណីដែលត្រូវចេញដីកាសម្រេចចំពោះពាក្យសុំលែងលះ មិនចាំបាច់ត្រូវឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់ទេ (កថាខណ្ឌទី ១ មាត្រា ២៨ នៃច្បាប់ស្ដីពីនីតិវិធីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង)។

ខ. ធ្វើការពន្យល់ថា ពាក្យបណ្ដឹងទាមទារលែងលះអាចដាក់បានលុះត្រាតែនៅក្នុងករណីដែលស្របទៅនឹងចំណុចណាមួយនៃកថាខណ្ឌទី ១ មាត្រា ៩៧៨ នៃក្រមរដ្ឋប្បវេណី (កថាខណ្ឌទី ១ មាត្រា ៩៧៨ នៃក្រមរដ្ឋប្បវេណី) ហើយជំរុញភាគីឲ្យអះអាងអំពីមូលហេតុជាក់ស្ដែងនៃការលែងលះ។ ក្នុងករណីដែលភាគីទាំងសងខាងបានព្រមព្រៀងគ្នាអំពីការលែងលះ គឺជាករណីដែលភាគីទាំងសងខាងពុំមានឆន្ទៈបន្តទំនាក់ទំនងអាពាហ៍ពិពាហ៍ ដូច្នេះហើយ ត្រូវនឹងមូលហេតុដែលលើកឡើងថា "ទំនាក់ទំនងអាពាហ៍ពិពាហ៍ត្រូវបានបែកបាក់ ហើយគ្មានសង្ឃឹមថានឹងអាចបដិទានឡើងវិញបាន" (ចំណុច ង)។

ក្នុងករណីដែលភាគីមិនយល់ព្រម តុលាការត្រូវធ្វើការបកស្រាយពាក្យបណ្ដឹងថា គឺការអះអាងបែបនេះគឺជាការអះអាងដែលមានលក្ខណៈស្មៀមស្ងាត់ ហើយបន្តនីតិវិធីតទៅមុខ។

---

[1] បណ្ដឹងទាមទារលែងលះ គឺជាបណ្ដឹងដែលតុលាការ "មិនអាចគណនា" (កថាខណ្ឌទី ៣ មាត្រា ៦០ នៃក្រមនីតិវិធីរដ្ឋប្បវេណី)ដោយផ្អែកលើ "ផលប្រយោជន៍ដែលបានទាមទារក្នុងបណ្ដឹង" (កថាខណ្ឌទី ១ មាត្រា ៦០ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ដូច្នេះហើយតម្លៃកម្មវត្ថុនៃបណ្ដឹងនេះត្រូវចាត់ទុកថា មានចំនួន ៥.៥០០.០០០ (ប្រាំលានប្រាំសែន) រៀល។ ពន្ធដាក់ពាក្យសុំ ចំពោះភាគនៃតម្លៃកម្មវត្ថុនៃបណ្ដឹងដែលមានចំនួនត្រឹម ១០.០០០.០០០ (ដប់លាន) រៀល ពន្ធដាក់ពាក្យសុំដែលត្រូវបង់ក្នុងតម្លៃនៃកម្មវត្ថុចំនួន ១០០.០០០ (មួយសែន) រៀល គឺមានចំនួន ១.០០០ (មួយពាន់) រៀល (ចំណុច ក កថាខណ្ឌទី ១ មាត្រា ៦១ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ដូច្នេះ បើកម្មវត្ថុនៃបណ្ដឹងមានចំនួន ៥.៥០០.០០០ (ប្រាំលានប្រាំសែន) រៀល នឹងត្រូវបង់ពន្ធ ៥៥.០០០ (ប្រាំម៉ឺនប្រាំពាន់)រៀល។

"មូលហេតុ"

・ ដោយសារតែការចេញសាលក្រម ឬ សាលដីកាចាំបាច់ត្រូវធ្វើឡើងដោយផ្អែកលើការទាញហេតុផលដោយផ្ទាល់មាត់ (កថាខណ្ឌទី ១ មាត្រា ១១៤ និង កថាខណ្ឌទី ១ មាត្រា ១៧៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ដូច្នេះហើយ នីតិវិធីនឹងមានលក្ខខណៈតឹងរ៉ឹងជាងដីកាសម្រេចដែលអាចចេញបានដោយពុំធ្វើការទាញហេតុផលដោយផ្ទាល់មាត់ (វាក្យខណ្ឌទី ២ កថាខណ្ឌទី ១ មាត្រា ១១៤ និង កថាខណ្ឌទី ២ មាត្រា ១៧៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ បើភាគីបានជ្រើសរើសយកនីតិវិធីដែលមានលក្ខណៈតឹងរឹងនោះ ផ្អែកតាមច្បាប់នីតិវិធីគឺពុំមានបញ្ហាអ្វីទេ។

・ ក្រោយមកបញ្ហាដែលកើតមាន គឺផ្អែកតាមច្បាប់សារជាតុ។ លក្ខខណ្ឌនៃបណ្តឹងទាមទារលែងលះផ្អែកតាមច្បាប់សារជាតុ គឺមានចែងនៅក្នុងកថាខណ្ឌទី ១ មាត្រា ៩៧៨ នៃក្រមរដ្ឋប្បវេណី។ ប្រសិនបើការលែងលះបានបំពេញលក្ខខណ្ឌនេះ នឹងពុំមានបញ្ហាផ្អែកតាមច្បាប់សារជាតុទេ។

(２) ករណីដែលភាគីម្ខាងមិនបានព្រមព្រៀងអំពីការលែងលះគ្នា ឬ មិនទាន់បានកំណត់អំពីអ្នកមានអំណាចមេបា ហើយមិនបានដាក់បណ្តឹងទាមទារលែងលះគ្នាទេ បែរជាបានពាក្យសុំលែងលះដោយផ្អែកតាមច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងទៅវិញ (យោងតារាងលំហូរ ②)

→ ជំរុញឲ្យភាគីដកពាក្យសុំលែងលះ ហើយដាក់ពាក្យបណ្តឹងទាមទារលែងលះ។ ក្នុងករណីដែលភាគីមិនព្រម តុលាការនឹងត្រូវលើកចោលពាក្យសុំលែងលះ[2]។

"មូលហេតុ"

・ ក្នុងករណីដែលភាគីម្ខាងមិនបានព្រមព្រៀងគ្នាអំពីការលែងលះ ភាគីមិនអាចធ្វើការដាក់ពាក្យសុំលែងលះគ្នាបានតាំងពីដំបូងបានទេ។ ពាក្យសុំលែងលះ គឺអាចធ្វើទៅបានក្នុងករណីដូចបានចែងនៅក្នុងមាត្រា ៩៧៩ នៃក្រមរដ្ឋប្បវេណី ពោលគឺនៅក្នុងករណីដែលភាគីទាំងសងខាងបានព្រមព្រៀងគ្នាអំពីការលែងលះ។ (ចំណុចទី៥ ផ្នែកទី ៤ តារាងឧបសម្ព័ន្ធនៃច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង)។

・ នៅពេលដែលឪពុកម្តាយលែងលះគ្នា ត្រូវតែកំណត់យកឪពុក ឬ ម្តាយណាម្ខាងជាអ្នកមានអំណាចមេបាលើកូន (កថាខណ្ឌទី ១ មាត្រា ១០៣៧ នៃក្រមរដ្ឋប្បវេណី)។ ប្រសិនបើតុលាការទទួលស្គាល់នូវការទាមទារលែងលះទាំងមិនទាន់បានកំណត់អំពីអ្នកមានអំណាចមេបា នោះនឹងធ្វើឲ្យផ្ទុយពី

---

[2] ប្រសិនបើជានៅក្នុងនីតិវិធីចេញសាលក្រម ឬ សាលដីកា ទោះបីករណីតុលាការត្រូវធ្វើការ "ច្រានចោល"ក៏ដោយ ក៏នៅក្នុងនីតិវិធីចេញដីកាសម្រេច តុលាការនឹងចាត់ចែងដោយធ្វើការ "លើកចោល"។

※ ពិនិត្យមើលកំណត់ពន្យល់ក្នុង កថាខណ្ឌទី ២ មាត្រា ៣៩ នៃច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនបណ្តឹង និងកំណត់ពន្យល់ក្នុង មាត្រា ៥៤៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

ផលប្រយោជន៍របស់កុមារ ដោយសារតែមានការព្រួយបារម្ភថា នៅក្រោយពេលដែលឪពុកម្តាយបានលែងលះគ្នា នឹងធ្វើឲ្យកូនមិនអាចទទួលបាននូវការគ្រប់គ្រងបានពេញលេញ។ ដូច្នេះហើយ ក្នុងករណីដែលមិនទាន់មានការកំណត់អំពីអ្នកមានអំណាចមេបាទេ តុលាការមិនអាចចេញដីកាសម្រេចទទួលស្គាល់ពាក្យសុំលែងលះបានទេ។ ដូច្នេះក្នុងករណីបែបនេះ ភាគីមិនត្រូវដាក់ពាក្យសុំលែងលះទេ គឺត្រូវដាក់ជាពាក្យបណ្តឹងទាមទារលែងលះ ហើយតុលាការនឹងត្រូវសម្រេចសេចក្តីអំពីការកំណត់អ្នកមានអំណាចមេបានៅក្នុងសាលាក្រម ឬ សាលដីកាដែលទទួលស្គាល់នោះ (កថាខណ្ឌទី ១ មាត្រា ២២ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល)។

យ៉ាងណាមិញ នៅក្នុងដីកាសម្រេចទទួលស្គាល់ពាក្យសុំលែងលះ ត្រូវតែសម្រេចសេចក្តីអំពីការកំណត់អ្នកមានអំណាចមេបាដោយផ្អែកទៅតាមការពិភាក្សារបស់ឪពុកម្តាយដែលបានកំណត់។ នៅក្នុងតារាងឧបសម្ព័ន្ធនៃច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង មិនបានកត់ត្រាអំពី "ការកំណត់អំពីអ្នកមានអំណាមេបាតាមបញ្ញត្តិនៃមាត្រា ១០៣៧ នៃក្រមរដ្ឋប្បវេណី" ទេ ចំណុចនេះ គឺមានន័យថា តុលាការ នឹងមិនទទួលស្គាល់ទៅលើពាក្យសុំដែលគ្រាន់តែទាមទារនូវកំណត់អំពីអ្នកមានអំណាចមេបាតែមួយមុខនោះទេ។ នៅពេលដែលតុលាការចេញដីកាសម្រេចទទួលស្គាល់ពាក្យសុំលែងលះ គឺចាំបាច់ត្រូវធ្វើការសម្រេចអំពីការកំណត់អំពីអ្នកមានអំណាចមេបា (យោង កថាខណ្ឌទី ១ មាត្រា ២២ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល)។

（３） ករណីដែលភាគីបានដាក់ពាក្យសុំលែងលះដោយផ្អែកតាមច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ឬ បានដាក់ពាក្យបណ្តឹងទាមទារលែងលះ ទាំងដែលនីតិវិធីនៃការលែងលះពុំមានភាពចាំបាច់ (យោង តារាងលំហូរ③)

→ ធ្វើការពន្យល់អំពីភាពមិនចាំបាច់នៃការដាក់ពាក្យសុំលែងលះ ឬ បណ្តឹងទាមទារលែងលះ រួចជំរុញឲ្យភាគីដកពាក្យសុំ ឬ ពាក្យបណ្តឹង។

"មូលហេតុ"

・ ការលែងលះគឺជានីតិវិធីរំលាយទំនាក់ទំនងអាពាហ៍ពិពាហ៍ (យោង វាក្យខណ្ឌទី ២ មាត្រា ៩៧៩ នៃក្រមរដ្ឋប្បវេណី)។ អាពាហ៍ពិពាហ៍នឹងមានអានុភាព ដោយការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ការជូនដំណឹងជាសាធារណៈ ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ និង ការចុះបញ្ជីនៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន (មាត្រា ៩៥៥ នៃក្រមរដ្ឋប្បវេណី)។ ដូច្នេះ ក្នុងករណីដែលមិនទាន់បានចុះបញ្ជីអាពាហ៍ពិពាហ៍ទេ អានុភាពនៃអាពាហ៍ពិពាហ៍នឹងមិនកើតមានឡើងទេ។ ក្នុងករណីនេះ ការលែងលះពុំចាំបាច់មាននីតិវិធីនៃការលែងលះទេ។

→ ក្នុងករណីដែលមានវិវាទអំពីការកំណត់អ្នកមានអំណាចមេបាលលើកូន ហើយឪពុកបានទទួល

ស្គាល់កូននោះ តុលាការត្រូវធ្វើការពន្យល់ទៅភាគីថា អាចដាក់ពាក្យសុំកំណត់អំពីអ្នកមានអំណាចមេបា តាមបញ្ញត្តិនៃកថាខណ្ឌទី ៣ មាត្រា ១០៣៨ នៃក្រមរដ្ឋប្បវេណីបាន។ ប៉ុន្តែ តុលាការត្រូវពន្យល់ថា ក្នុងករណីដែលឪពុកមិនទាន់បានទទួលស្គាល់កូនទេ ផ្អែកតាមក្រមរដ្ឋប្បវេណី ម្តាយគឺជាអ្នកមានអំណាចមេបាលើកូននោះ ហេតុនេះហើយ ពុំចាំបាច់កំណត់អំពីអ្នកមានអំណាចមេបាទេ។

"មូលហេតុ"

- ក្នុងករណីដែលគូភាគីមានកូនជាអនីតិជន អ្នកមានអំណាចមេបាលើកូននោះ គឺជាម្តាយ (កថាខណ្ឌទី ១ មាត្រា ១០៣៨ នៃក្រមរដ្ឋប្បវេណី) ។

ប៉ុន្តែ ក្នុងករណីដែលឪពុកបានទទួលស្គាល់កូននោះ ឪពុកក៏អាចក្លាយទៅជាអ្នកមានអំណាចមេបាបានផងដែរ (កថាខណ្ឌទី ២ មាត្រា ១០៣៨ នៃក្រមរដ្ឋប្បវេណី) ដូច្នេះ ក្នុងករណីនេះ ភាគីអាចដាក់ពាក្យសុំកំណត់អំពីអ្នកមានអំណាចមេបាបាន (កថាខណ្ឌទី ៣ មាត្រា ១០៣៨ នៃក្រមរដ្ឋប្បវេណី, មាត្រា ៣ និង ចំណុច ១១ ផ្នែកទី ៤ ក្នុងតារាងឧបសម្ព័ន្ធ នៃច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង)។

## ３. ចំណុចដែលត្រូវប្រុងប្រយ័ត្ននៅពេលដែលបន្តនីតិវិធី

（1） ពាក្យសុំលែងលះ (ចំណុចទី ៥ ផ្នែកទី ៤ ក្នុងតារាងឧបសម្ព័ន្ធ នៃច្បាប់ស្តីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង)

នីតិវិធីនឹងត្រូវបន្តដោយផ្អែកតាមច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង។

ចំពោះ នីតិវិធីទាំងអស់ គឺត្រូវបានកំណត់នៅក្នុងច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង (យោងមាត្រា ១ នៃច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង)។

（2） បណ្តឹងទាមទារលែងលះ (ចំណុច គ មាត្រា ៣ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល)

នីតិវិធីនឹងត្រូវបន្តដោយផ្អែកតាមច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល និង ក្រមនីតិវិធីរដ្ឋប្បវេណី។

ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ចែងអំពី "ករណីពិសេសនៃក្រមរដ្ឋប្បវេណី" ចំពោះនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល (យោង មាត្រា ១ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល)។

ដូច្នេះហើយ ចំណុចដែលមានចែងនៅក្នុងច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល នឹងត្រូវអនុវត្តតាមច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ហើយចំណុចក្រៅពីនេះ នឹងត្រូវអនុវត្តតាមក្រមនីតិវិធីរដ្ឋប្បវេណីដែលជាច្បាប់ទូទៅ។

ប្រសិនបើជាចំណុចដែលមានចែងនៅក្នុងច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ហើយតុលាការមិនបានបន្តនីតិវិធីដោយផ្អែកតាមច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល បែរជាបានបន្តនីតិវិធីដោយផ្អែកតាមក្រមនីតិវិធីរដ្ឋប្បវេណីដែលជាច្បាប់ទូទៅ នីតិវិធីនោះគឺជានីតិវិធីដែលខុសច្បាប់ដោយសារ

តែផ្ទុយនឹងច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល។ ចៅក្រម ត្រូវតែស្វែងយល់ទុកនូវចំណុចដែលមានចែងនៅក្នុងច្បាប់ស្តីពីនិតិវិធីទាក់ទងនឹងឋានៈបុគ្គលឲ្យបានច្បាស់លាស់។

"ជាពិសេសមាត្រាដែលសំខាន់ៗ"

- មាត្រា ១២

ដើមចោទ អាចផ្លាស់ប្តូរនូវការទាមទារ ឬ មូលហេតុនៃការទាមទារបាន រហូតដល់ពេលចប់ការទាញហេតុផលដោយផ្ទាល់មាត់នៃការជម្រះក្តីលើកទី ១ ឬ ការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍។ ចុងចម្លើយក៏អាចដាក់ពាក្យបណ្តឹងតបបានរហូតដល់ពេលនោះដែរ។

- កថាខណ្ឌទី ១ មាត្រា ១៣

ក្នុងករណីដែលភាគីមិនបានបង្ហាញច្បាស់លាស់អំពីឆន្ទៈមានវិវាទទៅលើអង្គហេតុដែលភាគីម្ខាងបានអះអាងក៏ដោយ ក៏តុលាការត្រូវចាត់ទុកថាភាគីបានសារភាពចំពោះអង្គហេតុនោះដែរ។ អង្គហេតុដែលភាគីបានសារភាពក៏ដោយ ក៏តុលាការត្រូវទទួលស្គាល់ដោយផ្អែកតាមភស្តុតាងដែរ។ ម្យ៉ាងទៀតតុលាការមិនអាចចេញសាលក្រម ឬ សាលដីកាកំបាំងមុខបានទេ។

※ ក្រៅពីចំណុចខាងលើនេះ ក៏នៅមានផ្នែកមួយចំនួនទៀតដែលបញ្ញត្តិនៃក្រមនីតិវិធីរដ្ឋប្បវេណីមិនត្រូវយកមកអនុវត្ត ដូច្នេះសូមផ្ទៀតផ្ទាត់ក្នុងមាត្រា!

- កថាខណ្ឌទី ២ មាត្រា ១៣

ភាគីមិនអាចធ្វើការផ្សះផ្សាលើបណ្តឹង ការលះបង់នូវការទាមទារ និង ការទទួលស្គាល់នូវការទាមទារបានទេ។

- មាត្រា ១៤

តុលាការអាចយកអង្គហេតុដែលភាគីមិនបានអះអាងមកធ្វើជាមូលដ្ឋាននៃសាលក្រមបាន។

- មាត្រា ១៦

ការទាញហេតុផលដោយផ្ទាល់មាត់នៃបណ្តឹងទាក់ទងនឹងឋានៈបុគ្គល មិនត្រូវធ្វើជាសាធារណៈឡើយ។

- មាត្រា ១៧

សាលក្រម ឬ សាលដីកាស្ថាពរនៃបណ្តឹងទាក់ទងនឹងឋានៈបុគ្គលក៏មានអានុភាពចំពោះតតិយជនដែរ[3]។

---

[3] ពាក្យថា "សាលក្រម ឬ សាលដីកាស្ថាពរនៃបណ្តឹងទាក់ទងនឹងឋានៈបុគ្គល" នៅត្រង់នេះ គឺសំដៅទៅលើសាលក្រម ឬ សាលដីកាស្ថាពរនៃបណ្តឹងដែលបានកំណត់នៅក្នុងមាត្រា ៣ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល។ ដូច្នេះ នៅក្នុងសាលក្រម ឬ សាលដីកាដែលទទួលស្គាល់នូវទាមទារលែងលះ ហើយបើសិនជាតុលាការបានបង្គាប់ឲ្យភាគីប្រគល់កូន ឬ បង់ប្រាក់ ឬ ផ្តល់តាវកាលិកផ្សេងទៀត (កថាខណ្ឌទី ១ និង កថាខណ្ឌទី ២ មាត្រា ២២ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល) គឺផ្នែកដែលតុលាការទទួលស្គាល់នូវការទាមទារលែងលះ នឹងមានអានុភាពដល់តតិយជន ប៉ុន្តែ ផ្នែកដែលតុលាការបានបង្គាប់ឲ្យភាគីប្រគល់កូន ឬ បង់ប្រាក់ ឬ ផ្តល់តាវកាលិកផ្សេងទៀត នឹងមិនមានអានុភាពដល់តតិយជនទេ។

- មាត្រា ២១

ទោះបីជាគ្មានពាក្យសុំរបស់ភាគីក៏ដោយ ក៏តុលាការអាចបង្គាប់ឲ្យធ្វើការចាត់ចែងរក្សាការពារដោយធន្ទានុសិទ្ធិបានដែរ។

- មាត្រា ២២

មាត្រានេះ បានចែងអំពីចំណុចដែលតុលាការត្រូវតែសម្រេចសេចក្ដីក្នុងពេលជាមួយគ្នានៅក្នុងករណីដែលតុលាការទទួលស្គាល់ការទាមទាររបស់ដើមចោទនៅក្នុងបណ្ដឹងទាមទារលែងលះគ្នា។ ទាក់ទងនឹងចំណុចទាំងនោះ តុលាការក៏អាចបង្គាប់ឲ្យភាគីផ្ដល់តាវកាលិកក្នុងចំនួនទឹកប្រាក់ច្រើនជាងទឹកប្រាក់ដែលភាគីបានទាមទារផងដែរ។

- មាត្រា ២៣

តុលាការអាចបង្គាប់អំពីការអនុវត្តករណីយកិច្ចដោយប្រើនីតិវិធីងាយស្រួល ហើយខុសពីការអនុវត្តដោយបង្ខំ។

## 4. របៀបសរសេរសេចក្ដីសម្រេចបញ្ចប់

（1） ការលែងលះ

ក. ចំណុចដែលត្រូវពិចារណាក្នុងករណីពាក្យសុំលែងលះ

ជាដំបូងតុលាការត្រូវបញ្ជាក់ថា "តើគូភាគីទាំងសងខាងមានបំណងពិតប្រាកដក្នុងការរំលាយទំនាក់ទំនងអាពាហ៍ពិពាហ៍ដែរឬទេ?" (មាត្រា ៩៧៩ នៃក្រមរដ្ឋប្បវេណី) ។

បន្ទាប់មក ក្នុងករណីដែលប្ដីប្រពន្ធមានកូនដែលជាអនីតិជន ដើម្បីធ្វើការរំលាយទំនាក់ទំនងអាពាហ៍ពិពាហ៍ ចាំបាច់ត្រូវតែមានការកំណត់អំពីអ្នកមានអំណាចមេបានៅក្រោយពេលលែងលះគ្នា (យោង ចំណុច（2）នៃចំណុចលេខ 2 ខាងលើ)។ ដូច្នេះ ឃ្លាដែលលើកឡើងថា "តើគូភាគីទាំងសងខាងមានបំណងពិតប្រាកដក្នុងការរំលាយទំនាក់ទំនងអាពាហ៍ពិពាហ៍ដែរឬទេ?" គឺតុលាការចាំបាច់ត្រូវបញ្ជាក់អំពី ①ការព្រមព្រៀងអំពីការលែងលះគ្នា និង ②ការព្រមព្រៀងអំពីអ្នកមានអំណាចមេបា ។

ក្នុងករណីដែលអាចធ្វើការបញ្ជាក់បានថា គូភាគីទាំងសងខាងបានព្រមព្រៀងគ្នាពិតប្រាកដចំពោះចំណុចទាំងពីរដូចបានសរសេរខាងលើនេះ តុលាការនឹងទទួលស្គាល់ពាក្យសុំលែងលះ។ ក្នុងករណីដែលតុលាការមិនអាចទទួលស្គាល់អំពីការព្រមព្រៀងគ្នាពិតប្រាកដចំពោះចំណុចទាំងពីរដូចបានសរសេរខាងលើនេះទេ តុលាការត្រូវជំរុញឲ្យអ្នកដាក់ពាក្យសុំដកពាក្យសុំលែងលះ ហើយដាក់ពាក្យបណ្ដឹងទាមទារលែងលះ។ បើសិនជាអ្នកដាក់ពាក្យសុំមិនយល់ព្រមទេ តុលាការត្រូវលើកចោលនូវពាក្យសុំលែងលះ។

ខ. ចំណុចដែលត្រូវពិចារណាក្នុងករណីបណ្ដឹងទាមទារលែងលះ

ជាដំបូងតុលាការត្រូវធ្វើការវិនិច្ឆ័យដោយផ្អែកតាមភស្តុតាងថា តើមានមូលហេតុនៃការលែងលះដែលបានចែងនៅក្នុងចំណុចនីមួយៗនៃកថាខណ្ឌទី ១ មាត្រា ៩៧៨ នៃក្រមរដ្ឋប្បវេណីដែរឬទេ? យ៉ាងណាមិញ បើសិនជាតុលាការអាចទទួលស្គាល់ថា ភាគីទាំងសងខាងពុំមានឆន្ទៈបន្តនូវទំនាក់ទំនងអាពាហ៍ពិពាហ៍ទេ

វាគឺជាករណីដែលត្រូវនឹង "ករណីដែលទំនាក់ទំនងអាពាហ៍ពិពាហ៍ត្រូវបានបែកបាក់ ហើយគ្មានសង្ឃឹមថានឹងអាចធ្វើបដិទានឡើងវិញបាន" (ចំណុច ង) (យោងចំណុច ខ នៃលេខ (1) នៅក្នុងចំណុចលេខ 2 ខាងលើ)។

ក្នុងករណីដែលតុលាការទទួលស្គាល់អំពីមូលហេតុនៃការលែងលះ ហើយនៅពេលដែលក្នុងមានការអះអាងពីភាគី (ចុងចម្លើយ) អំពី "ការលែងលះគ្នានោះនឹងបណ្តាលឲ្យការទ្រទ្រង់ជីវភាពរបស់សហព័ទ្ធ ឬ កូន ក្រលំបាកយ៉ាងខ្លាំង ឬ មានការឈឺចាប់ដែលពុំអាចទ្រាំទ្របាន" (កថាខណ្ឌទី ២ មាត្រា ៩៧៨ នៃក្រមរដ្ឋប្បវេណី) តុលាការត្រូវធ្វើការពិចារណាទៅលើការអះអាងនោះ។ ក្នុងករណីនេះ តុលាការអាចច្រានចោលការទាមទារលែងលះបាន។

ម្យ៉ាងទៀត ក្នុងករណីដែលតុលាការទទួលស្គាល់អំពីមូលហេតុនៃការលែងលះដូចមានចែងនៅក្នុងចំណុច ឃ ឬ ចំណុច ង កថាខណ្ឌទី ១ មាត្រា ៩៧៨ នៃក្រមរដ្ឋប្បវេណី ហើយប្រសិនបើយល់ឃើញថាការទាមទារនោះផ្ទុយនឹងភាពសុចរិត ដោយជនដែលទាមទារឲ្យលែងលះគ្នានោះ ធ្វេសប្រហែសយ៉ាងខ្លាំងក្នុងការសហប្រតិបត្តិ និង ជួយសង្គ្រោះចំពោះសហព័ទ្ធ តុលាការអាចច្រានចោលការទាមទារលែងលះគ្នានោះ "ដោយឆន្ទានុសិទ្ធិបាន" (កថាខណ្ឌទី ៣ មាត្រា ៩៧៨ នៃក្រមរដ្ឋប្បវេណី)។

គ. របៀបសរសេរសេចក្តីសម្រេចបញ្ចប់ក្នុងករណីដែលទទួលស្គាល់នូវការលែងលះ

- ករណីពាក្យសុំលែងលះ

  **"លែងលះអ្នកដាក់ពាក្យសុំ និង ភាគីម្ខាងទៀត[4]។"**

- ករណីបណ្តឹងទាមទារលែងលះ

  **"លែងលះដើមចោទ និង ចុងចម្លើយ។"**

※ហេតុអ្វីបានជាខ្លឹមសារខាងលើនេះដូចជាឆ្លង?

មូលហេតុ គឺដោយសារតែខ្លឹមសារនៃសេចក្តីសម្រេចបញ្ចប់នេះ គឺជាសាលក្រម ឬសាលដីកានៃបណ្តឹងទាមទារឲ្យបង្កើត ប្តូរ ឬ រំលត់ទំនាក់ទំនងគតិយុត្ត។

ខាងក្រោមនេះ យោងទំព័រ ៤៩ ដល់ ទំព័រ ៥២ នៃសៀវភៅសេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី (ភាគ ១ ៖ នីតិវិធីបណ្តឹង)

"បណ្តឹងទាមទារឲ្យបង្កើត ប្តូរ ឬ រំលត់ទំនាក់ទំនងគតិយុត្ត គឺជាបណ្តឹងទាមទារឲ្យតុលាការចេញសាលក្រមប្រកាសបង្កើតជាថ្មីនូវទំនាក់ទនងគតិយុត្ត (ការកើតមានឡើង ការប្តូរ ឬ ការរំលត់) ដោយផ្អែកលើការអះអាងអំពីអត្ថិភាពនៃសិទ្ធិបង្កើត ឬ អំពីមូលហេតុនៃការបង្កើតទំនាក់ទំនងគតិយុត្តកំណត់

[4] នៅក្នុងច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ភាគីឲ្យឈ្មោះថា "អ្នកដាក់ពាក្យសុំ" និង " ភាគីម្ខាងទៀត" (យោង កថាខណ្ឌទី ១ មាត្រា ២៧, កថាខណ្ឌទី ២ មាត្រា ២៨, កថាខណ្ឌទី ១ មាត្រា ២៩ ជាអាទិ៍ នៃច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង)។

មួយដែលជាការទាមទារតាមផ្លូវបណ្ដឹង។ បណ្ដឹងប្រភេទនេះមានដូចជា បណ្ដឹងសុំលែងលះគ្នា។ ប្រសិនបើការព្រមព្រៀងលែងលះគ្នារវាងភាគីដែលមានទំនាក់ទំនងអាពាហ៍ពិពាហ៍មិនអាចសម្រេចបានទេ ហើយក្នុងករណីដែលភាគីខាងប្ដី ឬ ខាងប្រពន្ធចង់លែងលះគ្នា ភាគីនោះត្រូវដាក់ពាក្យបណ្ដឹសុំលែងលះគ្នា។ ក្នុងករណីនៃការលែងលះគ្នាតាមរយៈបណ្ដឹងសុំលែងលះគ្នា ទាល់តែមានសាលក្រមលែងលះគ្នាទើបមានអានុភាពបង្កើតនូវទំនាក់ទំនងគតិយុត្តដែលរំលាយនូវទំនាក់ទំនងអាពាហ៍ពិពាហ៍ដែលមានពីមុនមករវាងដើមចោទ និង ចុងចម្លើយ។ ទោះជាមានមូលហេតុលែងលះគ្នាដែលមានចែងក្នុងក្រមរដ្ឋប្បវេណី ( ចំណុចនីមួយៗ កថាខណ្ឌទី ១ មាត្រា ៩៧៨ នៃក្រមរដ្ឋប្បវេណី ) ហើយភាគីម្ខាងបានបង្ហាញឆន្ទៈលែងលះគ្នាក៏ដោយ ក៏មិនមានអនុភាពលែងលះគ្នាដែរ។ ដើម្បីឲ្យអានុភាពលែងលះគ្នា ដែលជាការរំលាយនូវចំណងអាពាហ៍ពិពាហ៍នោះកើតមានឡើង ទាល់តែតុលាការចេញសាលក្រមលែងលះគ្នា។ ដូច្នេះហើយ ជាគោលការណ៍ ច្បាប់ទទួលស្គាល់នូវការបង្កើតទំនាក់ទំនងគតិយុត្តថ្មី ដោយផ្អែកលើឆន្ទៈរបស់ភាគីណាម្ខាង ក៏ប៉ុន្តែ មានករណីមួយចំនួនដែល ដើម្បីឲ្យអានុភាពនៃការបង្កើតទំនាក់ទំនងគតិយុត្តនោះកើតមានឡើង ការបង្ហាញឆន្ទៈរបស់ភាគីមិនមែនជាការគ្រប់គ្រាន់ទេ គឺចាំបាច់មានបណ្ដឹងហើយឲ្យតុលាការចេញសាលក្រម។ បណ្ដឹងដែលទាមទារឲ្យតុលាការចេញសាលក្រមដែលមានអនុភាពបែបនេះ ហៅថា បណ្ដឹងទាមទារឲ្យបង្កើត ប្ដូរ ឬ រំលត់ទំនាក់ទំនងគតិយុត្ត។”

"ចំពោះបណ្ដឹងទាមទារឲ្យបង្កើត ប្ដូរ ឬ រំលត់ទំនាក់ទំនងគតិយុត្ត ពេលដែលតុលាការទទួលស្គាល់ថា ការទាមទាររបស់ដើមចោទត្រឹមត្រូវ តុលាការចេញសាលក្រម បង្កើត (ផ្លាស់ប្ដូរ) នូវទំនាក់ទំនងគតិយត្តកំណត់មួយតាមការទាមទារនោះ។ សាលក្រមប្រភេទនេះ គេហៅថា សាលក្រមបង្កើត ប្ដូរ ឬ រំលត់ទំនាក់ទំនងគតិយុត្ត។ សាលក្រមបង្កើត ប្ដូរ ឬ រំលត់ទំនាក់ទំនងគតិយុត្តិមានអានុភាពប្រតិសកម្ម (ឧទាហរណ៍ សាលក្រមទទួលស្គាល់ សាលក្រមរំលាយចោលនូវសេចក្ដីសម្រេចរបស់មហាសន្និបាតម្ចាស់ហ៊ុនជាដើម ) ឬ មានអានុភាពឆ្ពោះទៅអនាគត ( ឧទាហរណ៍ សាលក្រមលែងលះគ្នា សាលក្រមលុបចោលអាពាហ៍ពិពាហ៍ជាដើម ) ក្នុងការបង្កើត ប្ដូរ ឬ រំលត់នូវទំនាក់ទំនងគតិយុត្តដោយផ្ទាល់ តាមច្បាប់សារធាតុ ឬ ច្បាប់នីតិវិធី ទៅតាមខ្លឹមសារនៃសាលក្រមនោះ មានន័យថា មានអានុភាពបង្កើតទំនាក់ទំនងគតិយុត្ត (តើអានុភាពបង្កើតទំនាក់ទំនងគតិយុត្តនោះ ជាអានុភាពប្រតិសកម្ម ឬ យ៉ាងណាដែរនោះ ត្រូវបានកំណត់ដោយបញ្ញត្តិនៃច្បាប់សារធាតុ )។ អានុភាពនៃសាលក្រមបង្កើតទំនាក់ទំនងគតិយុត្តិ ដែលមានខ្លឹមសាររំលាយចោលនូវចំណងអាពាហ៍ពិពាហ៍រវាងភាគី ដោយសាលក្រមលែងលះគ្នា នឹងកើតមានឡើងចំពោះតតិយជនទូទៅផងដែរ។”

→ អានុភាពនៃការលែងលះនឹងកើតមានឡើងដំបូងតាមរយៈសាលក្រមស្ថាពរ ឬ ដីកាសម្រេចដែលបានចូលជាស្ថាពររបស់តុលាការ។ ពោលគឺ តុលាការគឺជាអ្នកលែងលះភាគី។

ដូច្នេះហើយ តុលាការដែលត្រូវចេញសាលក្រម ឬ សាលដីកានឹងត្រូវសរសេរសេចក្ដីសម្រេចបញ្ជាប់ថា "លែងលះ ដើមចោទ និង ចុងចម្លើយ”។

ឃ. របៀបសរសេរសេចក្ដីសម្រេចបញ្ចប់ក្នុងករណីដែលមិនទទួលស្គាល់នូវការលែងលះ

- ករណីពាក្យសុំលែងលះ

"លើកចោលពាក្យសុំរបស់អ្នកដាក់ពាក្យសុំ[5]។"

- ករណីបណ្ដឹងទាមទារលែងលះ

"ច្រានចោលការទាមទាររបស់ដើមចោទ។"

(2) ការកំណត់អំពីអ្នកមានអំណាចមេបា

នៅពេលដែលតុលាការទទួលស្គាល់អំពីការលែងលះ ដាច់ខាតចាំបាច់ត្រូវសម្រេចសេចក្ដីអំពីការកំណត់អ្នកមានអំណាចមេបា នៅក្នុងសេចក្ដីសម្រេចបញ្ចប់ ទោះបីជាដីកាសម្រេច ឬ សាលក្រម ឬ សាលដីកា ក៏ដោយ។

ច្បាប់មិនអនុញ្ញាតឲ្យមានការទទួលស្គាល់អំពីការលែងលះទាំងមិនបានកំណត់អំពីអ្នកមានអំណាចមេបាទេ ដោយសារតែផ្ទុយនឹងផលប្រយោជន៍របស់កុមារ។

ក. ចំណុចដែលត្រូវពិចារណាក្នុងករណីពាក្យសុំលែងលះ

តុលាការត្រូវកំណត់អំពីអ្នកមានអំណាចមេបាដោយពិចារណាទៅលើ "ផលប្រយោជន៍របស់កូន" (កថាខណ្ឌទី ៣ មាត្រា ១០៣៧ នៃក្រមរដ្ឋប្បវេណី)។ ចំពោះ "ផលប្រយោជន៍របស់កូន" គឺអាចធ្វើការពិចារណាដោយការញែកគ្នារវាង ① ស្ថានភាពរបស់ខាងឪពុកឬម្ដាយ និង ② ស្ថានភាពរបស់កូន។ ① ស្ថានភាពរបស់ខាងឪពុកឬម្ដាយ អាចមានដូចជា លទ្ធភាពក្នុងការគ្រប់គ្រង (អាយុ និង ស្ថានភាពសុខភាពជាដើម) ស្ថានភាពសេដ្ឋកិច្ច (ប្រាក់ចំណូលប្រចាំឆ្នាំ មុខរបរ មាន ឬ គ្មានលំនៅដ្ឋានជាដើម) និងស្ថានភាពនៃការគ្រប់គ្រងកូន មាន ឬ គ្មានជំនួយពីសាច់ញាតិ ការផ្ដល់ក្ដីស្រលាញ់ចំពោះកូនជាអាទិ៍ ដែលធ្លាប់មានកន្លងមក។ ② ស្ថានភាពរបស់កូនអាមានដូចជា អាយុ ស្ថានភាពនៃការលូតលាស់រាងកាយ និង ចិត្តគំនិត ឆន្ទៈរបស់កូន ភាពជិតស្និតរមួតនៃចំណងរវាងឪពុកឬម្ដាយ និង សាច់ញាតិជាដើម។ ចំពោះឆន្ទៈរបស់កូននឹងត្រូវធ្វើការពិចារណាថ្លឹងថ្លែងសមស្របទៅតាមអាយុ និង សភាពចាស់ទុំរបស់កូននោះ (កថាខណ្ឌទី ៤ មាត្រា ២២ នៃច្បាប់ស្ដីពីនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល និង មាត្រា ៥២ នៃច្បាប់ស្ដីពីនីតិវិធីរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង) ។

ខ. ករណីពាក្យសុំលែងលះ

" កំណត់ថា អ្នកដាក់ពាក្យសុំ (ឬ ភាគីម្ខាងទៀត) ជាអ្នកមានអំណាចមេបាលើ........................ (កើតនៅថ្ងៃទី.......ខែ............ឆ្នាំ............)[6]ដែលជាកូនរវាងអ្នកដាក់ពាក្យសុំ និង ភាគីម្ខាងទៀត។"

---

[5] យោងFootnoteចំណុចលេខ 2។

[6] អំណាចមេបាយកមកអនុវត្តចំពោះ "កូនដែលជាអនីតិជន" (មាត្រា ១០៣៤ នៃក្រមរដ្ឋប្បវេណី) ដូច្នេះហើយ តាមរយៈការសរសេរ

គ. ករណីបណ្តឹងទាមទារលែងលះ

**"កំណត់ថា ដើមចោទ (ឬ ចុងចម្លើយ) ជាអ្នកមានអំណាចមេបាលើ........................ (កើតនៅថ្ងៃទី.......ខែ............ឆ្នាំ............)ដែលជាកូនរវាងដើមចោទ និង ចុងចម្លើយ។"**

ឃ. អំពីការប្រគល់កូន

ក្នុងករណីដែលតុលាការកំណត់ថា ឪពុក ឬ ម្តាយដែលមិនបានគ្រប់គ្រងកូននាពេលបច្ចុប្បន្ន ជាអ្នកមានអំណាចមេបា (ក្នុងករណីដែលតុលាការទទួលស្គាល់ថា ស្ថានភាពនៃការគ្រប់គ្រងបច្ចុប្បន្ននេះមានបញ្ហា ហើយគួរតែផ្លាស់ប្តូរអ្នកគ្រប់គ្រងឲ្យទៅឪពុក ឬ ម្តាយម្ខាងទៀតវិញ) នាំឲ្យឪពុក ឬ ម្តាយដែលតុលាការបានកំណត់ជាអ្នកមានអំណាចមេបា អាចទាមទារទៅភាគីម្ខាងទៀត (ឪពុក ឬ ម្តាយដែលបានគ្រប់គ្រងកូនកន្លងមក) ឲ្យប្រគល់កូន (កថាខណ្ឌទី ២ មាត្រា ១០៤៧ នៃក្រមរដ្ឋប្បវេណី)។

នៅក្នុងការបន្តដំណើរការនៃនីតិវិធីបណ្តឹងទាមទារលែងលះ ក្នុងករណីដែលមានពាក្យសុំពីភាគីឲ្យប្រគល់កូន ហើយតុលាការបានទទួលស្គាល់ការទាមទារលែងលះ និងនៅពេលដែលមានហេតុផលសមរម្យក្នុងការទទួលស្គាល់ទៅលើពាក្យសុំនោះ (ករណីដែលមានការព្រួយបារម្ភខ្ពស់ថា ឪពុក ឬ ម្តាយដែលកំពុងគ្រប់គ្រងកូនក្នុងពេលបច្ចុប្បន្ននេះ (ឪពុក ឬ ម្តាយដែលមិនមែនជាអ្នកមានអំណាចមេបានៅក្រោយពេលលែងលះ) នឹងមិនប្រគល់កូនឲ្យទៅភាគីម្ខាងទៀតដោយស្ម័គ្រចិត្តនៅក្រោយពេលលែងលះគ្នា) ដូច្នេះ តុលាការអាចបង្គាប់អំពីការប្រគល់កូនបាន (កថាខណ្ឌទី ២ មាត្រា ២២ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល)។ សេចក្តីសម្រេចបញ្ចប់ក្នុងករណីនេះ នឹងសរសេរថា **"បង្គាប់ឲ្យចុងចម្លើយ (ឪពុក ឬ ម្តាយដែលតុលាការមិនបានកំណត់ជាអ្នកមានអំណាចមេបា) ប្រគល់កូនដែលជាអនីតិជនឲ្យទៅដើមចោទ (ឪពុក ឬ ម្តាយដែលតុលាការនឹងកំណត់អ្នកមានអំណាចមេបា)"**។

ក្រៅពីករណីខាងលើនេះ ពោលគឺនៅមាន ① ករណីដែលនៅក្នុងការបន្តដំណើរការនៃនីតិវិធីបណ្តឹងទាមទារលែងលះមិនមានការដាក់ពាក្យសុំឲ្យប្រគល់កូនទេ ប៉ុន្តែក្រោយពេលដែលសាលក្រម ឬ សាលដីកាទទួលស្គាល់ការទាមទារលែងលះបានចូលជាស្ថាពរ បែរជាឪពុក ឬ ម្តាយដែលមិនមែនជាអ្នកមានអំណាចមេបាមិនប្រគល់កូនដោយស្ម័គ្រចិត្ត និង ② ករណីដែលមានពាក្យសុំលែងលះដោយផ្អែកតាមច្បាប់ស្តីពីនិតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ហើយអ្នកមានអំណាចមេបាដាក់ពាក្យបណ្តឹងឡើងវិញ ដើម្បីទាមទារឲ្យឪពុក ឬ ម្តាយដែលមិនមែនជាអ្នកមានអំណាចមេបាប្រគល់កូន ដោយផ្អែកតាមកថាខណ្ឌទី ២ មាត្រា ១០៤៧ នៃក្រមរដ្ឋប្បវេណី។

(3) ការសម្រេចសេចក្តីអំពីរបៀបចូលជួប និង ប្រាស្រ័យទាក់ទងជាមួយកូន

ក. តើក្នុងករណីបែបណាទើបមានភាពចាំបាច់ក្នុងការសម្រេចសេចក្តី?

ក្រោយពេលលែងលះ ឪពុក ឬ ម្តាយដែលមិនមានអំណាចមេបាលើកកូន មានសិទ្ធិចូលជួប និង

---

អំពីថ្ងៃខែឆ្នាំកំណើតរបស់កូន នឹងធ្វើឲ្យកាលបរិច្ឆេទបញ្ចប់នូវអំណាចមេបាមានភាពច្បាស់លាស់។

ប្រាស្រ័យទាក់ទងជាមួយកូន (កថាខណ្ឌទី ១ មាត្រា ១០៤០ នៃក្រមរដ្ឋប្បវេណី)។ ឪពុកម្តាយដែលមានបំណងចង់លែងលះគ្នា ត្រូវពិភាក្សា និង កំណត់អំពីរបៀបចូលជួប (កថាខណ្ឌទី ២ មាត្រា ១០៤០ នៃក្រមរដ្ឋប្បវេណី)។ បើការពិភាក្សាគ្នាពុំបានសម្រេច ឬ ពុំអាចធ្វើការពិភាក្សាបានទេ តុលាការត្រូវកំណត់អំពីរបៀបចូលជួបប្រាស្រ័យ តាមការទាមទាររបស់ឪពុក ឬ ម្តាយ (កថាខណ្ឌទី ៤ មាត្រា ១០៤០ នៃក្រមរដ្ឋប្បវេណី)។

ដូច្នេះហើយ តុលាការត្រូវតែកំណត់អំពីរបៀបចូលជួបប្រាស្រ័យទាក់ទង ក្នុងករណីដែលមានការទាមទារពីឪពុក ឬ ម្តាយ។ ផ្ទុយមកវិញ បើមិនមានការទាមទារពីឪពុក ឬ ម្តាយទេ តុលាការមិនអាចកំណត់អំពីរបៀបចូលជួបប្រាស្រ័យទាក់ទងបានទេ។

ហេតុនេះ តើឪពុក ឬ ម្តាយអាចទាមទារបែបណាបាន?

- ដាក់ពាក្យសុំដោយផ្អែកតាមចំណុចលេខ ១៣ ផ្នែកទី ៤ ក្នុងតារាងឧបសម្ព័ន្ធ នៃច្បាប់ស្តីពីនិតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង (មាត្រា ២៦ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង)។

ពាក្យសុំនេះ មិនចាំបាច់ដាក់ក្នុងពេលជាមួយគ្នានិងពាក្យសុំលែងលះឡើយ។ ចាំក្រោយពេលលែងលះ ឪពុក ឬ ម្តាយដែលមិនមែនជាអ្នកមានអំណាចមេបាលើកូន ចាំដាក់ពាក្យសុំនេះ ក៏បានដែរ។

- ដាក់ពាក្យសុំ ឲ្យកំណត់អំពីរបៀបចូលជួបប្រាស្រ័យទាក់ទងទៅតុលាការក្នុងករណីដែលបណ្តឹងទាមទារលែងលះកំពុងតែបន្តដំណើរការនីតិវិធី រហូតដល់ពេលបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៃបណ្តឹងនោះ។

ដោយសារតែការកំណត់អំពីរបៀបចូលជួបប្រាស្រ័យទាក់ទង គឺជា "ការចាត់ចែងទាក់ទងនឹងការបីបាច់រក្សាកូន" ហេតុនេះ តុលាការត្រូវតែសម្រេចសេចក្តីនៅពេលដែលមានពាក្យសុំរបស់ភាគី (កថាខណ្ឌទី ១ មាត្រា ២២ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល)។ ប្រសិនបើភាគីបានដាក់ពាក្យសុំឲ្យកំណត់អំពីរបៀបចូលជួបប្រាស្រ័យទាក់ទងទៅតុលាការក្នុងចន្លោះពេលមុនការបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៃបណ្តឹងទាមទារលែងលះគ្នា តុលាការនឹងត្រូវសម្រេចសេចក្តីអំពីពាក្យសុំនោះផងដែរ ដាក់នៅក្នុងសាលក្រម ឬ សាលដីកាដែលទទួលស្គាល់នូវការលែងលះ (យោងមាត្រា ១២ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល)។

យ៉ាងណាមិញ ក្នុងករណីដែលភាគីមិនបានដាក់ពាក្យសុំនៅក្នុងចន្លោះពេលមុនការបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៃបណ្តឹងទាមទារលែងលះទេ ហើយនៅពេលដែលបញ្ហាអំពីរបៀបចូលជួបប្រាស្រ័យទាក់ទងបានកើតមានបញ្ហា ភាគីនឹងត្រូវដាក់ពាក្យសុំដោយផ្អែកតាមចំណុច ១៣ ផ្នែកទី ៤ ក្នុងឧបសម្ព័ន្ធនៃច្បាប់ស្តីពីនីតិវិធីបណ្តឹងនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង។

ខ. ចំណុចដែលត្រូវពិចារណានៅពេលដែលកំណត់អំពីរបៀបចូលជួបប្រាស្រ័យទាក់ទង

តុលាការត្រូវកំណត់អំពីការចូលជួបប្រាស្រ័យទាក់ទង ដោយយក "ផលប្រយោជន៍របស់កូនជាអាទិភាព"

(កថាខណ្ឌទី ៦ មាត្រា ១០៤០ នៃក្រមរដ្ឋប្បវេណី)។ ក្នុងករណីដែលតុលាការយកផលប្រយោជន៍របស់កូនជាអាទិភាព ចំពោះរបៀបចូលជួបប្រាស្រ័យទាក់ទង គឺ តុលាការគប្បីសរសេរសេចក្ដីសម្រេចបញ្ចប់ដែលអាចឆ្លើយតបទៅនឹងភាពបត់បែនចំពោះស្ថានភាពរបស់កូនជាដើម ហើយនៅពេលដែលចូលជួបប្រាស្រ័យទាក់ទងជាមួយកូនជាក់ស្ដែង ឪពុក ឬ ម្ដាយដែលមិនមែនជាអ្នកមានអំណាចមេបាត្រូវសហការគ្នាជាមួយឪពុក ឬ ម្ដាយដែលជាអ្នកមានអំណាចមេបាអនុវត្តនូវការប្រាស្រ័យទាក់ទងនោះទើបជាការប្រសើរ។

ផ្ទុយមកវិញ បើឪពុក ឬ ម្ដាយដែលមិនមែនជាអ្នកមានអំណាចមេបាលើកូនទាមទារទៅតុលាការឲ្យកំណត់អំពីរបៀបចូលជួបប្រាស្រ័យទាក់ទងកូន គឺមកពីការពិភាក្សាគ្នាពុំបានសម្រេច ឬ ពុំអាចធ្វើការពិភាក្សាបានទេ (កថាខណ្ឌទី ៤ មាត្រា ១០៤០ ក្រមរដ្ឋប្បវេណី) ។ ដូច្នេះហើយ ភាគច្រើន គឺ ឪពុក ឬ ម្ដាយដែលមិនមែនជាអ្នកមានអំណាចមេបាមានការពិបាកចំពោះការទទួលបាននូវការសហការពីឪពុក ឬ ម្ដាយដែលជាអ្នកមានអំណាចមេបា នៅពេលដែលចូលជួបប្រាស្រ័យទាក់ទងកូនជាក់ស្ដែង។

ក្នុងករណីនេះ តុលាការត្រូវតែបង្គាប់ទៅឪពុក ឬ ម្ដាយដែលជាអ្នកមានអំណាចមេបាឲ្យអនុញ្ញាតអំពីការចូលជួបប្រាស្រ័យទាក់ទងកូនរបស់ឪពុក ឬ ម្ដាយដែលមិនមែនជាអ្នកមានអំណាចមេបា ហើយប្រសិនបើឪពុក ឬ ម្ដាយដែលជាអ្នកមានអំណាចមេបាមិនគោរពតាមការបង្គាប់នេះទេ តុលាការចាំបាច់ត្រូវតែចេញការសម្រេចសេចក្ដីដែលអាចឲ្យឪពុក ឬ ម្ដាយដែលមិនមែនជាអ្នកមានអំណាចមេបាអាចត្រៀមសម្រាប់យកទៅអនុវត្តដោយបង្ខំបាន។

នៅត្រង់នេះ ការអនុវត្តដោយបង្ខំចំពោះកាតព្វកិច្ចដែលមានគោលបំណងឲ្យធ្វើឬ មិនឲ្យធ្វើសកម្មភាពណាមួយ ក៏អាចធ្វើបានតាមវិធីដែលតុលាការអនុវត្តចេញដីកាសម្រេចបង្គាប់ឲ្យកូនបំណុលនៃការអនុវត្តបង់នូវចំនួនទឹកប្រាក់ជាកំណត់ដែលទទួលស្គាល់ថាសមរម្យដើម្បីធានាការអនុវត្តកាតព្វកិច្ច ទៅឲ្យម្ចាស់បំណុលនៃការអនុវត្ត ស្របទៅតាមអំឡុងពេលនៃការយឺតយ៉ាវ ឬ កំណត់អំឡុងពេលដែលទទួលស្គាល់ថាសមរម្យដើម្បីអនុវត្តកាតព្វកិច្ច ហើយបង្គាប់ឲ្យកូនបំណុលនៃការអនុវត្តបង់នូវចំនួនទឹកប្រាក់ជាកំណត់ដែលទទួលស្គាល់ថាសមរម្យដើម្បីធានាការអនុវត្តកាព្វកិច្ច ទៅឲ្យម្ចាស់បំណុលនៃការអនុវត្តដោយភ្លាមៗ បើពុំបានអនុវត្តក្នុងអំឡុងពេលនោះ (កថាខណ្ឌទី ១ មាត្រា ៥២៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ នៅក្នុងលិខិតអនុវត្ត តុលាការគ្រាន់តែបង្គាប់ទៅឪពុក ឬ ម្ដាយដែលជាអ្នកមានអំណាចមេបាឲ្យផ្ដល់តាវកាលិកជាក់លាក់ក្នុងគោលបំណងឲ្យធ្វើសកម្មភាព ឬ មិនធ្វើសកម្មភាព ហើយប្រសិនបើឪពុក ឬ ម្ដាយនោះមិនបានអនុវត្តតាមការបង្គាប់នេះ ឪពុក ឬ ម្ដាយដែលមិនមែនជាអ្នកមានអំណាចមេបាអាចដាក់ពាក្យសុំអនុវត្តដោយបង្ខំ (វិធានបង្ខំដោយប្រយោល)បាន ។

ម្យ៉ាងទៀត នៅក្នុងសាលក្រម ឬ សាលដីកាដែលទទួលស្គាល់នូវការទាមទារលែងលះ តុលាការត្រូវតែបង្គាប់អំពីការប្រគល់កូន ឬ បង់ប្រាក់ ឬ ការផ្ដល់តាវកាលិកផ្សេងទៀត (កថាខណ្ឌទី ២ មាត្រា ២២

នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល)។ នៅក្នុងករណីដែលតុលាការចេញដីកាសម្រេច ដោយផ្អែកតាមច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ក៏អាចចេញដីកាសម្រេច ដោយបង្គាប់នូវការផ្តល់តាវកាលិកបានផងដែរ (យោង មាត្រា ៣៨ ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណី ដែលមិនមែនជាបណ្តឹង)។ ម្យ៉ាងទៀត ក្នុងករណីដែលតុលាការបង្គាប់អំពីតាវកាលិកទាំងនេះ ហើយ ក្រោយមកបានចូលជាស្ថាពរ នាំឲ្យតាវកាលិកទាំងអស់នោះនឹងក្លាយទៅជាលិខិតអនុវត្ត (ចំណុច ក ឬ ចំណុច គ កថាខណ្ឌទី ២ មាត្រា ៣៥០ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

ដូច្នេះហើយ ក្នុងករណីដែលកំណត់អំពីរបៀបចូលជួបប្រាស្រ័យទាក់ទង តុលាការនឹងបង្គាប់អំពីការ ផ្តល់តាវកាលិកដែលមានខ្លឹមសារថា ឪពុក ឬ ម្តាយដែលជាអ្នកមានអំណាចមេបានឹងមិនរារាំង (មិនធ្វើ សកម្មភាព) នៅក្នុងអំឡុងពេលដែលប្រគល់កូន (ការធ្វើសកម្មភាព) ហើយ ឪពុក ឬ ម្តាយដែលមិនមែន ជាអ្នកមានអំណាចមេបាកំពុងចូលជួបប្រាស្រ័យទាក់ទងជាមួយកូននៅទីកន្លែងដែលបានកំណត់ទេ។ ជាក់ស្តែងចាំបាច់ត្រូវតែកំណត់ដូចជា ① ថ្ងៃនិងម៉ោង ឬ ចំនួនដងនៃការចូលជួបប្រាស្រ័យទាក់ទង (តើ ឪពុក ឬ ម្តាយជាអ្នកមានអំណាចមេបាមានករណីយកិច្ចឲ្យចូលជួបនៅពេលណា? ចំនួនប៉ុន្មានដង?) ② រយៈពេលនៅពេលដែលចូលជួបក្នុងមួយលើកៗ (ដើម្បីឲ្យខ្លឹមសារនៃករណីយកិច្ចរបស់ឪពុក ឬ ម្តាយ ដែលជាអ្នកមានអំណាចមេបាដែលនឹងមិនរារាំងក្នុងការជួបប្រាស្រ័យទាក់ទងកាន់តែច្បាស់លាស់ តើគួរ តែឲ្យរយៈពេលប៉ុន្មានម៉ោងសម្រាប់ការប្រាស្រ័យទាក់ទង? ) ③ វិធីនៃការប្រគល់កូន (នៅពេលដែល ឪពុក ឬ ម្តាយ ដែលជាអ្នកមានអំណាចមេបាប្រគល់កូនទៅ ឪពុក ឬ ម្តាយ ដែលមិនមែនជាអ្នកមាន អំណាចមេបា តើ ឪពុក ឬ ម្តាយ ដែលជាអ្នកមានអំណាចមេបាចាំបាច់ត្រូវអ្វីខ្លះ?) ជាអាទិ៍។

គ. របៀបសរសេរអំពីសេចក្តីសម្រេចបញ្ចប់ដែលកំណត់អំពីរបៀបចូលជួបប្រាស្រ័យទាក់ទង

ផ្អែកតាមការពិចារណាដូចបានសរសេរនៅក្នុងចំណុច ខ ខាងលើនេះ នៅពេលដែលតុលាការកំណត់ អំពីរបៀបដែល ឪពុក ឬ ម្តាយ ដែលមិនមែនជាអ្នកមានអំណាចមេបាលើកូនចូលជួបប្រាស្រ័យទាក់ទង ជាមួយកូន គឺចាំបាច់ត្រូវតែយក "ផលប្រយោជន៍របស់កូន" ជាអាទិភាព ហើយសរសេរសេចក្តីសម្រេច បញ្ចប់ (សេចក្តីសម្រេចបញ្ចប់ដែលអាចកំណត់ជាក់លាក់អំពីខ្លឹមសារនៃការផ្តល់តាវកាលិក) ដែល អាចយកទៅអនុវត្តដោយបង្ខំ (វិធានបង្ខំដោយប្រយោល) នៅក្នុងករណីដែល ឪពុក ឬ ម្តាយ ដែលមិន មានអំណាចមេបាមិនគោរពតាម ។

ឧទាហរណ៍ សេចក្តីសម្រេចបញ្ចប់អាចមានដូចខាងក្រោមនេះ៖

ករណីមួយនេះ គឺជាករណីដែលនៅក្នុងការបន្តដំណើរការនៃនីតិវិធីបណ្តឹងទាមទារលែងលះ មាន ពាក្យសុំឲ្យកំណត់អំពីរបៀបចូលជួបប្រាស្រ័យទាក់ទងកូនពីចុងចម្លើយ ហើយតុលាការបានទទួល ស្គាល់នូវការទាមទារលែងលះ ដោយពេលនោះបានកំណត់ថា ដើមចោទគឺជាអ្នកមានអំណាចមេបាលើ កូនវាង ដើមចោទ និង ចុងចម្លើយ ដូច្នេះ តុលាការនឹងត្រូវសរសេរសេចក្តីសម្រេចបញ្ចប់ដែលកំណត់

អំពីរបៀបដែលចុងចម្លើយត្រូវចូលជួបប្រាស្រ័យទាក់ទងជាមួយកូន។

ក្នុងករណីដែលតុលាការកំណត់អ្នកមានអំណាចមេបាលើកូន មិនមែនជាដើមចោទ បែរជាចុងចម្លើយវិញនោះ ឃ្លាដែលសរសេរនៅក្នុងសេចក្តីសម្រេចខាងក្រោម គឺត្រូវតែប្តូរពីពាក្យ "ដើមចោទ" ជំនួសទៅជា "ចុងចម្លើយ" ។

ម្យ៉ាងវិញទៀត នៅក្នុងសេចក្តីសម្រេចបញ្ចប់នៃដីកាសម្រេចដែលទទួលស្គាល់ពាក្យសុំដោយផ្អែកតាមចំណុច ១៣ ផ្នែកទី ៤ ក្នុងតារាងឧបសម្ព័ន្ធនៃច្បាប់ស្តីពីនីតិវិធីបណ្តឹងនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ឃ្លាដែរសេរសេរនៅក្នុងសេចក្តីសម្រេចខាងក្រោម គឺ ចាំបាច់ត្រូវតែសរសេរជំនួសពាក្យថា "ដើមចោទ" ទៅជាពាក្យថា "អ្នកដាក់ពាក្យសុំ" ហើយពាក្យថា "ចុងចម្លើយ" ទៅជាពាក្យថា "ភាគីម្ខាងទៀត"។

"ដើមចោទត្រូវតែឲ្យ.............ដែលជាកូនរវាងដើមចោទ និង ចុងចម្លើយ (តទៅហៅថា "......") ចូលជួបប្រាស្រ័យទាក់ទងជាមួយចុងចម្លើយ មានដូចខាងក្រោមនេះ៖

ក. ចំនួនដង

ក្នុង ១ខែ ១ដង។ ថ្ងៃដែលកំណត់តាមការពិភាក្សាគ្នាដែលបានសម្រេចរវាងគូភាគី នៅក្នុងចន្លោះពីថ្ងៃពុធ រហូតដល់ ថ្ងៃសៅរ៍ នៃសប្តាហ៍ទី ២ ។ ប៉ុន្តែ បើសិនជាគូភាគីពិភាក្សាគ្នាមិនបានសម្រេចទេ ត្រូវយកថ្ងៃសៅរ៍នៃសប្តាហ៍ទី ២។

ខ. រយៈពេលនៃការចូលជួបប្រាស្រ័យទាក់ទងមួយលើកៗ

ក្នុង ១ លើករយៈពេល ៥ ម៉ោង។ ម៉ោងជាក់លាក់នឹងត្រូវកំណត់តាមការពិភាក្សាគ្នាដែលបានសម្រេចរវាងគូភាគី។ ប៉ុន្តែ បើសិនជាគូភាគីពិភាក្សាគ្នាមិនបានសម្រេចទេ ត្រូវយកគិតចាប់ពីម៉ោង ១០ ព្រឹក រហូតដល់ម៉ោង ៣ រសៀល។

គ. វិធីប្រគល់.........

នៅពេលចាប់ផ្តើមការចូលជួបប្រាស្រ័យទាក់ទង ដើមចោទប្រគល់..........ឲ្យទៅចុងចម្លើយនៅទីកន្លែងប្រគល់ ហើយនៅពេលបញ្ចប់ការចូលជួបប្រាស្រ័យទាក់ទង ចុងម្លើយប្រគល់ ........... ឲ្យទៅដើមចោទនៅទីកន្លែងប្រគល់។ ទីកន្លែងប្រគល់ត្រូវកំណត់តាមការពិភាក្សាគ្នាដែលបានសម្រេចរវាងគូភាគី ប៉ុន្តែ ក្នុងករណីដែលការពិភាក្សាគ្នាមិនបានសម្រេចទេ ត្រូវធ្វើនៅប្រកចេញហាងកាហ្វេស្តាបាក់ ផ្សារទំនើបអ៊ីអន១។ [7]

ឃ. ថ្ងៃជំនួស

ក្នុងករណីដែលមិនអាចអនុវត្តនូវការចូលជួបប្រាស្រ័យទាក់ទងតាមកាលបរិច្ឆេទដែលបានកំណត់ដូចនៅក្នុងចំណុច ក ដោយសារតែស្ថានភាពដែលមិនអាចជៀសវាងបានដូចជា ជម្ងឺ ឬ កម្មវិធីសិក្សាថ្នាក់មត្តេយ្យ ឬ សាលារៀន ជាអាទិ៍ របស់............ គូភាគីទាំងសងខាងត្រូវ

---

7 ប្រសិនបើពិចារណាអំពីផលប្រយោជន៍របស់កូន គប្បីកំណត់យកទីកន្លែងដែលជិតគ្នានឹងទីកន្លែងស្នាក់នៅបច្ចុប្បន្នរបស់កូន ។ ប្រសិនបើកំណត់យកកន្លែងរៀងឆ្ងាយ នាំឲ្យកូនត្រូវតែទៅដល់កន្លែងនោះនៅពេលដែលចូលជួបប្រាស្រ័យទាក់ទង ដូច្នេះហើយវានឹងក្លាយទៅជាបន្ទុករបស់កូន។

**កំណត់ថ្ងៃជំនួសតាមការពិភាក្សាគ្នា។ ប៉ុន្តែ ក្នុងករណីដែលការពិភាក្សាគ្នារវាងគូភាគីមិនបាន សម្រេចទេ ត្រូវយកថ្ងៃសៅរ៍នៃសប្តាហ៍ទី ៣ ឬ ថ្ងៃសៅរ៍នៃសប្តាហ៍ទី ៤ បន្ទាប់។"**

（4） ការសម្រេចសេចក្តីទាក់ទងនឹងបន្ទុកលើសោហ៊ុយដែលចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន

ក. តើករណីបែបណាទើបចាំបាច់ត្រូវសម្រេចសេចក្តី?

ក្រោយលែងលះគ្នា ឪពុក ឬ ម្តាយដែលមិនមែនជាអ្នកមានអំណាចមេបាលើកូន មានករណីយកិច្ច ទទួលបន្ទុកលើសោហ៊ុយដែលចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន (កថាខណ្ឌទី ១ មាត្រា ១០៤០ នៃក្រម រដ្ឋប្បវេណី)។ ឪពុក ឬ ម្តាយ ដែលមានបំណងចង់លែងលះគ្នា ត្រូវពិភាក្សា និង កំណត់អំពីសោហ៊ុយ ចាំបាច់ដែលត្រូវទទួលបន្ទុកដើម្បីគ្រប់គ្រងថែរក្សាកូន (កថាខណ្ឌទី ២ មាត្រា ១០៤០ នៃក្រមរដ្ឋប្បវេណី)។ នៅពេលដែលការពិភាក្សាពុំបានសម្រេច ឬ នៅពេលដែលពុំអាចធ្វើការពិភាក្សាបានទេ តុលាការត្រូវ កំណត់អំពីបន្ទុកនៃសោហ៊ុយដែលចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន តាមការទាមទាររបស់ឪពុក ឬ ម្តាយ (កថាខណ្ឌទី ៤ មាត្រា ១០៤០ នៃក្រមរដ្ឋប្បវេណី)។

ដូច្នេះ ក្នុងករណីដែលមានការទាមទាររបស់ឪពុក ឬ ម្តាយ តុលាការត្រូវតែកំណត់អំពីបន្ទុកនៃ សោហ៊ុយដែលចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន។ ផ្ទុយមកវិញ ដរាបណាគ្មានការទាមទាររបស់ឪពុក ឬ ម្តាយទេ តុលាការមិនអាចកំណត់អំពីបន្ទុកនៃសោហ៊ុយដែលចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូនទេ។

ហេតុនេះ តើឪពុក ឬ ម្តាយអាចទាមទារបែបណាបាន?

- ដាក់ពាក្យសុំដោយផ្អែកតាមចំណុចលេខ ១៣ ផ្នែកទី ៤ ក្នុងតារាងឧបសម្ព័ន្ធ នៃច្បាប់ស្តីពីនិតិវិធី នៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង (មាត្រា ២៦ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណី ដែលមិនមែនជាបណ្តឹង)។

  ពាក្យសុំនេះ មិនចាំបាច់ដាក់ក្នុងពេលជាមួយគ្នានិងពាក្យសុំលែងលះឡើយ។ ចាំក្រោយពេល លែងលះ បើសិនជាកើតមានជុំវិញបន្ទុកនៃសោហ៊ុយដែលចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន រវាងឪពុក ឬ ម្តាយដែលជាអ្នកមានអំណាចមេបា និង មិនមែនជាអ្នកមានអំណាចមេបាលើកូន ចាំដាក់ពាក្យសុំ នេះ ក៏បានដែរ។
- ដាក់ពាក្យសុំឲ្យកំណត់អំពីរបៀបចូលជួបប្រាស្រ័យទាក់ទងទៅតុលាការក្នុងករណីដែលបណ្តឹង ទាមទារលែងលះកំពុងតែបន្តដំណើរការនីតិវិធី រហូតដល់ពេលបញ្ចប់ការទាញហេតុផលដោយផ្ទាល់ មាត់នៃបណ្តឹងនោះ។

  ដោយសារតែការកំណត់អំពីបន្ទុកនៃសោហ៊ុយដែលចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន គឺជា "ការ ចាត់ចែងទាក់ទងនឹងការបីបាច់រក្សាកូន" ហេតុនេះ តុលាការត្រូវតែសម្រេចសេចក្តីនៅពេលដែល មានពាក្យសុំរបស់ភាគី (កថាខណ្ឌទី ១ មាត្រា ២២ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈ បុគ្គល)។ ប្រសិនបើភាគីបានដាក់ពាក្យសុំឲ្យកំណត់អំពីបន្ទុកនៃសោហ៊ុយដែលចាំបាច់ដើម្បីគ្រប់គ្រង ថែរក្សាកូនទៅតុលាការក្នុងចន្លោះពេលមុនការបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៃបណ្តឹង

ទាមទារលែងលះគ្នា តុលាការនឹងត្រូវសម្រេចសេចក្តីអំពីពាក្យសុំនោះផងដែរ ដាក់នៅក្នុងសាលក្រម ឬ សាលដីកាដែលទទួលស្គាល់នូវការទាមទារលែងលះ (យោងមាត្រា ១២ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល)។

យ៉ាងណាមិញ ក្នុងករណីដែលភាគីមិនបានដាក់ពាក្យសុំនៅក្នុងចន្លោះពេលមុនការបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៃបណ្តឹងទាមទារលែងលះទេ ហើយនៅពេលដែលបញ្ហាជុំវិញបន្ទុកនៃសោហ៊ុយដែលចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូនបានកើតមានបញ្ហា ភាគីនឹងត្រូវដាក់ពាក្យសុំដោយផ្អែកតាមចំណុច ១៣ ផ្នែកទី ៤ ក្នុងតារាងឧបសម្ព័ន្ធ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង។

ខ. ចំណុចដែលត្រូវពិចារណានៅពេលដែលកំណត់អំពីបន្ទុកនៃសោហ៊ុយដែលចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន

ក្រោយលែងលះគ្នា មូលហេតុដែលនាំឲ្យឪពុក ឬ ម្តាយដែលមិនមែនជាអ្នកមានអំណាចមេបាលើកូន ត្រូវទទួលបន្ទុកនៃសោហ៊ុយដែលចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន (កថាខណ្ឌទី ៤ មាត្រា ១០៤០ នៃក្រមរដ្ឋប្បវេណី) គឺដើម្បីកុំឲ្យមានការកើតឡើងនូវការខាតបង់ប្រយោជន៍ដល់កូនដោយសារតែការលែងលះដែលជាស្ថានភាពរបស់ឪពុកម្តាយ ជាក់ស្តែងគឺ ដើម្បីឲ្យកូនអាចបន្តនូវស្តង់ដារជីវភាពដូចគ្នានឹងកម្រិតមុនពេលលែងលះ។ ហេតុនេះហើយ បើទោះបីជានៅពេលដែលលែងលះគ្នាគ្មានប្រាក់សន្សំក៏ដោយ ក៏ឪពុក ឬ ម្តាយដែលមិនមែនជាអ្នកមានអំណាចមេបាតាមរយៈការលែងលះ ត្រូវតែបំពេញឲ្យបាននូវចំនួនទឹកប្រាក់ដែលកន្លងមកឪពុក ឬ ម្តាយរូបនោះអាចបំពេញបានចំពោះការគ្រប់គ្រងថែរក្សាកូន ដើម្បីឲ្យទៅកូនបន្តទៀតទោះបីជានៅក្រោយពេលលែងលះក៏ដោយ ដូច្នេះហើយ ទើបចំណែកនៃទឹកប្រាក់នោះ ត្រូវក្លាយទៅជាករណីយកិច្ចរបស់ឪពុក ឬ ម្តាយរូបនោះដដែលត្រូវទទួលបន្ទុក។[8]

ដូច្នេះ <u>ចំពោះចំនួនទឹកប្រាក់នៃសោហ៊ុយដែលឪពុក ឬ ម្តាយដែលមិនមែនជាអ្នកមានអំណាចមេបាត្រូវទទួលបន្ទុក នឹងត្រូវគណនាដូចមានតទៅនេះ។ ជាដំបូង ត្រូវកំណត់ជាបណ្តោះអាសន្នសិនថា</u>

[8] នៅក្នុងការអនុវត្តជាក់ស្តែង មានការសង្កេតឃើញថា ភាគច្រើនមានរឿងក្តីដែលបង្គាប់ឲ្យយកប្រាក់សន្សំនៅពេលលែងលះដែលជាភាគរបស់ឪពុក ឬ ម្តាយដែលមិនមែនជាអ្នកមានអំណាចមេបា យកមកបង់ផ្តាច់ឲ្យអ្នកមានអំណាចមេបាធ្វើជាសោហ៊ុយដែលចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន។ ប៉ុន្តែ សោហ៊ុយដែលចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន គឺមិនកំណត់តែចំពោះចំនួនប្រាក់សន្សំដែលឪពុក ឬ ម្តាយមាននៅពេលលែងលះគ្នាប៉ុណ្ណោះទេ វាគឺជាប្រាក់ដែលត្រូវយកមកបង់ដើម្បីឲ្យកូននោះអាចបន្តជីវភាពដែលធ្លាប់បានមានកន្លងមក ឲ្យមានបន្តទៀតទោះបីជានៅក្រោយពេលលែងលះក៏ដោយ (ធ្វើយ៉ាងណាកុំឲ្យមានការទទួលរងនូវផលប៉ះពាល់ដល់កូនដោយសារតែការលែងលះគ្នារបស់ឪពុកម្តាយ)។ ដូច្នេះ ទឹកប្រាក់ដែលឪពុក ឬ ម្តាយដែលមិនមែនជាអ្នកមានអំណាចមេបាត្រូវទទួលបន្ទុក គឺចាំបាច់ត្រូវមានការគណនាដោយយកភាគរយពីក្នុងចំនួននៃប្រាក់ចំណូលរបស់ឪពុក ឬ ម្តាយក៏ដែលបានប្រើប្រាស់ចំពោះកូនកន្លងមកនេះ មកធ្វើជាមូលដ្ឋាន។ ការគណនាដោយយកមូលដ្ឋាននៃប្រាក់សន្សំដែលឪពុកម្តាយមាននៅពេលលែងលះ គឺជាការយល់ច្រឡំ។ ដោយសារតែឪពុក ឬ ម្តាយដែលមិនមែនជាអ្នកមានអំណាចមេបាមានករណីយកិច្ចទទួលបន្ទុកនូវសោហ៊ុយដែលចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូនទោះបីជាមាន ឬ គ្មានប្រាក់សន្សំនៅពេលដែលធ្វើការលែងលះក៏ដោយ ហេតុនេះហើយ តុលាការត្រូវបង្គាប់ឲ្យធ្វើការបង់ប្រាក់ដោយទៀងទាត់ (មួយខែម្តង) សម្រាប់នាពេលអនាគត មិនមែនបង្គាប់ឲ្យបង់ផ្តាច់នោះទេ។ យ៉ាងណាមិញ ចំពោះវិធីនៃការបង់ប្រាក់ សូមយោងតាម Footnote １０ ផងដែរ។

ឪពុក ឬ ម្ដាយដែលមិនមែនជាអ្នកមានអំណាចមេបាកំពុងតែរស់នៅរួមគ្នាជាមួយកូនបន្តទៀតទោះបីជាក្រោយពេលលែងលះក៏ដោយ នៅពេលនោះ ត្រូវយកចំនួនសរុបនៃប្រាក់ចំណូលរបស់ខ្លួន ដែលបានបូកនិងប្រាក់ចំណូលរបស់ឪពុក ឬ ម្ដាយម្ខាងទៀត ហើយគណនារកចំនួនទឹកប្រាក់ប៉ុន្មានដែលបានចំណាយសម្រាប់កូន? ម្យ៉ាងទៀត ប្រសិនបើរក្សាបាននូវចំនួនទឹកប្រាក់ដែលដូចបានគណនានោះនឹងមានភាពប្រសើរសម្រាប់កូនទោះបីជានៅក្រោយពេលលែងលះក៏ដោយ ហេតុនេះ ចំនួនទឹកប្រាក់ដដែលនោះនឹងត្រូវយកមកបែងចែងគ្នាធៀបទៅនឹងភាគរយនៃប្រាក់ចំណូលរបស់ ឪពុក ឬ ម្ដាយ ដែលជាអ្នកមានអំណាចមេបា និង មិនមែនជាអ្នកមានអំណាចមេបា។

បន្ទុកនៃសោហ៊ុយដែលចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន ត្រូវពិចារណាទៅលើ "ស្ថានភាពនៃជីវភាព និង ស្ថានភាពសេដ្ឋកិច្ចរបស់ឪពុកម្ដាយ" (កថាខណ្ឌទី ៦ មាត្រា ១០៤០ នៃក្រមរដ្ឋប្បវេណី) គឺសំដៅទៅលើខ្លឹមសារដូចខាងលើនេះ។

ម្យ៉ាងទៀត នៅក្នុងសាលក្រម ឬ សាលដីកាដែលទទួលស្គាល់នូវការទាមទារលែងលះ តុលាការអាចបង្គាប់អំពីការបង់ប្រាក់បាន (កថាខណ្ឌទី ២ មាត្រា ២២ នៃច្បាប់ស្ដីពីនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល)។ នៅក្នុងករណីដែលតុលាការចេញដីកាសម្រេចដោយផ្អែកតាមច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹងក៏ដោយ ក៏អាចចេញដីកាសម្រេចដោយបង្គាប់ឲ្យបង់ប្រាក់បានផងដែរ (យោង មាត្រា ៣៨ច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង)។ ម្យ៉ាងទៀត ក្នុងករណីដែលតុលាការបង្គាប់អំពីតាវកាលិកទាំងនេះ ហើយក្រោយមកបានចូលជាស្ថាពរ នាំឲ្យតាវកាលិកទាំងអស់នោះនឹងក្លាយទៅជាលិខិតអនុវត្ត (ចំណុច ក ឬ ចំណុច គ កថាខណ្ឌទី ២ មាត្រា ៣៥០ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

ក្នុងករណីដែលភាគីមិនបង់នូវបន្ទុកនៃសោហ៊ុយដែលចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូនដែលតុលាការបានបង្គាប់ទេ នឹងត្រូវយកទៅធ្វើជា "ការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារដែលមានគោលបំណងឲ្យសងជាប្រាក់" (ជំពូកទី ២ គន្ថីទី ៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

បន្ថែមពីនេះ ក្នុងករណីដែលមានការខកខាននូវបន្ទុកនៃសោហ៊ុយដែលចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូនដែលតុលាការបានបង្គាប់នៅក្នុងសាលក្រម ឬ សាលដីកាដែលទទួលស្គាល់នូវការទាមទារលែងលះ ប្រសិនបើយល់ឃើញថា មានភាពសមរម្យ តុលាការដែលបានចេញការបង្គាប់នោះ អាចចេញដីកាសម្រេចបង្គាប់ឲ្យអ្នកមានករណីយកិច្ច (ឪពុក ឬ ម្ដាយដែលមិនមែនជាអ្នកមានអំណាចមេបាលើកូន) អនុវត្តករណីយកិច្ចនោះ ដោយកំណត់អំឡុងពេលសមរម្យមួយ តាមពាក្យសុំរបស់អ្នកមានសិទ្ធិបាន (អ្នកមានអំណាចមេបាលើកូន) (កថាខណ្ឌទី ១ មាត្រា ២៣ នៃច្បាប់ស្ដីពីនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល)។ បើអ្នកមានករណីយកិច្ចមិនអនុវត្តតាមការបង្គាប់នេះដោយគ្មានមូលហេតុត្រឹមត្រូវទេ តុលាការអាចបង្គាប់ឲ្យពិន័យជាប្រាក់មិនលើសពី ១.០០០.០០០ (មួយលាន) រៀល ដោយដីកាសម្រេចបាន (កថាខណ្ឌទី ៣ មាត្រា ២៣ នៃច្បាប់ស្ដីពីនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល)។

យ៉ាងណាមិញ ប្រសិនបើប្រាក់ចំណូលរបស់ភាគីមានភាពប្រែប្រួល ចំនួនទឹកប្រាក់ដែលចំណាយដើម្បីកូន ដែលឆ្លើយតបទៅនឹងការលូតលាស់របស់កូនក៏នឹងមានភាពប្រែប្រួលផងដែរ។ ក្នុងករណីដែលកើតមាននូវភាពចាំបាច់ដែលត្រូវកែត្រូវនូវចំនួនទឹកប្រាក់នៃសោហ៊ុយដែលចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូនដែលបានការកំណត់ម្តងរួចហើយ ភាគីអាចសុំទៅតុលាការឲ្យផ្លាស់ប្តូរនូវបន្ទុកនៃសោហ៊ុយដែលចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន តាមរយៈការទាមទារ (កថាខណ្ឌទី ៥ មាត្រា ១០៤០ នៃក្រមរដ្ឋប្បវេណី)។ ក្នុងករណីនេះ ភាគីដែលសុំឲ្យផ្លាស់ប្តូរនឹងត្រូវដាក់ពាក្យសុំផ្អែកតាមចំណុច ១៣ ផ្នែកទី ៤ ក្នុងតារាងឧបសម្ព័ន្ធ នៃច្បាប់ស្តីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង។

គ. របៀបសរសេរសេចក្តីសម្រេចបញ្ចប់កំណត់អំពីបន្ទុកនៃសោហ៊ុយដែលចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន

・ករណីពាក្យសុំដោយផ្អែកតាមចំណុច ១៣ ផ្នែកទី ៤ ក្នុងតារាងឧបសម្ព័ន្ធ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង

**“បង្គាប់ឲ្យភាគីម្ខាងទៀត (ឬ អ្នកដាក់ពាក្យសុំ) បង់ប្រាក់ចំនួន .........រៀលក្នុង១ខែ [9]គិតត្រឹមថ្ងៃចុងក្រោយជារៀងរាល់ខែ ក្នុងអំឡុងពេលគិតចាប់ពីថ្ងៃដែលសាលក្រមនេះបានចូលជាស្ថាពរ រហូតដល់.......... ដែលជាកូនរវាងអ្នកដាក់ពាក្យសុំ និង ភាគីម្ខាងទៀត (កើតថ្ងៃទី... ខែ... ឆ្នាំ...)[10] ក្លាយទៅជានីតិជន ឲ្យទៅអ្នកដាក់ពាក្យសុំ (ឬ ភាគីម្ខាងទៀត)។”**

・ករណីដាក់ពាក្យសុំក្នុងការបន្តដំណើរការនីតិវិធីនៃបណ្តឹងទាមទារលែងលះ

**“បង្គាប់ឲ្យចុងចម្លើយ (ឬ ដើមចោទ) បង់ប្រាក់ចំនួន .........រៀលក្នុង១ខែ [11] គិតត្រឹមថ្ងៃចុងក្រោយជារៀងរាល់ខែ ក្នុងអំឡុងពេលគិតចាប់ពីថ្ងៃដែលសាលក្រមនេះបានចូលជាស្ថាពរ រហូតដល់ .......... ដែលជាកូនរវាងដើមចោទ និង ចុងចម្លើយ (កើតថ្ងៃទី... ខែ... ឆ្នាំ...)[12] ក្លាយទៅជានីតិជន ឲ្យ**

---

[9] ចំពោះការកំណត់តាមខែអំពីសោហ៊ុយដែលចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន មិនមានបទប្បញ្ញត្តិចែងក្នុងក្រមរដ្ឋប្បវេណីទេ។ ដូច្នេះហើយ មិនមែនមានន័យថា ការកំណត់វិធីផ្សេងក្រៅពីការបង់តាមខែ គឺជាវិធីដែលខុសទេ។

ប៉ុន្តែ មូលហេតុដែលឪពុក ឬ ម្តាយដែលមិនមែនជាអ្នកមានអំណាចមេបាមានករណីយកិច្ចទទួលបន្ទុកនៃសោហ៊ុយដែលចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន គឺធ្វើឡើងដើម្បីរក្សាឲ្យបាននូវស្តង់ដារជីវភាពរបស់កូនឲ្យនៅកម្រិតដដែលទោះបីជានៅក្រោយពេលលែងលះក៏ដោយ (យោង 4 (4) ចំណុច ខ) ។ ចំពោះសោហ៊ុយដែលចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន នឹងត្រូវបានបង់ពីឪពុក ឬ ម្តាយដែលមិនមែនជាអ្នកមានអំណាចមេបាឲ្យទៅអ្នកមានអំណាចមេបា ប៉ុន្តែ ការកំណត់វិធីបង់ដែលផ្ទុយទៅគោលបំណងក្នុងការរក្សាឲ្យបាននូវស្តង់ដារជីវភាពរបស់កូន នឹងមិនត្រូវបានអនុញ្ញាតឡើយ។ ដូច្នេះ ឧទាហរណ៍ថា តុលាការបានគណនាសោហ៊ុយដែលត្រូវចំណាយរហូតដល់កូនក្លាយទៅជានីតិជន ហើយបង្គាប់ឲ្យបង់នូវចំនួនទឹកប្រាក់នោះសរុបផ្តាច់តែម្តង នោះនឹងមានការព្រួយបារម្ភខ្លាចថា អ្នកមានអំណាចមេបាលើកូននឹងមិនយកទឹកប្រាក់ទាំងអស់នោះមកចំណាយចំពោះកូនទេ (បារម្ភខ្លាចថា បែរជាមានការយកមួយផ្នែកទៅប្រើសម្រាប់ខ្លួនឯង) ដូច្នេះហើយ ការបង់ផ្តាច់នេះ អាចនិយាយបានថា មិនត្រឹមត្រូវទេ។

[10] កាលបរិច្ឆេទបញ្ចប់នូវការបង់ប្រាក់នឹងមានភាពច្បាស់លាស់ តាមរយៈការសរសេរអំពីថ្ងៃខែឆ្នាំកំណើតរបស់កូន។

[11] យោង Footnote 9។

[12] យោង Footnote 10។

**ទៅដើមចោទ (ឬ ចុងចម្លើយ)។"**

(5) ការបែងចែកទ្រព្យសម្បត្តិ

ក. តើករណីបែបណាទើបចាំបាច់ត្រូវសម្រេចសេចក្តី?

ក្នុងករណីដែលប្តីប្រពន្ធលែងលះគ្នា ត្រូវបែងចែកទ្រព្យសម្បត្តិដោយយុត្តិធម៌ផ្អែកតាមការពិភាក្សារបស់ភាគីទាំងសងខាង (កថាខណ្ឌទី ១ មាត្រា ៩៨០ នៃក្រមរដ្ឋប្បវេណី)។ ក្នុងករណីដែលមិនអាចពិភាក្សាគ្នារវាងប្តីប្រពន្ធបានទេ ត្រូវបែងចែកទ្រព្យសម្បត្តិទៅតាមចំណុចនីមួយៗនៃកថាខណ្ឌទី ២ មាត្រា ៩៨០ នៃក្រមរដ្ឋប្បវេណី (កថាខណ្ឌទី ២ មាត្រា ៩៨០ នៃក្រមរដ្ឋប្បវេណី)។

ហេតុនេះនៅក្នុងករណីដែលប្តីប្រពន្ធមិនអាចពិភាក្សាគ្នាបាន តើគួរប្រើនីតិវិធីបែបណាទើបជាការប្រសើរ?

- ដាក់ពាក្យសុំដោយផ្អែកតាមចំណុច ៦ ផ្នែកទី ៤ ក្នុងតារាងឧបសម្ព័ន្ធ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង (មាត្រា ២៦ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង)។

  ពាក្យសុំនេះ មិនចាំបាច់ដាក់ក្នុងពេលជាមួយគ្នានិងពាក្យសុំលែងលះឡើយ។ ទោះបីជានៅក្រោយពេលលែងលះក៏ដោយ ក្នុងករណីដែលភាគីជាប្តី និង ភាគីជាប្រពន្ធមិនអាចពិភាក្សាគ្នាអំពីការបែងចែកទ្រព្យសម្បត្តិ គឺអាចដាក់ពាក្យសុំបាន។

- ដាក់ពាក្យសុំឲ្យតុលាការបែងចែកទ្រព្យសម្បត្តិ ក្នុងករណីដែលបណ្តឹងទាមទារលែងលះកំពុងតែបន្តដំណើរការនីតិវិធី ហើយនៅក្នុងចន្លោះពេលគិតត្រឹមពេលបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៃនីតិវិធីនោះ (កថាខណ្ឌទី ១ មាត្រា ២២ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល)។ បើសិនជាភាគីម្ខាងបានដាក់ពាក្យសុំឲ្យតុលាការបែងចែកទ្រព្យសម្បត្តិនៅក្នុងចន្លោះពេលគិតត្រឹមពេលបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ តុលាការនឹងត្រូវសម្រេចសេចក្តីទៅលើពាក្យសុំនោះផងដែរ ដាក់នៅក្នុងសាលក្រម ឬ សាលដីកាដែលទទួលស្គាល់នូវការទាមទារលែងលះ (យោងមាត្រា ១២ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល)។

  យ៉ាងណាមិញ ក្នុងករណីដែលភាគីមិនបានដាក់ពាក្យសុំនៅក្នុងចន្លោះពេលគិតត្រឹមពេលបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៃបណ្តឹងទាមទារលែងលះទេ គឺត្រូវដាក់ពាក្យសុំនៅពេលដែលភាគីមិនអាចពិភាក្សាគ្នាអំពីការបែងចែកទ្រព្យសម្បត្តិ ដោយផ្អែកតាមចំណុច ៦ ផ្នែកទី ៤ ឧបសម្ព័ន្ធនៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ។

ខ. ចំណុចដែលតុលាការពិចារណានៅពេលដែលបែងចែកទ្រព្យសម្បត្តិ

ជាដំបូង សហព័ទ្ធនីមួយៗ ត្រូវទទួលបាននូវទ្រព្យសម្បត្តិដោយឡែកដែលបានកំណត់នៅក្នុងមាត្រា ៩៧២ នៃក្រមរដ្ឋប្បវេណី (ចំណុច ក កថាខណ្ឌទី ២ មាត្រា ៩៨០ នៃក្រមរដ្ឋប្បវេណី)។

បន្ទាប់មកទៀត សហព័ទ្ធនីមួយៗ មានសិទ្ធិទទួលយក ១ ភាគ ២ នៃទ្រព្យសម្បត្តិរួម។ ប៉ុន្តែ បើ

មានករណីពិសេស និង មានការទាមទាររបស់ប្ដីប្រពន្ធណាម្ខាង តុលាការក៏អាចបែងចែកទ្រព្យសម្បត្តិរួមដោយពិចារណាទៅលើស្ថានភាពផ្សេងៗ ដូចជា ទំហំនៃការបរិច្ចាគរបស់ភាគីនីមួយៗ ទំហំនៃការបរិច្ចាគរបស់ភាគីនីមួយៗចំពោះលទ្ធកម្មនៃទ្រព្យសម្បត្តិ ការថែរក្សា ឬ ការបង្កើនទ្រព្យ អំឡុងពេលអាពាហ៍ពិពាហ៍ កម្រិតជីវភាពរស់នៅនៅមុនពេលមានចំណងអាពាហ៍ពិពាហ៍ អាយុ ស្ថានភាពផ្លូវចិត្ត និងផ្លូវកាយ វិជ្ជាជីវៈ ប្រាក់ចំណូល លទ្ធភាពធ្វើការងាររបស់ភាគីនីមួយៗ និង ផលប្រយោជន៍របស់កូនជាអាទិ៍។ គេហកិច្ច ត្រូវចាត់ទុកថាមានតម្លៃស្មើនឹងការងារដែលធ្វើក្រៅផ្ទះដែរ។ (ចំណុច ខ កថាខណ្ឌទី២ និង កថាខណ្ឌទី ៣ មាត្រា ៩៨០ នៃក្រមរដ្ឋប្បវេណី)

→ទ្រព្យសម្បត្តិរបស់ប្ដីប្រពន្ធមាន ទ្រព្យសម្បត្តិដោយឡែក និង ទ្រព្យសម្បត្តិរួម (មាត្រា ៩៧២ និង មាត្រា ៩៧៣ នៃក្រមរដ្ឋប្បវេណី) ប៉ុន្តែ ចំពោះទ្រព្យសម្បត្តិដែលនឹងត្រូវក្លាយជាកម្មវត្ថុក្នុងករណីដែលតុលាការបែងចែក គឺទ្រព្យសម្បត្តិរួម។

★ ចំណុចសំខាន់

① លទ្ធផលដែលបានមកពីបែងចែកទ្រព្យសម្បត្តិ ទ្រព្យសម្បត្តិដែលទទួលបាន គឺ "សហព័ទ្ធនីមួយៗ" (ចំណុច ក និង ចំណុច ខ មាត្រា ៩៨០ នៃក្រមរដ្ឋប្បវេណី)។ តតិយជនក្រៅពីសហព័ទ្ធនីមួយៗ (ឧទាហរណ៍ កូនរបស់ប្ដីប្រពន្ធ) មិនអាចទទួលបានទ្រព្យសម្បត្តិតាមរយៈការបែងចេកទ្រព្យសម្បត្តិបានទេ។

ប្រាកដណាស់ ប្ដីប្រពន្ធ អាចប្រទានកម្មទ្រព្យសម្បត្តិរួមរបស់ប្ដីប្រពន្ធទៅឲ្យកូនបាន ដោយមានការព្រមព្រៀងគ្នាទាំងសងខាង (កថាខណ្ឌទី ១ មាត្រា ៩៧៦ នៃក្រមរដ្ឋប្បវេណី)។ ប៉ុន្តែ ក្នុងករណីដែល បានប្រទានកម្មទ្រព្យសម្បត្តិទៅឲ្យកូន ទ្រព្យសម្បត្តិនោះលែងជាទ្រព្យសម្បត្តិរួមរបស់ប្ដីប្រពន្ធទៀតហើយ (ក្លាយជាទ្រព្យសម្បត្តិរបស់កូន) ហេតុនេះ វាមិនមែនជាកម្មវត្ថុនៃការបែងចែកទ្រព្យសម្បត្តិទៀតទេ។

② មិនអាចបែងចែកកាតព្វកិច្ចដោយសាមគ្គីភាពរបស់ប្ដីប្រពន្ធតែរវាងប្ដីប្រពន្ធទេ។

យោងតាមកថាខណ្ឌទី ១ មាត្រា ៩២១ នៃក្រមរដ្ឋប្បវេណី ក្នុងករណីដែលបុគ្គលច្រើននាក់ទទួលបន្ទុកនូវកាតព្វកិច្ចសាមគ្គីភាព ម្ចាស់បំណុលអាចទាមទារឲ្យកូនបំណុលណាម្នាក់ អនុវត្តកាតព្វកិច្ចទាំងអស់ ឬ មួយភាគ ដោយព្រមគ្នា ឬ ដោយបន្តបន្ទាប់។ ដូច្នេះ ម្ចាស់បំណុលកាតព្វកិច្ចដោយសាមគ្គីភាពរបស់ប្ដីប្រពន្ធ (ឧទាហរណ៍ ធនាគារ) អាចទាមទារឲ្យទាំងប្ដីទាំងប្រពន្ធ អនុវត្តទាំងអស់បាន។ ទោះបីជា យ៉ាងណាក៏ដោយ ប្រសិនបើកាតព្វកិច្ចរវាងតែប្ដីប្រពន្ធបែងចែកក្នុងម្នាក់១ ភាគ ២ នឹងនាំឲ្យបំពានផលប្រយោជន៍ របស់ម្ចាស់បំណុល (ផលប្រយោជន៍ដែលអាចទាមទារឲ្យទាំងប្ដីទាំងប្រពន្ធ អនុវត្តទាំងអស់ (២ ភាគ ២))។ នៅក្នុងអំឡុងពេលនីតិវិធីដែលម្ចាស់បំណុលមិនពាក់ព័ន្ធ (នីតិវិធីដែលមានតែប្ដី និង ប្រពន្ធ) កូនបំណុល (ប្ដីនិងប្រពន្ធ) មិនអាចបែងចែកកាតព្វកិច្ចតាមអំពើចិត្តបានទេ។

គ. ការញែកទ្រព្យសម្បត្តិដោយឡែក និង ទ្រព្យសម្បត្តិរួម

ក្នុងករណីដែលភាគីបានដាក់ពាក្យសុំមកតុលាការឲ្យបែងចែកទ្រព្យសម្បត្តិ ជាដំបូង តុលាការត្រូវធ្វើការវែកញែកថា ទ្រព្យសម្បត្តិដែលភាគីកំពុងតែទាមទារឲ្យបែងចែក គឺជាទ្រព្យសម្បត្តិដោយឡែក ឬ ជាទ្រព្យសម្បត្តិរួម។ មូលហេតុ គឺដោយសារតែទ្រព្យសម្បត្តិដែលតុលាការនឹងយកមកបែងចែក គឺទ្រព្យសម្បត្តិរួម ។

ក្នុងករណីដែលគូភាគីមានវិវាទគ្នាទៅអំពីទ្រព្យសម្បត្តិណាមួយជាទ្រព្យសម្បត្តិដោយឡែក ហើយទ្រព្យសម្បត្តិណាមួយជាទ្រព្យសម្បត្តិរួមនោះ នាំឲ្យមានការយល់ឃើញថា បើភាគីដែលអះអាងថា ទ្រព្យសម្បត្តិនោះគឺជាទ្រព្យសម្បត្តិដោយឡែក ភាគីនោះត្រូវទទួលបន្ទុកនៅក្នុងការបញ្ជាក់ភស្តុតាងអំពីទ្រព្យសម្បត្តិនោះ។ ព្រោះ **ទ្រព្យសម្បត្តិដែលទទួលបានក្នុងអំឡុងពេលអាពាហ៍ពិពាហ៍** ជាគោលការណ៍ គឺជាទ្រព្យសម្បត្តិរួម (មាត្រា៩៧៣ នៃក្រមរដ្ឋប្បវេណី)។

"មាត្រា ៩៧២"

ទ្រព្យសម្បត្តិដែលកំណត់ដូចខាងក្រោមនេះ គឺជាទ្រព្យសម្បត្តិដោយឡែក ដែលស្ថិតក្រោមកម្មសិទ្ធិរបស់សហព័ទ្ធណាម្នាក់ ៖

ក- ទ្រព្យសម្បត្តិដែលសហព័ទ្ធមាន នៅមុនពេលអាពាហ៍ពិពាហ៍។

ខ- ទ្រព្យសម្បត្តិដែលសហព័ទ្ធទទួលបាន ដោយប្រទានកម្ម សន្តតិកម្ម អច្ច័យទាន នៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍។

គ- ទ្រព្យសម្បត្តិជាតម្លៃតប ដែលទទួលបានពីការចាត់ចែងទ្រព្យសម្បត្តិដែលបានកំណត់នៅក្នុងចំណុច ក និង ចំណុច ខ ខាងលើនេះ។

"មាត្រា ៩៧៣"

ទ្រព្យសម្បត្តិរួម គឺជាទ្រព្យសម្បត្តិទាំងឡាយដែលប្តីប្រពន្ធទាំងសងខាង ឬ តែម្ខាងទទួលបាននៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ លើកលែងតែទ្រព្យសម្បត្តិដែលកំណត់នៅក្នុងចំណុច ខ និង ចំណុច គ នៃមាត្រា ៩៧២។

ឃ. វិធីបែងចែកទ្រព្យសម្បត្តិ

តុលាការនឹងធ្វើការបែងចែកទ្រព្យសម្បត្តិរួមនៅពេលដែលមានពាក្យសុំរបស់ភាគី។

ប្រសិនបើមានការអះអាងពីភាគី តុលាការអាចពិចារណាអំពីស្ថានភាពដែលបានកំណត់នៅក្នុងវាក្យខណ្ឌទី ២ ចំណុច ខ កថាខណ្ឌទី ២ មាត្រា ៩៨០ នៃក្រមរដ្ឋប្បវេណី ហើយអាចមិនធ្វើការបែងចែកឲ្យម្នាក់ៗត្រូវតែទទួលបាន ១ ភាគ ២ នោះឡើយ។

ប៉ុន្តែ បើទោះបីជាតុលាការធ្វើការបែងចែកដោយភាគបែបណាក៏ដោយ ក៏ភាពចាំបាច់ដំបូងគឺត្រូវតែរកឲ្យឃើញអំពីតម្លៃសរុបទាំងអស់នៃទ្រព្យសម្បត្តិរួម ដែលនឹងត្រូវក្លាយទៅជាកម្មវត្ថុនៃការបែងចែក។ ដូច្នេះ បន្ទាប់ពីបានរកឃើញតម្លៃសរុបទាំងអស់រួចហើយ តុលាការនឹងត្រូវបែងចែកទ្រព្យសម្បត្តិមួយៗ ឲ្យទៅប្តី ឬ ប្រពន្ធ ស្របទៅតាមភាគនៃការបែងចែក។

ឧទាហរណ៍ ៖ ប្រសិនបើទ្រព្យសម្បត្តិរួមមានតែអចលនវត្ថុ ១ ប៉ុណ្ណោះ ហើយពុំមានបញ្ហាចំពោះភាគនៃការបែងចែកដោយចំណែក ១ ភាគ ២ ទេ នាំឲ្យតុលាការចាំបាច់ត្រូវបែងចែកទ្រព្យសម្បត្តិរួមនោះ ដោយចំណែក ១ ភាគ ២ របស់ប្តី និង ចំណែក ១ ភាគ ២ របស់ប្រពន្ធ គឺជាកម្មសិទ្ធិអវិភាគ (មាត្រា ២០២ នៃក្រមរដ្ឋប្បវេណី)។ ក្នុងករណីដែលទ្រព្យសម្បត្តិគឺជាទ្រព្យសម្បត្តិរួម ប្តី ឬ ប្រពន្ធតែម្ខាង មិនអាចចាត់ចែងតែម្នាក់ឯងបានទេ (កថាខណ្ឌទី ១ មាត្រា ៩៧៦ នៃក្រមរដ្ឋប្បវេណី) ប៉ុន្តែ ប្តី ឬ ប្រពន្ធតែម្ខាងនោះអាចចាត់ចែងចំណែករបស់ខ្លួនតែម្នាក់ឯងបាន ដោយធ្វើឲ្យទ្រព្យសម្បត្តិនោះក្លាយទៅជាទ្រព្យសម្បត្តិនៃកម្មសិទ្ធិអវិភាគ (មាត្រា ២០៤ នៃក្រមរដ្ឋប្បវេណី) តាមរយៈការបែងចែកទ្រព្យសម្បត្តិ។ ដូច្នេះ តុលាការចាំបាច់ត្រូវធ្វើការផ្លាស់ប្តូរពីទ្រព្យសម្បត្តិរួមប្តីប្រពន្ធឲ្យក្លាយទៅជាទ្រព្យសម្បត្តិនៃកម្មសិទ្ធិអវិភាគនៃបទប្បញ្ញត្តិសិទ្ធិប្រត្យក្សតាមរយៈការបែងចែកទ្រព្យសម្បត្តិ។

ផ្ទុយមកវិញ ឧទាហរណ៍ថា ក្នុងករណីដែលមានអចលនវត្ថុចំនួន ២ គឺជាទ្រព្យសម្បត្តិរួម ហើយពុំមានបញ្ហាចំពោះភាគនៃការបែងចែកដោយចំណែក ១ ភាគ ២ ទេ ហើយប្រសិនបើតម្លៃនៃអចលនវត្ថុមានចំនួនដូចគ្នា គឺតុលាការអាចបែងចែកដោយឲ្យអចលនវត្ថុមួយជាកម្មសិទ្ធិរបស់ប្តី ហើយឲ្យអចលនវត្ថុមួយជាកម្មសិទ្ធិរបស់ប្រពន្ធបាន។ ក្នុងករណីដែលតម្លៃនៃអចលនវត្ថុទាំង ២ មានចំនួនខុសគ្នា តុលាការក៏អាចឲ្យប្តី និង ប្រពន្ធមានកម្មសិទ្ធិអវិភាគក្នុងចំណែក ១ ភាគ ២ ទៅលើអចលនវត្ថុនីមួយៗបានផងដែរ (មាត្រា ២០២ នៃក្រមរដ្ឋប្បវេណី)។ ម្យ៉ាងវិញទៀត តុលាការក៏អាចប្រើប្រាស់វិធីបែងចែកដោយឲ្យអចលនវត្ថុមួយជាកម្មសិទ្ធិរបស់ប្តី ហើយឲ្យអលចនវត្ថុមួយទៀតជាកម្មសិទ្ធិរបស់ប្រពន្ធ ហើយឲ្យអ្នកទទួលបានអចលនវត្ថុដែលមានតម្លៃថ្លៃបង់ប្រាក់នូវចំនួនដែលខុសគ្នានោះ ឲ្យទៅអ្នកដែលទទួលបានអចលនវត្ថុដែលមានតម្លៃថោកក៏បានដែរ។ មូលហេតុនេះ គឺដោយសារតែ វិធីបែងចែកបែបនេះ ក៏ធ្វើឲ្យតម្លៃដែលភាគីនីមួយៗទទួលបានក្នុងម្នាក់ៗ ១ ភាគ ២ ដែរ។ តុលាការចាំបាច់ត្រូវតែពិចារណាថា តើការបែងចែកដោយវិធីណាមួយទើបជាការប្រសើរ ដោយគិតទាំងវិធីបែងចែកដែលភាគីបានអះអាងផងដែរ។

ង. របៀបសរសេរអំពីសេចក្តីសម្រេចបញ្ចប់នៃការបែងចែកទ្រព្យសម្បត្តិ

ចំពោះទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធទាំងអស់ តុលាការត្រូវធ្វើការកំណត់ឲ្យជាក់លាក់ចំពោះទ្រព្យសម្បត្តិនីមួយៗ ហើយចាំបាច់ត្រូវសរសេរអំពី ទ្រព្យសម្បត្តិនីមួយៗ ដោយញែកដាច់មួយៗ ឲ្យទៅជាកម្មសិទ្ធិរបស់ប្តី ឬ ប្រពន្ធ (ក្នុងករណីដែលធ្វើឲ្យទ្រព្យសម្បត្តិណាមួយទៅជាកម្មសិទ្ធិអវិភាគ គឺត្រូវកំណត់អំពីចំណែករបស់ប្តីប្រពន្ធម្នាក់ៗ)។

ក្នុងករណីដែលតុលាការមិនបានកំណត់ជាក់លាក់ចំពោះទ្រព្យសម្បត្តិ នឹងនាំឲ្យភាគីមិនអាចធ្វើនីតិវិធីចុះបញ្ជីលើអចលនវត្ថុ ឬ នីតិវិធីចុះបញ្ជីលើរថយន្ត ឬ ម៉ូតូបានទេ។ នៅក្នុងសេចក្ដីសម្រេចបញ្ចប់ចាំបាច់ត្រូវតែសរសេរឲ្យបានត្រឹមត្រូវអំពីការកត់ត្រាដែលមាននៅក្នុងសៀវភៅគោលបញ្ជី ឬ នៅក្នុងប័ណ្ណសំគាល់ ចំពោះទ្រព្យសម្បត្តិរួមទាំងអស់។

ឧទាហរណ៍៖ ក្នុងករណីដែលមានពាក្យសុំបែងចែកទ្រព្យសម្បត្តិពីភាគី នៅក្នុងនីតិវិធីនៃបណ្ដឹងទាមទារលែងលះ បើតុលាការទទួលស្គាល់នូវការទាមទារលែងលះ គឺត្រូវសរសេរសេចក្ដីសម្រេចបញ្ចប់អំពីការបែងចែកទ្រព្យសម្បត្តិ។

ក្នុងករណីដែលជាពាក្យសុំដោយផ្អែកតាមចំណុច ៦ ផ្នែកទី ៤ ឧបសម្ព័ន្ធនៃច្បាប់ស្ដីពីរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង សេចក្ដីសម្រេចបញ្ចប់នៃដីកាសម្រេចចាំបាច់ត្រូវសរសេរដោយប្ដូរពាក្យពី "ដើមចោទ" ទៅជា "អ្នកដាក់ពាក្យសុំ" ហើយ "ចុងចម្លើយ" ទៅជា "ភាគីម្ខាងទៀត"។

យ៉ាងណាមិញ ចំពោះឧទាហរណ៍ខាងក្រោមនេះ សូមកំណត់ថា ទ្រព្យសម្បត្តិរួមមានដូចជាអចលនវត្ថុ ១ កន្លែង រថយន្ត ១ គ្រឿង លុយនៅសន្សំនៅធនាគារ ១ គណនី។

**" បែងចែកទ្រព្យសម្បត្តិនីមួយៗដែលបានកត់ត្រានៅក្នុង "បញ្ជីទ្រព្យសម្បត្តិរួម" នៃឧបសម្ព័ន្ធដូចតទៅ៖**

**ក. ដីលេខ ១. ដែលបានកត់ត្រានៅក្នុង"បញ្ជីទ្រព្យសម្បត្តិរួម" នៃឧបសម្ព័ន្ធ ជាកម្មសិទ្ធិរបស់ ដើមចោទ។ / ជាកម្មសិទ្ធិអវិភាគរវាងដើមចោទ និង ចុងចម្លើយ ដោយដើមចោទមានចំណែក......ភាគ..... ហើយចុងចម្លើយមានចំណែក......ភាគ.....។** [13]

---

[13] នៅក្នុងសេចក្ដីសម្រេចបញ្ចប់នេះ បានធ្វើការកំណត់ជាមុនថា នៅក្នុងសៀវភៅគោលបញ្ជី ដីនេះត្រូវបានចុះបញ្ជីជា " ទ្រព្យសម្បត្តិរួមប្ដីប្រពន្ធ" ។ ក្នុងករណីនេះ ប្រសិនបើសាលក្រម ឬ សាលដីកានេះបានចូលជាស្ថាពរ គេយល់ថា ភាគីអាចដាក់ពាក្យសុំចុះបញ្ជីតែម្នាក់ឯងបាន (អាចគិតដូចគ្នាទៅនឹង "ការផ្ទេរសិទ្ធិដោយសារសន្តតិកម្ម" នៃកថាខណ្ឌទី ២ ប្រការ ១០ នៃប្រកាសអន្តរក្រសួងស្ដីពីនីតិវិធីនៃការចុះបញ្ជីអំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី)។

ផ្ទុយមកវិញ បើទោះបីជាទ្រព្យសម្បត្តិរួមក៏ដោយ ប៉ុន្តែដីនោះបានចុះបញ្ជីដាក់តែឈ្មោះប្ដី ឬ ប្រពន្ធតែម្នាក់ឯង ក្នុងករណីដែលឲ្យដីនោះទៅជាកម្មសិទ្ធិរបស់បុគ្គលដែលមានឈ្មោះនៅក្នុងការចុះបញ្ជីនោះ តាមរយៈការបែងចែកទ្រព្យសម្បត្តិ នៅក្នុងសេចក្ដីសម្រេចបញ្ចប់គឺអាចសរសេរថា "...ជាកម្មសិទ្ធិរបស់បុគ្គលនោះ" បាន។ ប៉ុន្តែ បើសិនជាឲ្យដីនោះទៅជាកម្មសិទ្ធិរបស់បុគ្គលដែលមិនមានឈ្មោះនៅក្នុងការចុះបញ្ជី ឬ ឲ្យទៅជាកម្មសិទ្ធិអវិភាគ នៅក្នុងសេចក្ដីសម្រេចបញ្ចប់នោះ គឺត្រូវបន្ថែមនូវសេចក្ដីសម្រេចបញ្ចប់ដែលបង្គាប់ឲ្យបុគ្គលដែលមានឈ្មោះនៅក្នុងការចុះបញ្ជីធ្វើនីតិវិធីចុះបញ្ជីឲ្យទៅបុគ្គលដែលមិនមានឈ្មោះនៅក្នុងការចុះបញ្ជី។ ឧទាហរណ៍៖ ទោះបីជាទ្រព្យសម្បត្តិរួមក៏ដោយ ប៉ុន្តែការចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិបានដាក់ឈ្មោះរបស់ដើមចោទ (យ៉ាងណាមិញ ចំពោះការចុះបញ្ជីបែបនេះ គឺមិនបានឆ្លុះបញ្ចាំងអំពីភាពត្រឹមត្រូវនៃលក្ខណៈសារធាតុទេ ជាគោលការណ៍គប្បីមិនត្រូវទទួលបានការអនុញ្ញាតទេ) ហើយតាមរយៈលទ្ធផលនៃការបែងចែក ដើមចោទទទួលបានចំណែក ១ ភាគ ២ ហើយចុងចម្លើយទទួលបានចំណែក ១ ភាគ ២ ជាកម្មសិទ្ធិអវិភាគ តុលាការនឹងត្រូវសរសេរសេចក្ដីសម្រេចបញ្ចប់ថា "(ដីនោះ) ជាកម្មសិទ្ធិអវិភាគរវាងដើមចោទ និង ចុងចម្លើយ ដោយដើមចោទមានចំណែក ១ ភាគ ២ ហើយចុងចម្លើយមានចំណែក ១ ភាគ ២។ បង្គាប់ឲ្យដើមចោទធ្វើនីតិវិធីចុះបញ្ជីផ្ទេរមួយផ្នែកនៃកម្មសិទ្ធិដែលស្មើនឹង ១ ភាគ ២ ចំពោះ (ដីនោះ)ទៅជាចំណែករបស់ចុងចម្លើយ ឲ្យទៅចុងចម្លើយដោយមូលហេតុការបែងចែកទ្រព្យសម្បត្តិ។

ខ. រថយន្តលេខ ២. ដែលបានកត់ត្រានៅក្នុង"បញ្ជីទ្រព្យសម្បត្តិរួម" នៃឧបសម្ព័ន្ធ ជាកម្មសិទ្ធិរបស់ចុងចម្លើយ។[14]

គ. ប្រាក់សន្សំលេខ ៣ . ដែលបានកត់ត្រានៅក្នុង"បញ្ជីទ្រព្យសម្បត្តិរួម" នៃឧបសម្ព័ន្ធ ជាកម្មសិទ្ធិរបស់ដើមចោទ។

ឃ. បង្គាប់ឲ្យដើមចោទបង់ប្រាក់ចំនួន ..........រៀលទៅចុងចម្លើយ។[15]

(ឧបសម្ព័ន្ធ ) "បញ្ជីទ្រព្យសម្បត្តិរួម"

១. ដី

" ទីតាំងដី" ...........................

"លេខក្បាលដី" ...........................

២. រថយន្ត

"ប្រភេទ" ..........................

"ម៉ាក" ..........................

"ពណ៌" ..........................

"កម្មសិទ្ធិករ" ..........................

"អាសយដ្ឋាន" ..........................

"ផ្លាកលេខ" ..........................

៥. ប្រាក់សន្សំ

"ស្ថាប័នហិរញ្ញវត្ថុ" ធនាគារ........សាខា ......

"ប្រភេទ និង លេខគណនី" ប្រាក់សន្សំធម្មតា ××× ××× ×××

"ឈ្មោះម្ចាស់គណនី" ដើមចោទ"

សូមអរគុណ៕

---

[14] ចំពោះរថយន្ត និង ម៉ូតូ បច្ចុប្បន្នេះ គេឮថា ការចុះបញ្ជីអាចដាក់ឈ្មោះបានតែម្នាក់ប៉ុណ្ណោះ (មិនអាចចុះបញ្ជីជាម្ចាស់កម្មសិទ្ធិអវិភាគបានទេ)។ ប្រសិនបើ តទៅថ្ងៃមុខ នៅតែបន្តការអនុវត្តនេះតទៀត (យ៉ាងណាមិញ ការអនុវត្តបែបនេះ គឺមិនត្រឹមត្រូវទេ) រថយន្ត និង ម៉ូតូជាដើម នឹងមិនសមយកមកធ្វើជាកម្មសិទ្ធិអវិភាគ (មាត្រា ២០២ នៃក្រមរដ្ឋប្បវេណី) តាមរយៈការបែងចែកទ្រព្យសម្បត្តិនោះទេ ដោយសារតែគ្មានវិធីសម្រាប់ចុះបញ្ជីក្នុងករណីបែបនោះទេ។

[15] ជាដំបូង តុលាការ ត្រូវតែរកឲ្យឃើញនូវតម្លៃនៃទ្រព្យសម្បត្តិរួមទាំងអស់ ហើយកំណត់អំពីភាគនៃការបែងចែកដោយផ្អែកតាមកថាខណ្ឌទី ២ មាត្រា ៩៨០ នៃក្រមរដ្ឋប្បវេណី បន្ទាប់មកត្រូវបែងចែកទ្រព្យសម្បត្តិមួយៗ ស្របតាមភាគនៃការបែងចែកនោះ។ ក្នុងករណីដែលពេលនោះ តុលាការ បានឲ្យ ប្តី ឬ ប្រពន្ធ ណាម្ខាងទទួលបានចំនួនច្រើនជាងភាគដែលបានកំណត់ គឺត្រូវតែឲ្យ ប្តី ឬ ប្រពន្ធ ណាម្ខាងនោះបង់ប្រាក់ឲ្យទៅភាគីម្ខាងទៀត ទើបអាចសម្រួលចំនួននោះបាន។

# ទ្រព្យសម្បត្តិរួម និង ទ្រព្យសម្បត្តិដោយឡែក



# រឿងក្តីទាមទារការលែងលះជាអាទិ៍

○ ការអះអាងរបស់X

ខ្ញុំជាមួយនិង Y គឺជាអ្នកជិតខាងដែលស្គាល់គ្នាតាំងពីកុមារភាព ហើយបន្ទាប់ពីបានស្រលាញ់គ្នារយៈពេលជាង ១ ឆ្នាំមក នៅថ្ងៃទី ៣ ខែសីហា ឆ្នាំ២០១៥ ខ្ញុំបានទៅចុះបញ្ជីអាពាហ៍ពិពាហ៍នៅក្នុងសៀវភៅអាពាហ៍ពិពាហ៍នៅឯសាលាឃុំដែលខ្ញុំរស់នៅ ហើយបន្ទាប់មក ក៏បានចាប់ផ្ដើមរួមរស់ជីវភាពជាមួយគ្នានៅទីក្រុងភ្នំពេញដែលជាកន្លែងរបស់ Y រស់នៅ។

នៅថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៦ ខ្ញុំបានសម្រាលកូនប្រុសឈ្មោះ សុក សុជាតិ (តទៅហៅថា "សុជាតិ") ហើយ នៅថ្ងៃទី ២២ ខែកក្កដា ឆ្នាំ២០១៨ ខ្ញុំបានសម្រាលកូនស្រីឈ្មោះ សុក សុជាតា (តទៅហៅថា "សុជាតា") ។

ទោះបីជាខ្ញុំធ្វើការបណ្ដើរ និង មើលថែទាំកូនបណ្ដើរនៅទីក្រុងភ្នំពេញដោយពុំមានសាច់ញាតិក៏ដោយ ហើយបើទោះបីជាក្រោយពេលដែលសុជាតិបានកើតក៏ដោយ ក៏ភាគច្រើន Y បានយកការងារ និង ការជួបជុំជាមួយដៃគូដែលសហការជាមួយក្រុមហ៊ុនជាធំ ជាហេតុនាំឲ្យម៉ោងត្រលប់មកផ្ទះវិញកាន់តែយប់ជ្រៅ។ មិនត្រឹមតែប៉ុណ្ណោះទេ ក្រោយពេលខ្ញុំមានទំងន់ សុជាតា ក៏ដោយ ក៏ Y មិនជួយចូលរួមសហការក្នុងការមើលថែទាំកូនទាល់តែសោះឡើយ បើទោះជាថ្ងៃសម្រាកក៏ដោយ ក៏គាត់បានចេញទៅក្រៅដោយនិយាយថា "មានការជួបជុំជាមួយដៃគូដែលសហការជាមួយក្រុមហ៊ុន" ជាដើម។ បើសិនជាខ្ញុំរវល់មើលថែទាំកូនទាំង ២ ហើយខ្ញុំមិនអាចរៀបចំបាយទឹកឲ្យ Y នោះ Y ក៏ធ្លាប់បានស្ដីបន្ទោសឲ្យខ្ញុំដូចជា "ផ្ទះនេះមិនត្រូវការអ្នកណាដែលមិនចេះធ្វើការងារផ្ទះទេ" ឬក៏ថា "ឲ្យខ្ញុំត្រលប់ទៅស្រុកកំណើតវិញទៅ" ជាដើមថែមទៀតផង។

ដោយសារគិតពីកូនតូចទាំងពីរ ខ្ញុំបានសុខចិត្តទ្រាំនឹងអាកប្បកិរិយាអស់ទាំងនេះរបស់ Y ។ ប៉ុន្តែ នៅថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ២០១៩ Y បានផឹកស្រា ហើយត្រលប់មកផ្ទះវិញពាក់កណ្ដាលអាធ្រាត ហើយថែមទាំងធ្វើឲ្យភ្ញាក់សុជាតិដែលកំពុងតែគេងលក់ទៀត ដោយសារខ្ញុំចង់ឲ្យគាត់បិទមាត់ឈប់និយាយតទៀត ទើបខ្ញុំបានព្រមានទៅគាត់ស្រាប់តែគាត់ផ្ទុះកំហឹង ហើយបានប្រើអំពើហិង្សាមកលើខ្ញុំភ្លាមៗតែម្ដង។

ដោយសារតែខ្ញុំមិនមែនត្រឹមតែបានទទួលរងនូវពាក្យពេចន៍ហិង្សាតែប៉ុណ្ណោះទេ ថែមទាំងបានទទួលរងអំពើហិង្សាជាក់ស្ដែងទៀតផងដែរ ដូច្នេះហើយបានធ្វើឲ្យខ្ញុំយល់ថា បើបន្តរួមរស់ជីវភាពជាមួយ Y ថែមទៀត នឹងមានបញ្ហា ហេតុនេះហើយ ទើប

នៅថ្ងៃទី ៤ ខែមករា ឆ្នាំ២០២០ ខ្ញុំក៏បាននាំកូនទាំងពីរគឺ សុជាតិ និង សុជាតា ត្រលប់ទៅស្រុកកំណើតរបស់ខ្ញុំវិញ ហើយបានរស់បែកគ្នាពី Y ។

ដោយសារតែខ្ញុំមិនអាចធ្វើការរួមរស់ជីវភាពរួមគ្នាជាមួយ Y ឲ្យលើសពីនេះទៀតបានឡើយ ដូច្នេះ ខ្ញុំចង់លែងលះជាមួយ Y។

ម្យ៉ាងទៀត ក្រោយពេលលែងលះ ខ្ញុំនឹងធ្វើជាអ្នកមានអំណាចមេបាទៅលើ សុជាតិ និង សុជាតា ហើយបន្តចិញ្ចឹមបីបាច់កូនតទៅមុខទៀត។ ក្រោយពីការសម្រាល សុជាតិ និង សុជាតា ខ្ញុំបានបីបាច់រក្សារូបកាយរបស់ពួកគេរហូតមក។ ទោះបីជាក្រោយពេលដែលរស់នៅបែកគ្នាពី Y ក៏ដោយ ក៏ខ្ញុំបានទទួលការជួយទំនុកបម្រុងពីឪពុកម្តាយនៅស្រុកកំណើតរបស់ខ្ញុំបន្តបន្ទាប់ដែរ ដូច្នេះកូនទាំងពីរគឺធំលូតលាស់បានដោយល្អប្រសើរ។ សុជាតិ ទើបតែមានអាយុ ៣ ឆ្នាំ ចំណែកឯ សុជាតា ទើបមានអាយុ ១ ឆ្នាំ ដែលពួកគេទាំងពីរ គឺសុទ្ធតែនៅតូចៗនៅឡើយ។ ដើម្បីឲ្យពួកគេទាំងពីរធំលូតលាស់បានគឺ មិនអាចខ្វះវត្តមានរបស់ខ្ញុំដែលជាម្តាយបានឡើយ។ ម្យ៉ាងវិញទៀត រហូតមកទល់ពេលនេះ Y ក៏មិនដែលជួយមើលថែរក្សាកូនតូចៗទាំងពីរនេះទាល់តែសោះ ពោលគឺស្ទើរតែពុំដែលបានប៉ះពាល់កូនឡើយ។

បច្ចុប្បន្ននេះ ខ្ញុំកំពុងរស់នៅស្រុកកំណើតដោយគ្មានប្រាក់ចំណូល ដោយសារតែមិនមានការងារធ្វើ។ ប៉ុន្តែ Y ធ្វើការជាបុគ្គលិកក្រុមហ៊ុននៅភ្នំពេញ ហើយមានប្រាក់ចំណូលប្រចាំឆ្នាំប្រហែលជា ៧.០០០ ដុល្លារអាមេរិក។ ហេតុដូច្នេះ ខ្ញុំទាមទារទៅ Y ឲ្យបង់ប្រាក់ចំនួន ១៥០ ដុល្លារអាមេរិកប្រចាំខែនីមួយៗ ( សរុបចំនួន ៣០០ ដុល្លារអាមរិក ) ដែលជាសោហ៊ុយចិញ្ចឹមបីបាច់កូនទាំងពីរ។ ហើយខ្ញុំទាមទារប្រាក់ចំនួន ១០០ ដុល្លារអាមេរិកក្នុង ១ ខែ ជាអាហារកិច្ច។

ម្យ៉ាងវិញទៀត ចំពោះការបែងចែកទ្រព្យសម្បត្តិ ខ្ញុំស្នើសុំឲ្យធ្វើទៅតាមឧបសម្ព័ន្ធ។

○ ការអះអាងរបស់Y

ខ្ញុំទទួលស្គាល់ថា ខ្ញុំបានរៀបអាពាហ៍ពិពាហ៍ជាមួយ X នៅថ្ងៃទី ៣ ខែសីហា ឆ្នាំ ២០១៥។ ហើយ ខ្ញុំក៏ទទួលស្គាល់ថា ខ្ញុំ និង X មានកូនឈ្មោះ សុជាតិ និង កូនឈ្មោះ សុជាតា។ មិនតែប៉ុណ្ណោះ ខ្ញុំក៏ទទួលស្គាល់ថា X បាននាំកូនទាំងពីរត្រលប់ទៅស្រុកកំណើតរបស់ X កាលពីថ្ងៃទី ៤ ខែ មករា ឆ្នាំ ២០២០ ហើយក៏បានបន្តរស់នៅ

បែកគ្នារហូតចាប់តាំងពីពេលនោះមក។

ប៉ុន្តែ ខ្ញុំមិនអាចទទួលស្គាល់ចំពោះដំណើររឿងដែលនាំឲ្យឈានដល់ការរស់នៅបែកគ្នាជាមួយ X បានឡើយ ពីព្រោះ ការអះអាងរបស់ X គឺខុសស្រឡះពីការពិត។

ខ្ញុំ និង X គឺមិត្តនឹងគ្នាតាំងពីកុមារភាព ដូច្នេះខ្ញុំស្គាល់ X ច្បាស់ណាស់ទាំងពីពេលនៅតូចៗ។ ខ្ញុំរៀបការជាមួយ X ដោយសារបាក់ចិត្តស្រលាញ់ចំពោះសុខភាពមាំមួន និង អត្តចរិតឆ្លាតវៃរបស់ X ។ នាពេលដែលខ្ញុំរៀបការជាមួយ X ខ្ញុំបានទទួលប្រាក់ខែខ្ពស់ ហេតុនេះហើយខ្ញុំបានចាកចេញពីស្រុកកំណើតនៅខេត្តបាត់ដំបង ដើម្បីមកធ្វើការនៅភ្នំពេញ។ ដោយសារតែការរៀបអាពាហ៍ពិពាហ៍ជាមួយគ្នានេះហើយ X ក៏បានផ្លាស់ទីលំនៅមករស់នៅទីក្រុងភ្នំពេញដែលជាកន្លែងខ្ញុំរស់នៅ។ ក្រោយពេលផ្លាស់ទីលំនៅមករស់នៅទីក្រុងភ្នំពេញ X ក៏ឈប់ចេញទៅដើរលេងនៅខាងក្រៅហើយក៏លែងមានសុខភាពមាំមួន និង បាត់បង់អស់នូវអត្តចរិកវៃឆ្លាតដូចកាលពីមុន។ ក្រោយពេលដែលបានចាប់ផ្តើមរួមរស់ជីវភាពជាមួយគ្នាមក ដើម្បីទទួលបាននូវប្រាក់ខែបន្ថែមកាន់តែច្រើន ខ្ញុំបានធ្វើការងារថែមម៉ោងធ្វើការ ឬ ក៏ទៅជួបជុំមួយដៃគូដែលសហការជាមួយក្រុមហ៊ុនយ៉ាងសកម្មជាដើម។ ហេតុដូច្នេះ ភាគច្រើនធ្វើឲ្យម៉ោងដែលខ្ញុំត្រលប់មកផ្ទះវិញ មានភាពយឺតយ៉ាវផងដែរ។ X មិនបានស្វែងយល់ពីការខំប្រឹងប្រែងរបស់ខ្ញុំបែបនេះទេ ប៉ុន្តែផ្ទុយមកវិញបែរទៅជាមានចិត្តសង្ស័យថា ខ្ញុំបានប្រព្រឹត្តអំពើផិតទៅវិញ។ បន្ទាប់ពីកំណើត សុជាតា មក X កាន់តែយ៉ាប់ខ្លាំងទៅៗហើយបែរទៅជាគិតតែពីរអ៊ូរទាំដាក់មកខ្ញុំដែលត្រលប់មកផ្ទះវិញទាំងភាពនឿយហត់អស់កម្លាំងពីការងារថា "តើថ្ងៃនេះទើបមកពីដើរផឹកជាមួយស្រីនៅកន្លែងណា?" ជាដើម។ លើសពីនេះទៀត ថ្ងៃដែល X មិនបានរៀបចំបាយទឹកហូបចុកក៏កាន់តែច្រើនឡើងៗ។ បើទោះជាខ្ញុំបានធុញទ្រាន់ទៅនឹងអាកប្បកិរិយារបស់ X ដែលបានធ្វើជាមិនយល់ពីការងាររបស់ខ្ញុំក៏ដោយ ប៉ុន្តែ ខ្ញុំបានធ្វើចិត្តឲ្យត្រជាក់ហើយគិតថា អាកប្បកិរិយារបស់ X ទៅជាបែបនេះ ក៏ព្រោះតែ X លែងមានពេលលំហែអារម្មណ៍ដោយសារតែត្រូវធ្វើការងារ និង មើលថែទាំកូនទៀត ដូច្នេះ ខ្ញុំក៏បានសាកផ្តល់ជាគំនិតទៅ X ថា " ដើម្បីផ្លាស់ប្តូរអារម្មណ៍ សាកទៅសម្រាកនៅស្រុកកំណើតមួយរយៈលមើល ?" ជាដើម។

ថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ២០១៩ ដោយសារតែខ្ញុំចូលរួមកម្មវិធីជប់លៀងគ្រិស្តម៉ាសជាមួយដៃគូដែលសហការជាមួយក្រុមហ៊ុន ហេតុនេះខ្ញុំក៏បានត្រលប់ទៅផ្ទះវិញយឺត។ ពេល

ត្រលប់ទៅដល់ផ្ទះវិញ កូនទាំងពីរបានគេងលក់បាត់ទៅហើយ ប៉ុន្តែ ដោយសារខ្ញុំបានរៀបចំកាដូគ្រិស្តម៉ាសឲ្យទៅពួកគេ ហើយចង់ឲ្យកូនទាំង ២ ចាប់អារម្មណ៍នៅពេលដែលក្រោកពីដំណេកថ្ងៃបន្ទាប់ ដូច្នេះ ខ្ញុំក៏បានគិតថាយកកាដូនោះទៅទុកនៅលើក្បាលដំណេក។ ពេលដែលខ្ញុំកំពុងទុកកាដូនោះ X បានចាប់អារម្មណ៍ឃើញខ្ញុំ ហើយក៏បានខឹងហើយស្រែកខ្លាំងៗថា "ធ្វើស្អីហ្នឹង?!" ហើយក៏បានយកដៃរុញមកខ្ញុំដែលបានខិតចូលទៅជិតក្បាលដំណេកកូនៗ។ ដោយសារតែខ្ញុំគិតថា ដៃរបស់ X អាចនឹងប៉ះត្រូវចំកូនជាមិនខាន ក៏បានហាមឃាត់ X ទាំងភ័យស្លន់ស្លោ។ ហើយដើម្បីកុំឲ្យកូនភ្ញាក់ ខ្ញុំក៏បានបី Xពីបន្ទប់គេងចេញមកក្រៅ។ ក្រោយពីនោះមក នៅថ្ងៃទី ៤ ខែ មករា ឆ្នាំ២០២០ X បានត្រលប់ទៅស្រុកកំណើតរបស់ X នៅឯខេត្តបាត់ដំបងវិញ ដោយបាននាំយកកូនទាំងពីរទៅជាមួយផងដែរ ដោយមិនបាននិយាយពន្យល់អ្វីមកឲ្យខ្ញុំដឹងសោះ។

ដូចដែលខ្ញុំបានរៀបរាប់ពីខាងលើនេះ ដោយហេតុថា មិនមានអង្គហេតុដូចដែល X បានអះអាងទេ ដូច្នេះហើយ ខ្ញុំមិនអាចយល់ស្របចំពោះការលែងលះបានទេ។

ហើយប្រសិនបើ X មានចិត្តចង់លែងលះជាមួយខ្ញុំ អ្នកមានអំណាចមេបាទៅលើ សុជាតិ និង សុជាតា គួរតែត្រូវឲ្យមកខ្ញុំ។ X ជាមនុស្សមានសតិអារម្មណ៍មិននឹងនរ ហើយស្រែកខ្លាំងៗភ្លាមៗមួយរំពេចជាដើម។ ការចិញ្ចឹមបីបាច់របស់គាត់ចំពោះ សុជាតិ និង សុជាតា គឺមិនអាចធ្វើបានត្រឹមត្រូវឡើយ។ ខ្ញុំចង់កូនទាំងពីរមករស់នៅទីក្រុងភ្នំពេញ ហើយទទួលបាននូវការអប់រំដល់កម្រិតខ្ពស់។

ចាប់ពីពេលនេះតទៅ ខ្ញុំនឹងធ្វើជាអ្នកមានអំណាចមេបាក្នុងការបីបាច់រក្សារូបកាយកូនទាំងពីរ ដូច្នេះ X អាចទៅធ្វើការបានដោយខ្លួនឯង ហើយប្រាកដជាអាចរកប្រាក់ចំណូលបានជាមិនខាន។ ដូច្នេះហើយ ខ្ញុំមិនអាចយល់ស្របតាមការទាមទារនូវអាហារកិច្ចពី X បានទេ។

ការអះអាងរបស់ខ្ញុំទាក់ទងទៅនឹងការបែងចែកទ្រព្យសម្បត្តិ គឺមានដូចនៅក្នុងឧបសម្ព័ន្ធ។

**ឧបសម្ព័ន្ធ**

| | ទ្រព្យសម្បត្តិ | X (ប្រពន្ធ) | | | Y (ប្តី) | | |
|---|---|---|---|---|---|---|---|
| មុនពេល<br>អាពាហ៍ពិពាហ៍ | | ចិញ្ចៀន | ម៉ូតូ | ប្រាក់សន្សំ<br>1.000$ | ដី<br>(ខេត្តបាត់ដំបង) | ឡាន | ប្រាក់សន្សំ<br>2.500$ |
| 3.8.2015<br>អាពាហ៍ពិពាហ៍ | | | | | | | |
| 11.8.2016<br>កំណើតកូន<br>ប្រុសច្បង | | | | | | | |
| 19.12.2016 | ដី L 1 (ខេត្តបាត់ដំបង)<br>ទិញ 5.000$ | | | | | | -1.000$<br>(សល់<br>1.500$) |
| 2.1.2017 | ធនាគារ A ⇔ X・Y<br>(កាតព្វកិច្ចសាមគ្គី)<br>កម្ចី ① 4.000 $<br>បង្កើតហ៊ីប៉ូតែកលើដី L 1 | | | | | | |
| 18.9.2017 | ឡាន (ឡិចស៊ីស)<br>ទិញ 15.000$ | | | | | លក់<br>9.000$ | |
| 24.12.2017 | ម៉ូតូ (យ៉ាម៉ាហា)<br>ទិញ 2.000$ | | លក់<br>1.500$ | | | | |
| 22.7.2018<br>កំណើតកូនស្រី | | | | | | | |
| 1.10.2018 | ដី L 2 (ខេត្តបាត់ដំបង)<br>ទិញ 8.000$ | | | -800$<br>(សល់ 200$) | | | -800$<br>(សល់ 700$) |
| 12.10.2018 | ធនាគារ B⇔X・Y<br>(កាតព្វកិច្ចសាមគ្គី)<br>កម្ចី ② 6.400$<br>បង្កើតហ៊ីប៉ូតែកលើដី L 2 | | | | | | |
| 4.1.2020<br>រស់នៅបែកគ្នា | | | | | | | |
| | | | | | | | |
| សរុប | "ទ្រព្យសកម្ម"<br>ដី L 1 (6.000$)<br>"សរសេរក្នុងសៀវភៅគោលបញ្ជី៖ ទ្រព្យរួមប្តីប្រពន្ធ"<br>ដី L 2 (10.000$)<br>"សរសេរក្នុងសៀវភៅគោលបញ្ជី៖ ទ្រព្យរួមប្តីប្រពន្ធ"<br>ឡាន (ឡិចស៊ីស) (10.000$)<br>"សរសេរក្នុងបណ្ណយានជំនិះ៖ ឈ្មោះចុងចម្លើយ"<br>ម៉ូតូ (យ៉ាម៉ាហា) (1.500$)<br>"សរសេរក្នុងបណ្ណយានជំនិះ៖ ឈ្មោះដើមចោទ"<br>ប្រាក់សន្សំ (500$)<br>"ម្ចាស់គណនី៖ឈ្មោះចុងចម្លើយ"<br>"ទ្រព្យអកម្ម"<br>កម្ចី ① (3.000$)<br>"កាតព្វកិច្ចដោយសាមគ្គីភាពរវាងដើមចោទ និង ចុងចម្លើយ"<br>កម្ចី ② (6.000$)<br>"កាតព្វកិច្ចដោយសាមគ្គីភាពរវាងដើមចោទ និង ចុងចម្លើយ"<br><u>**※ចំនួនទឹកប្រាក់ដែលនៅចំណុចបែកលំនៅគ្នា**</u> | -ម៉ូតូ គឺជារបស់ដែលខ្ញុំត្រូវការសម្រាប់ជិះទៅទិញទំនិញប្រើប្រាស់ជាប្រចាំថ្ងៃ ដូច្នេះ ខ្ញុំចង់យកធ្វើជាកម្មសិទ្ធតែម្នាក់ឯង។<br>~~-ដី L 1 គឺខ្ញុំចង់ឲ្យទៅសុជាតិ។~~ដី L 1 គឺយកទៅលក់ ហើយប្រាក់នោះខ្ញុំចង់ចែកពាក់កណ្តាល ជាមួយ Y។ (※ 1)<br>-ដី L 2 គឺខ្ញុំចង់លក់ ហើយយកប្រាក់នោះមកចែកពាក់កណ្តាលម្នាក់ជាមួយ Y ។<br>~~-កម្ចី① និង ② ខ្ញុំចង់ឲ្យ Y បង់ឲ្យខ្ញុំទាំងអស់។~~ (※ 3) | | | -ឡាន គឺជារបស់ដែលខ្ញុំប្រើប្រាស់នៅក្នុងការងារ ដូច្នេះ ខ្ញុំចង់យកធ្វើជាកម្មសិទ្ធតែម្នាក់ឯង។<br>~~-ដី L 1 ឲ្យសុជាតិក៏បានដែរ។~~ (※ 2)<br>-ដី L 1 និង L 2 កំពុងតែឡើងថ្លៃ ដូច្នេះ ឥឡូវនេះខ្ញុំមិនទាន់ចង់លក់ទេ។<br>-កម្ចី① និង ② ខ្ញុំចង់បង់ពាក់កណ្តាលម្នាក់ជាមួយ X។ | | |

※1 ការបែងចែកទ្រព្យសម្បត្តិ គឺជាការបែងចែកនូវទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធវាងប្តីប្រពន្ធនោះ ក្នុងករណីដែលប្តីប្រពន្ធលែងលះគ្នា (យោងកថាខណ្ឌទី ២ មាត្រា ៩៨០ នៃក្រមរដ្ឋប្បវេណី)។ តុលាការពុំអាចធ្វើការបែងចែកទ្រពសម្បត្តិដែលបានកំណត់ជាក់លាក់ឲ្យទៅតតិយជនផ្សេងក្រៅពីប្តីប្រពន្ធ (រួមទាំងកូនរបស់ប្តីប្រពន្ធ) ធ្វើជាការបែងចែកទ្រព្យសម្បត្តិបាននោះទេ។ ក្នុងករណីដែលប្តីប្រពន្ធទាំងសងខាងយកទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធមកធ្វើប្រទានកម្មឲ្យទៅតតិយជន គឺនឹងត្រូវចាត់ចែងទ្រព្យសម្បត្តិរួមនោះដោយផ្អែកទៅលើការយល់ព្រមរបស់ប្តីប្រពន្ធទាំងសងខាង (យោងកថាខណ្ឌទី ១ មាត្រា ៩៧៦)។ ហើយបើសិនជាប្តីប្រពន្ធបានចាត់ចែងទ្រព្យសម្បត្តិរួមដោយផ្អែកលើការយល់ព្រមទាំងសងខាងហើយ គិតចាប់ពីពេលនោះមក ទ្រព្យសម្បត្តិនោះនឹងលែងក្លាយទៅជាទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធ ដូច្នេះ វាក៏លែងក្លាយទៅជាកម្មវត្ថុនៃការបែងចែកទ្រព្យសម្បត្តិទៀតដែរ។

នៅក្នុងរឿងក្តីនេះ ដី L 1 គឺជាទ្រព្យសម្បត្តិដែលប្តីប្រពន្ធទាំងសងខាងទទួលបាននៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍រវាងដើមចោទ និង ចុងចម្លើយ ដូច្នេះហើយ វាគឺជាទ្រព្យសម្បត្តិរួមរវាងដើមចោទ និង ចុងចម្លើយ (មាត្រា ៩៧៣ នៃក្រមរដ្ឋប្បវេណី)។ ម្យ៉ាងវិញទៀត ដើមចោទ និង ចុងចម្លើយ មិនមែនបានធ្វើប្រទានកម្មនូវ ដី L 1 ឲ្យទៅកូនរបស់ពួកគេទាំងពីរឈ្មោះ សុជាតិ ដោយផ្អែកលើការយល់ព្រមទាំងសងខាងនោះទេ។ ហេតុដូច្នេះហើយ ដី L 1 គឺនៅតែជាទ្រព្យសម្បត្តិរួមរបស់ដើមចោទ និង ចុងចម្លើយដដែល ហេតុនេះ នៅពេលដែលអ្នកទាំងពីរនេះលែងលះគ្នា ចាំបាច់ត្រូវយកដីនេះមកធ្វើការបែងចែករវាងអ្នកទាំងពីរ។

ចំពោះការបែងចែកទ្រព្យសម្បត្តិ ដើមចោទបានយល់ដឹងថា មិនអាចធ្វើការបែងចែក ដី L 1 ឲ្យទៅសុជាតិបានទេ ដូច្នេះហើយក៏បានកែតម្រូវទៅលើការដាក់ពាក្យសុំទាមទារ ដោយសុំបែងចែកដីនោះរវាងចុងចម្លើយវិញ ហើយវិធីនៃការបែងចែកនោះនឹងត្រូវធ្វើឡើងតាមការលក់ដេញថ្លៃហើយចែកប្រាក់លក់នោះតាមចំណែក (មាត្រា ២១២ នៃក្រមរដ្ឋប្បវេណី)។

ម្យ៉ាងវិញទៀត បើទោះបីជាដើមចោទមិនកែតម្រូវនូវពាក្យសុំក៏ដោយ ក៏ការសម្រេចសេចក្តីចំពោះការចាត់ចែងទាក់ទងនឹងការបែងចែកទ្រព្យសម្បត្តិ នឹងមិនត្រូវបានអនុវត្តតាមបទប្បញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ១៨២ នៃក្រមនីតិវិធីរដ្ឋប្បវេណីទេ (កថាខណ្ឌទី ៣ មាត្រា ២២ នៃច្បាប់ស្តីពីឋានៈបុគ្គល) ដូច្នេះហើយ តុលាការក៏អាចសម្រេចសេចក្តីចំពោះចំណុចដែលភាគីមិនទាន់បានស្នើសុំបានផងដែរ។ ក្នុងករណីដែលតុលាការអាចទទួលស្គាល់ថា ដី L 1 គឺជាទ្រព្យសម្បត្តិរួមរបស់ដើមចោទ និង ចុងចម្លើយ (គិតត្រឹមរយៈពេលការបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ ប្រសិនបើមិនមានការទទួលស្គាល់ថា ដើមចោទ និង ចុងចម្លើយបានធ្វើប្រទានកម្មនូវ ដី L 1 ឲ្យទៅសុជាតិដោយបានព្រមព្រៀងគ្នាទាំងសងខាង ) នឹងត្រូវយកដី L 1 មកធ្វើការសម្រេចបែងចែកគ្នារវាងដើមចោទ និង ចុងចម្លើយ (ការសម្រេចសេចក្តីមិនអាចបែងចែកឲ្យទៅសុជាតិបានទេ)។

※2 ចំណុចនេះ ចុងចម្លើយក៏បានដកការតវ៉ាដែរស្របទៅតាមការកែតម្រូវនូវការទាមទាររបស់ដើមចោទ ដូចនៅក្នុងចំណុច「※1」។

※3　កម្ម៌ ① គឺជាកាតព្វកិច្ចដោយសាមគ្គីភាព ដោយមានម្ចាស់បំណុលគឺជាធនាគារ A និង កូនបំណុល គឺជាដើមចោទ និង ចុងចម្លើយ។ កម្ម៌ ② គឺជាកាតព្វកិច្ចដោយសាមគ្គីភាព ដោយមានម្ចាស់បំណុល គឺជាធនាគារ B និងកូនបំណុល គឺជាដើមចោទ និង ចុងចម្លើយ។ ក្នុងករណីដែលបុគ្គលច្រើននាក់ទទួលបន្ទុកនូវកាតព្វកិច្ចដោយសាមគ្គីភាព ម្ចាស់បំណុលអាចទាមទារឲ្យកូនបំណុលណាម្នាក់អនុវត្តកាតព្វកិច្ចទាំងអស់ ឬ មួយភាគ ឬ ឲ្យកូនបំណុលទាំងអស់ អនុវត្តកាតព្វកិច្ចទាំងអស់ ឬ មួយភាគ ដោយព្រមគ្នា ឬ ដោយបន្តបន្ទាប់ (កថាខណ្ឌទី ១ មាត្រា ៩២១ នៃក្រមរដ្ឋប្បវេណី)។ ដូច្នេះ ធនាគារ A និង ធនាគារ B អាចទាមទារទៅដើមចោទក៏បាន ឬ ទាមទារទៅចុងចម្លើយក៏បានឲ្យសងកាតព្វកិច្ច។ ការផ្លាស់ប្តូរកូនបំណុលនៃកម្ម៌ ① និង ② ទៅជាចុងចម្លើយតែម្នាក់ នឹងធ្វើឲ្យរងការខូចខាតដល់ផលប្រយោជន៍របស់ធនាគារ A និង ធនាគារ B ដែលអាចធ្វើការទាមទារទៅដើមចោទ និងចុងចម្លើយទាំងសងខាងឲ្យសងកាតព្វកិច្ចបាន។ ការបែងចែកទ្រព្យសម្បត្តិរបៀបនេះនឹងមិនត្រូវបានអនុញ្ញាតឲ្យកើតមានឡើងនៅក្នុងបណ្តឹងលែងលះដែលធនាគារ A និង ធនាគារ B មិនមែនជាភាគីនៃបណ្តឹងនោះទេ។

ដោយសារតែ ដើមចោទបានយល់ដឹងអំពីការបែងចែកទ្រព្យសម្បត្តិថា មិនអាចយកកាតព្វកិច្ចមកធ្វើការបែងចែករវាងដើមចោទ និង ចុងចម្លើយបានទេ ដូច្នេះហើយ ក៏បានដកពាក្យស្នើសុំនេះ។

យ៉ាងណាមិញ ប្រសិនបើនៅក្រោយពេលដែលបានលែងលះគ្នា ដើមចោទ និង ចុងចម្លើយ ចង់ទទួលបន្ទុកលើកម្ម៌ ① និង ② ម្នាក់ពាក់កណ្តាល ក្នុងករណីនេះ នៅក្រៅនីតិវិធីបណ្តឹង ម្ចាស់បំណុលដែលជាធនាគារ A និង ធនាគារ B ត្រូវធ្វើការលើកលែងសាមគ្គីភាពចំពោះចុងចម្លើយ និងដើមចោទ (កថាខណ្ឌទី៣ មាត្រា៩២២ នៃក្រមរដ្ឋប្បវេណី)។ កូនបំណុលដែលបានទទួលការលើកលែងសាមគ្គីភាព ចាប់តាំពីពេលលើកលែងនោះមក ត្រូវទទួលបន្ទុកកាតព្វកិច្ចតែចំនួនទឹកប្រាក់សមរម្យនៃភាគទទួលបន្ទុកដែលមានមុនពេលលើកលែង (កថាខណ្ឌទី៤ មាត្រា៩២២ នៃក្រមរដ្ឋប្បវេណី)។ម្យ៉ាងទៀត ប្រសិនបើដើមចោទ និង ចុងម្លើយ នៅក្រោយពេលលែងលះ បានព្រមព្រៀងគ្នាឲ្យចុងចម្លើយតែម្នាក់ទទួលបន្ទុកទៅលើកម្ម៌ ① និង ② ហើយបើធនាគារ A និង ធនាគារ B ក៏មានការព្រមព្រៀងដែរ នាំឲ្យ<u>នៅក្រៅនីតិវិធីបណ្តឹង</u> ឧទាហរណ៍ ធនាគារ A និង ធនាគារ B ដែលជាម្ចាស់បំណុលត្រូវលើកលែងសាមគ្គីភាពចំពោះដើមចោទ និង ចុងចម្លើយ (កថាខណ្ឌទី ៣ មាត្រា ៩២២ នៃក្រមរដ្ឋប្បវេណី) ដោយឲ្យដើមចោទទទួលបន្ទុក〝0〞ភាគ និង ឲ្យចុងចម្លើយទទួលបន្ទុក 〝10〞ភាគ (យ៉ាងណាមិញ បើសិនជាគ្មានការព្រមព្រៀងគ្នាទេ ភាគនៃការទទួលបន្ទុករបស់កូនបំណុលដែលមានកាតព្វកិច្ចដោយសាមគ្គីភាពនីមួយៗ ត្រូវបានសន្មតថា ស្មើគ្នា (កថាខណ្ឌទី ៥ មាត្រា ៩២២ នៃក្រមរដ្ឋប្បវេណី )។) ។ ក្រោយពីពេលដែលលើកលែងនោះមក កូនបំណុលដែលបានទទួលការលើកលែងសាមគ្គីភាព នឹងត្រូវទទួលបន្ទុកកាតព្វកិច្ច (កថាខណ្ឌទី ៤ មាត្រា ៩២២ នៃក្រមរដ្ឋប្បវេណី) ត្រឹមចំនួនប្រាក់ដែលស្មើនឹងបន្ទុកដែលខ្លួនធ្លាប់មានមុនពេលលើកលែង ដូច្នេះហើយចំពោះកម្ម៌ ① និង ② ដើមចោទនឹងត្រូវទទួលបន្ទុក〝 0 〞ភាគ ហើយចុងចម្លើយ〝10〞។ ពោលគឺ

មានតែចុងចម្លើយប៉ុណ្ណោះនឹងត្រូវទទួលបន្ទុក។ កិច្ចការដែលបានរៀបរាប់ទាំងនេះ គឺចាំបាច់ត្រូវមានការលើកលែងនូវសាមគ្គីភាពពីម្ចាស់បំណុល ដូច្នេះហើយមិនអាចធ្វើឡើងនៅក្នុងនីតិវិធីបណ្តឹងដែលមានដើមចោទនិងចុងចម្លើយជាភាគីបានទេ។

## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

# ពាក្យបណ្ដឹង

## ដើមចោទ

ឈ្មោះ ៖ X

អាសយដ្ឋាន ៖ ផ្ទះលេខ 00 ផ្លូវលេខ 00 ភូមិ...... ឃុំ.......ស្រុក......... ខេត្តបាត់ដំបង[1]។

## អ្នកតំណាងដោយអាណត្តិ

លោក/លោកស្រី ៖ P

អាសយដ្ឋានការិយាល័យ ៖ ..................................

ឈ្មោះការិយាល័យមេធាវី/ក្រុមមេធាវី/ក្រុមហ៊ុនមេធាវី ៖ ..........................................

លេខទូរស័ព្ទ ៖ ..................................................

**ទីកន្លែងបញ្ជូន** ៖ ការិយាល័យមេធាវី/ ក្រុមមេធាវី/ ក្រុមហ៊ុនមេធាវី.................. [2]

## ចុងចម្លើយ

ឈ្មោះ ៖ Y

អាសយដ្ឋាន ៖ ផ្ទះលេខ 00 ផ្លូវលេខ 00 សង្កាត់មនោរម្យ ខណ្ឌ ៧ មករា រាជធានីភ្នំពេញ។

---

[1] ឈ្មោះ និងអាសយដ្ឋាន មានបញ្ញត្តិនៅក្នុងចំណុច ក កថាខណ្ឌទី ២ មាត្រា ៧៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី ប៉ុន្តែ ចំពោះចំណុចផ្សេងទៀត ដូចជា ថ្ងៃខែឆ្នាំកំណើតជាអាទិ៍ ជាចំណុចដែលពុំមានបញ្ញត្តិក្នុងច្បាប់ទេ។ ប៉ុន្តែ ក៏មានករណីដែលពុំអាចកំណត់អំពីភាគី តាមរយៈឈ្មោះ និង អាសយដ្ឋានបានផងដែរ ដូច្នេះ ត្រូវសរសេរចំណុចទាំងនោះក្នុងកម្រិតមួយដែលចាំបាច់ ដើម្បីអាចកំណត់អំពីភាគី។

[2] មាត្រា ២៤៩ និងមាត្រា ២៥០ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ ការដាក់ពីទីកន្លែងដែលត្រូវបញ្ជូន មិនមែនជាកាតព្វកិច្ចនោះទេ។ ប្រសិនបើពុំមានការសរសេរអំពីទីកន្លែងដែលត្រូវបញ្ជូនទេ ការបញ្ជូននឹងត្រូវធ្វើឡើងនៅលំនៅឋានរបស់ដើមចោទ ជាអាទិ៍។ ហេតុនេះ ក្នុងករណីដែលអ្នកតំណាងដោយអាណត្តិរបស់ដើមចោទមានបំណងធ្វើការបញ្ជូនទៅកាន់ទីកន្លែងណាផ្សេងក្រៅពីលំនៅដ្ឋានរបស់ដើមចោទជាអាទិ៍ គឺមានភាពចាំបាច់ក្នុងការសរសេរអំពីទីកន្លែងដែលត្រូវបញ្ជូននៅក្នុងលិខិតពាក្យបណ្ដឹងជាអាទិ៍។

## សូមគោរពជូន
## លោកប្រធានសាលាដំបូងខេត្តបាត់ដំបង [3]

## ក. ខ្លឹមសារនៃសាលក្រម និង ការចាត់ចែងបន្ទាប់បន្សំដែលដើមចោទទាមទារឲ្យតុលាការចេញ [4] ៖

(១) លែងលះដើមចោទ និង ចុងចម្លើយ ។[5]

---

[3] ដើមចោទត្រូវតែដាក់ពាក្យបណ្តឹងទៅតុលាការដែលមានសមត្ថកិច្ច (មាត្រា ៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ សមត្ថកិច្ចសាលាជម្រះក្តីត្រូវកំណត់តាមពេលដាក់ពាក្យបណ្តឹង (មាត្រា ១៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ បណ្តឹងទាមទារលែងលះគ្នាស្ថិតនៅក្រោមសមត្ថកិច្ចផ្តាច់មុខរបស់សាលាដំបូងដែលមានសមត្ថកិច្ចនៅលំនៅដ្ឋានរបស់ភាគី (កថាខណ្ឌទី ១ មាត្រា ៩៨២ នៃក្រមរដ្ឋប្បវេណី និង កថាខណ្ឌទី ១ មាត្រា ១០ នៃក្រមនិតិវិធីរដ្ឋប្បវេណី)។

នៅក្នុងរឿងក្តីនេះ លំនៅដ្ឋានរបស់ដើមចោទ នៅខេត្តបាត់ដំបង ហើយលំនៅដ្ឋានរបស់ចុងចម្លើយនៅទីក្រុងភ្នំពេញ ហេតុនេះហើយ សាលាដំបូងខេត្តបាត់ដំបង និង សាលាដំបូងរាជធានីភ្នំពេញ គឺជាសាលាដំបូងដែលមានសមត្ថកិច្ច។

រវាងសាលាដំបូងខេត្តបាត់ដំបង ឬ សាលាដំបូងរាជធានីភ្នំពេញ ដើមចោទអាចដាក់ពាក្យបណ្តឹងទៅសាលាដំបូងណាមួយក៏បាន ប៉ុន្តែ នៅក្នុងរឿងក្តីនេះ លំនៅដ្ឋានរបស់ដើមចោទរស់នៅខេត្តបាត់ដំបង ហើយបានចុះបញ្ជីអាពាហ៍ពិពាហ៍នៅសាលាស្រុកខេត្តបាត់ដំបងជាដើមផងដែរ ហេតុនេះហើយ ដើមចោទបានដាក់ពាក្យបណ្តឹងទៅសាលាដំបូងខេត្តបាត់ដំបង។

[4] ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារ គឺជាចំណុចដែលចាំបាច់ត្រូវសរសេរនៅក្នុងពាក្យបណ្តឹង (ចំណុច ខ កថាខណ្ឌទី ២ មាត្រា ៧៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ ម្យ៉ាងទៀត ប្រសិនបើតុលាការចេញសាលក្រម ឬ សាលដីកាដែលទទួលស្គាល់បណ្តឹងទាមទារលែងលះ តុលាការនឹងត្រូវសម្រេចសេចក្តីអំពីការចាត់ចែងបន្ទាប់បន្សំ (កំណត់អ្នកមានអំណាចមេបា ការចាត់ចែងទាក់ទងនឹងការបីបាច់រក្សាកូន ឬ ការចាត់ចែងទាក់ទងនឹងការបែងចែកទ្រព្យសម្បត្តិ) ដោយឆន្ទានុសិទ្ធិ ឬ តាមពាក្យសុំ ដូច្នេះហើយ ដើមចោទគប្បីសរសេរទុកជាមុនអំពីខ្លឹមសារនៃការចាត់ចែងបន្ទាប់បន្សំដែលទាមទារឲ្យតុលាការចេញ ទើបជាការប្រសើរ (កថាខណ្ឌទី ១ មាត្រា ២២ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល)។

[5] ភាគីនៃការអាពាហ៍ពិពាហ៍ អាចដាក់ពាក្យបណ្តឹងលែងលះគ្នា (តាមលក្ខណៈត្រឹមត្រូវ គឺពាក្យសុំលែងលះ) ទៅតុលាការបាន ក្នុង "ករណីដែលភាគីសងខាងបានព្រមព្រៀងអំពីការលែងលះគ្នា" (មាត្រា ៩៧៩ នៃក្រមរដ្ឋប្បវេណី)។ ក្នុងករណីនេះ តុលាការត្រូវសម្រេចសេចក្តី (ដីកាសម្រេច) ដោយផ្អែកតាមច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង (មាត្រា ៣ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង តារាងឧបសម្ព័ន្ធចំណុច ៥ ផ្នែកទី ៤ )។ "ករណីដែលភាគីសងខាងបានព្រមព្រៀងអំពីការលែងលះគ្នា" គឺសំដៅទៅលើករណីដែលភាគីសងខាងមានកូនដែលជាអនីតិជន ហើយភាគីសងខាងបានព្រមព្រៀងគ្នាចំពោះការសម្រេចអំពី ① ការលែងលះ និង ② អ្នកមានអំណាចមេបា។ មូលហេតុ គឺដោយសារតែនៅពេលដែលឪពុកម្តាយលែងលះគ្នាត្រូវតែកំណត់ឪពុក ឬ ម្តាយណាម្ខាង ជាអ្នកមានអំណាចមេបា តាមការពិភាក្សារបស់ឪពុកម្តាយ (កថាខណ្ឌទី ១ មាត្រា ១០៣៧ នៃក្រមរដ្ឋប្បវេណី)។ ការលែងលះគ្នាទាំងមិនបានកំណត់អំពីអ្នកមានអំណាចមេបា មិនត្រូវបានទទួលស្គាល់តាមក្រមរដ្ឋប្បវេណីទេ។ ដូច្នេះហើយ ក្នុងករណីដែលតុលាការចេញដីកាសម្រេចទទួលស្គាល់នូវការលែងលះដោយផ្អែកតាមពាក្យសុំរបស់ភាគីនៃអាពាហ៍ពិពាហ៍ នៅក្នុងសេចក្តីសម្រេចបញ្ចប់នៃដីកាសម្រេច មិនមែនត្រឹមតែឲ្យ ① ភាគីលែងលះគ្នាទេ គឺចាំបាច់ត្រូវតែ ②កំណត់អំពីអ្នកមានអំណាចមេបាផងដែរ។ នៅក្នុងតារាងឧបសម្ព័ន្ធនៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង មិនបានសរសេរអំពី "ដីកា

(២) កំណត់ថា ដើមចោទជាអ្នកមានអំណាចមេបាលើកូនប្រុសរវាងដើមចោទ និងចុងចម្លើយដែលមានឈ្មោះ សុក សុជាតិ (កើតនៅថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៦) ។[6]

(៣) កំណត់ថា ដើមចោទជាអ្នកមានអំណាចមេបាលើកូនស្រីរវាងដើមចោទ និងចុងចម្លើយដែលមានឈ្មោះ សុក សុជាតា (កើតនៅថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១៨) ។[7]

(៤) បង្គាប់ឲ្យចុងចម្លើយបង់ប្រាក់ចំនួន ១៥០ ដុល្លារអាមេរិកក្នុង ១ ខែ ឲ្យទៅដើមចោទគិតត្រឹមថ្ងៃចុងក្រោយជារៀងរាល់ខែ ក្នុងអំឡុងពេលគិតចាប់ពីថ្ងៃដែលសាលក្រម

---

សម្រេចអំពីអ្នកមានអំណាចមេបាដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ៣ មាត្រា ១០៣៧" គឺដោយសារតែមានការព្យាករថា នៅពេលដែលធ្វើការសម្រេចសេចក្តីអំពី " ពាក្យសុំលែងលះដោយការព្រមព្រៀងដោយយោងតាមបញ្ញត្តិនៃមាត្រា ៩៧៩ (ការលែងលះដោយការព្រមព្រៀង) (តារាងឧបសម្ព័ន្ធ ផ្នែកទី ៤ ចំណុចទី ៥" គឺចាំបាច់ត្រូវតែសម្រេចអំពីអ្នកមានអំណាចមេបាផងដែរ (មិនអាចដាក់ពាក្យសុំអំពីការសម្រេចអំណាចមេបាដោយឯករាជ្យដាច់តែឯងបានទេ។ ចាំបាច់ត្រូវឲ្យតុលាការសម្រេចជាមួយគ្នានៅក្នុងពាក្យសុំលែងលះ។)។

ប៉ុន្តែ ក្នុងករណីដែលភាគីម្ខាងនៃអាពាហ៍ពិពាហ៍មិនព្រមព្រៀងលែងលះគ្នា ឬ ភាគីសងខាងបានព្រមព្រៀងលែងលះគ្នា ប៉ុន្តែ មិនបានព្រមព្រៀងគ្នាសម្រេចអំពីអ្នកមានអំណាចមេបាទេ នឹងត្រូវដាក់ពាក្យបណ្តឹងទាមទារលែងលះគ្នា (មាត្រា ៩៧៨ និង មាត្រា ៩៨២ នៃក្រមរដ្ឋប្បវេណី)។ ក្នុងករណីទាំងនេះ តុលាការនឹងត្រូវធ្វើការសម្រេចសេចក្តី(សាលក្រម) ដោយផ្អែកតាមច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល (មាត្រា ១៣នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល) ដែលជានីតិវិធីមួយខុសគ្នាខ្លាំងទៅនឹងនីតិវិធីរដ្ឋប្បវេណីធម្មតា។ ក្នុងករណីដែលតុលាការបានចេញសាលក្រម ដោយប្រើប្រាស់នូវបញ្ញត្តិនៃក្រមនីតិវិធីរដ្ឋប្បវេណីដែលមិនអាចយកមកអនុវត្តបាននៅក្នុងនីវិធីឋានៈបុគ្គល សាលក្រមនោះនឹងក្លាយទៅជាសាលក្រមដែលខុសច្បាប់ ដូច្នេះហើយ ត្រូវមានការប្រុងប្រយ័ត្ន ជាពិសេសគឺ ចៅក្រម។

[6] ប្រសិនបើតុលាការចេញសាលក្រមទទួលស្គាល់បណ្តឹងទាមទារលែងលះ តុលាការត្រូវធ្វើការសម្រេចសេចក្តីអំពីការកំណត់អ្នកមានអំណាចមេបា "ដោយឆន្ទានុសិទ្ធិ" (កថាខណ្ឌទី ១ មាត្រា ២២ នៃច្បាប់ស្តីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល)។ ពាក្យថា "ដោយឆន្ទានុសិទ្ធិ" គឺមានន័យថា តុលាការចាំបាច់ត្រូវតែសម្រេចសេចក្តីបើទោះបីជាគ្មានពាក្យសុំរបស់ភាគីក៏ដោយ។ ប្រសិនបើនៅក្នុងពាក្យបណ្តឹងដើមចោទមិនបានសរសេរអំពីការកំណត់អ្នកមានអំណាចមេបានៅក្នុងខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញក៏ដោយ ក៏តុលាការត្រូវកំណត់អ្នកមានអំណាចមេបាឲ្យទៅដើមចោទ ឬ ចុងចម្លើយណាម្ខាងដែរ ក្នុងករណីដែលទទួលស្គាល់បណ្តឹងទាមទារលែងលះ។ ប៉ុន្តែ ការកំណត់អំណាចមេបានេះ ក៏តុលាការនឹងយកមកយោងនៅពេលដែលសម្រេចថាតើកំណត់អំណាចមេបាឲ្យទៅដើមចោទ ឬ ចុងចម្លើយណាម្ខាងផងដែរ? (តើដើមចោទមាន ឬ គ្មានឆន្ទៈបីបាច់រក្សារូបកាយកូនដែរទេ?) ដូច្នេះហើយ បើសិនជាដើមចោទមានឆន្ទៈ តុលាការក៏អាចសរសេរអំពីឆន្ទៈនោះបានផងដែរ។

[7] ខ្លឹមសារដូចគ្នានឹង Footnote 6។

នេះចូលជាស្ថាពររហូតដល់ឈ្មោះ សុក សុជាតិ ដែលបានកត់ត្រានៅក្នុងចំណុច (២) ខាងលើនេះក្លាយជានីតិជន។[8]

**(៥)** បង្គាប់ឲ្យចុងចម្លើយបង់ប្រាក់ចំនួន ១៥០ ដុល្លារអាមេរិកក្នុង ១ ខែ ឲ្យទៅដើមចោទគិតត្រឹមថ្ងៃចុងក្រោយជារៀងរាល់ខែ ក្នុងអំឡុងពេលគិតចាប់ពីថ្ងៃដែលសាលក្រមនេះចូលជាស្ថាពររហូតដល់ឈ្មោះ សុក សុជាតា ដែលបានកត់ត្រានៅក្នុងចំណុច (៣) ខាងលើនេះក្លាយជានីតិជន។[9]

**(៦)** បង្គាប់ឲ្យចុងចម្លើយបង់ប្រាក់ចំនួន ១០០ ដុល្លារអាមេរិកក្នុង ១ខែ ឲ្យទៅដើមចោទគិតត្រឹមថ្ងៃចុងក្រោយជារៀងរាល់ខែ ក្នុងអំឡុងពេលគិតចាប់ពីថ្ងៃដែលសាលក្រមនេះចូលជាស្ថាពររហូតដល់ដើមចោទរៀបអាពាហ៍ពិពាហ៍ថ្មី។[10]

---

[8] ឪពុក ឬ ម្ដាយដែលពុំមានអំណាចមេបា ក្រោយពេលលែងលះគ្នា មានសិទ្ធិចូលជួប និង ប្រាស្រ័យទាក់ទងជាមួយកូន និង មានករណីយកិច្ចទទួលបន្ទុកលើសោហ៊ុយដែលចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន (កថាខណ្ឌទី ១ មាត្រា ១០៤០ នៃក្រមរដ្ឋប្បវេណី)។

បើតុលាការចេញសាលក្រមដែលទទួលស្គាល់បណ្ដឹងទាមទារលែងលះ ហើយបើមានពាក្យសុំពីភាគី ត្រូវធ្វើការសម្រេចសេចក្ដីអំពីការចាត់ចែងទាក់ទងនឹងការបីបាច់រក្សាកូន (កថាខណ្ឌទី ១ មាត្រា ២២ នៃច្បាប់ស្ដីពីនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល)។ ក្នុងករណីនេះ នៅក្នុងសាលក្រម តុលាការអាចបង្គាប់ឲ្យភាគីប្រគល់កូន ឬ បង់ប្រាក់ ឬ ផ្ដល់តាវកាលិកផ្សេងទៀត (កថាខណ្ឌទី ២ មាត្រា ២២)។

ដើមចោទ បានដាក់ពាក្យសុំទាមទារទៅចុងចម្លើយដែលមិនបានក្លាយជាអ្នកមានអំណាចមេបាលើកូនតាមរយៈការលែងលះឲ្យបង់ប្រាក់ដែលជាការទទួលបន្ទុកទៅលើសោហ៊ុយចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន។ ក្នុងករណីនេះ តុលាការត្រូវតែសម្រេចទៅលើពាក្យសុំនេះ។

[9] ខ្លឹមសារដូចគ្នានឹង Footnote 8។

[10] ក្នុងករណីលែងលះគ្នា ភាគីដែលគ្មានកំហុស ហើយខ្វះខាត អាចស្នើសុំអាហារកិច្ចពីភាគីម្ខាងទៀតបាន។ ភាគីខាងក្រោយនេះ ត្រូវតែជួយឧបត្ថម្ភទៅតាមលទ្ធភាពរបស់ខ្លួន។ កំរិតអាហារកិច្ចត្រូវសំរេចទៅតាមការយល់ព្រមរបស់គូភាគីទាំងសងខាង។ ក្នុងករណីដែលគូភាគីទាំងសងខាងមិនឯកភាពគ្នា តុលាការប្រជាជនត្រូវសំរេចសេចក្ដី។ បើជនដែលទទួលអាហារកិច្ច រៀបអាពាហ៍ពិពាហ៍ថ្មីទៀត ជននោះឈប់មានសិទ្ធិទទួលអាហារកិច្ចទៀតហើយ ( មាត្រា ៧៦ នៃច្បាប់ស្ដីពីអាពាហ៍ពិពាហ៍និងគ្រួសារ)។

ដើមចោទ បានទាមទារទៅចុងចម្លើយឲ្យបង់អាហារកិច្ចដោយផ្អែកតាមមាត្រា ៧៦ នៃច្បាប់ស្ដីពីអាពាហ៍ពិពាហ៍និងគ្រួសារ។

**(៧)** បែងចែកទ្រព្យសម្បត្តិនីមួយៗ ដែលបានកត់ត្រានៅក្នុង "បញ្ជីទ្រព្យសម្បត្តិរួម"[11]នៃឧបសម្ព័ន្ធ ដូចខាងក្រោមនេះ ៖[12]

**ក.** ដីចំណុច ១. ដែលកត់ត្រានៅក្នុង " បញ្ជីទ្រព្យសម្បត្តិរួម " នៃឧបសម្ព័ន្ធ (តទៅហៅថា "ដី L 1") ជាកម្មសិទ្ធិរបស់កូនប្រុសរវាងដើមចោទ និង ចុងចម្លើយដែលមានឈ្មោះ សុក សុជាតិ។[13] ***(※ ការទាមទារនេះ មិនត្រឹមត្រូវទេ។ ដោយសារតែនៅក្នុង "លិខិតពាក្យសុំកែតម្រូវលើពាក្យបណ្ដឹង" ត្រូវបានកែតម្រូវ ហេតុនេះចំពោះការទាមទារដែលត្រឹមត្រូវ សូមពិនិត្យមើលឯកសារនៃលិខិតនោះ។)***

**ខ.** ដីចំណុច ២. ដែលកត់ត្រានៅក្នុង " បញ្ជីទ្រព្យសម្បត្តិរួម " នៃឧបសម្ព័ន្ធ (តទៅហៅថា " ដី L2 " ) ជាកម្មសិទ្ធិអវិភាគរវាងដើមចោទ និង ចុងចម្លើយក្នុងចំណែកម្នាក់ៗចំនួន ១ ភាគ ២ ។

---

[11] ឧបសម្ព័ន្ធ ជាឯកសារមួយដែលបានបង្កើតដើម្បីដាក់បញ្ចូលព័ត៌មាននោះ ហើយជាផ្នែកតែមួយនៃឯកសារដើម។ ឧបសម្ព័ន្ធ គឺគ្រាន់តែជាការសរសេរដើម្បីធ្វើការសរុបនូវខ្លឹមសារមួយផ្នែកដាក់នៅក្នុងទំព័រចុងក្រោយ ដោយផ្អែកលើការពិចារណាអំពីភាពងាយស្រួលនៃការអានខ្លឹមសារទាំងស្រុងនៃឯកសារដើម។ ដូច្នេះហើយ ប្រសិនបើ "ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ" ត្រូវបានដកស្រង់ខ្លឹមសារទៅដាក់នៅក្នុងឧបសម្ព័ន្ធនោះមានន័យថា គេគ្រាន់តែបានយកខ្លឹមសារមួយផ្នែកដែលមានភាពចាំបាច់ត្រូវសរសេរនៅក្នុង "ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ" មកសរសេរសរុបដាក់នៅក្នុងទំព័រចុងក្រោយតែប៉ុណ្ណោះ ហើយ <u>"ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ" ក៏រួមបញ្ចូលទាំងឧបសម្ព័ន្ធ</u> <u>ផងដែរ</u>។

[12] ក្នុងករណីដែលប្ដីប្រពន្ធលែងលះគ្នា ត្រូវបែងចែកទ្រព្យសម្បត្តិដោយយុត្តិធម៌ ផ្អែកតាមការពិភាក្សារបស់ភាគីទាំងសងខាង (កថាខណ្ឌទី ១ មាត្រា ៩៨០ នៃក្រមរដ្ឋប្បវេណី)។ ក្នុងករណីដែលមិនអាចពិភាក្សាគ្នារវាងប្ដីប្រពន្ធបានទេ ត្រូវបែងចែកទ្រព្យសម្បត្តិដោយផ្អែកទៅតាមចំណុចនីមួយៗ នៅក្នុងកថាខណ្ឌទី ២ នៃមាត្រា ៩៨០ នៃក្រមរដ្ឋប្បវេណី។

បើតុលាការចេញសាលក្រមដែលទទួលស្គាល់បណ្ដឹងទាមទារលែងលះ ហើយបើមានពាក្យសុំពីភាគី ត្រូវធ្វើ ការសម្រេចសេចក្ដីអំពីការចាត់ចែងទាក់ទងនឹងការបីបាច់រក្សាកូន (កថាខណ្ឌទី ១ មាត្រា ២២ នៃច្បាប់ស្ដីពីនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល)។ ក្នុងករណីនេះ នៅក្នុងសាលក្រម តុលាការអាចបង្គាប់ឲ្យភាគីប្រគល់កូន ឬ បង់ប្រាក់ ឬ ផ្ដល់តាវកាលិកផ្សេងទៀត (កថាខណ្ឌទី ២ មាត្រា ២២)។

ដើមចោទបានដាក់ពាក្យសុំទាមទារឲ្យបែងចែកទ្រព្យសម្បត្តិរួម។ ក្នុងករណីនេះ តុលាការត្រូវតែសម្រេចសេចក្ដីចំពោះពាក្យសុំនេះផងដែរ។

[13] នៅក្នុងការបែងចែកទ្រព្យសម្បត្តិ មិនអាចប្រទានកម្មទ្រព្យសម្បត្តិទៅឲ្យតតិយជនក្រៅពីប្ដីប្រពន្ធបានទេ។ ប្រធានដែលទទួលបាននូវទ្រព្យសម្បត្តិ គឺ "សហព័ទ្ធនីមួយៗ" ដែលមានចែងនៅក្នុងចំណុចនីមួយៗនៃកថាខណ្ឌទី២ មាត្រា៩៨០ នៃក្រមរដ្ឋប្បវេណី។ ការណ៍ដែលឲ្យតតិយជនក្រៅពីសហព័ទ្ធនីមួយៗទទួលបាន គឺក្រមរដ្ឋប្បវេណីមិនទទួលស្គាល់នោះទេ។

<u>**ការអះអាងនេះ ត្រូវបានកែតម្រូវដោយ "លិខិតពាក្យសុំកែតម្រូវលើពាក្យបណ្ដឹង" ហេតុនេះសូមពិនិត្យមើលទាំងឯកសារនៃលិខិតនោះផង។**</u>

បង្គាប់ឲ្យលក់ដេញថ្លៃលើ " ដី L2 " ហើយយកចំនួនទឹកប្រាក់ដែលបានដកសោហ៊ុយសម្រាប់នីតិវិធីពីថ្លៃលក់នោះមកបែងចែកឲ្យទៅដើមចោទ និងចុងចម្លើយក្នុងម្នាក់ៗ ចំនួន ១ ភាគ ២។

គ. ឡានចំណុច ៣. ដែលបានកត់ត្រានៅក្នុង " បញ្ជីទ្រព្យសម្បត្តិរួម " នៃឧបសម្ព័ន្ធ (តទៅហៅថា " រថយន្តនៃរឿងក្តីនេះ " ) ជាកម្មសិទ្ធិរបស់ចុងចម្លើយ។

បង្គាប់ឲ្យចុងចម្លើយបង់ប្រាក់ចំនួន ៥.000 ដុល្លារអាមេរិកឲ្យទៅដើមចោទ។

ឃ. ម៉ូតូចំណុច ៤. ដែលបានកត់ត្រានៅក្នុង " បញ្ជីទ្រព្យសម្បត្តិរួម " នៃឧបសម្ព័ន្ធ (តទៅហៅថា " ម៉ូតូនៃរឿងក្តីនេះ " ) ជាកម្មសិទ្ធិរបស់ដើមចោទ។

ង. ប្រាក់សន្សំចំណុច ៥. ដែលបានកត់ត្រានៅក្នុង " បញ្ជីទ្រព្យសម្បត្តិរួម " នៃឧបសម្ព័ន្ធ (តទៅហៅថា " ប្រាក់សន្សំនៃរឿងក្តីនេះ " ) ជាកម្មសិទ្ធិចុងចម្លើយ។

បង្គាប់ឲ្យចុងចម្លើយបង់ប្រាក់ចំនួន ២៥0 ដុល្លារអាមេរិកឲ្យទៅដើមចោទ។

ច. កាតព្វកិច្ចចំណុច ៦. ដែលបានកត់ត្រានៅក្នុង " បញ្ជីទ្រព្យសម្បត្តិរួម " នៃឧបសម្ព័ន្ធ ជាបន្ទុករបស់ចុងចម្លើយ។ *(※ ការទាមទារនេះ មិនត្រឹមត្រូវទេ។ ដោយសារតែនៅក្នុង "លិខិតពាក្យសុំកែតម្រូវលើពាក្យបណ្តឹង" ត្រូវបានកែតម្រូវ ហេតុនេះ ចំពោះការទាមទារដែលត្រឹមត្រូវ សូមពិនិត្យមើលឯកសារនៃលិខិតនោះ។)*

ឆ. កាតព្វកិច្ចចំណុច ៧. ដែលបានកត់ត្រានៅក្នុង " បញ្ជីទ្រព្យសម្បត្តិរួម " នៃឧបសម្ព័ន្ធ ជាបន្ទុករបស់ចុងចម្លើយ។ *(※ ការទាមទារនេះ មិនត្រឹមត្រូវទេ។ ដោយសារតែនៅក្នុង "លិខិតពាក្យសុំកែតម្រូវលើពាក្យបណ្តឹង" ត្រូវបានកែតម្រូវ ហេតុនេះ ចំពោះការទាមទារដែលត្រឹមត្រូវ សូមពិនិត្យមើលឯកសារនៃលិខិតនោះ។)*

(៨) ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ចុងចម្លើយ។[14]

## ខ. អង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ និង អង្គហេតុដែលជាមូលហេតុនៃការទាមទារ [15]

### ខ.១. ការបង្កើតអាពាហ៍ពិពាហ៍ និង ការរួមរស់ជីវភាពជាមួយគ្នាបន្ទាប់ពីពេលនោះ

**ខ.១.១.** ចុងចម្លើយកាលពីមុនបានរស់នៅក្បែរលំនៅដ្ឋានបច្ចុប្បន្នរបស់ដើមចោទ (ស្រុកកំណើតរបស់ដើមចោទ) ហើយដើមចោទស្ថិតនៅជាកុមារភាពនៅឡើយ។ ដោយសារតែការដើរស្វែងរកការងារធ្វើ ចុងចម្លើយក៏បានរើផ្ទះមកទីលំនៅបច្ចុប្បន្នរបស់ចុងចម្លើយ។ ក្រោយមក ដើមចោទ និង ចុងចម្លើយបានស្រលាញ់គ្នារយៈពេលជាង ១ឆ្នាំ ។ ហើយនៅថ្ងៃទី ៣ ខែ សីហា ឆ្នាំ២០១៥ ដើមចោទ និង ចុងចម្លើយបានទៅចុះបញ្ជីអាពាហ៍ពិពាហ៍នៅសាលាឃុំដែលជាលំនៅដ្ឋានបច្ចុប្បន្នរបស់ដើមចោទ (ស្រុកកំណើតរបស់ដើមចោទ) បន្ទាប់មកក៏បានចាប់ផ្ដើមរួមរស់ជីវភាពជាមួយគ្នានៅលំនៅដ្ឋានរបស់ចុងចម្លើយ។ **(ភស្តុតាង $X_1$ ・ $X_2$)**

**ខ.១.២.** នៅថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៦ កូនប្រុសឈ្មោះ សុក សុជាតិ (តទៅហៅថា "សុជាតិ") បានកើត ។ **( ភស្តុតាង $X_3$ )**

**ខ.១.៣.** នៅថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១៧ កូនស្រីឈ្មោះ សុក សុជាតា (តទៅហៅថា "សុជាតា") បានកើត ។ **( ភស្តុតាង $X_4$ )**

### ខ.២. មូលហេតុនៃការលែងលះគ្នា (ចំណុច ង កថាខណ្ឌទី ១ នៃមាត្រា ៩៧៨ ក្រមរដ្ឋប្បវេណី)

---

[14] តុលាការត្រូវសម្រេចសេចក្ដីអំពីករណីយកិច្ចទទួលបន្ទុកប្រាក់ប្រដាប់ក្ដី ទោះបីជាគ្មានពាក្យសុំរបស់ភាគីក៏ដោយ (កថាខណ្ឌទី ៣ មាត្រា ១៨២ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ ហើយ ប្រាក់ប្រដាប់ក្ដី គឺជាបន្ទុករបស់ភាគីចាញ់ក្ដី (មាត្រា ៦៥ កថាខណ្ឌទី ១)។

[15] អង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ គឺជាចំណុចដែលចាំបាច់ត្រូវសរសេរនៅក្នុងពាក្យបណ្ដឹង (ចំណុច ខ កថាខណ្ឌទី ២ មាត្រា ៧៥ នៃក្រមរដ្ឋប្បវេណី)។

ម្យ៉ាងទៀត នៅក្នុងពាក្យបណ្ដឹង ត្រូវសរសេរបញ្ជាក់ឲ្យបានច្បាស់លាស់នូវអង្គហេតុដែលជាមូលហេតុនៃការទាមទារ និង តាមចំណុចដែលត្រូវការបញ្ជាក់ភស្តុតាង គប្បីសរសេរបញ្ជាក់នូវអង្គហេតុសំខាន់ៗ ក្នុងចំណោមអង្គហេតុទាំងមូលដែលទាក់ទងនឹងអង្គហេតុដែលជាមូលហេតុនៃការទាមទារ និង ភស្តុតាង (កថាខណ្ឌទី ៣ មាត្រា ៧៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

**ខ.២.១.** ដើមចោទបានធ្វើការងារបណ្ដើរ ហើយមើលថែទាំកូនបណ្ដើរនៅទីក្រុងភ្នំពេញទាំងពុំមានសាច់ញាតិណាម្នាក់នៅទីក្រុងភ្នំពេញឡើយ ហើយបើទោះបីជានៅក្រោយកំណើតសុជាតិក៏ដោយ ក៏ភាគច្រើនចុងចម្លើយនៅតែបានយកការងារ និង ការជួបជុំជាមួយដៃគូដែលសហការជាមួយក្រុមហ៊ុនជាធំជាហេតុនាំអោយម៉ោងត្រលប់មកផ្ទះវិញកាន់តែយប់ជ្រៅ។ មិនត្រឹមតែប៉ុណ្ណោះទេ ក្រោយពេលដើមចោទមានទម្ងន់សុជាតា ក៏ដោយ ក៏ចុងចម្លើយមិនជួយសហការក្នុងការមើលថែទាំកូនទាល់តែសោះឡើយ បើទោះបីជាថ្ងៃសម្រាកក៏ដោយ ក៏គាត់បានចេញទៅក្រៅដោយនិយាយថា "មានការជួបជុំជាមួយដៃគូដែលសហការជាមួយក្រុមហ៊ុន" ជាដើម។ ពេលដែលខ្ញុំរវល់មើលថែទាំកូនទាំង ២ ហើយខ្ញុំមិនអាចរៀបចំបាយទឹកឲ្យ Y នោះ Y ក៏ធ្លាប់បានស្ដីបន្ទោសអោយខ្ញុំដូចជា "ផ្ទះនេះមិនត្រូវការអ្នកណាដែលមិនចេះធ្វើការងារផ្ទះទេ" ឬក៏ថា "ឲ្យខ្ញុំត្រលប់ទៅស្រុកកំណើតវិញទៅ" ជាដើមថែមទៀតផង។ **(ភស្តុតាង $X_5$)**

**ខ.២.២.** ដោយសារគិតអំពីកូនតូចទាំងពីរ ដើមចោទបានសុខចិត្តទ្រាំនឹងអាកប្បកិរិយាអស់ទាំងនេះរបស់ចុងចម្លើយ ដូចបានសរសេរនៅក្នុងចំណុច "**ខ.២.១**" ខាងលើនេះ ។ ប៉ុន្តែ នៅថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ២០១៩ Y បានផឹកស្រាហើយត្រលប់មកផ្ទះវិញពាក់កណ្ដាលអាធ្រាត ដើមចោទបានព្រមានទៅចុងចម្លើយ ដោយសារតែបាន ធ្វើអោយភ្ញាក់ សុជាតិ ដែលកំពុងតែគេងលក់ស្រាប់តែចុងចម្លើយផ្ទុះកំហឹង ហើយបានប្រើអំពើហឹង្សាមកលើដើមចោទភ្លាមៗតែម្ដង។ **(ភស្តុតាង $X_5$)**

**ខ.២.៣.** ដោយសារតែដើមចោទបានទទួលរងអំពើហិង្សាជាក់ស្ដែងពីចុងចម្លើយហេតុនេះ ហើយបានធ្វើអោយដើមចោទយល់ថា បើសិនជាបន្តរួមរស់ជីវភាពជាមួយចុងចម្លើយតទៀត នឹងមានបញ្ហា ទើបនៅថ្ងៃទី ៨ ខែ មករា ឆ្នាំ ២០២០ ដើមចោទក៏បាននាំកូនទាំងពីរគឺ សុជាតិ និង សុជាតា ត្រលប់ទៅស្រុកកំណើតរបស់ដើមចោទវិញ ។ ចាប់ពីពេលនោះមក ដើមចោទ និង ចុងចម្លើយក៏បានបន្តរស់បែកគ្នា។ **(ភស្តុតាង $X_6$)**

**ខ.២.៤.** អាស្រ័យដូចបានលើកឡើងខាងលើនេះ ដោយហេតុថា ទំនាក់ទំនងអាពាហ៍ពិពាហ៍រវាងដើមចោទ និង ចុងចម្លើយបានបែកបាក់ ហើយគ្មានសង្ឃឹមថានឹងអាចបដិទានឡើងវិញបានទេ ដូច្នេះហើយ ដើមចោទទាមទារលែងលះជាមួយចុងចម្លើយដោយផ្អែកតាមចំណុច ង កថាខណ្ឌទី ១ មាត្រា ៩៧៨ នៃក្រមរដ្ឋប្បវេណី។

**ខ.៣. ការសម្រេចអំពីអ្នកមានអំណាចមេបា (កថាខណ្ឌទី១ និង ទី៣ នៃមាត្រា ១០៣៧ ក្រមរដ្ឋប្បវេណី)**

**ខ.៣.១.** ក្រោយពីការសម្រាល សុជាតិ និង សុជាតា ដើមចោទបានបីបាច់រក្សារូបកាយរបស់ពួកគេរហូតមក។ ហើយសុជាតិ ទើបតែមានអាយុ ៣ ឆ្នាំ ចំណែកសុជាតា ទើបមានអាយុ ១ ឆ្នាំ ដែលពួកគេទាំងពីរ គឺសុទ្ធតែនៅតូចៗនៅឡើយ។ ដើម្បីឲ្យពួកគេទាំងពីរធំលូតលាស់បានគឺ មិនអាចខ្វះ វត្តមានរបស់ដើមចោទដែលជាម្ដាយបានឡើយ។

**ខ.៣.២.** មកទល់ពេលនេះ ចុងចម្លើយក៏មិនដែលជួយសហការមើលថែរក្សាកូនតូចៗទាំងពីរនេះទាល់តែសោះ ហើយស្ទើរតែពុំដែលបានប៉ះពាល់កូនឡើយ។

**ខ.៣.៣.** ដូច្នេះហើយ ដើមចោទសុំឲ្យតុលាការពិចារណាអំពីផលប្រយោជន៍របស់កូនទាំងពីរនាក់ ហើយសុំកំណត់អ្នកមានអំណាចមេបាលើកូនទាំងពីរឲ្យមកដើមចោទ។

**ខ.៤. បន្ទុកលើសោហ៊ុយដែលចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន (សោហ៊ុយចិញ្ចឹមបីបាច់កូន) (កថាខណ្ឌទី១ ទី២ ទី៤ និង ទី ៦នៃមាត្រា ១០៤០ ក្រមរដ្ឋប្បវេណី)**

**ខ.៤.១.** ដើមចោទបានលាឈប់ពីការងារនៅទីក្រុងភ្នំពេញ បច្ចុប្បន្ននេះកំពុងតែគ្រប់គ្រងថែរក្សាកូនទាំងពីរ ដោយទទួលបានជំនួយពីឪពុកម្ដាយនៅឯស្រុកកំណើត។ បច្ចុប្បន្ននេះ ដើមចោទគ្មានប្រាក់ចំណូលទេ ដោយសារតែមិនមានការងារធ្វើ។

**ខ.៤.២.** ប៉ុន្តែ ចុងចម្លើយកំពុងតែធ្វើការជាបុគ្គលិកក្រុមហ៊ុននៅភ្នំពេញ ហើយមានប្រាក់ចំណូលប្រចាំឆ្នាំប្រហែលជា ៧.០០០ ដុល្លារអាមេរិក។

**ខ.៤.៣.** ហេតុដូច្នេះ ដើមចោទទាមទារទៅចុងចម្លើយឲ្យបង់ប្រាក់សម្រាប់កូនម្នាក់ៗ ចំនួន ១៥០ ដុល្លារអាមេរិកប្រចាំខែនីមួយៗ ( សរុបចំនួន ៣០០

ដុល្លារអាមរិក ) ដែលជាសោហ៊ុយដែលចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូនទាំងពីរ (សោហ៊ុយចិញ្ចឹមបីបាច់កូន) ក្នុងអំឡុងពេលរហូតដល់កូនម្នាក់ៗក្លាយជានីតិជន។

**ខ.៥. ការទាមទារអាហារកិច្ច (ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ មាត្រា ៧៦)**

**ខ.៥.១.** ដើមចោទមិនមានកំហុសចំពោះការលែងលះគ្នាទេ ដូចបានសរសេរនៅក្នុងចំណុច "**ខ.២**" ខាងលើនេះ។ ម្យ៉ាងវិញទៀត ដើមចោទមិនមានប្រាក់ចំណូលទេ ដូចបានកត់ត្រានៅក្នុងចំណុច "**ខ.៤.១**" ។ ដូច្នេះ ដើមចោទទាមទារឲ្យចុងចម្លើយបង់អាហារកិច្ច។

**ខ.៥.២.** ដោយមើលឃើញថា ប្រាក់ចំណូលរបស់ចុងចម្លើយដូចបានកត់ត្រានៅក្នុងចំណុច "**ខ.៤.២**" ខាងលើ នៅក្នុង១ឆ្នាំបានប្រហែល ៧.០០០ ដុល្លារអាមេរិក ហើយចុងចម្លើយត្រូវទទួលបន្ទុកចំពោះសោហ៊ុយចិញ្ចឹមបីបាច់កូនទាំងពីរដូចបានកត់ត្រានៅក្នុងចំណុច "**ខ.៤.២**" នៅក្នុង ១ឆ្នាំ ចំនួន ៣.៦០០ ដុល្លារអាមេរិក (៣០០ ដុល្លារអាមេរិក X ១២ ខែ = ៣.៦០០ ដុល្លារអាមេរិក) ដូច្នេះ ចំពោះចំនួនទឹកប្រាក់នៃអាហារកិច្ចគប្បីកំណត់នៅក្នុង ១ ខែ ចំនួន ១០០ ដុល្លារអាមេរិក។

**ខ.៥.៣.** ដូច្នេះហើយ ដើមចោទទាមទារទៅចុងចម្លើយឲ្យបង់ប្រាក់ក្នុង ១ ខែ ចំនួន ១០០ ដុល្លារអាមេរិកជាអាហារកិច្ចក្នុងអំឡុងពេលគិតត្រឹមដើមចោទរៀបអាពាហ៍ពិពាហ៍ថ្មី។

**ខ.៦. ការបែងចែងទ្រព្យសម្បត្តិ (កថាខណ្ឌទី ២ នៃមាត្រា ៩៨០ ក្រមរដ្ឋប្បវេណី)**

**ខ.៦.១.** រវាងដើមចោទ និង ចុងចម្លើយមានទ្រព្យសម្បត្តិរួមដូចបានកត់ត្រានៅក្នុង "បញ្ជីទ្រព្យសម្បត្តិរួម" នៃឧបសម្ព័ន្ធ។[16] **(ភស្តុតាង $X_7$ $X_8$ $X_9$ $X_{10}$)**

---

[16] ករណីដែលមិនអាចពិភាក្សាបានរវាងប្តីប្រពន្ធ ត្រូវបែងចែកទ្រព្យសម្បត្តិអនុលោមតាមចំណុចនីមួយៗ នៅក្នុងកថាខណ្ឌទី២ មាត្រា៩៨០ នៃក្រមរដ្ឋប្បវេណី។ ចំពោះទ្រព្យសម្បត្តិដោយឡែកដែលកំណត់ នៅក្នុងមាត្រា៩៧២ នៃក្រមរដ្ឋប្បវេណី គឺសហព័ទ្ធនីមួយៗត្រូវទទួលបានទ្រព្យសម្បត្តិដោយឡែកនោះ ហេតុនេះមិនមានភាពចាំបាច់ដែលតុលាការត្រូវបែងចែកនោះទេ។ ចំពោះទ្រព្យសម្បត្តិរួម (មាត្រា៩៧៣) ជាគោលការណ៍ សហព័ទ្ធនីមួយ មានសិទ្ធិទទួលបាន ១ ភាគ ២ នៃទ្រព្យសម្បត្តិរួម ប៉ុន្តែជាករណី លើកលែង ប្រសិនបើមាន ① ករណីពិសេស និង ② ការទាមទាររបស់ប្តីប្រពន្ធណាម្ខាង តុលាការអាច បែងចែកសមាមាត្រដែលខុសពី ១ ភាគ ២ បាន។

នៅក្នុងរឿងក្តីនេះ ដើមចោទ អះអាង "ទំហំនៃការបរិច្ចាគរបស់ភាគីនីមួយៗចំពោះ" "លទ្ធកម្មនៃទ្រព្យសម្បត្តិ" (វាក្យខណ្ឌទី២ ចំណុច ខ កថាខណ្ឌទី២ មាត្រា៩៨០ នៃក្រមរដ្ឋប្បវេណី) ដែលជាករណីពិសេស ហើយសុំទាមទារឲ្យតុលាការបែកចែកសមាមាត្រដែលមិនមែន ១ ភាគ ២។

**ខ.៦.២.** ចំពោះដី L1 និង ដី L 2 គឺដើមចោទ និង ចុងចម្លើយ បានទិញដោយប្រើប្រាស់ប្រាក់សន្សំដែលមានរៀងៗខ្លួននៅមុនពេលអាពាហ៍ពិពាហ៍ និង ប្រាក់ដែលបានខ្ចីពីធនាគាររួមគ្នា។ ចំពោះដី L 1 គឺចង់ប្រទានកម្មទៅឲ្យសុជាតិ ដែលជាកូនរបស់ខ្លួនទាំងពីរ។[17] ***(※ ការអះអាងនេះ មិនត្រឹមត្រូវទេ។ ដោយសារតែនៅក្នុង "លិខិតពាក្យសុំកែតម្រូវលើពាក្យបណ្ដឹង" ត្រូវបានកែតម្រូវ ហេតុនេះ ចំពោះការអះអាងដែលត្រឹមត្រូវ សូមពិនិត្យមើលឯកសារនោះ។)*** *ចំពោះដី L 2 នឹងលក់ចេញ ហើយប្រាក់ថ្លៃលក់នោះ គឺចង់ចែកពាក់កណ្ដាលជាមួយចុងចម្លើយ។*

ចំពោះរថយន្តនៃរឿងក្ដីនេះ តម្លៃនាពេលបច្ចុប្បន្ន គឺ ១០.០០០ ដុល្លារអាមេរិច។ ដើមចោទ មិនសូវជាប្រើប្រាស់រថយន្តនៃរឿងក្ដីនេះទេ ហេតុនេះ ប្រសិនបើអាចទទួលបានចំនួនទឹកប្រាក់ ៥.០០០ ដុល្លារអាមេរិច ដែលជាចំនួនប្រាក់ពាក់កណ្ដាលពីចុងចម្លើយ គឺចុងចម្លើយអាចយកមកធ្វើជាកម្មសិទ្ធិបាន។

ចំពោះម៉ូតូនៃរឿងក្ដីនេះ គឺដើមចោទបានទិញដោយ ប្រាក់បានមកពីលក់ម៉ូតូដែលមានកម្មសិទ្ធិមុនពេលអាពាហ៍ពិពាហ៍ និង បន្ថែមដោយប្រាក់សន្សំរបស់ប្ដីប្រពន្ធ។ ក្រោយពីបានរស់នៅបែកគ្នាជាមួយនឹងចុងចម្លើយក៏ដោយ ក៏ដើមចោទនៅតែប្រើប្រាស់ម៉ូតូនៃរឿងក្ដីនេះ ហើយវាក៏ជាមានភាពចាំបាច់សម្រាប់ទៅទិញទំនិញប្រើប្រាស់ជាប្រចាំ ដូច្នេះ ដើមចោទចង់យកមកធ្វើជាកម្មសិទ្ធិរបស់ខ្លួន។

ចំពោះប្រាក់សន្សំនៃរឿងក្ដីនេះ គឺស្ថិតក្រោមឈ្មោះរបស់ចុងចម្លើយ ហេតុនេះ ទោះបីជាចុងចម្លើយយកមកធ្វើជាកម្មសិទ្ធិក៏មិនអីដែរ ប៉ុន្តែនៅចំណុចនៃពេលចាប់ផ្ដើមរស់នៅបែកគ្នារវាង ដើមចោទ

---

[17] នៅក្នុងការបែងចែកទ្រព្យសម្បត្តិ មិនអាចប្រទានកម្មទ្រព្យសម្បត្តិទៅឲ្យតតិយជនក្រៅពីប្ដីប្រពន្ធបានទេ។ ប្រធានដែលទទួលបាននូវទ្រព្យសម្បត្តិ គឺ "សហព័ទ្ធនីមួយៗ" ដែលមានចែងនៅក្នុងចំណុចនីមួយៗនៃកថាខណ្ឌទី២ មាត្រា៩៨០ នៃក្រមរដ្ឋប្បវេណី។ ការណ៍ដែលឲ្យតតិយជនក្រៅពីសហព័ទ្ធនីមួយៗទទួលបាន គឺក្រមរដ្ឋប្បវេណីមិនទទួលស្គាល់នោះទេ។

**ការអះអាងនេះ ត្រូវបានកែតម្រូវដោយ "លិខិតពាក្យសុំកែតម្រូវលើពាក្យបណ្ដឹង" ហេតុនេះសូមពិនិត្យមើលទាំងឯកសារនៃលិខិតនោះផង។**

និង ចុងចម្លើយ គឺនៅមានសល់ប្រាក់ចំនួន ៥០០ ដុល្លារអាមេរិច ដូច្នេះ ទាមទារឲ្យបង់ប្រាក់ចំនួន ២៥០ ដុល្លារអាមេរិច ដែលជាចំនួនទឹកប្រាក់ពាក់កណ្តាល។

ចំពោះកាតព្វកិច្ចនីមួយៗ ដែលបានកត់ត្រានៅក្នុង "បញ្ជីទ្រព្យសម្បត្តិរួម" នៃឧបសម្ព័ន្ធ ចំណុចលេខ ៦ និង ៧ គឺដើមចោទមិនអាចបង់ប្រាក់បានទេ ហេតុនេះចង់ឲ្យចុងចម្លើយទទួលបន្ទុក។[18] *(※ ការអះអាងនេះ មិនត្រឹមត្រូវទេ។ ដោយសារតែនៅក្នុង "លិខិតពាក្យសុំកែតម្រូវលើពាក្យបណ្តឹង" ត្រូវបានកែតម្រូវ ហេតុនេះ ចំពោះការអះអាងដែលត្រឹមត្រូវ សូមពិនិត្យមើលឯកសារនោះ។)*

## គ. ប្រាក់ប្រដាប់ក្តី

ប្រាក់ប្រដាប់ក្តីនៃរឿងក្តីនេះ គប្បីជាបន្ទុករបស់ចុងចម្លើយ (កថាខណ្ឌទី ១ មាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

## ឃ. ភស្តុតាង

១. សំបុត្រអាពាហ៍ពិពាហ៍របស់ដើមចោទ និង ចុងចម្លើយ (**ភស្តុតាង** $X_1$)[19]

២. សៀវភៅស្នាក់នៅរបស់ចុងចម្លើយ (**ភស្តុតាង** $X_2$)[20]

---

[18] កាតព្វកិច្ចដោយសាមគ្គីភាពរបស់ប្តីប្រពន្ធ មិនអាចធ្វើការបែងចែកតែរវាងប្តីប្រពន្ធទេ។ ប្រសិនបើចង់ផ្លាស់ប្តូរអ្នកទទួកបន្ទុក ឬ ភាគទទួលបន្ទុកនៃកាតព្វកិច្ច ត្រូវពិភាក្សាជាមួយម្ចាស់បំណុល (ក្នុងរឿងក្តីនេះ គឺធនាគារ)។ ចំពោះវិធីលម្អិត សូមយោងការពន្យល់បន្ថែមនៅក្នុងឯកសារស្តីពីឧបសម្ព័ន្ធស្តីពី "ការអះអាងនីមួយៗរបស់ដើមចោទ និង ចុងចម្លើយ" ចំណុច ※ 3 ។

**ការអះអាងនេះ ត្រូវបានកែតម្រូវដោយ "លិខិតពាក្យសុំកែតម្រូវលើពាក្យបណ្តឹង" ហេតុនេះសូមពិនិត្យមើលទាំងឯកសារនៃលិខិតនោះផង។**

[19] "ភាគីនៃអាពាហ៍ពិពាហ៍" អាចដាក់ពាក្យបណ្តឹងទាមទារលែងលះបាន។

"អាពាហ៍ពិពាហ៍" នឹងមានអានុភាព ដោយ ①ការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ②ការជូនដំណឹងជាសាធារណៈ ③ ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ និង ④ការចុះបញ្ជីនៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន (មាត្រា ៩៥៥ នៃក្រមរដ្ឋប្បវេណី)។

ដូច្នេះ បុគ្គលដែលមិនទាន់បានចុះបញ្ជីអាពាហ៍ពិពាហ៍ទេ គឺមិនអាចដាក់ពាក្យបណ្តឹងទាមទារលែងលះបានទេ។

ក្នុងករណីដែលដាក់ពាក្យបណ្តឹងទាមទារលែងលះត្រូវតែដាក់នូវភស្តុតាងបញ្ជាក់អំពីការបានចុះបញ្ជីអាពាហ៍ពិពាហ៍ ពោល គឺសំបុត្រអាពាហ៍ពិពាហ៍។

[20] បណ្តឹងទាមទារលែងលះគ្នា ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចផ្តាច់មុខរបស់សាលាដំបូងដែលមានលំនៅដ្ឋានរបស់ភាគី (កថាខណ្ឌទី ១ មាត្រា ១០ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ "ផ្តាច់មុខ" គឺមានន័យថា មានតែតុលាការដែលបាន

៣. សំបុត្រកំណើតរបស់សុជាតិ (**ភស្តុតាង** $X_3$)[21]

៤. សំបុត្រកំណើតរបស់សុជាតា (**ភស្តុតាង** $X_4$)[22]

៥. កំណត់ហេតុប្រចាំថ្ងៃរបស់ដើមចោទ (**ភស្តុតាង** $X_5$)

៦. សៀវភៅស្នាក់នៅរបស់ឪពុករបស់ដើមចោទ (**ភស្តុតាង** $X_6$)[23]

៧. ច្បាប់ចម្លងនៃវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុរបស់ដី L 1 (**ភស្តុតាង** $X_7$)

៨. ច្បាប់ចម្លងនៃវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុរបស់ដី L 2 (**ភស្តុតាង** $X_8$)

៩. ច្បាប់ចម្លងនៃបណ្ណសម្គាល់យានជំនិះរបស់រថយន្តនៃរឿងក្តីនេះ (**ភស្តុតាង** $X_9$)

១០. បណ្ណសម្គាល់យានជំនិះរបស់ម៉ូតូនៃរឿងក្តីនេះ (**ភស្តុតាង** $X_{10}$)

សេចក្តីដូចមានកំណត់ សូម **លោកប្រធាន** សម្រេចតាមការស្នើសុំ ដោយក្តីអនុគ្រោះ។ សូម **លោកប្រធាន** ទទួលនូវសេចក្តីគោរពដ៏ជ្រាលជ្រៅអំពីខ្ញុំ។

---

កំណត់ប៉ុណ្ណោះទើបមានសមត្ថកិច្ច ក្រៅពីតុលាការនោះគឺពុំមានសមត្ថកិច្ចទេ (យោងតាមមាត្រា ១៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

តាមធម្មតា ក្រមនីតិវិធីរដ្ឋប្បវេណីទទួលស្គាល់អំពី សមត្ថកិច្ចសាលាជម្រះក្តីដែលបានកើតឡើងដោយគ្មានការតវ៉ាពីចុងចម្លើយ (មាត្រា១៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ដូច្នេះហើយ បើសិនជានៅពេលដែលដាក់ពាក្យបណ្តឹងដើមចោទបានយកពាក្យបណ្តឹងទៅដាក់នៅតុលាការដែលគ្មានសមត្ថកិច្ចក៏ដោយ ក៏ចុងក្រោយតុលាការនោះនឹងនៅតែមានសមត្ថកិច្ច។ ប៉ុន្តែ ករណីបែបនេះ នឹងមិនអាចកើតមានចំពោះពាក្យបណ្តឹងទាមទារលែងលះគ្នាបានទេ (នៅក្នុងមាត្រា ១៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី មិនយកមាត្រា ១៤ នៃក្រមដដែលនេះ មកអនុវត្តឡើយ)។

ហេតុដូច្នេះ ដំណាក់កាលនៃការដាក់ពាក្យបណ្តឹង ដើមចោទចាំបាច់ត្រូវសរសេរអំពីអាសយដ្ឋានរបស់ភាគីទុកជាមុនឲ្យបានច្បាស់លាស់។ ដូច្នេះ នៅពេលដាក់ពាក្យបណ្តឹងទាមទារលែងលះគ្នា គឺចាំបាច់ត្រូវតែដាក់នូវឯកសារដែលបញ្ជាក់ឲ្យបានច្បាស់លាស់អំពីអាសយដ្ឋានរបស់ដើមចោទ និង ចុងចម្លើយ ពោលគឺ សៀវភៅស្នាក់នៅរបស់ភាគីនីមួយៗ។

[21] អ្នកដែលមានអំណាចមេបា មានសិទ្ធិ និង ករណីយកិច្ច ត្រូវបីបាច់រក្សារូបកាយរបស់ "កូនដែលជាអនីតិជន" និង គ្រប់គ្រងទ្រព្យសម្បត្តិរបស់កូននោះ (មាត្រា ១០៣៩ នៃក្រមរដ្ឋប្បវេណី)។ ឪពុក ឬ ម្តាយដែលពុំមានអំណាចមេបាក្រោយពេលលែងលះគ្នា មានសិទ្ធិចូលជួប និង ប្រាស្រ័យទាក់ទងជាមួយកូន និង មានករណីយកិច្ចទទួលបន្ទុកលើសោហ៊ុយដែលចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន (កថាខណ្ឌទី១ មាត្រា ១០៤០ នៃក្រមរដ្ឋប្បវេណី)។ ដោយសារតែកូនដែលឪពុកម្តាយត្រូវគ្រប់គ្រងថែរក្សា គឺជាកូនដែលជាអនីតិជន ដូច្នេះហើយ ការទទួលកាតព្វកិច្ចនូវបន្ទុកលើសោហ៊ុយដែលចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូនដោយឪពុក ឬ ម្តាយដែលពុំមានអំណាចមេបាតាមរយៈការលែងលះ គឺធ្វើឡើងនៅក្នុងអំឡុងពេលដែលកូននោះនៅជាអនីតិជន។ ម្យ៉ាងវិញទៀត អនីតិជន គឺសំដៅលើជនដែលមានអាយុក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ (មាត្រា ១៧ នៃក្រមរដ្ឋប្បវេណី)។ ដើមចោទចាំបាច់ត្រូវតែបង្ហាញឲ្យបានច្បាស់លាស់អំពីកូនរវាងដើមចោទ និង ចុងចម្លើយថាជាអនីតិជន ដើម្បីទាមទារទៅចុងចម្លើយឲ្យអនុវត្តនូវកាតព្វកិច្ចទទួលបន្ទុកលើសោហ៊ុយចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន (សោហ៊ុយចិញ្ចឹមបីបាច់កូន)។

[22] ខ្លឹមសារដូចគ្នានឹង Footnote 21 ។

[23] ខ្លឹមសារដូចគ្នានឹង Footnote 20 ។

ខេត្តបាត់ដំបង, ថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០២០

**អ្នកតំណាងដោយអាណត្តិ**

<u>ឯកសារភ្ជាប់</u> P

១-លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ "ច្បាប់ដើម"

២-ច្បាប់ថតចម្លងនៃភស្តុតាងនីមួយៗខាងលើ "ចំនួន ០២ ច្បាប់"

**ឧបសម្ព័ន្ធ**

## បញ្ជីទ្រព្យសម្បត្តិរួម

១. អចលនវត្ថុ

"ទីតាំងដី" ផ្លូវលេខ...... ភូមិ........ ឃុំ........... ស្រុក........ ខេត្តបាត់ដំបង

"លេខក្បាលដី" ..........

២. អចលនវត្ថុ

"ទីតាំងដី" ផ្លូវលេខ...... ភូមិ........ ឃុំ........... ស្រុក........ ខេត្តបាត់ដំបង

"លេខក្បាលដី" .........

៣. រថយន្ត

"ប្រភេទ" ទេសចរណ៍

"ម៉ាក" **LEXUS RX300**

"ពណ៌" ស

"កម្មសិទ្ធិករ" ចុងចម្លើយ

"អាសយដ្ឋាន" ផ្ទះលេខ 00 ផ្លូវ 00 សង្កាត់មនោរម្យ ខណ្ឌ៧មករា ភ្នំពេញ

"ផ្លាកលេខ" ......-........

៤. ម៉ូតូ

"ប្រភេទ" ស្រី

"ម៉ាក" **YAMAHA QBIX**

"ពណ៌" ខ្មៅ

"កម្មសិទ្ធិករ" ដើមចោទ

"អាសយដ្ឋាន" ផ្ទះលេខ 00 ផ្លូវ 00 សង្កាត់មនោរម្យ ខណ្ឌ៧មករា ភ្នំពេញ

"ផ្លាកលេខ"  ......-........

៥. ប្រាក់សន្សំ

"ស្ថាប័នហិរិញ្ញវត្ថុ"  ធនាគារ...... សាខា........

"ប្រភេទ និង លេខគណនី"  ប្រាក់សន្សំធម្មតា ××× ××× ×××

"ឈ្មោះម្ចាស់គណនី"  ចុងចម្លើយ

៦. កាតព្វកិច្ច

"ស្ថាប័នហិរិញ្ញវត្ថុ"  ធនាគារ A សាខា........

"កូនបំណុល"  ដើមចោទ និង ចុងចម្លើយ (កាតព្វកិច្ចដោយសាមគ្គីភាព)

៧. កាតព្វកិច្ច

"ស្ថាប័នហិរញ្ញវត្ថុ"  ធនាគារ B សាខា........

"កូនបំណុល"  ដើមចោទ និង ចុងចម្លើយ (កាតព្វកិច្ចដោយសាមគ្គីភាព)

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# លិខិតពាក្យសុំកែតម្រូវលើពាក្យបណ្ដឹង

**ដើមចោទ**

ឈ្មោះ ៖ X

អាសយដ្ឋាន ៖ ផ្ទះលេខ ០០ ផ្លូវលេខ ០០ ភូមិ...... ឃុំ.......ស្រុក......... ខេត្តបាត់ដំបង។

**អ្នកតំណាងដោយអាណត្តិ**

លោក/លោកស្រី ៖ P

អាសយដ្ឋានការិយាល័យ ៖ ..................................

ឈ្មោះការិយាល័យមេធាវី/ក្រុមមេធាវី/ក្រុមហ៊ុនមេធាវី៖ ............................................
.

លេខទូរស័ព្ទ ៖ ..................................................

**ទីកន្លែងបញ្ជូន** ៖ ការិយាល័យមេធាវី/ ក្រុមមេធាវី/ ក្រុមហ៊ុនមេធាវី..................

**ចុងចម្លើយ**

ឈ្មោះ ៖ Y

អាសយដ្ឋាន ៖ ផ្ទះលេខ ០០ ផ្លូវលេខ ០០ សង្កាត់មនោរម្យ ខណ្ឌ ៧មករា រាជធានីភ្នំពេញ។

**សូមគោរពជូន**
**លោកចៅក្រម J នៃសាលាដំបូងខេត្តបាត់ដំបង**

**កម្មវត្ថុ ៖** ដាក់**លិខិតពាក្យសុំកែតម្រូវ**លើពាក្យបណ្ដឹងរបស់ X ចុះថ្ងៃទី ៤ ខែ ឧសភា ឆ្នាំ ២០២០

**យោង ៖** - ចំណុច ខ កថាខណ្ឌទី ២ មាត្រា ៧៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី

- សំណុំរឿងរដ្ឋប្បវេណីលេខ................ចុះថ្ងៃទី ៤ ខែ ឧសភា ឆ្នាំ ២០២០

**ដោយសារតែនៅក្នុងពាក្យបណ្ដឹងដែលបានដាក់នៅថ្ងៃទី ៤ ខែ ឧសភា ឆ្នាំ ២០២០ មានកំហុស ដូច្នេះ ខ្ញុំសុំកែតម្រូវដូចខាងក្រោម៖**

## ក. កែតម្រូវមួយផ្នែកនៅលើ "ខ្លឹមសារនៃសាលក្រម និង ការចាត់ចែងបន្ទាប់បន្សំដែលដើមចោទទាមទារឲ្យតុលាការចេញ"

**ក.១. កែតម្រូវលេខ (៧) ចំណុច ក នៃ "ខ្លឹមសារនៃសាលក្រម និង ការចាត់ចែងបន្ទាប់បន្សំដែលដើមចោទទាមទារឲ្យតុលាការចេញ" ដូចខាងក្រោម[1]៖**

"មុនពេលកែ"

ដីចំណុច ១ ដែលកត់ត្រានៅក្នុង "បញ្ជីទ្រព្យសម្បត្តិរួម" នៃឧបសម្ព័ន្ធ (តទៅហៅថា "ដី L 1" ) ជាកម្មសិទ្ធិរបស់កូនប្រុសរវាងដើមចោទ និង ចុងចម្លើយដែលមានឈ្មោះ សុក សុជាតិ។

"ក្រោយពេលកែ"

ដីចំណុច ១ ដែលកត់ត្រានៅក្នុង "បញ្ជីទ្រព្យសម្បត្តិរួម" នៃឧបសម្ព័ន្ធ (តទៅហៅថា "ដី L 1" ) ជាកម្មសិទ្ធិអវិភាគរវាងដើមចោទ និង ចុងចម្លើយក្នុងចំណែកម្នាក់ៗ ចំនួន ១ ភាគ ២ ។

បង្គាប់ឲ្យលក់ដេញថ្លៃលើ "ដី L 2" ហើយយកចំនួនទឹកប្រាក់ដែលបានដកសោហ៊ុយសម្រាប់នីតិវិធីពីថ្លៃលក់នោះមកបែងចែកឲ្យទៅដើមចោទ និង ចុងចម្លើយក្នុងម្នាក់ៗ ចំនួន ១ ភាគ ២។

**ក.២. កែតម្រូវលេខ (៧) ចំណុច ច. នៃ " ខ្លឹមសារនៃសាលក្រម និង ការចាត់ចែងបន្ទាប់បន្សំដែលដើមចោទទាមទារឲ្យតុលាការចេញ" ដូចខាងក្រោម[2] ៖**

---

[1] នៅក្នុងការបែងចែកទ្រព្យសម្បត្តិ មិនអាចប្រទានកម្មទ្រព្យសម្បត្តិទៅឲ្យតតិយជនក្រៅពីប្ដីប្រពន្ធបានទេ។ ប្រធានដែលទទួលបាននូវទ្រព្យសម្បត្តិ គឺ "សហព័ទ្ធនីមួយៗ" ដែលមានចែងនៅក្នុងចំណុចនីមួយៗនៃកថាខណ្ឌទី២ មាត្រា៩៨០ នៃក្រមរដ្ឋប្បវេណី។ ការណ៍ដែលឲ្យតតិយជនក្រៅពីសហព័ទ្ធនីមួយៗទទួលបាន គឺក្រមរដ្ឋប្បវេណីមិនទទួលស្គាល់នោះទេ។

[2] កាតព្វកិច្ចដោយសាមគ្គីភាពរបស់ប្ដីប្រពន្ធ មិនអាចធ្វើការបែងចែកតែរវាងប្ដីប្រពន្ធទេ។ ប្រសិនបើចង់ផ្លាស់ប្ដូរអ្នកទទួកបន្ទុក ឬ ភាគទទួលបន្ទុកនៃកាតព្វកិច្ច ត្រូវពិភាក្សាជាមួយម្ចាស់បំណុល (ក្នុងរឿងក្ដីនេះ

"មុនពេលកែ"

កាតព្វកិច្ចចំណុច ៦ ដែលបានកត់ត្រានៅក្នុង "បញ្ជីទ្រព្យសម្បត្តិរួម" នៃឧបសម្ព័ន្ធ ជាបន្ទុករបស់ចុងចម្លើយ។

"ក្រោយពេលកែ"

លុបចោលចំណុចនេះ។

**ក.៣. កែតម្រូវលេខ (៧) ចំណុច ឆ នៃ " ខ្លឹមសារនៃសាលក្រម និង ការចាត់ចែងបន្ទាប់បន្សំដែលដើមចោទទាមទារឲ្យតុលាការចេញ" ដូចខាងក្រោម[3] ៖**

"មុនពេលកែ"

កាតព្វកិច្ចចំណុច ៧ ដែលបានកត់ត្រានៅក្នុង "បញ្ជីទ្រព្យសម្បត្តិរួម" នៃឧបសម្ព័ន្ធ ជាបន្ទុករបស់ចុងចម្លើយ។

"ក្រោយពេលកែ"

លុបចោលចំណុចនេះ។

សូម **លោកចៅក្រម** សម្រេចតាមការអះអាងខាងលើ ដោយក្ដីអនុគ្រោះ។

ខេត្តបាត់ដំបង, ថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០២០

**អ្នកតំណាងដោយអាណត្តិ**

P

គឺធនាគារ)។ ចំពោះវិធីលម្អិត សូមយោងការពន្យល់បន្ថែមនៅក្នុងឯកសារស្ដីពីឧបសម្ព័ន្ធស្ដីពី "ការអះអាងនីមួយៗរបស់ ដើមចោទ និង ចុងចម្លើយ" ចំណុច ※ 3 ។

[3] យោង Footnote 2។

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# ឯកសារចម្លើយ[1]

## ដើមចោទ

ឈ្មោះ ៖ X

អាសយដ្ឋាន ៖ ផ្ទះលេខ ០០ ផ្លូវលេខ ០០ ភូមិ...... ឃុំ.......ស្រុក......... ខេត្តបាត់ដំបង។

## ចុងចម្លើយ

ឈ្មោះ ៖ Y

អាសយដ្ឋាន ៖ ផ្ទះលេខ ០០ ផ្លូវលេខ ០០ សង្កាត់មនោរម្យ ខណ្ឌ៧មករា រាជធានីភ្នំពេញ។

## អ្នកតំណាងដោយអាណត្តិ

លោក/លោកស្រីមេធាវី ៖ B

អាសយដ្ឋានការិយាល័យ ៖............................

ឈ្មោះការិយាល័យមេធាវី/ក្រុមមេធាវី/ក្រុមហ៊ុនមេធាវី៖..........................................

លេខទូរស័ព្ទ ៖..................................................

**ទីកន្លែងបញ្ជូន** ៖ ការិយាល័យមេធាវី/ ក្រុមមេធាវី/ ក្រុមហ៊ុនមេធាវី.................[2]

[1] ឯកសារត្រៀមដែលចុងចម្លើយដាក់ទៅតុលាការជាលើកដំបូង ហៅថា "ឯកសារចម្លើយ"។ នៅក្នុងឯកសារនេះនឹងត្រូវសរសេរអំពី ① ការឆ្លើយតបចំពោះខ្លឹមសារនៃសាលក្រមដែលដើមចោទបានសរសេរនៅក្នុងពាក្យបណ្ដឹង ② ការទទួលស្គាល់ ឬ មិនទទួលស្គាល់នូវអង្គហេតុដែលមានសរសេរនៅក្នុងពាក្យបណ្ដឹង និង ③ អង្គហេតុដើម្បីតវ៉ាចំពោះអង្គហេតុដែលមានសរសេរនៅក្នុងពាក្យបណ្ដឹង (កថាខណ្ឌទី ៣ មាត្រា ១០១នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

[2] មាត្រា ២៤៩ និង មាត្រា ២៥០ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ ការសរសេរអំពីកន្លែងបញ្ជូន មិនមែនជាកាតព្វកិច្ចទេ។ ប្រសិនបើមិនបានសរសេរអំពីទីកន្លែងបញ្ជូន ការបញ្ជូននឹងត្រូវធ្វើឡើងនៅលំនៅដ្ឋានរបស់ចុងចម្លើយជាអាទិ៍។ ដូច្នេះ ក្នុងករណីដែលអ្នកតំណាងដោយអាណត្តិរបស់ចុងចម្លើយចង់ធ្វើការបញ្ជូនទៅទីកន្លែងណាផ្សេងក្រៅពីលំនៅដ្ឋានរបស់ចុងចម្លើយជាអាទិ៍ ចាំបាច់ត្រូវសរសេរអំពីកន្លែងបញ្ជូនចូលទៅក្នុងលិខិតលាយលក្ខណ៍អក្សរ ដូចជាឯកសារចម្លើយជាអាទិ៍។

**សូមគោរពជូន**

**លោក ✔ ចៅក្រមនៃសាលាដំបូងខេត្តបាត់ដំបង**

**<u>កម្មវត្ថុ</u>** ៖ សុំដាក់**ឯកសារចម្លើយដើម្បីឆ្លើយតប**នឹងពាក្យបណ្ដឹងចុះថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០២០ និង លិខិតពាក្យសុំកែតម្រូវលើពាក្យបណ្ដឹងចុះថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ២០២០ របស់ឈ្មោះ X

**<u>យោង</u>**៖-មាត្រា **១០១ កថាខណ្ឌទី ៣** នៃក្រមនីតិវិធីរដ្ឋប្បវេណី

-សំណុំរឿងរដ្ឋប្បវេណី .........ចុះថ្ងៃទី០៤ ខែ ឧសភា ឆ្នាំ ២០២០

## ក. ការឆ្លើយតបចំពោះខ្លឹមសារនៃសាលក្រម និង ការចាត់ចែងបន្ទាប់បន្សំដែលដើមចោទទាមទារឲ្យតុលាការចេញ

(១) ច្រានចោលការទាមទាររបស់ដើមចោទ។

(២) ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ដើមចោទ។

## ខ. ការទទួលស្គាល់ ឬ មិនទទួលស្គាល់នូវអង្គហេតុដែលមានសរសេរនៅក្នុងពាក្យបណ្ដឹង

**ខ.១. ការទទួលស្គាល់ ឬ មិនទទួលស្គាល់អំពី "ការបង្កើតអាពាហ៍ពិពាហ៍ និង ការរួមរស់ជីវភាពជាមួយគ្នាបន្ទាប់ពីពេលនោះ នៃចំណុច ខ.១." នៅក្នុងពាក្យបណ្ដឹង**

**ខ.១.១.** អង្គហេតុដែលត្រូវបានសរសេរនៅក្នុងចំណុច **"ខ.១.១."** នៃពាក្យបណ្ដឹង ៖ ចុងចម្លើយទទួលស្គាល់ ។

**ខ.១.២.** អង្គហេតុដែលត្រូវបានសរសេរនៅក្នុងចំណុច **"ខ.១.២."** នៃពាក្យបណ្ដឹង ៖ ចុងចម្លើយទទួលស្គាល់ ។

**ខ.១.៣.** អង្គហេតុដែលត្រូវបានសរសេរនៅក្នុងចំណុច **"ខ.១.៣"** នៃពាក្យបណ្ដឹង ៖ ចុងចម្លើយទទួលស្គាល់ ។

**ខ.២. ការទទួលស្គាល់ ឬ មិនទទួលស្គាល់អំពី "មូលហេតុនៃការលែងលះគ្នា (ចំណុច ង កថាខណ្ឌទី ១ នៃមាត្រា ៩៧៨ ក្រមរដ្ឋប្បវេណី) នៃចំណុច ខ.២." នៅក្នុងពាក្យបណ្ដឹង**

ខ.២.១. អង្គហេតុដែលត្រូវបានសរសេរនៅក្នុងចំណុច "ខ.២.១." នៃពាក្យបណ្តឹង ៖ ចុងចម្លើយទទួលស្គាល់ថា ដើមចោទពុំមានសាច់ញាតិណាម្នាក់នៅទីក្រុងភ្នំពេញឡើយ ហើយអង្គហេតុក្រៅពីនោះ ចុងចម្លើយមិនទទួលស្គាល់។ មូលហេតុ គឺមានដូចបានសរសេរនៅក្នុងចំណុច "**គ. ការអះអាងរបស់ចុងចម្លើយ**" ខាងក្រោម។

ខ.២.២. អង្គហេតុដែលត្រូវបានសរសេរនៅក្នុងចំណុច "ខ.២.២." នៃពាក្យបណ្តឹង ៖ ចុងចម្លើយមិនទទួលស្គាល់។ មូលហេតុ គឺមានដូចបានសរសេរនៅក្នុងចំណុច "**គ. ការអះអាងរបស់ចុងចម្លើយ**" ខាងក្រោម។

ខ.២.៣. អង្គហេតុដែលត្រូវបានសរសេរនៅក្នុងចំណុច "ខ.២.៣." នៃពាក្យបណ្តឹង ៖ ចុងចម្លើយទទួលស្គាល់ថា នៅថ្ងៃទី ៤ ខែមករា ឆ្នាំ ២០២០ ដើមចោទបាននាំសុជាតិ និង សុជាតា ត្រឡប់ទៅស្រុកកំណើតរបស់ដើមចោទវិញ ហើយចាប់ពីពេលនោះមក ដើមចោទ និង ចុងចម្លើយក៏បានបន្តរស់នៅបែកគ្នា រីឯអង្គហេតុក្រៅពីនោះ ចុងចម្លើយមិនទទួលស្គាល់។ មូលហេតុ គឺមានដូចបានសរសេរនៅក្នុងចំណុច"**គ.ការអះអាងរបស់ចុងចម្លើយ**" ខាងក្រោម។

ខ.២.៤. អង្គហេតុដែលត្រូវបានសរសេរនៅក្នុងចំណុច "ខ.២.៤." នៃពាក្យបណ្តឹង ៖ ចុងចម្លើយមានវិវាទ។

**ខ.៣. ការទទួលស្គាល់ ឬ មិនទទួលស្គាល់អំពី " ការសម្រេចអំពីអ្នកមានអំណាចមេបា (កថាខណ្ឌទី ១ និង ទី ៣ នៃមាត្រា ១០៣៧ ក្រមរដ្ឋប្បវេណី) នៃចំណុច ខ.៣." នៅក្នុងពាក្យបណ្តឹង**

ខ.៣.១. អង្គហេតុដែលត្រូវបានសរសេរនៅក្នុងចំណុច "ខ.៣.១." នៃពាក្យបណ្តឹង ៖ ចុងចម្លើយទទួលស្គាល់ថា សុជាតិ អាយុ ៣ឆ្នាំ និង សុជាតា អាយុ ១ ឆ្នាំ ហើយអង្គហេតុក្រៅពីនោះ ចុងចម្លើយមិនទទួលស្គាល់។ មូលហេតុ គឺមានដូចបានសរសេរនៅក្នុងចំណុច "**គ. ការអះអាងរបស់ចុងចម្លើយ**" ខាងក្រោម។

ខ.៣.២. អង្គហេតុដែលត្រូវបានសរសេរនៅក្នុងចំណុច "ខ.៣.២." នៃពាក្យបណ្ដឹង ៖ ចុងចម្លើយមិនទទួលស្គាល់។ មូលហេតុ គឺមានដូចបានសរសេរនៅក្នុងចំណុច "**គ. ការអះអាងរបស់ចុងចម្លើយ**" ខាងក្រោម។

ខ.៣.៣. អង្គហេតុដែលត្រូវបានសរសេរនៅក្នុងចំណុច "ខ.៣.៣." នៃពាក្យបណ្ដឹង ៖ ចុងចម្លើយមានវិវាទ។

**ខ.៤. ការទទួលស្គាល់ ឬ មិនទទួលស្គាល់អំពី " បន្ទុកលើសោហ៊ុយដែលចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន (សោហ៊ុយចិញ្ចឹមបីបាច់កូន) (កថាខណ្ឌទី ១ ទី ២ ទី ៤ និង ទី ៦ នៃមាត្រា ១០៤០ ក្រមរដ្ឋប្បវេណី) នៃចំណុច ខ.៤." នៅក្នុងពាក្យបណ្ដឹង**

ខ.៤.១. អង្គហេតុដែលត្រូវបានសរសេរនៅក្នុងចំណុច "ខ.៤.១." នៃពាក្យបណ្ដឹង ៖ ចុងចម្លើយទទួលស្គាល់ថា ដើមចោទគ្មានប្រាក់ចំណូល ហើយអង្គហេតុក្រៅពីនោះ ចុងចម្លើយមិនដឹង។

ខ.៤.២. អង្គហេតុដែលត្រូវបានសរសេរនៅក្នុងចំណុច "ខ.៤.២." នៃពាក្យបណ្ដឹង ៖ ចុងចម្លើយទទួលស្គាល់ ។

ខ.៤.៣. អង្គហេតុដែលត្រូវបានសរសេរនៅក្នុងចំណុច "ខ.៤.៣." នៃពាក្យបណ្ដឹង ៖ ចុងចម្លើយមានវិវាទ ។

**ខ.៥. ការទទួលស្គាល់ ឬ មិនទទួលស្គាល់អំពី "ការទាមទារអាហារកិច្ច (ច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និង គ្រួសារ មាត្រា ៧៦) នៃចំណុច ខ.៥." នៅក្នុងពាក្យបណ្ដឹង**

ខ.៥.១. អង្គហេតុដែលត្រូវបានសរសេរនៅក្នុងចំណុច "ខ.៥.១." នៃពាក្យបណ្ដឹង ៖ ចុងចម្លើយទទួលស្គាល់ថា ដើមចោទគ្មានប្រាក់ចំណូល ហើយអង្គហេតុក្រៅពីនោះ ចុងចម្លើយមិនទទួលស្គាល់។ មូលហេតុនោះគឺមានដូចបានសរសេរនៅក្នុងចំណុច "**គ.ការអះអាងរបស់ចុងចម្លើយ**" ខាងក្រោម។

ខ.៥.២. អង្គហេតុដែលត្រូវបានសរសេរនៅក្នុងចំណុច "ខ.៥.២." នៃពាក្យបណ្ដឹង ៖ ចុងចម្លើយទទួលស្គាល់ថា ប្រាក់ចំណូលរបស់ចុងចម្លើយនៅក្នុង១ឆ្នាំបានប្រហែល ៧.០០០ដុល្លារអាមេរិក ហើយអង្គហេតុក្រៅពីនោះចុងចម្លើយមិនទទួលស្គាល់ទេ។ ដើមចោទបាននៀយ

ហាត់នឹងការមើលថែទាំកូន ដូច្នេះហើយគ្រាន់តែត្រឡប់ទៅស្រុកកំណើតវិញតែប៉ុណ្ណោះ។ ចុងចម្លើយមិនបានគិតថា ទំនាក់ទំនងអាពាហ៍ពិពាហ៍រវាងដើមចោទនិងចុងម្លើយបានបែកបាក់ទេ ប៉ុន្តែបើសិនជាដើមចោទបានគិតថា ទំនាក់ទំនងអាពាហ៍ពិពាហ៍ជាមួយនិងចុងម្លើយបានបែកបាក់ ហើយគ្មានសង្ឃឹមថានឹងអាចបដិទានឡើងវិញបានទេ កំហុសនោះ គឺជាកំហុសរបស់ដើមចោទ។ ចុងចម្លើយមិនមានកាតព្វកិច្ចចំពោះការបង់អាហារកិច្ចទេ។

ខ.៥.៣. អង្គហេតុដែលត្រូវបានសរសេរនៅក្នុងចំណុច "ខ.៥.៣." នៃពាក្យបណ្ដឹង ៖ ចុងចម្លើយមានវិវាទ ។

**ខ.៦. ការទទួលស្គាល់ ឬមិនទទួលស្គាល់អំពី "ការបែងចែងទ្រព្យសម្បត្តិ (កថាខណ្ឌទី ២ នៃមាត្រា ៩៨០ ក្រមរដ្ឋប្បវេណី) នៃចំណុច ខ.៦." នៅក្នុងពាក្យបណ្ដឹង**

ខ.៦.១. អង្គហេតុដែលត្រូវបានសរសេរនៅក្នុងចំណុច "ខ.៦.១." នៃពាក្យបណ្ដឹង ៖ ចុងចម្លើយទទួលស្គាល់។

ខ.៦.២. អង្គហេតុដែលត្រូវបានសរសេរនៅក្នុងចំណុច "ខ.៦.២." នៃពាក្យបណ្ដឹង ៖ ចុងចម្លើយមានវិវាទ។ ដើម្បីទទួលបាន "ដី L 1" និង "រថយន្តនៃរឿងក្ដីនេះ" ចុងម្លើយមិនត្រឹមតែបានប្រើប្រាស់ទ្រព្យសម្បត្តិរួមតែប៉ុណ្ណោះទេ ថែមទាំងបានប្រើប្រាស់នូវទ្រព្យសម្បត្តិដោយឡែករបស់ចុងចម្លើយមួយភាគផងដែរ ដូច្នេះហើយ សូមតុលាការពិចារណាទៅលើទំហំនៃការបរិច្ចាគរបស់ចុងចម្លើយចំពោះលទ្ធកម្មនៃទ្រព្យសម្បត្តិទាំងនេះ នៅពេលដែលបែងចែកទ្រព្យសម្បត្តិរួម ("ទំហំនៃការបរិច្ចាគរបស់ភាគីនីមួយៗចំពោះលទ្ធកម្មនៃទ្រព្យសម្បត្តិ ការថែរក្សា ឬ ការបង្កើនទ្រព្យ" វាក្យខណ្ឌទី ២ ចំណុច ខ កថាខណ្ឌទី ២ នៃមាត្រា ៩៨០ )។

## គ. ការអះអាងរបស់ចុងចម្លើយ

### គ.១. ពុំមានមូលហេតុនៃការលែងលះគ្នា (ចំណុច ង កថាខណ្ឌទី ១ នៃមាត្រា ៩៧៨ ក្រមរដ្ឋប្បវេណី)

**គ.១.១.** ចាប់តាំងពីបានចាប់ផ្តើមរួមរស់ជីវភាពរួមគ្នាជាមួយដើមចោទ ដើម្បីរកប្រាក់ចំណូលឲ្យបានច្រើនបន្ថែមទៀត ភាគច្រើនចុងចម្លើយបានធ្វើការបន្ថែមម៉ោង និង បានចូលរួមយ៉ាងសកម្មចំពោះការជួបជុំជាមួយដៃគូដែលសហការជាមួយក្រុមហ៊ុនជាដើម ដែលជាហេតុធ្វើឲ្យម៉ោងត្រឡប់មកផ្ទះវិញកាន់តែយប់ជ្រៅ។ ប៉ុន្តែ ដើមចោទបែរជាសង្ស័យថាចុងចម្លើយមិនស្មោះត្រង់ ហើយក្រោយពេលសុជាតា កើតមក ដើមចោទបែរជាគិតតែពីនិយាយរអ៊ូថា " តើថ្ងៃនេះទើបមកពីផឹកជាមួយស្រីនៅកន្លែងណា?" ជាដើម។ ហើយថ្ងៃដែលដើមចោទមិនបានរៀបចំបាយទឹកហូបចុកក៏កាន់តែច្រើនឡើងៗ។ បើទោះជាចុងចម្លើយបានធុញទ្រាន់ទៅនឹងអាកប្បកិរិយារបស់ដើមចោទដែលមិនបានយល់ពីការងាររបស់ចុងចម្លើយក៏ដោយ ប៉ុន្តែ ចុងចម្លើយបានធ្វើចិត្តឲ្យត្រជាក់ហើយគិតថា អាកប្បកិរិយារបស់ដើមចោទទៅជាបែបនេះក៏ព្រោះតែដើមចោទលែងមានពេលលំហែអារម្មណ៍ ដោយសារតែត្រូវធ្វើការងារ និង មើលថែរទាំកូនទៀត ដូច្នេះ ចុងចម្លើយក៏បានសាកផ្តល់ជាគំនិតទៅដើមចោទថា " ដើម្បីផ្លាស់ប្តូរអារម្មណ៍សាកទៅសម្រាកនៅស្រុកកំណើតមួយរយៈលមើល ?" ជាដើម។ (**ភស្តុតាង $Y_1$**)

**គ.១.២.** ថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ២០១៩ ដោយសារតែចុងចម្លើយចូលរួមកម្មវិធីជប់លៀងគ្រីស្តម៉ាសជាមួយដៃគូដែលសហការជាមួយក្រុមហ៊ុន ហេតុនេះក៏បានត្រលប់ទៅផ្ទះវិញយឺត។ ពេលត្រលប់ទៅដល់ផ្ទះវិញ កូនទាំងពីរបានគេងលក់បាត់ទៅហើយ ប៉ុន្តែ ដោយសារចុងចម្លើយបានរៀបចំកាដូគ្រីស្តម៉ាសឲ្យទៅពួកគេ ហើយចង់ឲ្យកូនទាំង ២ ចាប់អារម្មណ៍ឃើញនៅពេលដែលក្រោកពីដំណេកថ្ងៃបន្ទាប់ ដូច្នេះ ចុងចម្លើយក៏បានគិតថាយកកាដូនោះទៅទុកនៅលើក្បាលដំណេករបស់ពួកគេ ។ ពេលដែលចុងចម្លើយបានធ្វើបែបនេះ ស្រាប់តែដើមចោទ

បានខឹងស្រែកខ្លាំងៗថា "ធ្វើស្អីហ្នឹង?!" ហើយក៏បានយកដៃរុញមកចុងចម្លើយដែលបានខិតចូលទៅជិតក្បាលដំណេកកូនៗ។ ដោយសារតែចុងចម្លើយគិតថា ដៃរបស់ដើមចោទអាចនឹងប៉ះត្រូវចំកូនជាមិនខាន ក៏បានហាមឃាត់ដើមចោទទាំងភ័យស្លន់ស្លោ។ ហើយដើម្បីកុំឲ្យកូនភ្ញាក់ ចុងចម្លើយក៏បានបីដើមចោទពីបន្ទប់គេងចេញមកក្រៅ។ ដើមចោទបានអះអាងថា បានរងនូវអំពើហិង្សាពីចុងចម្លើយ ប៉ុន្តែ អង្គហេតុបែបនេះគឺគ្មានទាល់តែសោះឡើយ។ **(ភស្តុតាង $Y_1$)**

**គ.១.៣.** នៅថ្ងៃទី ៤ ខែ មករា ឆ្នាំ ២០២០ ដើមចោទបានត្រលប់ទៅស្រុកកំណើតវិញ ដោយបាននាំយកកូនទាំងពីរទៅជាមួយផងដែរ ទាំងមិនបាននិយាយពន្យល់អ្វីមកអោយចុងចម្លើយដឹងសោះ។

**គ.១.៤.** បើផ្អែកតាមដំណើររឿងដែលបានលើកឡើងខាងលើនេះ គឺពុំមានមូលហេតុនៃការលែងលះដូចដែលដើមចោទបានអះអាងទេ។ បើទោះបីជារវល់នឹងការងារក៏ដោយ ក៏ចុងចម្លើយបានរក្សាអារម្មណ៍របស់ខ្លួនហើយបានយកចិត្តទុកដាក់ទៅលើដើមចោទផងដែរ ដូច្នេះហើយទំនាក់ទំនងអាពាហ៍ពិពាហ៍មិនទាន់បានបែកបាក់នៅឡើយទេ។ ផ្ទុយមកវិញ ដើមចោទបែរជាចាប់ផ្តើមរស់នៅបែកគ្នាដោយចិត្តឯង ហេតុនេះហើយ គួរតែដើមចោទទៅវិញទេ ដែលចង់ឲ្យទំនាក់ទំនងអាពាហ៍ពិពាហ៍ជាមួយចុងចម្លើយមានការបែកបាក់នោះ។

## គ.២. អំពីការចាត់ចែងបន្ទាប់បន្សំ

ដូចដែលបានអះអាងនៅក្នុងចំណុច " គ.១" ខាងលើនេះ ដោយសារតែទំនាក់ទំនងអាពាហ៍ពិពាហ៍រវាងដើមចោទ និង ចុងចម្លើយមិនទាន់បានបែកបាក់ទេ ដូច្នេះ ចុងចម្លើយយល់ថា បណ្តឹងទាមទារឲ្យលែងលះរបស់ដើមចោទ នឹងមិនត្រូវបានទទួលស្គាល់ទេ។ ដូច្នេះហើយ ចំពោះការចាត់ចែងបន្ទាប់បន្សំដែលបានលើកយកមកផ្អែកជាមុន ទៅលើកករណីដែលការទាមទាររបស់ដើមចោទត្រូវបានទទួលស្គាល់នោះ ក៏ចុងចម្លើយមិនអាចទទួលស្គាល់មួយណាបានផងដែរ។

ម្យ៉ាងវិញទៀត ដើមចោទជាមនុស្សមានសតិអារម្មណ៍មិននឹងនរ ហើយស្រែកខ្លាំងៗភ្លាមៗមួយរំពេចទៅកាន់ចុងចម្លើយជាដើម។ ការចិញ្ចឹមបីបាច់របស់ដើមចោទចំពោះកូនទាំងពីរនឹងមិនអាចធ្វើឲ្យបានត្រឹមត្រូវឡើយ។ ដើមចោទមិនសមនឹងក្លាយទៅជាអ្នកមានអំណាចមេបាលើកូនទាំងពីរនេះទេ។

**ឃ. ភស្តុតាង**

១. កំណាត់ត្រាដែលសាមីចុងចម្លើយបានបង្កើតឡើងដោយផ្អែកតាមការចងចាំ **(ភស្តុតាង$Y_1$)**

២. ការសាកសួរសាមីចុងចម្លើយ

សូម **លោកចៅក្រម** សម្រេចតាមការស្នើសុំ ដោយក្តីអនុគ្រោះ។

រាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០២០

**អ្នកតំណាងដោយអាណត្តិ**

B

<u>ឯកសារភ្ជាប់</u>

១-លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ "ច្បាប់ដើម"

២-ច្បាប់ថតចម្លងនៃភស្តុតាងនីមួយៗខាងលើ "ចំនួន ០២ ច្បាប់"

៣-ឯកសារចម្លងនៃឯកសារចម្លើយ "ចំនួន ០២ ច្បាប់"

**<u>កំណត់ត្រាអំពីដំណើរការនៃនីតិវិធីបណ្តឹង</u>**

※ ថ្ងៃខែទាំងអស់ គឺស្ថិតនៅក្នុងឆ្នាំ ២០២០។

※ មាត្រាដែលបានដកស្រង់ចេញមក គឺជាមាត្រានៃក្រមនីតិវិធីរដ្ឋប្បវេណី

| ថ្ងៃខែ | តួអង្គ | ខ្លឹមសារនៃសកម្មភាពបណ្តឹង |
|---|---|---|
| ថ្ងៃទី៨ ខែឧសភា | ដើមចោទ | ដាក់ពាក្យបណ្តឹង |
| ～ថ្ងៃទី១៤ | តុលាការ | ការពិនិត្យពាក្យបណ្តឹង (កថាខណ្ឌទី ១ នៃមាត្រា ៧៥) |
| | | ស្នើឲ្យដើមចោទធ្វើការកែតម្រូវចំណុចខ្វះខាតដោយស្ម័គ្រចិត្ត |
| ថ្ងៃទី១៥ | ដើមចោទ | ដាក់លិខិតពាក្យសុំកែតម្រូវលើពាក្យបណ្តឹង |
| ថ្ងៃទី២២ | តុលាការ | បញ្ជូន ①ពាក្យបណ្តឹង និង ②លិខិតពាក្យសុំកែតម្រូវលើពាក្យបណ្តឹងទៅចុងចម្លើយ (កថាខណ្ឌទី១ នៃមាត្រា ៧៩) |
| | | បញ្ជូនដីកាកោះអំពីកាលបរិច្ឆេទនៃនីតិវិធីត្រៀមទាញហេតុផលលើកទី១ (ថ្ងៃទី១២ ខែមិថុនា) ទៅចុងចម្លើយ (កថាខណ្ឌទី១ មាត្រា៨០, មាត្រា២៥២) |
| ថ្ងៃទី១២ ខែមិថុនា | ចុងចម្លើយ | ដាក់ឯកសារចម្លើយ (កថាខណ្ឌទី ៣ នៃមាត្រា ១០១) |
| | តុលាការ | កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកទី១ (កថាខណ្ឌទី ២ នៃមាត្រា ៨០) |
| | ដើមចោទ | ថ្លែងការណ៍អំពី①ពាក្យបណ្តឹង និង ②លិខិតពាក្យសុំកែតម្រូវលើពាក្យបណ្តឹង |
| | ចុងចម្លើយ | ថ្លែងការណ៍អំពីឯកសារចម្លើយ |
| ថ្ងៃទី១ ខែកក្កដា | តុលាការ | កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកទី២ |
| | ចុងចម្លើយ | ក្រោយពីការបានដកនូវការអះអាងនៅក្នុងឯកសារចម្លើយ រួចហើយបានអះអាងថា "**ខ្លួនមិនមានឆន្ទៈបន្តអាពាហ៍ពិពាហ៍ជាមួយដើមចោទតទៀតទេ**"។ |
| | | បានបន្ថែមអំពីការអះអាងទាក់ទងនឹងបន្ទុកលើសោហ៊ុយដែលចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន (កូន១នាក់ ក្នុង១ខែគួរតែបង់ ១០០ ដុល្លារអាមេរិក) និង ការអះអាងទាក់ទងនឹងការបែងចែកទ្រព្យសម្បត្តិ (ការអះអាងអំពីទំហំនៃការបរិច្ចាគរបស់ចុងចម្លើយចំពោះលទ្ធកម្មទៅលើដី L1 និងរថយន្តនៃរឿងក្តីនេះ និង ការអះអាងទាក់ទងទៅនឹងវិធីបែងចែកដី L1 និងដីL2) |
| | | បានយកប្រវត្តិប្រតិបត្តិការនៃការដកប្រាក់ពី "គណនីសន្សំធម្មតាដែលបានដាក់ឈ្មោះរបស់ចុងចម្លើយនៅសាខា........របស់ធនាគារ...... (XXX XXX XXX) ដាក់ជាភស្តុតាង។<br>(**ភស្តុតាង** $Y_2$) |
| | ដើមចោទ | បានអះអាងថា "**ខ្លួនមិនមានឆន្ទៈបន្តអាពាហ៍ពិពាហ៍ជាមួយចុងចម្លើយតទៀតទេ**"។ |
| | តុលាការ | បញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល (មាត្រា ១០៧) |
| ថ្ងៃទី២២ | តុលាការ | កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់<br>(កថាខណ្ឌទី ១ នៃមាត្រា ១១៤ កថាខណ្ឌទី ១ និងទី ២ មាត្រា ១១៦) |
| | | ការសាកសួរសាមីភាគី<br>(ដើមចោទ និង ចុងចម្លើយ) (មាត្រា ១៩០) |
| | | បញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ (កថាខណ្ឌទី១ នៃមាត្រា ១៨០) |
| ថ្ងៃទី១២ ខែសីហា | តុលាការ | កាលបរិច្ឆេទនៃការប្រកាសសាលក្រម<br>(មាត្រា ១៨៦ មាត្រា ១៨៧ មាត្រា ១៨៨) |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តបាត់ដំបង

**តុលាការរដ្ឋប្បវេណី**
សំណុំរឿងរដ្ឋប្បវេណីលេខ .......
ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០២០
សាលក្រមលេខ .........
ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ២០២០

# សាលក្រម[1]
# ក្នុងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងខេត្តបាត់ដំបង [2]

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៅ
ថ្ងៃទី ២២ ខែកក្កដា ឆ្នាំ២០២០ [3] [4]

## ចៅក្រមជំនុំជម្រះ

លោក J ជាចៅក្រមនៃសាលាដំបូងខេត្តបាត់ដំបង

[1] ការសម្រេចសេចក្តី គឺចែកចេញជា សាលក្រម និង ដីកាសម្រេច (មាត្រា ១៧៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ដូច្នេះ មានភាពចាំបាច់នៅក្នុងការបញ្ជាក់ឲ្យបានច្បាស់លាស់ថា អំពីប្រភេទនៃការសម្រេចសេចក្តីដាក់នៅត្រង់ចំណុចចាប់ផ្តើម។ ដោយសារតែ សាលក្រម និង ដីកាសម្រេច មានភាពខុសគ្នាចំពោះវិធីក្នុងការធ្វើឧបាស្រ័យ ជាអាទិ៍ ។ ជាគោលការណ៍ បណ្តឹងឧបាស្រ័យចំពោះសាលក្រម គឺ បណ្តឹងឧទ្ធរណ៍ ហើយ បណ្តឹងឧបាស្រ័យចំពោះដីកាសម្រេច គឺ បណ្តឹងជំទាស់ (កថាខណ្ឌទី ១ មាត្រា ២៥៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

[2] នៅក្នុងលិខិតសាលក្រមរដ្ឋប្បវេណី ត្រូវតែសរសេរអំពីចំណុចដែលចែងនៅក្នុងមាត្រា ១៨៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

[3] ចំណុច ខ កថាខណ្ឌទី ១ មាត្រា ១៨៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ សាលក្រម នឹងត្រូវកំណត់ជាស្ថាពរនូវទំនាក់ទំនងសិទ្ធិ ឬទំនាក់ទំនងគតិយុត្តិ នាពេលបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ (កថាខណ្ឌទី ២ មាត្រា ១៩៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ហេតុនេះ ចាំបាច់ត្រូវសរសេរឲ្យបានច្បាស់លាស់អំពី ពេលដែលបានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់។ សាលក្រម គឺជាការសម្រេចសេចក្តីរបស់តុលាការដែលត្រូវបានធ្វើឡើងដោយកំណត់ជាមូលដ្ឋានចម្បងនូវទំនាក់ទំនងអង្គហេតុគិតមកដល់ត្រឹមថ្ងៃបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់។

[4] ជាគោលការណ៍ ការប្រកាសសាលក្រម ត្រូវធ្វើឡើងក្នុងអំឡុងពេល ១ (មួយ) ខែ គិតចាប់ពីថ្ងៃដែលបានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ (មាត្រា ១៨៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ ហើយការប្រកាសសាលក្រម ចាំបាច់ត្រូវធ្វើឡើងដោយផ្អែកលើច្បាប់ដើមនៃមូលសាលក្រម (កថាខណ្ឌទី ១ មាត្រា ១៨៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ដូច្នេះហើយ ចាំបាច់ត្រូវតែបញ្ចប់នូវការតាក់តែងច្បាប់ដើមនៃមូលសាលក្រមឲ្យបាន គិតត្រឹមពេលប្រកាសសាលក្រម។

# **ក្រឡាបញ្ជី**

លោកស្រី C ជាក្រឡាបញ្ជីនៃសាលាខេត្តបាត់ដំបង

## **ដើមចោទ**

ឈ្មោះ ៖ X

អាសយដ្ឋាន ៖ ផ្ទះលេខ ០០ ផ្លូវលេខ ០០ ភូមិ...... ឃុំ.......ស្រុក......... ខេត្តបាត់ដំបង។

## **អ្នកតំណាងដោយអាណត្តិ**

លោក/លោកស្រី ៖ P

អាសយដ្ឋានការិយាល័យ ៖ ................................

ឈ្មោះការិយាល័យមេធាវី/ក្រុមមេធាវី/ក្រុមហ៊ុនមេធាវី ៖ ..........................................

លេខទូរស័ព្ទ ៖ ..................................................

## **ចុងចម្លើយ**

ឈ្មោះ ៖ Y

អាសយដ្ឋាន ៖ ផ្ទះលេខ ០០ ផ្លូវលេខ ០០ សង្កាត់មនោរម្យ ខណ្ឌ៧មករា រាជធានីភ្នំពេញ។

## **អ្នកតំណាងដោយអាណត្តិ**

លោក/លោកស្រី ៖ B

អាសយដ្ឋានការិយាល័យ ៖ ................................

ឈ្មោះការិយាល័យមេធាវី/ក្រុមមេធាវី/ក្រុមហ៊ុនមេធាវី ៖ ..........................................

លេខទូរស័ព្ទ ៖ ..................................................

## អង្គហេតុ និង ចំណុចវិវាទ

### ក. ខ្លឹមសារនៃសាលក្រម និង ការចាត់ចែងបន្ទាប់បន្សំដែលដើមចោទ ទាមទារឲ្យតុលាការចេញ[5]៖

(១) លែងលះដើមចោទ និង ចុងចម្លើយ ។

(២) កំណត់ថា ដើមចោទជាអ្នកមានអំណាចមេបាលើកូនប្រុសរវាងដើមចោទ និង ចុងចម្លើយដែលមានឈ្មោះ សុក សុជាតិ (កើតនៅថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៦) ។

(៣) កំណត់ថា ដើមចោទជាអ្នកមានអំណាចមេបាលើកូនស្រីរវាងដើមចោទ និង ចុងចម្លើយដែលមានឈ្មោះ សុក សុជាតា (កើតនៅថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១៨) ។

(៤) បង្គាប់ឲ្យចុងចម្លើយបង់ប្រាក់ចំនួន ១៥០ ដុល្លារអាមេរិកក្នុង ១ ខែ ឲ្យទៅដើមចោទ គិតត្រឹមថ្ងៃចុងក្រោយជារៀងរាល់ខែ ក្នុងអំឡុងពេលគិតចាប់ពីថ្ងៃដែលសាលក្រម នេះចូលជាស្ថាពររហូតដល់ឈ្មោះ សុក សុជាតិ ដែលបានកត់ត្រានៅក្នុង ចំណុច (២) ខាងលើនេះក្លាយជានីតិជន។

(៥) បង្គាប់ឲ្យចុងចម្លើយបង់ប្រាក់ចំនួន ១៥០ ដុល្លារអាមេរិកក្នុង ១ ខែ ឲ្យទៅដើមចោទ គិតត្រឹមថ្ងៃចុងក្រោយជារៀងរាល់ខែ ក្នុងអំឡុងពេលគិតចាប់ពីថ្ងៃដែលសាលក្រម នេះចូលជាស្ថាពររហូតដល់ឈ្មោះ សុក សុជាតា ដែលបានកត់ត្រានៅក្នុង ចំណុច (៣) ខាងលើនេះក្លាយជានីតិជន។

(៦) បង្គាប់ឲ្យចុងចម្លើយបង់ប្រាក់ចំនួន ១០០ ដុល្លារអាមេរិកក្នុង ១ខែ ឲ្យទៅដើមចោទ គិតត្រឹមថ្ងៃចុងក្រោយជារៀងរាល់ខែ ក្នុងអំឡុងពេលគិតចាប់ពីថ្ងៃដែលសាលក្រម នេះចូលជាស្ថាពររហូតដល់ដើមចោទរៀបអាពាហ៍ពិពាហ៍ថ្មី។

---

[5] ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារ គឺជាចំណុចដែលចាំបាច់ត្រូវសរសេរនៅក្នុងពាក្យបណ្ដឹង (ចំណុច ខ កថាខណ្ឌទី ២ មាត្រា ៧៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ ម្យ៉ាងទៀត ប្រសិនបើតុលាការចេញសាលក្រម ឬ សាលដីកាដែលទទួលស្គាល់បណ្ដឹងទាមទារលែងលះ តុលាការនឹងត្រូវសម្រេចសេចក្ដីអំពីការចាត់ចែងបន្ទាប់បន្សំ (កំណត់អ្នកមានអំណាចមេបា ការចាត់ចែងទាក់ទងនឹងការបីបាច់រក្សាកូន ឬ ការចាត់ចែងទាក់ទងនឹងការបែងចែកទ្រព្យសម្បត្តិ) ដោយឆន្ទានុសិទ្ធិ ឬ តាមពាក្យសុំ ដូច្នេះហើយ ដើមចោទគប្បីសរសេរទុកជាមុនអំពីខ្លឹមសារនៃការចាត់ចែងបន្ទាប់បន្សំដែលទាមទារឲ្យតុលាការចេញ ទើបជាការប្រសើរ (កថាខណ្ឌទី ១ មាត្រា ២២ នៃច្បាប់ស្ដីពីនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល)។

**(៧)** បែងចែកទ្រព្យសម្បត្តិនីមួយៗ ដែលបានកត់ត្រានៅក្នុង "បញ្ជីទ្រព្យសម្បត្តិរួម" នៃឧបសម្ព័ន្ធ ដូចខាងក្រោមនេះ ៖

**ក.** ដីចំណុច ១. ដែលកត់ត្រានៅក្នុង "បញ្ជីទ្រព្យសម្បត្តិរួម" នៃឧបសម្ព័ន្ធ (តទៅហៅថា "ដី L 1") ជាកម្មសិទ្ធិអវិភាគរវាងដើមចោទ និង ចុងចម្លើយក្នុងចំណែកម្នាក់ៗចំនួន ១ ភាគ ២។

បង្គាប់ឲ្យលក់ដេញថ្លៃលើ "ដី L 1" ហើយយកចំនួនទឹកប្រាក់ដែលបានដកសោហ៊ុយសម្រាប់នីតិវិធីពីថ្លៃលក់នោះមកបែងចែកឲ្យទៅដើមចោទ និង ចុងចម្លើយក្នុងម្នាក់ៗ ចំនួន ១ ភាគ ២។

**ខ.** ដីចំណុច ២. ដែលកត់ត្រានៅក្នុង " បញ្ជីទ្រព្យសម្បត្តិរួម " នៃឧបសម្ព័ន្ធ (តទៅហៅថា "ដី L 2" ) ជាកម្មសិទ្ធិអវិភាគរវាងដើមចោទ និង ចុងចម្លើយក្នុងចំណែកម្នាក់ៗចំនួន ១ ភាគ ២ ។

បង្គាប់ឲ្យលក់ដេញថ្លៃលើ "ដី L 2" ហើយយកចំនួនទឹកប្រាក់ដែលបានដកសោហ៊ុយសម្រាប់នីតិវិធីពីថ្លៃលក់នោះមកបែងចែកឲ្យទៅដើមចោទ និង ចុងចម្លើយក្នុងម្នាក់ៗ ចំនួន ១ ភាគ ២។

គ. ឡានចំណុច ៣. ដែលបានកត់ត្រានៅក្នុង " បញ្ជីទ្រព្យសម្បត្តិរួម " នៃឧបសម្ព័ន្ធ (តទៅហៅថា " រថយន្តនៃរឿងក្តីនេះ" ) ជាកម្មសិទ្ធិរបស់ចុងចម្លើយ។

បង្គាប់ឲ្យចុងចម្លើយបង់ប្រាក់ចំនួន ៥.០០០ ដុល្លារអាមេរិកឲ្យទៅដើមចោទ។

ឃ. ម៉ូតូចំណុច ៤. ដែលបានកត់ត្រានៅក្នុង "បញ្ជីទ្រព្យសម្បត្តិរួម" នៃឧបសម្ព័ន្ធ (តទៅហៅថា "ម៉ូតូនៃរឿងក្តីនេះ" ) ជាកម្មសិទ្ធិរបស់ដើមចោទ។

ង. ប្រាក់សន្សំចំណុច ៥. ដែលបានកត់ត្រានៅក្នុង "បញ្ជីទ្រព្យសម្បត្តិរួម" នៃឧបសម្ព័ន្ធ (តទៅហៅថា " ប្រាក់សន្សំនៃរឿងក្តីនេះ") ជាកម្មសិទ្ធិចុងចម្លើយ។

បង្គាប់ឲ្យចុងចម្លើយបង់ប្រាក់ចំនួន ២៥០ ដុល្លារអាមេរិកឲ្យទៅដើមចោទ។

**(៨)** ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ។

## ខ. ដំណើររឿងក្តី និង ចំណុចវិវាទ

### ខ.១. ការសង្ខេបអំពីរឿងក្តី

នៅក្នុងរឿងក្តីនេះ ដើមចោទបានអះអាងថា ទំនាក់ទំនងអាពាហ៍ពិពាហ៍ជាមួយចុងចម្លើយបានបែកបាក់ ហើយគ្មានសង្ឃឹមថានឹងអាចបដិទានឡើងវិញបានទេ ដូច្នេះ មានមូលហេតុនៃការលែងលះគ្នាដូចមានចែងនៅក្នុងចំណុច ង កថាខណ្ឌទី ១ មាត្រា ៩៧៨ នៃក្រមរដ្ឋប្បវេណី ហើយក្រៅពីធ្វើការទាមទារអំពីការលែងលះទៅកាន់ចុងចម្លើយរួចហើយ ដើមចោទក៏ទាមទារនូវការកំណត់ថាដើមចោទគឺជាអ្នកមានអំណាចមេបាលើកូនទាំងពីរ ហើយថែមទាំងបានដាក់ពាក្យសុំទាមទារនូវការបង់សោហ៊ុយចិញ្ចឹមបីបាច់ថែរក្សាកូន ការបង់អាហារកិច្ច និង ការបែងចែកទ្រព្យសម្បត្តិ ធ្វើជាការចាត់ចែងបន្ទាប់បន្សំផងដែរ។

### ខ.២. អង្គហេតុដែលជាមូលដ្ឋានដើម្បីពិចារណាអំពីចំណុចវិវាទ[6]

ខ.២.១. នៅថ្ងៃទី ៣ ខែ សីហា ឆ្នាំ ២០១៥ ដើមចោទ និង ចុងចម្លើយបានទៅចុះបញ្ជីអាពាហ៍ពិពាហ៍ ហើយបានចាប់ផ្តើមរួមរស់ជីវភាពជាមួយគ្នានៅលំនៅដ្ឋានរបស់ចុងចម្លើយ។ (**ភស្តុតាង** $X_1$ $X_2$)

ខ.២.២. ដើមចោទមិនមានសាច់ញាតិនៅក្នុងទីក្រុងភ្នំពេញទេ។ (**ដំណើរការ និង ខ្លឹមសារនៃការទាញហេតុផលដោយផ្ទាល់មាត់[7]**)

---

[6] នៅក្នុងនីតិវិធីបណ្តឹងនៃបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ផ្នែកដែលទាក់ទងនឹងអង្គហេតុដែលភាគីបានសារភាពចំពោះមុខតុលាការ នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ៩៦ និង កថាខណ្ឌទី ២ នៃមាត្រា ១២៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី មិនត្រូវយកមកអនុវត្តឡើយ (កថាខណ្ឌទី ១ មាត្រា ១៣ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល)។ ដូច្នេះហើយ ទោះបីជាអង្គហេតុដែលគូភាគីមិនមានវិវាទក៏ដោយ ក៏តុលាការត្រូវតែទទួលស្គាល់ដោយផ្អែកតាមភស្តុតាងផងដែរ (កថាខណ្ឌទី ១ មាត្រា ១២៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

នៅក្នុងលិខិតសាលក្រមនៃបណ្តឹងរដ្ឋប្បវេណីធម្មតា តុលាការបានសរសេរអំពី អង្គហេតុដែលមិនមែនជាចំណុចវិវាទ ពោលគឺ "អង្គហេតុដែលគ្មានវិវាទ" មុននឹងការសរសេរអំពី "ចំណុចវិវាទ" (ចំណុច ឃ កថាខណ្ឌទី ១ មាត្រា ១៨៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ ប៉ុន្តែ នៅក្នុងលិខិតសាលក្រមនៃបណ្តឹងទាក់ទងនឹងឋានៈបុគ្គល តុលាការត្រូវតែសរសេរអំពីដែលជាចំណុចវិវាទ និង អង្គហេតុដែលមិនមែនជាចំណុចវិវាទ ហើយត្រូវតែទទួលស្គាល់នូវអង្គហេតុទាំងពីរនេះដោយផ្អែកតាមភស្តុតាង។ ដូច្នេះ នៅក្នុងលិខិតសាលក្រមនៃបណ្តឹងទាក់ទងនឹងឋានៈបុគ្គល តុលាការនឹងសរសេរអំពី "អង្គហេតុដែលជាមូលដ្ឋានដើម្បីពិចារណាអំពីចំណុចវិវាទ" ដោយផ្អែកតាមភស្តុតាង។

[7] ក្នុងការចេញសាលក្រម តុលាការត្រូវវិនិច្ឆ័យទទួលស្គាល់ ឬ មិនទទួលស្គាល់ថា ការអះអាងអំពីអង្គហេតុ មាន ឬ គ្មានភាពពិត ដោយគិតពិចារណាយ៉ាងហ្មត់ចត់នូវលទ្ធផលនៃការពិនិត្យភស្តុតាង និង ដំណើរការនិងខ្លឹមសារនៃ

ខ.២.៣. ក្រោយពេលដែលបានចាប់ផ្តើមរួមរស់ជីវភាពជាមួយគ្នានិងដើមចោទ ចុងចម្លើយភាគច្រើនត្រឡប់មកផ្ទះវិញយប់ជ្រៅ។ **(ភស្តុតាង $X_5$ $Y_1$)**

ខ.២.៤. ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៦ ដើមចោទ និង ចុងចម្លើយកើតបានកូនប្រុសឈ្មោះ សុក សុជាតិ (តទៅហៅថា "សុជាតិ")។ **(ភស្តុតាង $X_3$)**

ខ.២.៥. ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១៨ ដើមចោទ និង ចុងចម្លើយកើតបានកូនស្រីឈ្មោះ សុក សុជាតា (តទៅហៅថា "សុជាតា")។ **(ភស្តុតាង $X_4$)**

ខ.២.៦. ថ្ងៃទី ៤ ខែ មករា ឆ្នាំ ២០២០ ដើមចោទបាននាំសុជាតិ និង សុជាតា ត្រឡប់ទៅស្រុកកំណើតរបស់ខ្លួនវិញ។ **(ភស្តុតាង $X_6$)**

ខ.២.៧. នៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកទី ១ ដែលត្រូវបានធ្វើឡើងនៅថ្ងៃទី ១២ ខែមិថុនា ឆ្នាំ ២០២០ ចុងចម្លើយបានឆ្លើយ (ឯកសារចម្លើយរបស់ចុងចម្លើយ) ថា "គ្មានមូលហេតុនៃការលែងលះគ្នាទេ" ប៉ុន្តែ នៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកទី ២ ដែលត្រូវបានធ្វើឡើងនៅថ្ងៃទី ១ ខែកក្កដា ឆ្នាំ ២០២០ ចុងចម្លើយបានដកការឆ្លើយបែបនោះ និងបាននិយាយថា "ខ្លួនមិនមានឆន្ទៈបន្តអាពាហ៍ពិពាហ៍ជាមួយនិងដើមចោទតទៅទៀតទេ"។ នៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកទី ២ ដើមចោទក៏បាននិយាយថា " ខ្លួនមិនមានឆន្ទៈបន្តអាពាហ៍ពិពាហ៍ជាមួយនិងចុងចម្លើយ" ដែរ ។ **(អង្គហេតុដែលមានភាពជាក់ស្តែងចំពោះតុលាការ[8])**

### ខ.៣. ចំណុចវិវាទ និង ការអះអាងរបស់ភាគីចំពោះចំណុចវិវាទ

**នៅក្នុងរឿងក្តីនេះ ដើមចោទ និង ចុងចម្លើយបានលើកឡើងថា ភាគីទាំងសងខាងមិនមានឆន្ទៈបន្តអាពាហ៍ពិពាហ៍ទេ ហើយទំនាក់ទំនងអាពាហ៍ពិពាហ៍របស់ដើមចោទ និង ចុងចម្លើយត្រូវបានបែកបាក់ ហើយគ្មានសង្ឃឹមថានឹងអាចបដិទានឡើងវិញបានទេ។ ដូច្នេះហើយ ដោយសារតែតុលាការទទួលស្គាល់អំពី**

---

ការទាញហេតុផលងដោយផ្ទាល់មាត់ តាមជំនឿទុកចិត្តដោយសេរីរបស់ខ្លួន (មាត្រា ១៨៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

[8] កថាខណ្ឌទី ២ មាត្រា ១២៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី និង កថាខណ្ឌទី ១ មាត្រា ១៣ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល។ នៅក្នុងនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល បើសិនជាអត្ថិភាពនៃអង្គហេតុនោះមានភាពជាក់ស្តែងចំពោះតុលាការនោះ តុលាការមិនចាំបាច់ទទួលស្គាល់ដោយផ្អែកតាមភស្តុតាងឡើយ។

មូលហេតុនៃការលែងលះគ្នាដែលមានចែងនៅក្នុងចំណុច ង កថាខណ្ឌទី ១ មាត្រា ៩៧៨ នៃក្រមរដ្ឋប្បវេណី ដូច្នេះ បណ្ដឹងទាមទារលែងលះរបស់ដើមចោទ គឺមានមូលហេតុ។

**ហេតុនេះ ចំណុចវិវាទនៅក្នុងរឿងក្ដីនេះមានចំណុចដូចតទៅ៖**

### ខ.៣.១. ការកំណត់អំពីអ្នកមានអំណាចមេបា

#### ខ.៣.១.១. ការអះអាងរបស់ដើមចោទ

ក្រោយពេលកើតសុជាតិ និង សុជាតា ដើមចោទបានបីបាច់រក្សារូបកាយរបស់កូននីមួយៗយ៉ាងជាប់លាប់រហូតមក។ ក្រោយពេលដែលដើមចោទបានរស់នៅបែកគ្នាជាមួយចុងចម្លើយក៏ដោយ ក៏កូនទាំងពីរនាក់នេះបានរស់នៅជាមួយគ្នានិងដើមចោទ ហើយក៏បានធំលូតលាស់ផងដែរ។

ចំណែកឯចុងចម្លើយវិញ កន្លងមកនេះបានលើកហេតុផលថា ខ្លួនរវល់ខ្លាំង ហើយមិនបានចូលរួមក្នុងការមើលថែទាំកូនទាំងពីរ ហើយក៏មិនបានបីបាច់រក្សារូបកាយរបស់កូនទាំងពីរទាល់តែសោះ។

តុលាការសមតែកំណត់ដើមចោទធ្វើជាអ្នកមានអំណាចមេបាលើកូនទាំងពីរ។

#### ខ.៣.១.២. ការអះអាងរបស់ចុងចម្លើយ

ដើម្បីតែការងារភាគច្រើនចុងម្លើយបានត្រឡប់មកផ្ទះវិញយប់ជ្រៅ ប៉ុន្តែ បើទោះបីជាពេលវេលាមានកម្រិតក៏ដោយ ក៏នៅក្នុងពេលវេលាទាំងនោះ ចុងចម្លើយបានផ្ដល់នូវការថែទាំទៅសុជាតិ និង សុជាតាយ៉ាងសមរម្យផងដែរ។ ការរៀបចំកាដូគ្រិស្តម៉ាសដែលចុងចម្លើយបានធ្វើឡើងសម្រាប់កូនទាំងពីរជាដើម ក៏អាចឆ្លុះបង្ហាញឲ្យឃើញពីការផ្ដល់នូវការថែនេះផងដែរ។

ចំណែកឯដើមចោទវិញ បែរជាខឹងភ្លាមៗមួយរំពេច ហើយស្រែកខ្លាំងៗមកកាន់ចុងចម្លើយ ហើយក៏ជាមនុស្សមានសតិស្មារតីមិននឹងនរដែរ។ ដើមចោទមិនអាចចិញ្ចឹមបីបាច់កូនទាំងពីរឲ្យមានភាពត្រឹមត្រូវបានទេ។

តុលាការសមតែកំណត់ចុងចម្លើយធ្វើជាអ្នកមានអំណាចមេបាលើកូនទាំងពីរ។

### ខ.៣.២. បន្ទុកលើសោហ៊ុយដែលចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន (សោហ៊ុយចិញ្ចឹមបីបាច់កូន)

### ខ.៣.២.១. ការអះអាងរបស់ដើមចោទ

បច្ចុប្បន្ននេះ ដើមចោទមិនមានប្រាក់ចំណូលទេ រីឯចុងចម្លើយវិញមានប្រាក់ចំណូលក្នុង ១ឆ្នាំ ប្រហែល ៧.០០០ ដុល្លារអាមេរិក។

ដូច្នេះហើយ ដើមចោទទាមទារឲ្យចុងចម្លើយទទួលបន្ទុកលើសោហ៊ុយដែលចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូនជាប្រាក់ចំនួន ១៥០ ដុល្លារអាមេរិកក្នុងកូន ១ នាក់ ( ២ នាក់ សរុបស្មើនឹង ៣០០ ដុល្លារអាមេរិក) ជារៀងរាល់ខែ ក្នុងអំឡុងគិតរហូតដល់កូនទាំងពីរក្លាយជានីតិជន ។

### ខ.៣.២.២. ការអះអាងរបស់ចុងចម្លើយ

ប្រសិនបើដើមចោទជាអ្នកមានអំណាចមេបាលើសុជាតិ និង សុជាតា ហើយគ្រប់គ្រងថែរក្សាកូនទាំងពីរនៅស្រុកកំណើតរបស់ដើមចោទ (នៅខេត្តបាត់ដំបង) នោះនឹងមានភាពខុសគ្នាពីការគ្រប់គ្រងថែរក្សាកូននៅក្នុងទីក្រុងភ្នំពេញ ដូច្នេះនឹងមិនមានការចំណាយសោហ៊ុយ ១៥០ ដុល្លារអាមេរិកក្នុងកូន ១ នាក់ នៅក្នុង ១ ខែឡើយ។ យ៉ាងច្រើនចុងចម្លើយទទួលបន្ទុក ១០០ ដុល្លារអាមេរិក ក្នុងកូន ១ នាក់នៅក្នុង ១ ខែ ( ២ នាក់ សរុបស្មើនឹង ២០០ ដុល្លារអាមេរិក) សម្រាប់ដើមចោទនោះនឹងមានភាពគ្រប់គ្រាន់។

## ខ.៣.៣. ការបង់អាហារកិច្ច

### ខ.៣.៣.១. ការអះអាងរបស់ដើមចោទ

ចំពោះទំនាក់ទំនងអាពាហ៍ពិពាហ៍របស់ ដើមចោទ និង ចុងចម្លើយ ដែលត្រូវបានបែកបាក់ ហើយគ្មានសង្ឃឹមថានឹងអាចបដិទានឡើងវិញបាន គឺមិនមានកំហុសរបស់ដើមចោទទេ។ ដោយសារតែបច្ចុប្បន្ន ដើមចោទមិនមានប្រាក់ចំណូល ដូច្នេះហើយទើបទាមទារឲ្យចុងចម្លើយបង់អាហារកិច្ច។ ដោយផ្អែកលើប្រាក់ចំណូលរបស់ចុងចម្លើយក្នុង ១ ឆ្នាំ ប្រហែល ៧.០០០ ដុល្លារអាមេរិក និងរួមទាំងការសង្ឃឹមថាចុងចម្លើយនឹងទទួលបន្ទុកលើសោហ៊ុយចិញ្ចឹមបីបាច់កូនសុជាតិ និង សុជាតានោះ ចំនួនទឹកប្រាក់នៃអាហារកិច្ចសក្តិសមតែកំណត់ថាក្នុង ១ ខែ ១០០ ដុល្លារអាមេរិក។

### ខ.៣.៣.២. ការអះអាងរបស់ចុងចម្លើយ

ចំពោះទំនាក់ទំនងអាពាហ៍ពិពាហ៍របស់ដើមចោទ និង ចុងចម្លើយដែលត្រូវបានបែកបាក់ ហើយគ្មានសង្ឃឹមថានឹងអាចបដិទានឡើងវិញបាន គឺដើមចោទក៏មានកំហុសដែរ មិនមែនមានតែចុងចម្លើយនោះទេ។ ចុងចម្លើយទទួលយកនូវការលែងលះគ្នាពីចុងចម្លើយ ប៉ុន្តែ មិនអាចទទួលយកនូវការបង់អាហារកិច្ចទេ។

### ខ.៣.៤. ការបែងចែកទ្រព្យសម្បត្តិ

#### ខ.៣.៤.១. ការអះអាងរបស់ដើមចោទ

រវាងដើមចោទ និង ចុងចម្លើយមានទ្រព្យសម្បត្តិរួមដូចបានកត់ត្រានៅក្នុង "បញ្ជីទ្រព្យសម្បត្តិរួម" នៃឧបសម្ព័ន្ធ។ ដើមចោទមានសិទ្ធិទទួលយក ១ ភាគ ២ នៃទ្រព្យសម្បត្តិនោះ។

ចំពោះដី L1 និង ដី L2 ដើមចោទទាមទារឲ្យលក់ដេញថ្លៃហើយយកប្រាក់ដែលបានពីការលក់នោះមកបែងចែកឲ្យទៅតាមចំណែក ដោយផ្អែកលើកម្មសិទ្ធិអវិភាគចំនួន ១ ភាគ ២ ដែលដើមចោទ និង ចុងចម្លើយម្នាក់ៗ មាន។

ចំពោះម៉ូតូនៃរឿងក្តីនេះ បច្ចុប្បន្នដើមចោទកំពុងតែប្រើប្រាស់ ហើយវាក៏មានភាពចាំបាច់សម្រាប់ការទិញអីវ៉ាន់ប្រើប្រាស់ប្រចាំថ្ងៃ ដូច្នេះ ដើមចោទទាមទារយកមកធ្វើជាកម្មសិទ្ធិរបស់ដើមចោទ។

#### ខ.៣.៤.២. ការអះអាងរបស់ចុងចម្លើយ

ចុងចម្លើយទទួលស្គាល់ថា រវាងដើមចោទ និង ចុងចម្លើយមានទ្រព្យសម្បត្តិរួមដូចបានកត់ត្រានៅក្នុង "បញ្ជីទ្រព្យសម្បត្តិរួម" នៃឧបសម្ព័ន្ធ។ ដើមចោទមានសិទ្ធិទទួលយក ១ ភាគ ២ នៃទ្រព្យសម្បត្តិនោះ។ ប៉ុន្តែ ដីដែលបានកត់ត្រានៅក្នុងចំណុច ១. នៃឧបសម្ព័ន្ធ " បញ្ជីទ្រព្យសម្បត្តិរួម" (តទៅហៅថា "ដី L1") និងរថយន្តដែលបានកត់ត្រានៅក្នុងចំណុច ៣. នៃឧបសម្ព័ន្ធ "បញ្ជីទ្រព្យសម្បត្តិរួម" (តទៅហៅថា "រថយន្តនៃរឿងក្តីនេះ") គឺមិនមែនជាទ្រព្យសម្បត្តិរួមសម្រាប់ធ្វើការធ្វើលទ្ធកម្មនោះទេ ទ្រព្យសម្បត្តិទាំងនោះគឺ ចុងចម្លើយមានតាំងពីមុនអាពាហ៍ពិពាហ៍ ហើយបាននិងកំពុងប្រើប្រាស់ជាទ្រព្យសម្បត្តិដោយឡែក។ នៅពេលដែលធ្វើការបែងចែកទ្រព្យសម្បត្តិរួមដែលបានកត់ត្រានៅក្នុងឧបសម្ព័ន្ធ "បញ្ជីទ្រព្យសម្បត្តិរួម" តុលាការគប្បីពិចារណាទៅលើទំហំនៃការបរិច្ចាគរបស់ចុងចម្លើយចំពោះលទ្ធកម្មនៃទ្រព្យសម្បត្តិទាំងនេះ ( "ទំហំនៃការបរិច្ចាគរបស់ភា

គឺនីមួយៗចំពោះលទ្ធកម្មនៃទ្រព្យសម្បត្តិ ការថែរក្សា ឬ ការបង្កើនទ្រព្យ" ចំណុច ខ កថាខណ្ឌទី ២ មាត្រា ៩៨០ នៃក្រមរដ្ឋប្បវេណី)។

ចំពោះដី L1 និង ដី L2 គឺត្រូវបានបង្កើតហ៊ីប៉ូតែកដើម្បីធានានូវកាតព្វកិច្ច ដោយសាមគ្គីភាពរវាងដើមចោទ និង ចុងចម្លើយ បន្ថែមពីនេះទៀត ដោយសារតែបច្ចុប្បន្ននេះដីទាំងពីរកំពុងតែបន្តឡើងថ្លៃ ហេតុនេះហើយ មិនគួរលក់ដេញថ្លៃនៅក្នុងពេលនេះទេ។ នាពេលបច្ចុប្បន្ននេះ រវាងដើមចោទ និងចុងចម្លើយមានចំណែកអវិភាគក្នុងម្នាក់ៗ ចំនួន ១ ភាគ ២ ដូច្នេះ ចាំពេលដែលកាតព្វកិច្ចបានសងរួចរាល់អស់ ហើយការចុះបញ្ជីបង្កើតហ៊ីប៉ូតែកត្រូវបានលុបចោលចាំធ្វើការពិចារណាអំពីវិធីបែងចែកទើបជាការប្រសើរ។

ចំពោះរថយន្តនៃរឿងក្តីនេះ ចុងចម្លើយកំពុងតែប្រើប្រាស់សម្រាប់ទៅធ្វើការ ដូច្នេះ ចុងចម្លើយទាមទារធ្វើជាកម្មសិទ្ធិរបស់ចុងចម្លើយ។

## សំអាងហេតុ

## ក. ការវិនិច្ឆ័យចំពោះការកំណត់អំពីអ្នកមានអំណាចមេបា[9]

**[9] "អំពីមូលដ្ឋាននៃការសម្រេចសេចក្តីអំពីការកំណត់អ្នកមានអំណាចមេបា"**

**តុលាការត្រូវកំណត់អ្នកមានអំណាចមេបា ដោយពិចារណាទៅលើ "ផលប្រយោជន៍របស់កូន" (កថាខណ្ឌទី ៣ មាត្រា ១០៣៧ នៃក្រមរដ្ឋប្បវេណី)។**

**នៅពេលដែលតុលាការធ្វើការសម្រេចសេចក្តីអំពីការកំណត់អ្នកមានអំណាចមេបា ឬ ការចាត់ចែងទាក់ទងនឹងការបីបាច់រក្សាកូន យោបល់របស់កូនត្រូវបានយកទៅពិចារណា ថ្លឹងថ្លែងសមស្របទៅតាមអាយុ និង សភាពចាស់ទុំរបស់កូននោះ(កថាខណ្ឌទី ៤ មាត្រា ២២ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល)។**

រដ្ឋភាគី ត្រូវធានាអះអាងដល់កុមារដែលមានសមត្ថភាពបង្កើតទស្សនៈផ្ទាល់ខ្លួន នូវសិទ្ធិបញ្ចេញទស្សនៈទាំងនោះដោយសេរី លើគ្រប់បញ្ហាពាក់ព័ន្ធនឹងកុមារ។ ទស្សនៈទាំងនេះរបស់កុមារ ត្រូវបានយកទៅពិចារណាថ្លឹងថ្លែងដោយគិតទៅតាមវ័យ និងភាពចាស់ទុំរបស់កុមារ។ ក្នុងទិសដៅនេះ កុមារត្រូវបានផ្តល់ជាពិសេសនូវឱកាសស្តាប់នីតិវិធីតុលាការ និង រដ្ឋបាល ដែលពាក់ព័ន្ធនឹងកុមារ ទោះដោយផ្ទាល់ ឬ តាមរយៈតំណាងម្នាក់ ឬ ស្ថាប័នសមស្របមួយ ស្របតាមបទបញ្ញត្តិនីតិវិធីនៃច្បាប់ជាតិ ។ (មាត្រា ១២ នៃអនុសញ្ញាអន្តរជាតិស្តីពី សិទ្ធិកុមារ) ។ បន្ថែមពីនេះ ប្រទេសកម្ពុជាបានចូលជាភាគីនៃអនុសញ្ញានេះកាលពីឆ្នាំ ១៩៩២។

"ផលប្រយោជន៍របស់កូន" អាចគិតទៅដល់ ① ស្ថានភាពរបស់ខាងឪពុក ឬ ម្តាយ ② ស្ថានភាពរបស់កូន។ ① ស្ថានភាពរបស់ខាងឪពុក ឬ ម្តាយ អាចមានដូចជា លទ្ធភាពក្នុងការគ្រប់គ្រងកូន (អាយុ និង ស្ថានភាពសុខភាពជាដើម) ស្ថានភាពសេដ្ឋកិច្ច (ប្រាក់ចំណូលប្រចាំឆ្នាំ មុខរបរ មាន ឬ គ្មានលំនៅដ្ឋានជាដើម) និងស្ថានភាពនៃការគ្រប់គ្រងកូន មាន ឬ គ្មានជំនួយពីសាច់ញាតិ ការផ្តល់ក្តីស្រលាញ់ចំពោះកូនជាអាទិ៍ ដែលធ្លាប់មានកន្លងមក ។ ② ស្ថានភាពរបស់កូន អាចមានដូចជា អាយុ ស្ថានភាពនៃការលូតលាស់រាងកាយ និង ចិត្តគំនិត ឆន្ទៈរបស់កូន ភាពស្អិតរមួតនៃចំណងរវាងឪពុកឬម្តាយ និងសាច់ញាតិជាដើម។

## ក.១. ការទទួលស្គាល់អង្គហេតុ

អង្គហេតុដែលតុលាការបានទទួលស្គាល់តាមរយៈភស្តុតាងដូចបានកត់ត្រាគិតមកដល់ចំណុចចុងក្រោយខាងលើនេះ មានដូចតទៅ៖

**ក.១.១.** ដើមចោទ និង ចុងចម្លើយបង្កើតបានកូនឈ្មោះសុជាតិនៅថ្ងៃទី ១១ ខែសីហា ឆ្នាំ ២០១៦ និង សុជាតានៅថ្ងៃទី ២២ ខែកក្កដា ឆ្នាំ ២០១៨។ **(ភស្តុតាង $X_3$ $X_4$)**

**ក.១.២.** នៅថ្ងៃទី 4 ខែ មករា ឆ្នាំ ២០២០ ដើមចោទ បាននាំសុជាតិ និង សុជាតាត្រឡប់ទៅស្រុកកំណើតវិញ ហើយកំពុងតែស្នាក់នៅស្រុកកំណើតរួមគ្នាជាមួយនិងឪពុកម្តាយរបស់ដើមចោទរហូតមកដល់បច្ចុប្បន្ននេះ។ **(ភស្តុតាង $X_6$)**

**ក.១.៣.** ក្នុងអំឡុងពេលដែលគិតមកដល់ពេលដើមចោទបានចាប់ផ្តើមរស់នៅបែកគ្នាជាមួយចុងចម្លើយ ដើមចោទបានបន្តនូវការគ្រប់គ្រងសុជាតិ និង សុជាតាតែម្នាក់ឯង រួមទាំងពេលដែលចុងចម្លើយបានត្រឡប់មកផ្ទះវិញយប់ជ្រៅក៏ដោយ។ **(ភស្តុតាង $X_5$ $Y_1$ ដំណើរការ និង ខ្លឹមសារនៃការទាញហេតុផលដោយផ្ទាល់មាត់)**

**ក.១.៤.** ដោយសារតែដើមចោទមិនអាចទទួលបាននូវការចូលរួមសហការចំពោះការមើលថែទាំកូនពីចុងចម្លើយ ដូច្នេះហើយក៏ធ្លាប់បានធ្វើឲ្យមានការធ្វេសប្រហែសចំពោះការងារផ្ទះ និងធ្វើឲ្យមានជម្លោះពាក្យសម្តីជាមួយចុងចម្លើយ ជាពិសេសគិតចាប់តាំងពីពេលដែលសុជាតាបានកើត។ **(ភស្តុតាង $X_5$ $Y_1$ លទ្ធផលនៃការសាកសួរសាមីដើមចោទ និងចុងចម្លើយនីមួយៗ)**

**ក.១.៥.** ........................................................................................................

**ក.១.៦.** ........................................................................................................

(សង្ខេប)

*※ នៅក្នុងរឿងក្តីជាក់ស្តែង គូភាគីទាំងសងខាងច្បាស់ជាមានការអះអាងយ៉ាងក្បោះក្បាយអំពីមូលហេតុដែលសក្តិសមឲ្យខ្លួនអាចក្លាយទៅជាអ្នកមានអំណាចមេបា។*

*ក្នុងករណីដែលភាគីគ្រាន់តែអះអាងខ្លីៗដោយមូលហេតុបែបអត្តនោម័តថា ព្រោះ តែខ្លួនស្រលាញ់កូននោះ តុលាការចាំបាច់ត្រូវប្រើប្រាស់នូវសិទ្ធិស្រាយបំភ្លឺ ហើយឲ្យភាគីអះអាងអំពីមូលហេតុបែបសត្យានុម័តថា "តើហេតុអ្វីបានជាទាល់តែមានការមើលថែទាំកូនពីភាគីនោះទើបអាចមានលក្ខណៈវិជ្ជមានសម្រាប់កូនជាងគេ? ហេតុអ្វីបានជាភាគីម្ខាងទៀតមិនអាចធ្វើបាន?"*

*តុលាការចាំបាច់ត្រូវកំណត់អំពីអ្នកមានអំណាចមេបាដោយពិចារណាអំពីស្ថានភាពផ្សេងៗជាច្រើនដែលភាគីទាំងសងខាងបានអះអាង ហើយត្រូវគិតថាតើកំណត់យកឪពុក ឬ ម្ដាយធ្វើជាអ្នកមានអំណាចមេបាទើបអាចមាន "ផលប្រយោជន៍របស់កូន"។*

*ហើយ តុលាការត្រូវសរសេរអំពី អង្គហេតុដំបូងដើម្បីយកមកធ្វើការសម្រេចបែបនោះ និងភស្តុតាង ដាក់នៅក្នុងចំណុចចំហាទាំងនេះ។*

## **ក.២. សេចក្ដីសន្និដ្ឋាន**

ផ្អែកតាមការសរុបនូវអង្គហេតុដែលបានទទួលស្គាល់នៅក្នុងចំណុច "ក.១" ខាងលើ តុលាការទទួលស្គាល់ថា ក្រោយពេលដែលសុជាតិ និង សុជាតាកើតមក ដើមចោទបានគ្រប់គ្រងកូនទាំងពីររៀងរហូតមក ហើយក៏បានបន្តនូវការគ្រប់គ្រងនោះផងដែរបើទោះបីជាក្រោយពេលដែលបានរស់នៅបែកគ្នាជាមួយចុងចម្លើយក៏ដោយ។ ម្យ៉ាងទៀត តុលាការមិនទទួលស្គាល់ថា ស្ថានភាពនៃការគ្រប់គ្រងរបស់ដើមចោទទៅកាន់កូនទាំងពីរនេះ មិនមានបញ្ហាជាក់លាក់ណាមួយឡើយ។

យ៉ាងណាមិញ ចុងចម្លើយបានអះអាងថា ដើមចោទបានខឹងភ្លាមៗ ហើយស្រែកខ្លាំងៗទៅកាន់ចុងចម្លើយ ហើយជាមនុស្សដែលមានសតិមិននឹងនរ ដូច្នេះទើបដើមចោទមិនអាចចិញ្ចឹមបីបាច់កូនទាំងពីរឲ្យបានត្រឹមត្រូវទេ។ ជាការពិតណាស់ តុលាការទទួលស្គាល់ថា ដើមចោទធ្លាប់មានជម្លោះពាក្យសម្ដីជាមួយចុងចម្លើយ ។ ប៉ុន្តែ តុលាការក៏មិនអាចទទួលស្គាល់រហូតទៅដល់អង្គហេតុដែលដើមចោទអាចខឹង ហើយស្រែកដាក់សុជាតិ និង សុជាតានោះទេ ដូច្នេះហើយ តុលាការមិនអាចទទួលស្គាល់ថា ជម្លោះពាក្យសម្ដីរវាងចុងចម្លើយ គឺបានកើតឡើងដោយសារតែ

ដើមចោទមានស្មារតីមិននឹងនរ ហើយមូលហេតុនោះដោយសារតែដើមចោទមិនទទួលបានការសហការឲ្យបានពេញលេញពីចុងចម្លើយឡើយ។

ផ្ទុយមកវិញ ទោះជាយ៉ាងណាក៏ដោយ ក៏ចុងចម្លើយមានការស្រលាញ់ចំពោះកូនទាំងពីរ ប៉ុន្តែ ចុងចម្លើយមិនបង្ហាញឲ្យច្បាស់ថា តើខ្លួនចង់គ្រប់គ្រងថែរក្សាកូនទាំងពីរនេះជាក់ស្តែងដោយរបៀបណានោះទេ ខណៈពេលដែលភាគច្រើនខ្លួនបានត្រឡប់មកផ្ទះវិញយប់ជ្រៅដោយសារតែការងារ។

ដូច្នេះហើយ ផ្អែកតាមស្ថានភាពដែលដើមចោទកំពុងតែគ្រប់គ្រងកូនទាំងពីរនាក់ពេលបច្ចុប្បន្ននេះ គឺពុំមានបញ្ហាជាពិសេសណាមួយទេ ម្យ៉ាងទៀត ក៏មិនអាចនិយាយបានថា បើធ្វើការផ្លាស់ប្តូរស្ថានភាពនៃការគ្រប់គ្រងកូន ហើយកំណត់មកឲ្យចុងចម្លើយជាអ្នកមានអំណាចមេបាលើកូនទាំងពីរវិញ នឹងអាចធ្វើឲ្យក្លាយទៅជាប្រយោជន៍ដល់កូនទាំងពីរនោះបានដែរ ដូច្នេះហើយ គប្បីយកដើមចោទធ្វើជាអ្នកមានអំណាចមេបាទើបជាការប្រសើរ។

## ខ. ការវិនិច្ឆ័យចំពោះបន្ទុកលើសោហ៊ុយដែលចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន (សោហ៊ុយចិញ្ចឹមបីបាច់កូន)

### ខ.១. ការទទួលស្គាល់អង្គហេតុ

អង្គហេតុដែលតុលាការបានទទួលស្គាល់តាមរយៈភស្តុតាងដូចបានកត់ត្រាគិតមកដល់ចំណុចចុងក្រោយខាងលើនេះ មានដូចតទៅ៖

ខ.១.១. បច្ចុប្បន្ននេះ ដើមចោទគ្មានប្រាក់ចំណូល ។ (**លទ្ធផលនៃការសាកសួរសាមីដើមចោទ**)

ខ.១.២. ចុងចម្លើយកំពុងធ្វើការជាបុគ្គលិកក្រុមហ៊ុន ហើយមានប្រាក់ចំណូលក្នុង១ឆ្នាំ ប្រហែល ៧.០០០ ដុល្លារអាមេរិក។ (**លទ្ធផលនៃការសាកសួរសាមីចុងចម្លើយ**)

ខ.១.៣. ចុងចម្លើយត្រូវបង់ពន្ធប្រហែល..............ដុល្លារអាមេរិក ហើយបង់ថ្លៃឈ្នួលផ្ទះប្រហែល............ដុល្លារអាមេរិកពីប្រាក់ចំណូលដែលបានកត់ត្រានៅក្នុងចំណុច “**ខ.១.២**” ខាងលើនេះ ។ (**លទ្ធផលនៃការសាកសួរសាមីចុងចម្លើយ**)

ខ.១.៤. កាលពីអំឡុងពេលដែលរស់នៅជុំគ្នាជាមួយសុជាតិ និង សុជាតានៅក្នុងលំនៅដ្ឋានរបស់ចុងចម្លើយ ចុងចម្លើយបានចំណាយសម្រាប់ថ្លៃជីវភាពរបស់កូនទាំងពីរចំនួន ៣.០០០ ដុល្លារអាមេរិក (ក្នុង ១ ខែ ប្រហែល ២៥០ ដុល្លារអាមេរិក) ពីចំនួនទឹកប្រាក់..................ដុល្លារអាមេរិកដែលបាននៅសល់បន្ទាប់ពីដកថ្លៃចំណាយក្នុងចំណុច "ខ.១.៣" ពីក្នុងប្រាក់ចំណូលនៃចំណុច "ខ.១.២" ខាងលើ។ **(លទ្ធផលនៃការសាកសួរសាមីដើមចោទ និង ចុងចម្លើយ)**

ខ.១.៥. បច្ចុប្បន្ននេះ ដើមចោទកំពុងតែគ្រប់គ្រងសុជាតិ និង សុជាតា នៅស្រុកកំណើតរបស់ដើមចោទ (ខេត្តបាត់ដំបង)។ **(ភស្តុតាង $X_6$)**

ខ.១.៦. ថ្លៃចំណាយសម្រាប់ជីវភាពនៅក្នុងខេត្តបាត់ដំបង ប្រហែលជាស្មើនឹង ៨០ % នៃថ្លៃចំណាយសម្រាប់ជីវភាពនៅក្នុងទីក្រុងភ្នំពេញ។ **(អង្គហេតុដែលមានភាពជាក់ស្តែងចំពោះតុលាការ)**

ខ.១.៧. ..........................................................................................................

(សង្ខេប)

*※ចំនួនទឹកប្រាក់នៃសោហ៊ុយដែលចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន (សោហ៊ុយចិញ្ចឹមបីបាច់កូន) ដំបូង ① ត្រូវកំណត់ជាបណ្ដោះអាសន្នថា ហើយធ្វើការគណនាថា បើសិនជាកូនរស់នៅជុំគ្នាជាមួយអ្នកដែលទទួលបន្ទុក (ឪពុក ឬ ម្ដាយដែលមិនមែនជាអ្នកមានអំណាចមេបា) តើចំណាយសម្រាប់ជីវភាពដែលត្រូវបានប្រើប្រាស់សម្រាប់កូននៅក្នុងករណីនេះអស់ចំនួនប៉ុន្មាន? ② យកចំនួនដែលបានគណនានេះ មកបែងចែកទៅតាមភាគរយនៃប្រាក់ចំណូលរបស់អ្នកទទួលបន្ទុក (ឪពុក ឬ ម្ដាយដែលមិនមែនជាអ្នកមានអំណាចមេបា) និង អ្នកដែលទាមទារ (ឪពុក ឬ ម្ដាយដែលជាអ្នកមានអំណាចមេបា) ។ នៅពេលនោះ ចំនួនទឹកប្រាក់ដែលបានមកពីការគណនាធៀបទៅនឹងភាគរយនៃប្រាក់ចំណូលរបស់អ្នកទទួលបន្ទុក នឹងក្លាយទៅជាសោហ៊ុយដែលចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន (សោហ៊ុយចិញ្ចឹមបីបាច់កូន) ដែលអ្នកទទួលបន្ទុកនោះត្រូវទទួលបន្ទុក។*

## ខ.២. សេចក្តីសន្និដ្ឋាន

តុលាការទទួលស្គាល់ថា ផ្អែកតាមខាងលើនេះ ប្រសិនបើកំណត់ជាបណ្តោះអាសន្នសិនថា បើចុងចម្លើយរស់ជុំគ្នានៅឯខេត្តបាត់ដំបងជាមួយសុជាតិ និង សុជាតា ចុងចម្លើយនឹងត្រូវចំណាយនូវថ្លៃជីវភាពចំនួនប្រហែល ២០០ ដុល្លារអាមេរិកក្នុង ១ ខែ សម្រាប់កូនទាំងពីរ (៨០% នៃចំនួន ២៥០ដុល្លារអាមេរិក) ។

ដូច្នេះ ចុងចម្លើយត្រូវទទួលបន្ទុកនូវប្រាក់ចំនួន ១០០ ដុល្លារអាមេរិកក្នុង១ខែ ចំពោះកូន ១ នាក់ ដែលជាសោហ៊ុយដែលចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូនទាំងពីរ (សោហ៊ុយចិញ្ចឹមបីបាច់កូន) ក្នុងអំឡុងពេលរហូតដល់កូនទាំងពីរនាក់ក្លាយជានីតិជន ។

# គ. ការវិនិច្ឆ័យចំពោះការបង់អាហារកិច្ច

## គ.១. ការទទួលស្គាល់អង្គហេតុ

**គ.១.១.** នៅក្នុងកាលបរិច្ឆេទនៃការត្រៀមសម្រាប់ការទាញហេតុផលលើកទី ២ ចុងចម្លើយបាននិយាយថា "មិនមានឆន្ទៈបន្តអាពាហ៍ពិពាហ៍ជាមួយដើមចោទតទៅទៀតទេ" ហើយនៅកាលបរិច្ឆេទដដែលនោះ ដើមចោទក៏បាននិយាយដែរថា "មិនមានឆន្ទៈបន្តអាពាហ៍ពិពាហ៍ជាមួយចុងចម្លើយតទៅទៀតទេ"។ **(អង្គហេតុដែលមានភាពជាក់ស្តែងចំពោះតុលាការ)**

**គ.១.២.** ចាប់តាំងពីក្រោយពេលដែលចុងចម្លើយបានរួមរស់ជីវភាពរួមគ្នា ជាមួយដើមចោទ ភាគច្រើនចុងចម្លើយបានត្រឡប់មកផ្ទះវិញយប់ជ្រៅ ហើយជាពិសេស នៅក្រោយពេលដែលបានកើតសុជាតារួចមក ចុងចម្លើយធ្លាប់បានមានជម្លោះពាក្យសម្តីរវាងដើមចោទជុំវិញការមើលថែរទាំកូន។ **(ភស្តុតាង $X_5$ ភស្តុតាង $Y_1$ លទ្ធផលនៃការសាកសួរសាមីដើមចោទ និងចុងចម្លើយនីមួយៗ)**

## គ.២. សេចក្តីសន្និដ្ឋាន

ទំនាក់ទំនងអាពាហ៍ពិពាហ៍រវាងដើមចោទ និង ចុងចម្លើយត្រូវបែកបាក់ ហើយគ្មានសង្ឃឹមថានឹងអាចបដិទានឡើងវិញបាន គឺដោយសារតែភាគីទាំងសងខាងដែលជាដើមចោទ និង ចុងចម្លើយមិនមានឆន្ទៈបន្តអាពាហ៍ពិពាហ៍។ មិនតែ

ប៉ុណ្ណោះ ភាគីទាំងសងខាងមិនមានឆន្ទៈបន្តអាពាហ៍ពិពាហ៍ គឺដោយសារតែភាគីទាំងសងខាងមិនបានទំនាក់ទំនងនិយាយគ្នាឲ្យបានគ្រប់គ្រាន់តែប៉ុណ្ណោះទេ ថែមទាំងបណ្ដាលមកពីលទ្ធផលដែលដើមចោទមិនពេញចិត្តចំពោះចុងចម្លើយផងដែរ ដូច្នេះ គឺមិនអាចនិយាយបានថា ភាគីណាម្ខាងមានកំហុសតែម្នាក់ឯងបានទេ។

ហេតុនេះហើយ ដោយសារតែមិនអាចនិយាយឲ្យដាច់ស្រេចថា ដើមចោទមិនមានកំហុសចំពោះការលែងលះទេ ដូច្នេះហើយ តុលាការមិនអាចទទួលស្គាល់អំពីអាហារកិច្ចដែលដើមចោទទាមទារទៅកាន់ចុងចម្លើយទេ។

## ឃ. ការវិនិច្ឆ័យចំពោះការបែងចែកទ្រព្យសម្បត្តិ

### ឃ.១. ការទទួលស្គាល់អង្គហេតុ

**ឃ.១.១.** រវាងដើមចោទ និង ចុងចម្លើយ មានទ្រព្យសម្បត្តិរួមដែលបានកត់ត្រានៅក្នុងឧបសម្ព័ន្ធ "បញ្ជីទ្រព្យសម្បត្តិរួម"។ ម្យ៉ាងវិញទៀត ចំនួនទឹកប្រាក់នៃការវាយតម្លៃដែលបានធ្វើឡើងនៅពេលបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់អំពីទ្រព្យសម្បត្តិរួមនីមួយៗ មានដូចតទៅ **(ភស្តុតាង $X_7$ $X_8$ $X_9$ $X_{10}$ $Y_2$ លទ្ធផលនៃការសាកសួរសាមីដើមចោទ និង ចុងចម្លើយនីមួយៗ ដំណើរការ និង ខ្លឹមសារនៃការទាញហេតុផលដោយផ្ទាល់មាត់ )៖**

| | |
|---|---|
| ដី L1 | ៦.០០០ ដុល្លារអាមេរិក |
| ដី L2 | ១០.០០០ ដុល្លារអាមេរិក |
| រថយន្តនៃរឿងក្តីនេះ | ១០.០០០ ដុល្លារអាមេរិក |
| ម៉ូតូនៃរឿងក្តីនេះ | ១.៥០០ ដុល្លារអាមេរិក |
| ប្រាក់សន្សំនៃរឿងក្តីនេះ | ៨០០ ដុល្លារអាមេរិក |

យ៉ាងណាមិញ ចំពោះប្រាក់សន្សំនៃរឿងក្តីនេះ នៅពេលដែលដើមចោទ និង ចុងចម្លើយបានចាប់ផ្ដើមរស់នៅបែកគ្នា (ថ្ងៃទី ៨ ខែមករា ឆ្នាំ ២០២០) នៅសល់ ៥០០ ដុល្លារអាមេរិក ប៉ុន្តែ ដោយសារតែចុងចម្លើយបានដកប្រាក់សន្សំអស់១ផ្នែក ដូច្នេះហើយ ចំនួនទឹកប្រាក់ដែលនៅសល់នៅ

ពេលបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់មានចំនួន ៥០០ ដុល្លារអាមេរិក។

ឃ.១.២. ចំពោះដី L1 ដើមចោទ និង ចុងចម្លើយបានទិញនៅក្នុងតម្លៃទិញចូលចំនួន ៥.០០០ ដុល្លារអាមេរិក នៅក្នុងនោះមានប្រាក់ ១.០០០ ដុល្លារអាមេរិក (២០% នៃតម្លៃទិញចូល) ដែលបានដកចេញពីប្រាក់សន្សំដែលជាទ្រព្យសម្បត្តិដោយឡែករបស់ចុងចម្លើយ ហើយចំពោះប្រាក់ដែលខ្វះ ៤.០០០ ដុល្លារអាមេរិក ដើមចោទ និង ចុងចម្លើយបានធ្វើកម្ចីរួមគ្នាដោយសាមគ្គីភាព។ ដី L1 ត្រូវបានបង្កើតហ៊ីប៉ូតែកដើម្បីកម្ចីនេះ។ **(លទ្ធផលនៃការសាកសួរសាមីដើមចោទ និង ចុងចម្លើយនីមួយៗ)**

ឃ.១.៣. ចំពោះដី L2 ដើមចោទ និង ចុងចម្លើយបានទិញនៅក្នុងតម្លៃទិញចូលចំនួន ៨.០០០ ដុល្លារអាមេរិក នៅក្នុងនោះមានប្រាក់ដែលបានដកចេញពីប្រាក់សន្សំដែលជាទ្រព្យសម្បត្តិដោយឡែករបស់ដើមចោទ និង ចុងចម្លើយក្នុងម្នាក់ៗ ចំនួន ៨០០ ដុល្លារអាមេរិក (ម្នាក់ ១០ % នៃតម្លៃទិញចូល) ហើយចំពោះប្រាក់ដែលខ្វះ ៦.៤០០ ដុល្លារអាមេរិក ដើមចោទ និង ចុងចម្លើយបានធ្វើកម្ចីរួមគ្នាដោយសាមគ្គីភាព។ ដី L2 ត្រូវបានបង្កើតហ៊ីប៉ូតែកដើម្បីកម្ចីនេះ។ **(លទ្ធផលនៃការសាកសួរសាមីដើមចោទ និង ចុងចម្លើយនីមួយៗ)**

ឃ.១.៤. ចំពោះរថយន្តនៃរឿងក្តីនេះ ដើមចោទ និង ចុងចម្លើយបានទិញនៅក្នុងតម្លៃ ១៥.០០០ ដុល្លារអាមេរិក នៅក្នុងនោះមានប្រាក់ចំនួន ៩.០០០ ដុល្លារអាមេរិក (៦០% នៃតម្លៃទិញចូល) គឺជាតម្លៃតបដែលទទួលបានពីការលក់រថយន្តដែលទ្រព្យសម្បត្តិដោយឡែករបស់ចុងចម្លើយ ហើយចំពោះប្រាក់ដែលខ្វះចំនួន ៦.០០០ ដុល្លារអាមេរិក ដើមចោទ និង ចុងចម្លើយបានដកចេញពីប្រាក់សន្សំដែលជាទ្រព្យសម្បត្តិរួម។ រថយន្តនៃរឿងក្តីនេះ ចុងចម្លើយកំពុងតែប្រើប្រាស់។ **(លទ្ធផលនៃការសាកសួរសាមីដើមចោទ និង ចុងចម្លើយនីមួយៗ)**

ឃ.១.៥. ចំពោះម៉ូតូនៃរឿងក្តីនេះ ដើមចោទ និង ចុងចម្លើយបានទិញនៅក្នុងតម្លៃ ២.០០០ ដុល្លារអាមេរិក នៅក្នុងនោះមានប្រាក់ចំនួន ១.៥០០ ដុល្លារអាមេរិក

(៧៥% នៃតម្លៃទិញចូល) គឺជាតម្លៃតបដែលទទួលបានពីការលក់ម៉ូតូ ដែលជាទ្រព្យសម្បត្តិដោយឡែករបស់ដើមចោទ ហើយចំពោះប្រាក់ ដែលខ្វះចំនួន ៥០០ ដុល្លារអាមេរិក ដើមចោទ និង ចុងចម្លើយបានដក ចេញពីប្រាក់សន្សំដែលជាទ្រព្យសម្បត្តិរួម។ ម៉ូតូនៃរឿងក្ដីនេះ ដើម ចោទកំពុងតែប្រើប្រាស់។ **(លទ្ធផលនៃការសាកសួរសាមីដើមចោទ និង ចុងចម្លើយនីមួយៗ)**

## ឃ.២. ការវិនិច្ឆ័យ

**ឃ.២.១.** អំពីទ្រព្យសម្បត្តិដែលត្រូវក្លាយជាកម្មវត្ថុនៃការបែងចែកទ្រព្យសម្បត្តិ

ទ្រព្យសម្បត្តិដែលប្តីប្រពន្ធទទួលបាននៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ ជាគោលការណ៍នឹងត្រូវក្លាយជាទ្រព្យសម្បត្តិរួម (មាត្រា ៩៧៣ នៃក្រម រដ្ឋប្បវេណី) ហើយនៅក្នុងករណីដែលប្តីប្រពន្ធលែងលះគ្នា សហព័ទ្ធ នីមួយៗមានសិទ្ធិទទួលយក ១ ភាគ ២ នៃទ្រព្យសម្បត្តិរួម (ចំណុច ខ កថាខណ្ឌទី ២ មាត្រា ៩៨០ នៃក្រមរដ្ឋប្បវេណី)។ ការណ៍ដែលលើកឡើង បែបនេះគឺ ដោយសារតែប្តីប្រពន្ធត្រូវរួមរស់ជីវភាពជាមួយគ្នា ហើយត្រូវ សហការ សង្គ្រោះគ្នាទៅវិញទៅមក (មាត្រា ៩៦៦ នៃក្រមរដ្ឋប្បវេណី) ហេតុនេះគឺអាចមានការយល់ឃើញថា ទ្រព្យសម្បត្តិដែលប្តីប្រពន្ធ ទទួលបាននៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ គឺជាទ្រព្យសម្បត្តិដែលប្តី ប្រពន្ធទទួលបានតាមរយៈការសហការគ្នារវាងប្តីប្រពន្ធ ដូច្នេះ នៅពេល ដែលប្តីប្រពន្ធលែងលះគ្នា ក៏គប្បីយកទ្រព្យសម្បត្តិនេះមកជម្រះបញ្ជី ផងដែរ។ ដូច្នេះ បើទោះបីជានៅមុនពេលដែលលែងលះគ្នាក៏ដោយ ក្នុង ករណីដែលប្តីប្រពន្ធមិនបានរួមរស់ជីវភាពជាមួយគ្នាបាត់ទៅហើយ ពោលគឺ បានរស់នៅបែកគ្នារួចហើយនោះ ទ្រព្យសម្បត្តិដែលប្តីប្រពន្ធ ទទួលបាននៅក្នុងអំឡុងពេលរស់នៅបែកគ្នា គឺមិនអាចនិយាយថា ជា ទ្រព្យសម្បត្តិដែលប្តីប្រពន្ធទទួលបានតាមរយៈការសហការគ្នារវាងប្តី ប្រពន្ធបានទេ ដូច្នេះហើយទ្រព្យសម្បត្តិទាំងនោះ មិនគប្បីយកមកធ្វើ ជាកម្មវត្ថុនៃការបែងចែកទ្រព្យសម្បត្តិទេ។ម្យ៉ាងទៀត ជាមួយគ្នានេះ ទោះបីជាក្នុងករណីដែលប្តី ឬ ប្រពន្ធណាម្ខាងបានប្រើប្រាស់ទ្រព្យ

សម្បត្តិរួមសម្រាប់ជីវភាពរបស់ខ្លួន នៅក្រោយពេលដែលបានរស់នៅបែកគ្នាក៏ដោយ ក៏មិនអាចនិយាយបានថា ករណីនោះគឺជាការយកមកប្រើប្រាស់សម្រាប់ការរួមរស់ជីវភាពជាមួយគ្នារបស់ប្តីប្រពន្ធបានដែរ ហេតុដូច្នេះហើយ ទើបចាំបាច់ត្រូវយកទ្រព្យសម្បត្តិនៅមុនពេលដែលត្រូវបានប្តី និង ប្រពន្ធប្រើប្រាស់សម្រាប់ជីវភាព មកធ្វើជាមូលដ្ឋាននៃការបែងចែកទ្រព្យសម្បត្តិ។ ជាពិសេស ទ្រព្យសម្បត្តិរួមដែលត្រូវក្លាយជាកម្មវត្ថុនៃការបែងចែក គួរតែជាទ្រព្យសម្បត្តិដែលប្តីប្រពន្ធទទួលបានគិតចាប់ពីពេលរៀបអាពាហ៍ពិពាហ៍រហូតដល់ពេលដែលរស់នៅបែកគ្នា។

នៅក្នុងរឿងក្តីនេះ នៅមុនពេលនៃការរស់នៅបែកគ្នា ប្រាក់សន្សំនៃរឿងក្តីនេះបាននៅសល់ចំនួន ៥០០ ដុល្លារអាមេរិក ប៉ុន្តែ ក្រោយមកដោយសារតែចុងចម្លើយបានដកយកប្រាក់សន្សំមួយផ្នែក ទើបធ្វើឲ្យចំនួនទឹកប្រាក់ដែលនៅសល់នៅពេលដែលបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់មានចំនួន ៤០០ ដុល្លារអាមេរិក ហេតុនេះនៅពេលដែលធ្វើការបែងចែកទ្រព្យសម្បត្តិរវាងដើមចោទ និង ចុងចម្លើយ គប្បីយកចំនួនទឹកប្រាក់ ៥០០ ដុល្លារអាមេរិកដែលបាននៅសល់នៅពេលដែលរស់នៅបែកគ្នាដំបូងមកធ្វើជាមូលដ្ឋាន។

**ឃ.២.២.** អំពីតម្លៃនៃទ្រព្យសម្បត្តិដែលត្រូវក្លាយជាកម្មវត្ថុនៃការបែងចែកទ្រព្យសម្បត្តិ

ជាបឋម ចំពោះដី L1 មានការវាយតម្លៃជាទឹកប្រាក់ស្មើនឹងចំនួន ៦. ០០០ ដុល្លារអាមេរិក ដែលក្នុងនោះមានចំណែក ២០% ដែលស្មើនឹងទឹកប្រាក់ចំនួន ១.២០០ ដុល្លារអាមេរិក គឺជាផ្នែកដែលបានយកទ្រព្យសម្បត្តិដោយឡែករបស់ចុងចម្លើយមកធ្វើជាដើមទុន។ ដូច្នេះ ចំនួននៃផ្នែកនេះគប្បីក្លាយទៅជារបស់ចុងចម្លើយវិញ ហើយផ្នែកដែលនៅសល់ចំនួន ៤.៨០០ ដុល្លារអាមេរិក គប្បីក្លាយទៅជាកម្មវត្ថុនៃការបែងចែក។

ជាបន្តទៀត ចំពោះដី L2 មានការវាយតម្លៃជាទឹកប្រាក់ស្មើនឹងចំនួន ១០.០០០ ដុល្លារអាមេរិក ដែលក្នុងនោះមានចំណែក ១០ % ដែលស្មើនឹង ១.០០០ ដុល្លារអាមេរិក គឺជាផ្នែកដែលបានយកទ្រព្យសម្បត្តិដោយ

ឡែករបស់ដើមចោទ និង ចំណែក ១០% ដែលស្មើនឹង១.០០០ ដុល្លារអាមេរិក គឺជាផ្នែកដែលបានយកទ្រព្យសម្បត្តិដោយឡែករបស់ចុងចម្លើយ មកធ្វើជាដើមទុន។ ដូច្នេះ ចំនួននៃផ្នែកនេះគប្បីក្លាយទៅជារបស់ដើមចោទ និង ចុងចម្លើយនីមួយៗវិញ ហើយផ្នែកដែលនៅសល់ចំនួន ៩.០០០ ដុល្លារអាមេរិក គប្បីក្លាយទៅជាកម្មវត្ថុនៃការបែងចែក។

ចំពោះរថយន្តនៃរឿងក្តីនេះ មានការវាយតម្លៃជាទឹកប្រាក់ស្មើនឹងចំនួន ១០.០០០ ដុល្លារអាមេរិកដែលក្នុងនោះមានចំណែក ៦០% ដែលស្មើនឹង ៦.០០០ ដុល្លារអាមេរិក គឺជាផ្នែកដែលបានយកទ្រព្យសម្បត្តិដោយឡែករបស់ចុងចម្លើយមកធ្វើជាដើមទុន។ ដូច្នេះ ចំនួននៃផ្នែកនេះគប្បីក្លាយទៅជារបស់ចុងចម្លើយវិញ ហើយផ្នែកដែលនៅសល់ចំនួន ៤.០០០ ដុល្លារអាមេរិក គប្បីក្លាយទៅជាកម្មវត្ថុនៃការបែងចែក។

ចំពោះម៉ូតូនៃរឿងក្តីនេះ មានការវាយតម្លៃជាទឹកប្រាក់ចំនួន ១.៥០០ ដុល្លារអាមេរិក ដែលក្នុងនោះមានចំណែក ៧៥% ដែលស្មើនឹង ១.១២៥ ដុល្លារអាមេរិកគឺជាដើមទុនដែលបានយកមកពីទ្រព្យសម្បត្តិដោយឡែករបស់ដើមចោទ។ ដូច្នេះហើយ ផ្នែកនៃទឹកប្រាក់នេះ គួរតែជារបស់ដើមចោទវិញ ហើយទឹកប្រាក់ដែលនៅសល់ចំនួន ៣៧៥ ដុល្លារអាមេរិក គួរតែយកទៅធ្វើជាកម្មវត្ថុនៃការបែងចែក។

ហេតុដូច្នេះហើយ តម្លៃរបស់ទ្រព្យសម្បត្តិដែលត្រូវក្លាយជាកម្មវត្ថុនៃការបែងចែក មានសរុបចំនួន ១៧.៦៧៥ ដុល្លារអាមេរិក ( ៤.៨០០ "ដី L1" + ៨.០០០ "ដី L2" + ៤.០០០ "រថយន្តនៃរឿងក្តីនេះ" + ៣៧៥ "ម៉ូតូនៃរឿងក្តីនេះ" +៥០០ "ប្រាក់សន្សំនៃរឿងក្តីនេះ" = ១៧.៦៧៥ )។

នៅពេលដែលយកចំនួនទឹកប្រាក់ខាងលើនេះមកបែងចែកឲ្យដើមចោទ និង ចុងចម្លើយក្នុងម្នាក់ៗ ១ ភាគ ២ ដូច្នេះនាំឲ្យដើមចោទ និង ចុងចម្លើយក្នុងម្នាក់ៗ មានសិទ្ធិទទួលបានចំនួនទឹកប្រាក់ ៨.៨៣៧,៥ ដុល្លារអាមេរិក ។

**ឃ.២.៣.** អំពីវិធីនៃការបែងចែកទ្រព្យសម្បត្តិ

ជាបឋម បើមើលទៅលើការបង្កើតហ៊ីប៉ូតែកចំពោះដី L1 និង ដី L2 ដើម្បីធានានូវកាតព្វកិច្ចដោយសាមគ្គីភាពរបស់ដើមចោទ និង ចុងចម្លើយ

គឺ ដីទាំងនេះមិនសក្តិសមយកមកធ្វើជាកម្មសិទ្ធិរបស់ ដើមចោទ ឬចុងចម្លើយតែម្នាក់ឯងទេ ដូច្នេះហើយ ដើមចោទ និង ចុងចម្លើយសក្តិសមតែមានកម្មសិទ្ធិអវិភាគក្នុងម្នាក់ៗ ចំនួន ១ ភាគ ២ ទៅលើដីនេះ។ ម្យ៉ាងទៀត តុលាការមិនទទួលស្គាល់ថា ក្នុងពេលបច្ចុប្បន្ននេះ គឺមានភាពចាំបាច់ដែលត្រូវយកដីនេះមកលក់ដោយបង្ខំភ្លាមៗទេ។ ដូច្នេះហើយ ចំពោះដី L1 នៅក្នុងចំណែកចំនួន ៤.៨០០ ដុល្លារអាមេរិកដែលត្រូវក្លាយជាកម្មវត្ថុនៃការបែងចែក នៅក្នុងនោះគឺដើមចោទគប្បីទទួលបានចំណែកចំនួន ៣.០០០ ដុល្លារអាមេរិក ហើយចុងចម្លើយគប្បីទទួលបានចំណែកចំនួន ១.៨០០ ដុល្លារអាមេរិក (បើបូកទាំងតម្លៃនៃចំនួន ១.២០០ ដុល្លារអាមេរិក ដែលយកទ្រព្យសម្បត្តិដោយឡែករបស់ចុងចម្លើយមកធ្វើជាដើមទុន ចំណែកដែលនឹងទទួលបានមានចំនួន៣០០០ ដុល្លារអាមេរិក) ។ ចំពោះដី L2 នៅក្នុងចំណែកចំនួន ៨.០០០ ដុល្លារអាមេរិកដែលត្រូវក្លាយជាកម្មវត្ថុនៃការបែងចែក នៅក្នុងនោះ គឺដើមចោទ និងចុងចម្លើយគប្បីទទួលបានចំណែករៀងៗខ្លួនចំនួន ៤.០០០ ដុល្លារអាមេរិក។

ចំពោះរថយន្តនៃរឿងក្តីនេះ គប្បីយកទៅធ្វើជាកម្មសិទ្ធិរបស់ចុងចម្លើយ ដូច្នេះហើយ ចំណែកទាំងអស់សរុបចំនួន ៤០០០ ដុល្លារអាមេរិកដែលត្រូវក្លាយជាកម្មវត្ថុនៃការបែងចែក គប្បីចុងចម្លើយជាអ្នកទទួលយក។

ចំពោះម៉ូតូនៃរឿងក្តីនេះ គប្បីយកទៅធ្វើជាកម្មសិទ្ធិរបស់ដើមចោទ ដូច្នេះហើយ ចំណែកទាំងអស់សរុបចំនួន ៣៧៥ ដុល្លារអាមេរិកដែលត្រូវក្លាយជាកម្មវត្ថុនៃការបែងចែក គប្បីដើមចោទជាអ្នកទទួលយក។

ចំពោះប្រាក់សន្សំនៃរឿងក្តីនេះ គប្បីយកទៅធ្វើជាកម្មសិទ្ធិរបស់ចុងចម្លើយដោយសារតែចុងចម្លើយជាម្ចាស់ឈ្មោះ។ ដូច្នេះ ចំណែកទាំងអស់សរុបចំនួន ៥០០ ដុល្លារអាមេរិកដែលត្រូវក្លាយជាកម្មវត្ថុនៃការបែងចែក គប្បីចុងចម្លើយជាអ្នកទទួលយក។

ហេតុដូច្នេះ ចំពោះតម្លៃរបស់ទ្រព្យសម្បត្តិដែលត្រូវក្លាយជាកម្មវត្ថុនៃការបែងចែកមានសរុបចំនួន ១៧.៦៧៥ ដុល្លារអាមេរិក ក្នុងនោះដើមចោទនឹងត្រូវទទួលបានចំនួន ៧.៣៧៥ ដុល្លារអាមេរិក ( ៣.០០០

"ដីL1" + ៤.០០០ "ដីL2" + ៣៧៥ "ម៉ូតូនៃរឿងក្ដីនេះ" = ៧.៣៧៥ ) ហើយចុងចម្លើយទទួលបាន ១០.៣០០ ដុល្លារអាមេរិក (១.៨០០ "ដី L1" + ៤.០០០ "ដីL2" + ៤.០០០ "រថយន្តនៃរឿងក្ដីនេះ" +៥០០ "ប្រាក់សន្សំនៃរឿងក្ដីនេះ" = ១០.៣០០ ) ។

ហេតុនេះហើយ ចំពោះចំនួនទឹកប្រាក់ ១.៤៦២,៥ ដុល្លារអាមេរិក (៨.៨៣៧,៥ – ៧.៣៧៥ = ១.៤៦២,៥) ដែលមានគម្លាតខុសគ្នាពីចំនួនទឹកប្រាក់ចំនួន ៨.៨៣៧,៥ ដុល្លារអាមេរិកដែលដើមចោទអាចទទួលបានតាំងពីដើមនោះ គឺចុងចម្លើយចាំបាច់ត្រូវបង់ចំនួនទឹកប្រាក់ស្មើគ្នានេះឲ្យទៅដើមចោទ ដោយសារតែចំនួនដែលចុងចម្លើយនឹងត្រូវទទួលបានគឺ ៨.៨៣៧,៥ ដុល្លារអាមេរិក ប៉ុន្តែ ជាក់ស្ដែង ចុងចម្លើយបានទទួលចំនួន ១០.៣០០ ដុល្លារអាមេរិក ដូច្នេះ ផ្នែកចំនួន ១.៤៦២,៥ ដុល្លារអាមេរិក (១០.៣០០ – ៨.៨៣៧,៥ = ១.៤៦២,៥ ) គឺជាចំនួនដែលទទួលបានលើស។

## ខ. សេចក្ដីសន្និដ្ឋាន

ដូចបានរៀបរាប់ខាងលើនេះ ចំពោះដី L1 និង ដី L2 ដើមចោទ និង ចុងចម្លើយក្នុងម្នាក់ៗ មានចំណែក ១ ភាគ ២ ហើយរថយន្តនៃរឿងក្ដីនេះជាកម្មសិទ្ធិរបស់ចុងចម្លើយ ហើយចំពោះម៉ូតូនៃរឿងក្ដីនេះជាកម្មសិទ្ធិរបស់ដើមចោទ ហើយចុងចម្លើយត្រូវបង់ប្រាក់ឲ្យទៅដើមចោទចំនួន ១.៤៦២,៥ ទើបជាការសមរម្យ។

## ច. ស្ដីពីបន្ទុកនៃប្រាក់ប្រដាប់ក្ដី

ស្ដីអំពីបន្ទុកនៃប្រាក់ប្រដាប់ក្ដី តុលាការទទួលស្គាល់អំពីការទាមទាររបស់ដើមចោទ (បណ្ដឹងទាមទារលែងលះគ្នា) ដោយសារតែនៅក្នុងនីតិវិធីបណ្ដឹងទាំងចុងចម្លើយក៏បានអះអាងថា ខ្លួនមិនមានឆន្ទៈបន្តអាពាហ៍ពិពាហ៍ជាមួយដើមចោទដែរ ដូច្នេះហើយ មិនមែនមានន័យថាតុលាការបានទទួលស្គាល់អំពីមូលហេតុនៃការលែងលះដូចដើមចោទបានអះអាងនោះទេ។ ហេតុនេះ ចំពោះបន្ទុកនៃប្រាក់ប្រដាប់ក្ដី ក៏គប្បីឲ្យភាគីដើមចោទដែលឈ្នះក្ដីទទួលបន្ទុកមួយផ្នែកដែរ (កថាខណ្ឌទី ២ មាត្រា ៦៤ នៃ

ក្រមនីតិវិធីរដ្ឋប្បវេណី)។ ចំពោះភាគនៃបន្ទុកដែលត្រូវទទួលនោះ បើពិចារណាទៅលើសំអាងហេតុដែលតុលាការបានទទួលស្គាល់នូវការទាមទារ គប្បីឲ្យដើមចោទ និង ចុងចម្លើយទទួលបន្ទុកម្នាក់ៗចំនួន ១ ភាគ ២។

## សេចក្តីសម្រេចបញ្ចប់

១. លែងលះដើមចោទ និង ចុងចម្លើយ ។

២. កំណត់ថា ដើមចោទជាអ្នកមានអំណាចមេបាលើកូនប្រុសរវាងដើមចោទ និង ចុងចម្លើយដែលមានឈ្មោះ សុក សុជាតិ (កើតនៅថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៦) ។

៣. កំណត់ថា ដើមចោទជាអ្នកមានអំណាចមេបាលើកូនស្រីរវាងដើមចោទ និង ចុងចម្លើយដែលមានឈ្មោះ សុក សុជាតា (កើតនៅថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១៨) ។

៤. បង្គាប់ឲ្យចុងចម្លើយបង់ប្រាក់ចំនួន ១០០ ដុល្លារអាមេរិកក្នុង ១ ខែ ឲ្យទៅដើមចោទ គិតត្រឹមថ្ងៃចុងក្រោយជារៀងរាល់ខែ ក្នុងអំឡុងពេលគិតចាប់ពីថ្ងៃដែលសាលក្រមនេះចូលជាស្ថាពររហូតដល់ឈ្មោះ សុក សុជាតិ ដែលបានកត់ត្រានៅក្នុង **ចំណុច ២** ខាងលើនេះក្លាយជានីតិជន។

៥. បង្គាប់ឲ្យចុងចម្លើយបង់ប្រាក់ចំនួន ១០០ ដុល្លារអាមេរិកក្នុង ១ ខែ ឲ្យទៅដើមចោទ គិតត្រឹមថ្ងៃចុងក្រោយជារៀងរាល់ខែ ក្នុងអំឡុងពេលគិតចាប់ពីថ្ងៃដែលសាលក្រមនេះចូលជាស្ថាពររហូតដល់ឈ្មោះ សុក សុជាតា ដែលបានកត់ត្រានៅក្នុង **ចំណុច ៣** ខាងលើនេះក្លាយជានីតិជន។

៦. បែងចែកទ្រព្យសម្បត្តិនីមួយៗ ដែលបានកត់ត្រានៅក្នុង "បញ្ជីទ្រព្យសម្បត្តិរួម" នៃឧបសម្ព័ន្ធ ដូចខាងក្រោមនេះ ៖

**ក.** ដីចំណុច ១. ដែលកត់ត្រានៅក្នុង "បញ្ជីទ្រព្យសម្បត្តិរួម" នៃឧបសម្ព័ន្ធជាកម្មសិទ្ធិអវិភាគរវាងដើមចោទ និង ចុងចម្លើយក្នុងចំណែកម្នាក់ៗចំនួន ១ ភាគ ២។

**ខ.** ដីចំណុច ២. ដែលកត់ត្រានៅក្នុង " បញ្ជីទ្រព្យសម្បត្តិរួម" នៃឧបសម្ព័ន្ធជាកម្មសិទ្ធិអវិភាគរវាងដើមចោទ និង ចុងចម្លើយក្នុងចំណែកម្នាក់ៗ ចំនួន ១ ភាគ ២ ។

គ. ឡានចំណុច ៣. ដែលបានកត់ត្រានៅក្នុង " បញ្ជីទ្រព្យសម្បត្តិរួម " នៃឧបសម្ព័ន្ធជាកម្មសិទ្ធិរបស់ចុងចម្លើយ។

ឃ. ម៉ូតូចំណុច ៤. ដែលបានកត់ត្រានៅក្នុង "បញ្ជីទ្រព្យសម្បត្តិរួម" នៃឧបសម្ព័ន្ធជាកម្មសិទ្ធិរបស់ដើមចោទ។

ង. ប្រាក់សន្សំចំណុច ៥. ដែលបានកត់ត្រានៅក្នុង " បញ្ជីទ្រព្យសម្បត្តិរួម " នៃឧបសម្ព័ន្ធជាកម្មសិទ្ធិចុងចម្លើយ។

ច. បង្គាប់ឲ្យចុងចម្លើយបង់ប្រាក់ចំនួន ១.៤៦២,៥ ដុល្លារអាមេរិកឲ្យទៅដើមចោទ។

៧. ច្រានចោលពាក្យសុំដែលដើមចោទទាមទារទៅចុងចម្លើយឲ្យបង់អាហារកិច្ច។

៨. ប្រាក់ប្រដាប់ក្តីចែកជា ២ ចំណែក ដោយ ១ ផ្នែកគឺជាបន្ទុករបស់ដើមចោទ ផ្នែកដែលនៅសល់គែជាបន្ទុករបស់ចុងចម្លើយ។

សាលក្រមនេះ ត្រូវបានប្រកាសនៅសវនការជាសាធារណៈ នៅថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០២០ ។ ក្នុងករណីដែលប្តឹងឧទ្ធរណ៍ ត្រូវតែធ្វើឡើងនៅក្នុងរយៈពេល ០១ (មួយ) ខែ គិតចាប់ពីថ្ងៃបានទទួលការបញ្ជូនលិខិតសាលក្រមនេះ។

ថ្ងៃព្រហស្បត្តិ៍ ទី២កើត ខែភទ្របទ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ខេត្តបាត់ដំបង, ថ្ងៃទី ១២ ខែ សីហា ឆ្នាំ២០២០

**ចៅក្រម**

**ឧបសម្ព័ន្ធ**

# **បញ្ជីទ្រព្យសម្បត្តិរួម**

១. អចលនវត្ថុ

"ទីតាំងដី" ផ្លូវលេខ...... ភូមិ........ ឃុំ............ ស្រុក........ ខេត្តបាត់ដំបង

"លេខក្បាលដី" ..........

២. អចលនវត្ថុ

"ទីតាំងដី" ផ្លូវលេខ...... ភូមិ........ ឃុំ............ ស្រុក........ ខេត្តបាត់ដំបង

"លេខក្បាលដី" .........

៣. រថយន្ត

"ប្រភេទ" ទេសចរណ៍

"ម៉ាក" **LEXUS RX300**

"ពណ៌" ស

"កម្មសិទ្ធិករ" ចុងចម្លើយ

"អាសយដ្ឋាន" ផ្ទះលេខ 00 ផ្លូវ 00 សង្កាត់មនោរម្យ ខណ្ឌ៧មករា ភ្នំពេញ

"ផ្លាកលេខ" ......-........

៤. ម៉ូតូ

"ប្រភេទ" ស្រី

"ម៉ាក" **YAMAHA QBIX**

"ពណ៌" ខ្មៅ

"កម្មសិទ្ធិករ" ដើមចោទ

"អាសយដ្ឋាន" ផ្ទះលេខ 00 ផ្លូវ 00 សង្កាត់មនោរម្យ ខណ្ឌ៧មករា ភ្នំពេញ

"ផ្លាកលេខ" ......-........

៥. ប្រាក់សន្សំ

"ស្ថាប័នហិរញ្ញវត្ថុ" ធនាគារ...... សាខា........

"ប្រភេទ និង លេខគណនី" ប្រាក់សន្សំធម្មតា ××× ××× ×××

"ឈ្មោះម្ចាស់គណនី" ចុងចម្លើយ

# ការបែងចែកទ្រព្យសម្បត្តិ Case 4




X
Y
L1
1000$ Y
4000$ XY
1200$ Y
4800$ XY
6000$
X ½ (3000$)
Y ½ (3000$)
3000$ XY
1200$ Y
1800$ XY
L2
800$ Y
800$ X
6400$ XY
1000$ Y
1000$ X
8000$ XY
10000$
X ½ (5000$)
Y ½ (5000$)
1000$ X
4000$ XY
1000$ Y
4000$ XY
9000$ Y
6000$ XY
6000$ Y
4000$ XY
10000$
Y (10000$)
6000$ Y
4000$ XY
1500$ X
500$ XY
1125$ X
375$ XY
1500$
X (1500$)
1125$ X
375$ XY
500$ XY
500$
Y (500$)
500$ XY
3000$+4000$+375$
=7375$
1800$+4000$+4000$+500$
=10300$
(7375$+10300$)÷2=8837.5$
+1462.5$
-1462.5$

# វិធីពិនិត្យពាក្យបណ្តឹង



Yoshie SASAKI / JICA Expert

Q 1　តើ "ពាក្យបណ្ដឹង" គឺជាអ្វី?

Q 2　តើ "បណ្ដឹង" គឺជាអ្វី?

Q 3　តើ "ការទាមទារ" គឺជាអ្វី?

Q 4　តើភាពខុសគ្នារវាង "បណ្ដឹង" និង "ការទាមទារ" គឺជាអ្វី?

Q 1 តើ "ពាក្យបណ្តឹង" គឺជាអ្វី?

A 1 ជាឯកសារសម្រាប់ដាក់ " បណ្តឹង "

Q 2 តើ "បណ្តឹង" គឺជាអ្វី?

Q 3 តើ "ការទាមទារ" គឺជាអ្វី?

Q 4 តើភាពខុសគ្នារវាង "បណ្តឹង" និង "ការទាមទារ" គឺជាអ្វី?

Q 1 តើ "ពាក្យបណ្ដឹង" គឺជាអ្វី?

Q 2 តើ "បណ្ដឹង" គឺជាអ្វី?

A 2 ជាការសុំទាមទារឲ្យតុលាការចេញសាលក្រមដែលមានខ្លឹមសារកំណត់មួយ ដោយផ្អែកលើ "ការទាមទារ" តាមផ្លូវបណ្ដឹង (កថាភាគទី១ "អត្ថន័យនៃបណ្ដឹង" ទំព័រទី៤០ នៃសេចក្ដីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគ១)

Q 3 តើ "ការទាមទារ" គឺជាអ្វី?

Q 4 តើភាពខុសគ្នារវាង "បណ្ដឹង" និង "ការទាមទារ" គឺជាអ្វី?

Q 1 តើ "ពាក្យបណ្ដឹង" គឺជាអ្វី ?

Q 2 តើ "បណ្ដឹង" គឺជាអ្វី ?

Q 3 តើ "ការទាមទារ" គឺជាអ្វី ?

A 3 ជាការអះអាងស្ដីពីអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត តាមផ្លូវច្បាប់នីតិឯកជនដែលបានកំណត់មួយ របស់ដើមចោទចំពោះចុងចម្លើយ (កថាភាគទី២ "ការទាមទារតាមផ្លូវបណ្ដឹង និង កម្មវត្ថុនៃបណ្ដឹង" ទំព័រទី៤១ នៃសេចក្ដីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគ១)

Q 4 តើភាពខុសគ្នារវាង "បណ្ដឹង" និង "ការទាមទារ" គឺជាអ្វី ?

# Q 4　តើភាពខុសគ្នារវាង “បណ្ដឹង” និង “ការទាមទារ” គឺជាអ្វី?




ពាក្យបណ្ដឹង
កថាខណ្ឌទី១ មាត្រា៧៥
នៃក្រមនីតិវិធីរដ្ឋប្បវេណី
តុលាការ
បណ្ដឹង
ការទាមទារ
ដើមចោទ
សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត តាមផ្លូវច្បាប់នីតិឯកជនដែលបានកំណត់មួយ
ចុងចម្លើយ

# តើនៅក្នុងពាក្យបណ្ដឹងត្រូវសរសេរអ្វីខ្លះ ?




**① ដើមចោទ**

**② ចុងចម្លើយ**

ចំណុច ក កថាខណ្ឌទី២ មាត្រា៧៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី

**③ សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត តាមផ្លូវច្បាប់នីតិឯកជនដែលបានកំណត់មួយ**

【ឧទាហរណ៍】

សិទ្ធិទាមទារឲ្យសងប្រាក់កម្ចីដោយផ្អែកលើកិច្ចសន្យាខ្ចីបរិភោគប្រាក់ ចុះថ្ងៃទី១ ខែតុលា ឆ្នាំ ២០២០ រវាងដើមចោទ និង ចុងចម្លើយ

←បើមានតែប៉ុណ្ណឹងគឺមិនអាចដឹងបានទេថា តើចង់ទាមទារបញ្ជាក់ថាមានសិទ្ធិទាមទារឲ្យសងប្រាក់កម្ចីនេះ ឬ តើចង់ទាមទារឲ្យសងប្រាក់កម្ចីដោយផ្អែកលើសិទ្ធិទាមទារឲ្យសងប្រាក់កម្ចីនេះ។

→នឹងច្បាស់លាស់តាមរយៈខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ។

**④ ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ**

"បង្គាប់ឲ្យចុងចម្លើយបង់ប្រាក់ចំនួន ១0.000.000 (ដប់លាន) រៀល ទៅដើមចោទ។"

ចំណុច ខ កថាខណ្ឌទី២ មាត្រា៧៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី


តុលាការ
បណ្តឹង ?
ដីកាសម្រេច
បង្គាប់ឲ្យកែតម្រូវ (កថាខណ្ឌទី១ មាត្រា៧៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី)
→នៅពេលមិនកែតម្រូវ ត្រូវលើកចោល "ពាក្យបណ្តឹង" (កថាខណ្ឌទី២ មាត្រា៧៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី)
? ? ?
ដើមចោទ
? ? ?
? ? ?

# តើនៅក្នុងការពិនិត្យពាក្យបណ្ដឹងត្រូវធ្វើអ្វីខ្លះ ?




## ① ដើមចោទ

ជាគោលការណ៍ អ្នកដែលបានដាក់បណ្ដឹង (អ្នកដាក់ពាក្យបណ្ដឹងទៅតុលាការ) គឺជាដើមចោទ ហេតុនេះ មានការកំណត់ដើមចោទ។

## ② ចុងចម្លើយ

ចុងចម្លើយ គឺជានរណា? មានការកំណត់ភាគីម្ខាងទៀតនៃបណ្ដឹងដែរឬទេ? មានត្រឹមតែ "ឬទ្ធី" គឺមិនអាចដឹងបានទេ។ តើជា "ឬទ្ធី" មួយណា?នៅឯណា?

## ③ សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត តាមផ្លូវច្បាប់នីតិឯកជនដែលបានកំណត់មួយ

- តើ "សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត" ត្រូវបានសរសេរដែរឬទេ?
- តើសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត "ចំពោះចុងចម្លើយ" ត្រូវបានសរសេរដែរឬទេ ?

## ④ ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ

មិនធ្វើការវិនិច្ឆ័យអំពី អត្ថិភាព ឬ នត្ថិភាពនៃ សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត (ថាតើទទួលស្គាល់ការទាមទាររបស់ដើមចោទដែរឬទេ) ទេ!!

ចំណុចនេះ ធ្វើការវិនិច្ឆ័យដោយ សាលក្រម។
មិនត្រូវធ្វើការវិនិច្ឆ័យនៅក្នុងការពិនិត្យពាក្យបណ្ដឹងទេ!

# ឧទាហរណ៍ជាក់ស្តែងនៅក្នុងការពិនិត្យពាក្យបណ្តឹង Case 1

ដើមចោទ A
អាសយដ្ឋាន　○○

ចុងចម្លើយ　B
អាសយដ្ឋាន　××

【ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ】
1．ដើមចោទ ទាមទាររំលាយកិច្ចសន្យា ចំពោះចុងចម្លើយ។
2．បង្គាប់ឲ្យមន្ត្រីចុះបញ្ជី ចុះបញ្ជីលុបអំពីការផ្ទេរកម្មសិទ្ធិ ចំពោះដើមចោទ។

【អង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ】
1．ដើមចោទ បានលក់ដីក្នុងតម្លៃ ៥0.000 (៥ម៉ឺន) ដុល្លារ នៅថ្ងៃទី១ ខែតុលា ឆ្នាំ២0២0 ឲ្យទៅចុងចម្លើយ។
2．ដើមចោទ និង ចុងចម្លើយ បានទៅកន្លែងមេឃុំ ហើយបានបង្កើតលិខិតលក់ផ្តាច់ បន្ទាប់មកបានធ្វើនិងដាក់ពាក្យសុំចុះបញ្ជីផ្ទេរកម្មសិទ្ធិនៅប្រកចេញចូលតែមួយ នៅថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២0២0។
3．ចុងចម្លើយ បានសន្យាថានឹងបង់ប្រាក់ថ្លៃលក់សរុបទាំងអស់រហូតដល់ថ្ងៃទី៣0 ខែវិច្ឆិកា ឆ្នាំ២0២0 ប៉ុន្តែនៅសល់ ២0.000 (២ម៉ឺន) ដុល្លារទៀត មិនទាន់បានបង់នៅឡើយទេ។
4．ដើមចោទ ចង់ទាមទាររំលាយកិច្ចសន្យាលក់ទិញ ហើយចង់ទាមទារឲ្យចុះបញ្ជីលុបអំពីការផ្ទេរកម្មសិទ្ធិ។

# ឧទាហរណ៍ជាក់ស្ដែងនៅក្នុងការពិនិត្យពាក្យបណ្ដឹង Case 1

ដើមចោទ A ✓
អាសយដ្ឋាន ○○ ✓

ចុងចម្លើយ B ✓
អាសយដ្ឋាន ×× ✓

ភាគីម្ខាងដែលមានសិទ្ធិរំលាយ អាចរំលាយកិច្ចសន្យា **ដោយបង្ហាញឆន្ទៈរំលាយ**ចំពោះភាគីម្ខាងទៀតបាន។ ការបង្ហាញឆន្ទៈរំលាយនេះអាចធ្វើឡើងក្រៅតុលាការបាន។ (កថាខណ្ឌទី ១ មាត្រា ៤០៩ នៃក្រមរដ្ឋប្បវេណី)

ប្រសិនបើចង់រំលាយកិច្ចសន្យា គ្រាន់តែធ្វើការបង្ហាញឆន្ទៈ អាចរំលាយបាន។

"សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត" មិនត្រូវបានសរសេរទេ។

【ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ】

1. ដើមចោទ ទាមទាររំលាយកិច្ចសន្យា ចំពោះចុងចម្លើយ។
2. បង្គាប់ឲ្យមន្ត្រីចុះបញ្ជី ចុះបញ្ជីលុបអំពីការផ្ទេរកម្មសិទ្ធិ ចំពោះដើមចោទ។

សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត "ចំពោះចុងចម្លើយ" មិនត្រូវបានសរសេរទេ។

ចុងចម្លើយ គឺជា B។

【អង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ】

1. ដើមចោទ បានលក់ដីក្នុងតម្លៃ ៥០.០០០ (៥ម៉ឺន) ដុល្លារ នៅថ្ងៃទី១ ខែតុ
2. ដើមចោទ និង ចុងចម្លើយ បានទៅកន្លែងមេឃុំ ហើយបានបង្កើតលិខិតលក់ ... ផ្ទេរកម្មសិទ្ធិនៅប្រកចេញចូលតែមួយ នៅថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០២០។
3. ចុងចម្លើយ បានសន្យាថានឹងបង់ប្រាក់ថ្លៃលក់សរុបទាំងអស់រហូតដល់ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០ ... នៅសល់ ២០.០០០ (២ម៉ឺន) ដុល្លារទៀត មិនទាន់បានបង់នៅឡើយទេ។
4. ដើមចោទ ចង់ទាមទាររំលាយកិច្ចសន្យាលក់ទិញ ហើយចង់ទាមទារឲ្យចុះបញ្ជីលុបអំពីការផ្ទេរកម្មសិទ្ធិ។

# តុលាការ

បណ្ដឹង ?

**<u>ដីកាសម្រេច</u>**

បង្គាប់ឲ្យកែតម្រូវ (កថាខណ្ឌទី១ មាត្រា៧៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី)

→នៅពេលមិនកែតម្រូវ ត្រូវលើកចោល "ពាក្យបណ្ដឹង" (កថាខណ្ឌទី២ មាត្រា៧៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី)

④ ？？？

① A ③ ？？？ ② B

តើ A ④ចង់ទាមទារអ្វី ③ដោយផ្អែកលើសិទ្ធិបែបណា ចំពោះ B?

# ឧទាហរណ៍ជាក់ស្តែងនៅក្នុងការពិនិត្យពាក្យបណ្តឹង Case 2

ដើមចោទ　A
អាសយដ្ឋាន　○○

ចុងចម្លើយ　រដ្ឋបាលសុរិយោដីរាជធានីភ្នំពេញ
អាសយដ្ឋាន　××

【ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ】
1．បង្គាប់ឲ្យចុងចម្លើយ ចុះបញ្ជីលុបអំពីការផ្ទេរកម្មសិទ្ធិ ចំពោះដើមចោទ។

【អង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ】
1．ដើមចោទ បានលក់ដីក្នុងតម្លៃ ៥0.000 (៥ម៉ឺន) ដុល្លារ នៅថ្ងៃទី១ ខែតុលា ឆ្នាំ២0២0 ឲ្យទៅ B។
2．ដើមចោទ និង B បានទៅកន្លែងមេឃុំ ហើយបានបង្កើតលិខិតលក់ផ្តាច់ បន្ទាប់មកបានធ្វើនិងដាក់ពាក្យសុំចុះបញ្ជីផ្ទេរកម្មសិទ្ធិនៅប្រកចេញចូលតែមួយ នៅថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២0២0។
3．B បានសន្យាថានឹងបង់ប្រាក់ថ្លៃលក់សរុបទាំងអស់រហូតដល់ថ្ងៃទី៣0 ខែវិច្ឆិកា ឆ្នាំ២0២0 ប៉ុន្តែនៅសល់ ២0.000 (២ម៉ឺន) ដុល្លារទៀត មិនទាន់បានបង់នៅឡើយទេ ហេតុនេះ ដើមចោទ បានរំលាយកិច្ចសន្យាលក់ទិញ។
4．ចុងចម្លើយ  មានករណីយកិច្ចចុះបញ្ជីលុបអំពីការផ្ទេរកម្មសិទ្ធិពីដើមចោទមក B។

# ឧទាហរណ៍ជាក់ស្តែងនៅក្នុងការពិនិត្យពាក្យបណ្តឹង Case 2

ដើមចោទ　A　✓
អាសយដ្ឋាន　○○　✓

ចុងចម្លើយ　រដ្ឋបាលសុរិយោដីរាជធានីភ្នំពេញ　✓
អាសយដ្ឋាន　××　✓

【ខ្លឹមសារនៃសាលសក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ】
1.　បង្គាប់ឲ្យចុងចម្លើយ ចុះបញ្ជីលុបអំពីការផ្ទេរកម្មសិទ្ធិ ចំពោះដើមចោទ។ ✓

【អង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ】
1.　ដើមចោទ បានលក់ដីក្នុងតម្លៃ ៥០.០០០ (៥ម៉ឺន) ដុល្លារ នៅថ្ងៃទី១ ខែតុលា ឆ្នាំ២០២០ ឲ្យទៅ B។
2.　ដើមចោទ និង B បានទៅកន្លែងមេឃុំ ហើយបានបង្កើតលិខិតលក់ផ្តាច់ បន្ទាប់មកបានធ្វើនិងដាក់ពាក្យសុំចុះបញ្ជីផ្ទេរកម្មសិទ្ធិនៅប្រកចេញចូលតែមួយ នៅថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០២០។
3.　B បានសន្យាថានឹងបង់ប្រាក់ថ្លៃលក់សរុបទាំងអស់រហូតដល់ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២០ ប៉ុន្តែនៅសល់ ២០.០០០ (២ម៉ឺន) ដុល្លារទៀត មិនទាន់បានបង់នៅឡើយទេ ហេតុនេះ ដើមចោទ បានរំលាយកិច្ចសន្យាលក់ទិញ។
4.　ចុងចម្លើយ　មានករណីយកិច្ចចុះបញ្ជីលុបអំពីការផ្ទេរកម្មសិទ្ធិពីដើមចោទមក B។


សាលាដំបូងរាជធានីភ្នំពេញ
បណ្ដឹង
④ ការទាមទារ បង្គាប់ឲ្យចុះបញ្ជីលុបអំពីការផ្ទេរកម្មសិទ្ធិ
① A
③ សិទ្ធិទាមទារចុះបញ្ជីលុបអំពីការផ្ទេរកម្មសិទ្ធិ
② រដ្ឋបាល
សុរិយោដី
រាជធានីភ្នំពេញ




ករណីយកិច្ចចុះបញ្ជីរបស់រដ្ឋបាលសុរិយោដី មានចែងនៅក្នុងវាក្យខណ្ឌទី២ ប្រការ៦ នៃប្រកាសអន្តរក្រសួងស្ដីពីនីតិវិធីនៃការចុះបញ្ជីអំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី។
រដ្ឋបាលសុរិយោដីរាជធានី ខេត្ត មានករណីយកិច្ចចុះបញ្ជី "ទៅតាមចំណុចដែលមាននៅក្នុងពាក្យសុំរបស់អ្នកដាក់ពាក្យសុំ ឬ លិខិតផ្ទុកផ្ដាក់"។

ពោលគឺ <u>ករណីយកិច្ចដែលរដ្ឋបាលសុរិយោដីចុះបញ្ជី គឺនៅក្រោយពេលដែលត្រូវបានធ្វើនិងដាក់ "ពាក្យសុំ ឬ លិខិតផ្ទុកផ្ដាក់"</u>។

<u>នៅពេលនេះ A និង B មិនទាន់បានធ្វើនិងដាក់ពាក្យសុំចុះបញ្ជីលុបអំពីការផ្ទេរកម្មសិទ្ធិ ចំពោះរដ្ឋបាលសុរិយោដីនៅឡើយទេ!!</u>

ករណីយកិច្ចចុះបញ្ជីរបស់រដ្ឋបាលសុរិយោដី មានចែងនៅក្នុងវាក្យខណ្ឌទី២ ប្រការ៦ នៃប្រកាសអន្តរក្រសួងស្តីពីនីតិវិធីនៃការចុះបញ្ជីអំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី។
រដ្ឋបាលសុរិយោដីរាជធានី ខេត្ត មានករណីយកិច្ចចុះបញ្ជី "ទៅតាមចំណុចដែលមាននៅក្នុងពាក្យសុំរបស់អ្នកដាក់ពាក្យសុំ ឬ លិខិតផ្ទុកផ្តាក់"។

ពោលគឺ <u>ករណីយកិច្ចដែលរដ្ឋបាលសុរិយោដីចុះបញ្ជី គឺនៅក្រោយពេលដែលត្រូវបានធ្វើនិងដាក់ "ពាក្យសុំ ឬ លិខិតផ្ទុកផ្តាក់"</u>។

<u>នៅពេលនេះ A និង B មិនទាន់បានធ្វើនិងដាក់ពាក្យសុំចុះបញ្ជីលុបអំពីការផ្ទេរកម្មសិទ្ធិ ចំពោះរដ្ឋបាលសុរិយោដីនៅឡើយទេ!!</u>

ដូច្នេះ នៅក្នុងរឿងក្តីពេលនេះ គឺរដ្ឋបាលសុរិយោដី មិនមានករណីយកិច្ចចុះបញ្ជីលុបចោលការផ្ទេរកម្មសិទ្ធិ ចំពោះដើមចោទទេ។

ពោលគឺ មិនមានសិទ្ធិដែលដើមចោទអះអាងទេ។

ប៉ុន្តែ នៅក្នុងការពិនិត្យពាក្យបណ្តឹង **មិនធ្វើការវិនិច្ឆ័យអំពី អត្ថិភាព ឬ នត្ថិភាពនៃ សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត (ថាតើទទួលស្គាល់ការទាមទាររបស់ដើមចោទដែរឬទេ)ទេ!!**

➡ ការពិនិត្យពាក្យបណ្តឹង គ្មានបញ្ហា
បញ្ជូនពាក្យបណ្តឹងទៅចុងចម្លើយ (រដ្ឋបាលសុរិយោដីរាជធានីភ្នំពេញ)។

# ប្រភេទនៃការសម្រេចសេចក្ដី ( មាត្រា១៧៩ )





សាលក្រម
គ្មានល័ក្ខខ័ណ្ឌបណ្តឹង
→លើកចោល
សាលក្រមលើកចោលបណ្តឹង ជាគោលការណ៍ ត្រូវទាញហេតុផលដោយផ្ទាល់មាត់ (កថាខណ្ឌទី១ មាត្រា១៧៩, មាត្រា១៨០) ប៉ុន្តែ ជាករណីលើកលែង ក៏ត្រូវបានអនុញ្ញាតឲ្យចេញសាលក្រមដោយមិនឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់ផងដែរ(មាត្រា៨១)
តុលាការ
នៅពេលធ្វើការវិនិច្ឆ័យលើ ការទាមទារ ជាដាច់ខាត ត្រូវទាញហេតុផលដោយផ្ទាល់មាត់
បណ្តឹង
សាលក្រម
គ្មានសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត
→ច្រានចោល
មានសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត
→ទទួលស្គាល់
ការទាមទារ
ដើមចោទ
សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត តាមផ្លូវច្បាប់នីតិឯកជនដែលបានកំណត់មួយ
ចុងចម្លើយ

# ឧទាហរណ៍ជាក់ស្តែងនៅក្នុងការពិនិត្យពាក្យបណ្តឹង

ចំពោះ Case 1 នៅក្នុងការពិនិត្យពាក្យបណ្តឹង បង្គាប់ឲ្យកែតម្រូវពាក្យបណ្តឹង។
ចាំបាច់ត្រូវធ្វើឲ្យច្បាស់លាស់ថាចង់ទាមទារអ្វី ដោយផ្អែកលើ សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត របស់ A ចំពោះ B។

ចំពោះ Case 2 នៅក្នុងពាក្យបណ្តឹងមិនមានបញ្ហានោះទេ ហេតុនេះ តុលាការ បញ្ជូនពាក្យបណ្តឹងទៅចុងចម្លើយ។
ច្រានចោលការទាមទាររបស់ដើមចោទនៅក្នុងសាលក្រម បន្ទាប់ពីបានធ្វើការទាញហេតុផលដោយផ្ទាល់មាត់រួច។

ហេតុអ្វីបានជាច្រានចោលការទាមទាររបស់ដើមចោទ ប៉ុន្តែបែជាមិនលើកចោលពាក្យបណ្តឹង នៅក្នុងដំណាក់កាលនៃការពិនិត្យពាក្យបណ្តឹង ?

តើអត្ថន័យដែលដាក់ឲ្យដំណើរការនីតិវិធីស្ថិតនៅត្រង់ណា ?

តើ "សាលក្រម" មានអត្ថន័យបែបណា ? ( តើអត្ថន័យដែលមាននៅក្នុងសាលក្រម ហើយមិនមាននៅក្នុងដីកាសម្រេច គឺជាអ្វី ? )

# Q&A Session



# រឿងក្ដីរឹបអូសជាបណ្ដោះអាសន្ន
# ចំពោះអចលនវត្ថុ និងរឿងក្ដី
# អនុវត្តចំពោះអចលនវត្ថុ

# សេចក្តីសង្ខេបករណីសិក្សា Case.5

## ១. ការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ

នៅថ្ងៃទី១ ខែតុលា ឆ្នាំ២០១៩ X បានបង្កើតកិច្ចសន្យាខ្ចីបរិភោគប្រាក់ចំនួន ៤០.០០០.០០០ (សែសិបលាន) រៀល ដោយយកការប្រាក់ ចំនួន ៥ ភាគរយ (ប្រាំភាគរយ) ក្នុងមួយឆ្នាំ និងកំណត់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០ ជាពេលកំណត់សងជាមួយ Y ហើយបានប្រគល់សាច់ប្រាក់ចំនួន ៤០.០០០.០០០ (សែសិបលាន) រៀល ទៅឱ្យ Y។ កិច្ចសន្យានេះ ត្រូវបានធ្វើឡើងដោយលាយល័ក្ខណ៍អក្សរនៃលិខិតកិច្ចសន្យា ដោយមានចុះហត្ថលេខារបស់ភាគីទាំងពីរ។

កាលកំណត់អំឡុងពេលសងថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០ បានកន្លងផុត ដោយសារតែ Y មិនបានសងទាល់តែសោះ ទើប X បានទាមទារឱ្យសងជាច្រើនលើកច្រើនសារទៅកាន់ Y ចាប់ពីអំឡុងខែតុលា ឆ្នាំ២០២០។ ប៉ុន្តែ Y មិនបានធ្វើការឆ្លើយតបទេ រហូតមកដល់អំឡុងដើមខែវិច្ឆិកា ឆ្នាំ២០២០ សូម្បីទាក់ទងក៏លែងបានដែរ។

X បានឮពីអ្នកដែលបានស្គាល់ Y ថា Y មានអាជីវកម្មហាងបោកអ៊ុត ប៉ុន្តែ អាជីវកម្មនោះមិនបានដំណើរទៅដោយយ៉ាងរលូននោះទេ ហើយលើសពីនេះបានខ្ចីប្រាក់ពីសាច់ញាតិ និងអ្នកស្គាល់គ្នាជាច្រើនទៀតផង។ ម្យ៉ាងវិញទៀត ក្រៅពីដីដែលមានសរសេរនៅក្នុងបញ្ជីឧបសម្ព័ន្ធអំពីវត្ថុ (តម្លៃ ប្រហែល ១៥.០០០ (មួយម៉ឺនប្រាំពាន់) ដុល្លាអាមេរិក) រកមិនឃើញទ្រព្យសម្បត្តិផ្សេងទៀតមានតម្លៃនោះទេ។

អាស្រ័យហេតុនេះ បានពឹងពាក់មេធាវី P ហើយបានដាក់ពាក្យសុំរឹបអូសជាបណ្តោះអាសន្នចំពោះដីដែលមានសរសេរក្នុងបញ្ជីឧបសម្ព័ន្ធអំពីវត្ថុដែលជាកម្មសិទ្ធិរបស់ Y ដើម្បីរក្សាការពារការអនុវត្តដោយបង្ខំនូវសិទ្ធិលើបំណុលដែលទាមទារផ្អែកតាមកិច្ចសន្យានៃរឿងក្តីនេះ។

## ២. ការអនុវត្តចំពោះអចលនវត្ថុ

នៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២០ X បានពឹងពាក់មេធាវី P ហើយបានដាក់បណ្តឹងទាមទារឱ្យសងប្រាក់ផ្អែកតាមកិច្ចសន្យានៃរឿងក្តីនេះទៅកាន់ Y។ នៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២១ តុលាការបានចេញសាលក្រមដែលមានអត្ថន័យទទួលស្គាល់នូវការទាមទាររបស់ X ហើយសាលក្រមដដែលនេះបានចូលជាស្ថាពរ នៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២១។ លើសពីនេះទៀត ទោះបីជាក្រោយពីសាលក្រមបានចូលជាស្ថាពរក៏ដោយ ក៏ Y មិនបានសងប្រាក់កម្ចីមក X ទាល់តែសោះ។

ដូច្នេះហើយ X បានពឹងពាក់មេធាវី P ហើយបានដាក់ពាក្យសុំឱ្យចាប់ផ្តើមនីតិវិធីដេញថ្លៃលក់ដោយបង្ខំចំពោះដីដែលមានសរសេរក្នុងបញ្ជីឧបសម្ព័ន្ធអំពីវត្ថុដែលជាកម្មសិទ្ធិរបស់ Y ផ្អែកតាមសាលក្រមខាងលើ។

# តារាងពេលវេលា Case.5

## ១. ការរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ

1.10.2019 X•Y បង្កើតកិច្ចសន្យានៃរឿងក្ដីនេះ

| | |
|---|---|
| ពេលកំណត់សង | 30.9.2020 |
| ប្រាក់ដើម | 40.000.000 រៀល |
| ការប្រាក់ | 5 ភាគរយ ក្នុងមួយឆ្នាំ |

30.9.2020 ពេលកំណត់សងកន្លងផុត

30.11.2020 X→Y ដាក់ពាក្យសុំឱ្យរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ

ដីកាសម្រេចដាក់ប្រាតិភោគ

4.12.2020 ដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន

7.12.2020 X→Yដាក់ពាក្យសុំឱ្យអនុវត្តរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ

## ២. ការអនុវត្តចំពោះអចលនវត្ថុ

21.12.2020 X→Y ដាក់បណ្ដឹងអង្គសេចក្ដី

21.6.2021 X ឈ្នះក្ដី

22.7.2021 សាលក្រមឈ្នះក្ដីចូលជាស្ថាពរ

9.8.2021 X→Y ដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# ពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ

## ម្ចាស់បំណុល

ឈ្មោះ ៖ X

អាសយដ្ឋាន ៖ ផ្ទះលេខ 00 ផ្លូវលេខ 00 ភូមិ...... ឃុំ.......ស្រុក......... ខេត្តបាត់ដំបង។[1]

## អ្នកតំណាងដោយអាណត្តិ

ឈ្មោះ៖លោក/លោកស្រី ៖ P

អាសយដ្ឋានការិយាល័យ ៖ .................................

ឈ្មោះការិយាល័យមេធាវី/ក្រុមមេធាវី/ក្រុមហ៊ុនមេធាវី ៖ ..........................................

លេខទូរស័ព្ទ ៖ ..................................................

**ទីកន្លែងបញ្ជូន** ៖ ការិយាល័យមេធាវី/ ក្រុមមេធាវី/ ក្រុមហ៊ុនមេធាវី[2]..................

## កូនបំណុល

ឈ្មោះ ៖ Y

---

[1] អំពីឈ្មោះ និងអាសយដ្ឋាន មានបញ្ញត្តិនៅក្នុងចំណុច ក កថាខណ្ឌទី ១ មាត្រា ៥៤១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ប៉ុន្តែ ចំពោះចំណុចផ្សេងទៀត ដូចជា ថ្ងៃខែឆ្នាំកំណើតជាអាទិ៍ ជាចំណុចដែលពុំមានបញ្ញត្តិក្នុងច្បាប់ទេ។ ប៉ុន្តែ ក៏មានករណីដែលពុំអាចកំណត់អំពីភាគី តាមរយៈឈ្មោះ និង អាសយដ្ឋានបានផងដែរ។ ដូច្នេះ ករណីត្រូវសរសេរចំណុចទាំងនោះក្នុងកម្រិតមួយដែលចាំបាច់ ដើម្បីអាចកំណត់អំពីភាគីបាន។

[2] យោងមាត្រា ៥៣៩ មាត្រា ២៤៩ និងមាត្រា ២៥០ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ ការសរសេរអំពីទីកន្លែងបញ្ជូន មិនមែនជាករណីយកិច្ចទេ។ ប្រសិនបើមិនសរសេរទីកន្លែងបញ្ជូន នោះការបញ្ជូន នឹងបញ្ជូនទៅអាសយដ្ឋានរបស់ម្ចាស់បំណុល ជាអាទិ៍។ ហេតុដូច្នេះ ករណីដែលអ្នកតំណាងដោយអាណត្តិរបស់ម្ចាស់បំណុលមានបំណងចង់ឱ្យធ្វើការបញ្ជូនទៅទីកន្លែងក្រៅពីអាសយដ្ឋានរបស់ម្ចាស់បំណុល ជាអាទិ៍ ចាំបាច់ត្រូវសរសេរទីកន្លែងបញ្ជូនជាលាយលក្ខអក្សរដូចជានៅក្នុងពាក្យសុំ ជាអាទិ៍។

អាសយដ្ឋាន៖ ផ្ទះលេខ ០០ ផ្លូវលេខ ០០ ភូមិ...... ឃុំ.......ស្រុក......... ខេត្តបាត់ដំបង។

**សូមគោរពជូន**

**ឯកឧត្តម/លោកជំទាវប្រធានសាលាដំបូងរាជធានីភ្នំពេញ**[3]

## ក. ខ្លឹមសារនៃដីកាសម្រេចរក្សាការពារដែលអ្នកដាក់ពាក្យសុំទាមទារ៖[4]

រឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ ដែលមានសរសេរនៅក្នុងបញ្ជីឧបសម្ព័ន្ធអំពីវត្ថុដែលជាកម្មសិទ្ធិរបស់កូនបំណុល។

---

[3] រឿងក្ដីនៃដីកាសម្រេចរក្សាការពារ ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់តុលាការដែលមានសមត្ថកិច្ចលើអង្គសេចក្ដី ឬ សាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងវត្ថុដែលនឹងត្រូវរឹបអូសជាបណ្ដោះអាសន្ន ឬ វត្ថុដែលជាកម្មវត្ថុនៃវិវាទស្ថិតនៅ (កថាខណ្ឌទី ១ មាត្រា ៥៤០ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

នៅក្នុងរឿងក្ដីនេះ ដោយសារតែលំនៅដ្ឋានរបស់កូនបំណុលនៅខេត្តបាត់ដំបង ហើយលំនៅដ្ឋានរបស់កម្ចាស់បំណុល និងទីកន្លែងដែលត្រូវអនុវត្តនូវកាតព្វកិច្ចប្រាក់កម្ចី នៅខេត្តបាត់ដំបងដែរ ហេតុនេះហើយ សាលាដំបូងខេត្តបាត់ដំបង គឺជាសាលាដំបូងដែលមានសមត្ថកិច្ចលើអង្គសេចក្ដី ឬ សាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងវត្ថុ។ ម្យ៉ាងវិញទៀត អចលនវត្ថុដែលជាកម្មវត្ថុនៃវិវាទ ស្ថិតនៅរាជធានីភ្នំពេញ ដូច្នេះហើយសាលាដំបូងរាជធានីភ្នំពេញក៏មានសមត្ថកិច្ចលើលើរឿងក្ដីរឹបអូសជាបណ្ដោះអាសន្នផងដែរ។ រវាងសាលាដំបូងខេត្តបាត់ដំបង ឬ សាលាដំបូងរាជធានីភ្នំពេញ ម្ចាស់បំណុលអាចដាក់ពាក្យសុំ ទៅសាលាដំបូងណាមួយក៏បាន ប៉ុន្តែ នៅក្នុងរឿងក្ដីនេះ បានដាក់ពាក្យសុំទៅសាលាដំបូងរាជធានីភ្នំពេញ ដោយសារលំនៅដ្ឋានរបស់អចលនវត្ថុដែលជាកម្មវត្ថុនៃវិវាទនៅជិតជាង។

[4] ខ្លឹមសារនៃដីកាសម្រេចរក្សាការពារដែលអ្នកពាក្យសុំទាមទារ ជាចំណុចត្រូវសរសេរជាចាំបាច់ក្នុងពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ (ចំណុច ខ កថាខណ្ឌទី ១ មាត្រា ៥៤១ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ ក្នុងករណី ស្នើសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្ដោះ គឺស្នើសុំដីកាសម្រេចដែលមានន័យថា រឹបអូសជាបណ្ដោះអាសន្នចំពោះទ្រព្យសម្បត្តិរបស់កូន ។ ម្យ៉ាងវិញទៀត ត្រូវកំណត់ជាក់លាក់នូវអលនវត្ថុដែលជាកម្មវត្ថុនោះ (មាត្រា ៥៤៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ហើយវិធីដើម្បីកំណត់ជាក់លាក់នេះ ត្រូវភ្ជាប់បញ្ជីឧបសម្ព័ន្ធអំពីសិទ្ធិ លើបំណុលដែលទាមទារ និងបញ្ជីឧបម្ព័ន្ធអំពីវត្ថុនៅក្នុងពាក្យសុំ និងយោងតាមរយៈបញ្ជីឧបសម្ព័ន្ធទាំងនេះ។

យ៉ាងណាមិញ ចំពោះប្រាក់រំដោះពីការរឹបអូសជាបណ្ដោះអាសន្ន (កថាខណ្ឌទី ១ មាត្រា ៥៤៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី) និងករណីយកិច្ចទទួលបន្ទុកប្រាក់ប្រដាប់ក្ដី (មាត្រា ៥៣៩ និង មាត្រា ១៨២ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ទោះបីជាមាន ឬ មិនមានពាក្យសុំពីភាគី ក៏ត្រូវកំណត់ប្រាក់រំដោះពីការរឹបអូសជាបណ្ដោះអាសន្ននៅក្នុងដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ដូច្នេះ អ្នកដាក់ពាក្យសុំ មិនមានភាពចាំបាច់ដែលត្រូវសរសេរនៅក្នុងខ្លឹមសារនៃដិកាសម្រេចរក្សាការពារដែលអ្នកដាក់ពាក្យសុំទាមទារនោះទេ។

## ខ. សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារ[5]

### ខ.១ ការបង្កើតកិច្ចសន្យាខ្ចីបរិភោគប្រាក់

នៅថ្ងៃទី១ ខែតុលា ឆ្នាំ២០១៩ ម្ចាស់បំណុលបានបង្កើតកិច្ចសន្យាខ្ចីបរិភោគប្រាក់ចំនួន ៤០.០០០.០០០ (សែសិបលាន) រៀល ជាមួយកូនបំណុល។ នៅក្នុងកិច្ចសន្យាដដែលនេះ ម្ចាស់បំណុល និងកូនបំណុល បានកំណត់ថា ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ ២០២០ ជាពេលកំណត់សង។ ម្យ៉ាងវិញទៀត ម្ចាស់បំណុល និងកូនបំណុល បានព្រមព្រៀងទៅលើខ្លឹមសារដែលបង់ការប្រាក់ ចំនួន ៥ ភាគរយ (ប្រាំភាគរយ) ក្នុងមួយឆ្នាំនៃប្រាក់ដើមចំនួន ៤០.០០០.០០០ (សែសិបលាន) រៀល ហើយការព្រមព្រៀងនេះបានធ្វើឡើងជាលាយល័ក្ខណ៍អក្សរ ដោយមានចុះហត្ថលេខារបស់កូនបំណុល។ (**ភស្តុតាង**$X_1$)

នៅថ្ងៃទី១ ខែតុលា ឆ្នាំ២០១៩ ដោយផ្អែកតាមកិច្ចសន្យាខាងលើ ម្ចាស់បំណុលបានប្រគល់សាច់ប្រាក់ចំនួន ៤០.០០០.០០០ (សែសិបលាន) រៀល ទៅកូនបំណុល។ (**ភស្តុតាង**$X_2$) [6]

### ខ.២ ការកន្លងផុតនៃពេលកំណត់សង

ពេលកំណត់សង ដែលជាថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០ បានកន្លងផុត។

---

[5] សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារ ជាចំណុចត្រូវសរសេរជាចាំបាច់ក្នុងពាក្យសុំឱ្យចេញនៃដីកាសម្រេចរក្សាការពារ (ចំណុច គ កថាខណ្ឌទី ១ មាត្រា ៥៤១ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ ហើយចំណុចនេះ ត្រូវសរសេរឱ្យបានលម្អិតនូវអង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវសិទ្ធិ និងអង្គហេតុដែលជាមូលហេតុនៃសិទ្ធិ។ ម្យ៉ាងទៀត ដើម្បីឱ្យដីកាសម្រេចចេញបានដោយយ៉ាងឆាប់រហ័ស និងការកំណត់ចំនួនទឹកប្រាក់ប្រាតិភោគឱ្យបានទាបតាមដែលអាចធ្វើបាន គួរតែសរសេរនូវការតវ៉ាតបចំពោះការតវ៉ាដែលនឹងត្រូវបានរំពឹងទុក។

[6] អំពីសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារ (ចំណុច គ កថាខណ្ឌទី ១ មាត្រា ៥៤១ នៃក្រមនីតិវិធីរដ្ឋប្បវេណី) និងភាពចាំបាច់នៃការរក្សាការពារ (ចំណុច ឃ កថាខណ្ឌទី ១ មាត្រា ៥៤១ នៃក្រមនីតិវិធីរដ្ឋប្បវេណី) គួរតែខិតខំប្រឹងប្រែងសរសេរនូវភស្តុតាងតាមហេតុនីមួយៗដែលត្រូវបញ្ជាក់ (កថាខណ្ឌទី ២ មាត្រា ៥៤១ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ វិធីកំណត់អំពីសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តិដែលនឹងត្រូវបានរក្សាការពារ ត្រូវធ្វើការយោង និងភ្ជាប់ឧបសម្ព័ន្ធសិទ្ធិលើបំណុលដែលនឹងទាមទារទៅនឹងពាក្យសុំ។

### ខ.៣ ការសន្និដ្ឋានអំពីសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តិដែលនឹងត្រូវបានរក្សាការពារ

ហេតុដូច្នេះ ម្ចាស់បំណុល មានសិទ្ធិទាមទារចំពោះកូនបំណុលដោយផ្អែកតាមកិច្ចសន្យាខ្ចីបរិភោគនៃរឿងក្ដីនេះដូចមានសរសេរនៅក្នុងបញ្ជីឧបសម្ព័ន្ធអំពីសិទ្ធិលើបំណុលដែលទាមទារ (១) ប្រាក់ដើម ចំនួន ៨០.០០០.០០០ (សែសិបលាន) រៀល , (២) ការប្រាក់ ចំនួន ៥ ភាគរយ (ប្រាំភាគរយ) ក្នុងមួយឆ្នាំ នៃប្រាក់ដើមចំនួន ៨០.០០០.០០០ (សែសិបលាន) រៀល គិតចាប់ពីថ្ងៃទី១ ខែតុលា ឆ្នាំ២០១៩ ដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០ គឺចំនួន ២.០០០.០០០ (ពីរលាន) រៀល, (៣) ប្រាក់សំណងនៃការខូចខាតដោយសារការយឺតយ៉ាវ ចំនួន ៥ ភាគរយ (ប្រាំភាគរយ) ក្នុងមួយឆ្នាំ នៃប្រាក់ដើម ចំនួន ៨០.០០០.០០០ (សែសិបលាន) រៀល គិតចាប់ពីថ្ងៃទី១ ខែតុលា ឆ្នាំ២០២០ ដល់ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២០ គឺ ចំនួន ៣២៨.០០០ (បីសែនពីរម៉ឺនប្រាំបីពាន់) រៀល។

## គ. ភាពចាំបាច់នៃការរក្សាការពារ[7]

**គ.១** ក្រោយពេលកំណត់សង ដែលជាថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២០ បានកន្លងផុត កូនបំណុលមិនបានសងទាល់តែសោះមកម្ចាស់បំណុល។ អំឡុងពេលខែតុលា ឆ្នាំ២០២០ ម្ចាស់បំណុល បានទាមទារឱ្យសងជាច្រើនលើកទៅកាន់កូនបំណុល ប៉ុន្តែកូនបំណុលមិនបានឆ្លើយតបទេ រហូតមកដល់អំឡុងដើម ខែវិច្ឆិកា ឆ្នាំ២០២០ សូម្បីទាក់ទងក៏លែងបានដែរ។ (**ភស្តុតាង**$X_3$)

**គ.២**យោងតាមដែលម្ចាស់បំណុលបានសួរ និងឮពីអ្នកដែលបានស្គាល់កូនបំណុលថា កូនបំណុល មានអាជីវកម្មហាងបោកអ៊ុត ប៉ុន្តែអាជីវកម្មនោះមិនបានដំណើរទៅដោយយ៉ាងរលូននោះទេ ហើយដើម្បីមើលថែទាំឪពុកដែលមានជំងឺ កូន

---

[7] ភាពចាំបាច់នៃការរក្សាការពារ ជាចំណុចត្រូវសរសេរជាចាំបាច់ក្នុងពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ (ចំណុច ឃ កថាខណ្ឌទី១ មាត្រា ៥៤១ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

នៅក្នុងការរឹបអូសជាបណ្ដោះអាសន្ន ត្រូវសរសេរនូវស្ថានភាពឱ្យបានច្បាស់លាស់ផ្អែកតាមការបារម្ភថាការអនុវត្តដោយបង្ខំនឹងមិនអាចធ្វើបាន ឬ នឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តដោយបង្ខំ។

បំណុលបានខ្ចីប្រាក់ពីសាច់ញាតិ និងអ្នកស្គាល់គ្នាជាច្រើន។ លើសពីនេះ ការស្រាវជ្រាវរបស់ម្ចាស់បំណុល គឺថាកូនបំណុលមានកម្មសិទ្ធិលើដីដែលមានសរសេរនៅក្នុងបញ្ជីឧបសម្ព័ន្ធអំពីវត្ថុ (**ភស្តុតាង**$X_4$) ប៉ុន្តែ ក្រៅពីនេះទៀត រកមិនឃើញទ្រព្យសម្បត្តិផ្សេងទៀតមានតម្លៃទេ។ (**ភស្តុតាង**$X_3$)

**គ.៣** ម្ចាស់បំណុល កំពុងតែរៀបចំដើម្បីដាក់បណ្តឹងទាមទារឱ្យបង់សិទ្ធិលើបំណុលដែលមានសរសេរនៅក្នុងបញ្ជីឧបសម្ព័ន្ធអំពីសិទ្ធិលើបំណុលដែលទាមទារចំពោះកូនបំណុល ប៉ុន្តែ ប្រសិនបើមិនធ្វើការរឹបអូសជាបណ្តោះអាសន្នចំពោះដីដែលមានសរសេរក្នុងបញ្ជីឧបសម្ព័ន្ធអំពីវត្ថុនាពេលនេះទេ នាពេលក្រោយ ទោះបីជាទទួលបានសាលក្រមឈ្នះក្តីក្នុងបណ្តឹងអង្គសេចក្តីក៏ដោយ ក៏នឹងមិនអាចអនុវត្ត ឬ មានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តនោះ ។

**ឃ. ភស្តុតាង**[8]

១. លិខិតកិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី១ ខែតុលា ឆ្នាំ២០១៩ (**ភស្តុតាង**$X_1$)

២. លិខិតវិក្កយបត្រទទួលប្រាក់កម្ចី ចុះថ្ងៃទី ១ ខែតុលា ឆ្នាំ២០១៩(**ភស្តុតាង**$X_2$)

៣. របាយការណ៍ (**ភស្តុតាង**X3)

៤. ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់សៀវភៅចុះបញ្ជី (**ភស្តុតាង**$X_4$)

សេចក្តីដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តម/លោកជំទាវប្រធាន** សម្រេចតាមការស្នើសុំ ដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តម/លោកជំទាវប្រធាន** ទទួលនូវសេចក្តីគោរពដ៏ជ្រាលជ្រៅអំពីខ្ញុំ។

---

[8] អំពីសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារ (ចំណុច គ កថាខណ្ឌទី ១ មាត្រា ៥៤១ នៃក្រមនីតិវិធីរដ្ឋប្បវេណី) និងភាពចាំបាច់នៃការរក្សាការពារ ( ចំណុច ឃ កថាខណ្ឌទី ១ មាត្រា ៥៤១ នៃក្រមនីតិវិធីរដ្ឋប្បវេណី) មានភាពចាំបាច់ត្រូវភ្ជាប់នូវឯកសារដើម្បីធ្វើសេចក្តីបញ្ជាក់ដំបូង (កថាខណ្ឌទី ៣ មាត្រា ៥៤១ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

ខេត្តបាត់ដំបង, ថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ២០២០

**អ្នកតំណាងដោយអាណត្តិ**

P

<u>ឯកសារភ្ជាប់</u>

១-លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ "ច្បាប់ដើម"

២-ច្បាប់ថតចម្លងនៃភស្តុតាងនីមួយៗខាងលើ "ចំនួន ០១ ច្បាប់"

**ឧបសម្ព័ន្ធ**

## បញ្ជីឧបសម្ព័ន្ធអំពីសិទ្ធិលើបំណុលដែលទាមទារ[9]

ចំនួនទឹកប្រាក់៖ ៤២.៣២៨.០០០ (សែសិបពីរលានបីសែនពីរម៉ឺនប្រាំបីពាន់) រៀល

ផ្អែកតាមកិច្ចសន្យាខ្ចីបរិភោគប្រាក់ដែលបង្កើតឡើងរវាងម្ចាស់បំណុល និងកូនបំណុល ចុះថ្ងៃទី១ ខែតុលា ឆ្នាំ២០១៩ ដោយយកថ្ងៃទី៣០ កញ្ញា ឆ្នាំ២០២០ ជាពេលកំណត់សង មានចំនួនសរុបនៃសិទ្ធិទាមទារទឹកប្រាក់ដូចខាងក្រោម៖

១. ប្រាក់ដើម ចំនួន ៤០.០០០.០០០ (សែសិបលាន) រៀល

២. ការប្រាក់ ចំនួន ២០.០០០.០០០ (ពីរលាន) រៀល

ការប្រាក់ ចំនួន ៥ ភាគរយ (ប្រាំភាគរយ) ក្នុងមួយឆ្នាំ នៃប្រាក់ដើម ចំនួន ៤០.០០០.០០០ (សែសិបលាន) រៀល គិតចាប់ពីថ្ងៃទី១ ខែតុលា ឆ្នាំ២០១៩ រហូតដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០

៣. ប្រាក់សំណងនៃការខូចខាតដោយសារការយឺតយ៉ាវ ចំនួន ៣២៨.០០០ (បីសែនពីម៉ឺនប្រាំបីពាន់) រៀល

[9] សិទ្ធិបំណុលដែលទាមទារ ត្រូវកំណត់ជាក់លាក់នូវ ខ្លឹមសារ និង ចំនួនទឹកប្រាក់ ជាអាទិ៍ ក្នុងកម្រិតដែលអាចបែងចែកជាមួយនឹងសិទ្ធិលើបំណុលផ្សេងទៀតបាន។ ប្រសិនបើជាកិច្ចសន្យាខ្ចីបរិភោគប្រាក់ ត្រូវសរសេរកំណត់ជាក់លាក់ដោយសរសេរ អំពីភាគី កាលបរិច្ឆេទនៃកិច្ចសន្យា ពេលកំណត់សង ជាអាទិ៍។ ម្យ៉ាងទៀត បន្ថែមពីប្រាក់ដើមដែលជាប្រាក់កម្ចី ក្នុងករណីដែលទាមទារការប្រាក់ និង ប្រាក់សំណខូចខាត ត្រូវកំណត់ឱ្យបានច្បាស់លាស់នូវចំនួនទឹកប្រាក់នីមួយៗ ព្រមទាំងកំណត់ឱ្យបានច្បាស់លាស់នូវអត្រាការប្រាក់ និង អំឡុងពេល ជាអាទិ៍។

ប្រាក់សំណងខូចខាតដោយសារការយឺតយ៉ាវ ចំនួន ៥ ភាគរយ (ប្រាំភាគរយ) ក្នុងមួយឆ្នាំ នៃប្រាក់ដើម ចំនួន ៥០.០០០.០០០ (សែសិបលាន) រៀល គិតចាប់ពីថ្ងៃទី១ ខែតុលា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២០

**ឧបសម្ព័ន្ធ**

## បញ្ជីឧបសម្ព័ន្ធអំពីវត្ថុ

"ទីតាំងដី" ផ្លូវលេខ ០០ ភូមិ...... សង្កាត់.......ខណ្ឌ.........រាជធានីភ្នំពេញ

"លេខឡូត៍" ០០

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងរាជធានីភ្នំពេញ

សំណុំរឿងរក្សាការពារលេខៈ 00

ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២០

ដីកាសម្រេចលេខៈ00

ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០២០

# ដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន[1]

យើង J ជាចៅក្រមនៃសាលាដំបូងរាជធានីភ្នំពេញ

- បានឃើញ ចំណុច ក មាត្រា ៥៣១, មាត្រា ៥៤២, កថាខណ្ឌទី ១ មាត្រា ៥៤៥, កថាខណ្ឌទី ១ មាត្រា ៥៤៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី។[2]
- បានឃើញពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ចំពោះអចលនវត្ថុ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២០។

---

[1] ការសម្រេចសេចក្ដី មាន សាលក្រម និង ដីកាសម្រេច (មាត្រា ១៧៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ដូច្នេះ គឺមានភាពចាំបាច់ដែលត្រូវសសេរប្រភេទនៃការសម្រេចសេចក្ដីនៅក្នុងក្បាលដើមនៃឯកសារ។ ពីព្រោះថា វិធីនៃឧបាស្រ័យជាអាទិ៍ មានភាពខុសគ្នារវាង សាលក្រម និងដីកាសម្រេច។ បណ្ដឹងឧបាស្រ័យចំពោះសាលក្រមរបស់សាលាដំបូង ជាគោលការណ៍ គឺត្រូវធ្វើឡើងជាបណ្ដឹងឧទ្ធរណ៍ ចំណែកឯបណ្ដឹងឧបាស្រ័យចំពោះដីកាសម្រេច គឺត្រូវឡើងជាបណ្ដឹងជំទាស់ (កថាខណ្ឌទី ១ មាត្រា ២៥៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

ម្យ៉ាងទៀត នៅក្នុងដីកាសម្រេចរក្សាការពារ មានដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន និងដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន ដូច្នេះ គឺមានការចាំបាច់កំណត់ឱ្យបានច្បាស់លាស់ថាជាដីកាសម្រេចណាមួយ។

[2] នៅពេលដែលយោងក្រមនីតិវិធីរដ្ឋប្បវេណី គួរតែសរសេរឱ្យបានលម្អិតត្រឹមតែលេខមាត្រាដែលត្រូវអនុវត្ត។

## ម្ចាស់បំណុល

ឈ្មោះ ៖ X

អាសយដ្ឋាន ៖ ផ្ទះលេខ ០០ ផ្លូវលេខ ០០ ភូមិ...... ឃុំ.......ស្រុក......... ខេត្តបាត់ដំបង។

## អ្នកតំណាងដោយអាណត្តិ

ឈ្មោះ៖លោក/លោកស្រី ៖ P

អាសយដ្ឋានការិយាល័យ ៖ .................................

ឈ្មោះការិយាល័យមេធាវី/ក្រុមមេធាវី/ក្រុមហ៊ុនមេធាវី ៖ .........................................

លេខទូរស័ព្ទ ៖ ..................................................

## កូនបំណុល

ឈ្មោះ ៖ Y

អាសយដ្ឋាន៖ផ្ទះលេខ ០០ ផ្លូវលេខ ០០ ភូមិ...... ឃុំ.......ស្រុក......... ខេត្តបាត់ដំបង។

## ខ្លឹមសារនៃដីកាសម្រេចរក្សាការពារដែលអ្នកដាក់ពាក្យសុំទាមទារ[3]

រឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ ដែលមានសរសេរនៅក្នុងបញ្ជីឧបសម្ព័ន្ធអំពីវត្ថុដែលជាកម្មសិទ្ធិរបស់កូនបំណុល។

## សំអាងហេតុ[4]

---

[3] មាត្រា ៥៣៩, មាត្រា ២១៦, ចំណុច ឃ កថាខណ្ឌទី ១ មាត្រា ១៨៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

[4]មាត្រា ៥៣៩, មាត្រា ២១៦, ចំណុច ង មាត្រា ១៨៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ ប្រសិនបើមើលពីគោលគំនិតនៃលក្ខណៈបន្ទាន់បង្ហំ (លក្ខណៈឆាប់រហ័ស) នៃការរក្សាការពារផ្នែករដ្ឋប្បវេណី ដីកាសម្រេចរក្សាការពារ ត្រូវធ្វើឱ្យបានឆាប់រហ័ស ហើយជាពិសេសនៅក្នុងដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ជាធម្មតា ប្រសិនបើមិនបើកការទាញហេតុផលដោយផ្ទាល់មាត់ និងសួរកូនបំណុលទេ នាំឱ្យការសរសេរនៅក្នុងសំអាងហេតុ គ្រាន់តែសរសេរឱ្យមានលក្ខណៈជារួម និងខ្លីៗ គឺគ្រប់គ្រាន់។ លើសពីនេះ នៅក្នុងសម្អាងហេតុក្រោយពី បានកំណត់អំពីប្រភេទ ខ្លឹមសារ និងចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលដែលម្ចាស់បំណុលមាន ត្រូវសរសេរនូវខ្លឹមសារថា រឹបអូសជាបណ្តោះចំពោះទ្រព្យសម្បត្តិរបស់កូនបំណុល

យោងតាមសំណុំរឿងនៃរឿងក្តីនេះ ទទួលស្គាល់ថាម្ចាស់បំណុលមានសិទ្ធិលើបំណុលដូចមានសរសេរនៅក្នុងបញ្ជីឧបសម្ព័ន្ធអំពីសិទ្ធិលើបំណុលដែលទាមទារចំពោះកូនបំណុល និងទទួលស្គាល់ផងដែរនូវភាពចាំបាច់នៃដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ។

ដូច្នេះ តុលាការ ទទួលស្គាល់ថា ពាក្យសុំរបស់ម្ចាស់បំណុលគឺសមរម្យ ហើយឱ្យម្ចាស់បំណុលដាក់ប្រាតិភោគចំនួន ១២.០០០.០០០ (ដប់ពីរលាន) រៀល ដើម្បីរក្សាការពារនូវការអនុវត្តសិទ្ធិលើបំណុលដូចមានសរសេរនៅក្នុងបញ្ជីឧបសម្ព័ន្ធអំពីសិទ្ធិលើបំណុលដែលទាមទាររបស់ម្ចាស់បំណុលចំពោះកូនបំណុល ដូចក្នុងការសម្រេចសេចក្តីខាងក្រោម។

## សេចក្តីសម្រេចបញ្ចប់[5]

១.រឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ ដែលមានសរសេរនៅក្នុងបញ្ជីឧបសម្ព័ន្ធអំពីវត្ថុដែលជាកម្មសិទ្ធិរបស់កូនបំណុល។

២. កូនបំណុល ត្រូវផ្ញើចំនួនប្រាក់ ចំនួន ៤២.៣២៨.០០០ (សែសិបពីរលានបីសែន ពីរម៉ឺនប្រាំបីពាន់) រៀល[6] ដើម្បីទទួលបាននូវការលុបចោលការអនុវត្តដីកាសម្រេចនេះ។

៣. ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់កូនបំណុល។

ដើម្បីរក្សាការពារការអនុវត្តនេះ។ នៅក្នុងឯកសារទម្រង់គំរូនេះ មានភ្ជាប់បញ្ជីឧបសម្ព័ន្ធអំពីសិទ្ធិលើបំណុលដែលទាមទារនៅក្នុងលិខិតដីកាសម្រេច ហើយតាមរយៈការយោងបញ្ជីឧបសម្ព័ន្ធនេះ មានការកំណត់ជាក់លាក់សិទ្ធិលើបំណុលដែលម្ចាស់បំណុលមាន។

[5] មាត្រា ៥៣៩, មាត្រា ២១៦, ចំណុច ច កថាខណ្ឌទី ១ មាត្រា ១៨៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ជាគោលការណ៍ ត្រូវចេញដីកាសម្រេច ដោយកំណត់ជាក់លាក់នូវកម្មវត្ថុ (មាត្រា ៥៤៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ នៅក្នុងឯកសារទម្រង់គំរូនេះ មានភ្ជាប់បញ្ជីឧបសម្ព័ន្ធអំពីវត្ថុនៅក្នុងលិខិតដីកាសម្រេច ហើយតាមរយៈការយោងបញ្ជីឧបសម្ព័ន្ធនេះ មានការកំណត់ជាក់លាក់នូវអចលនវត្ថុដែលជាកម្មវត្ថុ។

យ៉ាងណាមិញ ទោះបីមាន ឬ មិនមានពាក្យសុំពីភាគី ក៏ត្រូវកំណត់ប្រាក់រំដោះពីការរឹបអូសជាបណ្តោះអាសន្ន (កថាខណ្ឌទី ១ មាត្រា ៥៤៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី) និងករណីយកិច្ចទទួលបន្ទុកប្រាក់ប្រដាប់ក្តី (មាត្រា ៥៣៩, មាត្រា ២១៦, កថាខណ្ឌទី ៣ មាត្រា ១៨២ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

[6] នេះគឺជាចំនួនទឹកប្រាក់សមរម្យនៃសិទ្ធិលើបំណុលដែលមានសរសេរនៅក្នុងបញ្ជីឧបសម្ព័ន្ធអំពីសិទ្ធិលើបំណុលដែលទាមទារ ។

ដីកាសម្រេចនេះអាចអនុវត្តបានភ្លាម។

ចំពោះដីកាសម្រេចនេះ អាចដាក់ពាក្យសុំតវ៉ាយោងតាមមាត្រា ៥៥០ នៃក្រមនីតិវិធីរដ្ឋប្បវេណីបាន។

ថ្ងៃសុក្រ ៤រោជ ខែមិគសិរ ឆ្នាំជូត ទោស័ក ពស ២៥៦៤

រាជធានីភ្នំពេញ, ថ្ងៃទី ៤ ខែធ្នូ ឆ្នាំ ២០២០

**ចៅក្រម**

**ឧបសម្ព័ន្ធ**

## បញ្ជីឧបសម្ព័ន្ធអំពីសិទ្ធិលើបំណុលដែលទាមទារ[7]

ចំនួនទឹកប្រាក់៖ ៥២.៣២៨.០០០ (សែសិបពីរលានបីសែនពីរម៉ឺនប្រាំបីពាន់) រៀល

ផ្អែកតាមកិច្ចសន្យាខ្ចីបរិភោគប្រាក់ដែលបង្កើតឡើងរវាងម្ចាស់បំណុល និងកូនបំណុលនៅថ្ងៃទី១ ខែតុលា ឆ្នាំ២០១៩ ដោយកំណត់ថ្ងៃទី៣០ កញ្ញា ឆ្នាំ២០២០ ជាពេលកំណត់សង មានចំនួនសរុបនៃសិទ្ធិទាមទារទឹកប្រាក់ដូចខាងក្រោម៖

១. ប្រាក់ដើម ចំនួន ៥០.០០០.០០០ (សែសិបលាន) រៀល

២. ការប្រាក់ ចំនួន ២.០០០.០០០ (ពីរលាន) រៀល

ការប្រាក់ ចំនួន ៥ ភាគរយ (ប្រាំភាគរយ) ក្នុងមួយឆ្នាំ នៃប្រាក់ដើម ចំនួន ៥០.០០០.០០០ (សែសិបលាន) រៀល គិតចាប់ពីថ្ងៃទី១ ខែតុលា ឆ្នាំ២០១៩ រហូតដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០

៣. ប្រាក់សំណងនៃការខូចខាតដោយសារការយឺតយ៉ាវ ចំនួន ៣២៨.០០០ (បីសែនពីរម៉ឺនប្រាំបីពាន់) រៀល

---

[7] សិទ្ធិដែលនឹងត្រូវបានរក្សាការពារ (សិទ្ធិលើបំណុលដែលទាមទារ) ត្រូវកំណត់ជាក់លាក់ដូចជា ខ្លឹមសារ និង ចំនួនទឹកប្រាក់ ជាអាទិ៍ ក្នុងកម្រិតដែលអាចបែងចែកចេញពីសិទ្ធិលើបំណុលផ្សេងទៀត។ ប្រសិនបើជាកិច្ចសន្យាខ្ចីបរិភោគប្រាក់ ត្រូវកំណត់ជាកលាក់ដោយសរសេរដូចជា ភាគី កាលបរិច្ឆេទ នៃកិច្ចសន្យា និងពេលកំណត់សង ជាអាទិ៍។ ម្យ៉ាងទៀត បន្ថែមពីប្រាក់ដើម ក្នុងករណីសិទ្ធិដែលនឹងត្រូវបានរក្សាការពារ គឺជាការប្រាក់ និង ប្រាក់សំណងខូចខាត គឺមានភាពចាំបាច់ត្រូវកំណត់ឱ្យបានច្បាស់អំពីចំនួនទឹកប្រាក់នីមួយៗ ព្រមទាំងចំនួនទឹកប្រាក់ដើមដែលជាកម្មវត្ថុ អត្រាការប្រាក់ និង អំឡុងពេល ជាអាទិ៍ ពីព្រោះទាំងអស់នេះ គឺជាសិទ្ធិដាច់ដោយឡែកផ្សេងៗពីគ្នា។

ប្រាក់សំណងនៃការខូចខាតដោយសារការយឺតយ៉ាវ ចំនួន ៥ ភាគរយ (ប្រាំភាគរយ) ក្នុងមួយឆ្នាំ នៃប្រាក់ដើម ចំនួន ៥០.០០០.០០០ (សែសិបលាន) រៀល គិតចាប់ពីថ្ងៃទី១ ខែតុលា ឆ្នាំ២០២០ រហូតដល់ ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២០

**ឧបសម្ព័ន្ធ**

## បញ្ជីឧបសម្ព័ន្ធអំពីវត្ថុ

"ទីតាំងដី" ផ្លូវលេខ ០០ ភូមិ...... សង្កាត់.......ខណ្ឌ.........រាជធានីភ្នំពេញ

"លេខឡូត៍" ០០

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## ពាក្យសុំឱ្យអនុវត្តរឹបអូសជាបណ្ដោះអាសន្ន

### ម្ចាស់បំណុល

ឈ្មោះ ៖ X

អាសយដ្ឋាន ៖ ផ្ទះលេខ ០០ ផ្លូវលេខ ០០ ភូមិ...... ឃុំ.......ស្រុក......... ខេត្តបាត់ដំបង[1]។

### អ្នកតំណាងដោយអាណត្តិ

ឈ្មោះ៖លោក/លោកស្រី ៖ P

អាសយដ្ឋានការិយាល័យ ៖ .................................

ឈ្មោះការិយាល័យមេធាវី/ក្រុមមេធាវី/ក្រុមហ៊ុនមេធាវី ៖ ..........................................

លេខទូរស័ព្ទ ៖ ..................................................

**ទីកន្លែងបញ្ជូន** ៖ ការិយាល័យមេធាវី/ ក្រុមមេធាវី/ ក្រុមហ៊ុនមេធាវី..................[2]

### កូនបំណុល

ឈ្មោះ ៖ Y

អាសយដ្ឋាន ផ្ទះលេខ ០០ ផ្លូវលេខ ០០ ភូមិ...... ឃុំ.......ស្រុក......... ខេត្តបាត់ដំបង។

---

[1] យោងមាត្រា ៥៦៤ , ចំណុច ក កថាខណ្ឌទី ១ និង ចំណុច ក កថាខណ្ឌទី ២ មាត្រា ៣៩៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

[2] យោងមាត្រា ៥៣៩, មាត្រា ២៤៩ និងមាត្រា ២៥០ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ ការសរសេរអំពីទីកន្លែងបញ្ជូន មិនមែនជាករណីយកិច្ចទេ។ ប្រសិនបើមិនសរសេរទីកន្លែងបញ្ជូន នោះការបញ្ជូន នឹងបញ្ជូនទៅអាសយដ្ឋានរបស់ម្ចាស់បំណុល ជាអាទិ៍។ ហេតុដូច្នេះ ករណីដែលអ្នកតំណាងដោយអាណត្តិរបស់ម្ចាស់បំណុលមានបំណងចង់ឱ្យធ្វើការបញ្ជូនទៅទីកន្លែងក្រៅពីអាសយដ្ឋានរបស់ម្ចាស់បំណុល ជាអាទិ៍ ចាំបាច់ត្រូវសរសេរទីកន្លែងបញ្ជូនជាលាយល័ក្ខអក្សរដូចជានៅក្នុងពាក្យសុំ ជាអាទិ៍។

**សូមគោរពជូន**

**ឯកឧត្តម/លោកជំទាវ ប្រធានសាលាដំបូងរាជធានីភ្នំពេញ[3]**

**លិខិតអនុវត្តៈ ដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន លេខ ០០ ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ**

ម្ចាស់បំណុល ទាមទារឱ្យអនុវត្តរឹបអូសជាបណ្ដោះអាសន្ន តាមរបៀបនៃការចុះបញ្ជីរឹបអូសជាបណ្ដោះអាសន្ន ចំពោះអចលនវត្ថុដែលមានសរសេរនៅក្នុងបញ្ជីឧបសម្ព័ន្ធអំពីវត្ថុដែលជាកម្មសិទ្ធិរបស់កូនបំណុល ដែលជាការអនុវត្តតាមការបង្ខំដោយផ្ទាល់ ផ្អែកតាមដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន[4]លេខ០០ ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ។ [5]

សេចក្ដីដូចមានកំណត់ សូម **ឯកឧត្តម/លោកជំទាវប្រធាន** សម្រេចតាមការស្នើសុំដោយក្ដីអនុគ្រោះ។

សូម **ឯកឧត្តម/លោកជំទាវប្រធាន** ទទួលនូវសេចក្ដីគោរពដ៏ជ្រាលជ្រៅអំពីខ្ញុំ។

ខេត្តបាត់ដំបង, ថ្ងៃទី ៧ ខែធ្នូ ឆ្នាំ ២០២០

**អ្នកតំណាងដោយអាណត្តិ**

P

<u>ឯកសារភ្ជាប់</u>

១-ឯកសារថតចម្លងយថាភូតនៃដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ១ច្បាប់

២-លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ ១ច្បាប់

---

[3] ការអនុវត្តរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ តុលាការដែលចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ត្រូវមានសមត្ថកិច្ចជាតុលាការអនុវត្តរក្សាការពារ (កថាខណ្ឌទី ២ មាត្រា ៥៦៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ សាលាដំបូងរាជធានីភ្នំពេញ បានចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ដូច្នេះ សាលាដំបូងរាជធានីភ្នំពេញ មាន សមត្ថកិច្ចជាតុលាការអនុវត្តរឹបអូសជាបណ្ដោះអាសន្ន។

[4] យោងមាត្រា ៥៦៤ និង ចំណុច ខ កថាខណ្ឌទី ២ មាត្រា ៣៤៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

[5] យោងមាត្រា ៥៦៤, ចំណុច គ និង ចំណុច ឃ កថាខណ្ឌទី ២ មាត្រា ៣៤៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

**ឧបសម្ព័ន្ធ**

## បញ្ជីឧបសម្ព័ន្ធអំពីវត្ថុ

"ទីតាំងដី" ផ្លូវលេខ ០០ ភូមិ...... សង្កាត់.......ខណ្ឌ.........រាជធានីភ្នំពេញ

"លេខ/លេខឡូត៍" ០០

# នីតិវិធីនៃការរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ

## I. ចរិតលក្ខណៈនៃការចាត់ចែងរក្សាការពារ

### ១. លក្ខណៈបន្ទាប់បន្សំ

ការចាត់ចែងរក្សាការពារ គឺជានីតិវិធីបន្ទាប់បន្សំនៃបណ្ដឹងអង្គសេចក្ដី [1] ។ នៅពេលដែលមិនមានការដាក់បណ្ដឹងអង្គសេចក្ដីទេ នឹងត្រូវលុបចោលតាមពាក្យសុំរបស់កូនបំណុល (មាត្រា ៥៥៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ តទៅ ចំពោះមាត្រានៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី នឹងយោងតែលេខមាត្រាទេ។)។

### ២. លក្ខណៈបណ្ដោះអាសន្ន (ភាពកំណត់ជាបណ្ដោះអាសន្ន)

ដីកាសម្រេចរក្សាការពារ គឺជាដីកាសម្រេចមានលក្ខណៈជាបណ្ដោះអាសន្ន ដោយសន្មតថាមានការដាក់បណ្ដឹងអង្គសេចក្ដី និងពុំមានឥទ្ធិពលដល់ការជំនុំជម្រះបណ្ដឹងអង្គសេចក្ដីទេ។ ការអនុវត្តរក្សាការពារ ក៏បំលែងទៅជាការអនុវត្តដោយបង្ខំដែរ ដូច្នេះដីកាសម្រេចរក្សាការពារ គ្រាន់តែជាការចាត់ចែងមានលក្ខណៈបណ្ដោះអាសន្នទម្រាំរហូតដល់អាចសម្រេចគោលបំណងនៃការអនុវត្តដោយបង្ខំ។

### ៣. លក្ខណៈបន្ទាន់បន្ទំ (ភាពជាប្រញាប់)

ការរឹបអូសជាបណ្ដោះអាសន្ន និងការចាត់ចែងជាបណ្ដោះអាសន្ន មិនអាចសម្រេចគោលបំណងបានទេប្រសិនបើមិនអនុវត្តឱ្យបានឆាប់រហ័ស។ សេចក្ដីសម្រេចទាក់ទងនឹងនីតិវិធីដីកាសម្រេចរក្សាការពារ ត្រូវធ្វើឡើងដោយដីកាសម្រេច (កថាខណ្ឌទី ១ មាត្រា ៥៣៥) ហើយសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារ និង ភាពចាំបាច់នៃការរក្សាការពារ គឺគ្រាន់តែធ្វើសេចក្ដីបញ្ជាក់ដំបូង [2] ជាការគ្រប់គ្រាន់ (កថាខណ្ឌទី ៣ មាត្រា ៥៤១)។ នីតិវិធីនៃការអនុវត្តរក្សាការពារ មានកម្រិតអំឡុងពេលអនុវត្ត (កថាខណ្ឌទី ២ មាត្រា ៥៦២) និងជាគោលការណ៍ មិនត្រូវការរូបមន្តអនុវត្តទេ (កថាខណ្ឌទី ១ មាត្រា ៥៦២)។

---

[1] បណ្ដឹងអង្គសេចក្ដី មានន័យថាជាការដាក់បណ្ដឹងរដ្ឋប្បវេណីស្ដីពីសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារ។

[2] សេចក្ដីបញ្ជាក់ដំបូង គឺរបៀបទទួលស្គាល់អង្គហេតុជាស្ថាពរ ទោះបីជាសេចក្ដីបញ្ជាក់ដំបូងនោះ មានកម្រិតនៃជំនឿទុកចិត្ត (កម្រិតនៃការបញ្ជាក់) ទាបជាងការបញ្ជាក់ក៏ដោយ។ ករណីដែលជាការបញ្ជាក់ គឺអាចធ្វើឱ្យតុលាការយល់ឃើញអំពីភាពជាក់ច្បាស់នៃអត្ថិភាព ឬ នត្ថិភាពនៃអង្គហេតុ ប៉ុន្តែករណីដែលសេចក្ដីបញ្ជាក់ដំបូងវិញ ប្រសិនបើអាចធ្វើឱ្យតុលាការយល់ឃើញថាវាមានភាពដែលហាក់ដូចជាការពិតនៃអត្ថិភាព ឬ នត្ថិភាពនៃអង្គហេតុ គឺជាការគ្រប់គ្រាន់ (មាត្រា ១៣១ "សេចក្ដីពន្យល់កំណត់មាត្រា") ។

### ៤. លក្ខណៈសម្ងាត់

ការរឹបអូសជាបណ្ដោះអាសន្ន និងការចាត់ចែងជាបណ្ដោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ គឺអាចធ្វើការជំនុំជម្រះ និងចេញដីកាសម្រេចដោយមិនជូនដំណឹងទៅកូនបំណុលអំពីនីតិវិធីបាន ព្រោះប្រសិនបើ កូនបំណុលដឹងអំពីនីតិវិធីទាំងនេះ នោះកូនបំណុលនឹងប្រព្រឹត្តអំពើការពារខ្លួន (ចំណុចនេះតុលាការត្រូវថ្លឹងថ្លែងឱ្យបានច្បាស់លាស់នូវលក្ខណៈបន្ទាន់បង្ខំនៃនីតិវិធី និង ភាពសុចរិតរបស់ម្ចាស់បំណុល និងកូនបំណុល)។

## II. ដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន

### ១. ល័ក្ខខ័ណ្ឌនៃការរឹបអូសជាបណ្ដោះអាសន្ន

#### (១)សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារ

សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារនៅក្នុងការរឹបអូសជាបណ្ដោះអាសន្ន ត្រូវតែជាសិទ្ធិលើបំណុលដែលគោលបំណងសងជាប្រាក់ "សិទ្ធិលើបំណុលជាប្រាក់" (ចំណុច ក មាត្រា ៥៣១, កថាខណ្ឌទី ១ មាត្រា ៥៤៥)។ ប្រសិនបើមានសិទ្ធិលើបំណុលជាប្រាក់ ទោះបីជាសិទ្ធិលើបំណុលនេះភ្ជាប់នឹងល័ក្ខខ័ណ្ឌ ឬ ពេលកំណត់ក៏ដោយ ក៏អាចក្លាយជាសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារ (កថាខណ្ឌទី ២ មាត្រា ៥៤៥)។

សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារ ត្រូវតែកំណត់ឱ្យបានច្បាស់លាស់នូវខ្លឹមសារ និង ចំនួនទឹកប្រាក់ ជាអាទិ៍ ក្នុងកម្រិតដែលអាចបែងចែកចេញពីសិទ្ធិលើបំណុលផ្សេងទៀត។ ការកំណត់សិទ្ធិលើបំណុលដែលនឹងត្រូវបានរក្សាការពារ ត្រូវសរសេរ សារជាតុតាមច្បាប់នៃសិទ្ធិលើបំណុលនោះ (ប្រាក់កម្ចី ប្រាក់ថ្លៃលក់ទិញ កម្រៃចំពោះលទ្ធផលនៃការងារ ជាអាទិ៍) និង ជាតុផ្សំសំខាន់នៃសិទ្ធិលើបំណុលនោះ (ពេលវេលានៃការកើតឡើងនៃសិទ្ធិលើបំណុល មូលហេតុនៃការកកើត ពេលកំណត់សង ខ្លឹមសារនៃល័ក្ខខ័ណ្ឌ ជាដើម)។

【Case.5】X អះអាង សិទ្ធលើបំណុលនៃប្រាក់កម្ចី ជាសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបាន រក្សាការពារ ដោយផ្អែកតាមកិច្ចសន្យាខ្ចីបរិភោគប្រាក់ដែលបានបង្កើត នៅថ្ងៃទី១ ខែតុលា ឆ្នាំ ២០១៩ ជាមួយ Y ដោយយកថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០ ជាពេលកំណត់សង។ សិទ្ធិលើបំណុលនៃប្រាក់កម្ចីនេះ គឺជាសិទ្ធិលើបំណុលជាប្រាក់ ដូច្នេះសិទ្ធិលើបំណុលនេះ ក្លាយជាសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារនៅក្នុងការរឹបអូសជាបណ្ដោះអាសន្ន។

## ២. ភាពចាំបាច់នៃការរក្សាការពារ

ភាពចាំបាច់នៃការរក្សាការពារនៅក្នុងការរឹបអូសជាបណ្តោះអាសន្ន នឹងទទួលស្គាល់នៅពេលដែលមានការបារម្ភថា ការអនុវត្តដោយបង្ខំនឹងមិនអាចធ្វើបាន ឬ នៅពេលដែលមានការបារម្ភថា នឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តដោយបង្ខំ (កថាខណ្ឌទី ១ មាត្រា ៥៤៥)។

ភាពចាំបាច់នៃការរក្សាការពារ នឹងទទួលស្គាល់នៅក្នុងករណីដែលមានការបារម្ភអំពីការកើតឡើងនូវឧបសគ្គតាមអង្គហេតុនៅក្នុងការអនុវត្តដូចជា នៅក្នុងករណីដែលស្ថានភាពទ្រព្យសម្បត្តិរបស់កូនបំណុលទំនងជាធ្លាក់តម្លៃ ជាបរិមាណ ឬ ជាគុណភាព ឬ ដោយសារការចាយវាយខ្ជះខ្ជាយ ការលក់ក្នុងតម្លៃថោក ការខូចខាត ការបំបាត់ ឬ នៅក្នុងករណីដែលកូនបំណុលបានគេចខ្លួន ឬ បានប្តូរលំនៅឋានជាច្រើនលើកច្រើនសារ ដែលធ្វើឱ្យមានការពិបាកដើម្បីដឹងអំពីទ្រព្យសម្បត្តិរបស់កូនបំណុល ជាអាទិ៍។ ចំពោះភាពលំបាកនៅក្នុងការអនុវត្ត ដោយសារតែការធ្លាក់ចុះទ្រព្យសម្បត្តិរបស់កូនបំណុល នឹងវិនិច្ឆ័យជាសត្យានុម័ត ដោយពិចារណា មុខរបរ ឋានៈ និងស្ថានភាពទ្រព្យសម្បត្តិ (រួមទាំងតម្លៃអចលនវត្ថុដែលជាកម្មវត្ថុ) របស់កូនបំណុល។ ចំពោះភាពចាំបាច់នៃការរក្សាការពារ ចាំបាច់ត្រូវសរសេរអង្គហេតុបង្ហាញស្ថានភាពទាំងនោះឱ្យបានលម្អិត។

【Case.5】 Y មានអាជីវកម្មបើកហាងបោកអ៊ុត ប៉ុន្តែអាជីវកម្មនេះ មិនដំណើការទៅដោយរលូនទេ ហើយបានខ្ចីប្រាក់ពីបុគ្គលផ្សេងក្រៅពី X ទៀត។ លើសពីនេះ គាត់មិនមានទ្រព្យសម្បត្តិណាដែលមានតម្លៃ ក្រៅពីអចលនវត្ថុដែលជាកម្មវត្ថុទេ។ យោងតាមស្ថានភាពទាំងអស់នេះហើយ ត្រូវវិនិច្ឆ័យថាទ្រព្យសម្បត្តិរបស់ Y មានការធ្លាក់ចុះ តើនឹងមានការបារម្ភថា ការអនុវត្តដោយបង្ខំ នឹងមិនអាចធ្វើបាន ឬបារម្ភថាការអនុវត្តដោយបង្ខំ នឹងមានភាពលំបាកយ៉ាងនៅក្នុងការអនុវត្តដែរឬទេ?

## ២. ការដាក់ពាក្យសុំរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ

### (១) សមត្ថកិច្ចតុលាការ

រឿងក្តីនៃដីកាសម្រេចរក្សាការពារ ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់តុលាការដែលមានសមត្ថកិច្ចលើអង្គសេចក្តី ឬ សាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលវត្ថុដែលនឹងត្រូវរឹបអូសជាបណ្តោះអាសន្ន ឬ វត្ថុដែលជាកម្មវត្ថុនៃវិវាទ ស្ថិតនៅ (កថាខណ្ឌទី ១ មាត្រា ៥៤០)។

នៅក្នុងករណីដែលតុលាការបានដឹងរឿងក្តីនៃដីកាសម្រេចរក្សាការពារ មិនស្ថិតនៅក្រោមសមត្ថកិច្ចទេ តុលាការនេះត្រូវផ្ទេរសមត្ថកិច្ចទៅតុលាការដែលមានសមត្ថកិច្ច តាមពាក្យសុំ ឬ ដោយឆន្ទានុសិទ្ធិ (កថាខណ្ឌទី ១ មាត្រា ១៨)។ ដីកាសម្រេចនៃការផ្ទេរនេះ ប្រសិនបើបកស្រាយថា ត្រូវជូនដំណឹងទៅកូនបំណុល នឹងនាំឱ្យមានការ

បែកធ្លាយភាពជាសម្ងាត់។ ការអនុវត្តជាក់ស្តែងនៅប្រទេសជប៉ុន មិនបញ្ជូនដីកា សម្រេចនៃការផ្ទេរទេ គឺគ្រាន់តែផ្តល់ដំណឹងទៅកាន់ម្ចាស់បំណុលឱ្យធ្វើការដេក ដោយប្រាប់ថាសមត្ថកិច្ចមិនត្រឹមត្រូវទេ (ស្ទើរតែ ១០០ ភាគរយ (មួយរយភាគរយ) ម្ចាស់បំណុល អនុវត្តតាម)។

【Case.5】លំនៅឋានរបស់ Y (ចំណុច ក មាត្រា ៨) និងកន្លែងដែលត្រូវអនុវត្តកាតព្វកិច្ចនៃប្រាក់កម្ចី (ចំណុច ក មាត្រា ៩) គឺនៅក្នុងខេត្តបាត់ដំបង ដូច្នេះសាលាដំបូងខេត្តបាត់ដំបងមានសមត្ថកិច្ចនៃរឿងក្តីទាមទារឱ្យសងប្រាក់កម្ចីដែលជាបណ្តឹងអង្គសេចក្តី។ ហេតុនេះ សាលាដំបូងខេត្តបាត់ដំបងមានសមត្ថកិច្ចនៃរឿងក្តីរឹបអូសជាបណ្តោះអាសន្ន។ ម្យ៉ាងទៀត អចលនវត្ថុដែលជាកម្មវត្ថុនៃការរឹបអូសជាបណ្តោះអាន្ន មានទីតាំងស្ថិតនៅក្នុងរាជធានីភ្នំពេញ ដូច្នេះសាលាដំបូងរាជធានីភ្នំពេញ ក៏មានសមត្ថកិច្ចនៃរឿងក្តីរឹបអូសជាបណ្តោះអាសន្នផងដែរ។

### (២) **ពាក្យសុំ**

ពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ត្រូវតែធ្វើជាលាយល័ក្ខណ៍អក្សរ (ចំណុច ក មាត្រា ៥៣៤)។ ពន្ធដាក់ពាក្យសុំ គឺមានចំនួន ៥.០០០ (ប្រាំពាន់) រៀល (កថាខណ្ឌទី ១ មាត្រា ៥៣៧)។ ចំពោះចំណុចដែលត្រូវ សរសេរនៅក្នុងពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន និងឯកសារសេចក្តីបញ្ជាក់ដំបូងដែលត្រូវភ្ជាប់ សូមយោងឯកសារទម្រង់គំរូ និងសេចក្តីពន្យល់នៅក្នុងឯកសារនោះ។

## ៣. **ការវិនិច្ឆ័យ**

### (១) **ដីកាសម្រេច**

ការសម្រេចសេចក្តីចំពោះនីតិវិធីទាក់ទងនឹងដីកាសម្រេចរក្សាការពារ ត្រូវធ្វើឡើងដោយដីកាសម្រេច (កថា ខណ្ឌទី១ មាត្រា៥៣៥)។ ដូច្នេះ វាខុសគ្នានឹងករណីដែលចេញជាសាលក្រម ដោយមិនចាំបាច់ត្រូវឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់ទេ ហើយតុលាការនឹងកំណត់អំពីការធ្វើ ឬ មិនធ្វើការទាញហេតុផលដោយផ្ទាល់ ដោយឆន្ទានុសិទ្ធិ (វាក្យខណ្ឌទី ២ កថាខណ្ឌទី ១ មាត្រា ១១៤)។ តុលាការអាចសួរភាគីទាំងសងខាង ឬ តែម្ខាងបាន (កថាខណ្ឌទី ២ មាត្រា ១១៤)។ ម្យ៉ាងទៀត ករណីដែលរឹបអូសជាបណ្តោះអាសន្ន គឺត្រូវការភាពជាសម្ងាត់ ដូច្នេះ ជាធម្មតា គ្រាន់តែដាក់ចេញឱ្យសួរតែម្ចាស់សិទ្ធិបំណុលទេ។

【 Case.5 】តុលាការ មិនចាំបាច់ឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់ និងក៏មិនចាំបាច់សួរភាគីដែរ។ ក្នុងករណីដែលតុលាការមានអារម្មណ៍ថាចំណុចដែលសរសេរនៅក្នុងពាក្យសុំ ឬ ឯកសារដែលបានដាក់មក មិនទាន់គ្រប់គ្រាន់នៅឡើយ គឺតុលាការអាចទាមទារឱ្យ X បំពេញតម្រូវនៅក្នុងពាក្យសុំ ឬ បន្ថែមឯកសារជាលាយលក្ខណ៍អក្សរ ឬ ដោយផ្ទាល់មាត់បាន (ការសួរម្ចាស់បំណុល)។ម្យ៉ាងទៀត ប្រសិនបើ Y ដឹងអំពីការរឹបអូសជាបណ្ដោះអាសន្ននេះ នឹងមានការបារម្ភនូវវិធីការពារដូចជាអនុប្បទានអចលនវត្ថុដែលជាកម្មវត្ថុទៅឱ្យតតិយជន ជាដើម ដូច្នេះការសួរ Y ជាគោលការណ៍ ដាច់ខាតមិនត្រូវធ្វើនោះទេ។

### (២) សេចក្ដីបញ្ជាក់ដំបូង

ការបញ្ជាក់ដោយគ្រាន់តែធ្វើសេចក្ដីបញ្ជាក់ដំបូងទៅលើលក្ខខ័ណ្ឌនៃការរឹបអូសជាបណ្ដោះអាសន្ន ដែលមាន ① សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែល នឹងត្រូវបានរក្សាការពារ និង ② ភាពចាំបាច់នៃការរក្សាការពារ នោះជាការគ្រប់គ្រាន់ (កថាខណ្ឌទី ៣ មាត្រា ៥៤១)។ ប្រសិនបើចាំបាច់ត្រូវការកម្រិតនៃការបញ្ជាក់ខ្ពស់ វាមិនខុសគ្នាពីបណ្ដឹងអង្គសេចក្ដីទេ ព្រោះវាបាននាំឱ្យផ្ទុយនឹងលក្ខណៈជាបណ្ដោះអាសន្ន និងលក្ខណៈនៃភាពឆាប់រហ័ស។ សេចក្ដីបញ្ជាក់ដំបូង ត្រូវតែធ្វើដោយភស្តុតាងដែលអាចស្រាវជ្រាវបានយ៉ាងឆាប់រហ័ស ដូចជា ឯកសារ និង វត្ថុដែលនឹងត្រូវបានត្រួតពិនិត្យ ប៉ុន្តែមិនអាចប្រគល់កិច្ចការស្រាវជ្រាវ ដីកាសម្រេចបង្គាប់ឱ្យផ្ដល់ឯកសារ ការសាកសួរសាក្សីដែលចាំបាច់ត្រូវកោះហៅ ជាអាទិ៍ នោះទេ(មាត្រា ១៣១)។

ភស្តុតាងដើម្បីក្លាយជាសេចក្ដីបញ្ជាក់ដំបូង មានដូចជា លិខិតកិច្ចសន្យា លិខិតមតកសាសន៍ លិខិតវិក្កយបត្រ លិខិតពិនិត្យវិនិច្ឆ័យ កំណត់ហេតុ លិខិតរបាយការណ៍ដែលធ្វើឡើងដោយម្ចាស់បំណុល ឬ តតិយជន រូបថត ជាអាទិ៍។ នៅពេលបង្កើតលិខិតរបាយការណ៍ ត្រូវតែសរសេរឱ្យបានលម្អិតអំពីសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលនឹង ត្រូវបានរក្សាការពារ និង ភាពចាំបាច់នៃការរក្សាការពារ។

【Case.5】X ត្រូវដាក់លិខិតកិច្ចសន្យាខ្ចីប្រាក់ និងលិខិតវិក្កយបត្រទទួលប្រាក់កម្ចី ជាភស្តុតាងនៃសេចក្ដីបញ្ជាក់ដំបូង ទៅលើសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារ និងត្រូវដាក់លិខិតរបាយការណ៍ដែលធ្វើឡើងដោយ X ជាភស្តុតាងនៃសេចក្ដីបញ្ជាក់ដំបូងទៅលើ ភាពចាំបាច់រក្សាការពារ។ លិខិតរបាយការណ៍ដែលធ្វើឡើង ដោយ X គឺ X ត្រូវធ្វើការស្រាវជ្រាវ ហើយត្រូវសរសេរអំពីស្ថានភាពឱ្យបានលម្អិតនូវស្ថានភាពដូចជា Y មានជាប់ប្រាក់កម្ចី និងមិនមានទ្រព្យសម្បត្តិដែលមានតម្លៃណាផ្សេងទៀតក្រៅពីអចលនវត្ថុដែលជាកម្មវត្ថុទេ ព្រមទាំង គួរតែសរសេរទាំងតម្លៃអចលនវត្ថុដែលជាម្មវត្ថុតាមដែលអាចធ្វើបាន។ ព្រោះតម្លៃអចលនវត្ថុដែលជាកម្មវត្ថុ ជាធាតុផ្សំសំខាន់ក្នុងការវិនិច្ឆ័យអំពីភាពចាំបាច់រក្សាការពារ។

## ៤. ដីកាសម្រេច

### (១) មូលដ្ឋាន

សេចក្តីសម្រេចចំពោះពាក្យសុំដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ត្រូវធ្វើឡើងដោយដីកាសម្រេច។

ក្នុងករណីដែលខ្វះល័ក្ខខ័ណ្ឌបណ្តឹង (សមត្ថភាពភាគី លក្ខណៈជាភាគី ជាអាទិ៍) ដែលត្រូវបានយកមកអនុវត្តដូចនឹងនីតិវិធីដីកាសម្រេចរក្សាការពារ ឬ ករណីដែលមិនអាចទទួលស្គាល់ល័ក្ខខ័ណ្ឌនៃការរឹបអូសជាបណ្តោះអាសន្ន នោះពាក្យសុំនឹងត្រូវលើកចោល។ ចំពោះដីកាសម្រេចលើកចោលពាក្យសុំ អាចប្តឹងជំទាស់បាន (មាត្រា ៥៤៤)។

ក្នុងករណីដែលទទួលស្គាល់ល័ក្ខខ័ណ្ឌនៃការរឹបអូសជាបណ្តោះអាសន្ន ហើយបានបំពេញទាំងល័ក្ខខ័ណ្ឌផ្សេងទៀត នោះត្រូវចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន។ ជាគោលការណ៍ តុលាការ ត្រូវតែចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ដោយកំណត់ជាក់លាក់នូវកម្មវត្ថុ (មាត្រា ៥៤៦)។ ចំណុចដែលត្រូវសរសេរនៅក្នុងដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន សូមយោងឯកសារទម្រង់គំរូ និងសេចក្តពន្យល់នោះ។

តុលាការ ត្រូវតែបញ្ជូនដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នទៅភាគី (មាត្រា ៥៤៣)។ ម្យ៉ាងវិញទៀត ការអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ ត្រូវធ្វើតាមរបៀបចុះបញ្ជីរឹបអូសជាបណ្តោះអាសន្ន (មាត្រា ៥៦៧) ហើយប្រសិនបើដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នត្រូវបានបញ្ជូនទៅភាគីនៅមុនពេលចុះបញ្ជីរឹបអូសជាបណ្តោះអាសន្ន នោះកូនបំណុលនឹងប្រព្រឹត្តិអំពើការពារ ហេតុដូច្នេះគួរតែពិនិត្យជាសិនថាបានចុះបញ្ជីរឹបអូសជាបណ្តោះអាសន្នរួច ទើបបញ្ជូនដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នទៅកូនបំណុល។

### (២) ប្រាតិភោគ

ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន អាចធ្វើដោយឱ្យដាក់ប្រាតិភោគ ឬ មិនដាក់ប្រាតិភោគ តាមឆន្ទានុសិទ្ធិរបស់តុលាការ (មាត្រា ៥៤២)។ ប្រាតិភោគ គឺជាការសងសំណងខូចខាតដែលកើតឡើងចំពោះកូនបំណុលនៅក្នុងករណីដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នមានលក្ខណៈមិនត្រឹមត្រូវ។ ជំនួសដោយឱ្យដាក់ប្រាតិភោគទុកជាមុន ក៏អាចបង្គាប់ឱ្យផ្តល់នូវប្រាតិភោគសម្រាប់ជាល័ក្ខខ័ណ្ឌនៃការអនុវត្ត។ វិធីផ្តល់នូវប្រាតិភោគ ត្រូវធ្វើតាមវិធីផ្ញើរប្រាក់ ឬ ឧបករណ៍អាចជួញដូរបាន ដែលតុលាការទទួលស្គាល់ថាសមរម្យ ទៅតុលាការដែលបង្គាប់ឱ្យដាក់ប្រាតិភោគនោះ (មាត្រា ៥៣៦)។

ចំនួនទឹកប្រាក់ប្រាតិភោគ ត្រូវសម្រេចដោយសេរីភាពនៃឆន្ទានុសិទ្ធិរបស់តុលាការ។ ប្រាតិភោគ គឺជាការសងសំណងខូចខាតដែលកើតឡើងចំពោះកូនបំណុល ប៉ុន្តែ តុលាការនឹងមានការពិបាកក្នុងការគណនាទុកជាមុនឱ្យបានត្រឹមត្រូវនូវការខូចខាតដែលកើតឡើងចំពោះកូនបំណុល។ តុលាការមានតែខំប្រឹងពិចារណានូវស្ថានភាពលម្អិត (ខ្លឹមសារនៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារ និង តម្លៃ ប្រភេទនៃវត្ថុដែលជាកម្មវត្ថុ

នៃការរក្សាការពារ និងតម្លៃ មុខរបររបស់កូនបំណុល, ទ្រព្យសម្បត្តិ ជាអាទិ៍) និង កម្រិតនៃសេចក្តីបញ្ជាក់ដំបូង[3] ទើបចេញដីកាសម្រេចចំនួនទឹកប្រាក់ដែលសមរម្យ។

ក្នុងករណីដែលតុលាការបង្គាប់ឱ្យផ្តល់នូវប្រាតិភោគ នោះតុលាការត្រូវកំណត់អំពីអំឡុងពេលផ្តល់នូវប្រាតិភោគនោះ ហើយក្នុងករណីដែលមិនមានការដាក់ប្រាតិភោគនៅក្នុងអំឡុងពេលដែលបានកំណត់ទេ នោះពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ត្រូវលើកចោល។ យ៉ាងណាមិញ ម្ចាស់បំណុល អាចស្នើសុំពន្យារអំឡុងពេល ដោយដាក់ជាលាយល័ក្ខណ៍អក្សរដែលបានសរសេរនូវស្ថានភាពដែលមិនអាចដាក់ប្រាតិភោគនៅក្នុងអំឡុងពេលត្រូវបានផ្តល់នោះ។

【 Case.5 】តុលាការ ស្នើរសុំឱ្យផ្តល់នូវប្រាតិភោគដែលសមរម្យក្នុងចំនួន ១២.០០០.០០០ (ដប់ពីរលាន) រៀល។ ចំនួនទឹកប្រាក់នេះ គឺជាចំនួនទឹកប្រាក់ដែលសមរម្យក្នុងចំនួនប្រហែល ២០ ភាគរយ (ម្ភៃភាគរយ) នៃតម្លៃអចលនវត្ថុដែលជាកម្មវត្ថុ (ប្រហែល ១៥.០០០ (មួយម៉ឺនប្រាំពាន់) ដុល្លារអាមេរិក)។

### (៣) ប្រាក់រំដោះពីការរឹបអូសជាបណ្តោះអាសន្ន

នៅក្នុងដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ទោះបីគ្មានពាក្យសុំរបស់ភាគីក៏ដោយ ក៏តុលាការត្រូវកំណត់ចំនួនទឹកប្រាក់ (ប្រាក់រំដោះ) ដែលកូនបំណុលត្រូវធ្វើ ដើម្បីទទួលបាននូវការលុបចោលការអនុវត្តការរឹបអូសជាបណ្តោះអាសន្ន (កថាខណ្ឌទី ១ មាត្រា ៥៤៧)។ ប្រាក់រំដោះ គឺជាប្រព័ន្ធដែលបានបង្កើតឡើងដើម្បីការពារកូនបំណុល និងរារាំងការអនុវត្តដែលមិនចាំបាច់។ កូនបំណុល អាចទទួលបាននូវការលុបចោលការអនុវត្តការរឹបអូសជាបណ្តោះអាសន្ន ដោយការធ្វើប្រាក់រំដោះ ហើយម្ចាស់បំណុល អាចទទួលបានការពេញចិត្តនឹង សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារ ពីប្រាក់រំដោះដែលបានធ្វើនោះ។ ការធ្វើប្រាក់រំដោះ ត្រូវធ្វើឡើងនៅតុលាការដែលបានចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ឬ តុលាការអនុវត្តរក្សាការពារ (កថាខណ្ឌទី ២ មាត្រា ៥៤៧)។

ចំនួនទឹកប្រាក់រំដោះពីការរឹបអូសជាបណ្តោះអាសន្ន ជាគោលការណ៍ ត្រូវកំណត់យកស្តង់ដារនៃតម្លៃអចលនវត្ថុដែលជាកម្មវត្ថុ ហើយក្នុងករណីដែលចំនួនទឹកប្រាក់នៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារ ទាបជាងតម្លៃវត្ថុដែលជាកម្មវត្ថុ ត្រូវកំណត់យកស្តង់ដារនៃចំនួនទឹកប្រាក់សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែល

[3] ប៉ុន្តែ ក្នុងករណីដែលមិនធ្វើសេចក្តីបញ្ជាក់ដំបូងទៅលើ សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារ និង ភាពចាំបាច់នៃការរក្សាការពារ គឺមិនអាចចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ដោយកំណត់ប្រាតិភោគក្នុងចំនួនទឹកប្រាក់ច្រើននោះទេ។

នឹងត្រូវបានរក្សាការពារ។ ពោលគឺ ត្រូវកំណត់យកស្តង់ដារថាមួយណាទាបជាងរវាងតម្លៃវត្ថុដែលជាកម្មវត្ថុ និងចំនួនទឹកប្រាក់សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារ។

【Case.5】ចំនួនទឹកប្រាក់នៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារ មានចំនួន ៤២.៣២៨.០០០ (សែសិបពីរលានបីសែនពីរម៉ឺនប្រាំបីពាន់) រៀល ដែលជាចំនួនទាបជាងតម្លៃអចលនវត្ថុដែលជាកម្មវត្ថុ មានចំនួនប្រហែល ១៥.០០០ (មួយម៉ឺនប្រាំពាន់) ដុល្លារអាមេរិក ហេតុនេះ តុលាការ បានកំណត់ចំនួនទឹកប្រាក់រំដោះដែលយកស្តង់ដារនៃតម្លៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារ នៅក្នុងដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន។

## III. ការអនុវត្តការរឹបអូសជាបណ្តោះអាសន្ន

### ១. លក្ខខណ្ឌនៃការអនុវត្តរឹបអូសជាបណ្តោះអាសន្ន

#### (១) ភាពមិនចាំបាច់នៃរូបមន្តអនុវត្ត

ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ត្រូវអនុវត្តដោយផ្អែកលើឯកសារចម្លងយថាភូតនៃដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ដូច្នេះជាគោលការណ៍ រូបមន្តអនុវត្ត មិនត្រូវការនោះទេ (វាក្យខណ្ឌទី ១ កថាខណ្ឌទី ១ មាត្រា ៥៦២)។ ប៉ុន្តែ ការអនុវត្តរឹបអូសជាបណ្តោះអាសន្ន សម្រាប់ជនក្រៅពីម្ចាស់បំណុល ដែលត្រូវបានកំណត់នៅក្នុងដីកាសម្រេច ឬ ចំពោះជនក្រៅពីកូនបំណុល ដែលត្រូវបានកណត់នៅក្នុងដីកាសម្រេច ត្រូវធ្វើឡើងដោយចាំបាច់ត្រូវភ្ជាប់នឹងរូបមន្តអនុវត្ត (រូបមន្តអនុវត្តពិសេស) (វាក្យខណ្ឌទី ២ កថាខណ្ឌទី ១ មាត្រា ៥៦២) ដើម្បីកំណត់ភាគីអនុវត្ត (យោងវាក្យខណ្ឌទី ១ កថាខណ្ឌទី ១ មាត្រា ៣៥១)។

#### (២) អំឡុងពេលអនុវត្ត

ការអនុវត្តរឹបអូសជាបណ្តោះអាសន្ន មិនត្រូវធ្វើឡើយ បើអំឡុងពេល ២ សប្តាហ៍ បានកន្លងហួស ចាប់ពីថ្ងៃដែលដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ត្រូវបានបញ្ជូនទៅម្ចាស់បំណុល (កថាខណ្ឌទី ២ មាត្រា ៥៦២)។ ការអនុវត្តរឹបអូសជាបណ្តោះអាសន្នអាចធ្វើបាន ទោះបីជានៅមុនពេលពេលបញ្ជូនដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នទៅកូនបំណុលក៏ដោយ (កថាខណ្ឌទី ៣ មាត្រា ៥៦២)។

### ២. ការអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ

#### (១) សមត្ថកិច្ច

ការអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ តុលាការដែលបានចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ត្រូវមានសមត្ថកិច្ចជាតុលាការអនុវត្តរក្សាការពារ (កថាខណ្ឌទី ២ មាត្រា ៥៦៧)។

(២) **ការដាក់ពាក្យសុំ**

កាដាក់ពាក្យសុំឱ្យអនុវត្តរឹបអូសជាបណ្ដោះអាសន្ន ត្រូវតែធ្វើជាលាយល័ក្ខណ៍អក្សរ (ចំណុច ច មាត្រា ៥៣៤)។ ចំពោះចំណុចដែលត្រូវសរសេរនៅក្នុងពាក្យសុំ សូមយោងឯកសារទម្រង់គំរូ និងសេចក្ដីពន្យល់នោះ។

(៣) **វិធីអនុវត្ត**

ការអនុវត្តរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ ត្រូវធ្វើតាមរបៀបចុះបញ្ជីរឹបអូសជាបណ្ដោះអាសន្ន (កថាខណ្ឌទី ១ មាត្រា ៥៦៧)។ ការចុះបញ្ជីរឹបអូសជាបណ្ដោះអាសន្ន ក្រឡាបញ្ជីត្រូវផ្ទុកផ្ដាក់ (កថាខណ្ឌទី ៣ មាត្រា ៥៦៧) ហើយនីតិវិធីនោះ ដូចគ្នានឹងមូលដ្ឋាននៃនីតិវិធីរឹបអូសអនុវត្តអចលនវត្ថុ (កថាខណ្ឌទី ៤ មាត្រា ៥៦៧, កថាខណ្ឌទី ៣ មាត្រា ៤២១, មាត្រា ៤២៥, មាត្រា ៤២៧, មាត្រា ៤២៨)។

【Case.5】បន្ទាប់ពីទទួលបានការបញ្ជូនដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន X ដាក់ពាក្យសុំអនុវត្តរឹបអូសជាបណ្ដោះអាសន្ន ទៅសាលាដំបូងរាជធានីភ្នំពេញ។ ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ ត្រូវផ្ទុកផ្ដាក់ការចុះបញ្ជីរឹបអូសជាបណ្ដោះអាសន្ន។

## IV. **អានុភាពនៃការរឹបអូសជាបណ្ដោះអាសន្ន**

ប្រសិនបើចុះបញ្ជីរឹបអូសជាបណ្ដោះអាសន្ន កូនបំណុល នឹងត្រូវបានកម្រិតនូវ សកម្មភាពអនុប្បទានដូចជា លក់ទិញ ប្រទានកម្ម ជាអាទិ៍ ឬ សកម្មភាពបង្កើតសិទ្ធិប្រាតិភោគ ដូចជា ការបញ្ចាំ ហ៊ីប៉ូតែក ជាអាទិ៍ និងការចាត់ចែងផ្សេងទៀតទាំងអស់។ យ៉ាងណាមិញ អានុភាពនៃការកម្រិតនេះ ក្នុងករណីដែលម្ចាស់បំណុលបានទទួលលិខិតអនុវត្ត ហើយបានដាក់ពាក្យសុំអនុវត្តដោយបង្ខំដោយយកកូនបំណុលជាភាគីម្ខាងទៀត នឹងនាំឱ្យត្រូវបដិសេធអានុភាពនៃការចាត់ចែងដែលបានផ្ទុយនឹងការកម្រិតនៅក្នុងទំនាក់ទំនងជាមួយនឹងនីតិវិធីនៃ ការអនុវត្តដោយបង្ខំ។

មានន័យថា តាមផ្លូវច្បាប់ ក្រោយពីបានចុះបញ្ជីរឹបអូសជាបណ្ដោះអាសន្ន កូនបំណុល អាចចាត់ចែងដូចជាអនុប្បទាន ឬ បង្កើតហ៊ីប៉ូតែកបាន ប៉ុន្តែ ប្រសិនបើម្ចាស់បំណុលទទួលបាននូវលិខិតអនុវត្ត នោះម្ចាស់បំណុល មិនចាំបាច់ខ្វាយខ្វល់នឹងការចាត់ចែងទាំងនោះទេ និងអាចដាក់ពាក្យសុំអនុវត្តដោយបង្ខំ ដោយយកកូនបំណុល ជាភាគីម្ខាងទៀតបាន។

【 Case.5 】ទោះបីជា អចលនវត្ថុដែលជាកម្មវត្ថុ ត្រូវបានចុះបញ្ជីរឹបអូសជាបណ្ដោះអាសន្ន ហើយ Y អនុប្បទាន អចលនវត្ថុដែលជាកម្មវត្ថុទៅឱ្យ Z និងបានចុះបញ្ជីក៏ដោយ ប្រសិន X ទទួល បាន លិខិតអនុវត្តចំពោះ Y នោះ X អាចដាក់ពាក្យសុំអនុវត្តដោយបង្ខំចំពោះអចលនវត្ថុដែលជាកម្មវត្ថុ ដោយយក Y ជាភាគីម្ខាងទៀតបាន។

## V. ការបំលែងជាការអនុវត្តដោយបង្ខំ

ក្រោយពីបានចុះបញ្ជីរឹបអូសជាបណ្ដោះអាសន្ន ក្នុងករណីដែលម្ចាស់បំណុលទទួលបាននូវលិខិតអនុវត្ត ហើយដាក់ពាក្យសុំអនុវត្តដោយបង្ខំ ដោយយកកូនបំណុលជាភាគីម្ខាងទៀត នោះការរឹបអូសជាបណ្ដោះអាសន្ន ត្រូវបំលែងជាការអនុវត្តដោយបង្ខំ។ ដើម្បីបំលែងការរឹបអូសជាបណ្ដោះអាសន្នទៅជាការអនុវត្តដោយបង្ខំ ចាំបាច់ត្រូវទទួលបានដីកាសម្រេចចាប់ផ្ដើមលក់ដោយបង្ខំ ហើយធ្វើការចុះបញ្ជីរឹបអូសសារជាថ្មី។ ដើម្បីបំលែងការរឹបអូសជាបណ្ដោះអាសន្នទៅជាការអនុវត្តដោយបង្ខំ ចាំបាច់ត្រូវការ ①អត្ថិភាពនៃលិខិតអនុវត្ត ②ភាគីនៃការអនុវត្តរក្សាការពារ និងការអនុវត្តដោយបង្ខំ ជាភាគីដូចគ្នា ③ការណ៍ដែលអាចទទួលស្គាល់ថា សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពាររឹបអូសជាបណ្ដោះអាសន្ន ដូចគ្នាជាមួយនឹងសិទ្ធិលើបំណុលដែលទាមទារនៅក្នុងការអនុវត្តដោយបង្ខំ[4]។

[4] ក្នុងករណីនេះ ត្រូវផ្ដល់ដំណឹងទៅតុលាការអនុវត្តថា ជាបំលែងទៅការអនុវត្តដោយបង្ខំ ហើយដើម្បីបង្ហាញថាបានបំពេញល័ក្ខខ័ណ្ឌ ①~③ គួរតែសរសេរនៅក្នុងពាក្យសុំលក់ដោយបង្ខំថា ជាការបំលែងជាការអនុវត្តដោយបង្ខំពីការរឹបអូសជាបណ្ដោះអាសន្ន ព្រមទាំងភ្ជាប់ជាមួយនឹងឯកសារចម្លងយថាភូតនៃដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន។

# ឯកសារទម្រង់គំរូពាក់ព័ន្ធនឹងការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ

## I. ពាក្យសុំដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ

### ១. ចំណុចដែលត្រូវសរសេរនៅក្នុងពាក្យសុំ

ការដាក់ពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ ត្រូវធ្វើឡើងជាលាយល័ក្ខណ៍អក្សរ (ចំណុច ក មាត្រា ៥៣៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ តទៅ តទៅ ចំពោះមាត្រានៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី នឹងយោងតែលេខមាត្រាទេ។)។ នៅក្នុងពាក្យសុំ ត្រូវតែសរសេរចំណុចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ មាត្រា ៥៤១។

**(១) ឈ្មោះ ឬ នាមករណ៍ និង អាសយដ្ឋានរបស់ភាគី ហើយនិង ឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់ (ចំណុច ក កថាខណ្ឌទី ១ មាត្រា ៥៤១)**

នៅក្នុងពាក្យសុំ ក៏ដូចគ្នានឹងពាក្យបណ្តឹងដែរ (ចំណុច ក កថាខណ្ឌទី ២ មាត្រា ៧៥) ដែលត្រូវតែសរសេរអំពីឈ្មោះ ឬ នាមករណ៍ និង អាសយដ្ឋាន របស់ភាគី ហើយនិង ឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់។ ក្នុងករណីដែលមិនអាចកំណត់ភាគីដោយគ្រាន់តែមានឈ្មោះ ឬ នាមករណ៍ និង អាសយដ្ឋាន គួរតែកំណត់ភាគីតាម ទំហំដែលចាំបាច់ ដូចជាសរសេរ ថ្ងៃ ខែ ឆ្នាំកំណើត ជាអាទិ៍។

ការសរសេរអំពីអ្នកតំណាងដោយអាណត្តិ មិនមែនជាចំណុចដែលត្រូវសរសេរចាំបាច់នោះទេ ប៉ុន្តែគួរតែសរសេរឈ្មោះ ឬ នាមករណ៍ និង អាសយដ្ឋានរបស់អ្នកតំណាងដោយអាណត្តិ។ ព្រោះវានឹងផ្តល់ភាពច្បាស់លាស់ដែលថា តើនរណា ជាអ្នកដំណើរការនីតិវិធី និងផ្តល់ភាពងាយស្រួលក្នុងការបញ្ជូនឯកសារ។

ម្ចាស់បំណុល ក៏អាចសរសេរអំពីទីកន្លែងបញ្ជូន ជាអាទិ៍ ផងដែរ (មាត្រា ៥៣៩, មាត្រា ២៥០)។

**(២) ខ្លឹមសារនៃដីកាសម្រេចរក្សាការពារដែលអ្នកដាក់ពាក្យសុំទាមទារ (ចំណុច ខ កថាខណ្ឌទី ១ មាត្រា ៥៤១)**

នៅក្នុងការចាត់ចែងរក្សាការពារ មាន ៣ ប្រភេទ (មាត្រា ៥៣១) ដូច្នេះមានភាពចាំបាច់ត្រូវកំណត់ឱ្យបានច្បាស់លាស់នូវខ្លឹមសារនៃដីកាសម្រេចរក្សាការបារដែលម្ចាស់បំណុលទាមទារ។

ក្នុងករណីដែលសុំទាមទារដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ជាការសុំទាមទារដីកាសម្រេចដែលត្រូវរឹបអូសជាបណ្តោះអាសន្ននូវទ្រព្យសម្បត្តិរបស់កូនបំណុល។

ម្យ៉ាងទៀត ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ជាគោលការណ៍ ត្រូវចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ដោយកំណត់ជាក់លាក់នូវកម្មវត្ថុ (មាត្រា ៥៤៦) ដូច្នេះនៅក្នុងការសរសេរនូវខ្លឹមសារនៃដីកាសម្រេចរក្សាការពារដែលអ្នកដាក់ពាក្យសុំទាមទារ ជាគោលការណ៍ ក៏ត្រូវកំណត់ជាក់លាក់នូវកម្មវត្ថុផងដែរ។ វិធីដើម្បីកំណត់អចលនវត្ថុ គឺធ្វើការភ្ជាប់បញ្ជីឧបសម្ព័ន្ធអំពីវត្ថុនៅក្នុងពាក្យសុំ និងយោងពីបញ្ជីឧបសម្ព័ន្ធនោះ។

ដោយឡែក នៅក្នុងដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ត្រូវកំណត់អំពីប្រាក់រំដោះពីការរឹបអូសជាបណ្តោះអាសន្ន (កថាខណ្ឌទី ១ មាត្រា ៥៤៧) និង ករណីយកិច្ចទទួលបន្ទុកប្រាក់ប្រដាប់ក្តី (មាត្រា ៥៣៩, មាត្រា ២១៦, កថាខណ្ឌទី៣ មាត្រា១៨២) ប៉ុន្តែចំណុចទាំងអស់នេះ ទោះបីជា មាន ឬ មិនមាន នៅក្នុងពាក្យសុំរបស់ភាគី ក៏ត្រូវតែធ្វើការកំណត់ ដូច្នេះ អ្នកដាក់ពាក្យសុំ មិនចាំបាច់សរសេរនៅក្នុងខ្លឹមសារនៃដីកាសម្រេចរក្សាការពារដែលអ្នកដាក់ពាក្យសុំទាមទារទេ។

**(៣) សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារ (ចំណុច គ កថាខណ្ឌទី ១ មាត្រា ៥៤១)**

ចំពោះ សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារ ត្រូវតែសរសេរឱ្យបានលម្អិតទាំងអង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវសិទ្ធិ ព្រមទាំងអង្គហេតុដែលជាមូលហេតុនៃសិទ្ធិផងដែរ។ នេះគឺជា អង្គហេតុដែលជាមូលហេតុនៃការទាមទារនៅក្នុងពាក្យបណ្តឹង (កថាខណ្ឌទី ២ មាត្រា ៧៥)។ ម្យ៉ាងទៀត ដើម្បីជំរុញឱ្យចេញដីកាសម្រេចមានភាពឆាប់រហ័ស និងចំនួនទឹកប្រាក់ប្រាតិភោគមានចំនួនទាប គួរតែសរសេរទាំងមតិផ្ទុយតបទៅនឹងការតវ៉ាដែលបានរំពឹងទុក។ វិធីដើម្បីកំណត់ប្រភេទខ្លឹមសារ និងចំនួនទឹកប្រាក់សិទ្ធិលើបំណុលដែលម្ចាស់បំណុលមាន គឺត្រូវភ្ជាប់បញ្ជីឧបសម្ព័ន្ធអំពីសិទ្ធិលើបំណុលដែលទាមទារនៅក្នុងពាក្យសុំ និងយោងពីបញ្ជីឧបសម្ព័ន្ធនោះ។

**(៤) ភាពចាំបាច់នៃការរក្សាការពារ (ចំណុច គ មាត្រា ៥៤១)**

ចំពោះភាពចាំបាច់នៃការរក្សាការពារ ត្រូវតែសរសេរអង្គហេតុឱ្យបានលម្អិត ដើម្បីក្លាយជាមូលដ្ឋាននៃភាពចាំបាច់នោះ។

**(៥) ភស្តុតាងតាមហេតុនីមួយៗ (កថាខណ្ឌទី ២ មាត្រា ៥៤១)**

ចំពោះ សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារ (ចំណុច គ កថាខណ្ឌទី ១ មាត្រា ៥៤១) និង ភាពចាំបាច់នៃការរក្សាការពារ (ចំណុច ឃ កថាខណ្ឌទី ១ មាត្រា ៥៤១) ត្រូវតែព្យាយាមសរសេរឱ្យបានលម្អិត និង សរសេរភស្តុតាងតាមហេតុនីមួយៗដែលត្រូវបញ្ជាក់។

## ២. ឯកសារសេចក្តីបញ្ជាក់ដំបូង ( កថាខណ្ឌទី ៣ មាត្រា ៥៤១ )

នៅក្នុងពាក្យសុំ ត្រូវភ្ជាប់ឯកសារសេចក្តីបញ្ជាក់ដំបូង។ ឯកសារសេចក្តីបញ្ជាក់ដំបូងនៅក្នុងឯកសារទម្រង់គំរូ មានដូចខាងក្រោមនេះ ៖

### ( ១ ) លិខិតកិច្ចសន្យាខ្ចីប្រាក់

នៅក្នុងពាក្យសុំ ត្រូវសរសេរឱ្យបានលម្អិតនូវអង្គហេតុដែលជាមូលហេតុនៃសិទ្ធិ ទៅលើសិទ្ធិដែលត្រូវបានរក្សាការពារ។ នៅក្នុងចំណោមអង្គហេតុទាំងនេះ លិខិតកិច្ចសន្យាខ្ចីប្រាក់ គឺជាភស្តុតាងដែលធ្វើសេចក្តីបញ្ជាក់ដំបូងនូវអង្គហេតុបង្កើតកិច្ចសន្យាខ្ចីបរិភោគប្រាក់។

### ( ២ ) វិក្កយបត្រទទួលប្រាក់កម្ចី

ចំពោះសិទ្ធិដែលនឹងត្រូវបានរក្សាការពារ គឺជាភស្តុតាងដែលធ្វើសេចក្តីបញ្ជាក់ដំបូងនូវអង្គហេតុទទួលប្រាក់កម្ចីជាសាច់ប្រាក់ នៅក្នុងចំណោមអង្គហេតុដែលជាមូលហេតុនៃសិទ្ធិ។

### ( ៣ ) លិខិតរបាយការណ៍

ម្ចាស់បំណុល ត្រូវស្រាវជ្រាវដូចជា មុខរបរ ឋានៈ និង ស្ថានភាពទ្រព្យសម្បត្តិ (រួមទាំងតម្លៃអចលនវត្ថុដែលជាកម្មវត្ថុ) ជាអាទិ៍ ហើយជាលទ្ធផលពីកាស្រាវជ្រាវនេះ ម្ចាស់បំណុលត្រូវសរសេរស្ថានភាពឱ្យបានលម្អិតអំពីភាពចាំបាច់នៃការរក្សាការពារនៅក្នុងពាក្យសុំ។ ក្នុងករណីដែលមិនមានឯកសារដែលបញ្ជាក់លទ្ធផលពីការស្រាវជ្រាវរបស់ម្ចាស់បំណុលទេ នោះម្ចាស់បំណុល អាចធ្វើជាលិខិតរបាយការណ៍ដោយសរសេរអំពីលទ្ធផលនៃការស្រាវជ្រាវ ហើយដាក់ជាភស្តុតាងដែលធ្វើសេចក្តីបញ្ជាក់ដំបូងអំពីភាពចាំបាច់នៃការរក្សាការពារ។

នៅក្នុងរឿងក្តីនេះ ម្ចាស់បំណុល បានសួរទៅកាន់មិត្តជិតស្និទ្ធ ជាអាទិ៍ ហើយបានស្រាវជ្រាវអាជីវកម្មរបស់កូនបំណុល និងស្ថានភាពអាជីវកម្មនោះ មាន ឬ មិនមានជាប់កម្ចី ព្រមទាំងពិនិត្យមើលទីតាំងដីនៃអាសយដ្ឋាន និងហាងបោកអ៊ុតរបស់កូនបំណុល នៅក្នុងសៀវភៅចុះបញ្ជីសៀវភៅចុះបញ្ជី និងបានដឹងថាទីតាំងដីទាំងនេះ មិនស្ថិតនៅក្រោម កម្មសិទ្ធិរបស់កូនបំណុលទេ។ ម្ចាស់បំណុល នៅពេលទទួលបានឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នៃសៀវភៅចុះបញ្ជីសៀវភៅចុះបញ្ជី និងបានដឹងថាអចលនវត្ថុដែលជាកម្មវត្ថុ ស្ថិតនៅក្រោមកម្មសិទ្ធិរបស់កូនបំណុល ទើបក៏បានស្រាវជ្រាវ អំពីតម្លៃអចលនវត្ថុដែលជាកម្មវត្ថុនោះ។ ម្ចាស់បំណុល បានដាក់ជាភស្តុតាងដោយសរសេរនៅក្នុងលិខិតរបាយការណ៍អំពីលទ្ធផលពីកាស្រាវជ្រាវនោះ។

### (៤) ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នៃសៀវភៅចុះបញ្ជីសៀវភៅចុះបញ្ជី

ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ជាគោលការណ៍ ត្រូវចេញដីកាសម្រេចដោយកំណត់ជាក់លាក់នូវកម្មវត្ថុ (មាត្រា ៥៤៦) ហើយនៅក្នុងពាក្យសុំរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុដែលត្រូវបានចុះបញ្ជី ត្រូវដាក់ជាឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នៃសៀវភៅចុះបញ្ជីសៀវភៅចុះបញ្ជី។ ម្យ៉ាងទៀត វត្ថុដែលជាកម្មវត្ថុនៃការរឹបអូសជាបណ្តោះអាសន្ន ត្រូវតែស្ថិតនៅក្រោមកម្មសិទ្ធិរបស់កូនបំណុល (ចំណុច ក មាត្រា ៥៣១) ហើយតាមរយៈ ការដាក់ជាឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នៃសៀវភៅចុះបញ្ជីសៀវភៅចុះបញ្ជី គឺអាចបង្ហាញថាអចលនវត្ថុដែលជាកម្មវត្ថុ ស្ថិតនៅក្រោមកម្មសិទ្ធិរបស់កូនបំណុល។

### ៣. លិខិតតំណាង

លិខិតនេះ គឺជាឯកសារដែលបញ្ជាក់អំពីសិទ្ធិអំណាចរបស់អ្នកតំណាងដោយអាណត្តិ (កថាខណ្ឌទី ២ មាត្រា ៥៣)។

## II. ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន

ដីកាសម្រេចរក្សាការពារ ត្រូវបញ្ជូនទៅភាគី (មាត្រា ៥៤៣) ហើយការអនុវត្តរក្សាការពារ ត្រូវធ្វើឡើងដោយផ្អែកលើឯកសារចម្លងយថាភូតនៃដីកាសម្រេចរក្សាការពារ (កថាខណ្ឌទី ១ មាត្រា ៥៦២)។ ហេតុដូច្នេះ ដីកាសម្រេចរក្សាការពារ ត្រូវធ្វើជាលាយល័ក្ខណ៍អក្សរ។

ចំពោះចំណុចដែលត្រូវសរសេរនៅក្នុងលិខិតដីកាសម្រេចនៃដីកាសម្រេចរក្សាការពារ មិនមានបញ្ញត្តិច្បាស់លាស់នោះទេ ហេតុដូច្នេះ នៅពេលបង្កើតលិខិតដីកាសម្រេច ត្រូវយោងចំណុចដែលត្រូវសរសេរនៅក្នុងលិខិតសាលក្រម (មាត្រា ១៨៩) ហើយព្យាយាមពិចារណាឱ្យបានគ្រប់គ្រាន់នូវគោលគំនិតនៃការចាត់ចែងរក្សាការពារ។

### (១) តុលាការ និង ភាគី (ក្នុងករណីដែលមានអ្នកតំណាងដែលច្បាប់បានកំណត់ មានភាគី និង អ្នកតំណាងដោយអាណត្តិ)

ចំណុចទាំងនេះ ត្រូវសរសេរនៅក្នុងលិខិតដីកាសម្រេចដូចគ្នានឹងលិខិតសាលក្រម។

### (២) ខ្លឹមសារនៃដីកាសម្រេចរក្សាការពារដែលអ្នកដាក់ពាក្យសុំទាមទារ

នៅក្នុងលិខិតសាលក្រម ត្រូវសរសេរអំពីអង្គហេតុ និង ចំណុចវិវាទ ហើយនៅក្នុងនោះ ត្រូវសរសេរអំពីខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ។ ផ្ទុយមកវិញ នៅក្នុងនីតិវិធីនៃដីកាសម្រេចរក្សាការពារ

ភាគច្រើន ត្រូវបានចេញជាដីកាសម្រេច ដោយមិនឆ្លងកាត់ការទាញហេតុផលម្នាល់មាត់[1] និងការសួរកូនបំណុលទេ។ ករណីនេះ នៅក្នុងនីតិវិធីនៃដីកាសម្រេចរក្សាការពារ នឹងនាំឱ្យមានភាពមិនច្បាស់លាស់នូវការអះអាងរបស់កូនបំណុល និងចំណុចវិវាទ ដូច្នេះ នៅក្នុងលិខិតដីកាសម្រេច មិនចាំបាច់សរសេរនូវអង្គហេតុ និង ចំណុចវិវាទទេ[2]។ យ៉ាងណាមិញ ចំពោះខ្លឹមសារនៃដីកាសម្រេចរក្សាការពារដែលអ្នកដាក់ពាក្យសុំទាមទារ នឹងមានភាពច្បាស់លាស់នៅក្នុងពាក្យសុំ ដូច្នេះ នៅក្នុងលិខិតដីកាសម្រេច ត្រូវសរសេរអំពីចំណុចនេះ។

**(៣) សំអាងហេតុ**

សំអាងហេតុ គឺជាសំអាងហេតុដែលច្បាស់លាស់ ដោយជះឥទ្ធិពលទៅដល់ការវិនិច្ឆ័យដែលបង្ហាញនៅក្នុងសេចក្ដីសម្រេចបញ្ចប់នៃលិខិតដីកាសម្រេច ដូច្នេះសំអាងហេតុ ក៏ត្រូវតែសរសេរនៅក្នុងលិខិតដីកាសម្រេចផងដែរ។ ម្យ៉ាងទៀត ប្រសិនពិនិត្យទៅលើគោលគំនិតនៃលក្ខណៈបន្ទាន់បង្ខំ (ភាពជាប្រញាប់) ដែលជាលក្ខណៈពិសេសមួយនៃនីតិវិធីចាត់ចែងរក្សាការពារ ដីកាសម្រេចរក្សាការពារត្រូវធ្វើឱ្យបានលឿន ហើយជាពិសេសនៅក្នុងដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ជាទូទៅប្រសិនបើបើកការទាញហេតុផលដោយផ្ទាល់មាត់ និងមិនសួរកូនបំណុល នាំឱ្យការសរសេរសំអាងហេតុ គ្រាន់តែសរសេរជាលក្ខណៈងាយស្រួលខ្លីៗ គឺជាការគ្រប់គ្រាន់[3]។ ដោយសារតែការសេរសេរសំអាងហេតុមានលក្ខណៈងាយស្រួលខ្លីនាំឱ្យការបង្កើតលិខិតដីកាសម្រេចមានភាពឆាប់រហ័ស ហើយជាលទ្ធផលនាំឱ្យស្របទៅនឹងគោលគំនិតនៃលក្ខណៈបន្ទាន់បង្ខំ (ភាពជាប្រញាប់)។ បន្ថែមពីនេះ នៅក្នុងសំអាងហេតុ បន្ទាប់ពីបានកំណត់ប្រភេទ ខ្លឹមសារ និងចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលដែលម្ចាស់បំណុលមានរួចហើយ គួរតែធ្វើឱ្យមានភាពច្បាស់លាស់អំពីការរឹបអូសជាបណ្ដោះអាសន្ននូវទ្រព្យសម្បត្តិកូនបំណុល ដើម្បីរក្សាការពារការអនុវត្តនេះ។ នៅក្នុងឯកសារទម្រង់គំរូនេះ គឺបានធ្វើការកំណត់សិទ្ធិលើបំណុលដែលម្ចាស់បំណុលមានដោយភ្ជាប់ឧបសម្ព័ន្ធសិទ្ធិលើបំណុលដែលទាមទារ នៅក្នុងដីកាសម្រេច ហើយយោងឧបសម្ព័ន្ធនោះ។

---

[1] ក្នុងករណីដែលមិនឆ្លងកាត់ការទាញហេតុផលម្នាល់មាត់ ជាធម្មតា មិនសរសេរអំពីកាលបរិច្ឆេទនៃការបញ្ចប់ទាញហេតុផលដោយផ្ទាល់មាត់នៅក្នុងលិខិតដីកាសម្រេចទេ។

[2] ក្នុងករណីដែលបានបើកការទាញហេតុផលផ្ទាល់មាត់ និង សួរទៅកូនបំណុល ដែលជាករណីលើកលែង នឹងនាំឱ្យចំណុច វិវាទមានភាពច្បាស់លាស់តាមរយៈការអះអាងរបស់កូនបំណុល ដូច្នេះ គួរតែសរសេរអំពីអង្គហេតុ និង ចំណុចវិវាទ។

[3] ក្នុងករណីដែលបានបើកការទាញហេតុផលផ្ទាល់មាត់ និង សួរទៅកូនបំណុល ដែលជាករណីលើកលែង នឹងនាំឱ្យចំណុចវិវាទមានភាពច្បាស់លាស់ ដូច្នេះ ការវិនិច្ឆ័យរបស់តុលាការចំពោះចំណុចវិវាទ គួរតែសរសេរឱ្យបានលម្អិត។ ក្នុងករណីនេះ កូនបំណុល ដឹងថាមានការដាក់ពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ ដូច្នេះ មិនសូវជាមានភាពចាំបាច់ក្នុងការពិចារណា អំពីលក្ខណៈបន្ទាន់បង្ខំ (ភាពជាប្រញាប់) និង លក្ខណៈជាសម្ងាត់ទេ។ ចំពោះការជំនុំជម្រះអំពីការតវ៉ាចំពោះដីកាសម្រេច រក្សាការពារ ក៏ដូចគ្នាផងដែរ (មាត្រា ៥៥២)។

**(៤) សញ្ញាណប្រាតិភោគ**

នៅពេលតុលាការចេញដីកាសម្រេចប្រាតិភោគ ដោយឱ្យដាក់ប្រាតិភោគ (មាត្រា ៥៤២) នោះគួរតែសរសេរអំពីការណ៍ដែលឱ្យដាក់ប្រាតិភោគ និង ចំនួនទឹកប្រាក់ប្រាតិភោគ ក៏ដើម្បីផ្តល់ដំណឹងទៅកូនបំណុលផងដែរ។

**(៥) សេចក្តីសម្រេចបញ្ចប់**

- ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ជាគោលការណ៍ ត្រូវចេញដីកាសម្រេច ដោយកំណត់ដាក់លាក់នូវកម្មវត្ថុ (មាត្រា ៥៤៦)។ នៅក្នុងឯកសារទម្រង់គំរូនេះ មានភ្ជាប់បញ្ជីឧបសម្ព័ន្ធអំពីវត្ថុ[4] នៅក្នុងលិខិតដីកាសម្រេច ហើយតាមរយៈការយោងបញ្ជីឧបសម្ព័ន្ធនេះ កំណត់ដាក់លាក់នូវអចលនវត្ថុដែលជាកម្មវត្ថុ។

យ៉ាងណាមិញ ទោះបីជាមាន ឬ មិនមានពាក្យសុំរបស់ភាគី ក៏ត្រូវកំណត់ប្រាក់រំដោះពីការរឹបអូសជាបណ្តោះអាសន្ន (កថាខណ្ឌទី ១ មាត្រា ៥៤៧) និង ករណីយកិច្ចទទួលបន្ទុកប្រាក់ប្រដាប់ក្តី (មាត្រា ៥៣៩, មាត្រា ២១៦, កថាខណ្ឌទី ៣ មាត្រា ១៨២)។

- ក្នុងករណីលើកចោលពាក្យសុំ ត្រូវសរសេរនូវខ្លឹមសារថា លើកចោលពាក្យសុំសិទ្ធិលើបំណុល ព្រមទាំងសរសេរនូវខ្លឹមសារម្ចាស់បំណុលទទួលបន្ទុកប្រាក់ប្រដាប់ក្តី។

## III. ពាក្យសុំឱ្យអនុវត្តដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ

ពាក្យសុំអនុវត្តរឹបអូសជាបណ្តោះអាសន្ន ត្រូវតែធ្វើជាលាយល័ក្ខណ៍អក្សរ (ចំណុច ច មាត្រា ៥៣៤)។

### ១. ចំណុចដែលត្រូវសរសេរនៅក្នុងពាក្យសុំ

មាត្រា៥៦៤ នឹងអនុវត្តដូចគ្នានឹង មាត្រា ៣៤៩ ដូច្នេះ ចំពោះចំណុចដែលត្រូវសរសេរនៅក្នុងពាក្យសុំ ត្រូវតែអនុលោមតាមមាត្រានេះ។

(១) ឈ្មោះ ឬ នាមករណ៍ និង អាសយដ្ឋាន របស់ម្ចាស់បំណុលនៃការម្ចាស់បំណុលនៃការអនុវត្ត និង កូនបំណុលនៃការអនុវត្ត ហើយនិងឈ្មោះ និង អាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់ (មាត្រា ៥៦៤, ចំណុច ក កថាខណ្ឌទី ២ មាត្រា ៣៤៩)

(២) សញ្ញាណនៃលិខិតអនុវត្ត (មាត្រា ៥៦៤, ចំណុច ខ កថាខណ្ឌទី ២ មាត្រា ៣៤៩)

---

[4] ប្រសិនបើមិនមានបញ្ហានៅក្នុងការសរសេរបញ្ជីឧបសម្ព័ន្ធអំពីសិទ្ធិលើបំណុលដែលទាមទារ ដែលបានភ្ជាប់នៅក្នុងពាក្យសុំទេ គឺអាចប្រើប្រាស់បានដូចគ្នានៅក្នុងលិខិតដីកាសម្រេចផងដែរ។

ការអនុវត្តរក្សាការពារ ត្រូវធ្វើឡើងដោយផ្អែកលើឯកសារចម្លងយថាភូតនៃដីកាសម្រេចរក្សាការពារ (កថាខណ្ឌទី ១ មាត្រា ៥៦២) ដូច្នេះ ឯកសារចម្លងយថាភូតនៃដីកាសម្រេចរក្សាការពារ នឹងមានភាពសមរម្យសម្រាប់ជាលិខិតអនុវត្តនៅក្នុងការអនុវត្តដោយបង្ខំ។

(៣) សេចក្ដីសុំឱ្យអនុវត្ត តាមការបង្ខំដោយផ្ទាល់ ឬ ការអនុវត្តជំនួស ឬ វិធានបង្ខំដោយប្រយោល (មាត្រា ៥៦៤, ចំណុច គ កថាខណ្ឌទី ២ មាត្រា ៣៤៩)

ការរឹបអូសជាបណ្ដោះអាសន្ន គឺជាផ្នែកមួយនៃការអនុវត្តតាមការបង្ខំដោយផ្ទាល់ ដូច្នេះ គ្រាន់តែសរសេរថា រឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ ជាការគ្រប់គ្រាន់ជាលក្ខណៈនៃសេចក្ដីសុំ។ នៅក្នុងឯកសារទម្រង់គំរូនេះ ដោយសារគិតពីចំណុចងាយស្រួលយល់ គឺបានបន្ថែមពាក្យថា"តាមការបង្ខំដោយផ្ទាល់" ប៉ុន្តែទោះជាមិនមានពាក្យនេះ ក៏ដោយ ក៏មានភាពគ្រប់គ្រាន់ជាលក្ខណៈនៃសេចក្ដីសុំឱ្យអនុវត្ត តាមការបង្ខំដោយផ្ទាល់ ឬ ការអនុវត្តជំនួស ឬ វិធានបង្ខំដោយប្រយោលន៍។

(៤) សញ្ញាណនៃទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំ និង វិធីអនុវត្តដោយបង្ខំដែលម្ចាស់បំណុលនៃការអនុវត្តសុំ ក្នុងករណីដែលសុំឱ្យអនុវត្តតាមការបង្ខំដោយផ្ទាល់ (មាត្រា ៥៦៤, ចំណុច ឃ កថាខណ្ឌទី ២ មាត្រា ៣៤៩)

ការកំណត់ជាក់លាក់នូវអចលនវត្ថុដែលជាកម្មវត្ថុនៃការរឹបអូសជាបណ្ដោះអាសន្ន គឺជាសញ្ញាណដែលមានភាពចាំបាច់។ វិធីដើម្បីកំណត់ជាក់លាក់នូវអចលនវត្ថុ ត្រូវភ្ជាប់បញ្ជីឧបសម្ព័ន្ធអំពីវត្ថុនៅក្នុងពាក្យសុំ និងយោងបញ្ជីនោះ។

ចំពោះវិធីអនុវត្តវិញ ការរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ ត្រូវធ្វើតាមរបៀបចុះបញ្ជីរឹបអូសជាបណ្ដោះអាសន្ន ដែលមានចែងនៅក្នុងមាត្រា៥៦៧ ដូច្នេះ ប្រសិនបើគ្រាន់តែសរសេរថា សុំឱ្យអនុវត្តរឹបអូសជាបណ្ដោះអាសន្នចំពោះ អចលនវត្ថុ គឺជាការគ្រប់គ្រាន់។ នៅក្នុងឯកសារទម្រង់គំរូនេះ ដោយសារគិតពីចំណុចងាយស្រួលយល់ បានសរសេរថា "តាមរយៈវិធីធ្វើការចុះបញ្ជីនៃការរឹបអូសជាបណ្ដោះអាសន្ន" ប៉ុន្តែ ទោះជាមិនមានពាក្យនេះ ក៏ដោយ ក៏មានភាពគ្រប់គ្រាន់ជាលក្ខណៈនៃការសរសេរអំពីវិធីនៃការអនុវត្តដោយបង្ខំ នោះជាការគ្រប់គ្រាន់។

## ២. ឯកសារភ្ជាប់នៅក្នុងពាក្យសុំ

### (១) ឯកសារចម្លងយថាភូតនៃដីកាសម្រេចរក្សាការពារ

ការអនុវត្តរក្សាការពារ ត្រូវឡើងដោយផ្អែកលើឯកសារចម្លងយថាភូតនៃដីកាសម្រេចរក្សាការពារ (កថាខណ្ឌទី ១ មាត្រា ៥៦២) ដូច្នេះ នៅក្នុងពាក្យសុំ មានចាំបាច់ដែលត្រូវភ្ជាប់ឯកសារចម្លងយថាភូតនៃដីកាសម្រេចរក្សាការពារ។

រូបមន្តអនុវត្ត ជាគោលការណ៍ មិនត្រូវការនោះទេ។ ដីកាសម្រេចរក្សាការពារ នឹងមានអានុភាពអនុវត្តភ្លាមៗ និងដូចដែលមានកំណត់នៅក្នុងកថាខណ្ឌទី ២ មាត្រា ៥៦២ ជាគោលការណ៍ ត្រូវអនុវត្តឱ្យបានឆាប់រហ័ស ដូច្នេះ អត្ថិភាពនៃអានុភាពអនុវត្ត មិនចាំបាច់ត្រូវធ្វើនិយ័តកម្មដោយរូបមន្តទេ។

**(២) លិខិតតំណាង**

ជាឯកសារដែលបញ្ជាក់សិទ្ធិអំណាចរបស់អ្នកតំណាងដោយអាណត្តិ (កថាខណ្ឌទី ២ មាត្រា ៥៣)។

**សូមអរគុណ**

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## ពាក្យសុំឱ្យលក់ដោយបង្ខំ

### ម្ចាស់បំណុលនៃការអនុវត្ត

ឈ្មោះ ៖ X

អាសយដ្ឋាន ៖ ផ្ទះលេខ ០០ ផ្លូវលេខ ០០ ភូមិ...... ឃុំ.......ស្រុក......... ខេត្តបាត់ដំបង[1]។

### អ្នកតំណាងដោយអាណត្តិ

ឈ្មោះ៖លោក/លោកស្រី ៖ P

អាសយដ្ឋានការិយាល័យ ៖ .................................

ឈ្មោះការិយាល័យមេធាវី/ក្រុមមេធាវី/ក្រុមហ៊ុនមេធាវី ៖ ..........................................

លេខទូរស័ព្ទ ៖ ..................................................

**ទីកន្លែងបញ្ជូន** ៖ ការិយាល័យមេធាវី/ ក្រុមមេធាវី/ ក្រុមហ៊ុនមេធាវី.................. [2]

---

[1] យោងចំណុច ក កថាខណ្ឌទី ២ មាត្រា ៣៤៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ ម្ចាស់បំណុលនៃការអនុវត្ត និង កូនបំណុលនៃការអនុវត្តដែលសរសេរនៅក្នុងពាក្យសុំឱ្យអនុវត្តដោយបង្ខំ ត្រូវតែឱ្យដូចគ្នានឹងភាគីដែលមានសរសេរនៅក្នុងលិខិតអនុវត្ត និងរូបមន្តអនុវត្ត។ ករណីដែលមានការផ្លាស់ប្តូរ ឈ្មោះ ឬ នាមករណ៍ និង អាសយដ្ឋានរបស់ម្ចាស់បំណុលនៃការអនុវត្ត និងកូនបំណុលនៃការអនុវត្ត ត្រូវតែដាក់ម្ចាស់បំណុលនៃការអនុវត្ត និងកូនបំណុលនៃការអនុវត្ត ជាបុគ្គលឱ្យដូចគ្នានឹងភាគីដែលមានសរសេរនៅក្នុងលិខិតអនុវត្ត និងរូបមន្តអនុវត្ត។

[2] យោងមាត្រា ៣៣៥, មាត្រា ២៤៩ និងមាត្រា ២៥០ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ ការសរសេរអំពីទីកន្លែងបញ្ជូន មិនមែនជាករណីយកិច្ចទេ។ ប្រសិនបើមិនសរសេរទីកន្លែងបញ្ជូន នោះការបញ្ជូន នឹងបញ្ជូនទៅអាសយដ្ឋានរបស់ម្ចាស់បំណុលនៃការអនុវត្ត ជាអាទិ៍។ ហេតុដូច្នេះ ករណីដែលអ្នកតំណាងដោយអាណត្តិរបស់ម្ចាស់បំណុលនៃការអនុវត្ត មានបំណងចង់ឱ្យធ្វើការបញ្ជូនទៅទីកន្លែងក្រៅពីអាសយដ្ឋានរបស់ម្ចាស់បំណុលនៃការអនុវត្ត ជាអាទិ៍ ចាំបាច់ត្រូវសរសេរទីកន្លែងបញ្ជូនជាលាយលក្ខអក្សរដូចជានៅក្នុងពាក្យសុំ ជាអាទិ៍។

**កូនបំណុលនៃការអនុវត្ត**

ឈ្មោះ ៖ Y

អាសយដ្ឋាន៖ ផ្ទះលេខ ០០ ផ្លូវលេខ ០០ ភូមិ...... ឃុំ.......ស្រុក......... ខេត្តបាត់ដំបង។

**សិទ្ធិលើបំណុលដែលទាមទារ** ដូចមានសរសេរនៅក្នុងបញ្ជីឧបសម្ព័ន្ធអំពីសិទ្ធិលើបំណុល ដែល ទាមទារ[3]

**អចលនវត្ថុដែលជាកម្មវត្ថុ** ដូចមានសរសេរនៅក្នុងបញ្ជីឧបសម្ព័ន្ធអំពីវត្ថុ[4]

## សូមគោរពជូន
## លោកប្រធានសាលាដំបូងរាជធានីភ្នំពេញ[5]

### លិខិតអនុវត្តៈ អនុសារសាលក្រមដែលមានអានុភាពអនុវត្តសាលក្រមរដ្ឋប្បវេណី លេខ០០ ចុះថ្ងៃទី០០ ខែ០០ ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ

ម្ចាស់បំណុលនៃការអនុវត្ត មានសិទ្ធិលើបំណុលដូចដែលមានសញ្ញាណនៅក្នុងលិខិតអនុវត្ត [6] និងមានសរសេរក្នុងបញ្ជីឧបសម្ព័ន្ធអំពីសិទ្ធិលើបំណុលដែលទាមទារចំពោះកូនបំណុលនៃការអនុវត្ត ប៉ុន្តែ កូនបំណុលនៃការអនុវត្តមិនធ្វើការសងនូវសិទ្ធិលើបំណុលនោះទេ អាស្រ័យហេតុនេះ ម្ចាស់បំណុលនៃការអនុវត្ត ទាមទារឲ្យចាប់ផ្តើមនីតិវិធីការលក់ដោយបង្ខំចំពោះអចលនវត្ថុដែលមានសរសេរនៅក្នុងបញ្ជី

[3] កថាខណ្ឌទី ២ មាត្រា ៣៤៩ មិនបានចែងអំពីសញ្ញាណសិទ្ធិលើបំណុលដែលទាមទារទេ ប៉ុន្តែគួតែមានសញ្ញាណសិទ្ធិលើបំណុលដែលទាមទារ ដើម្បីឱ្យសិទ្ធិលើបំណុលដែលទាមទារ និងជាមូលហេតុនៃ ការអនុវត្តដោយបង្ខំចំពោះកូនបំណុលនៃការអនុវត្ត ឱ្យមានភាពកាន់តែច្បាស់លាស់។

[4] យោងចំណុច ឃ កថាខណ្ឌទី ២ មាត្រា ៣៤៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

[5] ចំពោះការអនុវត្តដោយបង្ខំដែលមានកម្មវត្ថុជាដី ឬ វត្ថុដែលត្រូវបានចុះបញ្ជី គឺសាលាដំបូងនៅទីកន្លែងដែលដី ឬវត្ថុដែលត្រូវបានចុះបញ្ជីនោះ ជាតុលាការអនុវត្តដែលមានសមត្ថកិច្ច (ចំណុច ក មាត្រា ៤១៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ នៅក្នុងរឿងក្តីនេះ អចលនវត្ថុដែលជាកម្មវត្ថុ មានទីតាំងនៅ រាជធានីភ្នំពេញ ដូច្នេះសាលាដំបូងរាជធានីភ្នំពេញមានសមត្ថកិច្ចលើរឿងក្តីនេះ។។

[6] យោងចំណុច គ កថាខណ្ឌទី ២ មាត្រា ៣៤៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

ឧបសម្ព័ន្ធអំពីវត្ថុដែលជាកម្មសិទ្ធិរបស់កូនបំណុលនៃការអនុវត្ត ជាការអនុវត្តតាមការបង្ខំដោយផ្ទាល់[7]។

ចំពោះរឿងក្តីនេះ បានចុះបញ្ជីរឹបអូសជាបណ្តោះអាសន្ន ដោយផ្អែកតាម ដីកាសម្រេចលេខ 00 AJ 00 របស់សាលាដំបូងរាជធានីភ្នំពេញ ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០២០[8]។

សេចក្តីដូចមានកំណត់ សូម **ឯកឧត្តម/ លោកជំនាញប្រធាន** សម្រេចតាមការស្នើសុំដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តម/លោកជំនាញប្រធាន** ទទួលនូវសេចក្តីគោរពដ៏ជ្រាលជ្រៅអំពីខ្ញុំ។

ខេត្តបាត់ដំបង, ថ្ងៃទី ៩ ខែសីហា ឆ្នាំ ២០២១

**អ្នកតំណាងដោយអាណត្តិ**

P

[7] យោងចំណុច គ និងចំណុច ឃ កថាខណ្ឌទី ២ មាត្រា ៣៤៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

[8] នៅពេលដាក់ពាក្យឱ្យសុំលក់ដោយបង្ខំ ចំពោះករណីដែលមានការរឹបអូសជាបណ្តោះអាសន្ន គួរតែសរសេរនូវខ្លឹមសារដែលការដាក់ពាក្យសុំឱ្យលក់ដោយបង្ខំ ជាការផ្ទេរទៅការអនុវត្តដោយបង្ខំពីការរឹបអូសជាបណ្តោះអាសន្ន ហើយភ្ជាប់ឯកសារថតចម្លងយថាភូតនៃដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន។ យ៉ាងណាមិញ ដើម្បីការរឹបអូសជាបណ្តោះផ្ទេរទៅជាការអនុវត្តដោយបង្ខំ ចាំបាច់ត្រូវការ ①អត្ថិភាពនៃលិខិតអនុវត្ត ②ភាគីនៃការអនុវត្តរក្សាការពារ និងការអនុវត្តដោយបង្ខំ ជាភាគីដូចគ្នា ③ការណ៍ដែលអាចទទួលស្គាល់ថាសិទ្ធិ ឬ ទំនាក់ទំនងដែលនឹងត្រូវបានរក្សា ការពាររឹបអូសជាបណ្តោះអាសន្ន ដូចគ្នាជាមួយនឹងសិទ្ធិលើបំណុលដែលទាមទារនៅក្នុងការអនុវត្តដោយបង្ខំ។

ឯកសារភ្ជាប់

១-អនុសារសាលក្រមដែលមានអានុភាពអនុវត្ត[9]

២-លិខិតបញ្ជាក់ការបញ្ជូន[10]

៣-ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នៃសៀវភៅចុះបញ្ជី

៤- ឯកសារថតចម្លងយថាភូតនៃដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន

៥-លិខិតប្រគល់សិទ្ធិអ្នកតំណាងដោយអាណត្តិ "ច្បាប់ដើម"

---

[9] នៅក្នុងពាក្យសុំឱ្យអនុវត្តដោយបង្ខំ ជាគោលការណ៍ ម្ចាស់បំណុលនៃការអនុវត្ត ត្រូវភ្ជាប់ជារបៀប ដែល បានទទួលរូបមន្តអនុវត្ត (មាត្រា ៣៥០ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ដោយបានសរសេរភ្ជាប់បន្ថែម នៅ ផ្នែកខាងក្រោមនៃឯកសារចម្លងនៃលិខិតអនុវត្ត (មាត្រា ៣៥៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

[10] ការអនុវត្តដោយបង្ខំ អាចចាប់ផ្តើមបាន តែក្នុងករណីដែលឯកសារចម្លងយថាភូត ឬ ឯកសារចម្លង ដែលមានសេចក្តីបញ្ជាក់នៃលិខិតអនុវត្ត ឬ សេចក្តីសម្រេចដែលនឹងក្លាយជាលិខិតអនុវត្តនៅពេលចូល ជាស្ថាពរ ត្រូវបញ្ជូនទៅកូនបំណុលនៃការអនុវត្តទុកជាមុន (មាត្រា ៣៦០ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

**ឧបសម្ព័ន្ធ**

## បញ្ជីឧបសម្ព័ន្ធអំពីសិទ្ធិលើបំណុលដែលទាមទារ

សិទ្ធិលើបំណុលដែលមានសញ្ញាណនៅក្នុងអនុសារសាលក្រមដែលមានអនុភាពអនុវត្តសាលក្រមរដ្ឋប្បវេណីលេខ ០០ ចុះថ្ងៃទី០០ ខែ០០ ឆ្នាំ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ រវាងម្ចាស់បំណុលនៃការអនុវត្ត និង កូនបំណុលនៃការអនុវត្ត មានដូចខាងក្រោម៖

១. ប្រាក់ដើម ចំនួន ៥០.០០០.០០០ (សែសិបលាន) រៀល

២. ការប្រាក់ចំនួន ២.០០០.០០០ (ពីរលានរៀល) រៀល

ការប្រាក់ ចំនួន ៥ ភាគរយ (ប្រាំភាគរយ) ក្នុងមួយឆ្នាំ នៃប្រាក់ដើមចំនួន ៥០.០០០.០០ (សែសិបលាន) រៀល គិតចាប់ពីថ្ងៃទី១ ខែតុលា ឆ្នាំ២០១៩ រហូតដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០

៣. ប្រាក់សំណងនៃការខូចខាតដោយសារការយឺតយ៉ាវ[11]

ប្រាក់សំណងនៃការខូចខាតដោយសារការយឺតយ៉ាវ ចំនួន ៥ ភាគរយ (ប្រាំភាគរយ) ក្នុងមួយឆ្នាំ នៃប្រាក់ដើមចំនួន ៥០.០០០.០០០ (សែសិបលាន) រៀល គិតចាប់ពីថ្ងៃទី១ ខែតុលា ឆ្នាំ២០២០ រហូតដល់ ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២០

[11] ម្ចាស់បំណុលនៃការអនុវត្តអាចទទួលបានការចែកចំណែកប្រាក់សំណងនៃការខូចខាតដោយសារការយឺតយ៉ាវ រហូតដល់កាលបរិច្ឆេទនៃការចែកចំណែក (យោង កថាខណ្ឌទី ៥ មាត្រា ៥៩០ ក្រមនីតិវិធីរដ្ឋប្បវេណី)។

ឧបសម្ព័ន្ធ

# បញ្ជីឧបសម្ព័ន្ធអំពីវត្ថុ

"ទីតាំងដី" ផ្លូវលេខ ០០ ភូមិ...... សង្កាត់.......ខណ្ឌ.........រាជធានីភ្នំពេញ

"លេខឡូតិ៍" ០០

# ឯកសារទម្រង់គំរូពាក់ព័ន្ធនឹងការអនុវត្តអចលនវត្ថុ

## I. ពាក្យសុំលក់ដោយបង្ខំ

### ១. ចំណុចដែលត្រូវសរសេរនៅក្នុងពាក្យសុំ

ពាក្យសុំអនុវត្តដោយបង្ខំ ត្រូវធ្វើជាលាយល័ក្ខណ៍អក្សរ (មាត្រា ៣៤៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ តទៅចំពោះមាត្រានៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី នឹងយោងតែលេខមាត្រាទេ។)។ នៅក្នុងពាក្យសុំ ត្រូវសរសេរចំណុចដែលត្រូវសរសេរដែលកំណត់នៅក្នុងកថាខណ្ឌទី ២ មាត្រា ៣៤៩។

**(១) ឈ្មោះ ឬ នាមករណ៍ និង អាសយដ្ឋាន របស់ម្ចាស់បំណុលនៃការអនុវត្ត និង កូនបំណុលនៃការអនុវត្ត ហើយនិងឈ្មោះ និង អាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់ (ចំណុច ក កថាខណ្ឌទី ២ មាត្រា ៣៤៩)**

ម្ចាស់បំណុលនៃការអនុវត្ត និង កូនបំណុលនៃការអនុវត្ត ដែលសរសេរនៅក្នុងពាក្យសុំអនុវត្តដោយបង្ខំ ត្រូវតែឱ្យដូចគ្នានឹងភាគីដែលសរសេរនៅក្នុងលិខិតអនុវត្ត និងរូបមន្តអនុវត្ត។ ករណីដែលមានការផ្លាស់ប្តូរ ឈ្មោះ ឬ នាមករណ៍ និង អាសយដ្ឋានរបស់ម្ចាស់បំណុលនៃការអនុវត្ត និងកូនបំណុលនៃការអនុវត្ត ត្រូវតែដាក់ម្ចាស់បំណុលនៃការអនុវត្ត និងកូនបំណុលនៃការអនុវត្ត ជាបុគ្គលឱ្យដូចគ្នានឹងភាគីដែលមានសរសេរនៅក្នុងលិខិតអនុវត្ត និងរូបមន្តអនុវត្ត។

យ៉ាងណាមិញ នៅក្នុងនីតិវិធីទាក់ទងនឹងការអនុវត្តដោយបង្ខំ មានករណីដែលបុគ្គលក្រៅពីមេធាវីក្លាយជាអ្នកតំណាងដោយអាណត្តិ ដោយទទួលការអនុញ្ញាតពីតុលាការអនុវត្ត ឬ សាលាដំបូង (ចំណុច ខ កថាខណ្ឌទី១ មាត្រា ៣៤៨)។

**(២) សញ្ញាណនៃលិខិតអនុត្ត (ចំណុច ខ កថាខណ្ឌទី ២ មាត្រា ៣៤៩)**

នៅក្នុងកថាខណ្ឌទី ២ មាត្រា ៣៥០ មានកំណត់អំពីប្រភេទនៃលិខិតអនុវត្ត។ លិខិតអនុវត្ត ត្រូវកំណត់ដាក់លាក់តាមប្រភេទនៃលិខិតអនុវត្ត និងស្ថាប័នបង្កើតលិខិតអនុវត្ត លេខសាលក្រម ជាអាទិ៍។

**(៣) សេចក្តីសុំឱ្យអនុវត្ត តាមការបង្ខំដោយផ្ទាល់ ឬ ការអនុវត្តជំនួស ឬ វិធានបង្ខំដោយប្រយោល (ចំណុច គ កថាខណ្ឌទី ២ មាត្រា ៣៤៩)**

ការលក់ដោយបង្ខំ គឺជាប្រភេទមួយនៃការអនុវត្តតាមការបង្ខំដោយផ្ទាល់ ដូច្នេះ ប្រសិនបើគ្រាន់តែសរសេរថាសុំឱ្យចាប់ផ្តើមនីតិវិធីនៃការលក់ដោយបង្ខំ ជាការគ្រប់គ្រាន់។ នៅក្នុងឯកសារទម្រង់គំរូនេះ ដោយសារគិតពីចំណុច

ងាយស្រួលយល់ គឺបានបន្ថែមពាក្យថា"តាមការបង្ខំដោយផ្ទាល់" ប៉ុន្តែទោះជាមិនប្រើពាក្យនេះក៏ដោយ ក៏មានភាពគ្រប់គ្រាន់ជាលក្ខណៈនៃសេចក្តីសុំឱ្យអនុវត្ត តាមការបង្ខំដោយផ្ទាល់ ឬ ការអនុវត្តជំនួស ឬវិធានបង្ខំដោយប្រយោល។

**(៤) សញ្ញាណនៃទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំ និង វិធីអនុវត្តដោយបង្ខំដែលម្ចាស់បំណុលនៃការអនុវត្តសុំ ក្នុងករណីដែលសុំឱ្យអនុវត្តតាមការបង្ខំដោយផ្ទាល់ (ចំណុច ឃ កថាខណ្ឌទី ២ មាត្រា ៣៤៩)**

ការអនុវត្តអចលនវត្ថុ ត្រូវកំណត់ជាក់លាក់ដោយមានសញ្ញាណអចលនវត្ថុដែលជាកម្មវត្ថុ។ វិធីដើម្បីកំណត់ជាក់លាក់អចលនវត្ថុ ត្រូវភ្ជាប់បញ្ជីឧបសម្ព័ន្ធអំពីវត្ថុនៅក្នុងពាក្យសុំ និងយោងបញ្ជីនោះ។

វិធីដើម្បីអនុវត្តដោយបង្ខំដែលម្ចាស់បំណុលនៃការអនុវត្តទាមទារ ប្រសិនបើគ្រាន់តែសរសេរថា សុំឱ្យចាប់ផ្តើមនីតិវិធីលក់ដោយបង្ខំ ជាការគ្រប់គ្រាន់។

**(៥) សិទ្ធិលើបំណុលដែលទាមទារ**

កថាខណ្ឌទី ២ មាត្រា ៣៤៩ មិនមានការកំណត់ជាក់លាក់ដោយបង្ហាញសញ្ញាណនៃសិទ្ធិលើបំណុលដែលទាមទារទេ ប៉ុន្តែ ដើម្បីឱ្យមានភាពច្បាស់លាស់នូវសិទ្ធិលើបំណុលដែលទាមទារ និងជាមូលហេតុនៃការអនុវត្តដោយបង្ខំ ចំពោះកូនបំណុលនៃការអនុវត្ត ទោះបីនៅក្នុងករណីដែលទាមទារសិទ្ធិលើបំណុលទាំងអស់ក៏ដោយ ក៏គួរតែបង្ហាញ សញ្ញាណសិទ្ធិលើបំណុលលើដែលទាមទារនោះ។ វិធីដើម្បីបង្ហាញសញ្ញាណសិទ្ធិលើបំណុលដែលទាមទារត្រូវភ្ជាប់ បញ្ជីឧបសម្ព័ន្ធអំពីសិទ្ធិលើបំណុលដែលទាមទារនៅក្នុងពាក្យសុំ និងយោងបញ្ជីនោះ។

**(៦) ការបំលែងទៅជាការអនុវត្តដោយបង្ខំ**

មុនពេលដាក់ពាក្យសុំលក់ដោយបង្ខំ ចំពោះករណីដែលមានការរឹបអូសជាបណ្តោះអាសន្ន គួរតែសរសេរនូវខ្លឹមសារដែលការដាក់ពាក្យសុំលក់ដោយបង្ខំ ជាការផ្ទេរទៅការអនុវត្តដោយបង្ខំពីការរឹបអូសជាបណ្តោះអាសន្ន។ យ៉ាងណាមិញ ដើម្បីការរឹបអូសជាបណ្តោះផ្ទេរទៅជាការអនុវត្តដោយបង្ខំ ចាំបាច់ត្រូវការ ①អត្ថិភាពនៃលិខិតអនុវត្ត ②ភាគីនៃការអនុវត្តរក្សាការពារ និងការអនុវត្តដោយបង្ខំ ជាភាគីដូចគ្នា ③ការណ៍ដែលអាចទទួលស្គាល់ថាសិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពាររឹបអូសជាបណ្តោះអាសន្ន ដូចគ្នាជាមួយនឹងសិទ្ធិលើបំណុលដែលទាមទារនៅក្នុងការអនុវត្ត ដោយបង្ខំ។

## ២. ឯកសារសេចក្តីបញ្ជាក់ដំបូង

**(១) លិខិតចម្លងយថាភូតនៃលិខិតអនុវត្ត ដែលមានអានុភាពអនុវត្ត (កថាខណ្ឌទី ២ មាត្រា ៣៤៩)**

នៅក្នុងពាក្យសុំអនុវត្តដោយបង្ខំ ជាគោលការណ៍ ត្រូវធ្វើឡើងតាមវិធីសរសេរភ្ជាប់បន្ថែម នៅផ្នែកខាងក្រោមនៃឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត (មាត្រា ៣៥០) ដែលម្ចាស់បំណុលនៃការអនុវត្តមាន (មាត្រា ៣៥៧)។

**(២) សេចក្តីបញ្ជាក់អំពីការបញ្ជូន (មាត្រា ៣៦០)**

ការអនុវត្តដោយបង្ខំ អាចចាប់ផ្តើមបាន តែក្នុងករណីដែលឯការចម្លងយថាភូត ឬ ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នៃលិខិតអនុវត្ត ឬ សេចក្តីសម្រេចដែលនឹងក្លាយជាលិខិតអនុវត្តនៅពេលចូលជាស្ថាពរ ត្រូវបានបញ្ជូនទៅកូនបំណុលនៃការអនុវត្តជាមុន។

**(៣) ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នៃសៀវភៅចុះបញ្ជី (ចំណុច ក កថាខណ្ឌទី ៣ មាត្រា ៤១៧)**

នៅក្នុងពាក្យសុំអនុវត្តដោយបង្ខំ ក្នុងករណីអចលនវត្ថុដែលជាកម្មវត្ថុត្រូវបានចុះបញ្ជី ត្រូវភ្ជាប់ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នៃសៀវភៅចុះបញ្ជី។

**(៤) លិខិតតំណាង**

ជាឯកសារដែលបញ្ជាក់អំពីសិទ្ធិអំណាចរបស់អ្នកតំណាងដោយអាណត្តិ (កថាខណ្ឌទី ២ មាត្រា ៥៣)។

**សូមអរគុណ**

## លំហាត់អនុវត្ត - Practice Questions

### "អង្គហេតុ"

A កំពុងរស់នៅខេត្តសៀមរាប ហើយ B រស់នៅខេត្តបាត់ដំបង។

នៅថ្ងៃទី៩ ខែសីហា ឆ្នាំ២០២១ A បានបង្កើតកិច្ចសន្យាលក់ទិញនូវរថយន្តដែលជាកម្មសិទ្ធិរបស់ A ជាមួយ B ក្នុងតម្លៃ ចំនួន ៥.០០០ (ប្រាំពាន់) ដុល្លារអាមេរិក ដោយយក ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២១ ជាថ្ងៃកំណត់បង់ប្រាក់ថ្លៃលក់។ ហើយនៅថ្ងៃទី៩ ខែសីហា ឆ្នាំ២០២១ A បានប្រគល់រថយន្តទៅឱ្យ B។ នៅថ្ងៃទី១៦ ខែសីហា ឆ្នា២០២១ B បានបង់ប្រាក់ថ្លៃលក់មួយផ្នែក ចំនួន ២.០០០ (ពីរពាន់) ដុល្លាអាមេរិក ទៅឱ្យ A ប៉ុន្តែ ចំពោះប្រាក់ថ្លៃលក់ដែលនៅសល់ មិនបានបង់សោះឡើយទោះបីជាផុតថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២១ហើយក៏ដោយ។

តាមដែល A បានស្រាវជ្រាវ បានឱ្យដឹងថា B មានដី L១ ដែលកំពុងរស់នៅ ( ៣០.០០០ (បីម៉ឺន) ដុល្លារអាមេរិក) ដែលជាកម្មសិទ្ធិរបស់ខ្លួននៅខេត្តបាត់ដំបង ហើយកំពុងធ្វើអាជីវកម្មភោជនីយដ្ឋាន ប៉ុន្តែឮថាអាជីវកម្មដំណើរការមិនរលូនទេ ។ ម្យ៉ាងទៀត ក្រៅពី ដី L១ អំឡុងពេលឆ្នាំមុន B ជនតែម្នាក់ដែលទទួលសន្តិកម្មពីឪពុកម្តាយនូវ ដី L២ (២០.០០០ (ពីរម៉ឺន) ដុល្លារអាមេរិក) និង ដី L៣ (១០.០០០ (មួយម៉ឺន) ដុល្លារអាមេរិក) ដែលមានអាសយដ្ឋាននៅខេត្តបាត់ដំបង។

### "សំណួរ"

**Q1** តើអ្នកគិតថា A នឹងដាក់ពាក្យសុំឱ្យចាត់ចែងរក្សាការពារបែបណា ទៅតុលាការមួយណា?

Q2 នៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១ A បានដាក់ពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នទៅតុលាការ។ នៅក្នុងពាក្យសុំនោះបានសរសេរអំពីសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលត្រូវរក្សាការពារដូចតទៅ៖

| |
|---|
| ថ្ងៃលក់ទិញ ៣.០០០ (បីពាន់) ដុល្លារអាមេរិក និងប្រាក់ចំនួន ៥ ភាគរយ (ប្រាំភាគរយ) ក្នុងមួយឆ្នាំ នៃប្រាក់ដើម ចាប់ពីថ្ងៃទី ២៤ ខែសីហា ឆ្នាំ២០២១ រហូតដល់ការទូទាត់ប្រាក់រួចរាល់។ |

តើការសសេរបែបនេះ មានបញ្ហាដែរឬទេ? ប្រសិនបើមានបញ្ហា តើត្រូវឱ្យកែតម្រូវបែបណា?

Q3 A បានស្នើរសុំឱ្យរឹបអូសជាបណ្តោះអាសន្នចំពោះដីទាំង ៣ មានដី L១ ដីL២ ដីL៣ ដែលជាកម្មសិទ្ធិរបស់ B នៅក្នុងពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន។ តើតុលាការត្រូវទទួលស្គាល់ការរឹបអូសជាបណ្តោះអាសន្នបែបនេះដែរឬទេ?

Q3 A បានដាក់បណ្តឹងទាមទារឱ្យបង់ប្រាក់ថ្លៃលក់ទិញរថយន្ត ចំពោះ B។ តុលាការបានចេញសាលក្រមទទួលស្គាល់នូវការទាមទាររបស់ A ហើយសាលក្រមដដែលនេះ បានចូលជាស្ថាពរ។ បន្ទាប់ក្រោយមក B បានទទួលមរណភាព ហើយ C ជាកូនទោលតែរបស់ B ដែលទទួលសន្តតិកម្មនូវទ្រព្យសម្បត្តិរបស់ B ទាំងអស់។ តើត្រូវមានរូបមន្តអនុវត្តបែបណា ដើម្បីឱ្យ A ដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះអចលនវត្ថុដែលបានធ្វើសន្តតិកម្មពី B ទៅ C បាន?

"**ចម្លើយ**"

A1 សិទ្ធិលើបំណុលដែលជាប្រាក់ថ្លៃលក់ទិញរបស់ A ចំពោះ B ជាសិទ្ធិលើបំណុលជាប្រាក់ ដូច្នេះដើម្បីធ្វើការរក្សាការពារនូវការអនុវត្តដោយបង្ខំនេះ A ត្រូវដាក់ពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន (ចំណុច ក មាត្រា ៥៣១ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ តទៅ ចំពោះមាត្រានៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី នឹងយោងតែលេខមាត្រាទេ។)

រឿងក្តីនៃដីកាសម្រេចរក្សាការពារ ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់តុលាការដែលមានសមត្ថកិច្ចលើអង្គសេចក្តី ឬ សាលាដំបូងដែលមានសមត្ថកិច្ចលើកន្លែងដែលវត្ថុដែលនឹងត្រូវបានរឹបអូសជាបណ្តោះអាសន្ន ឬ វត្ថុដែលជាកម្មវត្ថុនៃវិវាទស្ថិតនៅ (កថាខណ្ឌទី១ មាត្រា ៥៤០ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

ដោយសារតែសមត្ថកិច្ចនៃលំនៅឋានរបស់ B នៅខេត្តបាត់ដំបង (ចំណុច ក មាត្រា ៨) ដូច្នេះ សាលាដំបូងខេត្តបាត់ដំបងមានសមត្ថកិច្ចលើរឿងក្តីទាមទារឱ្យបង់ប្រាក់ថ្លៃលក់ទិញនៃរឿងក្តីនេះ។ ម្យ៉ាងវិញទៀត កន្លែងដែលត្រូវអនុវត្តកាតព្វកិច្ចថ្លៃលក់ទិញ (ចំណុច ក មាត្រា ៩) គឺនៅខេត្តសៀមរាបជាលំនៅឋានរបស់ A (មាត្រា ៤៤៥) ដូច្នេះសាលាដំបូងខេត្តសៀមរាប ក៏មានសមត្ថកិច្ចលើរឿងក្តីទាមទារឱ្យបង់ប្រាក់ថ្លៃលក់នៃរឿងក្តីនេះ។ ហេតុដូច្នេះ សាលាដំបូងខេត្តបាត់ដំបង និងសាលាដំបូងខេត្តសៀមរាប មានសមត្ថកិច្ចលើរឿងក្តីរឹបអូសជាបណ្តោះអាសន្ននេះ។ ម្យ៉ាងវិញទៀត ដោយសារទាំងដី L១ ដីL២ និង

ដីL៣ ដែលដីទាំងអស់នេះ មានអាសយដ្ឋាននៅខេត្តបាត់ដំបង ដូច្នេះ ក្នុងករណីអចលនវត្ថុដែលជាកម្មវត្ថុនៃការរឹបអូសជាបណ្តោះអាសន្នគឺជាដីទាំងអស់នេះ នាំឱ្យសាលាដំបូងខេត្តបាត់ដំបង ជាសាលាដំបូងដែលមានសមត្ថកិច្ចលើកន្លែងដែលវត្ថុដែលនឹងត្រូវបានរឹបអូសជាបណ្តោះអាសន្ន ដោយទោះបីក្នុងអត្ថន័យនេះក៏ដោយ ក៏ជាសាលាដំបូងខេត្តបាត់ដំបង មានសមត្ថកិច្ចលើរឿងក្តីរឹបអូសជាបណ្តោះអាសន្ន។

A2 សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារ ត្រូវកំណត់ឱ្យបានច្បាស់លាស់នូវខ្លឹមសារ និង ចំនួនទឹកប្រាក់ ជាអាទិ៍ ក្នុងកម្រិតដែលអាចបែងចែកបានជាមួយនឹងសិទ្ធិលើបំណុលផ្សេងទៀត។ ការកំណត់នូវសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពា ត្រូវសរសេរសារធាតុតាមច្បាប់នៃសិទ្ធិលើបំណុលនោះ (ប្រាក់កម្ចី, ប្រាក់ថ្លៃលក់ទិញ, កម្រៃចំពោះលទ្ធផលនៃការងារ ជាអាទិ៍) និង ធាតុផ្សំសំខាន់នៃសិទ្ធិលើបំណុលនោះ (ពេលវេលានៃការកើតឡើងនៃសិទ្ធិលើបំណុល, មូលហេតុនៃការកកើត, ពេលកំណត់សង, ខ្លឹមសារនៃល័ក្ខខ័ណ្ឌ ជាអាទិ៍)។

ការសរសេរឃ្លានៅក្នុងសំណួរ មានត្រឹមតែ "ប្រាក់ថ្លៃលក់ទិញ" តែប៉ុណ្ណោះ គឺមិនអាចនិយាយថាបានកំណត់ជាក់លាក់ក្នុងកម្រិតមួយដែលអាចបែងចែកបានជាមួយនឹងសិទ្ធិលើបំណុលផ្សេងទៀតបានទេ។ ចំពោះសិទ្ធិលើបំណុលដែលជាប្រាក់ថ្លៃលក់ទិញ មានភាពចាំត្រូវកំណត់ជាក់លាក់ ដោយសរសេរនូវ ភាគីនៃកិច្ចសន្យាលក់ទិញ កាលបរិច្ឆេទនៃកិច្ចសន្យា វត្ថុដែលជាកម្មវត្ថុ ជាអាទិ៍។ ម្យ៉ាងវិញទៀត ចំពោះសិទ្ធិលើបំណុលដែលទាមទារក្នុងករណីលើកឡើងនូវប្រាក់សំណងខូចខាតដោយសារការយឺតយ៉ាវទៀត ដែលក្រៅពីប្រាក់ថ្លៃលក់ទិញ ដោយសារតែទាំងអស់នេះជាសិទ្ធិដាច់ដោយឡែកៗពីគ្នា ដូច្នេះ មានភាពចាំបាច់ត្រូវកំណត់ជាក់លាក់នូវចំនួនទឹកប្រាក់នីមួយៗ ព្រមទាំងកំណត់ឱ្យបានច្បាស់លាស់នូវ ប្រាក់ដើមដែលជាកម្មវត្ថុ អត្រាការប្រាក់ និង អំឡុងពេល ជាអាទិ៍។ យ៉ាងណាមិញ ចំពោះអំឡុងពេលបញ្ចប់នៃការគណនាប្រាក់សំណងខូចខាត មិនមែនយក

ពេលវេលារហូតដល់ពេលបញ្ចប់ការទូទាត់ប្រាក់ទេ គឺយកពេលវេលារហូតដល់ការដាក់ពាក្យសុំ។[1]

"គំរូនៃការសរសេរ"

៣.០១២ (បីពាន់ដប់ពីរ) ដុល្លារអាមេរិក

ផ្អែកតាមកិច្ចសន្យាលក់ទិញចុះថ្ងៃទី៩ ខែសីហា ឆ្នាំ២០២០ ម្ចាស់បំណុល បានលក់ និងប្រគល់រថយន្ត (កំណត់ជាក់លាក់យោងតាមតួរថយន្តលេខ ជាអាទិ៍) នៃសិទ្ធិលើបំណុល ៣.០០០ (បីពាន់) ដុល្លារអាមេរិក និងប្រាក់សំណងខូចខាតដោយសារការយឺតយ៉ាវក្នុងអត្រា ចំនួន ៥ ភាគរយ (ប្រាំភាគរយ) ក្នុងមួយឆ្នាំ នៃប្រាក់ដើម ចាប់ពីថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០ ចំនួន ១២ (ដប់ពីរ) ដុល្លារអាមេរិក។

**A3** ការរឹបអូសជាបណ្តោះអាសន្ន ក្នុងករណីដែលម្ចាស់បំណុលមានសិទ្ធិលើបំណុលជាប្រាក់ចំពោះកូនបំណុល គឺជានីតិវិធីដើម្បីកម្រិតការចាត់ចែងនូវទ្រព្យសម្បត្តិរបស់កូនបំណុល ដើម្បីរក្សាការពារនូវការអនុវត្តដោយបង្ខំនៃសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យសងជាប្រាក់ (ចំណុច ក មាត្រា ៥៣១) ។ ករណីបកស្រាយថា តាមរយៈការអនុវត្តដោយបង្ខំចំពោះដីមួយណាក្នុងចំណោមដីទាំង៣ ដែលមាន ដីL១ ដីL២ ឬ ដីL៣ គឺអាចយកមកសងនូវចំនួនទឹកប្រាក់សរុបនៃសិទ្ធិលើបំណុលដែលទាមទារក៏បាន នាំឱ្យការរឹបអូសជាបណ្តោះអាសន្នដែលចំពោះដី L១ ដី L២ ឬដី L៣ នឹងលែងមានភាពចាំបាច់នៃការរក្សាការពារ។ ម្យ៉ាងទៀត ករណីដែលមានអចលនវត្ថុច្រើនដែលអាចយកមកសងនូវចំនួនទឹកប្រាក់សិទ្ធិលើបំណុលដែលទាមទារ គួរជ្រើសរើសចេញពីអចលនវត្ថុណាដែលធ្វើឱ្យម្ចាស់បំណុល មានការខូចខាតប្រយោជន៍កាន់តែតិច។ ហេតុដូច្នេះ ករណីមានអចលនវត្ថុច្រើនដែលអាចសងគ្រប់នូវចំនួនទកប្រាក់សិទ្ធិលើបំណុលដែលទាមទារបាន ហើយតម្លៃនៃ

[1] ក្រៅពីនេះ នៅក្នុងលិខិតពាក្យសុំ ត្រូវសរសេរអង្គហេតុដែលជាមូលហេតុនៃសិទ្ធិលើបំណុលរបស់ A និងការតវ៉ាតបចំពោះការតវ៉ាដែលត្រូវបានព្យាករណ៍ទុក។

អចលនវត្ថុនោះមានគម្លាតគ្នាច្រើន បើរឹបអូសជាបណ្ដោះអាសន្ននូវអចលនវត្ថុដែលមានតម្លៃទាបជាងគេ ជាការគ្រប់គ្រាន់។

ក្នុងករណីសិក្សានេះ ដី L១ (៣០.០០០ (បីម៉ឺន) ដុល្លារអាមេរិក) ដី L២ (២០.០០០ (ពីរម៉ឺន) ដុល្លារអាមេរិក) និងដី L៣ (១០.០០០ (មួយម៉ឺន) ដុល្លារអាមេរិក) ត្រូវរឹបអូសជាបណ្ដោះអាសន្នចំពោះដី L៣ ដែលមានតម្លៃទាបជាងគេ ដោយសារការអនុវត្តដោយបង្ខំលើដីទាំង ៣ នេះ មួយណាក៏អាចសងគ្រលប់នូវចំនួនទឹកប្រាក់សុរបនៃសិទ្ធិលើបំណុលដែលទាមទារ ហើយចំពោះដី L១ និងដី L២ ត្រូវដកពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ឬ លើកចោល។

A4 ករណីធ្វើការដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំ ដោយយកកូនបំណុលនៃការអនុវត្ត ជាយកបុគ្គលផ្សេង ក្រៅពីភាគីដែលត្រូវបានសរសេរលើលិខិតអនុវត្ត នោះម្ចាស់បំណុលនៃការអនុវត្ត ត្រូវទទួលការផ្ដល់រូបមន្តការអនុវត្តដែលមានសរសេរចំណុចនោះ (កថាខណ្ឌទី ២ មាត្រា ៣៥៦)។

ក្នុងករណីសិក្សានេះ នៅក្នុងសាលក្រមចូលជាស្ថាពរដែលជាលិខិតអនុវត្ត មិនបានបង្ហាញអត្តសញ្ញាណ C ទេ ដូច្នេះ A មានភាពចាំបាច់ត្រូវទទួលការផ្ដល់រូបមន្តការអនុវត្ត (រូបមន្តអនុវត្តពិសេស ឬរូបមន្តអនុវត្តទទួលបន្ត) ដែលយក C ជាកូនបំណុលនៃការអនុវត្ត។ ម្យ៉ាងទៀត ដោយសារ B បានទទួលមរណភាពក្រោយពេលសាលក្រមចូលជាស្ថាពរ ដូច្នេះ C បានសន្តតិកម្មនូវសិទ្ធិនិងករណីយកិច្ចរបស់ B ទាំងអស់ ដែលនាំឱ្យ C ស្ថិតនៅក្នុងទំហំអ្នកដែលអាចអនុវត្តដោយបង្ខំបាន (ចំណុច គ កថាខណ្ឌទី ១ មាត្រា ៣៥១)។

# រឿងក្តីចាត់ចែងជាបណ្តោះអាសន្ន
# ចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ

Case.6

# ខ្លឹមសារសង្ខេបករណីសិក្សា

A. X បានលក់ដី L ដែលខ្លួនមានកម្មសិទ្ធិ ក្នុងតម្លៃថ្លៃលក់ចំនួន ១០០.០០០ (ដប់ម៉ឺន) ដុល្លារអាមេរិច ទៅឱ្យ Y នៅថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២១ (តទៅហៅថា "កិច្ចសន្យាថ្លៃលក់រឿងក្ដីនេះ")។ X និង Y បានព្រមព្រៀងគ្នាទៅលើពេលវេលានៃការបង់ប្រាក់ថ្លៃលក់ថា នៅពេលដាក់ពាក្យសុំចុះបញ្ជីផ្ទេរកម្មសិទ្ធិទាំងមូល នឹងបង់ប្រាក់ ចំនួន ៥០.០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិច ហើយប្រាក់ចំនួន ៥០.០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិច ដែលនៅសល់នឹងបង់នៅក្នុងអំឡុងពេល ១ ខែ គិតចាប់ពីពេលដែលបានដាក់ពាក្យសុំចុះបញ្ជីផ្ទេរកម្មសិទ្ធិទាំងមូល។

B. X និង Y បានធ្វើលិខិតយថាភូត (លិខិតលក់ផ្ដាច់) ចំពោះ "កិច្ចសន្យាលក់ទិញរឿងក្ដីនេះ" ហើយបានដាក់ពាក្យសុំចុះបញ្ជីផ្ទេរកម្មសិទ្ធិទាំងមូលនៅសុរិយោដីរាជធានីភ្នំពេញ នៅថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២១។ Y បានបង់ប្រាក់ថ្លៃលក់ចំនួន ៥០.០០០ (ប្រាំម៉ឺន) ដុល្លារអាមរិច ទៅឱ្យ X នៅថ្ងៃដដែលនេះ។ នៅថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០២១ "ដី L" ត្រូវបានចុះបញ្ជីផ្ទេរកម្មសិទ្ធិទាំងមូលពី X ទៅ Y។

C. X បានប្រគល់ "ដី L" ទៅឱ្យ Y នៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២១។ Y បានចូលទៅរស់នៅក្នុងអាគារដែលមាននៅលើ "ដី L" ចាប់ពីថ្ងៃទី១ ខែតុលា ឆ្នាំ២០២១។

D. Y មិនបានបង់ប្រាក់ចំនួន ៥០.០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិច ដែលនៅសល់នោះទេ ទោះបីជាថ្ងៃទី១ ខែតុលា ឆ្នាំ២០២១ បានកន្លងផុតទៅក៏ដោយ ដូច្នេះ នៅថ្ងៃទី១១ ខែតុលា ឆ្នាំ២០២១ X បានដាស់តឿនទៅ Y ឱ្យបង់ប្រាក់ដែលនៅសល់ចំនួន ៥០.០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិច ដែលនៅសល់ក្នុងអំឡុងពេល ២ សប្ដាហ៍ ព្រមទាំងបានបង្ហាញឆន្ទៈនូវខ្លឹមសារថា ប្រសិនបើមិនបង់ប្រាក់ថ្លៃលក់នៅក្នុងអំឡុងពេល ២ សប្ដាហ៍នេះទេ នឹងរំលាយ "កិច្ចសន្យាលក់ទិញរឿងក្ដីនេះ" ។ ប៉ុន្តែ Y មិនបានបង់ប្រាក់ថ្លៃលក់ដែលនៅសល់ទេ ទោះបីជាអំឡុងពេល ២ សប្ដាហ៍ គិតចាប់ពីថ្ងៃដែលបានដាស់តឿនបានកន្លងផុតក៏ដោយ។

E. X កំពុងពិចារណាទៅលើការដាក់បណ្ដឹងរដ្ឋប្បវេណី ដើម្បីឱ្យ Y ប្រគល់ ដី L មកវិញ។ ប៉ុន្តែ Y មានអាជីវកម្មដែលមិនដំណើរទៅដោយរលូន និងជាប់បំណុលចំនួនទឹកប្រាក់គួរសមដែរ ដែលមានការបារម្ភថាគាត់នឹងលក់ "ដី L" ទៅឱ្យតតិយជន។ម្យ៉ាងទៀត អាគារនៅលើដី L មានការចេញចូលពីមិត្តជិតស្និទ្ធ និងសាច់ញាតិជាអាទិ៍របស់ Y ដែលមានការបារម្ភថាតតិយជនក្រៅពី Y កាន់កាប់លើ "ដី L"។

# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

## ពាក្យសុំឱ្យចេញដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ

### ម្ចាស់បំណុល

ឈ្មោះ ៖ X

អាសយដ្ឋាន ៖ ផ្ទះលេខ ០០ ផ្លូវលេខ ០០ ភូមិ...... សង្កាត់.......ខណ្ឌ......... រាជធានីភ្នំពេញ។[1]

### អ្នកតំណាងដោយអាណត្តិ

ឈ្មោះ៖លោក/លោកស្រី ៖ P

អាសយដ្ឋានការិយាល័យ ៖ .................................

ឈ្មោះការិយាល័យមេធាវី/ក្រុមមេធាវី/ក្រុមហ៊ុនមេធាវី ៖ ..........................................លេខទូរស័ព្ទ ៖ .................................................

**ទីកន្លែងបញ្ជូន** ៖ ការិយាល័យមេធាវី/ ក្រុមមេធាវី/ ក្រុមហ៊ុនមេធាវី[2].................

### កូនបំណុល

ឈ្មោះ ៖ Y

[1] ឈ្មោះ និងអាសយដ្ឋាន មានបញ្ញត្តិនៅក្នុងចំណុច ក កថាខណ្ឌទី ១ មាត្រា ៥៤១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ប៉ុន្តែចំពោះចំណុចផ្សេងទៀត ដូចជា ថ្ងៃខែឆ្នាំកំណើតជាអាទិ៍ ជាចំណុចដែលពុំមានបញ្ញត្តិក្នុងច្បាប់ទេ។ ប៉ុន្តែ ក៏មានករណីដែលពុំអាចកំណត់អំពីភាគី តាមរយៈឈ្មោះ និង អាសយដ្ឋានបានផងដែរ។ ក្នុងករណីនេះ ត្រូវសរសេរចំណុចទាំងនោះក្នុងកម្រិតមួយដែលចាំបាច់ ដើម្បីអាចកំណត់អំពីភាគីបាន។

[2] យោងមាត្រា ៥៣៩, មាត្រា ២៤៩ និងមាត្រា ២៥០ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ ការសរសេរអំពីទីកន្លែងបញ្ជូនមិនមែនជាករណីយកិច្ចទេ។ ប្រសិនបើមិនសរសេរទីកន្លែងបញ្ជូន នោះការបញ្ជូន នឹងបញ្ជូនទៅអាសយដ្ឋានរបស់ម្ចាស់បំណុល ជាអាទិ៍។ ហេតុដូច្នេះ ករណីដែលអ្នកតំណាងដោយអាណត្តិរបស់ ម្ចាស់បំណុលមានបំណងចង់ឱ្យធ្វើការបញ្ជូនទៅទីកន្លែងក្រៅពីអាសយដ្ឋានរបស់ម្ចាស់បំណុល ជាអាទិ៍ ចាំបាច់ត្រូវសរសេរទីកន្លែងបញ្ជូនជាលាយល័ក្ខណ៍អក្សរដូចជានៅក្នុងពាក្យសុំ ជាអាទិ៍។

អាសយដ្ឋាន៖ ផ្ទះលេខ ០០ ផ្លូវលេខ ០០ ភូមិ...... សង្កាត់.......ខណ្ឌ......... រាជធានីភ្នំពេញ។

**សូមគោរពជូន**
**ឯកឧត្តម/លោកជំទាវប្រធានសាលាដំបូងរាជធានីភ្នំពេញ**[3]

## ក. ខ្លឹមសារនៃដីកាសម្រេចរក្សាការពារដែលអ្នកដាក់ពាក្យសុំទាមទារ៖[4]

[3] រឿងក្តីនៃដីកាសម្រេចរក្សាការពារ ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់តុលាការដែលមានសមត្ថកិច្ចលើអង្គសេចក្តី ឬ សាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងវត្ថុដែលនឹងត្រូវរឹបអូសជាបណ្តោះអាសន្ន ឬ វត្ថុដែលជាកម្មវត្ថុនៃវិវាទស្ថិតនៅ (កថាខណ្ឌទី១ មាត្រា ៥៤០ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

នៅក្នុងរឿងក្តីនេះ ដោយសារតែលំនៅដ្ឋានរបស់កូនបំណុលនៅរាជធានីភ្នំពេញ ដូច្នេះ សាលាដំបូងរាជធានីភ្នំពេញ មានសមត្ថកិច្ចនៃរឿងក្តីនេះ (ចំណុច ក មាត្រា ៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ ម្យ៉ាងទៀត រឿងក្តីនេះ ជា "បណ្តឹងទាក់ទងនឹងការចុះបញ្ជី" ដែលទាមទារឱ្យធ្វើនីតិវិធីចុះបញ្ជីលុបការចុះបញ្ជីផ្ទេរកម្មសិទ្ធិ ដូច្នេះ តុលាការដែលស្ថិតនៅ "កន្លែងដែលត្រូវចុះបញ្ជី" ក៏មានសមត្ថកិច្ចផងដែរ (ចំណុច ជ មាត្រា ៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ "កន្លែងដែលត្រូវចុះបញ្ជី" គឺ "រដ្ឋបាលសុរិយោដីថ្នាក់រាជធានី ខេត្ត ដែលអចលនវត្ថុតាំងនៅ" (កថាខណ្ឌទី២ ប្រការ ៥ នៃប្រកាសអន្តរក្រសួងស្តីពីនីតិវិធីនៃការចុះបញ្ជីអំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី)។ នៅក្នុងរឿងក្តីនេះ ដោយសារតែអចលនវត្ថុស្ថិតនៅរាជធានីភ្នំពេញ ដូច្នេះ រដ្ឋបាលសុរិយោដីនៅរាជធានីភ្នំពេញ គឺជា "ទីកន្លែងដែលត្រូវចុះបញ្ជី" ហើយនៅក្នុងខ្លឹមសារនៃសមត្ថកិច្ចនេះ គឺសាលាដំបូងរាជធានីភ្នំពេញ មានសមត្ថកិច្ចលើរឿងក្តីនេះ។ លើសពីនេះទៅទៀត រឿងក្តីនេះ គឺជា "បណ្តឹងទាក់ទងនឹងអចលនវត្ថុ" ដែលទាមទារឱ្យប្រគល់អចលនវត្ថុ ដូច្នេះ តុលាការដែលអចលនវត្ថុស្ថិតនៅ ក៏មានសមត្ថកិច្ចផងដែរ (ចំណុច ឆ មាត្រា ៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ នៅក្នុងរឿងក្តីនេះ គឺអចលនវត្ថុ មានទីតាំងនៅក្នុងរាជធានីភ្នំពេញ ហេតុដូច្នេះ នៅក្នុងខ្លឹមសារនៃសមត្ថកិច្ចនេះ ក៏សាលាដំបូងរាជធានីភ្នំពេញ មានសមត្ថកិច្ចលើរឿងក្តីនេះផងដែរ។ ដូចដែលបានរៀបរាប់ដូចខាងលើ សាលាដំបូងរាជធានីភ្នំពេញ ជា "តុលាការដែលមានសមត្ថកិច្ចលើរឿងក្តីនេះ" ហើយមានសមត្ថកិច្ចលើរឿងក្តីឱ្យចេញដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន។

ម្យ៉ាងទៀត នៅក្នុងរឿងក្តីនេះ អចលនវត្ថុដែលជាកម្មវត្ថុនៃវិវាទ មានទីតាំងនៅក្នុងរាជធានីភ្នំពេញ ហេតុដូច្នេះ សាលាដំបូងរាជធានីភ្នំពេញ ជា "តុលាការដែលមានសមត្ថកិច្ចលើទីតាំងនៃវត្ថុដែលជាកម្មវត្ថុនៃវិវាទ" ហើយនៅក្នុងខ្លឹមសារនេះ ក៏សាលាដំបូងរាជធានីភ្នំពេញ មានសមត្ថកិច្ចលើរឿងក្តីឱ្យចេញដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នផងដែរ។

[4] ខ្លឹមសារនៃដីកាសម្រេចរក្សាការពារដែលអ្នកពាក្យសុំទាមទារ ជាចំណុចត្រូវសរសេរជាចាំបាច់នៅក្នុងពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ (ចំណុច ខ កថាខណ្ឌទី ១ មាត្រា ៥៤១ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

១. ហាមឃាត់មិនឱ្យកូនបំណុលធ្វើអនុប្បទាននូវកម្មសិទ្ធិ ឬ បង្កើតសិទ្ធិប្រាតិភោគ (សិទ្ធិបញ្ចាំ ឬ ហ៊ីប៉ូតែក ជាអាទិ៍) ឬ សិទ្ធិជួល ឬ ការចាត់ចែងផ្សេងទៀត ចំពោះអចលនវត្ថុ ដូចមានសរសេរនៅក្នុងបញ្ជីឧបសម្ព័ន្ធអំពីវត្ថុ ជាបណ្ដោះអាសន្ន។[5]

២. ហាមឃាត់មិនឱ្យកូនបំណុលផ្ទេរការកាន់កាប់ចំពោះអចលនវត្ថុ ដូចមានសរសេរនៅក្នុងបញ្ជីឧបសម្ព័ន្ធអំពីវត្ថុ ជាបណ្ដោះអាសន្ន។[6]

បង្គាប់ឱ្យកូនបំណុលប្រគល់អចលនវត្ថុ ដូចមានសរសេរនៅក្នុងបញ្ជីឧបសម្ព័ន្ធអំពីវត្ថុ ទៅឱ្យ អាជ្ញាសាលា ។

បង្គាប់ឱ្យអាជ្ញាសាលាថែរក្សាគ្រប់គ្រងអចលនវត្ថុ ដូចមានសរសេរក្នុងបញ្ជីឧបសម្ព័ន្ធអំពីវត្ថុ។

អាជ្ញាសាលា ត្រូវប្រកាសជាសាធារណៈថា កូនបំណុលត្រូវបានហាមឃាត់ការផ្ទេរការកាន់កាប់ចំពោះអចលនវត្ថុដូចមានសរសេរនៅក្នុងបញ្ជីឧបសម្ព័ន្ធអំពីវត្ថុ ហើយអាជ្ញាសាលាថែរក្សាគ្រប់គ្រងចំពោះអចលនវត្ថុដូចមានសរសេរនៅក្នុងបញ្ជីឧបសម្ព័ន្ធអំពីវត្ថុ ដោយលិខិតបិទប្រកាសជាសាធារណៈ តាមរបៀបដែលពុំងាយបកចេញ ឬ តាមរបៀបសមរម្យផ្សេងទៀត។

---

[5] ខ្លឹមសារនៃដីកាសម្រេចរក្សាការពារដែលអ្នកដាក់ពាក្យសុំទាមទារ នៅក្នុងកថាខណ្ឌទី ១ គឺជាការចាត់ចែងជាបណ្ដោះអាសន្នដែលហាមឃាត់ការចាត់ចែង ដើម្បីរក្សាការពារសិទ្ធិទាមទារចុះបញ្ជីទាក់ទងនឹងអចលនវត្ថុនៅក្នុងចំណោមការចាត់ចែងជាបណ្ដោះអាសន្នទាក់ទងនឹងវត្ថុដែលជាកម្មវត្ថុនៃវិវាទ (ចំណុច ខ មាត្រា ៥៣១ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

[6] ខ្លឹមសារនៃដីកាសម្រេចរក្សាការពារដែលអ្នកដាក់ពាក្យសុំទាមទារ នៅក្នុងកថាខណ្ឌទី២ គឺជាការចាត់ចែងជាបណ្ដោះអាសន្នដែលហាមឃាត់ការផ្ទេរការកាន់កាប់ ដើម្បីរក្សាការពារសិទ្ធិទាមទារឱ្យប្រគល់អចលនវត្ថុ នៅក្នុងចំណោមការចាត់ចែងជាបណ្ដោះអាសន្នទាក់ទងនឹងវត្ថុដែលជាកម្មវត្ថុនៃវិវាទ (ចំណុច ខ មាត្រា ៥៣១ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ ការចាត់ចែងដែលហាមឃាត់ការផ្ទេរការកាន់កាប់ មានខ្លឹមសារថាជាការហាមឃាត់មិនឱ្យកូនបំណុលផ្ទេរការកាន់កាប់វត្ថុដែលជាកម្មវត្ថុនៃវិវាទ និងបង្គាប់ឱ្យកូនបំណុលប្រគល់វត្ថុទៅអាជ្ញាសាលា ដោយដកហូតការកាន់កាប់នោះ ហើយបង្គាប់ឱ្យអាជ្ញាសាលាថែរក្សាគ្រប់គ្រងវត្ថុដែលជាកម្មវត្ថុនៃវិវាទនោះ ព្រមទាំងអាជ្ញាសាលាត្រូវប្រកាសជាសាធារណៈថា កូនបំណុលត្រូវបានហាមឃាត់ការផ្ទេរការកាន់កាប់វត្ថុដែលជាកម្មវត្ថុនៃវិវាទនោះ ហើយអាជ្ញាសាលាថែរក្សាគ្រប់គ្រងវត្ថុដែលជាកម្មវត្ថុនៃវិវាទនោះ (កថាខណ្ឌទី១ មាត្រា ៥៧១ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ ម្យ៉ាងទៀត ករណីដែលអនុញ្ញាតឱ្យកូនបំណុលប្រើប្រាស់វត្ថុដែលជាកម្មវត្ថុនៃវិវាទ ក៏ត្រូវបង្គាប់រួមទាំងខ្លឹមសារនេះផងដែរ។

បង្គាប់ឱ្យអាជ្ញាសាលាត្រូវអនុញ្ញាតឱ្យកូនបំណុលប្រើប្រាស់អចលនវត្ថុដូចមានសរសេរនៅក្នុងបញ្ជីឧបសម្ព័ន្ធអំពីវត្ថុ។

## ខ. សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារ[7]

### ខ.១ ការបង្កើតកិច្ចសន្យាលក់ទិញ

**ខ.១.១** ម្ចាស់បំណុល បានលក់អចលនវត្ថុដូចមានសរសេរនៅក្នុងបញ្ជីឧបសម្ព័ន្ធអំពីវត្ថុ ដែលស្ថិតនៅក្រោមកម្មសិទ្ធិរបស់ខ្លួន ទៅឱ្យកូនបំណុល ក្នុងតម្លៃ ១០០.០០០ (ដប់ម៉ឺន) ដុល្លារអាមេរិច នៅថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២១ (តទៅហៅថា "កិច្ចសន្យាលក់ទិញនៃរឿងក្តីនេះ")។ **(ភស្តុតាង $X_1$)**[8]

**ខ.១.២** ម្ចាស់បំណុល និង កូនបំណុល បានបង្កើតលិខិតយថាភូត (លិខិតលក់ផ្តាច់) ទៅលើ "កិច្ចសន្យាលក់ទិញនៃរឿងក្តីនេះ"។ **(ភស្តុតាង $X_2$)**

**ខ.១.៣** ម្ចាស់បំណុល និង កូនបំណុល បានព្រមព្រៀងគ្នាទៅលើកាលបរិច្ឆេទនៃការបង់ប្រាក់ថ្លៃលក់នៅក្នុង "កិច្ចសន្យាលក់ទិញនៃរឿងក្តីនេះ" ដែលមានសេចក្តីដូចខាងក្រោមៈ

i. ចំពោះប្រាក់ ចំនួន ៥០.០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិច ដែលជាប្រាក់ពាក់កណ្តាលនៃប្រាក់ថ្លៃលក់ ត្រូវបង់នៅពេលដែលបានដាក់ពាក្យសុំចុះបញ្ជីផ្ទេរកម្មសិទ្ធិទាំងមូល។

---

[7] សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារ ជាចំណុចត្រូវសរសេរជាចាំបាច់ក្នុងពាក្យសុំឱ្យចេញនៃដីកាសម្រេចរក្សាការពារ (ចំណុច គ កថាខណ្ឌទី ១ មាត្រា ៥៤១ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ ហើយចំណុចនេះត្រូវសរសេរឱ្យបានលម្អិតនូវអង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវសិទ្ធិ និងអង្គហេតុដែលជាមូលហេតុនៃសិទ្ធិ។ ម្យ៉ាងទៀត ដើម្បីឱ្យដីកាសម្រេចចេញបានដោយយ៉ាងឆាប់រហ័ស និងការកំណត់ចំនួនទឹកប្រាក់ប្រាតិភោគឱ្យបានទាបតាមដែលអាចធ្វើបាន គួរតែសរសេរនូវការតវ៉ាតបចំពោះការតវ៉ាដែលនឹងត្រូវបានរំពឹងទុក។

[8] អំពីសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារ (ចំណុច គ កថាខណ្ឌទី ១ មាត្រា ៥៤១ នៃក្រមនីតិវិធីរដ្ឋប្បវេណី) និងភាពចាំបាច់នៃការរក្សាការពារ (ចំណុច ឃ កថាខណ្ឌទី ១ មាត្រា ៥៤១ នៃក្រមនីតិវិធីរដ្ឋប្បវេណី) គួរតែខិតខំប្រឹងប្រែងសរសេរនូវភស្តុតាងតាមហេតុនីមួយៗដែលត្រូវបញ្ជាក់ (កថាខណ្ឌទី ២ មាត្រា ៥៤១ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

ii. ចំពោះប្រាក់ ចំនួន ៥០.០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិច ដែលជាប្រាក់ថ្លៃលក់នៅសល់ ត្រូវបង់នៅក្នុងអំឡុងពេល ១ (មួយ) ខែ គិតចាប់ពីពេលដែលបានដាក់ពាក្យសុំចុះបញ្ជីផ្ទេរកម្មសិទ្ធិទាំងមូល។

## ខ.២ ការរំលាយកិច្ចសន្យាលក់ទិញដោយសារមូលហេតុនៃការមិនអនុវត្តកាតព្វកិច្ចរបស់ចុងចម្លើយ

**ខ.២.១** ម្ចាស់បំណុល និង កូនបំណុល បានដាក់ពាក្យសុំចុះបញ្ជីផ្ទេរកម្មសិទ្ធិទាំងមូលនៅរដ្ឋបាលសុរិយោដីរាជធានីភ្នំពេញ ដោយផ្អែកតាម "កិច្ចសន្យាលក់ទិញនៃរឿងក្តីនេះ" នៅថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២១។ **(ភស្តុតាង $X_2$)**

កូលបំណុលបានបង់ប្រាក់ថ្លៃលក់ចំនួន ៥០.០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិក ទៅលើដី L ទៅឱ្យម្ចាស់បំណុល ដោយផ្អែកតាម "កិច្ចសន្យាលក់ទិញរឿងក្តីនេះ" នៅថ្ងៃដដែលនេះ។ **(ភស្តុតាង $X_3$)**

**ខ.២.៣** នៅថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០២១ "ដី L" ត្រូវបានចុះបញ្ជីផ្ទេរកម្មសិទ្ធិទាំងមូលពីម្ចាស់បំណុលទៅកូនបំណុល។ **(ភស្តុតាង $X_4$)**

**ខ.២.៤** ម្ចាស់បំណុល បានប្រគល់ "ដី L" ទៅកូនបំណុល នៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២១។ កូនបំណុល កំពុងរស់នៅលើ "ដី L" និង កំពុងកាន់កាប់ "ដី L" ចាប់ពីថ្ងៃទី១ ខែតុលា ឆ្នាំ២០២១។ **(ភស្តុតាង $X_{6,7}$)**

**ខ.២.៥** ថ្ងៃទី១ ខែតុលា ឆ្នាំ២០២១ បានកន្លងផុត។

**ខ.២.៦** ម្ចាស់បំណុល បានដាស់តឿន[9]ឱ្យកូនបំណុលបង់ប្រាក់ថ្លៃលក់ដែលនៅសល់ចំនួន ៥០.០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិច ក្នុងអំឡុងពេល ២ (ពីរ) សប្តាហ៍ នៅថ្ងៃទី១១ ខែតុលា ឆ្នាំ២០២១ ព្រមទាំងបានបង្ហាញឆន្ទៈ[10] នូវខ្លឹមសាថានឹងរំលាយ "កិច្ចសន្យាលក់ទិញ

---

[9] ចំណុច ក កថាខណ្ឌទី ១ មាត្រា ៤០៨ នៃក្រមរដ្ឋប្បវេណី។ ការរំលាយដោយមូលហេតុនៃការមិនអនុវត្តកាតព្វកិច្ច សូមយោងឯកសារនៅក្នុងសិក្ខាសាលាជុំទី៣។

[10] ចំណុច គ កថាខណ្ឌទី ១ មាត្រា ៤០៩ នៃក្រមរដ្ឋប្បវេណី។ ការរំលាយដោយមូលហេតុនៃការមិនអនុវត្តកាតព្វកិច្ច សូមយោងឯកសារនៅក្នុងសិក្ខាសាលាជុំទី ៣។

នៃរឿងក្តីនេះ" នៅពេល ដែលកូនបំណុលមិនបង់ប្រាក់ថ្លៃលក់ក្នុងអំឡុងពេល ២ (ពីរ) សប្តាហ៍។ (**ភស្តុតាង X$_7$**)

**ខ.២.៧** កូនបំណុល មិនបានបង់ប្រាក់ថ្លៃលក់ដែលនៅសល់ ចំនួន ៥០.០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិច ត្រឹមថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២១ នោះទេ។

## ខ.៣ ការសន្និដ្ឋានអំពី សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារ

ហេតុដូច្នេះ ម្ចាស់បំណុល មានសិទ្ធិទាមទារឱ្យចុះបញ្ជីលុបការចុះបញ្ជីផ្ទេរកម្មសិទ្ធិចំពោះ "ដី L" ដោយផ្អែកតាមការរំលាយ "កិច្ចសន្យាលក់ទិញនៃរឿងក្តីនេះ" ចំពោះកូនបំណុល (កថាខណ្ឌទី២ មាត្រា៥១១ នៃក្រមរដ្ឋប្បវេណី)។[11] ម្យ៉ាងទៀត ម្ចាស់បំណុល មានសិទ្ធិទាមទារឱ្យប្រគល់ "ដី L" ដោយផ្អែកតាមការរំលាយ "កិច្ចសន្យាលក់ទិញនៃរឿងក្តីនេះ" (កថាខណ្ឌទី២ មាត្រា៥១១ នៃក្រមរដ្ឋប្បវេណី)។[12]

## គ. ភាពចាំបាច់នៃការរក្សាការពារ[13]

---

[11] នេះគឺជាសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារនៃការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការចាត់ចែង។ សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារនៃការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការចាត់ចែង គឺជាសិទ្ធិទាមទារតាវកាលិកទាក់ទងនឹងវត្ថុដែលកម្មវត្ថុនៃវិវាទ ដែលផ្តោតសំខាន់ទៅលើសិទ្ធិទាមទារ ឱ្យចុះបញ្ជី។

[12] នេះគឺជាសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារនៃការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការកាន់កាប់។ សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារនៃការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការកាន់កាប់ គឺជាសិទ្ធិទាមទារឱ្យប្រគល់វត្ថុដែលជាកម្មវត្ថុនៃវិវាទ។ វាមិនត្រឹមតែជាសិទ្ធិទាមទារដោយផ្អែកលើសិទ្ធិនៃកម្មសិទ្ធិ ជាអាទិ៍ នោះទេ វាក៏ជាសិទ្ធិទាមទារលើបំណុលផងដែរ។

[13] ភាពចាំបាច់នៃការរក្សាការពារ ជាចំណុចត្រូវសរសេរជាចាំបាច់ក្នុងពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ (ចំណុច ឃ កថាខណ្ឌទី ១ មាត្រា ៥៤១ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ នៅពេលដាក់ពាក្យសុំចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការផ្ទេរការកាន់កាប់ ចាំបាច់ត្រូវមានការបារម្ភថា ការអនុវត្តសិទ្ធិនឹងមិនអាចធ្វើបាន ឬ នឹងមានការលំបាកយ៉ាងខ្លាំង ដោយសារតែការផ្លាស់ប្តូរអ្នកកាន់កាប់។ នៅពេលដាក់ពាក្យសុំចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការចាត់ចែង ចាំបាច់ត្រូវមានការបារម្ភថា ការអនុវត្តសិទ្ធិនាពេលអនាគត នឹងមិនអាចធ្វើបាន ឬ នឹងមានការលំបាកយ៉ាងខ្លាំង ដោយសារតែគ្រោះថ្នាក់កើតចេញពីការផ្លាស់ប្តូរស្ថានភាពបច្ចុប្បន្ន ដូចជាអនុប្បទាន ឬ ការបង្កើតសិទ្ធិប្រាតិភោគចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ ដែលបានធ្វើឡើងដោយកូនបំណុល។

**គ.១** ម្ចាស់បំណុល កំពុងត្រៀមរៀបចំដាក់បណ្ដឹងរដ្ឋប្បវេណី ដើម្បីសម្រេចនូវសិទ្ធិនីមួយៗដែលបានសរសេរនៅក្នុង ខ.៣។

**គ.២** ប៉ុន្តែ យោងតាមដែលម្ចាស់បំណុលបានសួរ និងឮពីអ្នកដែលបានស្គាល់កូនបំណុលថា កូនបំណុល មានអាជីវកម្មដែលមិនបានដំណើរទៅដោយយ៉ាងរលូននោះទេ និងមានជាប់ជំពាក់ប្រាក់កម្ចីក្នុងចំនួនច្រើនគួរសម ទើបនាំឱ្យមានការបារម្ភយ៉ាងខ្លាំងដែលកូនបំណុលនឹងចាត់ចែង "ដី L"។ **(ភស្តុតាង $X_7$)**

**គ.៣** ម្យ៉ាងទៀត កូនបំណុលកំពុងរស់នៅក្នុងអាគារលើ "ដី L" ក៏ពិតមែន ប៉ុន្តែជាញឹកញាប់ កូនបំណុលមិននៅក្នុងអាគារនោះទេ ហើយនៅក្នុងអំឡុងពេលដែលកូនបំណុលមិននៅ មានបុគ្គលដែលហាក់ដូចជាសាច់ញាតិ ឬ មិត្តភក្តិជិតស្និទ្ធរបស់កូនបំណុលចេញចូលអាគារនោះ។ ចំពោះស្ថានភាពបែបនេះ គឺមានការបារម្ភថា កូនបំណុលងាយនឹងផ្ទេរការកាន់កាប់ "ដី L" ទៅឱ្យតតិយជន។ **(ភស្តុតាង $X_7$)**

**គ.៤** ប្រសិនបើការបារម្ភទាំងនោះនឹងក្លាយជាការពិត នាំឱ្យម្ចាស់បំណុលទោះបីជាទទួលបានសាលក្រមឈ្នះលើបណ្ដឹងអង្គសេចក្ដី ក៏នឹងមិនអាចធ្វើបាន ឬ នឹងមានការលំបាកយ៉ាងខ្លាំងក្នុងអនុវត្តសិទ្ធិទាំងនោះ។

## ឃ. ភស្តុតាង[14]

១. លិខិតលក់ផ្ដាច់ ចុះនៅថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២១ **(ភស្តុតាង $X_1$)**

២. ឯកសារថតចម្លងពាក្យសុំចុះបញ្ជីផ្ទេរកម្មសិទ្ធិទាំងមូល **(ភស្តុតាង $X_2$)**

៣. វិក័យប័ត្រទទួល **(ភស្តុតាង $X_3$)**

៤. ឯកសារចម្លងដែលមានសេចក្ដីបញ្ជាក់នៃសៀវភៅគោលបញ្ជីដីធ្លី **(ភស្តុតាង $X_4$)**

៥. រូបថត (សារនៅក្នុង Telegram ដែលត្រូវបានបញ្ជូន និងទទួល រវាងម្ចាស់បំណុល និងកូនបំណុល នៅថ្ងៃទី១១ ខែតុលា ឆ្នាំ២០២១) **(ភស្តុតាង $X_5$)**

---

[14] អំពីសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារ (ចំណុច គ កថាខណ្ឌទី ១ មាត្រា ៥៤១ នៃក្រមនីតិវិធីរដ្ឋប្បវេណី) និងភាពចាំបាច់នៃការរក្សាការពារ (ចំណុច ឃ កថាខណ្ឌទី ១ មាត្រា ៥៤១ នៃក្រមនីតិវិធីរដ្ឋប្បវេណី) មានភាពចាំបាច់ត្រូវភ្ជាប់នូវឯកសារដើម្បីធ្វើសេចក្ដីបញ្ជាក់ដំបូង (កថាខណ្ឌទី ៣ មាត្រា ៥៤១ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

៦. រូបថត (ស្ថានភាពកាន់កាប់ ដី L នាពេលបច្ចុប្បន្ន) **(ភស្តុតាង $X_6$)**

៧. របាយការណ៍ **(ភស្តុតាង $X_7$)**

សេចក្តីដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តម/លោកជំទាវប្រធាន** សម្រេចតាមការស្នើសុំដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តម/លោកជំទាវប្រធាន** ទទួលនូវសេចក្តីគោរពដ៏ជ្រាលជ្រៅអំពីខ្ញុំ។

រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែធ្នូ ឆ្នាំ ២០២១

**អ្នកតំណាងដោយអាណត្តិ**

<u>ឯកសារភ្ជាប់</u>

១-លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ "ច្បាប់ដើម"

២-ច្បាប់ថតចម្លងនៃភស្តុតាងនីមួយៗខាងលើ "ចំនួន ០១ ច្បាប់"

P

**ឧបសម្ព័ន្ធ**

## បញ្ជីឧបសម្ព័ន្ធអំពីវត្ថុ

"ទីតាំងដី" ផ្លូវលេខ ០០ ភូមិ...... សង្កាត់.......ខណ្ឌ.........រាជធានីភ្នំពេញ

"លេខឡូត៍" ០០

"សមាសភាពនៃដីខាងលើ" អាគារ (ផ្ទះ)

លេខ៖ 00

ប្រភេទ៖ សម្រាប់លំនៅដ្ឋាន

លក្ខណៈនៃអាគារ៖ ធ្វើពីថ្មឥដ្ឋ

ទំហំអាគារ៖ 00 $m^2$

# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

សំណុំរឿងរក្សាការពារលេខៈ 00

ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២១

ដីកាសម្រេចលេខៈ00

ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២១

## ដីកាសម្រេចចាត់ចែងបណ្ដោះអាសន្ន[1]

យើង J ជាចៅក្រមនៃសាលាដំបូងរាជធានីភ្នំពេញ

- បានឃើញ ចំណុច ក មាត្រា ៥៣១, មាត្រា ៥៤២, កថាខណ្ឌទី ១ មាត្រា ៥៤៨, មាត្រា ៥៤៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី។[2]
- បានឃើញពាក្យសុំឱ្យចេញដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្នចំពោះ អចលនវត្ថុ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២១។

[1] ការសម្រេចសេចក្ដី មាន សាលក្រម និង ដីកាសម្រេច (មាត្រា១៧៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ដូច្នេះ គឺមានភាពចាំបាច់ដែលត្រូវសសេរប្រភេទនៃការសម្រេចសេចក្ដីនៅក្នុងក្បាលដើមនៃឯកសារ។ ពីព្រោះថា វិធីនៃឧបាស្រ័យជាអាទិ៍ មានភាពខុសគ្នារវាង សាលក្រម និងដីកាសម្រេច។ បណ្ដឹងឧបាស្រ័យចំពោះសាលក្រមរបស់សាលាដំបូងជាគោលការណ៍ គឺត្រូវធ្វើឡើងជាបណ្ដឹងឧទ្ធរណ៍ ចំណែកឯ បណ្ដឹងឧបាស្រ័យចំពោះដីកាសម្រេច គឺត្រូវឡើងជាបណ្ដឹងជំទាស់ (កថាខណ្ឌទី ១ មាត្រា ២៥៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ ចំពោះដីកាសម្រេចរក្សាការពារកូនបំណុល អាចដាក់ពាក្យសុំតវ៉ាទៅតុលាការដែលបានចេញដីកាសម្រេចនោះ (មាត្រា ៥៥០ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

ម្យ៉ាងទៀត នៅក្នុងដីកាសម្រេចរក្សាការពារ មានដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន និងដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន ដូច្នេះ គឺមានការចាំបាច់កំណត់ឱ្យបានច្បាស់លាស់ថាជាដីកាសម្រេចណាមួយ។

[2] នៅពេលដែលយោងក្រមនីតិវិធីរដ្ឋប្បវេណី គួរតែសរសេរឱ្យបានលម្អិតត្រឹមតែលេខមាត្រាដែលត្រូវអនុវត្ត។

**ម្ចាស់បំណុល**

ឈ្មោះ ៖ X

អាសយដ្ឋាន ៖ ផ្ទះលេខ ០០ ផ្លូវលេខ ០០ ភូមិ...... សង្កាត់.......ខណ្ឌ.........រាជធានីភ្នំពេញ។

**អ្នកតំណាងដោយអាណត្តិ**

ឈ្មោះ៖លោក/លោកស្រី ៖ P

អាសយដ្ឋានការិយាល័យ ៖ ..................................

ឈ្មោះការិយាល័យមេធាវី/ក្រុមមេធាវី/ក្រុមហ៊ុនមេធាវី ៖ ..........................................លេខទូរស័ព្ទ ៖ ..................................................

**កូនបំណុល**

ឈ្មោះ ៖ Y

អាសយដ្ឋាន៖ផ្ទះលេខ ០០ ផ្លូវលេខ ០០ ភូមិ...... សង្កាត់.......ខណ្ឌ.........រាជធានីភ្នំពេញ។

**ខ្លឹមសារនៃដីកាសម្រេចរក្សាការពារដែលអ្នកដាក់ពាក្យសុំទាមទារ**[3]

១. ហាមឃាត់មិនឱ្យកូនបំណុលធ្វើអនុប្បទាននូវកម្មសិទ្ធិ ឬ បង្កើតសិទ្ធិប្រាតិភោគ (សិទ្ធិបញ្ចាំ ឬ ហ៊ីប៉ូតែក ជាអាទិ៍) ឬ សិទ្ធិជួល ឬ ការចាត់ចែងផ្សេងទៀត ចំពោះអចលនវត្ថុ ដូចមានសរសេរនៅក្នុងបញ្ជីឧបសម្ព័ន្ធអំពីវត្ថុ ជាបណ្ដោះអាសន្ន។

២. ហាមឃាត់មិនឱ្យកូនបំណុលផ្ទេរការកាន់កាប់ចំពោះអចលនវត្ថុ ដូចមានសរសេរនៅក្នុងបញ្ជីឧបសម្ព័ន្ធអំពីវត្ថុ ជាបណ្ដោះអាសន្ន។

បង្គាប់ឱ្យកូនបំណុលប្រគល់អចលនវត្ថុ ដូចមានសរសេរនៅក្នុងបញ្ជីឧបសម្ព័ន្ធអំពីវត្ថុទៅឱ្យអាជ្ញាសាលា ។

---

[3] មាត្រា ៥៣៩, មាត្រា ២១៦, ចំណុច ឃ កថាខណ្ឌទី ១ មាត្រា ១៨៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

បង្គាប់ឱ្យអាជ្ញាសាលាថែរក្សាគ្រប់គ្រងអចលនវត្ថុ ដូចមានសរសេរក្នុងបញ្ជីឧបសម្ព័ន្ធអំពីវត្ថុ។

អាជ្ញាសាលា ត្រូវប្រកាសជាសាធារណៈថា កូនបំណុលត្រូវបានហាមឃាត់ការផ្ទេរការកាន់កាប់ចំពោះអចលនវត្ថុដូចមានសរសេរនៅក្នុងបញ្ជីឧបសម្ព័ន្ធអំពីវត្ថុ ហើយ អាជ្ញាសាលាថែរក្សាគ្រប់គ្រងចំពោះអចលនវត្ថុដូចមានសរសេរនៅក្នុងបញ្ជីឧបសម្ព័ន្ធអំពីវត្ថុ ដោយលិខិតបិទប្រកាសជាសាធារណៈ តាមរបៀបដែលពុំងាយបកចេញ ឬ តាមរបៀបសមរម្យផ្សេងទៀត។

បង្គាប់ឱ្យអាជ្ញាសាលាត្រូវអនុញ្ញាតឱ្យកូនបំណុលប្រើប្រាស់អចលនវត្ថុដូចមានសរសេរនៅក្នុងបញ្ជីឧបសម្ព័ន្ធអំពីវត្ថុ។

## សំអាងហេតុ[4]

យោងតាមសំណុំរឿងនៃរឿងក្តីនេះ ទទួលស្គាល់ថាម្ចាស់បំណុលមានសិទ្ធិទាមទារចុះបញ្ជីលុបការចុះបញ្ជីផ្ទេរកម្មសិទ្ធិ និង សិទ្ធិទាមទារឱ្យប្រគល់វិញ ទៅលើអចលនវត្ថុដូចមានសរសេរនៅក្នុងបញ្ជីឧបសម្ព័ន្ធអំពីវត្ថុ ចំពោះកូនបំណុល និងទទួលស្គាល់ផងដែរនូវភាពចាំបាច់នៃដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន ។

ដូច្នេះ តុលាការ ទទួលស្គាល់ថាពាក្យសុំរបស់ម្ចាស់បំណុលគឺសមរម្យ ហើយឱ្យម្ចាស់បំណុលដាក់ប្រាតិភោគចំនួន ៨០.០០០.០០០ (ប៉ែតសិបលាន) រៀល ទើបធ្វើការសម្រេចសេចក្តីដូចខាងក្រោម ដើម្បីរក្សាការពារនូវសិទ្ធិទាមទារចុះបញ្ជីលុបការចុះបញ្ជីផ្ទេរកម្មសិទ្ធិ

---

[4]មាត្រា ៥៣៩, មាត្រា ២១៦, ចំណុច ង កថាខណ្ឌទី ១ មាត្រា ១៨៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ ប្រសិនបើមើលពីគោលគំនិតនៃលក្ខណៈបន្ទាន់បង្ហំ (លក្ខណៈឆាប់រហ័ស) នៃការរក្សាការពារផ្នែករដ្ឋប្បវេណី ដីកាសម្រេចរក្សាការពារ ត្រូវធ្វើឱ្យបានឆាប់រហ័ស ហើយជាពិសេសនៅក្នុងដីកាសម្រេចរឹបអូសជា បណ្តោះអាសន្ន ជាធម្មតា ប្រសិនបើមិនបើកការទាញហេតុផលដោយផ្ទាល់មាត់ និងសួរកូនបំណុលទេ នាំឱ្យការសរសេរនៅក្នុងសំអាងហេតុគ្រាន់តែសរសេរឱ្យមានលក្ខណៈជារួម និងខ្លីៗ គឺគ្រប់គ្រាន់។ ម្យ៉ាងវិញទៀត ករណីដែលមានការស្នើរសុំទៅលើវិធីឱ្យអាជ្ញាសាលាថែរក្សាគ្រប់គ្រងវត្ថុដែលជាកម្មវត្ថុវិវាទ នៅក្នុងចំណោមការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការផ្ទេរការកាន់កាប់ នាំឱ្យជះឥទ្ធិពលយ៉ាងខ្លាំងទៅលើកូនបំណុល ដូច្នេះ គួរតែធ្វើការសាកសួរមិនត្រឹមតែទៅម្ចាស់បំណុលទេ ក៏ត្រូវសាកសួរកូនបំណុលផងដែរ ដើម្បីផ្តល់ឱកាសឱ្យកូនបំណុលធ្វើការអះអាង។ ក្នុងករណីនេះ ត្រូវតែសរសេរសំអាងហេតុឱ្យបានលម្អិតចំពោះករណីដែលបានមិនឱ្យកូនបំណុលធ្វើការអះអាង។

ចំពោះអចលនវត្ថុដូចមាន នៅក្នុងកំណត់បញ្ជីឧបសម្ព័ន្ធនៃវត្ថុដែលបានរៀបរាប់នៅក្នុងចំណុច ១ និង ដើម្បីរក្សាកាពារនូវសិទ្ធិទាមទារឱ្យប្រគល់វិញចំពោះអចលនវត្ថុដូចមានសរសេរនៅក្នុងរៀបរាប់ខាងលើនៅក្នុងចំណុច ២។

## សេចក្តីសម្រេចបញ្ចប់[5]

១.ហាមឃាត់មិនឱ្យកូនបំណុលធ្វើអនុប្បទាននូវកម្មសិទ្ធិ ឬ បង្កើតសិទ្ធិប្រាតិភោគ (សិទ្ធិបញ្ចាំ ឬ ហ៊ីប៉ូតែក ជាអាទិ៍) ឬ សិទ្ធិជួល ឬ ការចាត់ចែងផ្សេងទៀត ចំពោះអចលនវត្ថុ ដូចមានសរសេរនៅក្នុងបញ្ជីឧបសម្ព័ន្ធអំពីវត្ថុ ជាបណ្តោះអាសន្ន។[6]

២.ហាមឃាត់មិនឱ្យកូនបំណុលផ្ទេរការកាន់កាប់ចំពោះអចលនវត្ថុ ដូចមានសរសេរនៅក្នុងបញ្ជីឧបសម្ព័ន្ធអំពីវត្ថុ ជាបណ្តោះអាសន្ន។[7]

បង្គាប់ឱ្យកូនបំណុលប្រគល់អចលនវត្ថុ ដូចមានសរសេរនៅក្នុងបញ្ជីឧបសម្ព័ន្ធអំពីវត្ថុទៅឱ្យអាជ្ញាសាលា ។

បង្គាប់ឱ្យអាជ្ញាសាលាថែរក្សាគ្រប់គ្រងអចលនវត្ថុ ដូចមានសរសេរក្នុងបញ្ជីឧបសម្ព័ន្ធអំពីវត្ថុ។

---

[5] មាត្រា ៥៣៩, មាត្រា ២១៦, ចំណុច ច កថាខណ្ឌទី ១ មាត្រា ១៨៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ ករណីនេះខុសពីការរឹបអូសជាបណ្តោះអាសន្ន ហើយនៅក្នុងការចាត់ចែងជាបណ្តោះអាសន្ន មិនមានការបញ្ញត្តអំពីប្រាក់ដែលកូនបំណុលត្រូវផ្ញើរ (ប្រាក់រំដោះ) ដើម្បីលុបចោលការអនុវត្តនោះទេ។

[6] នៅក្នុងកថាខណ្ឌទី ១ គឺជាការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការចាត់ចែង ដើម្បីរក្សាការពារសិទ្ធិទាមទារឱ្យប្រគល់វិញនូវអចលនវត្ថុ នៅក្នុងចំណោមការចាត់ចែងជាបណ្តោះអាសន្នទាក់ទងនឹងវត្ថុដែលជាកម្មវត្ថុនៃវិវាទ (ចំណុច ខ មាត្រា ៥៣១ នៃ ក្រមនីតិវិធីរដ្ឋប្បវេណី)។

[7] នៅក្នុងកថាខណ្ឌទី២ គឺជាការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការផ្ទេរការកាន់កាប់ ដើម្បីរក្សាការពារទាមទារឱ្យប្រគល់អចលនវត្ថុ នៅក្នុងចំណោមការចាត់ចែងជាបណ្តោះអាសន្នទាក់ទងនឹងវត្ថុដែលជា កម្មវត្ថុនៃវិវាទ (ចំណុច ខ មាត្រា ៥៣១ នៃក្រមនីតិ វិធីរដ្ឋប្បវេណី)។ ការចាត់ចែងដែលហាមឃាត់ការផ្ទេរការកាន់កាប់មានខ្លឹមសារថាជាការហាមឃាត់មិនឱ្យកូនបំណុលផ្ទេរការកាន់កាប់វត្ថុដែលជាកម្មវត្ថុនៃវិវាទ និងបង្គាប់ឱ្យកូនបំណុលប្រគល់វត្ថុទៅអាជ្ញាសាលា ដោយដកហូតការកាន់កាប់នោះ ហើយបង្គាប់ឱ្យអាជ្ញាសាលាថែរក្សាគ្រប់គ្រងវត្ថុដែលជាកម្មវត្ថុនៃវិវាទនោះ ព្រមទាំងអាជ្ញាសាលា ត្រូវប្រកាសជាសាធារណៈថា កូនបំណុលត្រូវបានហាមឃាត់ការផ្ទេរការកាន់កាប់វត្ថុដែលជាកម្មវត្ថុនៃវិវាទនោះ ហើយអាជ្ញាសាលាថែរក្សាគ្រប់គ្រងវត្ថុដែលជាកម្មវត្ថុនៃវិវាទនោះ (កថាខណ្ឌទី ១ មាត្រា ៥៧១ នៃក្រមនីតិវិធីរដ្ឋ ប្បវេណី)។ ម្យ៉ាងទៀត ករណីដែលអនុញ្ញាតឱ្យកូនបំណុលប្រើប្រាស់វត្ថុដែលជាកម្មវត្ថុនៃវិវាទ ក៏ត្រូវបង្គាប់រួមទាំងខ្លឹមសារនេះផងដែរ។

អាជ្ញាសាលា ត្រូវប្រកាសជាសាធារណៈថា កូនបំណុលត្រូវបានហាមឃាត់ការផ្ទេរការកាន់កាប់ចំពោះអចលនវត្ថុដូចមានសរសេរនៅក្នុងបញ្ជីឧបសម្ព័ន្ធអំពីវត្ថុ ហើយ អាជ្ញាសាលាថែរក្សាគ្រប់គ្រងចំពោះអចលនវត្ថុដូចមានសរសេរនៅក្នុងបញ្ជីឧបសម្ព័ន្ធអំពីវត្ថុ ដោយលិខិតបិទប្រកាសជាសាធារណៈ តាមរបៀបដែលពុំងាយបកចេញ ឬ តាមរបៀបសមរម្យផ្សេងទៀត។

បង្គាប់ឱ្យអាជ្ញាសាលាត្រូវអនុញ្ញាតឱ្យកូនបំណុលប្រើប្រាស់អចលនវត្ថុដូចមានសរសេរនៅក្នុងបញ្ជីឧបសម្ព័ន្ធអំពីវត្ថុ។

៣. ប្រាក់ប្រដាប់ក្តី គឺជាបន្ទុករបស់កូនបំណុល។[8]

ដីកាសម្រេចនេះអាចអនុវត្តបានភ្លាម។

ចំពោះដីកាសម្រេចនេះ អាចដាក់ពាក្យសុំតវ៉ាយោងតាមមាត្រា ៥៥០ នៃក្រមនីតិវិធីរដ្ឋប្បវេណីបាន។

ថ្ងៃ ខែ ឆ្នាំ ជូត ទោស័ក ពស ២៥៦៤

រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែធ្នូ ឆ្នាំ ២០២០

**ចៅក្រម**

[8] ទោះបីជាជាមាន ឬ មិនមានពាក្យសុំរបស់ភាគីក៏ដោយ ក៏ត្រូវតែកំណត់អំពីករណីយកិច្ចទទួលបន្ទុកប្រាក់ប្រដាប់ក្តី (មាត្រា ៥៣៩, មាត្រា ២១៦, កថាខណ្ឌទី ៣ មាត្រា ១៨២ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

**ឧបសម្ព័ន្ធ**

# បញ្ជីឧបសម្ព័ន្ធអំពីវត្ថុ

"ទីតាំងដី" ផ្លូវលេខ ០០ ភូមិ...... សង្កាត់.......ខណ្ឌ.........រាជធានីភ្នំពេញ

"លេខឡូត៍" ០០

"សមាសភាពនៃដីខាងលើ" អាគារ (ផ្ទះ)

លេខ៖ 00

ប្រភេទ៖ សម្រាប់លំនៅដ្ឋាន

លក្ខណៈនៃអាគារ៖ ធ្វើពីថ្មឥដ្ឋ

ទំហំអាគារ៖ 00 $m^2$

# ការចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ

## ១. ការចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ

ការចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ គឺជាការចាត់ចែងដែលរក្សាទុកនូវស្ថានភាពបច្ចុប្បន្ន នៃវត្ថុដែលជាកម្មវត្ថុនៃវិវាទ ក្នុងករណីដែលមានការបារម្ភថា ម្ចាស់បំណុលនឹងមិនអាចអនុវត្តសិទ្ធិ ឬនឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តសិទ្ធិ ដោយសារមានការប្រែប្រួលស្ថានភាពបច្ចុប្បន្ននៃវត្ថុនោះ (ចំណុច ខ មាត្រា៥៣១ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ តទៅ ចំពោះមាត្រានៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី នឹងយោងតែលេខមាត្រាទេ។)។

ការរឹបអូសជាបណ្តោះអាសន្ន និងការចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ ដែលប្រភេទទាំងពីរនេះ គឺជាការចាត់ចែងដើម្បីរក្សាស្ថានភាពបច្ចុប្បន្ននូវវត្ថុដែលជាកម្មវត្ថុ ដើម្បីរក្សាការពារក្នុងការសម្រេចឱ្យបាននូវសិទ្ធិដែលនឹងមាននាពេលអនាគត ហើយទាំងពីរនេះមានចំណុចរួមគ្នាជាច្រើន។ ប៉ុន្តែ ការរឹបអូសជាបណ្តោះអាសន្ន មានគោលបំណងរក្សាការពារការអនុវត្តដោយបង្ខំ ចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យសងជាប្រាក់ (សិទ្ធិលើបំណុលជាប្រាក់) ប៉ុន្តែ ផ្ទុយមកវិញ ការចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ មានគោលបំណងរក្សាការពារនូវការអនុវត្តសិទ្ធិនាពេលអនាគតចំពោះសិទ្ធិលើបំណុលមិនមែនជាប្រាក់។ នេះគឺជាចំណុចខុសគ្នាខ្លាំងរវាងការរឹបអូសជាបណ្តោះអាសន្ន និង ការចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ។

## ២. ឧទាហរណ៍តំណាងឱ្យការចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ

### ២.១ ការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ផ្ទេរការកាន់កាប់

ការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ផ្ទេរការកាន់កាប់ គឺជាការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការផ្លាស់ប្តូរការកាន់កាប់ចំពោះកូនបំណុល ដើម្បីរក្សាការពារនូវសិទ្ធិទាមទារឱ្យប្រគល់វត្ថុដែលជាកម្មវត្ថុនៃវិវាទ (មាត្រា៥៧១)។

ឧទាហរណ៍ A បានឱ្យ B ជួលដីដែលខ្លួនមានកម្មសិទ្ធិ ប៉ុន្តែ A បានរំលាយកតិសន្យា ដោយសារតែ B មិនបានបង់ថ្លៃឈ្នួលដែលជួលដី។ ទោះបីជាកតិសន្យាត្រូវបានរំលាយហើយក៏ដោយក្តី ក៏ B មិនប្រគល់ដីទៅឱ្យ A ដោយស្ម័គ្រចិត្តនោះទេ។ ក្នុងករណីនេះ ដើម្បីទទួលបានដីត្រលប់មកវិញ A ត្រូវដាក់បណ្តឹងទាមទារឱ្យប្រគល់ដី

ដោយយក B ជាចុងចម្លើយ ហើយនៅពេលទទួលបានសាលក្រមឈ្នះក្តី A ត្រូវអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ (មាត្រា ៥២៤)។

ប្រសិនបើ A ដាក់បណ្តឹងដោយយក B ជាចុងចម្លើយ ដូចដែលបានរៀបរាប់នៅខាងលើនេះ ទោះបីជា B បានផ្ទេរការកាន់កាប់ដីទៅឱ្យ C ដែលជាតតិយជនក្រោយពេលដែលបានដាក់បណ្តឹងក៏ដោយ ក៏មិនមានឥទ្ធិពលទៅលើបណ្តឹងដែរ (កថាខណ្ឌទី ១ និងកថាខណ្ឌទី ២ នៃមាត្រា ៨៨)។ ប្រសិនបើ A បន្តបណ្តឹងដោយយក B ជាចុងចម្លើយ ហើយទទួលបានសាលក្រមឈ្នះក្តីចំពោះ B នោះ A នឹងទទួលបាននូវការផ្តល់ជារូបមន្តអនុវត្តពិសេស (រូបមន្តអនុវត្តបន្ត) ហើយអាចដាក់ពាក្យសុំអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុចំពោះ C បាន (ចំណុច គ មាត្រា ១៩៨, វាក្យខណ្ឌទី ២ ចំណុច គ កថាខណ្ឌទី ១ មាត្រា ៣៥១, កថាខណ្ឌទី ២ មាត្រា ៣៥៦)។ ប៉ុន្តែ ករណីដែល B ចេញពីដីមួយរយៈដោយបានបន្សល់ទុកនូវចលនវត្ថុដូចជាគ្រឿងសង្ហារឹមជាអាទិ៍ ហើយក្នុង អំឡុងពេលនោះ C បានកាន់កាប់ដោយខុសច្បាប់លើដីនោះ នាំឱ្យ A ទោះបីជាទទួលបានសាលក្រមឈ្នះក្តីចំពោះ B ក៏ដោយ ក៏មិនអាចអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុចំពោះ C បានឡើយ។ ព្រោះ C មិនមែនបន្តកាន់កាប់ពី B នោះទេ ដូច្នេះករណីនេះមិនត្រូវនឹងបុគ្គលដែលទទួលបន្តនូវសិទ្ធិ ឬ កាតព្វកិច្ច (ចំណុច គ មាត្រា ១៩៨, វាក្យខណ្ឌទី ២ ចំណុច គ កថាខណ្ឌទី ១ មាត្រា ៣៥១) នោះទេ ហើយមិនអាចបញ្ចូលនៅក្នុងទំហំនៃបុគ្គលដែលអាចអនុវត្តដោយបង្ខំបានឡើយ។

វិធីដែលជៀសផុតនូវស្ថានភាពខាងលើ A ត្រូវដាក់ពាក្យសុំចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការផ្ទេរការកាន់កាប់ ដើម្បីរក្សាការពារសិទ្ធិទាមទារឱ្យប្រគល់ដីចំពោះ B។ នៅពេលដែលការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការផ្ទេរការកាន់កាប់ត្រូវបានអនុវត្ត ហើយករណីដែល C បានកាន់កាប់ដីទាំងដឹងថាមានការអនុវត្តនោះ នាំឱ្យ A អាចដាក់ពាក្យសុំអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុចំពោះ C ក្រោយពេលទទួលបាននូវការផ្តល់រូបមន្តអនុវត្តពិសេស (រូបមន្តអនុវត្តបន្ត) ដោយផ្អែកតាមសាលក្រមឈ្នះក្តីចំពោះ B បាន។

ម្យ៉ាងទៀត ចំពោះវិធីអនុវត្តការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការផ្ទេរការកាន់កាប់ មានវិធីដែលអនុញ្ញាតឱ្យកូនបំណុលប្រើប្រាស់វត្ថុដែលជាកម្មវត្ថុនៃវិវាទ និងវិធីដែលអាជ្ញាសាលាថែរក្សាគ្រប់គ្រងវត្ថុដែលជាកម្មវត្ថុនៃវិវាទដោយខ្លួនឯង ។

## ២.២ ការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការចាត់ចែង

ការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការចាត់ចែង គឺជាការចាត់ចែងដែលហាមឃាត់ការចាត់ចែងចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទចំពោះកូនបំណុល ដើម្បីរក្សាការពារសិទ្ធិទាមទារតាវកាលិកចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ (ជាពិសេស សិទ្ធិទាមទារឱ្យចុះបញ្ជី)។

ឧទាហរណ៍ A ទិញដីពី B ហើយទោះបីជា A បានបង់ប្រាក់ថ្លៃលក់ទិញរួចក៏ដោយ ក៏ B មិនធ្វើនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិឱ្យ A នោះទេ ករណីនេះប្រសិនបើទុកចោលទាំងបែបនេះ នឹងមានការបារម្ភថា B លក់ដីនោះទៅឱ្យ C ដែលជាតតិយជន និងផ្ទេរការចុះបញ្ជី។ ហេតុដូច្នេះ ក្នុងនាមជា A ត្រូវដាក់ពាក្យសុំចាត់ចែងជាបណ្ដោះអាសន្នដែលហាមឃាត់ការចាត់ចែង ដើម្បីរក្សាការពារសិទ្ធិទាមទារឱ្យចុះបញ្ជីផ្ទេរកម្មសិទ្ធិទាក់ទងដីនោះ។ នៅពេលដែលការចាត់ចែងជាបណ្ដោះអាសន្នដែលហាមឃាត់ការចាត់ចែងត្រូវបានអនុវត្ត ឧបមាថាទោះបីជា B ប្រឆាំងនឹងការហាមឃាត់នោះ ហើយបានចាត់ចែងដីទៅ C នាំឱ្យការចាត់ចែងនោះ មិនអាចតតាំងនឹង A បានទេ។

## ៣. លក្ខខណ្ឌនៃការចាត់ចែងជាបណ្ដោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ

### ៣.១ សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារ

សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារ គឺជាសិទ្ធិទាមទារតាវកាលិកចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ។ សិទ្ធិទាមទារតាវកាលិកចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ ទោះបីជាមានភ្ជាប់នឹងលក្ខខណ្ឌ ឬ ពេលកំណត់ក៏ដោយ ក៏អាចក្លាយជាសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារ (កថាខណ្ឌទី ៣ មាត្រា ៥៤៨, កថាខណ្ឌទី ២ មាត្រា ៥៤៥)។

- សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារនៃការចាត់ចែងជាបណ្ដោះអាសន្នដែលហាមឃាត់ការផ្ទេរការកាន់កាប់ គឺជាសិទ្ធិទាមទារឱ្យប្រគល់វត្ថុដែលជាកម្មវត្ថុនៃវិវាទ។ នេះមិនកំណត់ថាទាល់តែជាសិទ្ធិទាមទារដោយផ្អែកលើសិទ្ធិនៃកម្មសិទ្ធិជាអាទិ៍នោះទេ ទោះបីជាសិទ្ធិទាមទារសិទ្ធិលើបំណុល ក៏អាចធ្វើបាន។ ក្នុងករណីដែលសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារនូវសិទ្ធិទាមទារដោយផ្អែកលើសិទ្ធិនៃកម្មសិទ្ធិជាអាទិ៍ មិនមែនបានន័យថាចាំបាច់ត្រូវតែមានការចុះបញ្ជីនោះទេ ប៉ុន្តែ ប្រសិនបើជាករណីដែលកូនបំណុលត្រូវជា "តតិយជន" ដែលមានបញ្ញត្តនៅក្នុងកថាខណ្ឌទី ១ និង កថាខណ្ឌទី ២ មាត្រា ១៣៤ នៃក្រមរដ្ឋប្បវេណី ចាំបាច់ត្រូវបំពេញក្ខខ័ណ្ឌតតាំងដូចជា ការចុះបញ្ជី ជាអាទិ៍។
- សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារនៃការចាត់ចែងជាបណ្ដោះអាសន្នដែលហាមឃាត់ការចាត់ចែង គឺជាសិទ្ធិទាមទារតាវលិកចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ ហើយជាពិសេស គឺជាសិទ្ធិទាមទារឱ្យចុះបញ្ជី។

### ៣.២ ភាពចាំបាច់នៃការរក្សាការពារ

ភាពចាំបាច់នៃការរក្សាការពារ ត្រូវបានទទួលស្គាល់នៅក្នុងករណីដែលមានការបារម្ភថា ម្ចាស់បំណុលនឹងមិនអាចអនុវត្តសិទ្ធិបាន ឬ នឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តសិទ្ធិ ដោយសារមានការប្រែប្រួលស្ថានភាពបច្ចុប្បន្ននៃវត្ថុនោះ (កថាខណ្ឌទី ១ មាត្រា ៥៤៨)។

- នៅក្នុងការដាក់ពាក្យសុំចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ផ្ទេរការកាន់កាប់ គឺចាំបាច់ឱ្យមានការបារម្ភថា នឹងមិនអាចអនុវត្ត ឬ នឹងមានការលំបាកក្នុងការអនុវត្តសិទ្ធិតាមរយៈការផ្លាស់ប្តូរម្ចាស់កាន់កាប់។ ករណីដែលធ្វើការអះអាងភាពចាំបាច់នៃការរក្សាការពារនៅក្នុងពាក្យសុំ គឺត្រូវលើកឡើងអង្គហេតុលម្អិតដែលបង្ហាញថាមានការបារម្ភកូនបំណុលផ្ទេរការកាន់កាប់។ ចំពោះវិធីចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ផ្ទេរការកាន់កាប់ ករណីដាក់ពាក្យសុំទៅលើវិធីដែលអាជ្ញាសាលាថែរក្សាគ្រប់គ្រងវត្ថុដែលជាកម្មវត្ថុនៃវិវាទ នឹងមានការជះឥទ្ធិពលខ្លាំងទៅលើកូនបំណុល ប្រសិនបើប្រៀបធៀបជាមួយនឹងករណីដាក់ពាក្យសុំទៅលើវិធីដែលអនុញ្ញាតឱ្យកូនបំណុលប្រើប្រាស់វត្ថុដែលជាកម្មវត្ថុនៃវិវាទ ដូច្នេះ ត្រូវទាមទារឱ្យមានភាពចាំបាច់រក្សាការពារខ្លាំង ដោយសារតែមានឥទ្ធិពលខ្លាំង។
- នៅក្នុងការដាក់ពាក្យសុំចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការចាត់ចែង គឺចាំបាច់ឱ្យមានការបារម្ភថា នឹងមិនអាចអនុវត្ត ឬ នឹងមានការលំបាកក្នុងការអនុវត្តសិទ្ធិនាពេលអនាគត ដោយសារគ្រោះថ្នាក់នៃការផ្លាស់ប្តូរស្ថានភាពបច្ចុប្បន្ន ដូចជាអនុប្បទានវត្ថុដែលជាកម្មវត្ថុនៃវិវាទ ឬ ការបង្កើតសិទ្ធិប្រាតិភោគ ដោយកូនបំណុលជាអាទិ៍។

## ៤. ការដាក់ពាក្យសុំ ជំនុំជម្រះ និង ដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ

### ៤.១ សមត្ថកិច្ចតុលាការ

រឿងក្តីនៃដីកាសម្រេចរក្សាការពារ ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់តុលាការដែលមានសមត្ថកិច្ចលើអង្គសេចក្តី ឬ សាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលវត្ថុដែលនឹងត្រូវបានរឹបអូសជាបណ្តោះអាសន្ន ឬ វត្ថុដែលជាកម្មវត្ថុនៃវិវាទស្ថិតនៅ (កថាខណ្ឌទី ១ មាត្រា ៥៤០)។

### ៤.២ ចំណុចដែលត្រូវសរសេរនៅក្នុងពាក្យសុំ

ពាក្យសុំដីកាសម្រេចរក្សាការពារ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ (ចំណុច ក មាត្រា ៥៣៤)។ ពន្ធពាក្យសុំគឺមានចំនួន ៥.០០០ (ប្រាំពាន់) រៀល (កថាខណ្ឌទី ១ មាត្រា ៥៣៧)។ ចំពោះចំណុចដែលត្រូវសរសេរនៅក្នុងពាក្យសុំ និង ឯកសារសេចក្តីបញ្ជាក់ដំបូងដែលត្រូវភ្ជាប់ជាមួយ សូមយោងនៅក្នុងឯកសារទម្រង់គំរូ។

### ៤.៣ ការវិនិច្ឆ័យ

ការសម្រេចសេចក្តីទាក់ទងនឹងនីតិវិធីនៅក្នុងដីកាសម្រេចរក្សាការពារ ត្រូវធ្វើឡើងដោយដីកាសម្រេច (កថាខណ្ឌទី ១ មាត្រា ៥៣៥)។ ហេតុដូច្នេះ តុលាការ អាចវិនិច្ឆ័យ ដោយមិនចាំបាច់ឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់បាន (វាក្យខណ្ឌទី ២ កថាខណ្ឌទី ១ មាត្រា ៥៣៥)។ ម្យ៉ាងទៀត តុលាការ អាចសួរភាគីទាំងសងខាង ឬ តែម្ខាង ក្នុងករណីដែលមិនបើកការទាញហេតុផលដោយផ្ទាល់មាត់នេះបាន (កថាខណ្ឌទី ២ មាត្រា ១១៤)។

ដោយសារតែករណីរឹបអូសជាបណ្ដោះអាសន្ន ត្រូវការការសម្ងាត់ ដូច្នេះ ជាធម្មតា អាចចេញដីកាសម្រេចដោយគ្រាន់តែសួរម្ចាស់បំណុលបាន។ ទោះបីជាការចាត់ចែងជាបណ្ដោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទជាមូលដ្ឋាន អាចពិចារណាបានដូចគ្នាជាមួយនឹងការរឹបអូសជាបណ្ដោះអាសន្នបាន ប៉ុន្តែនៅក្នុងការចាត់ចែងជាបណ្ដោះអាសន្នដែលហាមឃាត់ផ្ទេរការកាន់កាប់ ចំពោះករណីដែលដាក់ពាក្យសុំទៅលើវិធីដែលអាជ្ញាសាលាថែរក្សាគ្រប់គ្រងវត្ថុដែលជាកម្មវត្ថុនៃវិវាទ នាំឱ្យជះឥទ្ធិពលខ្លាំងទៅលើកូនបំណុល ដូច្នេះគួរតែផ្ដល់ឱកាសទៅកូនបំណុលធ្វើការអះអាង ដោយសាកសួរមិនត្រឹមតែម្ចាស់បំណុលទេ ក៏សាកសួរផងដែរទៅកូនបំណុលផងដែរ។

### ៤.៤ ប្រាតិភោគ

ដីកាសម្រេចប្រាតិភោគ អាចធ្វើដោយឱ្យដាក់ប្រាតិភោគ ឬ មិនឱ្យដាក់ប្រាតិភោគបាន ដោយឆន្ទានុសិទ្ធិរបស់តុលាការបាន (មាត្រា ៥៤២)។ ចំពោះគោលគំនិតនៃប្រាតិភោគ សូមយោងឯកសារជុំទី ៦។

### ៤.៥ ដីកាសម្រេច

នេះគឺខុសគ្នាជាមួយនឹងការរឹបអូសជាបណ្ដោះអាសន្ន ហើយនៅក្នុងការចាត់ចែងជាបណ្ដោះអាសន្ន មិនមានបញ្ញត្តិណាដែលចែងអំពីប្រាក់ដែលកូលបំណុលត្រូវធ្វើ ដើម្បីទទួលបាននូវការលុបចោលការអនុវត្តនោះ (ប្រាក់រំដោះ)។ ព្រោះការចាត់ចែងជាបណ្ដោះអាសន្ន ជាការចាត់ចែងដោយមិនមានគោលបំណងរក្សាការពារការអនុវត្តជាប្រាក់។

- ចំពោះសេចក្ដីសម្រេចបញ្ចប់នៅក្នុងដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្នដែលហាមឃាត់ផ្ទេរការកាន់កាប់ ត្រូវសរសេរដូចខាងក្រោម ស្របតាមវិធីអនុវត្តនោះ៖

- **វិធីដែលអនុញ្ញាតឱ្យកូនបំណុលប្រើប្រាស់វត្ថុដែលជាកម្មវត្ថុនៃវិវាទ**

ហាមឃាត់មិនឱ្យកូនបំណុលផ្ទេរការកាន់កាប់ចំពោះអចលនវត្ថុដែលបានសរសេរនៅក្នុងបញ្ជីឧបសម្ព័ន្ធអំពីវត្ថុ ជាបណ្ដោះអាសន្ន។

បង្គាប់ឱ្យកូនបំណុលត្រូវប្រគល់អចលនវត្ថុដែលបានសរសេរនៅក្នុងបញ្ជីឧបសម្ព័ន្ធអំពីវត្ថុទៅឱ្យអាជ្ញាសាលា។

បង្គាប់ឱ្យអាជ្ញាសាលាត្រូវថែរក្សាគ្រប់គ្រងអចលនវត្ថុដែលបានសរសេរនៅក្នុងបញ្ជីឧបសម្ព័ន្ធអំពីវត្ថុ។

អាជ្ញាសាលា ត្រូវប្រកាសជាសាធារណៈថា កូនបំណុលត្រូវបានហាមឃាត់ការផ្ទេរការកាន់កាប់ចំពោះអចលនវត្ថុដូចមានសរសេរនៅក្នុងបញ្ជីឧបសម្ព័ន្ធអំពីវត្ថុ ហើយអាជ្ញាសាលាថែរក្សាគ្រប់គ្រងចំពោះអចលនវត្ថុដូចមានសរសេរនៅក្នុងបញ្ជីឧបសម្ព័ន្ធអំពីវត្ថុ ដោយលិខិតបិទប្រកាសជាសាធារណៈតាមរបៀបដែលពុំងាយបកចេញ ឬ តាមរបៀបសមរម្យផ្សេងទៀត។

បង្គាប់ឱ្យអាជ្ញាសាលាត្រូវអនុញ្ញាតឱ្យកូនបំណុលប្រើប្រាស់អចលនវត្ថុដូចមានសរសេរនៅក្នុងបញ្ជីឧបសម្ព័ន្ធអំពីវត្ថុ។

- **វិធីដែលអាជ្ញាសាលាថែរក្សាគ្រប់គ្រងវត្ថុដែលជាកម្មវត្ថុនៃវិវាទដោយខ្លួនឯង**

ហាមឃាត់មិនឱ្យកូនបំណុលផ្ទេរការកាន់កាប់ចំពោះអចលនវត្ថុដែលបានសរសេរនៅក្នុងបញ្ជីឧបសម្ព័ន្ធអំពីវត្ថុ។

បង្គាប់ឱ្យកូនបំណុលត្រូវប្រគល់អចលនវត្ថុដែលបានសរសេរនៅក្នុងបញ្ជីឧបសម្ព័ន្ធអំពីវត្ថុទៅឱ្យអាជ្ញាសាលា។

បង្គាប់ឱ្យអាជ្ញាសាលាត្រូវថែរក្សាគ្រប់គ្រងអចលនវត្ថុដែលបានសរសេរនៅក្នុងបញ្ជីឧបសម្ព័ន្ធអំពីវត្ថុ។

អាជ្ញាសាលា ត្រូវប្រកាសជាសាធារណៈថា កូនបំណុលត្រូវបានហាមឃាត់ការផ្ទេរការកាន់កាប់ ចំពោះអចលនវត្ថុដូចមានសរសេរនៅក្នុងបញ្ជីឧបសម្ព័ន្ធអំពីវត្ថុ ហើយអាជ្ញាសាលាថែរក្សាគ្រប់គ្រង ចំពោះអចលនវត្ថុដូចមានសរសេរនៅក្នុងបញ្ជីឧបសម្ព័ន្ធអំពីវត្ថុ ដោយលិខិតបិទប្រកាសជាសាធារណៈ តាមរបៀបដែលពុំងាយបកចេញ ឬ តាមរបៀបសមរម្យផ្សេងទៀត។

- ចំពោះសេចក្តីសម្រេចបញ្ចប់នៅក្នុងដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការចាត់ចែងសរសេរដូចខាងក្រោម៖

ហាមឃាត់មិនឱ្យកូនបំណុលធ្វើអនុប្បទាននូវកម្មសិទ្ធិ ឬ បង្កើតសិទ្ធិប្រាតិភោគ (សិទ្ធិបញ្ចាំ ឬ ហ៊ីប៉ូតែកជាអាទិ៍) ឬ សិទ្ធិជួល ឬ ការចាត់ចែងផ្សេងទៀត ចំពោះអចលនវត្ថុ ដូចមានសរសេរនៅក្នុងបញ្ជីឧបសម្ព័ន្ធអំពីវត្ថុជាបណ្តោះអាសន្ន។

## ៥. ការអនុវត្តចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ

### ៥.១ លក្ខខណ្ឌអនុវត្ត

- ដីកាសម្រេចរក្សាការពារ ត្រូវអនុវត្តដោយផ្អែកលើឯកសារចម្លងយថាភូតនៃដីកាសម្រេចរក្សាការពារ ដូច្នេះជាគោលការណ៍ មិនត្រូវការរូបមន្តអនុវត្តទេ (កថាខណ្ឌទី ១ មាត្រា ៥៦២)។ ប៉ុន្តែ នៅពេលមានការអនុវត្តសម្រាប់បុគ្គលក្រៅពីម្ចាស់បំណុល ឬ ចំពោះបុគ្គលក្រៅពីកូនបំណុល ដែលត្រូវបានកំណត់នៅក្នុងដីកាសម្រេចរក្សាការពារ គឺចាំបាច់ត្រូវការការផ្តល់នូវរូបមន្តអនុវត្ត (រូបមន្តអនុវត្តពិសេស) (វាក្យខណ្ឌទី ២ កថាខណ្ឌទី ១ មាត្រា ៥៦២) ដើម្បីបង្ហាញភាគីអនុវត្ត (ចំណុច ក កថាខណ្ឌទី ១ មាត្រា ៣៥១)។
- ការអនុវត្តដីកាសម្រេចរក្សាការពារ មិនត្រូវធ្វើឡើយ បើអំឡុងពេល ២ សប្តាហ៍ បានកន្លងហួស ចាប់ពីថ្ងៃដែលដីកាសម្រេចរក្សាការពារ ត្រូវបានបញ្ជូនទៅម្ចាស់បំណុល (កថាខណ្ឌទី ២ មាត្រា ៥៦២)។ ការអនុវត្តដីកាសម្រេចរក្សាការពារ អាចធ្វើបាន ទោះបីជាមុនពេលដីកាសម្រេចរក្សាការពារត្រូវបានបញ្ជូនទៅកូនបំណុលក៏ដោយ (កថាខណ្ឌទី ៣ មាត្រា ៥៦២)។

## ៥.២ វិធី និង សមត្ថកិច្ចអនុវត្ត

តាមក្រមនីតិវិធីរដ្ឋប្បវេណី ចំពោះការអនុវត្តការចាត់ចែងជាបណ្តោះអាសន្ន មានកំណត់ថា ត្រូវអនុវត្តតាមវិធីដូចគ្នានឹងការអនុវត្តរឹបអូសជាបណ្តោះអាសន្ន ឬ ការអនុវត្តដោយបង្ខំតែប៉ុណ្ណោះ (មាត្រា ៥៧០)។ ហេតុដូច្នេះចំពោះវិធីអនុវត្តចាត់ចែងជាបណ្តោះអាសន្ន និងសមត្ថកិច្ចនោះ លុះត្រាតែមិនមានបញ្ញត្តិពិសេស ទើបត្រូវចាំបាច់វិនិច្ឆ័យដោយអនុវត្តតាមវិធីដូចគ្នានឹងការអនុវត្តរឹបអូសជាបណ្តោះអាសន្ន ឬ ការអនុវត្តដោយបង្ខំ ឱ្យបានត្រឹមត្រូវដោយស្របតាមលក្ខណៈនៃការចាត់ចែងជាបណ្តោះអាសន្ន។

- ការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ផ្ទេរការកាន់កាប់ ត្រូវបង្គាប់ហាមឃាត់មិនឱ្យកូនបំណុលផ្ទេរការកាន់កាប់វត្ថុ និង បង្គាប់ឱ្យកូនបំណុលប្រគល់វត្ថុទៅអាជ្ញាសាលា ដោយដកហូតការកាន់កាប់នោះហើយបង្គាប់ឱ្យអាជ្ញាសាលាថែរក្សាគ្រប់គ្រងវត្ថុនោះ ដើម្បីរក្សាការពារសិទ្ធិទាមទារឱ្យប្រគល់វត្ថុនោះ ត្រូវបានចេញ អាជ្ញាសាលាត្រូវប្រកាសជាសាធារណៈថា កូនបំណុលត្រូវបានហាមឃាត់ការផ្ទេរការកាន់កាប់វត្ថុនោះ ហើយអាជ្ញាសាលាថែរក្សាគ្រង់គ្រងវត្ថុនោះ ដោយបិទប្រកាសជាសាធារណៈ តាមរបៀបដែលពុំងាយបចេញ ឬ តាមរបៀបសមរម្យផ្សេងទៀត (កថាខណ្ឌទី ១ មាត្រា ៥៧១)។ ម្យ៉ាងទៀត ទោះបីជាអាជ្ញាសាលាយកវត្ថុដែលជាកម្មវត្ថុនៃវិវាទចេញពីកូនបំណុលមួយខណៈក៏ដោយ ក៏វិធីថែរក្សាគ្រប់គ្រងជាលម្អិតនៅពេលបន្ទាប់នោះ មានវិធី ដូចខាងក្រោមៈ

  វិធីទី១ គឺជាវិធីដែលអនុញ្ញាតឱ្យកូនបំណុលបន្តប្រើប្រាស់វត្ថុដែលជាកម្មវត្ថុនៃវិវាទនោះ។ វិធីនេះមិនសូវជាជះឥទ្ធិពលដល់កូនបំណុលទេ និងជាទម្រង់ប្រើប្រាស់ជាមូលដ្ឋានទោះបីនៅក្នុងប្រទេសជប៉ុន។

  វិធីទី២ គឺជាវិធីដែលអាជ្ញាសាលាថែរក្សាគ្រប់គ្រងវត្ថុដែលជាកម្មវត្ថុនៃវិវាទដោយខ្លួនឯង។ ករណីវត្ថុដែលជាកម្មវត្ថុនៃវិវាទគឺជាចលនវត្ថុដូចជា វត្ថុសិល្បៈ និង វត្ថុជាគ្រឿងមាសប្រាក់ ជាអាទិ៍ ប្រសិនបើទុកនៅក្នុងដៃរបស់កូនបំណុល នោះនឹងលទ្ធភាពដែលតតិយជនធ្វើលទ្ធកម្មដោយសុចរិតនូវវត្ថុដែលជាកម្មវត្ថុនៃវិវាទនោះ (មាត្រា ១៩៣ នៃក្រមរដ្ឋប្បវេណី)។ ក្នុងករណីនេះ អាជ្ញាសាលា មិនត្រូវឱ្យកូនបំណុលប្រើប្រាស់វត្ថុដែលជាកម្មវត្ថុនៃវិវាទទេ គឺត្រូវថែរក្សាគ្រប់គ្រងវត្ថុដែលជាកម្មវត្ថុនៃវិវាទដោយខ្លួនឯង។

  ចំពោះវិធីទី២ នឹងជះឥទ្ធិពលយ៉ាងខ្លាំងទៅកូនបំណុល ដូច្នេះ ដើម្បីចេញដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន ក្រៅពីទាមទារឱ្យមានភាពចាំបាច់ខ្លាំងក្នុងការរក្សាការពារ ក៏នៅពេលជំនុំជម្រះចំពោះពាក្យសុំឱ្យចេញដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន គួរតែផ្តល់ឱកាសទៅកូនបំណុលធ្វើការអះអាងដោយសាកសួរមិនត្រឹមតែម្ចាស់បំណុលទេ ក៏សាកសួរផងដែរទៅកូនបំណុលផងដែរ។

  ការអនុវត្តចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ផ្ទេរការកាន់កាប់ គឺម្ចាស់បំណុលត្រូវដាក់ពាក្យសុំជាលាយល័ក្ខណ៍អក្សរ (ចំណុច ច មាត្រា ៥៣៤) ចំពោះអាជ្ញាសាលានៃសាលាដំបូងដែលមាន

សមត្ថកិច្ចលើកន្លែងដែលវត្ថុដែលជាកម្មវត្ថុនៃវិវាទស្ថិតនៅ (មាត្រា ៥៧០, កថាខណ្ឌទី ១ មាត្រា ៥២៤, កថាខណ្ឌទី ១ មាត្រា ៥២៥)។

- ការអនុវត្តចាត់ចែងជាបណ្ដោះអាសន្នដែលហាមឃាត់ចាត់ចែង ត្រូវធ្វើតាមវិធីដូចគ្នានឹងការអនុវត្តរឹបអូសជាបណ្ដោះអាសន្ន។ ការអនុវត្តចាត់ចែងជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ ត្រូវអនុវត្តតាមវិធីចុះបញ្ជីហាមឃាត់ការចាត់ចែង (មាត្រា ៥៧០, កថាខណ្ឌទី ១ មាត្រា ៥៦៧, ប្រការ ២០ នៃប្រកាសអន្តរក្រសួងស្តីពីការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី ជាអាទិ៍)។

ការអនុវត្តចាត់ចែងជាបណ្ដោះអាសន្នដែលហាមឃាត់ការចាត់ចែង គឺកំណត់ឱ្យតុលាការដែលបានចេញដីកាសម្រេចហាមឃាត់ការចាត់ចែង ជាតុលាការអនុវត្តរក្សាការពារ ហើយក្រឡាបញ្ជីនៃតុលាការនេះ ត្រូវផ្ទុកផ្ដាក់ការចុះបញ្ជី (មាត្រា ៥៧០, កថាខណ្ឌទី ២ និង កថាខណ្ឌទី ៣ មាត្រា ៥៦៧)។

## ៦. អានុភាពនៃការអនុវត្តចាត់ចែងជាបណ្ដោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ

- នៅពេលដែលបានធ្វើការចាត់ចែងជាបណ្ដោះអាសន្នដែលហាមឃាត់ផ្ទេរការកាន់កាប់ ម្ចាស់បំណុលអាចអនុវត្តដោយបង្ខំឱ្យប្រគល់វត្ថុដែលជាកម្មវត្ថុនៃវិវាទ ដោយផ្អែកលើលិខិតអនុវត្តនៅក្នុងអង្គសេចក្ដី។ ប៉ុន្តែអាចអនុវត្តបានតែចំពោះជនដែលកាន់កាប់វត្ថុនោះ ដោយដឹងថាការអនុវត្តការចាត់ចែងជាបណ្ដោះអាសន្ននោះត្រូវបានធ្វើហើយ (កថាខណ្ឌទី ២ មាត្រា ៥៧១)។ មានន័យថា នេះមិនមែនជាការបន្តពីកូនបំណុលទេ គឺទោះបីជាមានការលេចឡើងតតិយជនដែលបានលទ្ធកម្មការកាន់កាប់វត្ថុដែលជាកម្មវត្ថុនៃវិវាទ ប្រសិនបើតតិយជននោះទុច្ចរិត ពោលគឺបានដឹងថាការចាត់ចែងជាបណ្ដោះអាសន្នដែលហាមឃាត់ផ្ទេរការកាន់កាប់ត្រូវបានអនុវត្ត នាំឱ្យម្ចាស់បំណុល អាចអនុវត្តដោយបង្ខំឱ្យប្រគល់វត្ថុដែលជាកម្មវត្ថុនៃវិវាទ ដោយផ្អែកលើលិខិតអនុវត្តនៅក្នុងអង្គសេចក្ដីចំពោះកូនបំណុលបាន។ម្យ៉ាងទៀត នេះជាករណីអនុវត្តដោយបង្ខំចំពោះកូនបំណុលអនុវត្តដែលជាបុគ្គលក្រៅពីភាគីដែលត្រូវបានកំណត់នៅក្នុងលិខិតអនុវត្ត ដូច្នេះចាំបាច់ត្រូវផ្ដល់រូបមន្តអនុវត្តពិសេស (រូបមន្តអនុវត្តបន្ត) (កថាខណ្ឌទី ២ មាត្រា ៣៥៦)។

ករណីដែលមិនមែនបន្តពីកូនបំណុល ហើយតតិយដែលបានលទ្ធកម្មការកាន់កាប់នូវវត្ថុដែលជាកម្មវត្ថុនៃវិវាទ បានសុចរិត ពោលគឺជាករណីដែលមិនបានដឹងថាការចាត់ចែងជាបណ្ដោះអាសន្នដែលហាមឃាត់ផ្ទេរការកាន់កាប់ត្រូវបានអនុវត្ត នាំឱ្យម្ចាស់បំណុល មិនអាចអនុវត្តដោយបង្ខំឱ្យប្រគល់វត្ថុដែលជាកម្មវត្ថុនៃវិវាទ ដោយផ្អែកលើលិខិតអនុវត្តនៅក្នុងអង្គសេចក្ដីចំពោះកូនបំណុល (កថាខណ្ឌទី ២ មាត្រា ៥៧១)។ ម្យ៉ាងទៀត បុគ្គលដែលបានកាន់កាបវត្ថុដែលជាកម្មវត្ថុនៃវិវាទនៅក្រោយពេលអនុវត្តចាត់ចែងជាបណ្ដោះអាសន្នដែលហាមឃាត់ផ្ទេរការកាន់កាប់ ត្រូវសន្មតថាបានកាន់កាប់ដោយដឹងថាការអនុវត្តចាត់ចែងជាបណ្ដោះអាសន្ននោះត្រូវបានអនុវត្ត (កថាខណ្ឌទី ៣ មាត្រា ៥៧១) ដូច្នេះ ករណីដែលអាចទទួលស្គាល់ថាតតិយជនជាជនសុចរិត គឺមិនមានច្រើននោះទេ។

ផ្ទុយមកវិញ តតិយជនដែលបានបានកាន់កាប់វត្ថុដែលជាកម្មវត្ថុនៃវិវាទតាមរយៈមូលហេតុកើតឡើងនៃសិទ្ធិដែលអាចតតាំងជាមួយនឹងម្ចាស់បំណុល និង មិនមែនបន្តពីកូនបំណុល ព្រមទាំងសុចរិតពោលគឺ តតិយជនដែលបានលទ្ធកម្មការកាន់កាប់នូវវត្ថុដែលជាកម្មវត្ថុនៃវិវាទ ដោយមិនបានដឹងថាការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ផ្ទេរការកាន់កាប់ត្រូវបានអនុវត្ត អាចអះអាងអំពីហេតុទាំងនោះ នៅក្នុងពាក្យសុំតវ៉ាអំពីការផ្តល់រូបមន្តអនុវត្ត (មាត្រា ៣៦២) និង បណ្តឹងតវ៉ាចំពោះការផ្តល់រូបមន្តអនុវត្ត (មាត្រា ៣៦៤)។

- នៅពេលដែលបានធ្វើការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការចាត់ចែង ទោះបីជាកូនបំណុលបានចាត់ចែងផ្ទុយនឹងការហាមឃាត់នោះក៏ដោយ ក៏ការចាត់ចែងនោះមិនអាចតតាំងជាមួយនឹងម្ចាស់បំណុលបានទេ ដែលនេះជាចំណុចដូចគ្នានឹងការរឹបអូសជាបណ្តោះអាសន្នផងដែរ។

**សូមអរគុណ**

## លំហាត់អនុវត្ត – Practice Questions

**【ករណីសិក្សា】**

X អាស្រ័យនៅក្នុងខេត្តកណ្ដាល និងមានដី L នៅក្នុងរាជធានីភ្នំពេញ។

X បានសាងសង់អាគារ B មានកំពស់ ២ ជាន់ នៅលើដី L នៅថ្ងៃទី១ ខែមេសា ឆ្នាំ២០១៨។ នៅថ្ងៃដដែលនេះ X បានបង្កើតភតិសន្យាលើអាគារ B ជាមួយ Y1 ដោយកម្មវត្ថុនៃកិច្ចសន្យា មានគោលបំណងនៃការអាស្រ័យនៅ និងថ្លៃឈ្នួលមានចំនួន ៣.០០០ (បីពាន់) ដុល្លារអាមេរិក (បង់រាល់ចុងខែ) ក្នុងរយៈពេល ៥ ឆ្នាំ (តទៅហៅថា "ភតិសន្យារឿងក្ដីនេះ") ហើយនៅថ្ងៃដដែលនេះ X បានប្រគល់អាគារ B ទៅឱ្យ Y1។ នៅថ្ងៃដដែលនេះ Y1 បានចូលរស់នៅក្នុង អាគារ B ជាមួយប្រពន្ធ Y2 និងកូនប្រុស Y3។

ចាប់ពីអំឡុងខែមេសា ឆ្នាំ២០២១ មក Y1 ដូចជាមានការយឺតយ៉ាវក្នុងការបង់ថ្លៃឈ្នួល ហើយទោះបីជា X បានដាស់តឿនជាច្រើនលើកជាច្រើនសារហើយក៏ដោយក្ដី ក៏នៅចំណុចនៃពេលវេលាដែលនៅថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២១ Y1 មិនបានបង់ថ្លៃឈ្នួលក្នុងចំនួន ១០ ខែ គិតចាប់ពីខែកក្កដា ឆ្នាំ២០២១។ ហេតុដូច្នេះ X បានរំលាយកិច្ចសន្យានៃភតិសន្យារឿងក្ដីនេះ នៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២១។

នៅថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២១ X ដើម្បីទាមទារឱ្យប្រគល់វិញ ក៏បានទៅអាគារ B ក៏បានដឹងថា Y1 បានដាក់ជួលបន្តអាគារ B ជាន់ទី ១ ទៅឱ្យ Z និងឃើញថា Z កំពុងតែគ្រប់គ្រងហាងអាជីវកម្មនៅជាន់នោះ។

នាពេលបច្ចុប្បន្ន ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២១ Y1 នៅតែបន្តអាស្រ័យនៅក្នុងអាគារ B ជាន់ទី ២ ជាមួយ Y2 និង Y3 ហើយ Z នៅតែបន្តគ្រប់គ្រងហាងអាជីវកម្មក្នុងអាគារ B ជាន់ទី ១។

ដោយឡែក Z មិនបានអាស្រ័យនៅនៅក្នុងអាគារ B ទេ គឺអាស្រ័យនៅក្នុងខេត្តកណ្ដាល។

**【សំណួរ】**

**Q1.** តើ X ត្រូវដាក់បណ្ដឹងបែបណា ដើម្បីទទួលបានការប្រគល់ត្រលប់អាគារ B មកវិញបាន ?

**Q2.** X ទោះបីជាបានដាក់បណ្ដឹង Q1 ក៏ដោយ ក៏នៅតែបារម្ភថាខ្លាចមានតតិយជនថ្មីទៀតចាប់ផ្ដើមកាន់កាប់អាគារ B នៅក្នុងអំឡុងពេលចំណាត់ការនៃបណ្ដឹង ដូចដែល Z1 បានចាប់ផ្ដើមកាន់កាប់អាគារ B ជាន់ទី ១ នៅពេលដែលខ្លួនមិនបានដឹង។ តើ X អាចដាក់ពាក្យសុំចាត់ចែងរក្សាការពារបែបណា ?

**Q3.** ក្នុងករណី X ដាក់ពាក្យសុំចាត់ចែងរក្សាការពារ Q2 តើត្រូវបញ្ចូល Z ជាកូនបំណុលដែរឬទេ ?

**Q4.** ក្នុងករណី X ដាក់ពាក្យសុំចាត់ចែងរក្សាការពារ Q2 តើត្រូវបញ្ចូល Y2 និង Y3 ជាកូនបំណុលដែរឬទេ ?

**Q5.** ក្នុងករណី X ដាក់ពាក្យសុំចាត់ចែងរក្សាការពារ Q2 តើត្រូវដាក់ពាក្យសុំទៅតុលាការមួយណា ?

**【ចម្លើយ】**

**A1.** X ត្រូវដាក់បណ្ដឹងទាមទារឱ្យប្រគល់អាគារ ជាលក្ខណៈនៃការទាមទារឱ្យប្រគល់វត្ថុដែលជាកម្មវត្ថុដោយផ្អែកលើការបញ្ចប់កតិសន្យា ចំពោះ Y1 និងត្រូវដាក់បណ្ដឹងទាមទារឱ្យប្រគល់អាគារ ជាលក្ខណៈនៃការទាមទារដោយផ្អែកលើសិទ្ធិនៃកម្មសិទ្ធិលើដី L ដែលមានជាប់ជាមួយនឹងអាគារ B ចំពោះ Z។

**A2.** X ត្រូវដាក់ពាក្យសុំចាត់ចែងជាបណ្ដោះអាសន្នដែលហាមឃាត់ការផ្ទេរការកាន់កាប់ (មាត្រា ៥៧១ នៃក្រមនីតិវិធីរដ្ឋប្បវេណី) លើអាគារ B ដើម្បីរក្សាការពារសិទ្ធិទាមទារឱ្យប្រគល់អាគារ B ចំពោះ Y1 ឬ Z។

**A3.** ចំពោះជាន់ទី១ នៃអាគារ B អ្នកកាន់កាប់ដោយផ្ទាល់ គឺជា Z ប៉ុន្តែ Y1 គឺជាអ្នកកាន់កាប់ដោយប្រយោលដោយឆ្លងកាត់ការកាន់កាប់របស់ Z។ ចំពោះផ្នែកទី១ នៃអាគារ B មានបញ្ហានៅត្រង់ថា តើ X ត្រូវដាក់ពាក្យសុំចាត់ចែងជាបណ្ដោះអាសន្នដែលហាមឃាត់ការផ្ទេរការកាន់កាប់ដោយយក Z ដែលជាអ្នកកាន់កាប់ដោយផ្ទាល់ក្នុងនាមជាកូនបំណុល ឬ ក៏អាចដាក់ពាក្យសុំចាត់ចែអជាបណ្ដោះអាសន្នដែលហាមឃាត់ការផ្ទេរការកាន់កាប់ដោយយក Y1 ដែលជាអ្នកកាន់កាប់ដោយប្រយោលជាកូនបំណុល ?

ដោយសារតែវិធីអនុវត្តចាត់ចែងជាបណ្ដោះអាសន្នដែលហាមឃាត់ផ្ទេរការកាន់កាប់ គឺអាជ្ញាសាលាទទួលការប្រគល់ដោយដកហូតដោយផ្ទាល់ពីការកាន់កាប់វត្ថុដែលជាកម្មវត្ថុចេញពីអ្នកកាន់កាប់វត្ថុដែលជាកម្មវត្ថុនៃវិវាទ (កថាខណ្ឌទី ១ មាត្រា ៥៧១ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ដូច្នេះ ប្រសិនបើមិនមែនជាបុគ្គលដែលកាន់កាប់ដោយផ្ទាល់នូវវត្ថុដែលជាកម្មវត្ថុនៃវិវាទទេ ករណីនេះមិនមែនជាបុគ្គលដែលស្ថិតនៅក្នុងកម្មវត្ថុនៃការអនុវត្តចាត់ចែងជាបណ្ដោះអាសន្នដែលហាមឃាត់ការផ្ទេរការកាន់កាប់នោះទេ។

ហេតុដូច្នេះ ចំពោះជាន់ទី១ នៃអាគារ B អ្នកកាន់កាប់ប្រយោល Y1 មិនមែនជាកូនបំណុលនៃការចាត់ចែងជាបណ្ដោះអាសន្នដែលហាមឃាត់ផ្ទេរការកាន់កាប់នោះទេ ហើយចាំបាច់ត្រូវយកអ្នកកាន់កាប់ដោយផ្ទាល់ Z ជាកូនបំណុល។

**A4.** Y2 និង Y3 កំពុងអាស្រ័យនៅក្នុងផ្នែកនៃជាន់ទី២ នៃអាគារ B ជាមួយ Y1 ហើយបញ្ហានៅត្រង់ថា តើ Y2 និង Y3 ជាអ្នកកាន់កាប់រួមគ្នាលើអាគារ B ដែរឬទេ ? ឬក៏ តើជាអ្នកជំនួយនូវការកាន់កាប់របស់ Y1 ដែរឬទេ ?

Y2 និង Y3 គឺជាគ្រួសារដែលអាស្រ័យនៅជាមួយ Y1 ដែលជាភតកៈនៃភតិសន្យានៃរឿងក្ដីនេះ។ គ្រួសារដែលអាស្រ័យនៅជាមួយគ្នាបែបនេះ បានត្រឹមតែជាអ្នកជំនួយនូវការកាន់កាប់របស់ភតកៈ ហើយប្រសិនបើមិន

អាចទទួលស្គាល់នូវការកាន់កាប់ដោយឯករាជ្យបានទេ នោះអាចបណ្តេញចេញដោយលិខិតអនុវត្តចំពោះភតិកៈ និងមិនមានភាពចាំបាច់ដែលត្រូវរួមបញ្ចូល Y2 និង Y3 ជាកូនបំណុលនោះទេ។

A5. រឿងក្តីនៃដីកាសម្រេចរក្សាការពារ ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់តុលាការដែលមានសមត្ថកិច្ចលើអង្គសេចក្តី ឬ សាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលវត្ថុដែលនឹងត្រូវបានរឹបអូសជាបណ្តោះអាសន្ន ឬ វត្ថុដែលជាកម្មវត្ថុនៃវិវាទ ស្ថិតនៅ (កថាខណ្ឌទី ១ មាត្រា ៥៤០ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

នៅក្នុងទំនាក់ទំនងជាមួយ Y1 តុលាការដែលមានសមត្ថកិច្ចនៃអង្គសេចក្តី ត្រូវមានសមត្ថកិច្ចលើលំនៅឋានរបស់Y1 ដែលជាចុងចម្លើយ (ចំណុច ក មាត្រា ៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ហើយត្រូវមានសមត្ថកិច្ចលើទីកន្លែងនៃអាគារ B ដែលជាកម្មវត្ថុនៃអចលវត្ថុស្ថិតនៅ (ចំណុច ឆ មាត្រា ៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ដែលជាសាលាដំបូងរាជធានីភ្នំពេញ។

នៅក្នុងទំនាក់ទំនងជាមួយ Z តុលាការដែលមានសមត្ថកិច្ចនៃអង្គសេចក្តី ត្រូវមានសមត្ថកិច្ចលើលំនៅឋានរបស់ Z ដែលជាចុងចម្លើយ (ចំណុច ក មាត្រា ៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ដែលជាសាលាដំបូងខេត្តកណ្តាល ហើយត្រូវមានសមត្ថកិច្ចលើទីកន្លែងនៃអាគារ B ដែលជាកម្មវត្ថុនៃអចលវត្ថុស្ថិតនៅ (ចំណុច ឆ មាត្រា ៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ដែលជាសាលាដំបូងរាជធានីភ្នំពេញ។

សាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងវត្ថុដែលជាកម្មវត្ថុនៃវិវាទ គឺសាលាដំបូងរាជធានីភ្នំពេញដែលមានសមត្ថកិច្ចលើទីកន្លែងនៃអាគារ B។

យោងតាមសេចក្តីខាងលើ សាលាដំបូងរាជធានីភ្នំពេញ មានសមត្ថិកិច្ចលើរឿងក្តីនៃដីកាសម្រេចរក្សាការពារ ទោះបីក្នុងទំនាក់ទំនងជាមួយ Y1 ឬ Z ក៏ដោយ ប៉ុន្តែសាលាដំបូងខេត្តកណ្តាល មានសមត្ថកិច្ចលើរឿងក្តីនៃដីកាសម្រេចរក្សាការពារនៅក្នុងទំនាក់ទំនងជាមួយ Z ហើយមិនមានសមត្ថកិច្ចលើរឿងក្តីរក្សាការពារក្នុងទំនាក់ទំនងជាមួយ Y1 នោះទេ។

**សូមអរគុណ**